ទាក់ទិននឹងឧស្សាហកម្មស្បែកជើង : វិស័យនេះ ត្រូវបានផ្តល់អនុសាសន៍ឱ្យរៀបចំផែនការមេដែលកិច្ចប្រឹងប្រែង គួរតែត្រូវបានធ្វើដើម្បីសំរេចឱ្យបាននូវបញ្ហាគោលនយោបាយចាំបាច់សំរាប់ទាក់ទាញការវិនិយោគបរទេសផ្ទាល់ ការអភិវឌ្ឍន៍ធនធានមនុស្ស ។ល។

ទាក់ទិននឹងឧស្សាហកម្មម៉ាស៊ីន អេឡិចត្រូនិក/អេឡិចទ្រិក : វិស័យនេះ ត្រូវបានផ្តល់អនុសាសន៍ឱ្យរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដោយរាប់បញ្ចូលទាំងបណ្តាញភស្តុភារអន្តរជាតិប្រកបដោយប្រសិទ្ធភាព និងតំបន់ឧស្សាហកម្មដែលបំពាក់ដោយហេដ្ឋារចនាសម្ព័ន្ធកំរិតពិភពលោក តាមការចាប់ផ្តើមនៃយុទ្ធនាការផ្សព្វផ្សាយយ៉ាងខ្លាំងខ្លា។

វិធានការជាក់លាក់លំអិត ត្រូវលើក និងគំរូវនៅក្នុងផែនការសកម្មភាពសំរាប់ឧស្សាហកម្មជ្រើសរើសទាំងនេះ ត្រូវបានសង្ខេបនៅក្នុងតារាង ១២-១-១ នៃជំពូកទី ១២។

សំណើសំរាប់ផែនការសកម្មភាពនៅវិស័យនៃយុទ្ធសាស្ត្រការវិនិយោគបរទេសផ្ទាល់ ត្រូវបានធ្វើ។ សំណើទាំងនេះ រួមមាន :

ផែការសកម្មភាពសំរាប់ការអភិវឌ្ឍន៍នៃអង្គការចាត់តាំងនៅក្នុង ក.អ.ក "គ.វ.ក"

ផែនការសកម្មភាពសំរាប់ការជំរុញការវិនិយោគនៅក្នុង ក.អ.ក "គ.វ.ក" ដែលបញ្ចូលទាំងការរៀបចំបញ្ជីជំរុញការវិនិយោគ បង្កើតសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម និងការរៀបចំសិក្ខាសាលាវិនិយោគ

កែលំអប្រភេទវាយតម្លៃម្ហូបអាហារ និងភ្នាក់ងារអធិការកិច្ច

បង្កើតហេដ្ឋារចនាសម្ព័ន្ធឃ្លាំងដែលមានសីតុណ្ហភាពទាប កន្លែងក្លាសេ និងឃ្លាំងក្លាសេ និងប្រព័ន្ធដឹកជញ្ជូនត្រជាក់ និងក្លាសសេ

ផែនការសកម្មភាពសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មកែច្នៃម្ហូបអាហារ ដែលមានរាប់បញ្ចូលទាំងការពង្រឹងសហករណ៍នេសាទ និងកសិកម្ម ដើម្បីធានាបានការផ្គត់ផ្គង់និរន្តភាពនៃវត្ថុធាតុដើម និងពង្រឹងការជំរុញការវិនិយោគ។

ជំពូកទី ១២ ក៏បានស្នើឡើងនូវគំរោងផែនការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សំរាប់ ក.អ.ក "គ.វ.ក" ផងដែរ។ ជំពូកនេះ គឺចាំបាច់ ដើម្បីអនុវត្តមធ្យោបាយប្រកបដោយប្រសិទ្ធភាពនៃគំរោងផែនការសហប្រតិបត្តិការដែលពង្រឹង ក.អ.ក "គ.វ.ក" ដើម្បីជំរុញការវិនិយោគបរទេស មកកម្ពុជាចំពោះវិស័យឧស្សាហកម្មសក្តានុពលទាំង ៥។ ការអភិវឌ្ឍន៍សមត្ថភាពជំរុញការវិនិយោគ ក៏ដូចជាការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មានវិទ្យាសំរាប់ ក.អ.ក "គ.វ.ក" នឹងត្រូវបានផ្តល់អនុសាសន៍ជាផ្នែកមួយនៃគំរោងជំនួយបច្ចេកទេស។ ក្នុងបរិការណ៍នៃការបញ្ចូនជំនាញការជំរុញការវិនិយោគ កាលវិភាគនៃការអនុវត្តន៏ ត្រូវបានស្នើឡើងជាពីរដំណាក់កាល។ គោល បំណងនៃដំណាក់កាលទី១ គឺដើម្បីបង្កើតនូវរចនាសម្ព័ន្ធអង្គការចាត់តាំងជាមូលដ្ឋានមួយសំរាប់ការជំរុញវិនិយោគរបស់ ក.អ.ក "គ.វ.ក"។ គោលបំណងនៃដំណាក់កាលទី២ គឺដើម្បីពង្រឹងសមត្ថភាពម៉ាយេទីងក្នុង ក.អ.ក "គ.វ.ក"។ ដូច្នេះ ជំនាញការកែទំរង់អង្គការចាត់តាំងមួយ និងជំនាញការផ្នែកផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈមួយ គួតែត្រូវបញ្ចូនមក ក.អ.ក "គ.វ.ក" នៅក្នុងដំណាក់កាលទាំងពីរនេះ។ ជាបន្ថែម គំរោងផែនការជំនួយបច្ចេកទេស សំរាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន គឺត្រូវបានស្នើឡើងផងដែរ ដើម្បីនឹងពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាននៅក្នុង ក.អ.ក "គ.វ.ក" ហើយការចែករំលែកពត៌មានរវាងនាយកដ្ឋានក្នុង ក.អ.ក "គ.វ.ក"។

**១.៣.៥ គំនូសបំព្រួញស្តីពីរចនាសម្ព័ន្ធនៃមាតិកាសិក្សា :** រចនាសម្ព័ន្ធរូបភាពនៃរបាយការណ៍អាចត្រូវពិពណ៌នាដូចខាងក្រោម :



# ផ្នែកទី ១

# ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងការទាក់ទាញការវិនិយោគបរទេសផ្ទាល់
# ក្នុងឧស្សាហកម្មសំខាន់ៗនៅកម្ពុជា

# ជំពូកទី ២
# ទស្សនៈវិស័យសំរាប់ម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

## ២.១ ទស្សនវិស័យសំរាប់ម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ២.១.១ សារៈសំខាន់នៃបទឧទ្ទេសនាមចក្ខុវិស័យសំរាប់ម៉ាក្រូសេដ្ឋកិច្ច

ការសិក្សាអភិវឌ្ឍន៍ ស្តីពីការគាំទ្រគោលនយោបាយសេដ្ឋកិច្ចកម្ពុជា នឹងរៀបចំនូវវិធានការ និងគោលនយោបាយ ដោយឆ្លងតាមការអនុវត្តន៍ជាក់ស្តែង ដើម្បីអភិវឌ្ឍន៍បរិស្ថានសំណើទាក់ទាញការវិនិយោគបរទេសផ្ទាល់ (FDI) សំរាប់កម្ពុជា ហើយសំខាន់បំផុតការវិនិយោគបរទេសផ្ទាល់ដែលមានប្រភពពីប្រទេសជប៉ុន។ បន្ថែមលើនេះ បរិស្ថានវិនិយោគនៅកម្ពុជា ត្រូវរំពឹងថានឹងប្រសើរឡើងស្របទៅតាមការអនុវត្តន៍នៃវិធានការ និងគោលនយោបាយទាំងនេះ។ ដូចនេះ ជំហានដំបូងគឺត្រូវវាយតំលៃទៅលើបរិយាកាសវិនិយោគនៅកម្ពុជា។ ដែលនោះ វាជាប្រការចាំបាច់ក្នុងការវិភាគលើទិន្នន័យម៉ាក្រូសេដ្ឋកិច្ចជាមូលដ្ឋាន សំដៅរៀបចំវិធានការ និងគោលនយោបាយនានាសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ។

ផ្អែកទៅលើដំណាក់កាលអន្តរកាលពីអតីតកាលនៃសូចនាករសំខាន់ៗ និងកត្តានានា ដែលទំនងជានឹងជះឥទ្ធិពលទៅលើសេដ្ឋកិច្ចកម្ពុជា និន្នាការនៃសូចនាករដល់ឆ្នាំ២០២០ នឹងត្រូវប៉ាន់ប្រមាណជាបរិមាណនៅក្នុងជំពូកនេះ។ តាមរយៈការធ្វើព្យាករណ៍ចំពោះសូចនាករនានា សេដ្ឋកិច្ចកម្ពុជា នឹងត្រូវបង្ហាញឱ្យឃើញនូវទស្សនអនាគតមួយដែលទូលំទូលាយ។ ក្នុងបរិការណ៍នេះ ការផ្លាស់ប្តូររចនាសម្ព័ន្ធរយៈពេលមធ្យម និងវែងនៃបរិស្ថានសេដ្ឋកិច្ចអន្តរជាតិជុំវិញប្រទេសកម្ពុជា និងនៅក្នុងរង្វង់កម្ពុជាផ្ទាល់ នឹងត្រូវបានពិនិត្យយ៉ាងជាក់លាក់។ ឥទ្ធិពលដែលនឹងកើតមានចំពោះសេដ្ឋកិច្ចកម្ពុជា ក៏នឹងត្រូវលើកយកមកធ្វើការពិចារណាផងដែរ ។

ដើម្បីធ្វើអោយកាន់តែច្បាស់ ទស្សនៈអនាគតនៃសេដ្ឋកិច្ច នឹងត្រូវបានទស្សន៍ទាយក្នុងការពិចារណាទៅលើលក្ខខណ្ឌនៃវិភាគទានធនធានរបស់កម្ពុជា និន្នាការនៃការវិនិយោគបរទេសផ្ទាល់ ការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធឧស្សាហកម្ម រចនាសម្ព័ន្ធពាណិជ្ជកម្ម (ដែលរួមមាននិន្នាការទីផ្សារអន្តរជាតិនៃផលិតផលផ្សេងៗគ្នា) និងលក្ខខណ្ឌប្រកួតប្រជែងក្នុងចំណោមប្រទេសជិតខាង ដូចជានៅអាស៊ីអាគ្នេយ៍ និងនៅប្រទេសចិន ។

ការសង្កេតនានា ដែលពាក់ព័ន្ធដល់និន្នាការអនាគតនៃសេដ្ឋកិច្ចកម្ពុជានឹងត្រូវបានដកស្រង់ចេញមកពីទស្សនៈវិស័យស្តីពីម៉ាក្រូសេដ្ឋកិច្ច។ ការសង្កេតបែបនេះ នឹងត្រូវបានប្រើប្រាស់ធ្វើជាព័ត៌មានជាមូលដ្ឋានសំដៅកំណត់ និងវាយតំលៃផលិតផលសក្តានុពល ដែលអាចជាវត្ថុនាំចេញសំខាន់នៅពេលអនាគតនៅកម្ពុជា។ ការសង្កេតនេះ ក៏នឹងត្រូវបានប្រើប្រាស់ផងដែរ ដើម្បីរៀបចំវិធានការ និងគោលនយោបាយសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មក្នុងវិស័យផ្សេងៗគ្នា ។

### ២.១.២ កត្តាផ្សេងៗ ដែលកំពុងជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចកម្ពុជា

ម៉ាក្រូសេដ្ឋកិច្ចកម្ពុជា បានទទួលប្រយោជន៍យ៉ាងសំខាន់ពីស្ថេរភាពនយោបាយនៅប៉ុន្មានឆ្នាំថ្មីៗនេះ ហើយក៏បានមកពីជោគជ័យក្នុងកំណែទំរង់នយោបាយ និងរដ្ឋបាលផងដែរដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ។ យុទ្ធសាស្ត្រនេះ

មានគោលបំណងសំរេចឱ្យបាននូវអភិបាលកិច្ចល្អដោយផ្តោតលើកំណែទំរង់ចំនួន៤សំខាន់ៗ ( ប្រឆាំងអំពើពុករលួយកំណែទំរង់ ច្បាប់ និងតុលាការ កំណែទំរង់រដ្ឋបាលសាធារណៈ និងកំណែទំរង់កងទ័ព និងរំសាយទ័ព)។ ថ្មីៗនេះ សេដ្ឋកិច្ចកម្ពុជា បានអភិវឌ្ឍប្រកបដោយស្ថេរភាព ដែលនោះវាជាលទ្ធផលនៃស្ថេរភាវូនីយកម្មនៃរូបិយវត្ថុ ការបន្ថយអត្រាអតិផរណា និងការពង្រីកឧស្សាហកម្មនាំចេញ ដែលនាំមុខដោយវិនិយោគបរទេស។ នៅក្នុងអំឡុងប៉ុន្មានឆ្នាំថ្មីៗនេះ (២០០៥-២០០៦) វិនិយោគទុនផ្ទាល់ពីបរទេសបានប្រមូលផ្តុំលើឧស្សាហកម្មកាត់ដេរ ក៏ទទួលបានការកើនឡើងផងដែរ។ កំណើននេះ ផ្អែកទៅលើនៃការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព ត្រូវបានគេរំពឹងទុកថា នឹងបន្តក្នុងមួយរយៈពេលទៀត ហើយដោយយោងទៅតាម "NSDP: ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ[1]" ដែលបានបោះពុម្ពផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជានៅដំណាច់ឆ្នាំ២០០៥ កំណើនសេដ្ឋកិច្ចពិតប្រមាណ៦% ត្រូវបានរំពឹងទុកថានឹងបន្តរហូតដល់ឆ្នាំ២០១០។

ទន្ទឹមនឹងនេះដែរ ទាំងនៅក្នុងជញ្ជីងពាណិជ្ជកម្ម និងតុល្យភាពគណនេយ្យចរន្ត ប្រទេសកម្ពុជាបាននឹងកំពុងប្រឈមនិងឱនភាពលើសពី ១0% នៃផលិតផលក្នុងស្រុកសរុប (GDP)។ នៅក្នុងពេលអនាគត ឱនភាពនេះ នឹងក្លាយជារបៀបវារៈដ៏សំខាន់ ដើម្បីកែលំអនូវជញ្ជីងពាណិជ្ជកម្ម តាមរយៈការជំរុញឧស្សាហកម្មនាំចេញ។ លើសពីនេះទៀត ចំនួនប្រហែល ៨0% នៃទំនិញនាំចេញរបស់កម្ពុជា ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ គឺជាផលិតផលសំលៀកបំពាក់ ហើយផលិតផលនេះបានក្លាយទៅជាផលិតផលអាទិភាពសំរាប់ការនាំចេញរបស់ប្រទេស។ ជាមួយ នឹងការរំពឹងទុក ចំពោះកំណើននៃការនាំចេញនៃផលិតផលសំលៀកបំពាក់ ការកើនឡើងនូវចំនួនភ្ញៀវទេសចរណ៍ និងការកើនឡើងនូវចំណាយរបស់ភ្ញៀវម្នាក់ៗ គឺជាកត្តាសំខាន់សំរាប់កែលំអនូវតុល្យភាពពាណិជ្ជកម្ម ទាំងសេវាកម្មនិងទំនិញ របស់ប្រទេសកម្ពុជា។

ការបង្ហាញក្នុងតារាងខាងក្រោម ដែលបានផ្តល់អោយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ខែធ្នូឆ្នាំ២០០៦) គូសបញ្ជាក់ពីតំលៃអនាគត សំរាប់អន្តរកាលនៃសូចនាករម៉ាក្រូសេដ្ឋកិច្ចរហូតដល់ឆ្នាំ២០១០។ កំណើនសេដ្ឋកិច្ចស្ថិតនៅក្នុងលំដាប់៦-៧% នៅក្នុងរយៈពេលមួយជាក់លាក់ ដែលត្រូវបានគេរំពឹងទុករហូតដល់ ឆ្នាំ២០១០។ សេដ្ឋកិច្ចកម្ពុជានឹងមានកើនឡើងច្រើនជាងលើសពីអ្វីដែលរដ្ឋាភិបាលបានរំពឹងទុក ប្រសិនបើឧស្សាហកម្មនាំចេញដូចជាការកើនឡើងដ៏ខ្លាំងនាពេលថ្មីៗនេះនូវឧស្សាហកម្មកាត់ដេរសំលៀកបំពាក់រក្សាបាននូវកំណើនរបស់ខ្លួនក្នុងពេលអនាគត និងការងារអភិវឌ្ឍន៍រុករកធនធានប្រេងអនុវត្តបានត្រឹមត្រូវ។ នៅពេលដែលការអភិវឌ្ឍន៍លើការនាំចេញជាអទិភាពសំរេចបាន ពេលនោះ ក៏វិតឱនភាពនៃជញ្ជីងគណនេយ្យចរន្ត នឹងត្រូវបានកាត់បន្ថយ។

**តារាង ២-១-១ កំណើនប្រកបដោយស្ថេរភាព និងបន្ត នៃសេដ្ឋកិច្ចកម្ពុជា**

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|
| GDP (Billion KHR 2000 constant prices) | 16,745 | 18,040 | 19,810 | 21,089 | 22,437 | 23,856 | 25,342 | 26,955 |
| GDP (Million USD current prices) | 4,345 | 4,886 | 5,525 | 5,957 | 6,485 | 7,048 | 7,643 | 8,297 |
| GDP per capita (USD) | 324 | 357 | 396 | 420 | 448 | 478 | 509 | 542 |
| Real GDP (% increase) | 7.0% | 7.7% | 9.8% | 6.5% | 6.4% | 6.3% | 6.2% | 6.4% |

[1] រាជរដ្ឋាភិបាលកម្ពុជា ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ 2006-2010, ខែធ្នូ ឆ្នាំ 2005

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| Inflation in KHR (% increase, year average) | 1.2% | 3.9% | 5.8% | 3.0% | 3.0% | 3.0% | 3.0% | 3.0% |
| KHR/USD parity (end of period) | 4,000 | 4,038 | 4,160 | 4,180 | 4,200 | 4,220 | 4,240 | 4,260 |
| | | | | | | | | |
| Exports of goods (% GDP) | 46.6% | 50.7% | 49.0% | 49.2% | 48.9% | 48.2% | 47.7% | 47.2% |
| Imports of goods (% GDP) | 58.9% | 65.4% | 67.7% | 70.0% | 69.6% | 68.5% | 67.7% | 66.6% |
| Trade balance (% GDP) | -12.3% | -14.7% | -18.7% | -20.8% | -20.7% | -20.3% | -20.0% | -19.4% |
| Current account balance (% GDP) | -10.4% | -10.0% | -10.0% | -11.0% | -10.1% | -8.9% | -7.9% | -6.8% |

Note: Values indicated after 2006 are predicted values
Source: Data from National Strategic Development Plan (NSDP) and the Ministry of Economy and Finance

ចំពោះទស្សនវិស័យអនាគតដែលបានពោលខាងលើ កត្តាចំបងដែលអាចមានផលប៉ះពាល់ខ្លាំងទៅលើសេដ្ឋកិច្ចកម្ពុជា រហូតដល់ឆ្នាំ២០២០ អាចត្រូវបានចាត់ទុកថាជា: និន្នាការនៃការវិនិយោគទុនផ្ទាល់ពីបរទេស វិមាត្រនៃការប្រកួតប្រជែង ការនាំចេញក្នុងចំណោមបណ្តាប្រទេសនៅជិតខាង និងឥទ្ធិពលនៃការអភិវឌ្ឍន៍ធនធានប្រេងរបស់ ប្រទេសកម្ពុជា ។ និន្នាការទាំងនេះ ត្រូវបានចង្អុលបង្ហាញអោយឃើញតាមកត្តាគន្លឹះ ៣ យ៉ាង ។

**(១) និន្នាការងើបឡើងនៃវិនិយោគបរទេសផ្ទាល់ ដែលកំពុងប្រមូលផ្តុំលើឧស្សាហកម្មកាត់ដេរ**

ប្រទេសកម្ពុជាថ្មីៗនេះបាន និងកំពុងតែទទួលវិនិយោគបរទេសផ្ទាល់ដែលផ្តោតលើឧស្សាហកម្មកាត់ដេរ ។ យោងទៅតាមស្ថិតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់កម្ពុជា ជាឧទាហរណ៍នោះ ប្រទេសកម្ពុជាបានទទួលវិនិយោគបរទេសផ្ទាល់ក្នុងទឹកប្រាក់ប្រមាណជា $223 លានដុល្លារ អាមេរិកនៅលើមូលដ្ឋាននៃការអនុវត្តន៍ការងារជាក់ស្តែងនាឆ្នាំ 1998, ដែលសឹងតែប្រហាក់ប្រហែលនឹង 7.2% នៃ GDP ។ នៅក្នុងលក្ខណនេះ ការវិនិយោគបរទេសផ្ទាល់គឺជាវិមាត្រដែលមានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។

ការវិនិយោគបរទេសផ្ទាល់នៅកម្ពុជា បានថយចុះ តាំងពីនោះមក ហើយបានធ្លាក់ចុះនៅត្រឹម១.៧% នៃ GDP នៅក្នុងឆ្នាំ ២០០៣ ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចមានរៀបរាប់ខាងក្រោយត្រង់ចំណុច "**ឱកាសវិនិយោគសំរាប់ទាក់ទាញឧស្សាហកម្មកាត់ដេរ**[២]" ដោយក្រុមសិក្សារបស់ JICA ការវិនិយោគបរទេសផ្ទាល់សំរាប់ឧស្សាហកម្មកាត់ដេរបន្ទាប់ពីឆ្នាំ ២០០៥ បានងើបឡើងវិញយ៉ាងខ្លាំងក្លា ហើយកំណើនបន្តនៃវិនិយោគ នឹងត្រូវបានរំពឹងថាមានអនាគតមួយដែលអាចទស្សន៍ទាយបាន ។ លើសពីនេះទៅទៀត ការវិនិយោគក្នុងឧស្សាហកម្មសេវាកម្ម ដែលប្រមូលផ្តុំលើហេដ្ឋារចនាសម្ព័ន្ធ វិស័យទេសចរណ៍ និងរោងចក្រផលិតសំភារៈសំណង់ មានសកម្មភាពរស់រវើក ហើយបញ្ហានេះអាចនាំឱ្យការវិនិយោគបរទេសផ្ទាល់កើនឡើង លើសពីអ្វីដែលរដ្ឋាភិបាលកម្ពុជារំពឹងទុក ។

ជាលទ្ធផលនៃលំហូរចូលជាវិជ្ជមាននៃវិនិយោបរទេសផ្ទាល់ ត្រូវបានរំពឹងទុកថាតំលៃនៃផលិតកម្មជាចំបងក្នុងចំណោមឧស្សាហកម្មនាំចេញរបស់កម្ពុជា នឹងពង្រីកវិសាលភាពមួយធំធេងជាងនេះ ។ គេអាចយល់បានដោយផ្អែកលើមូលដ្ឋាននៃក្តីរំពឹងទុកដែលថា GDP របស់កម្ពុជានឹងកើនលើសពីកំរិត ដែលរដ្ឋាភិបាលបានរំពឹងទុកនៅដំណាច់ឆ្នាំ២០០៥ ។ អ្វីច្រើនជាងនេះទៅទៀត គឺកំណើននៃផលិតកម្មសរុប ដែលពាក់ព័ន្ធដល់ការវិនិយោគបរទេសផ្ទាល់ ដែលមិនមាន

[2] Chapter 5-The Outlook and Recommendation for Investment Conditions for Attracting Foreign Garment Manufacturers to Cambodia

លក្ខណៈបណ្តោះអាសន្នទេ ប៉ុន្តែមានប្រសិទ្ធភាពទស្សនៈអនាគតបន្តទៀត ។

**តារាង ២-១-២ បរិមាណវិនិយោគនៅកម្ពុជា**

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| **Total Investment** | **879.4** | **691.0** | **718.9** | **776.1** | **751.3** | **846.7** | **951.7** | **872.4** | **952.2** | **1,120.5** |
| **Public Investment** | **200.6** | **150.9** | **165.2** | **190.5** | **213.6** | **280.7** | **354.4** | **298.3** | **304.7** | **322.5** |
| Domestic financed | (33.4) | 2.7 | 30.2 | 57.4 | 49.4 | 58.3 | 40.9 | 48.8 | 62.8 | 47.5 |
| Foreign financed | 234.0 | 148.2 | 135.0 | 133.1 | 164.2 | 222.4 | 313.5 | 249.5 | 241.8 | 275.0 |
| **Private Investment** | **678.8** | **540.1** | **553.7** | **585.6** | **537.7** | **566.0** | **597.3** | **574.1** | **647.5** | **798.0** |
| Domestic financed | 385.1 | 372.0 | 330.7 | 364.6 | 395.7 | 424.0 | 458.3 | 500.1 | 526.5 | 582.0 |
| Foreign financed | 293.7 | 168.1 | 223.0 | 221.0 | 142.0 | 142.0 | 139.0 | 74.0 | 121.0 | 216.0 |
| **Total Domestic Financed** | **351.7** | **374.7** | **360.9** | **422.0** | **445.1** | **482.3** | **499.2** | **549.0** | **589.3** | **629.5** |
| **Total Foreign Financed** | **527.7** | **316.3** | **358.0** | **354.1** | **306.2** | **364.4** | **452.5** | **323.5** | **362.8** | **491.0** |

(1) Note: Unit: 1 million USD
(2) Source: Data from Ministry of Economy and Finance

### (២) លទ្ធភាពនៃការប្រកួតប្រជែងនាំចេញក្នុងចំណោមប្រទេសជិតខាងដូចជាប្រទេសចិន និងវៀតណាម

ខណៈដែលកម្ពុជា ជាសមាជិករបស់ ASEAN និងដែលបានចូលជាសមាជិករបស់អង្គការ WTO, គេបានសន្មត់ថា សេដ្ឋកិច្ចរបស់កម្ពុជា និងបណ្តាប្រទេសនៅជុំវិញ នឹងក្លាយជាការបើកចំហខ្លាំងឡើង ចំពោះការប្រកួតប្រជែងសកល ហើយដោយហេតុនោះ ទំនាក់ទំនងសេដ្ឋកិច្ចក្នុងបណ្តាប្រទេសទាំងនេះ នឹងត្រូវពង្រីកឱ្យកាន់តែខ្លាំង ក្នុងខណៈប្រទេសវៀតណាម នឹងក្លាយទៅជាសមាជិកនៃអង្គការ WTO ឆាប់ៗ និងការជំរុញបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយដៃគូសន្ទនា (ជាពិសេសតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន) ។ ផលប៉ះពាល់នៃការប្រែប្រួលសេដ្ឋកិច្ច កម្ពុជាគឺរួមមាន : កម្មករចំណាកស្រុក កំណើនពាណិជ្ជកម្ម និងលំហូរវិនិយោគពីប្រទេសជិតខាង ដូចជាប្រទេស ថៃឡង់ដ៏ និងវៀតណាម ដែលសកម្មភាពឧស្សាហកម្មផ្សេងៗកំពុងមានលក្ខណៈសកម្ម ។

អនុលោមតាមលទ្ធផលនៃកិច្ចសំភាសន៏ជាមួយនឹងសេដ្ឋវិទូ អ្នកធ្វើគោលនយោបាយ និងអ្នកស្រាវជ្រាវនានា នៅប្រទេសថៃ និងវៀតណាម ការហូរចូលមកនូវទុនវិនិយោគសន្សឹមៗទៅតាមដំណាក់កាលមួយៗ ត្រូវបានគេរំពឹងថាជាផលប៉ះពាល់នៃការវិនិយោគពីបណ្តាប្រទេសជិតខាង ។ ស្តីពីលទ្ធភាពនៃការប្តូរមូលដ្ឋានផលិតកម្មចេញពីប្រទេសថៃ សម្ភាសិករជាច្រើន ធ្វើអត្ថាធិប្បាយថា មូលដ្ឋានដូចជាផលិតកម្ម និងការកែច្នៃផលិតផលកសិកម្ម/នេសាទ សំលៀកបំពាក់ និងស្បែកជើង អាចជាសេនារីយ៉ូប្រាកដនិយម ប៉ុន្តែផ្ទុយមកវិញ ការប្តូរទីតាំងនៃមូលដ្ឋានផលិតកម្មដែលចាំបាច់ត្រូវតែគិតដល់ខ្សែសង្វាក់ផ្គត់ផ្គង់ជាសកល ដូចជាផលិតផលអគ្គិសនី ហើយគ្រឿងបំលាស់នៃគ្រឿងចក្រដឹកជញ្ជូន មិនមានលក្ខណៈប្រាកដនិយមទេនៅក្នុងរយៈពេលខ្លីនោះ ។

ទន្ទឹមនឹងនោះ ទំនាក់ទំនងរវាងកម្ពុជា និងបណ្តាប្រទេសជិតខាង មានដែនកំណត់នៃ "ភាពប្រកួតប្រជែង" ដែលលេចធ្លោជាងគេនោះ គឺការប្រកួតប្រជែងជាមួយបណ្តាប្រទេសដទៃទៀតសំរាប់ការនាំចេញសំលៀកបំពាក់ ដែលបន្ថែមទៅលើចំនួន 80% នៃការនាំចេញសរុប ដែលមានចំនួនប្រហាក់ប្រហែលជា 70% នៃ GDP របស់កម្ពុជា។

បន្ថែមទៅនឹងភាពប្រកួតប្រជែងនៃថ្លៃ និងការប្តូររូបិយប័ណ្ណនៃប្រទេសនីមួយៗ ថាតើប្រទេសកម្ពុជា ទទួលបានការអនុគ្រោះពន្ធ ពីប្រទេសជាគោលដៅសំរាប់ការនាំចេញបានច្រើនជាង បណ្តាប្រទេសដែលកំពុងប្រកួតប្រជែងយ៉ាងណា និងថាតើមានការកំហិតពីប្រទេសទាំងនោះ ដែលនាំដល់ផលប៉ះពាល់លើភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរកម្ពុជាយ៉ាងណា។ ដូច្នេះហើយ វាងាយយល់ណាស់ថាសេដ្ឋកិច្ចកម្ពុជានឹងរងឥទ្ធិពលផងដែរ។ ជាលទ្ធផល វានឹងក្លាយទៅជាប្រការចាំបាច់ ដើម្បីយកកត្តាទាំងអស់នេះទៅធ្វើការពិចារណា នៅពេលដែលត្រួតពិនិត្យលើសេដ្ឋកិច្ចរបស់កម្ពុជា ។

ចំនុចទាំង ៧ ខាងក្រោមនេះ គឺជាកត្តាដែលអាចជះឥទ្ធិពលដល់ភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ ចំនុចលំអិតនៃកត្តាទាំងនេះ នឹងត្រូវពិពណ៌នានៅក្នុងផ្នែកមួយនៃឧស្សាហកម្មកាត់ដេរ។ មានឧទាហរណ៍មួយ គឺថាការលុបចោល MFA នាឆ្នាំ២០០៥ ត្រូវបានគេសន្មត់ថាជាកត្តាប្រឈមមួយសំរាប់ ឧស្សាហកម្មកាត់ដេរកម្ពុជាទៅតាមទ្រឹស្តីនោះ[3], ប៉ុន្តែការហាមឃាត់តាមរយៈវិធានការសុវត្ថិភាពផ្នែកវាយនភ័ណ្ឌចំពោះប្រទេសចិន អាចជាកត្តាជះឥទ្ធិពលប្រកបដោយលក្ខណៈអំណោយផល ទៅវិញសំរាប់កម្ពុជា។

**តារាង ២-១-៣ កត្តាគន្លឹះមានឥទ្ធិពលភាពប្រជែងឈ្នះនៃឧស្សាហកម្មកាត់ដេរកម្ពុជា**

- Abolition of MFA in January 2005;
- Imposition of safeguard measures by US and EU on garment export from China in June 2005;
- Rise in wages, surge of labor turnover, difficulty in finding suitable personnel in a garment sector, Vietnam and Thailand that have become outstanding since 2006, and appreciation of currency in China;
- Abolition of quota to Vietnam in January 2007 along with Vietnam's joining in WTO
- Lifting of garment safeguard measured on export from China after January 2009
- Revaluation of Chinese currency (CNY) which is assumed to be accelerated after January 2009
- Alleviation of antidumping measure to China in a garment sector in January 2016

Note: Refer to "Garment Industry Promotion Policy" in this report for details.

### (៣) ផលប៉ះពាល់នៃផលិតកម្មប្រេងឧស្ម័ន ដែលអាចធ្វើអោយមានការផ្លាស់ប្តូរយ៉ាងមហិមាទៅលើខឿនសេដ្ឋកិច្ចរបស់កម្ពុជា

កម្ពុជា មានពិពិធភាពធនធានរ៉ែដែលមិនទាន់បានធ្វើការអភិវឌ្ឍន៍នៅឡើយ។ ធនធានប្រេងឥន្ធនៈ (ប្រេង ឧស្ម័នធម្មជាតិ) និងរ៉ែដែកផងដែរ (ទង់ដែង បុកស៊ីត រ៉ែដែក ម៉ង់ហ្កាណេស ។ល។) ត្រូវបានឃើញថាមានលទ្ធភាពអភិវឌ្ឍន៍បំរើឱ្យពាណិជ្ជកម្ម និងដូច្នេះ មានលទ្ធភាពមួយដែលថាការអភិវឌ្ឍន៍វិស័យនេះ ប្រសិនបើវាត្រូវបានធ្វើក្នុងទ្រង់ទ្រាយធំ នឹងជំរុញលើកស្ទួយសេដ្ឋកិច្ចរបស់ប្រទេស។ ក្នុងលទ្ធភាពនេះ ការអភិវឌ្ឍន៍ប្រេង/ឧស្ម័នធម្មជាតិនៅតាមឆ្នេរ

[3] ចង់និយាយដល់ "គោលនយោបាយជំរុញឧស្សាហកម្មសំលៀកបំពាក់" ដែលបានរៀបរាប់នៅខាងក្រោយនេះ ។ យោងទៅតាមការវិភាគលំអិតបំផុត ឥទ្ធិពលនៃការលុបចោល MFA តាមពិតទៅ វាបានក្លាយទៅជារឿងពិសេសទៅវិញ ។

សមុទ្រ ក្នុងបច្ចុប្បន្នកាលនេះ ឃើញថាជាកត្តាចំបងមួយដែលអាចជះឥទ្ធិពលដល់ម៉ាក្រូសេដ្ឋកិច្ចប្រទេស។ ការរុករកធនធានប្រេង និងឧស្ម័នធម្មជាតិបានចាប់ដំណើរការនៅភាគខាងជើង និងក្នុងសមុទ្ររបស់កម្ពុជានៅទស្សវត្សរ៍ទី 70 ។ ទោះបីជាចំនួននៃការខួងរុករកបានចាប់ដំណើរការតាំងពីពេលនោះមកក្តី ក៏អណ្តូងប្រេង និងឧស្ម័នធម្មជាតិ ដែលអាចធ្វើពាណិជ្ជកម្មបាន នៅតែមិនទាន់ត្រូវបានរកឃើញនៅឡើយទេរហូតមកទល់ពេលនេះ។ នៅក្នុងកំឡុងឆ្នាំ ១៩៩៩ ទើបមានការជីករុករកប្រេងឥន្ធនៈក្នុងវិសាលភាពពេញលេញនៅក្នុងឈូងសមុទ្រសៀម។ កិច្ចសន្យាបែងចែកផលិតកម្ម (PSC) ត្រូវបានបញ្ចប់នៅឆ្នាំ២០០២ សំរាប់ការអភិវឌ្ឍន៍ប្លុក Block A។ អណ្តូងដែលមានធនធានប្រេងបំរុងគ្រប់គ្រាន់សំរាប់ធ្វើប្រតិបត្តិការ ត្រូវបានរកឃើញជាលើកដំបូង និងការចាប់ផ្តើមដំបូងនៃប្រតិបត្តិការ ត្រូវបានគេរំពឹងទុកយ៉ាងខ្ពស់រួចជាស្រេច ។

ឈរលើមូលដ្ឋាននៃរបាយការណ៍សារព័ត៌មាននាខែកក្កដា ឆ្នាំ 2006 នេះ គេបានរាយការណ៍មកថា ធនធានប្រេង និងឧស្ម័នធម្មជាតិនៅកម្ពុជាមានប្រហែលជា 2 កោដ្ឋបារ៉ែល និងឧស្ម័នធម្មជាតិប្រហែលជា 280 កោដ្ឋម៉ែត្រគូប ហើយវានឹងផ្តល់ប្រាក់ចំណូលសុទ្ធរបស់រដ្ឋាភិបាលប្រមាណជា 2 កោដ្ឋដុល្លារអាមេរិកក្នុងមួយឆ្នាំៗ ក្នុងស្ថានភាពដែលផលិតកម្មចាប់ផ្តើមដល់កំរិតពេញទំហឹងនោះ[4]។ យ៉ាងណាមិញ យោងទៅតាមអាជ្ញាធរប្រេងកាតជាតិកម្ពុជា ការប្រកាសជាផ្លូវការនោះបានបង្ហាញអំពីផលកំណនៃប្រេងចំនួន ៩៦ លានបារ៉ែល និងឧស្ម័នធម្មជាតិចំនួន ៧៤ លានម៉ែត្រគូប។ រដ្ឋាភិបាល បានបញ្ជាក់ដោយប្រុងប្រយ័ត្នថា គេត្រូវចំណាយពេលច្រើនជាងនេះទៀតដើម្បីចាប់ផ្តើមធ្វើផលិតកម្ម ហើយទំហំនៃបណ្តាអណ្តូងប្រេង និងឧស្ម័នធម្មជាតិមិនត្រូវបានគេបញ្ជាក់ ឬរាយការណ៍ អោយបានច្បាស់លាស់នោះទេ។ ផ្អែកលើទិន្នន័យផ្លូវការ ផលិតកម្មនឹងចាប់ផ្តើមដំបូងយ៉ាងឆាប់បំផុតនៅឆ្នាំ២០១២ ហើយផលិតកម្មពេញលេញនៅឆ្នាំ២០១៥។ ចំនួនផលិតកម្មនឹងឡើងដល់ ១៣,០០០ធុងបារ៉ែលក្នុងមួយថ្ងៃ ។ ពាក់ព័ន្ធដល់គណនីចំណូល និងចំណាយនោះ នៅក្នុងករណីផលិតកម្មក្នុងសមុទ្រ ទុនវិនិយោគ ត្រូវការដល់ទៅ ១.៧១ កោដ្ឋដុល្លារសហរដ្ឋអាមេរិក ការលក់នឹងបានប្រហែលជា 14.34 កោដ្ឋដុល្លារអាមេរិក (ឧស្ម័នធម្មជាតិ :0.00៥ USD/ m3, ផលកំណរប្រេង និងឧស្ម័នគឺ ៤0 USD/ក្នុងមួយធុងបារ៉ែល) ហើយផលចំណេញសរុបគឺ ១២.៦៥ កោដ្ឋដុល្លារ ។ បើសិនជា 50% នៃចំនួននោះត្រូវបានប្រើប្រាស់ជាចំណូលរបស់រដ្ឋាភិបាលនោះ រដ្ឋាភិបាលនឹងមានលទ្ធភាពទទួលបានចំណូលសរុបសុទ្ធសាចគឺ ៧កោដ្ឋដុល្លារអាមេរិកឆ្លងតាមវដ្តជីវិតរបស់ខ្លួន។ នេះគឺជាតំលៃមិនទាន់គិតដល់ហានិភ័យនៅឡើយទេ ដែលមានប្រហែលជាមួយភាគបីនៃតំលៃដែលរាយការណ៍តាមសារព័ត៌មាននោះ ។

ផលិតកម្មប្រេងនៅក្នុងសមុទ្ររបស់កម្ពុជាទាំងមូល នៅមិនទាន់ត្រូវបានដោះស្រាយទាំងស្រុងនៅឡើយ ដោយមានទិដ្ឋភាពផ្សេងទៀតលើពេលវេលា តម្លៃ និងឥទ្ធិពលចំពោះសេដ្ឋកិច្ច ដែលនឹងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់។ ទោះបីជាការអភិវឌ្ឍន៍ប្រេង អាចធ្វើអោយផ្លាស់ប្តូរជាខ្លាំងទៅលើសេដ្ឋកិច្ចរបស់កម្ពុជាក្តី ក៏កំរិតនៃឥទ្ធិពលនឹងនៅតែពឹងផ្អែកយ៉ាងធ្ងន់ធ្ងរទៅលើការអភិវឌ្ឍន៍ ដែលនឹងត្រូវពង្រីកបែបណា។ ប៉ុន្តែឥទ្ធិពលនៃការអភិវឌ្ឍន៍

[4] តាមកាសែត The Cambodian Daily ថ្ងៃទី 5 ខែកក្កដា ឆ្នាំ 2006, កាសែត Cambodia Sin Chew Daily 24 July 2006, ។ល។

ប្រេងនៅក្នុងការសិក្សានេះ គឺគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនសំរាប់ធ្វើការសម្មត់ជាមូលដ្ឋាន ទិន្នន័យដែលបានប្រកាសជាផ្លូវការ (ដែលជាការប៉ាន់ស្មានសមរម្យបំផុតនោះក្នុងចំណោមទិដ្ឋភាពផ្សេងៗទៀតនោះ) ដោយអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) នឹងត្រូវបានយកទៅធ្វើការពិចារណានៅពេលពិនិត្យទៅលើម៉ាក្រូសេដ្ឋកិច្ចនៅក្នុងការវិភាគនេះ ។

**តារាង ២-១-៤ សេនារីយោសំរាប់ផលិតកម្មប្រេងនៅតាមឆ្នេរសមុទ្រកម្ពុជានៅប្លុក A**

| Key factors | Settings |
|---|---|
| ប្រភពធនធានប្រេងបំរុង (Reserve): | |
| (៤) ប្រេង និងឧស្ម័នកំណរ (Oil and gas condensate) | ៩៦ លានបារ៉ែល |
| ឧស្ម័នធម្មជាតិ (Natural gas) | ៧៤ លានម៉ែត្រគូប |
| កាលវិភាគនៃការអភិវឌ្ឍន៍ : | |
| (៥) ចាប់ផ្តើមផលិតកម្ម (Start of production) | នៅឆ្នាំ ២០១២ |
| ផលិតកម្មពេញសមត្ថភាព (Production peak) | នៅឆ្នាំ ២០១៥ |
| កិច្ចសន្យាបែងចែកផលិតកម្ម (PSC): | រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបាន៥០% ពីចំណូលនៃការលក់ |
| ចំណាយអភិវឌ្ឍន៍ (Development cost): | 17.009 billion USD |
| វិនិយោគផ្ទាល់ (Direct inward investment): | 2.05 billion USD |

ប្រភព : ទិន្នន័យទទួលបានពីអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA)

## ២.១.៣ សេនារីយោនៃវិនិយោគបរទេសផ្ទាល់/ការអភិវឌ្ឍន៍សំរាប់ការនាំចេញ

ប្រសិនបើជាកត្តាផ្សេងៗដែលបាន ពោលខាងលើត្រូវបានយកមកធ្វើការពិចារណាជាមូលដ្ឋានស្របទៅតាម ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ក្នុងពេលត្រួតពិនិត្យទៅលើសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងរយៈពេលមធ្យម និងវែង គេនឹងពិតជាពិចារណាលើការធ្វើឱ្យមានការជឿនលឿនជាមូលដ្ឋានគ្រឹះចំពោះឧស្សាហកម្មទេសចរណ៍ និងការធានាប្រាក់ចំណូលរបស់រដ្ឋដោយការអភិវឌ្ឍន៍ប្រេង ថាជាមូលដ្ឋានគ្រឹះ។ លើសពីនេះទៀតនោះ គេអាចសន្មត់បានថានិន្នាការមួយដូចជាកំណើនមូលប័ត្រដើមទុន និងចំនួនបុគ្គលិក តាមរយៈការវិនិយោគបរទេសផ្ទាល់ កំពុងលេចចេញមកពីការកែលំអបរិស្ថានវិនិយោគ និងនិន្នាការដូចជា វឌ្ឍនភាពនៃជំនាញការងារជាមូលដ្ឋានស្របជាមួយនឹងភាពកាន់តែប្រសើរឡើងនៃកំរិតអប់រំបឋមសិក្សា និងមធ្យមសិក្សា នឹងផ្តល់ផលដល់ការពន្លឿន/ភាពជឿនលឿនទៅមុខនៃសមត្ថភាពផលិតកម្ម ឬផលិតភាព និងជំរុញការអភិវឌ្ឍន៍បន្ថែមទៀត។ ពាក់ព័ន្ធដល់ឧស្សាហកម្មកម្មន្តសាល វាក៏ជាបញ្ហាងាយយល់ផងដែរដើម្បីសន្មត់អំពីការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធឧស្សាហកម្មមានកំរិត ដែលមានទំនាក់ទំនងជាមួយនិន្នាការដូចបានពោលខាងលើ ដើម្បីឱ្យមានកំណើនជាសន្ទើមៗនៃឧស្សាហកម្មសេវាកម្ម និងឧស្សាហកម្មអតិកំលាំងពលកម្ម ក្រោមកាលៈទេសៈដែលមានការកើនឡើងនៃឧស្សាហកម្មមានតំលៃបន្ថែមខ្ពស់ គឺមានការខុសគ្នាយ៉ាងខ្លាំងពីឧស្សាហកម្មកាត់ដេរបច្ចុប្បន្ន ក្នុងពេលដែលផលិតភាពពលកម្ម មិនត្រូវបានរំពឹងទុក។

ទន្ទឹមនឹងនេះ បន្ថែមលើការកើនឡើងនៃមូលប័ត្រទុន និងចំនួនបុគ្គលិក និងវឌ្ឍនភាពនៃជំនាញការងារ ដែលមានការពាក់ព័ន្ធដល់បណ្តាប្រទេសជិតខាង វាគឺជាការចាំបាច់ដើម្បីត្រួតពិនិត្យទៅទស្សនវិស័យជាអនាគតជាមួយ នឹងការពិចារណាចំពោះឥទ្ធិពលនៃទំនាក់ទំនងប្រកួតប្រជែងសំរាប់នាំចេញនៅលើម៉ាក្រូសេដ្ឋកិច្ច។ នៅក្នុងការវិភាគនេះ គំរូម៉ាក្រូសេដ្ឋកិច្ចមាត្រដ៏សាមញ្ញមួយ ដែលពិចារណាអំពីកត្តានានដែលមានឥទ្ធិពលបែបនោះ នឹងត្រូវបានអភិវឌ្ឍន៍ ហើយសកម្មភាពសេដ្ឋកិច្ចរបស់កម្ពុជានាឆ្នាំ២០១០ និងក្នុងឆ្នាំ២០២០ ជាពិសេសគឺកំរិតនៃផលិតកម្ម និងនាំចេញ នឹងត្រូវបានព្យាករណ៍ជាមុន។

## ២.២ ការប៉ាន់ស្មានជាលក្ខណៈបរិមាណនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ២.២.១ លក្ខខណ្ឌនៃការបង្កើតគំរូ

គំរូម៉ាក្រូសេដ្ឋកិច្ចមាត្រសាមញ្ញមួយ ដែលនឹងត្រូវបង្កើតឡើងនៅក្នុងរបាយការណ៍នេះ អាចព្យាករណ៍អំពី ផលិតផលក្នុងស្រុកសរុប (GDP) រាល់ឆ្នាំរហូតដល់ឆ្នាំ២០២០ ចំណាយការប្រើប្រាស់ចុងក្រោយរបស់ឯកជន និមិត្តកម្មនៃដើមទុនសរុប និងតុល្យភាពនៃការនាំចេញ និងនាំចូល (នៃទំនិញ និងសេវាកម្ម)។ គេក៏ត្រូវគិត ផងដែរអំពីឥទ្ធិពលនៃវិនិយោគបរទេសផ្ទាល់លើ ផ.ស.ស និងផលប៉ះពាល់នៃកត្តាប្រកួតប្រជែងនៃការនាំចេញ ដូចជាការប្រកួតប្រជែងអន្តរជាតិលើតំលៃនាំចេញ និងសមត្ថភាពផលិតកម្មរបស់កម្ពុជា។ ទន្ទឹមនឹងនោះ ប្រជាពលរដ្ឋ វិនិយោគបរទេសផ្ទាល់ និងជំនាញរបស់កម្មករ នឹងត្រូវចាត់ជាអថេរខាងក្រៅ (exogenous variable)។

ទាក់ទិនដល់ឥទ្ធិពលនៃការអភិវឌ្ឍន៍ប្រេងលើកំរិតម៉ាក្រូសេដ្ឋកិច្ច វាផ្អែកជាសំខាន់លើថាតើប្រេងនៅត្រូវបាននាំចេញផ្ទាល់ពីសមុទ្រ ឬថាតើវានឹងត្រូវបានចំរាញ់នៅក្នុងរោងចក្រចំរាញ់ប្រេងក្នុងប្រទេសឬទេ ហើយឧស្សាហកម្មគីមីត្រូវបានបង្កើតឡើង ហើយនៅពេលនោះផលិតផលប្រេងឥន្ធនៈនឹងត្រូវចែកចាយ ឬមិនចែកចាយ។ បើសិនជាប្រេងនៅត្រូវបានចំរាញ់ ហើយប្រើប្រាស់នៅក្នុងប្រទេសនោះ ការវិភាគមួយដែលកំពុងប្រើប្រាស់តារាងធាតុចូល-ធាតុចេញ នឹងក្លាយទៅជាបញ្ហាសំខាន់។ យ៉ាងណាមិញនៅក្នុងការវិភាគនេះ មានតែផលប៉ះពាល់ដោយផ្ទាល់ នៃការអភិវឌ្ឍន៍ប្រេងលើតុល្យភាពនៃពាណិជ្ជកម្មដោយការនាំចេញ និងផលប៉ះពាល់ដោយផ្ទាល់នៃវិនិយោគបរទេសផ្ទាល់ជាមួយនឹងបន្សំនៃថ្លៃអភិវឌ្ឍន៍ ត្រូវបានយកមកធ្វើការពិចារណា ក្រោមការសន្មត់មួយដែលថាបរិមាណប្រេងទាំងមូលត្រូវបាននាំចេញដោយផ្ទាល់ចេញពីអណ្តូងខួងចំរាញ់ប្រេងនោះ ។

### ២.២.២ សមីការតាក់តែងជាគំរូ

ស្នូលនៃគំរូ គឺជាទំរង់មូលដ្ឋានគ្រឹះនៃគំរូកំណើនដែលនៅក្នុងនោះ ផលិតកម្មត្រូវបានកំណត់ថាជាមុខងារនៃពលកម្ម និងដើមទុន។ម្យ៉ាងទៀត Y=F (L, K)។ ដើម្បីអោយច្បាស់លាស់ជាងនេះ គំរូកំណើន តាមបែបតន្តិថ្មីនិយមដូចជា $Y=A \cdot L^{\alpha} \cdot K^{(1-\alpha)}$ (កំណត់ចំណាំ : Y= ផលិតកម្ម, L= ពលកម្ម, K= ដើមទុន, A= មេគុណផលិតភាព) គឺត្រូវបានអនុម័តជាទំរង់ដើមនៃមធ្យោបាយផលិតកម្មមួយ។ មេគុណផលិតភាព “A” គឺមិនត្រូវបានពិចារណាថាមានលក្ខណៈថេរទេ ប៉ុន្តែគឺជាអថេរខាងក្រៅ (exogenous variable) ដូចពេលមុន (ដូចការកែលំអកំរិតអប់រំក្នុងអណត្តិពិតប្រាកដ)។ វាក៏នឹងត្រូវបានពិចារណាថាជាអថេរមួយដែលពន្យល់អំពីផលិតកម្ម ដោយផ្អែកទៅលើគំនិត

ដែលវឌ្ឍនភាពនៃជំនាញរបស់ការងារ ឱ្យផលក្នុងការកែលំអផលិតភាពពលកម្ម ។

**រូបភាព ២-២-១ គំនូសបំព្រួញនៃគំរូម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**




ជាលទ្ធផល ការធ្វើតាមនៃគំរូ បានក្លាយទៅជាអ្វីដែលដូចក្នុងគំនូសបំព្រួញខាងលើ។ ជុំវិញលំហូរចូលមក នៃវិនិយោគ

បរទេសផ្ទាល់ ដូចក្នុងដែនកំណត់ចំបងមួយ ដែលកំពុងកើតមានជុំវិញម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងលទ្ធភាពនៃការប្រកួតប្រជែងនាំចេញជាមួយបណ្តាប្រទេសដទៃទៀត ដែនកំណត់នីមួយៗ ត្រូវបានពិចារណាជាអថេរដើមដំបូង។ ការតាក់តែងសមីការគំរូនេះ រួមមានសមីការសរុបចំនួន ៩ ដូចដែលបានសបញ្ជាក់នៅក្នុងតារាងខាងក្រោមនេះ[5] ។ ក្នុងចំណោមសមីការនោះ មានសមីការចំនួន ៥ មានសញ្ញានិមិត្តរូប * គឺជារូបមន្តបន្ទាត់ត្រឡប់ (linear regression formula) ហើយសមីការផ្សេងទៀត គឺជារូបមន្តរចនាសម្ព័ន្ធ (structural formular) ។

**តារាង ២-២-១ រូបមន្ត Constitutive នៃគំរូម៉ាក្រូរបស់កម្ពុជា**

- GDP= F (ចំនួននិយោជិត, ប៉ារ៉ាម៉ែត្រនៃកំរិតផលិតភាព មូលប័ត្រទុន [-1] ) *
- ការនាំចេញ/GDP= F (អត្រាប្តូរប្រាក់យ៉ាន់ចិន ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត បរិស្ថានពាណិជ្ជកម្ម ដូចជាវិធានការសុវត្ថិភាពនៃប្រទេសប្រកួតប្រជែង អត្រាប្តូរប្រាក់រៀលខ្មែរ) *
- តម្លៃនៃការនាំចេញ= ការនាំចេញ/GDP×GDP
- ចំណាយប្រើប្រាស់ចុងក្រោយរបស់ឯកជន= F (GDP, ចំណាយប្រើប្រាស់ចុងក្រោយរបស់ឯកជន [-1] ) *
- តម្លៃនៃការនាំចូល= F (តម្លៃនៃការនាំចេញ ចំណាយប្រើប្រាស់ចុងក្រោយរបស់ឯកជន) *
- តុល្យភាពពាណិជ្ជកម្ម= តម្លៃនៃការនាំចេញ-តម្លៃនៃការនាំចូល
- និមិត្តកម្មទុនដុល= F (GDP) *
- សញ្ញាប័ណ្ណទុន= និមិត្តកម្មទុនដុល + វិនិយោគចូលក្នុងប្រទេស + សញ្ញាប័ណ្ណទុន [-1]
- ចំនួននិយោជិត= F (ប្រជាជននៅវ័យដែលមានផលិតភាព= F <ភាពស្វាហាប់របស់ប្រជាជន> )

កំណត់សំគាល់ : មេគុន និងលក្ខខណ្ឌលំអៀងនៃប្រភេទទំនិញនីមួយៗត្រូវបានលុបចោល

ប្រភព : ក្រុមសិក្សាចៃកា

## ២.២.៣ ចរិតលក្ខណៈនៃរចនាសម្ព័ន្ធគំរូ

### (១) សមាសភាគនៃផលិតផលក្នុងស្រុកសរុប "ផសស" (GDP)

បើសិនជា ផសស ត្រូវបានបង្ហាញពីចំណាយ វាមានជាកត្តាបួនជាគោលការណ៍ ដូចជាចំណាយការប្រើប្រាស់ចុងក្រោយនៃឯកជន ការបង្កើតដើមទុនសរុប តុល្យភាពពាណិជ្ជកម្មនៃទំនិញ និងសេវាកម្ម និងការចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល ។

មុខងារសំរាប់ការប្រើប្រាស់ចុងក្រោយនៃឯកជន (private final consumption) យកគំរូពីស្តូកាស្ទិច (stochastic) ជារបៀបស្វ័យថយក្រោយ (autoregressive model) ។ នេះក៏ព្រោះតែ ចំណែកនៃការចំណាយប្រើប្រាស់ចុងក្រោយនៃឯកជននៅក្នុង ផសស ដែលត្រូវបានប៉ាន់ស្មានតាមរយៈមុខងារផលិតកម្ម បាននឹងកំពុងតែថយចុះជាបណ្តើរស្របទៅតាមភាពចាស់ទុំនៃខឿនសេដ្ឋកិច្ចនោះ ។

ម្យ៉ាងវិញទៀត ក្នុងបរិការនៃការប៉ាន់ស្មាននៃតំលៃនាំចេញ វាត្រូវបានគណនាដោយគិតអោយចេញចំនួនភាគរយនៃតំលៃនាំចេញនៅក្នុង ផសស ដែលជាអថេរមិនឯករាជ្យ ហើយគុណនឹងភាគរយរបស់វា ដោយ ផសស ដើម្បីនឹងឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលនៅក្នុងនោះភាគរយនៃទំនិញ/សេវាកម្ម នាំចេញ នៅក្នុងផសស គឺមានលក្ខណៈធំធេង ហើយក៏កំពុងតែមានការរីកចំរើនឡើង ។

លើសពីនេះ ភាគរយនៃការបង្កើតដើមទុនសរុបនៅក្នុង GDP បាននឹងកំពុងតែកើនឡើងជាបណ្តើរៗ ដល់ភាពចាស់ទុំនៃខឿនសេដ្ឋកិច្ច។ បាតុភូតនេះ ត្រូវបានចម្លងដោយការវិភាគបន្ទាត់ថយក្រោយសាមញ្ញ (simple linear regression analysis) នៅក្នុងគំរូនេះ ។

ទោះបីជាការចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល បានទទួលនូវដំណាក់កាលអន្តរកាលប្រហែលជា 10% នៃ GDP នៅក្នុងស្ថិតិពីអតីតកាល ក៏វានៅតែមិនត្រូវបានគេចាត់ទុកថាជាអថេរនៅក្នុងគំរូនេះ ដោយសារតែ មូលហេតុច្បាស់លាស់ ដែលវាកើតឡើងជាញឹកញាប់មានភាពមិនស្របគ្នាខាងស្ថិតិទំនងជាមានលក្ខណៈតូចជាង បើសិនជាគេពិនិត្យវាពីជ្រុងជ្រោយនៃស្ថិតិចំណាយនៃ GDP ។

អថេរ ដែលបានប្រើប្រាស់ជាអថេរពន្យល់មួយបាន នៅពេលណាការប៉ាន់ស្មាន ផសស ត្រូវបានគេពន្យល់ដូចតទៅនេះ :

(i) *ចំនួនកំលាំងពលកម្ម:*

ចំនួននិយោជិត ត្រូវបានគេចាត់ទុកថាជាអថេរ ចង្អុលបង្ហាញពីកំលាំងពលកម្ម ដែលជាកត្តាគន្លឹះមួយក្នុងចំណោមកត្តាជាគន្លឹះយ៉ាងច្រើនសំរាប់ផលិតកម្ម ហើយប្រើប្រាស់ប្រជាជនទៅតាមអាយុរហូតដល់ឆ្នាំ២០២០ ដែលបានប៉ាន់ប្រមាណដោយប្រើប្រាស់ការវិភាគជាក្រុមដោយ UNFPA ថាជាទិន្នន័យដើម។ នៅក្នុងរបាយការណ៍នេះ ប្រជាជនក្នុងវ័យពលកម្ម (ពីអាយុ១៥-៦៤) គឺត្រូវបានទទួលយកជាប្រជាជនដែលធ្វើការ។ ដូច្នេះហើយ ចំនួននិយោជិត ជាអថេរដើមដំបូង និងកត្តានានាដូចជាការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់ប្រជាជនស្របទៅតាមការបំរែបំរួលនៃកិរិតសេដ្ឋកិច្ច គឺមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគំរូនេះទេ ។

យោងទៅតាមតួលេខ stochastic នៃ UNFPA, ក្នុងបរិការណ៍នៃថាមវន្តរបស់ប្រជាជន គេរំពឹងថាប្រជាជនទាំងមូលនឹងកើនឡើងដល់ចំនួនជិត ២% និងមានប្រជាជនប្រមាណ ១៥.៣លាននាក់ នៅត្រឹមឆ្នាំ២០១០ និងមាន ១៨.៨លាននាក់ នៅត្រឹមឆ្នាំ២០២០។ ជាលទ្ធផលនៃកំណើនប្រជាជនស្ថិតក្រោមលក្ខខណ្ឌស្ថេរភាពនៃប្រទេសមួយ ដែលអតុល្យភាពនៃសន្ទស្សន៍ភេទត្រូវបានរំពឹងថានឹងអាចដោះស្រាយ ហើយនឹងក្លាយទៅជា ១.០៤:១ នៅត្រឹមឆ្នាំ២០២០។

សមាមាត្រនៃប្រជាជនក្នុងវ័យធ្វើការ ដែលមានចំនួនសរុបប្រមាណ ៥២% នៅក្នុងឆ្នាំ១៩៩៨ ហើយមានចំនួន៦០% នាពេលបច្ចុប្បន្ននេះ។ ចំនួននេះនឹងកើនឡើងដល់ ៦៣%នាឆ្នាំ២០១៤ ហើយនៅពេលនោះវានឹងចាប់ផ្តើមថយចុះតិចតួច នៅពេលដែលពលរដ្ឋមានវ័យចំណាស់នឹងកើនឡើងជំនួសវិញ ។

ក្នុងបរិការណ៍នៃមេគុណអន្តោប្រវេសន៍ វាជារឿងងាយយល់ណាស់ថា ការពិតប្រជាជននឹងកាន់តែកើនចំនួនច្រើនជាងអ្វីគេរំពឹង ដែលស្របទៅនឹងការធ្វើមាតុភូមិនិវត្តន៍របស់កម្មករចំណាកស្រុក ពីព្រោះតែចលនារីត

បន្ទឹងជាបណ្តើៗចំពោះអ្នកស្នាក់នៅខុសច្បាប់នៅប្រទេសថៃ មិនត្រូវបានរាប់ចូលនៅក្នុងរបាយការណ៍របស់ UNFPA ទេ។

(ii) *សញ្ញាប័ណ្ណមូលធន (Capital stock):*

សញ្ញាប័ណ្ណមូលធន គឺជាអថេរមួយ ដែលបានគេចាត់ទុកថាជាមូលធន ដែលជាដែនកំណត់មួយទៀតសំរាប់សកម្មភាពផលិតភាព។ ប៉ុន្តែ វាត្រូវបានបង្កើតឡើងជាអថេរ ដែលកំណត់នូវតំលៃដែលគ្មានលទ្ធភាពសង *(default value)* ហើយបូកបន្ថែមនូវមូលធនរៀងរាល់ឆ្នាំ ពីព្រោះស្ថិតិ សញ្ញាប័ណ្ណមូលធន គឺមិនមានបញ្ចូលទៅក្នុងគណនីជាតិរបស់ប្រទេសកម្ពុជាទេ។ តំលៃដែលគ្មានលទ្ធភាពសង ត្រូវបានកំណត់ត្រឹម ១០ ពាន់ កោដ្ឋរៀល ដែលជាតួលេខមួយ ដែលមេគុណមូលធន អាចកែលំអការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ការបង្កើនជារៀងរាល់ឆ្នាំនូវសញ្ញាប័ណ្ណមូលធន គឺជាការបង្កើតមូលធនសរុប ដែលត្រូវបានគណនាពី ផលសនៃឆ្នាំនោះ និងវិនិយោគបរទេស។ លើសពីនេះទៀត វាក្លាយទៅជាលទ្ធភាពមួយ ដើម្បីពិពណ៌នានូវរចនាសម្ព័ន្ធ ដែលសមាច័យ **(accumulation)** នៃការវិនិយោគ (*ដែលត្រូវបានដកចេញពីគណនេយ្យសេដ្ឋកិច្ចជាតិ ជាចម្លងការមូលធន (capital transaction) និងពី GDP ដែលជាលំហូរមួយ ដូច្នេះហើយវាមិនរួមបញ្ចូលការបង្កើតមូលធនដុល ប៉ុន្តែត្រូវបានកត់ត្រាទុនជាគណនីមួយ នៃការទទួលបានមូលធន*) មានឥទ្ធិពលមួយលើផលិតកម្ម ដោយកំពុងទទួលយកចលនាឡើងចុះ នៃទ្រព្យសម្បត្តិ ដែលជាអថេរខាងក្នុង **(endogenous variable)** ។

(iii) *មេគុណផលិតភាព:*

ឧស្សាហកម្មកម្មន្តសាល ដែលរំពឹងថានឹងអភិវឌ្ឍន៍នៅប្រទេសកម្ពុជាចាប់ពីពេលនេះតទៅ ត្រូវបានគេសន្មត់ថាទុកសំរាប់ផ្នែកដ៏ធំមួយនៃការងារពាក់ព័ន្ធដល់ពលកម្មតូចតាច។ ផ្អែកលើការអង្កេតនៃបទសំភាសន៍កន្លងមក កម្មករជំនាញ ដែលមានគុណវុឌ្ឍ *(qualification)* នៃការគ្រប់គ្រង ត្រូវបានគេចាត់ទុកថាជាកត្តាជាចំបងមួយ ដែលព្យាករណ៍ពីជោគជ័យ/បរាជ័យនៃឧស្សាហកម្មកម្មន្តសាលនៅកម្ពុជា ។

បើទោះបីជាមេគុណផលិតភាពធម្មតា ត្រូវការឆ្លុះបញ្ចាំងអំពីកំរិតជំនាញ និងផលិតភាពពលកម្មរបស់កម្មករដែលចូលរួមក្នុងផលិតកម្ម សន្ទស្សន៍នៃការចុះឈ្មោះចូលសិក្សានៅសាលាកំរិតមធ្យមសិក្សាបឋមភូមិ ត្រូវបានចាត់ទុកថាជាមេគុណផលិតភាពនៅក្នុងការវិភាគនេះ ពីព្រោះថាគ្មានស្ថិតិសមស្របជាធរមានណា ដែលអាចប្រើប្រាស់បានទេ។ ក្នុងចំណោមកម្មកររោងចក្រឧស្សាហកម្មជាច្រើននៅកម្ពុជា គឺបានបញ្ចប់ការសិក្សាក្នុងកំរិតមធ្យមសិក្សាបឋមភូមិ ឬមធ្យមសិក្សាទុតិយភូមិ ដូច្នេះហើយសាលាមធ្យមសិក្សាបឋមភូមិត្រូវបាន គេចាត់ទុកថាជាការសមស្រប សំរាប់កំរិតសិក្សាវិជ្ជាប្រកបដោយទិដ្ឋភាពអនាគតសំរាប់ជាគោលបំណង នៃការវិភាគនេះ។ សន្ទស្សន៍ចូលរៀនសាលាមធ្យមសិក្សាបឋមភូមិ ត្រូវបានគេប្រើប្រាស់ជាអថេរ

ក្រៅសម្ព័ន្ធ ប៉ុន្តែតំលៃទស្សនៈអនាគត ត្រូវបានកំណត់ដោយផែនការយុទ្ធសាស្ត្រវិស័យអប់រំ[5] និងលទ្ធផលនៃការសំភាសន៍ជាមួយក្រសួងអប់រំ យុវជន និងកីឡា[6] ។

**(២) ការនាំចេញ ការនាំចូល និងតុល្យភាព**

ភាគរយនៃតម្លៃទំនិញនាំចេញ និងសេវាកម្មក្នុង GDP បានថ្លឹងថ្លែងនូវលក្ខខណ្ឌប្រកួតប្រជែងរវាងប្រទេសជិតខាងនៅពេលធ្វើការនាំចេញ ។ ដើម្បីអោយច្បាស់ជាងនេះ ការប្តូររូបិយវត្ថុជាតិ KHR និង រូបិយវត្ថុអន្តរជាតិ USD ត្រូវបានចាត់ទុកជាដែនកំណត់សំខាន់មួយ ។ អាត្រាប្តូររូបិយវត្ថុចិន CNY ទៅ USD ក៏ត្រូវបានចាត់ទុកជាដែនកំណត់មួយផងដែរ ដែលមានឥទ្ធិពលលើសមត្ថភាពនាំចេញរបស់ប្រទេសចិន ដែលគេចាត់ទុក ជាប្រទេសប្រកួតប្រជែងធំមួយ ។ លើសពីនេះទៅទៀត ថាតើមានកូតានាំចេញនៅក្នុងសហរដ្ឋអាមេរិក ឬអត់ ដែលត្រូវបានចាត់ទុកជាអថេរមួយ (អថេរនិមិត្តរូប dummy variable) នៃបរិស្ថាននាំចេញ និងថាតើមានការគាំពារទីផ្សារដើម្បីប្រកួតប្រជែងជាមួយប្រទេសចិនយ៉ាងណា ដូចអថេរសំរាប់ពន្យល់មួយ ។

បរិកាណ៍នៃការនាំចូល វាត្រូវបានពន្យល់ដោយតម្លៃនាំចេញនិងចំណាយលើការប្រើប្រាស់ចុងក្រោយឯកជនដែលឆ្លុះបញ្ចាំងអោយឃើញថាវាយនភ័ណ្ឌ ជាទំនិញអន្តរការីនៃផលិតផលសំលៀកបំពាក់ ដែលជាទំនិញនាំចេញភាគច្រើននៃកម្ពុជានោះ ការពឹងផ្អែកទាំងស្រុងលើការនាំចូល និងកំពុងឆ្លុះបញ្ចាំងនូវភាគរយនៃផលិតផលនាំចូល ដែលជាទំនិញប្រើប្រាស់នៅកម្ពុជា ហាក់មានកំរិតខ្ពស់ ។

ទោះបីជាភាពខុសគ្នានៃការនាំចេញ និងការនាំចូលទំនិញនិងសេវាកម្ម ចង្អុលអោយឃើញពីតុល្យភាពក៏ដោយ ផ្អែកលើរចនាសម្ព័ន្ធតម្លៃនាំចូល ដែលពឹងផ្អែកយ៉ាងខ្លាំងលើតម្លៃនាំចេញ និងចំណាយលើការប្រើប្រាស់ចុងក្រោយនៃឯកជននោះ វាលេចចេញនូវការពិបាក ដើម្បីធ្វើអោយល្អឡើងនូវតុល្យភាព ប្រសិនបើមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការពង្រីកការនាំចេញ ។ ដូច្នេះហើយ ដើម្បីនឹងឆ្លុះបញ្ចាំងអោយឃើញពី ការធ្វើឱ្យល្អឡើងនូវរចនាសម្ព័ន្ធពាណិជ្ជកម្មទៅអនាគត ការកែសំរួលតម្លៃថេរ បានត្រូវអនុវត្តលើតម្លៃអនាគតផ្អែកលើការព្យាករណ៍របស់រដ្ឋាភិបាល ។

អថេរជាគន្លឹះ បានប្រើសំរាប់ពន្យល់អំពីការគណនាភាគរយតម្លៃនាំចេញ ដែលទុកសំរាប់ ផសស នឹងត្រូវពិពណ៌នាជូនដូចខាងក្រោម ។

---

[5] ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ 2006-2010, ខែធ្នូ ឆ្នាំ 2005 (ESP)

[5] សន្ទស្សន៍ចុះឈ្មោះចូលរៀនមធ្យមសិក្សាបឋមភូមិនៅកម្ពុជាគឺមានតែ 20% ទេបច្ចុប្បន្ននេះ ។ របាយការណ៍វឌ្ឍនភាពរបស់ MDGs និង NSDP ដែលផ្អែកទៅលើរបាយការណ៍នោះបានគាំទ្រការបង្កើតសន្ទស្សន៍អោយមាន 75% នៅត្រឹមឆ្នាំ 2010 ។ យ៉ាងណាមិញ នៅក្នុង ESPដែលបានប្រកាសដោយក្រសួងអប់រំ យុវជន និងកីឡានៅដំណាច់ 2005, គោលដៅនៃឆ្នាំ 2010 ត្រូវបានផ្លាស់ប្តូរដល់កំរិតទាបជាងមួយគឺ 50% ។ អ្វីដែលជាងនេះទៅទៀត នៅក្នុងកិច្ចសំភាសន៍ជាមួយក្រសួងអប់រំ យុវជន និងកីឡា គេបានរាយការណ៍មកថា គោលដៅរបស់ ESPជាហាក់បីដូចជាពិបាកសំរេចអោយបានណាស់ ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ។

(i) *អត្រាប្តូរប្រាក់រវាង KHR/USD :*

ចាប់តាំងពីឆ្នាំ១៩៩៨ អន្តរកាលនៃរូបិយប័ណ្ណរបស់កម្ពុជា KHR គឺមានស្ថេរភាពគួរសម ហើយថ្មីៗនេះបាន នឹងកំពុងនៅទ្រឹងត្រឹមភាគរយនៃអត្រាធ្លាក់ប្រចាំឆ្នាំដែលមានកំរិត 0.៥-១%។ នៅក្នុង NSDP របស់ រដ្ឋាភិបាលកម្ពុជា គេសន្មត់ថា KHR នឹងបន្តអន្តរកាលថេរមួយក្នុងកំរិតប្រហែល0.៥% នៃការបញ្ចុះថ្លៃ ប្រចាំឆ្នាំ។ ដោយសារតែការសន្និដ្ឋាននេះទំនងជាសមហេតុផល ប្រាក់រៀលខ្មែរ KHR ត្រូវបានចាត់ទុក ជាអថេរក្រៅសម្ព័ន្ធមួយ ដែលស្ថិតក្រោមអន្តរកាលនៃកំរិតដូចគ្នា។

នៅកម្ពុជា វាចាំបាច់ដើម្បីត្រូវកត់សំគាល់ថា ម៉ាក្រូសេដ្ឋកិច្ចដោយអត្រាប្តូរប្រាក់នៃរូបិយប័ណ្ណក្នុងស្រុកជា រៀល គឺត្រូវពិចារណាដើម្បីត្រូវបានប្រៀបធៀបជាមួយប្រទេសដទៃៗទៀត ដែលស្ទើតែមិនបានរាប់បញ្ចូល ដូចក្នុងអន្តរការធុរកិច្ចនៅក្នុងសង្គម ព្រមទាំងការទូទាត់ ដែលត្រូវបានធ្វើជាប្រាក់ដុល្លារអាមេរិក។

(ii) អត្រាប្តូរប្រាក់ចិន/អាមេរិក *CNY/USD :*

ឧបមាថា ប្រទេសប្រកួតប្រជែងសំខាន់មួយនៃការនាំចេញរបស់កម្ពុជា គឺប្រទេសចិន អត្រាប្តូរប្រាក់របស់ ប្រទេសនោះ ត្រូវបានចាត់ទុកជាប៉ារ៉ាម៉ែត្រមួយ ដែលឆ្លុះបញ្ចាំងពីអថេរប្រកួតប្រជែងមួយ។ និយាយតាម មួយបែបទៀត ដោយអត្រាប្តូរប្រាក់របស់រូបិយវត្ថុចិន CNY កើនឡើងនោះ វាធ្វើអោយមានគុណប្រយោជន៍ ដល់ការនាំចេញរបស់កម្ពុជា។ អត្រាប្តូរប្រាក់រវាងប្រាក់ CNY ទៅជាប្រាក់ USD បានធ្លាក់ចុះរហូតដល់ឆ្នាំ ១៩៩៧ ប៉ុន្តែបានមានអត្រាប្តូរប្រាក់មិនប្រែប្រួលមួយរហូតដល់ឆ្នាំ២00៤។ ចាប់តាំងពីពេលនោះមក វាបាននឹងកំពុងកើនឡើងសន្សឹមៗក្នុងល្បឿនយឺតមួយហើយក្នុងឆ្នាំ២00៥ វាបាននឹងកំពុងកើនឡើងប្រហែល ១% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ សព្វថ្ងៃនេះ ដោយសារមានសម្ពាធជាអន្តរជាតិ ចំពោះការវាយតម្លៃ ឡើងវិញលើប្រាក់ CNY បាននឹងកំពុងបន្តរឹតបន្តឹងនោះ អត្រាប្តូរប្រាក់ CNY ទៅជាប្រាក់ USD ត្រូវបានគេសន្និដ្ឋានថានឹងកើនឡើង៥% ក្នុងឆ្នាំ២00៦ ១0% បន្ទាប់ពីនោះ និងការកើនឡើងក្នុងល្បឿន ៥% ជាថ្មីម្តងទៀតបន្ទាប់ពីឆ្នាំ ២0១៥។

(iii) *កត្តាប្រកួតប្រជែងដទៃៗទៀត*

បន្ថែមពីលើអត្រាប្តូរប្រាក់ វិធានការគាំពារដើម្បីនាំចេញពីប្រទេសចិន ដោយ USA និង EU (នាឆ្នាំ២00៥ ដល់២00៨) កូតានាំចូលដោយ US (នាឆ្នាំ១៩៩៩ ដល់២00៤) និងការពង្រឹងនៃច្បាប់វិនិយោគថ្មី នៅកម្ពុជា (ឆ្នាំ២00៣) ត្រូវបានចាត់ទុកថាជាអថេរនិមិត្តរូប (dummy variable) ជាវិជ្ជមាន ។

**(៣) ការចំណាយការប្រើប្រាស់ចុងក្រោយនៃឯកជន និងការបង្កើតមូលធនដុល**

ការចំណាយការប្រើប្រាស់ចុងក្រោយនៃឯកជន និងការបង្កើតមូលធនដុល គឺចេញពី ផសស។ សន្ទស្សន៍នៃការ ប្រើប្រាស់ចុងក្រោយនៃឯកជន ចំពោះ ផសស ដែលឡើងជិតដល់៩៩% នាឆ្នាំ១៩៩៦ បានថយចុះមក ត្រឹម៧៦% នាឆ្នាំ២00៥។ បាតុភូតនេះ ត្រូវបានភ្ជាប់ទៅនឹងកំណើនមួយក្នុងសន្ទស្សន៍នៃការបង្កើតមូលធនដុល។ ដូចការចំណាយ ប្រើប្រាស់ចុងក្រោយនៃឯកជន ការប៉ាន់ស្មានតាមដំណើរថយក្រោយដោយស្វ័យប្រវត្តិ ត្រូវបានធ្វើដើម្បីតំណាងឱ្យ

បាតុភូត។ លទ្ធផលរបស់វា បង្ហាញថាសន្ទស្សន៍នៃការចំណាយប្រើប្រាស់ចុងក្រោយនៃឯកជន នឹងត្រូវបន្ថយមកត្រឹមប្រហែលជា៥០% នាឆ្នាំ២០២០។

សន្ទស្សន៍នៃការបង្កើតមូលធនដុល ដែលមាន៨% ជា ផសស នាឆ្នាំ១៩៩៦ បានកើនយ៉ាងកំហុករហូតដល់ ២៧% នៅត្រឹមឆ្នាំ ២០០៥។ ផ្អែកទៅលើការសន្មត់បែបនោះ លំហូរនៃវិនិយោគបរទេសផ្ទាល់ និងការអភិវឌ្ឍន៍នៃហេដ្ឋារចនាសម្ព័ន្ធសង្គម និងឧស្សាហកម្ម នឹងនាំទៅដល់កំណើនមួយនៅក្នុងអត្រានៃការបង្កើតមូលធនដុល និងអត្រានៃប្រាក់សន្សំ ត្រូវបានរំពឹងថានឹងកើនឡើង អត្រានេះ ក៏កើនជាបណ្តើរៗទៅតាមពេលវេលានៅក្នុងគំរូបែបនោះ ។

**(៤) ការវិនិយោគ**

នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ រដ្ឋាភិបាលកម្ពុជា បានដាក់គោលដៅនៃចំនួនវិនិយោគបរទេសផ្ទាល់។ ចំនួនគោលដៅសរុបគឺ ៤កោដ្ឋដុល្លាអាមេរិក (ដែលនៅក្នុងនោះ ១.៣កោដ្ឋដុល្លាអាមេរិក គឺបានមកពីការវិនិយោគបរទេសផ្ទាល់ និង ២.៧កោដ្ឋដុល្លាអាមេរិក គឺមកពីវិនិយោគក្នុងស្រុក)។ វិស័យជាគោលដៅ កំពុងមានផលិតកម្មដូចជាឧស្សាហកម្មកាត់ដេរ និងស្បែកជើង សេវាកម្ម (ទេសចរណ៍) ការកែឆ្នៃទំនិញកសិកម្ម និងការផលិតសំភារៈសំណង់ជាដើម។ នាឆ្នាំ២០១០ វិនិយោគឯកជន ត្រូវបានរំពឹងថានឹងកើនឡើងដល់ចំនួន ៧១.៤៨ លានដុល្លារអាមេរិក (ជាប្រាក់រៀលគឺ ២.៧៥៨,១កោដ្ឋ)។ បន្ទាប់ពីឆ្នាំ២០១០ និន្នាការជាគោលដៅនៃវិនិយោគរវាងឆ្នាំ២០០៥ និង២០១០ (កំណើនប្រចាំឆ្នាំគឺពី ៣ ដល់ ៥%) ត្រូវបានគេរំពឹងថានឹងបន្តមានកំណើន។

នៅក្នុងការប៉ាន់ស្មាន ដោយសារតែការអភិវឌ្ឍន៍ធនធានប្រេង វិនិយោគបរទេសផ្ទាល់ នឹងឡើងទៅដល់ចំនុចកំពូលនាឆ្នាំ២០១០ នៅពេលដែលចំនួនប្រាក់ ៦១.៥២៤លានដុល្លាអាមេរិក បន្ថែមទៀតនឹងហូរចូលមក។ វិនិយោគបរទេសផ្ទាល់ ត្រូវបានចាត់ទុកថាជាអថេរក្រៅសម្ព័ន្ធ ដោយសារតែមូលហេតុដូចខាងក្រោមនេះ : គោលដៅរដ្ឋាភិបាល និងឥទ្ធិពលនៃការអភិវឌ្ឍន៍ធនធានប្រេង អាចត្រូវជះឥទ្ធិពល ប្រសិទ្ធភាពលើកំណើនសេដ្ឋកិច្ចនៃការប្រែប្រួល នៅក្នុងការវិនិយោគ អាចត្រូវដណ្តើមបាន ។

**២.២.៤ ទស្សទាយអំពីលទ្ធផល**

**(១) អថេរខាងក្រៅ**

តំលៃអនាគតនៃអថេរខាងក្រៅ ដែលត្រូវបានកំណត់ថាជាការសន្មត់មួយ ត្រូវបានបង្ហាញដូចនៅខាងក្រោយនេះ[7]។ វិនិយោគបរទេសផ្ទាល់ នឹងកើនឡើងបន្តបន្ទាប់ស្របទៅតាមបន្ទាត់ជាគោលដៅរបស់រដ្ឋាភិបាលរហូតដល់ឆ្នាំ២០១០។ តួលេខវិនិយោគសំរាប់ឆ្នាំ ២០១០ រួមមានចំនួនគួរឱ្យកត់សំគាល់នៃវិនិយោគក្នុងការអភិវឌ្ឍន៍ប្រេង និងដូច្នេះហើយផលិតកម្មដល់កំរិតកំពូលនៃសកម្មភាពវិនិយោគក្នុងការអភិវឌ្ឍន៍ប្រេង ឧស្ម័ន ការវិនិយោគសរុប បង្ហាញនូវការថយចុះរហូតដល់ត្រឹមឆ្នាំ២០១៥។ បើតាមការទស្សទាយរបស់ UNFPA ប្រជាជន ត្រូវបានសន្មត់ថាកើនឡើងដល់ចំនួន ១៥លាននាក់នៅឆ្នាំ២០១០ និងឡើងរហូតដល់ ១៨លាននាក់នៅឆ្នាំ២០២០។

---

[7] លទ្ធផលប៉ាន់ស្មានប្រចាំឆ្នាំត្រូវបានបង្ហាញនៅក្នុងតារាង A-2-1, ឧបសម្ព័ន្ធ 2 ។

**តារាង ២-២-២ អថេរខាងក្រៅ និងអថេរដែលបានគណនាផ្ទាល់ពីអថេរខាងក្រៅ**

| ឆ្នាំ | ការវិនិយោគខាងក្នុង ( KHR bil ) | និយោជិត ( 1,000人 ) | ប្រជាជន ( 1,000人 ) | CNY/USD | KHR/USD |
|---|---|---|---|---|---|
| ២០០៥ | 1,895 | 8,086 | 13,807 | 8.19 | 4,118 |
| ២០១០ | [8] 5,132 | 9,468 | 15,269 | 5.11 | 4,253 |
| ២០១៥ | 3,260 | 10,588 | 16,936 | 3.02 | 4,353 |
| ២០២០ | 4,160 | 11,636 | 18,724 | 2.33 | 4,453 |

កំណត់សំគាល់ : តម្លៃបិយវត្ថុគឺមានតម្លៃថេរ ២០០០

ប្រភព : ក្រុមសិក្សា ចៃកា

**(2) អថេរខាងក្នុង**

តំលៃប៉ាន់ស្មាននៃសន្ទស្សន៍សំខាន់ ដែលផ្អែកទៅលើការគណនាឆ្លងតាមគំរូម៉ាក្រូសេដ្ឋកិច្ចមួយ ត្រូវបានបង្ហាញនៅក្នុងខាងក្រោមនេះ[9] ។ រហូតដល់ឆ្នាំ២០១០ កំណើននៃអថេរនីមួយៗ គឺមានលក្ខណៈទូលំទូលាយយោងទៅតាមការប៉ាន់ប្រមាណនៃកម្មវិធីអភិវឌ្ឍន៍ជាយុទ្ធសាស្រ្តជាតិរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែ នៅក្នុងគំរូមួយដែលសមាច័យនៃវិនិយោគបានជះឥទ្ធិពលដល់សញ្ញាប័ណ្ណមូលធន វេទយិតភាពចំពោះវិនិយោគបរទេសផ្ទាល់ គឺមានសភាពខ្ពស់ ។ លើសពីនេះតុល្យភាពនៃទំនិញនិងសេវាកម្មនានាព្រមទាំងការចំណាយប្រើប្រាស់ចុងក្រោយនៃឯកជនគឺមានលក្ខណៈទាបគួរសម ។ ក្នុងចំណោមសន្ទស្សន៍សំខាន់ៗនោះ GDP និងវិស័យនាំចេញ និងនាំចូលទំនិញ/សេវាកម្ម គឺមានពន្យល់ដូចនៅក្នុងតារាងខាងក្រោមនេះ ។

**តារាង ២-២-៣ តម្លៃបានព្យាករណ៍នៃអថេរខាងក្រៅ**

| ឆ្នាំ | GDP (កោដិរៀល) | អត្រាកំណើន (%) | ចំណាយប្រើប្រាស់ចុងក្រោយរបស់ឯកជន (កោដិរៀល) | និមិត្តកម្មទុនដុល (កោដិរៀល) | ការនាំចេញទំនិញ/សេវាកម្ម (កោដិរៀល) | ការនាំចូលទំនិញ/សេវាកម្ម (កោដិរៀល) | GDP ក្នុងម្នាក់ ( 1,000 រៀល ) |
|---|---|---|---|---|---|---|---|
| 2005 | 19,294 | 7% | 14,684 | 5,229 | 13,952 | 15,591 | 1,397 |
| 2010 | 28,264 | 8% | 18,562 | 8,330 | 23,112 | 22,084 | 1,851 |
| 2015 | 43,464 | 7% | 25,751 | 14,232 | 35,522 | 32,164 | 2,566 |
| 2020 | 59,434 | 7% | 33,476 | 20,432 | 48,904 | 45,166 | 3,174 |

កំណត់សំគាល់ : តម្លៃរូបិយវត្ថុ គឺមានតម្លៃថេរ ២០០០

ប្រភព : ក្រុមសិក្សា ចៃកា

[8] ក្នុងចំណោម 2374.1 កោដ្ឋដុល្លារត្រូវបានវិនិយោគសំរាប់ជំនួញអភិវឌ្ឍន៍ប្រេងនៅបាតសមុទ្រកម្ពុជា

[9] លទ្ធផលប៉ាន់ស្មានប្រចាំឆ្នាំត្រូវបានបង្ហាញនៅក្នុងតារាង A-2-2, ឧបសម្ព័ន្ធ 2 ។

*(i) ផលិតផលក្នុងស្រុកសរុប (GDP)*

នៅក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ នៅពេលដែលសន្ទស្សន៍នៃវិស័យផលិតកម្មកសិកម្ម ព្រៃឈើ និងនេសាទមានការថយចុះ ។ សន្ទស្សន៍នៃវិស័យសេវាកម្ម រ៉ែ និងផលិតកម្មកែច្នៃដទៃៗទៀតនៅតែមានលក្ខណៈជាប់លាប់ធម្មតាទៅតាមពេលវេលានោះ ។

ជាមួយនឹងការវិនិយោគបរទេសផ្ទាល់យ៉ាងសកម្មថ្មីៗនេះ គេរំពឹងថា នឹងមានកំណើនពី ៧% ដល់ ៩% រហូតដល់ឆ្នាំ ២០១០។ ពីឆ្នាំ ២០១០ កំណើនសេដ្ឋកិច្ចនឹងស្ថេរភាពពី ៦ ដល់ ៧%។ នាឆ្នាំ ២០១២ នៅពេលដែលផលិតកម្មប្រេងចាប់ផ្តើមហើយនោះ អត្រាកំណើនខាងផលទុនក្នុងស្រុកសរុប GDP នឹងឡើងដល់ ១២% ។ អាស្រ័យហេតុនេះ កំណើនស្ថេរភាពជាង ៦% នឹងពិតជាអាចសំរេចទៅបាន ។

ជាវិបាករបស់ភាគរយខ្ពស់នៃកំណើនសេដ្ឋកិច្ច ផសស នឹងបន្តកើនទ្វេរដងនៃកំរិតបច្ចុប្បន្នមុនឆ្នាំ ២០១៥ ហើយ នឹងឈានដល់ទៅបីដងនៃកំរិតបច្ចុប្បន្នបន្ទាប់ពីឆ្នាំ ២០២០។ ការទស្សន៍ទាយនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជានេះ ទោះបីវាអាចមានកំនើនឆាប់ពេក ប៉ុន្តែវាមានសង្គត់ភាពជាមួយនិងកំណើនដ៏ឆាប់រហ័យរបស់ប្រជាជនកម្ពុជាផងដែរ ព្រមទាំងការប៉ាន់ស្មានកំណើនខ្ពស់កំពុងបន្តនៅក្នុងប្រទេសជិតខាង ដូចជាវៀតណាម និងថៃឡង់ដ៏។ កម្ពុជា នឹងត្រូវដណ្តើមយកឱ្យបាននូវកំណើនឆាប់រហ័យ ដើម្បីបំពេញនូវភាពខុសគ្នានៃសេដ្ឋកិច្ចជាមួយប្រទេសជិតខាងរបស់ខ្លួន ប៉ុន្តែការប្រឹងប្រែងនោះ នឹងមិនអាចកើតបានទេ ប្រសិនបើអត្រាកំណើននៅក្នុងការព្យាករណ៍មិនបានទទួលផល ។

**រូបទី ២-២-២ ផលិតផលក្នុងស្រុកសរុប ( ផសស) និងកំណើន ផសស**




Source : JICA Study Team

*(ii) និហរណ៍ និងអាហរ័ណនៃទំនិញ និងសេវាកម្មនានា*

នៅក្នុងអតីតកាល ប្រទេសកម្ពុជាត្រូវរងនឹងបញ្ហាឱនភាពនៃពាណិជ្ជកម្មទំនិញ នឹងសេវាកម្ម។ ប៉ុន្តែ ជាមួយនឹងកំណើនយ៉ាងឆាប់រហ័សនៃផលិតកម្មសំលៀកបំពាក់នោះ អតិរេកពាណិជ្ជកម្ម ក្នុងវិស័យទេសចរណ៍ និងផលិតកម្មប្រេងក្រោយឆ្នាំ ២០១២ ប្រទេសកម្ពុជាពិតជា នឹងបង្ហាញអំពីកំនើនលើសខាងផ្នែកពាណិជ្ជកម្មមួយជាបណ្តោះអាសន្នហើយ។ វិស័យកាត់ដេរត្រូវបានគេ រំពឹងថានឹងកើនលើសពី 30% សំរាប់រយៈពេលខ្លី និងរួមវិភាគទានដល់ទិសឈានឡើងនៅក្នុងជញ្ជីញ តុល្យភាពពាណិជ្ជកម្ម។ បន្ថែមពីនេះទៀតការវិនិយោគចូលទៅផ្នែកក្នុងពីប្រទេសថៃ និង ម៉ាឡេស៊ី បានបន្តហូរចូលមកវិស័យសេវាកម្ម និងទេសចរណ៍ ហើយចំនួនភ្ញៀវទេសចរណ៍ដែលបានរំពឹងទុក ពិតជានឹងកើនឡើង។ តុល្យភាពនៃឧស្សាហកម្មសេវាកម្មត្រូវបានគេរំពឹងថានឹងរួមវិភាគទានដល់ ដំណើរឈានឡើងក្នុងតុល្យភាពទំនិញ និងសេវាកម្ម ។

**រូបទី ២-២-៣ ការនាំចេញ និងនាំចូលនៃទំនិញ និងសេវាកម្ម ព្រមទាំងតុល្យភាព**




## ២.២.៥ សេចក្តីសន្និដ្ឋាន : កំណើនសេដ្ឋកិច្ចដែលនាំទៅដល់ការនាំចេញ ត្រូវបានគាំទ្រដោយការកើនឡើងនៃវិនិយោគបរទេសផ្ទាល់

ការគណនាជាមួយនឹងគំរូម៉ាក្រូសេដ្ឋកិច្ចធម្មតា អាចឱ្យយើងកែតំរូវ និងគាំទ្រការគ្រោងទុករបស់រដ្ឋាភិបាលចំពោះសេដ្ឋកិច្ចរហូតដល់ឆ្នាំ ២០១៥ និងបង្ហាញពីការប៉ាន់ស្មានរហូតដល់ឆ្នាំ ២០២០។ ការប៉ាន់ស្មាននេះ ចង្អុលបង្ហាញថាសេដ្ឋកិច្ចកម្ពុជា ត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគបរទេសផ្ទាល់ ដូច្នេះ វាកំពុងបញ្ជាក់នូវការទាក់ទាញការវិនិយោគបរទេសផ្ទាល់ជាបញ្ហាគន្លឹះដើម្បីសំរេចបាននូវកំណើនជាចីរភាព។

ក្នុងគំរូនេះ សូចនាករមួយស្ដីពីជំនាញ និងផលិតភាពនៃកំលាំងពលកម្មរបស់កម្ពុជា ត្រូវបានគេជួល។ សូចនាករ បានផ្ដល់ប្រសិទ្ធិភាពក្នុងគំរូនេះ ឆ្លុះបញ្ចាំងពីការពិតថាវិស័យដែលកំពុងកើនជាឆាប់រហ័សនោះ គឺ កម្មន្ដសាល និងសេវាកម្ម ដែលផ្អែកយ៉ាងខ្លាំងទៅលើកំរិតជំនាញនៃកំលាំងពលកម្មនៅក្នុងសេដ្ឋកិច្ចរបស់កម្ពុជាបច្ចុប្បន្ន[១០] ។

លើសពីនេះទៅទៀត គេអាចនិយាយបានថាការការពន្លឿននៃនិម្មិតកម្មមូលធនដុល និងការកែលំអតុល្យភាពពាណិជ្ជកម្ម ព្រមទាំងការប្រើប្រាស់ចុងក្រោយនៃឯកជន គឺមានភាពចាំបាច់ណាស់។ ក្នុងពេលដែល និម្មិតកម្មមូលធនដុលនឹងកើនឡើងជាមួយកំណើននៃការវិនិយោគបរទេសផ្ទាល់ គេអាចសន្និដ្ឋានបានថាដើម្បីទាក់ទាញឧស្សាហកម្ម បំរើការនាំចេញ គឺជាជំរើសគោលនយោបាយអថេរមួយ ដើម្បីកែលំអតុល្យភាពពាណិជ្ជកម្ម។
គេអាចនិយាយថាអត្រាប្ដូរប្រាក់ CNY-USD គឺជាកត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាដ៏សំខាន់នានា សំរាប់ភាពប្រកួតប្រជែងនៃការនាំចេញរបស់កម្ពុជា។ វាគឺជាការចាំបាច់ណាស់ដើម្បីយកចិត្តទុកដាក់ឱ្យជិតដល់ចំពោះទស្សនៈអនាគតនៃការបង្កើនតំលៃ CNY ឡើងវិញ ។

**២.៣ វិធានការ និងគោលនយោបាយសេដ្ឋកិច្ច ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចចីរភាព**

សេដ្ឋកិច្ចកម្ពុជា គឺដូចជាត្រូវសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចចីរភាពក្រោមលក្ខខណ្ឌដែលរូបិយប័ណ្ណមានស្ថេរភាព លំហូរវិនិយោគបរទេសផ្ទាល់ រក្សាបាននូវកំលាំងចលកររបស់វា ហើយអតិផរណាក៏ស្ថិតក្រោមការត្រួតពិនិត្យ។ ដើម្បីបញ្ជាក់នូវការសម្មត់នេះ រដ្ឋាភិបាលកម្ពុជា នឹងត្រូវមានកាតព្វកិច្ចដើម្បីប្រកាន់ភ្ជាប់នូវគោលការណ៍គោលនយោបាយសេដ្ឋកិច្ចជាមូលដ្ឋានមួយចំនួន។ គោលការណ៍ដែលនឹងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា រក្សាបាននូវសន្ទុះសំរាប់កំណើនចីរភាពអាចត្រូវបានសង្ខេបដូចខាងក្រោម:

**ក. កិច្ចខិតខំប្រឹងប្រែងបន្តដើម្បីធ្វើសេរីភាវូបនីយកម្មទីផ្សាររបស់វា**

ក្នុងទស្សនៈទំហំទីផ្សារ សេដ្ឋកិច្ចកម្ពុជា ត្រូវបានកំរិតកំណត់ ហើយមិនត្រូវបានទាក់ទាញវិនិយោគបរទេសផ្ទាល់សំរាប់ទីផ្សារក្នុងស្រុកប៉ុន្មានទេ។ គុណសម្បត្តិនៃសេដ្ឋកិច្ចកម្ពុជា ក្រៅពីទីផ្សារគឺសក្ដានុពលភាពរបស់វា ដើម្បីក្លាយទៅជាចំណុចជាយុទ្ធសាស្ត្រនៃការធ្វើសមាហរណកម្មជាសកលសំរាប់សកម្មភាពធុរកិច្ច ការផលិតជាគោលការណ៍។ ដូច្នេះវាមានសារៈសំខាន់ណាស់ ចំពោះសេដ្ឋកិច្ចត្រូវបានស្ថិតក្នុងស្ថានភាព ដែលអនុញ្ញាតិឱ្យមានលំហូរដែលគ្មានព្រំដែននៃមូលធន ទំនិញ និងសេវាកម្ម។ ទីផ្សារកម្ពុជា អាចផ្ដល់ការលើកទឹកចិត្តដើម្បីទាក់ទាញធុរកិច្ច ប៉ុន្តែត្រូវតែបើកចំហរជាសកល និងទីផ្សារដែលសេរី។ រដ្ឋាភិបាល បានកំពុងខិតខំប្រឹងប្រែងដើម្បីបង្កើតទីផ្សារដែលសេរី និងបើកចំហរមួយ។ គោលនយោបាយ ត្រូវការចាំបាច់ត្រូវតែពង្រឹងដើម្បីធ្វើឱ្យបានភាពប្រកួតប្រជែង និងបើកចំហរទីផ្សារជាសកលរបស់ប្រទេស។ វាគឺជាភាពបើកចំហរ និងសេរី ដែលសេដ្ឋកិច្ចរបស់កម្ពុជា អាចត្រូវបានធ្វើសមាហរណកម្មទៅក្នុងសកម្មភាព ធុរកិច្ចសកល។

---

[10] Indicator for labor skill has been surrogated by lower secondary school enrolment ratio. The argument is therefore based on an assumption that improvement of enrolment ratio will directly push up the still level of workers

**ខ. គោលនយោបាយសារពើពន្ធដែលមានការប្រុងប្រយ័ត្ន**

តុល្យភាពគណើយចរន្តនៃកម្ពុជា រាប់បញ្ចូលទាំងជំនួយអភិវឌ្ឍន៍ផ្លូវការ គឺស្ថិតក្នុងឱនភាព។ លើសពីនេះ ការសន្សំគឺមិនគ្រប់គ្រាន់ដើម្បីទ្រទ្រង់ការវិនិយោគឡើយ។ ទោះបី និន្នាការ គឺធម្មតាដូចប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត សេដ្ឋកិច្ចកម្ពុជា គឺគ្មានការគៀបសង្កត់ដោយឱនភាពហិរញ្ញវត្ថុរបស់វា ដែលជាលទ្ធផលនៃប្រសិទ្ធភាពម៉ាក្រូសេដ្ឋកិច្ចនោះទេ។ ផ្អែកលើកិច្ចសំរបសំរួលដោយអង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ ធនធានហិរញ្ញវត្ថុរបស់កម្ពុជាត្រូវបានបែងចែងប្រកបដោយប្រសិទ្ធភាព ក្នុងវិស័យសេដ្ឋកិច្ច និងសង្គម។ ការប្រុងប្រយ័ត្នបន្តក្នុងគោលនយោបាយសារពើពន្ធ គឺជាសារៈសំខាន់សំរាប់កំណើនសេដ្ឋកិច្ចចីរភាពខាងមុខរបស់ប្រទេស។ នេះ គឺជាការពិតយ៉ាងពិសេសព្រោះកង្វះខាតការប្រុងប្រយ័ត្ន នឹងនាំដល់ការទប់លែងជាប់នូវអត្រារូបីយវត្ថុ និងអតិផរណា។ អស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនឹងមិនត្រឹមតែប៉ះពាល់ដល់កំណើនចីរភាពប៉ុណ្ណោះទេ ថែមទាំងនឹងនាំមកនូវការបាត់បង់ទំនុកចិត្តក្នុងការធ្វើធុរកិច្ចផងដែរ។ គោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្ន គឺជាកត្តាគ្រឹះសំរាប់កំណើនចីរភាពនៃសេដ្ឋកិច្ច។

**គ. ពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច** (Diversification of economic structure)

ថ្វីត្បិតតែការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកាច់ចង្កូតដ៏ប៉ិនប្រសព្វចំពោះសេដ្ឋកិច្ចរបស់ប្រទេសក៏ដោយ ប្រទេសនឹងជះឥទ្ធិពលដោយបរិស្ថានសេដ្ឋកិច្ចសកល។ ការប្រែប្រួលបរិស្ថានដែលបានរំពឹងទុក គឺមិនមែនតែអតិផរណា ឬការឡើងចុះនៃរូបិយប័ណ្ណប៉ុណ្ណោះទេ ប៉ុន្តែអាចមានផលប៉ះពាល់នៃចលាចលដែលមិនអាចមើលឃើញជាមុនដូចជាភាពវិកម្មសកល ដែលអាចរារាំងដល់សកម្មភាពវិនិយោគ និងធុរកិច្ចជុំវិញពិភពលោក។ ហានិភ័យ ដូចជាការធ្លាក់ចុះនៃបរិស្ថានទីផ្សារ នឹងប៉ះពាល់សេដ្ឋកិច្ចរបស់ប្រទេស មិនថាវាជាប្រទេសតូចឬធំទេ។ កម្ពុជា គឺជាសេដ្ឋកិច្ចតូច និងផុយស្រួយ ដែលស្ទើរតែងាយទទួលរងនូវផលប៉ះពាល់អវិជ្ជមាននៃឧប្បត្តិហេតុសកល និងតំបន់។ សំរាប់សេដ្ឋកិច្ចកម្ពុជាដើម្បីធានាបាននូវកំណើនចីរភាព វាមានសារសំខាន់ណាស់ដែលសេដ្ឋកិច្ច មានការអត់ធ្មត់ប្រឆាំងនឹងការផ្លាស់ប្តូរបរិស្ថានខាងក្រៅប្រទេស។ ម្យ៉ាងវិញទៀត សេដ្ឋកិច្ចកម្ពុជា ត្រូវបានតំរូវឱ្យធ្វើពិពិធកម្មរចនាសម្ព័ន្ធបច្ចុប្បន្ន ដែលពឹងផ្អែកខ្លាំងលើការនាំចេញសំលៀកបំពាក់ ទៅកាន់សេដ្ឋកិច្ចមួយដែលមានទ្រង់ទ្រាយច្រើនប្រការ ដោយរាប់បញ្ចូលការជំរុញទេសចរណ៍ និងសេវាកម្ម ការធ្វើឱ្យប្រាកដឡើងនូវឧស្សាហកម្មកែច្នៃកសិផល ។ល។ ការធ្វើពិពិធកម្មសកម្មភាពបង្កើតប្រាក់ចំណូលគឺជាបញ្ហារយៈពេលវែង-មធ្យម ដើម្បីដោះស្រាយ សម្រេច ការអភិវឌ្ឍន៍សេដ្ឋកិច្ចចីរភាពរបស់ប្រទេស។

## ២.៤ អនុសាសន៍សំរាប់រដ្ឋាភិបាលកម្ពុជា

តាមរយៈការវិភាគ យើងអាចបញ្ជាក់អះអាងថាគោលនយោបាយរបស់រដ្ឋាភិបាល ដែលកំពុងសង្កាត់ធ្ងន់ទៅលើសេចក្តីត្រូវការ ក្នុងការទាក់ទាញវិនិយោគបរទេសផ្ទាល់ គឺកំពុងដោះស្រាយយ៉ាងត្រឹមត្រូវចំពោះសេចក្តីត្រូវការនៃសេដ្ឋកិច្ចជាតិ។ ពីលទ្ធផលនៃការវិភាគគំរូវិនិយោគបរទេសផ្ទាល់ ត្រូវបានរកឃើញថា កំពុងតែដើរតួនាទីយ៉ាងស្រួចស្រាយសំរាប់កំណើនប្រាកដប្រជានៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ។

ការវិភាគមួយបែបនោះ អាចត្រូវបានលើកយកមកធ្វើបានតែជាមួយនឹងការគាំទ្រពីបណ្តាស្ថាប័នរដ្ឋនានា ដោយផ្តល់ឱ្យ

ក្រុមសិក្សានេះ នូវទិន្នន័យគ្រប់គ្រាន់ និងការពន្យល់ពីសារតារបស់វា។ គេគួរតែកត់សំគាល់ថា មិនមែនគ្រប់ទិន្នន័យសេដ្ឋកិច្ច និងសង្គមទាំងអស់នេះ សុទ្ធតែអាចទទួលបានពីវិជ្ជាស្ថានជាតិស្ថិតិនោះទេ។ ដូច្នេះហើយ វាអាចជាអនុសាសន៍មួយ ដែលថាគ្រប់ស្ថិតិទូលំទូលាយ និងបានធ្វើបច្ចុប្បន្នកម្មហើយ ដែលអាចរកបានជាសាធារណៈ តាមរយៈការបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ Interface សមស្រប រួមទាំងដាក់ក្នុងវេបសៃត៍ ។

ជាងនេះទៅទៀត NSDP ជាផែនការយុទ្ធសាស្ត្រជាតិសំរាប់រយៈពេលមធ្យម គឺមានប្រយោជន៍សំរាប់ការវិភាគដែលជាវិធានការ និងគោលដៅអនុវត្តជាក់ស្តែង ត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងបរិបទនេះ។ ផែនការនេះក៏មានបញ្ចូលការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចជាតួលេខ ហើយវានឹងផ្តល់ផលជាផ្លែផ្កា ដើម្បីបន្តត្រួតពិនិត្យឡើងវិញអោយបានទៀតទាត់ (ជាការល្អគឺរៀងរាល់ឆ្នាំ) ទៅលើស្ថានភាពពិត ដូច្នេះផែនការនេះ អាចត្រូវបានកែតម្រូវនៅលើមូលដ្ឋានដដែល។ បញ្ហានេះនឹងអាចជួយអោយរដ្ឋាភិបាលធ្វើការត្រួតពិនិត្យទៅលើកិរិត ឬការសំរេចបាននៃផែនការរបស់ខ្លួន ហើយពិចារណាអំពីវិធានការអនាគតឱ្យកាន់តែមានលក្ខណៈជាក់ស្តែងជាងនេះ។

# ជំពូកទី ៣

# ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធពាណិជ្ជកម្ម និងឧស្សាហកម្ម និងការកំណត់នូវវិស័យ និងមុខទំនិញដែលមានសក្តានុពលនាំចេញជោគជ័យ

## ៣.១ ទស្សនវិស័យសម្រាប់ម៉ាក្រូសេដ្ឋកិច្ច និង រចនាសម្ព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម

រហូតមកដល់ពេលនេះ យើងបានបង្ហាញថា សូម្បីតែគ្មានការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មយ៉ាងគំហុក បែបនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយនិរន្តរ៍ និងមិនប្រែប្រួល ដោយផ្អែក លើលក្ខខណ្ឌថា លំហូរការវិនិយោគបរទេសដោយផ្ទាល់នឹងនៅតែបន្តកើតមាន ព្រមជាមួយនឹងការកែលំអរជាប្រចាំនូវ កម្រិតជំនាញរបស់កម្មករ។ ផ្អែកលើការទស្សទាយទាំងនោះ វា នឹងមានប្រយោជន៍ផងដែរ ដែលចាំបាច់ត្រូវបញ្ជាក់និង ផ្តោតគោលដៅទៅលើវិស័យឧស្សាហកម្ម និងមុខទំនិញផលិត ដើម្បីសម្រេចអោយបាននូវតំលៃបន្ថែមកាន់តែខ្ពស់ និងពិពិតកម្មរចនាសម្ព័ន្ធឧស្សាហកម្ម។

ដោយគិតពិចារណាអំពីគោលនយោបាយ ភាពអំណោយផលនៃធនធានធម្មជាតិ បរិកាសសេដ្ឋកិច្ច ទីតាំង នៅក្នុងសេដ្ឋកិច្ចពិភពលោក និងទីផ្សារអន្តរជាតិ យើងអាចបញ្ជាក់អំពីវិស័យឧស្សាហកម្ម និងមុខទំនិញកម្មន្តសាល ដែលប្រទេសកម្ពុជាមានអត្ថប្រយោជន៍ប្រៀបធៀប។

## ៣.២ វិស័យឧស្សាហកម្មដែលមានទស្សនវិស័យសំរាប់កំណើននៅពេលអនាគត

### ៣.២.១ វិស័យដែលត្រូវបានកំណត់ជាវិស័យឧស្សាហកម្មយុទ្ធសាស្ត្រ នៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាល

ឯកសារគោលនយោបាយមួយចំនួន ដែលបានចេញដោយរដ្ឋាភិបាល និងអង្គការអន្តរជាតិ បានកំណត់ វិស័យឧស្សាហកម្មមួយចំនួនជាវិស័យយុទ្ធសាស្ត្រ។ នៅក្នុងផ្នែកនេះ យើងពិនិត្យទៅលើរបាយការណ៍បែបនេះចំនួន បីគឺ : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងយុទ្ធសាស្ត្រ ថ្មីសម្រាប់ការនាំចេញរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ។

ទីមួយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ ដូចដែលយើងបានឃើញនៅក្នុងជំពូកទី ២ មកហើយ បានកំណត់ទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ការកែច្នៃផលិតផលកសិឧស្សាហកម្ម អតិពលកម្ម និង វិស័យឧស្សាហកម្មតម្រង់ទិសនាំចេញ ជាវិស័យអាទិភាពសំរាប់ការអភិវឌ្ឍន៍វិស័យឯកជន និងការបង្កើតការងារ។

បន្ទាប់មកទៀត គឺផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៤-២០០៨ ដែលបានចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានចង្អុលបង្ហាញថា ការកែច្នៃផលិតផលកសិឧស្សាហកម្ម (ស្ករ ប្រេងដូង គ្រាប់ស្វាយចន្ទី ផលិតផលក្លួច គ្រាប់ធញ្ញជាតិ និងផ្លែឈើកំប៉ុង) និងឧស្សាហកម្មអតិពលកម្ម (សំលៀកបំពាក់ មួក ស្រោមជើង ស្រោមដៃ

របស់ក្មេងលេង ការតម្លើងគ្រឿងអេឡិកត្រូនិក និងមេកានិក) ចាំបាច់ត្រូវជម្រុញអោយបានសកម្ម ព្រមជាមួយនឹងការអភិវឌ្ឍន៍ធនធានរ៉ែ និងការធ្វើឧបត្ថម្ភធនសំរាប់ការនាំចូល។

លើសពីនេះទៅទៀត មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ដែលជាអង្គការមួយផ្នែកទៅលើសកម្មភាពរបស់អង្គការ UNTAD និង WTO កំពុងរៀបចំយុទ្ធសាស្ត្រថ្មីសម្រាប់ការនាំចេញឆ្នាំ ២០០៦-២០០៨ សម្រាប់រដ្ឋាភិបាលកម្ពុជា។ នៅក្នុងសេចក្តីព្រាងនេះបានកំណត់យក សំលៀកបំពាក់ ផលិតផលកសិឧស្សាហកម្ម ការនេសាទ ទឹកសាប ស្រូវ ផលិតផលធ្វើអំពីសូត្រ និងទេសចរណ៍ ជាវិស័យយុទ្ធសាស្ត្រសម្រាប់ការនាំចេញ។

ជារួម វាច្បាស់ណាស់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ជាពិសេសនូវផលិតផលកសិឧស្សាហកម្ម/ជលផល ដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងអតិពលកម្ម (សំលៀកបំពាក់ សម្ភារៈពាក់នៅជើង និងគ្រឿងយន្តជាដើម ...) ជាឧស្សាហកម្មយុទ្ធសាស្ត្រសម្រាប់នាំចេញរបស់ខ្លួន ដែលគួរទទួលបានអាទិភាពនៅក្នុងការអភិវឌ្ឍន៍។

### ៣-២-២ វិស័យឧស្សាហកម្មដែលមានសក្តានុពល ដោយផ្អែកលើរចនាសម្ព័ន្ធឯកទេសកម្មតាមមុខងារ នៅក្នុងតំបន់អាស៊ីខាងកើត

តំបន់អាស៊ីខាងកើត រួមមានប្រទេសដូចជា ជប៉ុន ចិន កូរ៉េ និងអាស៊ីអគ្នេយ៍ ដែលជាសមាសភាគសំខាន់នៃសេដ្ឋកិច្ច បានបង្ហាញនូវការពង្រឹងចំណងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍បន្ថែមទៀតទៅលើបណ្តាញឯកទេសកម្មតាមមុខងារ [១២] ។ កត្តាដាច់ខាតសំរាប់មុខងារទាំងឡាយនៃសេដ្ឋកិច្ចនីមួយៗ នៅក្នុងបណ្តាញឯកទេសកម្មតាមមុខងារបែបនេះ គឺជាអត្ថប្រយោជន៍ប្រៀបធៀបរបស់សេដ្ឋកិច្ចមួយ នៅក្នុងភាពអនុគ្រោះនៃធនធានរបស់ខ្លួន។ [១៣] អាស្រ័យហេតុនេះ សេដ្ឋកិច្ចមួយដែលមានកំលាំងពលកម្មសំបូរបែប និងក្នុងតំលៃថោក នឹងធ្វើឯកទេសកម្មនៅក្នុងវិស័យអតិពលកម្ម ចំណែកឯសេដ្ឋកិច្ចមួយដែលមានមូលធន និងបច្ចេកវិទ្យាខ្ពស់ នឹងធ្វើឯកទេសកម្មនៅក្នុងវិស័យអតិមូលធន និងជំនាញខ្ពស់។ បន្ទាប់មក ពាណិជ្ជកម្មអន្តរជាតិនឹងដំណើរការដើម្បីបំពេញបន្ថែមទៅដល់តម្រូវការសម្រាប់ផលិតផលរបស់ប្រទេសផ្សេង ជាជាងអ្វីដែលអាចផលិតបានដោយខ្លួនឯង។

ប្រទេសកម្ពុជាបានដំណើរការយឺតក្នុងការចូលទៅក្នុងបណ្តាញសេដ្ឋកិច្ចតំបន់ និងជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចនៅក្នុងតំបន់ អាស្រ័យហេតុនេះ ខ្លួនមានអត្ថប្រយោជន៍ចំពោះកំលាំងពលកម្មដែលមានតំលៃថោក និងមានចំនួនច្រើន ព្រមជាមួយនឹងវាលទំនាបធំធេងដែលអាចប្រើប្រាស់បានសម្រាប់សកម្មភាពឧស្សាហកម្ម។ ការប្រើប្រាស់នូវអត្ថប្រយោជន៍បែបនេះ និងសកម្មក្នុងការជំរុញលំហូរវិនិយោគ និងធុរៈកិច្ចប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការទាក់ទាញឧស្សាហកម្មកាត់ដេរ និងកម្មន្តសាលផ្នែកសម្ភារៈពាក់នៅជើងជាច្រើន។ ធុរៈកិច្ចទាំងនេះមិនទាន់បានក្លាយជាវិស័យគន្លឹះសម្រាប់ការនាំចេញរបស់ប្រទេសឡើយ។ វិស័យ

---

[12] c.f. ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន "ឯកសារសរស្តីពីសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ ២០០៦ ជំពូកទី ២

[13] តំណាងនៃទ្រឹស្តីទាំងឡាយគឺ Heckscher-Ohlim Theorem

អតិពលកម្មទាំងនេះដែលមិនទាមទារជំនាញខ្ពស់ មានលក្ខណៈសមស្របទៅនឹងអត្ថប្រយោជន៍ប្រៀបធៀបរបស់ប្រទេសកម្ពុជា ហើយដែលជាហេតុអាចអោយគេនិយាយបានថា វានៅតែជាឧស្សាហកម្មនាំចេញចំបងរបស់ប្រទេស។

ម្យ៉ាងវិញទៀត បណ្តាញនៃខ្សែរសង្វាក់ផ្គត់ផ្គង់របស់ឧស្សាហកម្មគ្រឿងយន្ត និងអេឡិកត្រូនិក ដែលសហគ្រាសជប៉ុន កូរ៉េ និងចិនមាន ត្រូវបានគេរំពឹងថានឹងអភិវឌ្ឍបន្ថែមទៀត ដើម្បីអនុញ្ញាតអោយមានឯកទេសកម្មតាមមុខងារនៃឧស្សាហកម្មនៅក្នុងតំបន់អាស៊ីខាងកើត។ ទោះឆាប់ឬយូរ ប្រទេសកម្ពុជាទំនងជានឹងត្រូវធ្វើសមា-ហរណកម្មទៅក្នុងបណ្តាញនេះ ដើម្បីបំពេញមុខងារសំខាន់មួយនៅក្នុងបណ្តាញនេះ។ នៅក្នុងករណីនេះ ជាការចាំបាច់ប្រទេសកម្ពុជានឹងចាប់ផ្តើមកាន់កាប់មុខងារមូលដ្ឋានបំផុតនៃបណ្តាញនេះ ដែលជាដំណើរការនៃអតិពលកម្មក្នុងអភិក្រមកម្មន្តសាល ដូចជាការតម្លើងគ្រឿងយន្តអេឡិកត្រូនិក។

### ៣.២.៣ វិស័យឧស្សាហកម្មដែលមានសក្តានុពលដោយផ្អែកលើធនធាន ដែលមាននិងគោលបំណងរបស់ធុរៈកិច្ចដើម្បីប្រើប្រាស់ធនធានទាំងនេះ

ប្រទេសកម្ពុជាសំបូរទៅដោយធនធានរ៉ែ ដូចជា ឥន្ធនៈ (ប្រេង ឧស្ម័ន) លោហៈ (ស្ពាន់ បុកស៊ីត ដែក សារៈធាតុរ៉ែ និងម៉ង់ហ្គាណែស ជាដើម) ថ្មកំបោរ ដីឥដ្ឋ ជាដើម។ គេរំពឹងថានឹងត្រូវអភិវឌ្ឍន៍ធនធានរ៉ែទាំងនេះបន្ថែមទៀតសម្រាប់ផលិតកម្មនៅក្នុងអនាគតដ៏ខ្លីខាងមុខ។ តែទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍រោងចក្រកែច្នៃសម្រាប់ឥន្ធនៈ និងធនធានលោហៈធាតុ ទាមទារអោយមានការវិនិយោគទ្រង់ទ្រាយធំ ហើយការកែច្នៃនេះទៀតសោត នឹងអាចអាចដំណើរការទៅបានតាមបែបពាណិជ្ជកម្ម តែនៅពេលណាដែលមានបរិមាណគ្រប់គ្រាន់សម្រាប់ការផលិតច្រើន។ ផ្អែកលើលក្ខខណ្ឌបែបនេះ ធនធានថាមពលនិងលោហៈធាតុ មិនទំនងជានឹងត្រូវធ្វើការកែច្នៃនៅក្នុងប្រទេសបានឡើយ ហើយទំនងជានឹងត្រូវនាំចេញនូវចំណែកកែច្នៃខ្លះ ឬមិនទាន់កែច្នៃតែម្តង។ ម្យ៉ាងវិញទៀត ធនធានរ៉ែដែលមិនមែនជាលោហៈធាតុ ដូចជា ថ្មកំបោរ ដីឥដ្ឋ និងថ្ម កំពុងត្រូវបានប្រើប្រាស់នៅក្នុងស្រុករួចទៅហើយ ដើម្បីបំពេញតម្រូវការក្នុងការសាងសង់។ អាស្រ័យហេតុនេះ គេអាចនិយាយបានថាធនធានរ៉ែទាំងឡាយ បើទោះបីជាវាមានតំលៃក៏ដោយ ក៏មិនសូវទំនងក្លាយទៅជាធនធានសម្រាប់វិស័យថ្មីផ្នែកកម្មន្តសាលសម្រាប់នាំចេញនោះឡើយ។

អ្វីដែលអាចចាត់ទុកថាជាធនធានសំបូរបែប ដែលអាចប្រើប្រាស់សម្រាប់កម្មន្តសាលសម្រាប់នាំចេញ គឺជាសក្តានុពលសម្រាប់ការកែច្នៃកសិឧស្សាហកម្ម ដែលមានការរួមផ្សំនូវដីធំល្វឹងល្វើយដែលអាចដាំដុះបាន និងកំលាំងពលកម្មច្រើន។ កសិកម្មរបស់ប្រទេសកម្ពុជានៅពេលនេះ មិនទាន់ត្រូវបានអភិវឌ្ឍន៍សម្រាប់ផលិតកម្មក្នុងបរិមាណច្រើន និងថេរនៅឡើយ ហើយមានផលិតភាពទាប។ ប៉ុន្តែ ការនាំយកនូវឧបករណ៍សមស្របមកប្រើប្រាស់និងមានជំនាញ ត្រូវបានគេមើលឃើញថាជាគន្លឹះសម្រាប់ប្រើប្រាស់អោយអស់លទ្ធភាព នូវធនធានដែលមានស្រាប់។ គេអាចនិយាយបានថា ឧស្សាហកម្មកែច្នៃផលិតផលកសិឧស្សាហកម្មរបស់កម្ពុជា មានសក្តានុពលនឹងក្លាយទៅជា

វិស័យឧស្សាហកម្មនាំចេញដ៏ចំបង បន្ទាប់ពីសំលៀកបំពាក់ និងសម្ភារៈពាក់នៅជើង។ លើសពីនេះទៅទៀត អត្ថប្រយោជន៍របស់កម្ពុជាក្នុងការមានធនធានជលផលទឹកសាប ជាពិសេសនៅក្នុងបឹង និងទន្លេ គឺជាធនធានសុំរបែប មួយទៀតសម្រាប់អភិវឌ្ឍ ជលវប្បកម្មក្នុងចំនួនច្រើន និងឧស្សាហកម្មកែឆ្នៃរបស់វា។

នៅក្នុងអំឡុងពេលនៃការសិក្សានេះ យើងបានធ្វើការអង្កេតតាមការបំពេញនៅក្នុងតារាងសំណួរ ជាមួយ ក្រុមហ៊ុនជប៉ុនចំនួន ២០០០ និងធ្វើបទសម្ភាសន៍ផងដែរជាមួយអាជីវកម្មជប៉ុនចំនួនជាង ១០០ ទាំងអាជីវកម្មដែល មានទីតាំងនៅក្នុងស្រុក និងនៅក្រៅប្រទេសផងដែរ (ថៃ ម៉ាឡេស៊ី វៀតណាម និងកម្ពុជា)។ ការអង្កេតទាំងនេះ ត្រូវបានធ្វើឡើងដើម្បីស្វែងយល់ថា តើអាជីវកម្មទាំងនេះមានការចាប់អារម្មណ៍យ៉ាងណាខ្លះចំពោះធនធាននៅកម្ពុជា និងដើម្បីសង្កេតមើលអំពីបំណងរបស់ពួកគេក្នុងការវិនិយោគនៅកម្ពុជា។ ជាលទ្ធផលនៃការអង្កេតនេះ បើទោះបី ជាមិនអាចកំណត់បានថាអាជីវកម្មណាមួយមានបំណងមកវិនិយោគនៅកម្ពុជា នៅក្នុងរយៈពេលខ្លីក៏ដោយ ក៏វាបាន បង្ហាញច្បាស់ថា អាជីវកម្មទាំងឡាយនៅក្នុងវិស័យឧស្សាហកម្ម កំពុងបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំង នៅក្នុងធនធាន និងអត្ថប្រយោជន៍របស់ប្រទេសកម្ពុជា។

គឺនៅក្នុងឧស្សាហកម្មកសិឧស្សាហកម្ម/ការកែឆ្នៃផលិតផលជលផល ដែលអាជីវកម្មទាំងនេះមានចំណាប់ អារម្មណ៍នៅក្នុងការសិក្សាអំពីលទ្ធភាពក្នុងការផលិត និងកែឆ្នៃបន្លែ ផ្លែឈើ និងសាច់ត្រី។ លើសពីនេះទៅទៀត ប្រតិបត្តិការដោយប្រើអតិពលកម្ម ដូចជាការតម្លើងគ្រឿងអេឡិកត្រូនិកយានយន្ត និង ការការតម្លើងសម្ភារៈ ក្មេងលេង និងផ្នែកមេកានិកយានយន្ត ត្រូវបានមើលឃើញថាអាចទទួលបានអត្ថប្រយោជន៍នៅក្នុងរយៈពេលវែង ពីអត្ថប្រយោជន៍របស់ប្រទេសកម្ពុជា ដែលមានកំលាំងពលកម្មក្នុងតំលៃថោក និងចំនួនច្រើន។

បើទោះបីជានៅមានបញ្ហាជាច្រើនដែលត្រូវដោះ ដើម្បីធ្វើអោយប្រសើរឡើងនូវបរិយាកាសវិនិយោគនៅ កម្ពុជាក៏ដោយ ក៏វិស័យទាំងឡាយដែលបានរៀបរាប់ខាងលើ អាចមានលក្ខណៈប្រកួតប្រជែងបាន ប្រសិនជាមាន មូលដ្ឋាននៅកម្ពុជា។ អាស្រ័យហេតុនេះ គេអាចនិយាយបានថា កម្ពុជាមានឱកាសល្អមួយដើម្បីទាក់ទាញការវិនិយោគ បរទេសដោយផ្ទាល់ នៅក្នុងវិស័យឧស្សាហកម្មបែបនេះ។

### ៣.២.៤ ការកំណត់វិស័យឧស្សាហកម្មដែលមានសក្ដានុពលនៅកម្ពុជា

ធ្វើការវិនិច្ឆ័យតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តួនាទីរបស់ខ្លួននៅក្នុងសេដ្ឋកិច្ច-សង្គមអន្តរជាតិ បរិយាកាសសេដ្ឋកិច្ច ភាពសំបូរធនធាន ព្រមទាំងតាមផលប្រយោជន៍ធុរៈជននៅក្នុងធនធានទាំងនោះផងនោះ ឃើញថាវិស័យឧស្សាហកម្ម ៥ អាចត្រូវបានកំណត់ថាមានសក្ដានុពលភាពរីកលូតលាស់នៅពេលអនាគត។ វិស័យ ទាំងនេះគឺ : រួមជាមួយនឹងវិស័យដែលមានស្រាប់ផង ១/សំលៀកបំពាក់ និង ២/វិស័យសម្ភារៈពាក់នៅជើង ៣/ការកែឆ្នៃផលិតផលកសិឧស្សាហកម្ម (និងជលផល) អាចត្រូវបានកំណត់ថាជាបេក្ខជនខ្ពស់បំផុតសំរាប់វិស័យ កម្មន្តសាលថ្មីសំរាប់នាំចេញ ថែមទាំងនៅក្នុងរយៈពេលមធ្យម/វែង ៤/ការតម្លើងគ្រឿងផ្សំអេឡិកត្រូនិក ៥/ការតម្លើងគ្រឿងយន្ត ក៏ទំនងជាដំណើរការបានសំរាប់កម្ពុជា ដើម្បីទទួលយកមកពីសេដ្ឋកិច្ចផ្សេងៗទៀត ដែលដើរ

លឿនជាងកម្ពុជាមួយជំហាន។ អាស្រ័យហេតុនេះ ជាការចាំបាច់ដែលត្រូវធ្វើការកែលំអរបរិកាសវិនិយោគនៅកម្ពុជា និងជំនះអោយបាននូវបញ្ហាដែលមានបច្ចុប្បន្ននេះ។ តាមលក្ខខណ្ឌបែបនេះ ទើបមានឱកាសល្អសំរាប់ការចូលមកនូវវិនិយោគដោយផ្ទាល់ពីបរទេស ដើម្បីបង្កើតអាជីវកម្មបែបនេះអោយដំណើរការជាផ្នែកមួយនៃ សាខាផ្គត់ផ្គង់ការផលិតគ្រឿងយន្ត និងអេឡិកត្រូនិក នៅក្នុងតំបន់អាស៊ីបូព៌ា។

## ៣.៣ មុខទំនិញដែលមានសក្តានុពលនាំចេញ នៅក្នុងវិស័យឧស្សាហកម្មនាពេលអនាគត

នៅក្នុងជំហានបន្ទាប់ យើងនឹងប៉ាន់ស្មានអំពីភាពដែលអាចប្រកួតប្រជែងបានសម្រាប់នាំចេញនាពេលអនាគតនៃមុខទំនិញចំបងៗនៅក្នុងវិស័យសំលៀកបំពាក់ ការកែឆ្នៃផលិតផលកសិឧស្សាហកម្ម សម្ភារៈពាក់នៅជើង ការតម្លើងគ្រឿងផ្សំអេឡិកត្រូនិក និងផលិតផលគ្រឿងយន្ត។

នៅក្នុងវិស័យទាំង ៥ យើងគូសបញ្ជាក់នូវមុខទំនិញណាមួយដូចខាងក្រោម ដែលទំនងជានាំឱ្យមានកំណើនធំ[១៤] ។ មុខទំនិញទាំងនេះក៏ត្រូវបានបញ្ជាក់នៅក្នុងទស្សនវិស័យនាពេលអនាគត និងអនុសាសន៍របស់វិស័យនីមួយៗ ទៅលើកាលៈទេសៈវិនិយោគសម្រាប់ទាក់ទាញកម្មន្តសាលបរទេស មកប្រទេសកម្ពុជា (ជំពូកទី ៥-៨)។ ការវិភាគពីស្ថានភាពទៅលើវិស័យនីមួយៗ នៅក្នុងវិស័យសំលៀកបំពាក់ និងសំភារៈសំរាប់ពាក់នៅជើង ត្រូវបានធ្វើឡើងនៅក្នុងជំពូកនីមួយៗ (ជំពូកទី ៥ និង ៧)។ អាស្រ័យហេតុនេះ យើងនឹងវិភាគទៅលើវិស័យទាំងមូលនៅក្នុងជំពូកនេះ។

**តារាងទី ៣-៣-១ មុខទំនិញដែលមានសក្តានុពលនៅក្នុងវិស័យនាំចេញចំបងៗ**

| វិស័យ | មុខទំនិញ | បរិយាយ |
|---|---|---|
| សំលៀកបំពាក់ | ផលិតផលសំលៀកបំពាក់ (S-284) | សំលៀកបំពាក់ជាទូទៅ។ មុខទំនិញនេះអាចត្រូវបានចាត់ថ្នាក់ជាសំលៀកបំពាក់ក្នុង និងសំលៀកបំពាក់ក្រៅ។ មុខទំនិញនាំ-ចេញចំបងនៅពេលនេះគឺសំលៀកបំពាក់ក្នុង ប៉ុន្តែ យើងសង្ឃឹមថានឹងប្តូរទៅជាសំលៀកបំពាក់ក្រៅក្នុងកំរិតណាមួយ។ |
| ផលិតផលកសិកម្មកែឆ្នៃ | សាច់ត្រីកក (S2-0344) | សាច់ត្រីអណ្តែងកក។ ធនធានត្រីអណ្តែងដ៏សំបូរបែបនៅក្នុងទន្លេមេគង្គ ត្រូវបានគេរំពឹងថានឹងផ្តល់កាលានុវត្តភាពសម្រាប់នាំចេញ។ |
| | ផលិតផលបង្គារ (S2-036) | បង្គារកកដែលការនាំចេញរបស់វាត្រូវបានសំរេចបានមួយផ្នែក |

[14] សំរាប់ការធ្វើចំណាត់ថ្នាក់មុខទំនិញ យើងប្រើប្រាស់ STIC Rev.2 ជាស្ថិតិពាណិជ្ជកម្មនៅវៀតណាម ស្របជាមួយនឹងមូលដ្ឋានទិន្នន័យ STIC. UN Comtrade ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានទិន្នន័យ។

| | | |
|---|---|---|
| | ម្សៅក្តួច និងផលិតផលដែលធ្វើមកពីក្តួច（S2-05645） | បច្ចុប្បន្ននេះ ប្រទេសកម្ពុជានាំចេញក្តួចដែលមិនកែឆ្នៃ។ ការកិនយកម្សៅកំពុងចាប់ផ្តើមបន្តិចម្តងៗនៅប្រទេសកម្ពុជា ហើយគេរំពឹងថា ផលិតផលសំរេចនៃម្សៅក្តួចគឺជាទំនិញនាំចេញដ៏ចំបង។ ការផលិតអេតាណុលជីវសាស្ត្រពីម្សៅក្តួចគឺជាលទ្ធភាពផ្សេងមួយទៀតនៃការនាំចេញដែលមានតំលៃបន្ថែមកាន់តែខ្ពស់។ |
| | ប្រេងដូង（S2-4242） | គេរំពឹងថាការនាំចេញពីចំការដូងប្រេង ទៅប្រទេសម៉ាឡេស៊ី នឹងត្រូវពង្រីក។ |
| សម្ភារៈពាក់នៅជើង | ផលិតផលជាសម្ភារៈពាក់នៅជើង（S2-85） | សម្ភារៈពាក់នៅជើងទូទៅ។ មុខទំនិញនេះអាចធ្វើចំណាត់ថ្នាក់ជាស្បែក កៅស៊ូ និងសំភារៈពាក់នៅជើងផ្នែកអត្តពលកម្ម។ |
| សមាសភាគសំរាប់តម្លើងគ្រឿងអេឡិកត្រូនិក | ឧបករណ៍ និងគ្រឿងបន្លាស់អេឡិកទ្រិកយានយន្ត（S2-7783） | មិនទាន់ផលិតនៅប្រទេសកម្ពុជានៅឡើយ។ ផលិតផលដូចជាអង់តែនរថយន្តត្រូវបានរំពឹងថាជាមុខទំនិញនាំចេញ។ |
| សមាសភាគសម្រាប់តម្លើងគ្រឿងយន្ត | គ្រឿងបន្លាស់ផ្សេងទៀត និងគ្រឿងតុបតែងយានយន្ត | |

**កំណត់សំគាល់ ៖** មុខទំនិញនីមួយៗត្រូវបានបញ្ជាក់នៅក្នុងទស្សនវិស័យនាពេលអនាគត និងអនុសាសន៍ទាំងឡាយរបស់វិស័យសនីមួយៗ ទៅលើកាលៈទេសៈវិនិយោគសំរាប់ទាក់ទាញកម្មន្តសាលបរទេសមកកម្ពុជា（ជំពូកទី ៥-៨）។
**ប្រភព ៖** ក្រុមសិក្សារបស់ JICA។

## ៣.៤ កំណត់មុខទំនិញចំបងៗដែលមានសក្តានុពលនាំចេញជាមួយការផ្លាស់ប្តូរចនាសម្ព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម

### ៣.៤.១ គោលការណ៍មូលដ្ឋានសំរាប់វិភាគ

ក្នុងនាមជាមុខទំនិញគន្លឹះសំរាប់នាំចេញនាពេលអនាគតរបស់ប្រទេសកម្ពុជា មុខទំនិញនីមួយៗនៅក្នុងវិស័យចំបងៗទាំង ៤ រួមមាន ៖ សំលៀកបំពាក់ ផលិតផលកសិកម្ម សំភារៈពាក់នៅជើង គ្រឿងផ្សំអេឡិកត្រូនិកសំរាប់តម្លើង និងផលិតផលគ្រឿងយន្ត ត្រូវបានបញ្ជាក់ដូចខាងក្រោមនេះ។ តំលៃនាំចេញនាពេលអនាគត និងអត្ថប្រយោជន៍ប្រៀបធៀបរបស់កម្ពុជា នឹងត្រូវធ្វើការប៉ាន់ស្មាន។

សមាមាត្រនៃតំលៃនាំចេញរបស់មុខទំនិញគោលដៅ ចំពោះការនាំចេញសរុប ត្រូវបានប្រើប្រាស់ជាអថេរគំរូ។ សំរាប់គោលបំណងនេះ ទីមួយ យើងធ្វើការវិភាគទៅលើកត្តានៃការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ឧស្សាហកម្ម និងពាណិជ្ជកម្មនៅប្រទេសវៀតណាម ដែលជាប្រទេសស្ថិតនៅលើគន្លងដូចគ្នានៃដំណាក់កាលអភិវឌ្ឍន៍ដូចកម្ពុជាដែរនោះ ក៏មានសមាសភាគនៃផលិតផលនាំចេញដូចគ្នាដែរ (សំលៀកបំពាក់ ប្រេង កាហ្វេ សណ្តែកខៀវ និងផលិតផលកសិកម្ម ដូចជាស្រូវជាដើម) និងមានគំរូដូចគ្នាផ្នែកធនធានធម្មជាតិ និងធនធានធម្មជាតិ។ បន្ទាប់មកយើងប្រើប្រាស់លទ្ធផលនៃការវិភាគកត្តានេះ ទៅនឹងករណីកម្ពុជា។ សមីការមួយដែលប្រើប្រាស់អថេរបីគឺ : (១) ទីផ្សារពិភពលោក (២) ការកែលំអរជំនាញ និង (៣) កំណើនមូលធនត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ស្មានអំពីការផ្លាស់ប្តូរនៅក្នុងសមាមាត្រនៃតំលៃនាំចេញរបស់មុខទំនិញជាក់លាក់ ចំពោះការនាំចេញសរុប។ ការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្មនៅប្រទេសកម្ពុជារហូតដល់ឆ្នាំ ២០០២ ត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់សមីការចំពោះប្រទេសកម្ពុជា ដោយផ្អែកលើក្តីសង្ឃឹមថា ប្រទេសកម្ពុជានឹងមានការផ្លាស់ប្តូររចនាសម្ព័ន្ធពាណិជ្ជកម្មដូចគ្នានេះដែរ ជាមួយនឹងការកើនឡើងនូវមូលធន។

## ៣.៤.២ វិធីសាស្រ្ត និង បុរេលក្ខខណ្ឌ

ការបង្កើតនូវមុខងារគំរូដោយអថេរនៃនិន្នាការទីផ្សារ ការអភិវឌ្ឍន៍ជំនាញ និងការកើនឡើងនូវសន្និធិមូលធន ដែលជាការវិភាគទៅលើនិន្នាការនៃសមាមាត្រមុខទំនិញនីមួយៗ យើងប៉ាន់ស្មានទៅលើកត្តាដូចខាងក្រោម :

(*i*) និន្នាការនៃតំលៃពាណិជ្ជកម្មពិភពលោក

(*ii*) ការអភិវឌ្ឍន៍ជំនាញនៅប្រទេសវៀតណាម

(*iii*) ការកើនឡើងនូវអត្រានៃឧបករណ៍មូលធន

ដើម្បីប្រើប្រាស់សមីកានេះចំពោះប្រទេសកម្ពុជា យើងកែតម្រូវពាក្យដែលមិនប្រែប្រួល។ ជាមួយនឹងសមីកាដែលអាចអនុវត្តបានចំពោះប្រទេសកម្ពុជា យើងប៉ាន់ស្មានអំពីតំលៃនាពេលអនាគតរបស់មុខទំនិញនីមួយៗ ចំពោះការនាំចេញសរុប។

ការប៉ាន់ស្មាន:

(*i*) ការអភិវឌ្ឍន៍ជំនាញនៅប្រទេសកម្ពុជា : អត្រានៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា

(*ii*) កំណើនសន្និធិមូលធននៅប្រទេសកម្ពុជា : តំលៃដែលបានមកពីគំរូម៉ាក្រូ

## ៣.៥ ការនាំចេញនាំទំនិញនីមួយៗក្នុងអតីតកាលរបស់ប្រទេសវៀតណាម

បើទោះបីជាប្រទេសវៀតណាមស្ថិតនៅជិតប្រទេសកម្ពុជា និងសំរេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រហាក់ប្រហែលគ្នាក៏ដោយ ក៏ប្រទេសនេះមានបរិយាកាសសេដ្ឋកិច្ច និងសង្គមខុសគ្នាដែរ។ ដូច្នេះ ប្រទេសវៀតណាមមិនអាច

ជាអនាគតសម្រាប់ប្រទេសកម្ពុជាបានឡើយ ។ ទីមួយ យើងបានធ្វើការវិភាគមូលដ្ឋានទៅលើនិន្នាការនាំចេញរបស់មុខទំនិញទីមួយៗនៅវៀតណាម ហើយទីពីរ យើងពិចារណាប្រើប្រាស់វាចំពោះប្រទេសកម្ពុជា និងដែនកំណត់របស់ខ្លួន ។

សំលៀកបំពាក់ និងសម្ភារៈពាក់នៅជើងគឺជានាំទំនិញនាំចេញចំបងរបស់ប្រទេសវៀតណាម ដែលរួមមានជាង ១០% នៃការនាំចេញសរុប ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ តំលៃនាំចេញរបស់មុខទំនិញទីមួយៗបានកើនឡើង ហើយសារៈសំខាន់របស់វាសម្រាប់ជាផលិតផលនាំចេញបានកើនឡើង ។ នៅប្រទេសវៀតណាម កម្មន្តសាលផលិតទំនិញច្រើនដោយប្រើប្រាស់អតិពលកម្ម នៅតែបន្តជាឧស្សាហកម្មដែលគួរអោយសង្ឃឹមបាននាពេលអនាគត ។

បច្ចុប្បន្ននេះ សាច់ត្រីកកគឺគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃការនាំចេញសរុប ប៉ុន្តែហាក់ដូចជាកំពុងកើនឡើង និងមានសក្តានុពលក្លាយជាមុខទំនិញចំបងសម្រាប់នាំចេញ ។

ការនាំចេញបង្គារគឺជាមុខទំនិញមួយយ៉ាងសំខាន់ ដែលស្មើនឹង ១០% នៃការនាំចេញសរុប ។ ប៉ុន្តែ សមាមាត្ររបស់វានៅតែមានកំរិតមិនប្រែប្រួលអស់រយៈជាច្រើនឆ្នាំមកហើយ ។

ការនាំចេញប្រេងដូង និងផលិតផលក្លូចនៅមានសមាមាត្រតិចតួច នៅក្នុងការនាំចេញរបស់វៀតណាម ហើយបរិមាណលក់ដូរនៅមានកំរិតតិចយ៉ាងខ្លាំង ។ ដោយគិតពិចារណាពីភាពខុសគ្នារវាងរចនាសម្ព័ន្ធធនធានធម្មជាតិរបស់វៀតណាម និងកម្ពុជា ប្រទេសកម្ពុជាក៏អាចមានសក្តានុពលជាងវៀតណាមផងដែរ លើផ្នែកផលិតផល ។

មានការនាំចេញតិចតួចបំផុតផ្នែកឧបករណ៍ និងសមាសភាគអេឡិកត្រូនិកយានយន្ត នៅវៀតណាម ។ ក្រុមហ៊ុនផលិតរថយន្តនៅវៀតណានាំចូលសមាសភាគរថយន្តទាំងអស់ពីបរទេស ហើយនៅមិនទាន់មានការផ្ទេរបច្ចេកវិទ្យានៅឡើយ ។ អាស្រ័យហេតុនេះ វាស្ទើរតែគ្មានឧស្សាហកម្មផលិតគ្រឿងបន្លាស់រថយន្តនៅក្នុងស្រុកឡើយនៅប្រទេសវៀតណាម ។ វាអាចចំណាយពេលវេលាយូរដើម្បីបង្កើតឧស្សាហកម្មគ្រឿងម៉ាស៊ីននៅវៀតណាម និងប្រទេសកម្ពុជា ។

ជាចុងក្រោយ ពាក់ព័ន្ធនឹងគ្រឿងបន្លាស់ និងសំភារៈរថយន្តបន្ទាប់បន្សំ រហូតមកដល់ពេលនេះនៅមានការនាំចេញតិចតួចនៅឡើយ ប៉ុន្តែ វាហាក់ដូចជាមានអត្រាកំណើនខ្ពស់ ។

**តារាងទី ៣-៥-១ ភាគរយនៃតំលៃនាំចេញរបស់មុខទំនិញទីមួយៗ ចំពោះតំលៃនាំចេញសរុប នៅវៀតណាម**

| ឆ្នាំ | សំលៀកបំពាក់ (S2-84) | សាច់ត្រីកក (S2-0344) | បង្គារ (S2-036) | ម្សៅក្លូចនិងផលិតផលដែលធ្វើមកពីក្លូចផ្សេងទៀត (S2-05645) | ប្រេងដូង (S2-4242) | សំភារៈពាក់នៅជើង (S2-85) | ផ្នែក និង ឧបករណ៍អេឡិកទ្រិករថយន្ត (S2-7783) | ផ្នែកផ្សេងៗទៀតនិងគ្រឿងតុបតែងរថយន្ត (S2-7849) |
|---|---|---|---|---|---|---|---|---|
| ២000 | ១២.៦៥% | 0.0៣% | ៨.៥២% | 0.00% | 0.២៤% | ១0.0៤% | 0.0៣% | 0.0១% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២០០១ | ១២.៤៤% | 0.១១% | ៩.៣៦% | 0.0២% | 0.១៥% | ១0.៥៦% | 0.0៣% | 0.0៣% |
| ២០០២ | ១៥.៨២% | 0.១៧% | ៩.0២% | 0.0២% | 0.0៣% | ១១.២២% | 0.0២% | 0.0៩% |
| ២០០៣ | ១៧.២៩% | 0.៣៧% | ៨.១៦% | 0.0៣% | 0.0៧% | ១១.២២% | 0.0២% | 0.១0% |

*ប្រភព : ក្រុមសិក្សារបស់ JICA*

## ៣.៦ តំលៃនាពេលអនាគតនៃមុខទំនិញដែលមានសក្តានុពលនៅកម្ពុជា

យើងប្រើប្រាស់សមីកាទាំងឡាយ ដែលត្រូវបានប៉ាន់ស្មានដោយអថេរជាច្រើន ដូចជានីន្នាការទីផ្សារអន្តរជាតិ ការអភិវឌ្ឍន៍ជំនាញ និងកំណើនមូលធន នៅវៀតណាម [១៥] ដើម្បីប្រមើលមើលទុកជាមុននូវតំលៃនៃការនាំចេញនាពេលអនាគតរបស់មុខទំនិញទាំងឡាយនៅប្រទេសកម្ពុជា។[១៦]

**តារាងទី ៣-៦-១ : ការទស្សន៍ទាយអំពីភាគរយនៃផលិតផល នៅក្នុងតំលៃនៃការនាំចេញសរុបរបស់កម្ពុជា**

| ឆ្នាំ | សំលៀកបំពាក់ (S2-84) | សាច់ត្រីកក (S2-0344) | បង្គារ (S2-036) | ម្សៅក្លួចនិងផលិតផលដែលធ្វើមកពីក្លួចផ្សេងទៀត (S2-05645) | ប្រេងដូង (S2-4242) | សំភារះពាក់នៅជើង (S2-85) | ផ្នែក និង ឧបករណ៍អេឡិកទ្រិករថយន្ត (S2-7783) | ផ្នែកផ្សេងៗទៀតនិងគ្រឿងតុបតែងរថយន្ត (S2-7849) |
|---|---|---|---|---|---|---|---|---|
| ២០០០ | ៦៩.៨១% | 0.២៣% | 0.១៧% | 0.0១% | 0.00% | ២.0៦% | 0.00% | 0.00% |
| ២០០៥ | ៧0.៧៩% | 0.0៩% | 0.៣៩% | 0.00% | 0.0៣% | ១.៤៥% | 0.00% | 0.0១% |
| ២០១០ | ៥១.៥៥% | 0.២៧% | 0.៤៦% | 0.0១% | 0.0១% | ៣.៩0% | 0.00% | 0.0៩% |
| ២០១៥ | ៥៦.៥៧% | 0.៦១% | 0.៦១% | 0.0២% | 0.0៣% | ៥.0៥% | 0.00% | 0.១៩% |
| ២០២០ | ៦៥.៨៧% | 0.៨៦% | 0.៨២% | 0.0៣% | 0.0៥% | ៦.0៤% | 0.00% | 0.២៦% |

*ប្រភព : ក្រុមសិក្សារបស់ JICA*

ជាលទ្ធផល ការនាំចេញសំលៀកបំពាក់ត្រូវបានចាត់ទុកថា បានស្រូបយកតំលៃនៃការនាំចេញសរុបជាង ៥0% សំរាប់បណ្តាឆ្នាំខាងមុខ។ យើងសង្ឃឹមថា សមាមាត្រនេះនឹងថយចុះនៅឆ្នាំ ២០១០ ប៉ុន្តែ អាចនឹងកើនឡើងបន្ទាប់ពីនេះ។

ការនាំចេញនូវផលិតផលសមុទ្រដែលបានកែឆ្នៃដូចជា សាច់ត្រី និងបង្គារកក ដែលបានចាប់ផ្តើមរួចមកហើយនោះ នឹងកើនឡើង ហើយសមាមាត្ររបស់វាចំពោះតំលៃនាំចេញសរុបនឹងកើនឡើង។ ដោយមើលឃើញថា តំលៃនៃការនាំចេញរបស់ផលិតផលនីមួយៗ មានចំនួនតែ ១% ប៉ុណ្ណោះនៃតំលៃនាំចេញសរុបនោះ វានៅតែមាន

---

[15] លទ្ធផលនៃការប៉ាន់ស្មានមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ 1A.1.3

[16] លទ្ធផលនៃការទស្សន៍ទាយមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ 1 A.1.4

ភាពមិនប្រាកដប្រជាខ្លះថា តើមុខទំនិញទាំងឡាយនឹងកើនឡើងទៅជាមុខទំនិញចំបង១សំរាប់នាំចេញដែរឬអត់។ ប៉ុន្តែ គេអាចនិយាយបានថា ផលិតផលជលផលបែបនេះមានសក្តានុពលយ៉ាងធំធេងសំរាប់កំណើន។

យើងទស្សន៍ទាយថា តំលៃនៃការនាំចេញប្រេងដូង និង ម្សៅក្តួច/ផលិតផលដែលធ្វើមកពីក្តួច នឹងកើនឡើង បន្តិចម្តង១។ ផ្អែកទៅលើបទសម្ភាសន៍ជាមួយផលិតករ គេអាចនិយាយបានថា បរិមាណនៃការនាំចេញពឹងផ្អែកយ៉ាង ខ្លាំងទៅលើកំរិតនៃបច្ចេកវិទ្យាកែច្នៃដែលបាននាំយកមកប្រើនៅកម្ពុជា។ ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ កម្ពុជាអាចមានអត្ថប្រយោជន៍សំរាប់ផលិតកម្មកែច្នៃផលិតផលកសិឧស្សាហកម្ម។

សារៈសំខាន់នៃការនាំចេញសម្ភារៈពាក់នៅជើង ទំនងជានឹងកើនឡើង ហើយការរួមចំណែករបស់វាចំពោះ ការនាំចេញសរុបនឹងឈានដល់ ៤% នៅឆ្នាំ ២០១០ និង ៦% នៅឆ្នាំ ២០២០។ ការកើនឡើងនូវសមាមាត្រនៃការ នាំចេញសម្ភារៈពាក់នៅជើង នឹងបំពេញបាននូវគម្លាតនៃការថយចុះនៃសមាមាត្រនាំចេញសំលៀកបំពាក់។

ពាក់ព័ន្ធនឹងការការតម្លើងគ្រឿងអេឡិកត្រូនិក តំលៃនៃការនាំចេញរបស់វាទៅអនាគត នឹងមានកំរិតស្ទួច ស្ទើងយ៉ាងខ្លាំង។ ដូចករណីជាច្រើននៅប្រទេសថៃ និងវៀតណាម ហេតុផលគឺថាវាត្រូវចំណាយពេលយូរដើម្បីបង្កើត នូវឧស្សាហកម្មទ្រទ្រង់មួយនៅកម្ពុជា។ តែទោះជាយ៉ាងនេះក៏ដោយ ការផលិតនូវផលិតផលដោយប្រើអតិពលកម្ម ដូចជា លួសរង្វេល ដែកលួស និងស្រោមលួស នឹងមានសក្តានុពល។

ម្យ៉ាងវិញទៀត វានឹងចំណាយពេលវេលាតិចដើម្បីចាប់ផ្តើមផលិតកម្មសមាសភាគមេកានិកដែលមិនមែនជា អេឡិកត្រូនិក (ដូចជាអង់តែន) បើប្រៀបធៀបជាមួយសមាសភាគអេឡិកត្រូនិក។

ជាសន្និដ្ឋាន នៅប្រទេសកម្ពុជា វិស័យសំលៀកបំពាក់ សំភារៈពាក់នៅជើង និងផលិតផលកសិកម្ម ដែលបានកែច្នៃ ទំនងជានឹងកើនឡើងនៅពេលអនាគត។ លើសពីនេះទៅទៀត នៅក្នុងរយៈពេលវែង ឧស្សាហកម្ម ផលិតគ្រឿងយន្ត និងសមាសភាគអេឡិកត្រូនិក នឹងអាចបង្កើតបាន និងរីកលូតលាស់ប្រសិនបើបរិយាកាសវិនិយោគ មានភាពប្រសើរឡើង ដោយទាញយកប្រយោជន៍ពីអត្ថប្រយោជន៍ប្រៀបរបស់កម្ពុជា នៅក្នុងឧស្សាហកម្មដែលប្រើ អតិពលកម្ម។

## ៣.៧ ការវិភាគបង្ហាញអំពីឧត្តមភាពប្រៀបធៀប (RCA) សំរាប់មុខទំនិញគន្លឹះនៅកម្ពុជា ដែលមានសក្តានុពល នាំចេញ

នៅចំណុចនេះ យើងធ្វើការវិភាគអំពីអត្ថប្រយោជន៍ប្រៀបធៀបសម្រាប់ផលិតផលគន្លឹះសម្រាប់នាំចេញ ដោយប្រើការវិភាគបង្ហាញអំពីអត្ថប្រយោជន៍ប្រៀបធៀប។ **RCA** ត្រូវបានប្រើប្រាស់ដើម្បីកំណត់មុខទំនិញដែលមាន អត្ថប្រយោជន៍ប្រៀបធៀប នៅក្នុងប្រទេសមួយចំនួន។ នៅក្នុងការវិភាគនេះ សន្ទស្សន៍ **RCA** ត្រូវបានគណនា ហើយ នៅពេលដែលសន្ទស្សន៍ខ្ពស់ វាបង្ហាញថាប្រទេសនោះមានអត្ថប្រយោជន៍ប្រៀបធៀបក្នុងការនាំចេញផលិតផល។

សន្ទស្សន៍ **RCA** សំរាប់មុខទំនិញ **X** របស់ប្រទេស **"ក"** = (តំលៃនាំចេញរបស់មុខទំនិញ **X** របស់ប្រទេស **"ក"** /តំលៃនាំចេញសរុបរបស់ប្រទេស **"ក"**) / (តំលៃនាំចេញរបស់មុខទំនិញ X នៅក្នុងពិភពលោក / តំលៃនាំចេញសរុបនៅក្នុងពិភពលោក)

សន្ទស្សន៍ **RCA** សំរាប់មុខទំនិញគន្លឹះដែលមានសក្តានុពលនាំចេញ ត្រូវបានគណនាដូចខាងក្រោមនេះ :[១៧]

**តារាង ៣-៧-១ សន្ទស្សន៍ RCA សំរាប់មុខទំនិញដែលមានសក្តានុពលរបស់កម្ពុជា**

| **ឆ្នាំ** | **សំលៀកបំពាក់** (S2-84) | **សាច់ត្រីកក** (S2-0344) | **បង្គារ** (S2-036) | **ម្សៅក្តួចនិងផលិតផលដែលធ្វើមកពីក្តួចផ្សេងទៀត** (S2-05645) | **ប្រេងដូង** (S2-4242) | **សំភារៈពាក់នៅជើង** (S2-85) | **ផ្នែក និង ឧបករណ៍អេឡិកត្រូនិករថយន្ត** (S2-7783) | **ផ្នែកផ្សេងៗទៀតនិងគ្រឿងតុបតែងរថយន្ត** (S2-7849) |
|---|---|---|---|---|---|---|---|---|
| ២00៥ | ៣៤.១៣៦ | ១.៤៣៤ | ២.៦៨៤ | ៥.៩៨0 | 0.១0៣ | ២.៣៦៩ | 0.00១ | 0.00៣ |
| ២0១0 | ២៤.៩0៩ | ៣.៧៣៤ | ២.៦៦៧ | ១៦.0១៨ | 0.0៣៥ | ៦.៣៦៨ | 0.00២ | 0.0៣៨ |
| ២0១៥ | ២៦.៦៧៦ | ៧.៩៦៧ | ៣.២៩៤ | ៣២.៦0៥ | 0.0៧៤ | ៨.0៤៤ | 0.00៣ | 0.0៦៦ |
| ២0២0 | ៣១.៨២៩ | ១១.៩៧៣ | ៤.៥១៨ | ៥៣.២៤៣ | 0.១៤៥ | ៩.៨៥៨ | 0.00៥ | 0.១0៨ |

*ប្រភព : ក្រុមសិក្សារបស់ JICA*

វិនិច្ឆ័យតាមលទ្ធផលនៃការទស្សន៍ទាយ កម្ពុជានឹងបាត់បង់បន្តិចបន្តួចនូវអត្ថប្រយោជន៍ប្រៀបធៀបរបស់ខ្លួននៅក្នុងផលិតផលសំលៀកបំពាក់ នៅអំឡុងឆ្នាំ ២0១0។ សន្ទស្សន៍ **RCA** នាពេលអនាគតសំរាប់ផលិតផលសំលៀកបំពាក់ មានកំរិតទាបជាងបច្ចុប្បន្ន។ នេះគឺជាការឆ្លុះបញ្ចាំងអំពីកំណើននៃបរិមាណនាំចេញ និងភាពប្រកួតប្រជែងនៃមុខទំនិញនាំចេញផ្សេងៗទៀត (សម្ភារៈពាក់នៅជើង និង ផលិតផលកសិកម្មដែលបានកែឆ្នៃ)។

អត្ថប្រយោជន៍ប្រៀបធៀបសម្រាប់ម្សៅក្តួច សាច់បង្គារ និងសាច់ត្រីកក ត្រូវបានបង្ហាញដោយការប៉ាន់ស្មានថាពួកវានឹងកើនឡើង។ នៅពេលដែលការកែឆ្នៃម្សៅក្តួចដែលមានតំលៃបន្ថែម (ដូចជាការទាញយកម្សៅ និងការផលិតអេតាណុលជីវសាស្ត្រ) ត្រូវបានធ្វើឡើង គេរំពឹងថាអត្ថប្រយោជន៍ប្រៀបធៀបនឹងកើនឡើងបន្ថែមទៀត។ ម្យ៉ាងវិញទៀត យើងបានរកឃើញថាប្រទេសកម្ពុជាមានអត្ថប្រយោជន៍ប្រៀបធៀបទាបជាងគេលើផ្នែកប្រេងដូង។ ដោយគេសង្ឃឹមថាទីផ្សារប្រេងចំរាញ់នឹងកើនឡើងយ៉ាងលឿន ដោយសារមានការកើនឡើងនូវតម្រូវការចំពោះ

[17] 1 តំលៃទស្សន៍ទាយប្រចាំឆ្នាំរបស់ RCA មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ A.1.5

ផលិតផលប្រេងម៉ាហ្សុតជីវសាស្ត្រនោះ អាចថានៅពេលអនាគត ប្រទេសកម្ពុជានឹងមានអត្ថប្រយោជន៍ប្រៀបធៀបផ្នែកប្រេងដូង។

អត្ថប្រយោជន៍ប្រៀបធៀបរបស់ប្រទេសកម្ពុជា ក្នុងផ្នែកសម្ភារៈពាក់នៅជើង នឹងកាន់តែរឹងមាំនៅពេលអនាគត។ គេរំពឹងថា កំណើននៃភាពប្រកួតប្រជែងនឹងមានទំហំធំធេង ហើយទំនងជានឹងកើនឡើងជាប្រចាំ។

អត្ថប្រយោជន៍ប្រៀបធៀបរបស់កម្ពុជា ក្នុងសមាសភាគសម្រាប់តម្លើងអេឡិកត្រូនិកមានកំរិតទាប ហើយនឹងមិនផ្លាស់ប្តូរឡើយនៅក្នុងអនាគតដែលអាចប្រម៉ើលមើលបាន។ បរិមាណនាំចេញនៃសមាសភាគសំរាប់តម្លើងគ្រឿងអេឡិកត្រូនិក មិនទំនងជាកើនឡើងឡើយ ហើយអត្ថប្រយោជន៍ប្រៀបធៀបនៅក្នុងផលិតផលសំលៀកបំពាក់ សម្ភារៈពាក់នៅជើង និងផលិតផលកសិកម្មកែច្នៃ នឹងមិនមានការផ្លាស់ប្តូរឡើយនៅពេលនេះ។ ប៉ុន្តែនៅក្នុងមុខទំនិញជាក់លាក់ដែលប្រើអតិពលកម្មវិញ កម្ពុជាអាចមានអត្ថប្រយោជន៍ប្រៀបធៀប។

នៅក្នុងសមាសភាគសំរាប់តម្លើងគ្រឿងយន្ត ប្រទេសកម្ពុជាមានអត្ថប្រយោជន៍ប្រៀបធៀបខ្ពស់ជាងសមាសភាគអេឡិកត្រូនិក។ បើទោះបីជាអត្ថប្រយោជន៍របស់វាទំនងជានឹងកើនឡើងបន្តិចបន្តួចនៅពេលខាងមុខក៏ដោយ សន្ទស្សន៍ **RCA** នឹងនៅតែមានកំរិតទាបនៅឆ្នាំ ២០២០។ គេអាចនិយាយបានថា ត្រូវចំណាយពេលវេលាយូរដើម្បីពូនជ្រោយឧស្សាហកម្មគ្រឿងយន្តនៅកម្ពុជា។

### រូបភាព ៣-៧-១ សន្ទស្សន៍ RCA នៃផលិតផលគន្លឹះរបស់កម្ពុជាដែលមានសក្តានុពលនាំចេញ




***ប្រភព: ក្រុមសិក្សារបស់ JICA***

**៣.៨ <u>សន្និដ្ឋាន</u> : កម្ពុជានឹងរក្សាបាននូវអត្ថប្រយោជន៍ប្រៀបធៀប នៅក្នុងផលិតផលសំលៀកបំពាក់ ហើយផលិតផលសំម្ភារះពាក់នៅជើង និងផលិតផលកសិកម្មកែឆ្នៃរបស់កម្ពុជា នឹងរីកលូតលាស់**

យើងបានវិភាគអំពីទស្សនវិស័យនាពេលអនាគត ទៅលើសមាមាត្រនៃមុខទំនិញគន្លឹះសំរាប់នាំចេញចំពោះការនាំចេញសរុប និង អត្ថប្រយោជន៍ប្រៀបធៀបនៅក្នុងការប្រកួតប្រជែងអន្តរជាតិ។ ផលិតផលសំលៀកបំពាក់នឹងដើរតួនាទីសំខាន់ជាមុខទំនិញចំបងសម្រាប់នាំចេញ។ ទន្ទឹមនឹងនេះ យើងក៏បានរកឃើញផងដែរថា ផលិតផលសម្ភារះពាក់នៅជើង និង ផលិតផលកសិកម្មកែឆ្នៃ (ជាពិសេសផលិតផលក្តួច/ម្សៅក្តួច និងផលិតផលទឹកសមុទ្រ) មានសក្តានុពលជាមុខទំនិញនាំចេញចំបង បន្ទាប់ពីសំលៀកបំពាក់ និងសម្ភារះពាក់នៅជើង។

ក្នុងចំណោមផលិតផលកសិកម្មកែឆ្នៃ យើងសង្ឃឹមថាប្រទេសកម្ពុជានឹងមានអត្ថប្រយោជន៍ប្រៀបធៀបខ្ពស់ក្នុងផលិតផលក្តួច/ម្សៅក្តួច។ ដោយហេតុថាបរិមាណនៃការនាំចេញសាច់ត្រីកក និងបង្គារទំនងជានឹងកើនឡើងនោះអត្ថប្រយោជន៍ប្រៀបធៀបរបស់វាក៏នឹងកើនឡើងផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ វានឹងចំណាយពេលវេលាយូរដើម្បីអោយប្រទេសកម្ពុជាមានកំលាំង នៅក្នុងសមាសភាគសំរាប់តម្លើងអេឡិកត្រូនិក និងសមាសភាគសំរាប់តម្លើងគ្រឿងយន្ត។ យើងរកឃើញថា ការនាំចេញសមាសភាគគ្រឿងយន្តនឹងពង្រីកលឿនជាងសមាសភាគសំរាប់គ្រឿងតម្លើងអេឡិកត្រូនិក។

# ជំពូកទី ៤

# ទស្សនវិស័យសម្រាប់គោលនយោបាយឧស្សាហកម្មនៅកម្ពុជា

## ៤.១ លក្ខខណ្ឌទូទៅ

ជាទូទៅ ពាក្យ "គោលនយោបាយឧស្សាហកម្ម" គឺជាពាក្យរួមសម្រាប់គោលនយោបាយទាំងឡាយ ដែលរដ្ឋាភិបាលធ្វើអន្តរាគមន៍នៅក្នុងសកម្មភាពសាជីវកម្ម ដើម្បីជួយទ្រទ្រង់ និងអភិវឌ្ឍឧស្សាហកម្ម។ ជាក់លាក់ជាងនេះទៅទៀតនោះ គឺរួមមានយុទ្ធសាស្ត្រនៅក្នុងវិស័យ ៤ ដូចតទៅនេះ : (១) រចនាសម្ព័ន្ធឧស្សាហកម្ម (២) ការគាំទ្រដល់ការអភិវឌ្ឍន៍បច្ចេកវិទ្យា (៣) អន្តរាគមន៍នៅក្នុងការរៀបចំឧស្សាហកម្មរបស់បុគ្គល និង (៤) ការបំពេញនូវគម្លាតអន្តរតំបន់ និងការប្រើប្រាស់កំណើនរបស់ឧស្សាហកម្មធុនតូចនិងមធ្យម (SMEs)។ យុទ្ធសាស្ត្រមានន័យរួមបញ្ចូលនូវប្រភេទផ្សេងៗនៃការលើកទឹកចិត្ត តាមរយៈការអនុម័តច្បាប់ពិសេស គោលការណ៍ណែនាំផ្នែករដ្ឋបាល ស្ថានភាពហេដ្ឋារចនា-សម្ព័ន្ធ ការបន្ថយពន្ធ ឧបត្ថម្ភធន និងហិរញ្ញប្បទានដែលតំរង់ទិសទៅតាមគោលនយោបាយ។ ក្នុងករណីប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី រដ្ឋាភិបាលប្រើប្រាស់យុទ្ធសាស្ត្រឧស្សាហកម្មដែលមានគោលដៅច្បាស់លាស់ ដូចជា : (១) ការជម្រុញការនាំចេញ (២) ការការពារឧស្សាហកម្មក្នុងស្រុក (មូលធន) ដើម្បីប្រើប្រាស់ឧស្សាហកម្មធុនធ្ងន់/គីមី និងការធ្វើអោយប្រសើរឡើងនូវរចនាសម្ព័ន្ធឧស្សាហកម្ម (៣) កំណើននៃការអភិវឌ្ឍន៍ធនធាន និងឧស្សាហកម្មកែច្នៃ (៤) កំណើន SMEs និង SI និង (៥) ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងការធ្វើអោយប្រសើរឡើងនូវផលិតភាព។

ឈរលើទស្សនវិស័យនេះ គេត្រូវតែនិយាយថា ប្រទេសកម្ពុជាដែលពឹងផ្អែកលើ ODA និង FDI និងកង្វះខាតនូវសន្និធិដើមទុនក្នុងស្រុក មិនមានយុទ្ធសាស្ត្រវាយចំខ្លាំងទៅលើឧស្សាហកម្ម ដូចយុទ្ធសាស្ត្រដែលគេបានឃើញនៅក្នុងប្រទេសអភិវឌ្ឍន៍ ឬសម្រាប់ឧស្សាហូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅអាស៊ីឡើយ។ តែទោះជាយ៉ាងណាក៏ដោយ កម្ពុជាបានចាត់វិធានការឧស្សាហកម្មជាច្រើន ជាពិសេសក្នុងការជំរុញឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ រួមមានការអនុម័តច្បាប់ដើម្បីផ្តល់ការលើកទឹកចិត្តសំដៅទាក់ទាញវិនិយោគបរទេស ដែលអាចបង្កើតការនាំចេញ និងការងារការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រ ដល់សកម្មភាពផលិតកម្ម និងសេវាកម្ម ការរៀបចំបណ្តាញសំរាប់ផលិតចែកចាយ និងដឹកជញ្ជូនមនុស្សការធានាការងារនិងការកែតម្រូវលក្ខខណ្ឌការងារការសាងសង់ទីតាំង ត្រួតពិនិត្យការនាំចេញ-នាំចូល និងការចរចាពាណិជ្ជកម្មជាមួយបណ្តាប្រទេសអភិវឌ្ឍន៍ ដើម្បីទទួលបានទីផ្សារនាំចេញ (ឧ. ការទទួលបាននូវកូតានាំចេញច្រើន និង ការអនុវត្តអគ្រាពន្ធ GSP)។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានចាត់វិធានការដើម្បីជំរុញការនាំចេញ ក្នុងគោលបំណងទាញយកមកវិញនូវរូបិយប័ណ្ណបរទេសជាផ្នែកមួយនៃការអភិវឌ្ឍន៍របស់ខ្លួនទៅលើធនធានធម្មជាតិ និងឧស្សាហកម្មចំបង (ឧ. កសិកម្ម ព្រៃឈើ និងជលផល) ព្រមទាំងឧស្សាហកម្មកែច្នៃផងដែរ។

យោងតាមរដ្ឋបាលបច្ចុប្បន្ននៅប្រទេសកម្ពុជា ដែលបានដាក់កំណើនសេដ្ឋកិច្ចនិងការប្រើប្រាស់ឧស្សាហកម្ម ជាអាទិភាពកំពូលនោះ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងទេសចរណ៍បានចាប់ផ្តើមរីកចំរើនទៅជាវិស័យចំបង នៃការបង្កើតការងារ និងការចំណេញរូបិយប័ណ្ណបរទេស។ តែទោះជាយ៉ាងណាក៏ដោយ ការសម្រេចបានទៅតាមគោល ដៅរយៈពេលមធ្យមនិងវែងដែលរដ្ឋាភិបាលបានកំណត់ នឹងទាមទារអោយមានការបន្តការកសាងធនធានឧស្សាហកម្ម តាមរយៈការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ដែលទាក់ទាញ ODA និង FDI។ ក៏រីតជោគជ័យ ក្នុងការទាក់ទាញការវិនិយោគបរទេសផ្ទាល់ តាមរយៈទីតាំងទាំងឡាយរបស់ពួកវា នឹងមានសារៈសំខានជាពិសេស សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម។ បន្ទាប់មក ជាសំខាន់ត្រូវជំរុញនូវការកំណត់ទីតាំង និងការប្រើប្រាស់ប្រកបដោយ ប្រសិទ្ធភាពនូវធនធានក្នុងស្រុកសម្រាប់ការអភិវឌ្ឍន៍បែបនេះ តាមរយៈការបង្កើតលក្ខខណ្ឌសមស្រប និងការអនុវត្តន៍ ច្បាប់និង បទប្បញ្ញត្តិផ្សេងៗ និង ការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលមាន ODA។ ច្រាសមកវិញ នេះតម្រូវ អោយមានសកម្មភាពទាំងឡាយ ដែលមានមូលដ្ឋាននៅលើយុទ្ធសាស្រ្តឧស្សាហកម្មត្រឹមត្រូវ ដែលកំណត់ ដោយរាជ-រដ្ឋាភិបាលកម្ពុជា។

ផ្នែកនេះបង្ហាញជូននូវសេចក្តីសង្ខេបនៃយុទ្ធសាស្រ្តឧស្សាហកម្ម ដែលផ្តោតលើវិស័យកម្មន្តសាល ដែលវាជា ប្រធានបទមួយធំនៃគំរោងនេះ។ នៅទីនេះ ពាក្យ "គោលនយោបាយឧស្សាហកម្ម" ត្រូវបានប្រើប្រាស់នៅក្នុងន័យ ទូលាយនៃគោលនយោបាយសំរាប់ពង្រីកកម្មន្តសាល ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ នៅ ពេលបច្ចុប្បន្ន វិស័យកម្មន្តសាលដែលកំពុងត្រូវបានអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា នៅមានក៏រីតយ៉ាងខ្លាំង (ជាពិសេស ចំពោះឧស្សាហកម្មកាត់ដេរសំលៀកបំពាក់)។ ផ្អែកលើតថភាពនេះ វិស័យយុទ្ធសាស្រ្តសំរាប់ការសិក្សាជាអាទិភាព មាន ៤ ដូច តទៅនេះ : (១) ការទទួលបានមូលធន និងបច្ចេកវិទ្យាតាមរយៈការទាក់ទាញ FDI (២) ការកែលំអរ ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ដើម្បីទាក់ទាញ FDI (៣) ការអភិវឌ្ឍន៍ធនធានមនុស្ស និង (៤) វិធានការជាក់លាក់ សម្រាប់ជំរុញឧស្សាហកម្មដែលអាចមានជោគជ័យ។ នៅក្នុងវិស័យណាមួយក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មាន ការរៀបចំបុគ្គលិក បទពិសោធន៍ និងចំណេះធ្វើគ្រប់គ្រាន់នៅពេលបច្ចុប្បន្ននេះនៅឡើយ ហេតុនេះ ត្រូវចាត់វិធានការ អោយបានទាន់ពេលវេលានិងសមស្រប ដោយមានជំនួយពីប្រទេសផ្សេងៗទៀត។

**តារាងទី ៤-១-១ គោលនយោបាយឧស្សាហកម្ម (ពាក់ព័ន្ធឧស្សាហកម្ម) សម្រាប់ជំរុញកម្មន្តសាលនៅកម្ពុជា**

| យុទ្ធសាស្រ្តពាក់ព័ន្ធឧស្សាហកម្ម | ប្រធានបទដែលត្រូវផ្តោតការយកចិត្តទុកដាក់ | ករណីជាក់ស្តែង |
|---|---|---|
| គោលនយោបាយ ដើម្បីទាក់ទាញ FDI (ការទទួលបានមូលធន និងបច្ចេកវិទ្យា) | - លក្ខខណ្ឌ និងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិ<br>- សមត្ថភាពអង្គការដើម្បីទាក់ទាញ FDI | - ច្បាប់ស្តីពីការវិនិយោគ ការលើកទឹកចិត្ត ការត្រួត ពិនិត្យលើការនាំចេញ-នាំចូល លក្ខខណ្ឌការងារ<br>- ការផ្ទេរអំណាច សមត្ថភាពក្នុងការវិភាគឧស្សាហកម្ម |

| | | |
|---|---|---|
| | | ផែនការមេ<br>- បរិយាកាសវិនិយោគ កូនសៀវភៅដៃ មជ្ឈមណ្ឌល ជប៉ុន-អាសាន |
| យុទ្ធសាស្ត្រសំរាប់កែលំអរហេដ្ឋារចនាសម្ព័ន្ធ (ការរៀបចំមូលដ្ឋានគ្រឹះឧស្សាហកម្ម) | - ការកសាងទីតាំងឧស្សាហកម្ម<br>- លក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ | - មុខងារ SEZ អំណាច ទឹក ការកែឆ្នៃទឹកកខ្វក់ ទូរគមនាគមន៍<br>- ការដឹកជញ្ជូនផ្លូវគោក (រថយន្តធំៗ និង ផ្លូវដែក) ការដឹកជញ្ជូនផ្លូវទឹក ការដឹកជញ្ជូនតាមអាកាស |
| យុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ធនធានមនុស្ស (ការផលិតបុគ្គលិកដែលចាំបាច់ដើម្បីដឹកនាំសហគ្រាស និង ប្រើប្រាស់យុទ្ធសាស្ត្រ) | - ប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស<br>-ការប្រើប្រាស់អ្នកជំនាញដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ | - សាលាបឋមសិក្សា និងមធ្យមសិក្សា សាកលវិទ្យាល័យ សាលាបច្ចេកទេស (សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ) បុគ្គលិកគ្រប់គ្រង<br>- បុគ្គលិកសម្រាប់កសាងយុទ្ធសាស្ត្រ FDI បុគ្គលិកសម្រាប់ SEZ |
| យុទ្ធសាស្ត្រសំរាប់ជំរុញឧស្សាហកម្ម (វិធានការសំរាប់ឧស្សាហកម្មរបស់បុគ្គលម្នាក់ៗ) | - វិធានការសម្រាប់ជម្រុញឧស្សាហកម្មដែលអាចទទួលជោគជ័យ | - ការជម្រុញការនាំចេញ ការអភិវឌ្ឍន៍ធនធាន (ធារាសាស្ត្រ កសិផល បច្ចេកវិទ្យាកែឆ្នៃ ជាដើម) ការរៀបចំផែនការមេ (សំលៀកបំពាក់ ការកែឆ្នៃម្ហូបអាហារ សម្ភារៈពាក់នៅជើង) |

***ប្រភព : ក្រុមសិក្សារបស់ JICA***

## ៤.២. ឧស្សាហកម្មកម្មន្តសាលដែលអាចទទួលជោគជ័យ និងយុទ្ធសាស្ត្រឧស្សាហកម្ម

គម្រោងនេះជ្រើសរើសវិស័យកម្មន្តសាល ៥ ជាវិស័យដែលសង្ឃឹមថាមានជោគជ័យសម្រាប់អភិវឌ្ឍន៍នៅកម្ពុជា (សំលៀកបំពាក់ កែឆ្នៃម្ហូបអាហារ សម្ភារៈពាក់នៅជើង និងសមាសភាគអេឡិកត្រូនិក/អេឡិកត្រូនិកសម្រាប់តម្លើងសាមញ្ញ និងការប្រើប្រាស់ម៉ាស៊ីនធម្មតា) ។ ចំណុចទាំងឡាយខាងក្រោមនេះបង្ហាញជូននូវការពិនិត្យពិចារណាពីស្ថានការ និងអនុសាសន៍សម្រាប់វិស័យនីមួយៗ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រដើម្បីទាក់ទាញមូលធនបរទេស និង ជម្រុញឧស្សាហកម្ម ដែលរួមមានវិធានការដើម្បីទាក់ទាញ FDI និងជម្រុញការនាំចេញ។ តារាងខាងក្រោមបង្ហាញពីចំណងទាក់ទងរវាងឧស្សាហកម្មដែលអាចទទួលជោគជ័យ និងយុទ្ធសាស្ត្រឧស្សាហកម្ម។

**តារាងទី ៤-២-១ : ចំណងទាក់ទងរវាងឧស្សាហកម្មដែលអាចទទួលជោគជ័យ និងយុទ្ធសាស្ត្រឧស្សាហកម្មនៅកម្ពុជា**

| វិស័យដែលជោគជ័យ | យុទ្ធសាស្ត្រដើម្បីទាក់ទាញ FDI | យុទ្ធសាស្ត្រកែលំអរហេដ្ឋារចនាសម្ព័ន្ធ | យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស | យុទ្ធសាស្ត្រជំរុញឧស្សាហកម្ម (កសាងចក្ខុវិស័យ) |
|---|---|---|---|---|
| សំលៀកបំពាក់ | Δ | Δ | ○ | ចាំបាច់ |

| | | | | |
|---|---|---|---|---|
| កែច្នៃម្ហូបអាហារ | ○ | © | © | ចាំបាច់ |
| សំម្ភារៈពាក់នៅជើង | ○ | ○ | ○ | ចាំបាច់ |
| អេឡិកត្រូនិក/អេឡិកត្រូនិក | © | © | © | ឆាប់ពេក |
| គ្រឿងម៉ាស៊ីនធម្មតា | © | © | © | ឆាប់ពេក |

### ៤.២.១ ឧស្សាហកម្មកាត់ដេរ

ប្រទេសកម្ពុជាមានបរិយាកាសវិនិយោគ ដែលមានលក្ខណៈអនុគ្រោះប្រៀបធៀប ហើយបរទេសបានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងចាប់យកទីតាំងនោះបន្ថែមទៀត។ ច្បាប់គោលស្តីពីការវិនិយោគបរទេស បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត និង ការអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនេះបានបង្កើតជាលក្ខខណ្ឌ និង ភាពប្រសើរឡើងដោយការយល់ដឹងអំពីឧស្សាហកម្មកាត់ដេរ។ មួយផ្នែកដោយសារការកាត់សំលៀកបំពាក់ មិនទាមទារនូវ ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មដែលមានការអភិវឌ្ឍន៍ខ្ពស់ ហើយការផ្គត់ផ្គង់ទឹក ភ្លើង តម្រូវការអោយមានគោលនយោបាយទាក់ទាញការវិនិយោគបរទេសផ្ទាល់និងលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ នៅមិនទាន់រឹងមាំខ្លាំងនៅឡើយ។ ប្រសិនបើឧស្សាហកម្មកាត់ដេរកម្ពុជា ដែលត្រូវបានរំពឹងថានឹងបន្តពង្រីកជាមួយ FDI ត្រូវលើកកំពស់ការប្រកួតប្រជែងអន្តរជាតិ រដ្ឋាភិបាលត្រូវតែចាត់វិធានការដើម្បីអភិវឌ្ឍធនធានមនុស្ស ដែលចាំបាច់ដើម្បីអោយមានការផ្ទេរដោយរលូននូវបច្ចេកវិទ្យាកាត់ដេរ និងចំណេះធ្វើក្នុងការគ្រប់គ្រង មកអោយអ្នកម្ចាស់ស្រុក។ ដូចអនុសាសន៍ដើម្បីជំរុញការវិនិយោគផ្ទាល់ចូលក្នុងឧស្សាហកម្មកាត់ដេរ វាអាចត្រូវបានចង្អុលបង្ហាញដូចជាការពង្រឹងនៃផលិតភាព ពិពិធកម្មនៃទីផ្សារនាំចេញ ការងាកទៅរកការអភិវឌ្ឍន៍ និងនាំចេញ ការបង្កើតហេដ្ឋារចនាសម្ព័ន្ធនៃឃ្លាំងរួចពន្ធគយកណ្តាលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

### ៤.២.២ ឧស្សាហកម្មកែច្នៃម្ហូបអាហារ

ប្រទេសកម្ពុជាមានសក្តានុពលយ៉ាងច្រើនសំរាប់ការផ្គត់ផ្គង់ផលិតផល និងធនធានកសិឧស្សាហកម្ម ហើយតម្រូវការសម្រាប់ការកែច្នៃម្ហូបអាហារកំពុងតែរីកដុះដាលនៅប្រទេសជប៉ុន និងប្រទេសផ្សេងៗទៀតនៅអាស៊ី។ តាមកាលៈទេសៈទាំងនេះ យុទ្ធសាស្ត្រសម្រាប់ជម្រុញឧស្សាហកម្មក្នុងវិស័យនេះ មានអាទិភាពខ្ពស់។ ប៉ុន្តែ ក្នុងអាទិភាពនេះឧស្សាហកម្មនេះមិនអាចជម្រុញដោយគ្រាន់តែពឹងផ្អែកលើវិនិយោគបរទេសប៉ុណ្ណោះទេ។ ការជម្រុញតម្រូវឱ្យមានយុទ្ធសាស្ត្រដែលគិតពិចារណាទៅលើកត្តាជាច្រើន រួមមានសង្គតភាពជាមួយយុទ្ធសាស្ត្រកសិកម្ម និងការជម្រុញការនាំចេញដោយមូលធនក្នុងស្រុក។ ហេតុនេះ ការប្រែក្លាយពីដីផ្ទៃដីជាតិដែលខូចខាត មកជាដីដែលមាន ជីវជាតិសម្រាប់ការផលិតធនធានកសិឧស្សាហកម្ម ជាការពិតណាស់រដ្ឋាភិបាលត្រូវតែកសាងយុទ្ធសាស្ត្រសម្រាប់ទាក់ទាញ FDI ដើម្បី

ទទួលបានមូលនិធិ និងបច្ចេកវិទ្យារបស់ប្រទេសអភិវឌ្ឍន៍ និងប្រទេសជិតខាង ប៉ុន្តែរដ្ឋាភិបាលត្រូវតែរៀបចំផង ដែរនូវរចនាសម្ព័ន្ធចាំបាច់សម្រាប់កែលំអរគុណភាព និងផ្គត់ផ្គង់ជានិរន្តរន៍នូវម្ហូបអាហារសម្រាប់កែឆ្នៃ។ នេះគឺជាភារកិច្ចដែលត្រូវបំពេញនៅក្នុងបរិការណ៍នៃយុទ្ធសាស្ត្រវិស័យកសិឧស្សាហកម្ម និងទាមទារអោយមានការសិក្សាឱ្យបានកាន់តែទូលំទូលាយ ។

បន្ថែមទៅលើការទាក់ទាញមូលធនបរទេស និងបច្ចេកវិទ្យា ប្រទេសកម្ពុជាត្រូវតែសិក្សាជាបន្ទាន់សម្រាប់រៀបចំចក្ខុវិស័យឧស្សាហកម្ម (ផែនការមេ) ដែលរួមបញ្ចូលនូវការប្រើប្រាស់ ODA និងការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រកសិឧស្សាហកម្ម។ នេះត្រូវរួមផ្សំជាមួយនឹងការស្វែងរកកុងសង់ស៊ុសមួយ នៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស សម្រាប់ជម្រុញឧស្សាហកម្មកែឆ្នៃ។

### ៤.២.៣ ឧស្សាហកម្មផលិតសម្ភារៈពាក់នៅជើង

ដូចឧស្សាហកម្មកាត់ដេរដែរ ឧស្សាហកម្មផលិតសម្ភារៈពាក់នៅជើងរបស់ប្រទេសកម្ពុជា ទទួលឥទ្ធិពលបន្តិចបន្តួចនៅក្នុងបរិយាកាសវិនិយោគ។ ជាពិសេសចំពោះសម្ភារៈផលិតពីស្បែក មានលទ្ធភាពដ៏ធំមួយនៃការបើកឡើងនៅកម្ពុជាដោយក្រុមហ៊ុនតៃវ៉ាន់មួយចំនួន ដែលមានទីតាំងនៅប្រទេសចិន និងវៀតណាមរួចទៅហើយ ដើម្បីគេចចេញពីការដាក់ទណ្ឌកម្មប្រឆាំងការនាំទំនិញច្រើនហួសហេតុ (anti-dumping) ដែលកំណត់ដោយទីផ្សារអឺរ៉ុប។ នេះចង្អុលបង្ហាញទៅដល់តម្រូវការអោយមានវិធានការ ដែលត្រូវបានរៀបចំឡើងសំដៅទាក់ទាញការចូលមករកស៊ីរបស់ក្រុមហ៊ុនផលិតសម្ភារៈពាក់នៅជើង (ទាំងក្រុមហ៊ុនធំៗ និងក្រុមហ៊ុនម៉ៅការបន្ត)។ ដូចក្នុងករណីឧស្សាហកម្មកាត់ដេរ វាមានការចាំបាច់តិចតួចចំពោះលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែ ការផ្គត់ផ្គង់ថាមពលអេឡិកទ្រិកជាដើមត្រូវតែពង្រឹង ដោយហេតុថាដំណើរការនៃការផលិតសម្ភារៈពាក់នៅជើង មានជំហានជាច្រើនដែលភាគច្រើនពឹងផ្អែកលើការប្រើប្រាស់ថាមពល។ ចំពោះការអភិវឌ្ឍន៍ធនធានមនុស្សវិញ ការកត់សំគាល់នៅក្នុងសេចក្តីយោងទៅដល់ឧស្សាហកម្មកាត់ដេរ ក៏អនុវត្តចំពោះឧស្សាហកម្មផលិតសម្ភារៈពាក់នៅជើងដែរ។ រួមមានស្លចេញជាផ្លាស្ទិកចាក់ក្នុងពុម្ពដែក បិទការ និងជំហានផ្សេងៗទៀត ដំណើរការផលិតកម្មមានទិដ្ឋភាពបច្ចេកទេសកាន់តែធំដែលទាមទារបុគ្គលិកដែលមានសមត្ថភាព។

ឧស្សាហកម្មផលិតសម្ភារៈពាក់នៅជើងរបស់ប្រទេសកម្ពុជា មានសក្តានុពលសំរាប់ការរីកចំរើនទៅ ជាឧស្សាហកម្មកែឆ្នៃដ៏ធំ បន្ទាប់ពីឧស្សាហកម្មកាត់ដេរ។ រដ្ឋាភិបាលគួរជម្រុញអោយមានលំហូរវិនិយោគបរទេស ដើម្បីពង្រឹងដំណាក់កាលអភិវឌ្ឍន៍របស់ខ្លួន។ ទន្ទឹមនឹងនេះ នៅក្នុងរយៈពេលវែង ខ្លួនត្រូវតែគាំទ្រនូវការផ្គត់ផ្គង់ក្នុងស្រុកផ្នែកគ្រឿងបន្លាស់ និងវត្ថុធាតុ ព្រមទាំងការចូលរួមដោយសហគ្រាសក្នុងស្រុក ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនេះនៅក្នុងទីផ្សារអន្តរជាតិ។ ពេលវេលានឹងមកដល់ជាយថាហេតុនៅពេលដែលប្រទេសកម្ពុជាធ្វើ ការសិក្សាដើម្បីរៀបចំផែនការមេ ដែលនឹងក្លាយជាចក្ខុវិស័យមួយសម្រាប់ឧស្សាហកម្មនេះ។

## ៤.២.៤ ឧស្សាហកម្មតម្លើងគ្រឿងអេឡិកទ្រិក/អេឡិកត្រូនិកធម្មតា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនមានក្រុមហ៊ុនធំមួយ ទោះជាក្រុមហ៊ុនក្នុងស្រុកឬសាខារបស់បរទេសទេនៅក្នុងវិស័យនេះ។ បទសម្ភាសន៍ជាមួយក្រុមហ៊ុនធំៗរបស់ជប៉ុនដែលមានទីតាំងនៅក្នុងប្រទេសជិតខាង បានរកឃើញថាក្រុមហ៊ុនមួយចំនួនដែលធ្វើការតម្លើងធម្មតា កំពុងចាប់ផ្តើមស្វែងរកទីតាំងផលិតកម្មថ្មីៗ ដើម្បីរក្សានូវតំលៃប្រកួតប្រជែងរបស់ខ្លួន។ សារៈសំខាន់បំផុតមិនអាចខ្វះបានសម្រាប់ការរកស៊ីនៅក្នុងវិស័យនេះ បានរងឥទ្ធិពលពីបរិយាកាសធុរៈកិច្ចសម្រាប់មុខទំនិញរបស់ខ្លួនដែលត្រូវផលិត និងហួសពីការបំពេញចិត្តនៃលក្ខខណ្ឌការងារ។ ជាការពិត សារៈសំខាន់ បំផុតមិនអាចខ្វះបាននោះគឺវត្តមាននៃទីតាំងឧស្សាហកម្ម ដែលមានហេដ្ឋារចនាម្ព័ន្ធត្រឹមត្រូវតាមខ្នាត និងការរៀបចំនូវរចនាសម្ព័ន្ធផ្គត់ផ្គង់អន្តរជាតិ។ ក្រៅពីការចាត់វិធានការដើម្បីឆ្លើយតប ទៅតាមសារៈសំខាន់នេះ រដ្ឋាភិបាលនឹងត្រូវធ្វើយុទ្ធនាការជម្រុញអោយបានខ្លាំងក្លាសំរាប់ FDI។

ទីតាំងទាំងឡាយគឺជាប្រភេទនៃទីតាំងកែឆ្នៃដើម្បីនាំចេញដែលផ្អែកលើវត្ថុធាតុនាំចូល។ វានឹងមានទីកន្លែងតិចតួចសម្រាប់ការចូលរួមដោយមូលធនកម្ពុជា ហើយការជម្រុញសកម្មភាពឧស្សាហកម្មមានការពឹងផ្អែកយ៉ាងខ្លាំងទៅលើមូលធនបរទេស។ ចំពោះហេតុផលនេះ ជាសំខាន់នោះត្រូវធ្វើការរៀបចំទាំងឡាយដែលចាំបាច់ដល់ការចូលមកចាប់ទីតាំងតាមការចាប់អារម្មណ៍របស់បរទេស (ឧ. លក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ និងច្បាប់)។ មានកន្លែងតិចតួចប៉ុណ្ណោះសំរាប់រៀបចំផែនការមេដើម្បីជម្រុញការរីកលូតលាស់ឧស្សាហកម្មនេះ ដោយកម្ពុជាតាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍន៍ធនធានមនុស្សក៏មានសារៈសំខាន់សម្រាប់ទាក់ទាញ FDI នៅក្នុងឧស្សាហកម្មនេះដែរ។ ក្រៅពីកម្មករ (ប្រតិបត្តិករ) ដែលបំពេញប្រតិបត្តិការងាយៗនោះ ប្រទេសកម្ពុជាត្រូវតែបណ្តុះបណ្តាលអ្នកបច្ចេកទេស និងវិស្វករដើម្បីគ្រប់គ្រងផលិតកម្ម និងដំណើរនានាដែលពាក់ព័ន្ធនឹងផលិតផលខ្ពស់ និងអ្នកគ្រប់គ្រងថ្នាក់មធ្យមដែលមានសមត្ថភាពផ្នែករដ្ឋបាលទូទៅ។

## ៤.២.៥ ការប្រើប្រាស់ម៉ាស៊ីនធម្មតា

ចំពោះវិស័យអេឡិកទ្រិក/អេឡិកត្រូនិក ប្រទេសកម្ពុជាមិនមានក្រុមហ៊ុនធំនៅក្នុងឧស្សាហកម្មនេះនៅឡើយទេនៅពេលនេះ។ យោងតាមលទ្ធផលនៃការធ្វើសម្ភាសន៍ជាមួយពួកគេ ក្រុមហ៊ុនជប៉ុនមួយចំនួនដែលដំណើរការនៅក្នុងវិស័យនេះ នៅក្នុងប្រទេសជិតខាង បានមើលឃើញនូវលទ្ធភាពមួយសម្រាប់វិនិយោគនៅក្នុងប្រទេសកម្ពុជាដោយសំអាងលើហេតុផលពីរគឺ : ភាពប្រកួតប្រជែងផ្នែកថ្លៃដើម និង ការប្រើប្រាស់ទីផ្សារក្នុងស្រុក។

ដូចជាឧស្សាហកម្មអេឡិកទ្រិក/អេឡិកត្រូនិកដែរ ការប្រើប្រាស់ម៉ាស៊ីនធម្មតាមិនត្រូវបានកត់សំគាល់ដោយការផ្តោតការយកចិត្តទុកដាក់ខ្លាំងលើលក្ខខណ្ឌការងារ នៅក្នុងទិដ្ឋភាពនៃថ្លៃដើមនោះទេ ហើយកត្តាសំខាន់បំផុតនៅក្នុងបរិយាកាសវិនិយោគនោះគឺការផ្គត់ផ្គង់កម្មករ និងវិស្វករដែលតម្រង់ទិសសម្រាប់ការប្រើប្រាស់ម៉ាស៊ីន វត្តមាននៃទីតាំងឧស្សាហកម្មដែលមានការផ្គត់ផ្គង់អគ្គិសនីល្អ និងធាតុផ្សំផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត និង ការរៀបចំនូវ

រចនាសម្ព័ន្ធផ្គត់ផ្គង់អន្តរជាតិ។ នៅទីនេះដែរ ក្រៅពីប្រើប្រាស់វិធានការដើម្បីបំពេញទៅតាមសារៈសំខាន់ ដែលមិនអាចខ្វះបានទាំងនេះ រដ្ឋាភិបាលនឹងត្រូវធ្វើយុទ្ធនាការជម្រុញការទាក់ទាញ FDI អោយបានខ្លាំងក្លា។

សម្រាប់អនាគតដែលគេអាចមើលឃើញ សកម្មភាពទាំងឡាយនឹងរួមមានការកែឆ្នៃសំរាប់នាំចេញ ដែលផ្អែកលើការនាំចូលវត្ថុធាតុ និង/ឬការផលិតសម្រាប់ទីផ្សារក្នុងស្រុក។ ជាការសំខាន់ត្រូវធ្វើការរៀបចំទាំងឡាយដែលចាំបាច់សំរាប់បើកការរកស៊ីទៅតាមការចាប់អារម្មណ៍បរទេស (លក្ខខណ្ឌច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធ)។ ទៅថ្ងៃអនាគត ឧស្សាហកម្មក្នុងស្រុកនឹងអាចដើរតួនាទីជា SI ហើយនេះនឹងបង្កើតជាទីកន្លែងមួយសម្រាប់រៀបចំផែនការមេ ដោយគិតពិចារណាអំពីការចូលរួមរបស់មូលធនកម្ពុជា។ តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលនេះវាហាក់ដូចជាឆាប់ពេកក្នុងការធ្វើផែនការបែបនេះ។

## ៤.៣ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងឧស្សាហកម្មនៅកម្ពុជា

ផ្នែកនេះដាក់ចេញនូវទិសដៅនៃគោលនយោបាយនៅក្នុងវិស័យទាក់ទាញ FDI លក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ធនធានមនុស្ស ជាយុទ្ធសាស្ត្រគោលពាក់ព័ន្ធនឹងឧស្សាហកម្ម ដែលដូចគ្នានឹងឧស្សាហកម្មជោគជ័យនានាដែលបានពិពណ៌នានៅក្នុងផ្នែក ៣.២។ ផ្នែកនេះក៏អធិប្បាយអំពីការរៀបចំចក្ខុវិស័យឧស្សាហកម្ម (ផែនការមេ) នៅក្នុងបរិការណ៍នៃយុទ្ធសាស្ត្ររួមសំរាប់ជម្រុញឧស្សាហកម្មផងដែរ។

### ៤.៣.១ គោលនយោបាយសំរាប់ទាក់ទាញការវិនិយោគបរទេសផ្ទាល់

#### (1) លក្ខខណ្ឌ និង ការអនុវត្តច្បាប់និងបទប្បញ្ញត្តិ:

ច្បាប់ស្តីពីការវិនិយោគ ដែលចែងអំពីសកម្មភាពរួចពន្ធគយនៃពន្ធលើប្រាក់ចំណេញសាជីវកម្ម (ការកំណត់ពេលវេលា) សកម្មភាពរួចពន្ធគយនៃការនាំចូលវត្ថុធាតុដើម សកម្មភាពទូទាត់ពិសេសបន្ថែម និង ច្រកចេញ-ចូលតែមួយក្នុងការអនុម័តយល់ព្រមទៅលើពាក្យស្នើស៊ីវិនិយោគ ត្រូវបានរៀបចំឡើងដោយផ្អែកលើការរៀបចំច្បាប់ តាមការជាក់ស្តែង នៅក្នុងបណ្តាប្រទេសអាស៊ានផ្សេងទៀត និងក្នុងគោលបំណងផ្តល់អោយមូលធនបរទេសនូវផលប្រយោជន៍កាន់តែធំជាងមុន។ ប្រទេសកម្ពុជា បានអនុវត្ត និងធ្វើអោយប្រសើរឡើងនូវច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធស្របជាមួយនឹងមូលដ្ឋានធុរៈកិច្ចបរទេសនៅក្នុងឧស្សាហកម្មកាត់ដេរ។ ចាប់ពីពេលនេះតទៅ វាអាចចាំបាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវការលើកទឹកចិត្តជាពន្ធដារ ជាឧទាហរណ៍ ការសន្ទត់នៃការទាក់ទាញ FDI នៅក្នុងឧស្សាហកម្មផ្សេងទៀតផងដែរ។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនបានបង្ហាញថា មានភាពមិនច្បាស់លាស់មួយចំនួនអំពីលក្ខខណ្ឌសំរាប់កំណត់គ្រឿងលើកទឹកចិត្ត។

នៅពេលនេះ រដ្ឋាភិបាលកំពុងធ្វើការសិក្សាពីស្ថានអំពីការបង្កើតច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ជាគន្លឹះក្នុងការទាក់ទាញ FDI ដែលតម្រង់ទិសក្នុងការនាំចេញ។ ក្រៅពីការសិក្សាអំពីវិធីសាស្ត្រក្នុងការអនុវត្ត ច្បាប់និងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងពាណិជកម្ម ក៏គួរធ្វើការស្រាវជ្រាវដោយប្រុងប្រយ័ត្ន អំពីករណីមុនៗ

ដែលបានកើតឡើង នៅក្នុងប្រទេសជិតខាង និងធ្វើការរៀបចំអោយបានត្រឹមត្រូវដើម្បី បំពេញទៅតាមនិយាមពិភពលោក តាមរយៈការ សិក្សាទាំងឡាយទៅតាមទស្សនៈនៃក្តីកង្វល់របស់បរទេស។ នេះក៏អនុវត្តចំពោះច្បាប់ទាំងឡាយ ដែលពាក់ព័ន្ធនឹង សកម្មភាពធុរៈកិច្ចនៃមូលធនបរទេស និងការអនុវត្តច្បាប់ ដោយចាប់ផ្តើមពីច្បាប់ការងារ ដែលក្រុមហ៊ុនបរទេសតែងតែជួបប្រទះនៅ ក្នុងសកម្មភាពប្រចាំថ្ងៃ របស់ខ្លួន។ ក្រុមហ៊ុនអន្តរជាតិកំពុងស្វែងរកនូវការកែលំអរនានាអោយបានត្រឹមត្រូវតាមការចាំបាច់ ដោយផ្អែកលើភាពសមស្របជាមួយនឹងសកម្មភាពរបស់ពួកគេ។

(2) **ស្ថាប័ន និង សមត្ថភាព**

អំណាចដើម្បីអនុម័ត FDI សព្វថ្ងៃនេះកំពុងស្ថិតនៅក្នុង ក.អ.ក/គ.វ.ក។ នៅក្នុងរយៈពេលវែង ជម្រើសនៃការបែងចែកវាតាមរយៈការផ្ទេរ (ការផ្ទេរអំណាច) គួរត្រូវបានពិចារណា។ នេះត្រូវបានស្នើឡើងដោយករណីជាច្រើននៃយុទ្ធសាស្ត្រ FDI នៅប្រទេសវៀតណាម និងហ្វីលីពីន ដែលជាករណីដែលបានកើតឡើងកន្លងមក។ ប្រទេសទាំងនេះបានទទួលជោគជ័យក្នុងការទាក់ទាញ FDI តាមរយៈការផ្ទេរអំណាចសម្រេចអនុម័តមួយចំនួនទៅអោយសាជីវកម្មសាធារណៈ និងស្ថាប័នក្រោមបង្គាប់ផ្សេងៗទៀត និងរដ្ឋបាលមូលដ្ឋាន ដែលធ្វើអោយការងារអនុម័តកាន់តែមានប្រសិទ្ធភាព និងបានដាក់ចេញនូវសមាសភាគប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគ។ គន្លឹះគឺប្រតិបត្តិការនៃទីតាំងឧស្សាហកម្ម និងយុទ្ធនាការទាក់ទាញ។ គួរកត់សំគាល់ថា ជាមួយនឹងចំណងទាក់ទងបែបនេះ ការលើកទឹកចិត្តដើរតួនាទីក្នុងការទាក់ទាញដ៏មានឥទ្ធិពល។ តាមធម្មតា CDC/CIB មានមុខងារជាភ្នាក់ងារផ្លូវការតែមួយគត់ ដែលទទួលបន្ទុកជម្រុញយុទ្ធសាស្ត្រទាក់ទាញ FDI ដូចជាស្ថាប័នផ្សេងៗទៀតដូចជា BOI នៅប្រទេសថៃ។ បញ្ហាគឺថាអនាគតទំនងជានាំមកនូវតម្រូវការកាន់តែស៊ីជម្រៅ សម្រាប់ការផ្ទេរអំណាចមួយចំនួន ដែលពាក់ព័ន្ធនឹងការងារនៅផ្នែកច្រកចេញ-ចូលតែមួយ សម្រាប់អនុម័តលើពាក្យស្នើសុំ។

វិស័យអាទិភាពសម្រាប់ទាក់ទាញ FDI នៅក្នុងវិស័យកម្មន្តសាល មានការកាត់សំលៀកបំពាក់ កែឆ្នៃម្ហូបអាហារ អេឡិកត្រូនិក/អេឡិកត្រូនិកដែលតម្លើងធម្មតា សម្ភារៈពាក់នៅជើង និងការប្រើម៉ាស៊ីនធម្មតា។ ដើម្បីទាក់ទាញ FDI អោយកាន់តែសកម្មនៅក្នុងវិស័យទាំងនេះ ជាការពិត ក.អ.ក/គ.វ.ក ត្រូវចូលរួមនៅក្នុងសកម្មភាពវិជ្ជាជីវៈទាំងឡាយ ប៉ុន្តែវានឹងមិនមានប្រសិទ្ធភាពឡើយប្រសិនបើធ្វើដោយគ្មានសណ្តាប់ធ្នាប់។ ផ្ទុយទៅវិញ ត្រូវបង្កើតអង្គភាពមួយសម្រាប់អង្កេត និងពិនិត្យតាមដាននូវលទ្ធភាពទៅថ្ងៃអនាគត សម្រាប់ឧស្សាហកម្មគោលដៅពាក់ព័ន្ធនឹងបរិយាកាសទីផ្សារ នវកម្មបច្ចេកទេស រចនាសម្ព័ន្ធឧស្សាហកម្ម និងអ្នកចូលមកធំៗ។ សហគ្រាសសាជីវកម្ម ទោះបីជាក្នុងស្រុកឬបរទេសក៏ដោយ ក៏មិនអាចធ្វើការសម្រេចចិត្តធំៗលើការវិនិយោគបានឡើយ លុះត្រាតែរដ្ឋាភិបាលបង្កើតឡើងនូវគោលការណ៍ណែនាំទៅតាមទស្សនវិស័យបែបនេះ។ គួរតែបង្កើតស្ថាប័នបែបនេះនៅក្នុង ក.អ.ក/គ.វ.ក។

ជម្រើសមួយផ្សេងទៀតគឺត្រូវថែទាំសមត្ថភាពបែបនេះនៅក្នុងវិទ្យាស្ថានសាធារណៈ-ឯកជន ដែលមានសមត្ថភាពជំនាញ។

ទោះក្នុងកម្រិតណាក៏ដោយ ប្រទេសកម្ពុជានឹងមិនអាចប្រើប្រាស់យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព សម្រាប់ទាក់ទាញ FDI បានឡើយ ទាល់តែខ្លួនមានសមត្ថភាពស្ថាប័នដែលអាចអោយទទួលបាននូវទិដ្ឋភាពគ្រប់ជ្រុងជ្រោយអំពីកំណើននៅពេលអនាគតនៅក្នុងឧស្សាហកម្មជោគជ័យ ដែលជាទីតាំងត្រូវបានគិតទុកជាមុន។ ក្នុងនាមជាអាជ្ញាធរយុទ្ធសាស្ត្រដែលមានយុត្តាធិការលើ FDI នោះ ក.អ.ក/គ.វ.ក គួរតែពង្រឹងសមត្ថភាពរបស់ខ្លួនឡើងវិញ សម្រាប់ការអង្កេត និងពិនិត្យពិច័យនៅក្នុងវិស័យឧស្សាហកម្មដែលរដ្ឋាភិបាលចង់ប្រើប្រាស់នៅពេលអនាគត។ សំណើជាក់លាក់នៅទីនេះគឺការរៀបចំក្រុមការងារមួយសម្រាប់ឧស្សាហកម្មនីមួយៗដែលរំពឹងថាជោគជ័យ។ នេះគឺជាភារកិច្ចរបស់ក្រុមការងារនីមួយៗក្នុងការកសាងសំណើយុទ្ធសាស្ត្រ ដោយផ្អែកលើលទ្ធផលអង្កេត និងការវិភាគដែលបានធ្វើឡើងក្នុងរយៈពេលពេញលេញមួយ ហើយយកសំណើទាំងនេះមកឆ្លុះបញ្ចាំងនៅក្នុងយុទ្ធនាការជម្រុញជាក់ស្តែង។ ក្រុមការងារទាំងនេះក៏គួរសិក្សាផងដែរអំពីការរៀបចំផែនការមេសំរាប់ឧស្សាហកម្មសំខាន់ៗ។ ជាពិសេស គេបានគិតថាមានតម្រូវការអោយមានការសិក្សាអំពីផែនការមេបែបនេះ សម្រាប់ឧស្សាហកម្មដែលមានស្រាប់ដូចជា កសិកម្មនេសាទ និងការកែឆ្នៃម្ហូបអាហារ និងស្បែកជើង។

<u>ករណីប្រទេសវៀតណាម</u>

នៅប្រទេសវៀតណាម គណៈកម្មាធិការរដ្ឋនិងសាជីវកម្មវិនិយោគ (SCCI) បានដើរតួនាទីក្នុងការអនុវត្តគោលនយោបាយ FDI រហូតដល់ពាក់កណ្តាលទសវត្សឆ្នាំ ១៩៩០។ ក្រោយពេលត្រួតពិនិត្យឡើងវិញនូវច្បាប់គ្រប់គ្រង FDI នៅឆ្នាំ ១៩៩៦ រដ្ឋាភិបាលបានបញ្ចូល SCCI និង គណៈកម្មាធិការធ្វើផែនការរដ្ឋ (SPC) ជាមួយគ្នា និងបានលើកកម្រិតអង្គភាពថ្មីទៅជាក្រសួង គឺក្រសួងផែនការនិងវិនិយោគ (MPI)។ MPI រួមមានសមាសភាពមកពីការិយាល័យធ្វើផែនការរដ្ឋ ដែលជាមុខងារសំខាន់នៅមុនពេលបញ្ចូលគ្នា និងដែលជាការិយាល័យវិនិយោគដែលពាក់ព័ន្ធសំខាន់ជាមួយ FDI និងការអង្កេតជាច្រើន និងការិយាល័យស្រាវជ្រាវ។ បើទោះបីជាការសម្របសម្រួលអន្តរការិយាល័យមិនល្អប្រណីតក៏ដោយ ក៏គោលនយោបាយសំរាប់ទាក់ទាញ FDI នៅក្នុងការិយាល័យវិនិយោគ ត្រូវបានរៀបចំឡើងនិងអនុវត្តដោយផ្អែកលើសកម្មភាពទាំងឡាយរបស់ការិយាល័យផែនការរដ្ឋផងដែរ ដែលថ្លឹងថ្លែងរវាងផែនការរដ្ឋបាល និងថវិការបស់ក្រសួងនិងភ្នាក់ងារទាំងឡាយ ស្របទៅតាមផែនការរយៈពេលមធ្យម និងវែង។ ទន្ទឹមនឹងនេះដែរ អាជ្ញាធរសម្រាប់អនុម័ត FDI ត្រូវបានបែងចែកក្នុងចំណោម MPI និង គណៈកម្មាធិការប្រជាជនស្របតាមភាពខុសគ្នានៃឧស្សាហកម្ម និងទំហំវិនិយោគ ហើយនេះធ្វើអោយការរៀបចំអង្គភាពកាន់តែមានប្រសិទ្ធភាព។

**(3) សមត្ថភាពជម្រុញ**

ការទាក់ទាញវិនិយោគបរទេសត្រូវរងផលប៉ះពាល់ដោយបរិយាកាសប្រកួតប្រជែងអន្តរជាតិ។ ក្នុងការស្វែងរកគោលដៅវិនិយោគរបស់ពួកគេ ដែលមានអត្ថប្រយោជន៍ជាង ក្រុមហ៊ុនទាំងឡាយសិក្សាប្រៀបធៀបទៅលើទីតាំងជាបេក្ខជន ដែលចាប់ផ្តើមជាមួយនឹងការប្រមូលពត៌មាន និងឈានទៅដល់ការស៊ើបអង្កេតពីស្ថានបឋម។ ប្រទេសជិតខាងជាច្រើនកំពុងប្រកួតប្រជែងជាមួយកម្ពុជាដើម្បីទទួលយក FDI។ បើទោះបីជាគូប្រជែងសំខាន់ៗត្រូវបានគិតថាមានប្រទេសវៀតណាម ឡាវ និងមីយ៉ាន់ម៉ាក៏ដោយ ក៏បញ្ជីនេះរួមមានប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន និង ប្រហែលថែមទាំងប្រទេសថៃ និងចិនផងដែរ ផ្អែកទៅតាមករណីនីមួយៗ។ បន្ទាប់មក ខាងប្រទេសម្ចាស់ផ្ទះត្រូវតែរៀបចំកូនសៀវភៅដៃដែលពណ៌នាអំពីរបបវិនិយោគ ដែលធ្វើអោយក្រុមហ៊ុនបរទេសជឿជាក់ និងអភិវឌ្ឍន៍សមត្ថភាពជម្រុញអោយកាន់តែពេញលេញនៅលើគ្រប់ទិដ្ឋភាពទាំងអស់។ បញ្ហាសំខាន់គឺត្រូវជម្រុញរបបវិនិយោគដែលមានកម្រិតហួសពីផលប្រយោជន៍សម្រាប់ទីតាំងរកស៊ី ហើយរួមបញ្ចូលនូវលទ្ធភាពនៃការផ្លាស់ប្តូរ និងការធ្វើអោយប្រសើរឡើងនៅក្នុងរយៈពេលមធ្យម និងវែង បើទោះបីជាវាមិនមានអត្ថប្រយោជន៍សម្រាប់មូលធនបរទេស នៅពេលនេះក៏ដោយ។ អ្វីដែលក្រុមហ៊ុនបរទេសផ្តោតការគួសបញ្ជាក់នៅក្នុងការវិភាគចុងក្រោយ គឺអាកប្បកិរិយារបស់មនុស្សនៅក្នុងប្រទេសម្ចាស់ផ្ទះ និងការសប្បាយរីករាយយ៉ាងខ្លាំងសំរាប់ឧស្សាហូបនីយកម្ម។ នេះគឺជាអ្វីដែលមានការចាំបាច់សំរាប់អ្នកដឹកនាំភ្នាក់ងារពាក់ព័ន្ធជាច្រើន ដើម្បីធ្វើនិងអនុវត្តសេចក្តីសម្រេចចិត្តដែលចាំបាច់សម្រាប់ទាក់ទាញ FDI ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

ក្នុងខណៈពេលនៃការអនុវត្តសកម្មភាពជម្រុញ ជាសំខាន់ក៏គួរកសាងគម្រោងមួយសម្រាប់ការកំណត់បញ្ហារបស់ក្រុមហ៊ុន និងបំណងរបស់ក្រុមហ៊ុនសាខាបរទេស ដែលមានទីតាំងនៅប្រទេសកម្ពុជារួចហើយ ដោយមានកិច្ចសហប្រតិប្តិការជាមួយក្រុមទាំងឡាយដូចជាសមាគមឧស្សាហកម្ម។ លទ្ធផលទាំងអស់នឹងឆ្លុះបញ្ចាំង នៅក្នុងការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌសម្រាប់របបវិនិយោគ ដើម្បីអោយការចាប់បារម្ភបរទេស អាចបន្តធ្វើវិនិយោគនៅក្នុងប្រទេសប្រកបដោយការទុកចិត្ត។ រដ្ឋាភិបាលត្រូវយល់ដឹងថា ការបង្កើនសមត្ថភាពសម្រាប់តាមដានត្រួតពិនិត្យគឺជាផ្លូវកាត់ចំពោះការធ្វើអោយប្រសើរឡើង នូវច្បាប់និងយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធនឹងការទាក់ទាញ FDI និងអាចនាំទៅដល់ការវិនិយោគបន្ថែមទៀត។ ប្រតិបត្តិការនៃសន្និសីទផ្នែកសាធារណៈ-កឯកជនបែបនេះគឺឆាប់នឹងធ្លាក់ ទៅដល់ទម្រង់និយម។ កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីបង្កាកុំអោយសន្និសីទទាំងនេះ គ្រាន់តែជានិម្មិត្តរូបហើយរក្សាវាឱ្យបានយូរអង្វែងដោយស្មោះត្រង់ ដែលមានគោលបំណងសំខាន់ក្នុងការពង្រីកទីតាំងសាជីវកម្ម។

### ៤.៣.២ លក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ

### (១) ទីតាំងឧស្សាហកម្ម

ការទាក់ទាញ FDI នៅក្នុងវិស័យកម្មន្តសាលទាមទារអោយមានការរៀបចំនូវទីតាំងឧស្សាហកម្ម ដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ។ ឧស្សាហកម្មកាត់ដេរ និងសម្ភារៈពាក់នៅជើង ដែលក្រុមហ៊ុនបរទេស ជាច្រើនបានមករកស៊ីហើយនោះ គឺជាឧស្សាហកម្មអតិពលកម្មយ៉ាងខ្លាំង។ នៅក្នុងករណីជាច្រើន ក្រុមហ៊ុនរកទីតាំងដោយខ្លួនគេផ្ទាល់ ហើយកសាងរោងចក្ររបស់ពួកគេក្រៅពី ទីតាំងឧស្សាហកម្ម ដើម្បីធានាពួកគេផ្ទាល់ នូវការផ្គត់ផ្គង់ពលកម្មគ្រប់គ្រាន់ និងចៀសវាងសំពាធនៃការឡើងថ្លៃឈ្នួល។ ទន្ទឹមនឹងនេះ ហេដ្ឋារចនាសម្ព័ន្ធដែលមានខ្នាតត្រឹមត្រូវសំរាប់ថាមពល និងការផ្គត់ផ្គង់ទឹកនិងការកែឆ្នៃទឹកកខ្វក់មិនមែនជាភាពចាំបាច់មិនអាចខ្វះបាននោះទេ។ ផ្ទុយទៅវិញ ឧស្សាហកម្មតម្លើងគ្រឿងអេឡិកត្រូនិក/អេឡិកត្រូនិក និងម៉ាស៊ីន ដែលក្នុងនោះកម្ពុជា សង្ឃឹមថានឹងទាក់ទាញការមករកស៊ីនៅពេលអនាគត តម្រូវអោយមានការវិនិយោគយ៉ាងច្រើន និង ទាមទារនូវការផ្គត់ផ្គង់ថេរផ្នែកអគ្គិសនី សំរាប់ទីតាំងផលិតកម្មនៅក្នុងករណីជាច្រើន។ ផ្អែកលើដំណើរការផលិតកម្ម អាចនឹងចាំបាច់ត្រូវមានទីតាំងសំរាប់ការផ្គត់ផ្គង់ទឹកជាប្រចាំ និងការកែឆ្នៃទឹកកខ្វក់នៅក្នុងដំណើរការផលិតកម្ម។ សំរាប់ហេតុផលនេះហើយទើបចាំបាច់ត្រូវអភិវឌ្ឍទីតាំងឧស្សា-ហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធបែបនេះពេញលេញ។

ករណីជាច្រើន ដែលបានកើតឡើងមុននៅក្នុងប្រទេសជិតខាងបង្ហាញអោយឃើញថាគោលដៅនៃការមករកស៊ីរបស់ក្រុមហ៊ុនជប៉ុនជាច្រើន នៅក្នុងវិស័យតម្លើងអេឡិកត្រូនិក/អេឡិកត្រូនិក និងម៉ាស៊ីន គឺជាទីតាំងឧស្សាហកម្មដែលត្រូវបានអភិវឌ្ឍ និងប្រតិបត្តិការដោយសាជីវកម្មសាធារណៈ ឬរដ្ឋបាល មូលដ្ឋាន។ នៅប្រទេសវៀតណាមទីតាំងមួយចំនួនគឺជាទីតាំងឧស្សាហកម្មដែលត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលបរទេស ឬត្រូវបានអភិវឌ្ឍ និងដំណើរការដោយផ្ទាល់ ដោយក្រុមហ៊ុនពាណិជ្ជកម្មជប៉ុន។ អាចនិយាយម្យ៉ាងទៀតបានថា ក្រុមហ៊ុនជប៉ុនជាច្រើនប្រម៉ើលមើលជាមុនឃើញនូវ សកម្មភាពផលិតកម្មនៅក្នុងអនាគតវែងឆ្ងាយ នៅលើទីតាំងទាំងនេះ ហើយសង្កត់ធ្ងន់លើ ការបែងចែកទីតាំងទាំងនេះ និងការគ្រប់គ្រងទីតាំងឧស្សាហកម្មដែលអាចអោយទុកចិត្តបានខ្ពស់។ បើទោះបីជា SMEs មួយចំនួន និងក្រុមហ៊ុនពិសេសៗដែលមានបំណងនៅក្រៅទីតាំងឧស្សាហកម្មក៏ដោយ ក៏ប្រទេសកម្ពុជាត្រូវតែកត់សំគាល់ឃើញថា ក្រុមហ៊ុនជប៉ុនចូលចិត្ត ទីតាំងទាំងឡាយនៅក្នុងទីតាំងឧស្សាហកម្ម ដែល គ្រប់គ្រងដោយវិស័យសាធារណៈ ឬក្រុមហ៊ុន ពាណិជ្ជកម្មជប៉ុន។ នៅក្នុងករណីជាច្រើន ការបើកទីតាំងនៅប្រទេសកម្ពុជាធ្វើទៅតាមគំរូនៃការនាំចូលរាល់គ្រឿងបន្លាស់ និងវត្ថុធាតុទាំងអស់ និងការនាំចេញនូវរាល់ទិន្នផល ដែលផលិតបានទាំងអស់។ នេះចង្អុលបង្ហាញអោយឃើញនូវតម្រូវការអោយមានបទប្បញ្ញត្តិតំបន់កែច្នៃសំរាប់នាំចេញ (EPZ) ពេញលេញ នៅក្នុងទីតាំងឧស្សាហកម្ម។

## (២) ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់

នៅក្នុងឧស្សាហកម្មតម្លើងអេឡិកត្រូនិក/អេឡិកត្រូនិក និងម៉ាស៊ីន (និងនៅក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហារផងដែរ) ការរៀបចំបណ្តាញចែកចាយជារូបវ័ន្តនៅក្នុងនិងក្រៅស្រុក គឺជាគន្លឹះនៃការទាក់ទាញ FDI។ ក្នុងករណីនៃឧស្សាហកម្មអេឡិកត្រូនិក/អេឡិកត្រូនិក ក្រុមហ៊ុនបានចូលរួមនៅក្នុង SCM នៅកំរិតពិភពលោក ហើយជាការចាំបាច់បំផុតដែលត្រូវមានការផ្គត់ផ្គង់អោយកាន់តែមានប្រសិទ្ធភាព សំរាប់ចែកចាយមិនត្រឹមតែនៅក្នុងតំបន់អាស៊ាន និងអាស៊ីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅអឺរ៉ុប និងអាមេរិកខាងជើងផងដែរ។ ជាទូទៅ ក្រុមហ៊ុនទាមទារពេលវេលាដឹកជញ្ជូនមិនអោយលើសរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ សម្រាប់រថយន្តដឹកទំនិញធំៗ ឬយន្តហោះដឹកទំនិញ និងពីរយៈពេលពេល ២ សប្តាហ៍ ទៅដល់ ១ ខែ សម្រាប់កប៉ាល់ដឹកទំនិញ។ លើកលែងតែការដឹកជញ្ជូនតាមសមុទ្រអន្តរជាតិចេញ ស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជានឹងតម្រូវអោយមានការកែលំអរយ៉ាងច្រើន។ ការកែលំអរលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់នឹងត្រូវការចំណាយយ៉ាងសន្ធឹកសន្ធាប់ ហើយជំនួយហិរញ្ញវត្ថុពីប្រទេសផ្សេងៗក្នុងទម្រង់ជា ODA គឺជាការចាំបាច់។ ដើម្បីធ្វើអោយប្រសើរឡើងដោយគ្មានការពន្យាពេលនោះ ប្រទេសកម្ពុជាគួរតែបង្កើនល្បឿនការរៀបចំរបស់ខ្លួននូវលក្ខខណ្ឌទាំងឡាយ ដែលប្រទេសម្ចាស់ជំនួយស្វែងរកនៅក្នុងប្រទេសទទួល។

ការផ្តោតទៅលើការរំពឹងទុកយ៉ាងខ្ពស់ ក្នុងការកែលំអរផ្នែកផ្គត់ផ្គង់ គឺបណ្តាញសម្រាប់ដឹកជញ្ជូនផ្លូវគោកនៅក្នុងនិងក្រៅប្រទេស។ ការងារកំពុងតែដំណើរការទៅមុខជាមួយនឹងការកសាងផ្លូវជាតិលេខ ១ ក្នុងរបៀងកើត-លិច ដែលនឹងភ្ជាប់ប្រទេសកម្ពុជាជាមួយប្រទេសថៃ និងវៀតណាម ត្រូវបានគិតទុកជាមុនថានឹងមានផលប៉ះពាល់កាន់តែធំធេងជាងមុន ព្រោះវានឹងភ្ជាប់ទីក្រុងបាងកក ជាមួយនឹងទីក្រុងភ្នំពេញ និងហូជីមិញ។ គេរំពឹងថាប្រទេសកម្ពុជានឹងចុះកិច្ចព្រមព្រៀងមួយជាមួយប្រទេសជិតខាងរបស់ខ្លួន សម្រាប់សេវាដឹកជញ្ជូនទំនិញតាមអាកាសទៅវិញទៅមកនៅក្នុងអនាគតដ៏ខ្លី ហើយអ្នកដែលពាក់ព័ន្ធទាំងអស់កំពុងរង់ចាំនូវការត្រួសត្រាយផ្លូវ ដែលមិនទាន់ត្រួសត្រាយនេះ និងការបញ្ចប់ការកសាងស្ពាននៅក្នុងប្រទេសកម្ពុជា។ សម្រាប់បណ្តាញដឹកជញ្ជូនផ្លូវគោក មានក្តីសង្ឃឹមថានឹងមានការកែលំអរផ្លូវរវាងក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ព្រមទាំងការកែលំអរផ្លូវដែកឡើងវិញ។

សម្រាប់ការដឹកជញ្ជូនតាមសមុទ្រវិញ ឧស្សាហកម្មកាត់ដេរប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ។ ការពង្រីកកំពង់ផែ និងមធ្យោបាយនៅកំពង់ផែ ត្រូវបានគ្រោងថានឹងបញ្ចប់ដោយប្រើប្រាស់ជំនួយពីធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន។ បច្ចុប្បន្ននេះ កប៉ាល់ជាច្រើនចូលមកប្រទេសសិង្ហបុរី ហើយនេះបង្កជាឧបសគ្គបណ្តោះអាសន្ន ប៉ុន្តែមានសង្ឃឹមច្រើនថានឹងអាចបង្រួញពេលវេលាក្នុងការតភ្ជាប់សេវាជាមួយទីផ្សារក្រៅប្រទេស តាមរយៈការប្រើប្រាស់កប៉ាល់ដឹកទំនិញធំៗ។ បណ្តាញផ្លូវអាកាសអន្តរជាតិមានសារៈសំខាន់មិនអាចខ្វះបានសម្រាប់ការដឹកជញ្ជូនសមាសភាគអេឡិកត្រូនិកតូចៗ។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងតម្រូវការកើនឡើង គេសង្ឃឹមថាក្រុមហ៊ុនដឹកជញ្ជូន

តាមផ្លូវអាកាសអន្តរជាតិ អាចនឹងចូលមកប្រទេសកម្ពុជា ហើយប្រហែលជាត្រូវការនូវការគាំទ្រពីអាជ្ញាធរដឹកជញ្ជូនតាមអាកាសរបស់កម្ពុជា តាមរបៀបនៃការបន្ធូរបន្ថយបទប្បញ្ញត្តិ។

### ៤.៣.៣ ការអភិវឌ្ឍន៍ធនធានមនុស្ស

ធនធានមនុស្សជាច្រើននឹងត្រូវការចាំបាច់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាក់ទាញ FDI នៅក្នុងបណ្តាឆ្នាំខាងមុខ។ នៅក្នុងជំហានទីមួយ ចាំបាច់ត្រូវចំរាញ់យកជំនាញបុគ្គលិកសម្រាប់អនុវត្តយុទ្ធសាស្ត្របែបនេះដោយរលូន។ ជាពិសេសទៅទៀតនោះ ប្រទេសកម្ពុជាត្រូវមានអ្នកជំនាញដែលអាចកសាងសំណើអោយកែប្រែឡើងវិញ នូវច្បាប់ស្តីពីការវិនិយោគ ច្បាប់ SEZ និង ច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀត និងអោយមានការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាក៏ត្រូវការបុគ្គលិកដែលអាចបំពេញការងារជម្រុញការវិនិយោគ និងវិភាគវិស័យនីមួយៗផងដែរ។ ពាក់ព័ន្ធនឹង SEZ ដែលនឹងត្រូវបង្កើតឡើងជាលើកទីមួយនោះ ត្រូវតែសាបព្រោះបណ្តុះធនធានមនុស្សដែលមានសមត្ថភាពក្នុងការផ្តល់សេវាច្រកចេញ-ចូលតែមួយ នៅក្នុងការបំពេញបែបបទគយនិងវិស័យផ្សេងៗទៀត និង គាំទ្រដល់ជំនាញវិស្វកម្មសម្រាប់រៀបចំទីតាំងឧស្សាហកម្ម និងថែរក្សាមធ្យោបាយទាំងនោះ។

តម្រូវការអោយមានការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងចំណោមក្រុមហ៊ុនធម្មតា ទំនងជានឹងត្រូវធ្វើអោយកាន់តែស៊ីជំរៅបន្ថែមទៀត ជាមួយនឹងការបោះទីតាំងដោយក្រុមហ៊ុនបរទេស។ ប្រសិនបើការបោះទីតាំងលឿននៅក្នុងឧស្សាហកម្មតម្លើងគ្រឿងអេឡិកទ្រិក/អេឡិកត្រូនិក និងម៉ាស៊ីននោះ វានឹងកាន់តែមានសារៈសំខាន់ក្នុងការបង្កើនសមត្ថភាពសម្រាប់សហគ្រិនដែលបានដុសខាត់។ តម្រូវការពិបាកនឹងកំណត់ត្រឹមកម្មករ និងប្រតិបត្តិករ ដែលត្រូវតែបំពេញមុខងារផលិតកម្មដែលមានការយល់ដឹងអំពីដំណើរការផលិតកម្ម និងឧបករណ៍ក្នុងកំរិតណាមួយនោះណាស់ គឺវាមានការកើនឡើងនូវតម្រូវការបុគ្គលិកគ្រប់ប្រភេទទាំងអស់។ បញ្ជីនេះរួមបញ្ចូលទាំងអ្នកបច្ចេកទេសនិងវិស្វករដែលមានសមត្ថភាពកសាង និងថែរក្សាប្រព័ន្ធផលិតកម្ម និងអ្នករដ្ឋបាលដូចជាអ្នកគ្រប់គ្រង ថ្នាក់កណ្តាលដើម្បីដឹកនាំរោងចក្រ ព្រមទាំងគណនេយ្យករផងដែរ។

ចំពោះវិធីសាស្ត្រវិញ ជាការពិតណាស់វាជាភារកិច្ចចំបង ដែលប្រទេសកម្ពុជាអាចធ្វើអោយប្រសើរឡើងនូវវិស័យអប់រំនៅកំរិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស។ ការផលិតបុគ្គលិកដែលមានជំនាញបែបវិទ្យាសាស្ត្រ និងបច្ចេកទេស ត្រូវតែធានាតាមរយៈពេលនៃការធ្វើអោយប្រសើរឡើងនូវការអប់រំនៅមហាវិទ្យាល័យ និងការបង្កើតសាលាវិជ្ជាជីវៈ។ មធ្យោបាយដែលអាចដឹងបានបន្ថែមទៀតសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស រួមមានគម្រោងសិក្សានៅបរទេស សិក្ខាសាលាក្រៅប្រទេស និងកម្មវិធីដែលចាត់ចែងដោយសភាពាណិជ្ជកម្មនិងឧស្សាហកម្ម ព្រមទាំងសមាគមឧស្សាហកម្មផងដែរ។ កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់វិស័យសាធារណៈ អាចដកយកប្រយោជន៍ពីគម្រោងគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលផ្តល់ដោយ

ប្រទេសជឿនលឿន។ វានឹងមានប្រសិទ្ធភាពបំផុតក្នុងការដកយកពីគម្រោងទាំងនេះ ទៅបំពេញក្នុងជំនួយអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈវិធានការទាំងឡាយដូចជាការបញ្ជូនអ្នកជំនាញ ការបង្កើតមជ្ឈមណ្ឌលបច្ចេកទេសជំនាញ និងការទទួលកម្មសិក្សាការី។

## ៤.៣.៤ ការកសាងចក្ខុវិស័យឧស្សាហកម្ម (ផែនការមេ)

បើទោះបីជាយល់ដឹងថាប្រទេសនេះមានស្ថានភាពកំពុងអភិវឌ្ឍន៍ ហើយប្រទេសនេះមានតួនាទីក្នុងការជម្រុញឧស្សាហកម្មតាមរយៈការទាក់ទាញ FDI ក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាមិនទាន់បានធ្វើការរៀបចំជាក់ស្តែង ឬចាត់វិធានការជាក់ស្តែងនៅឡើយទេ។ ឧទាហរណ៍ រដ្ឋាភិបាលមិនមានគំនិតល្អៗអំពីអ្វីដែលឧស្សាហកម្មទាំងឡាយត្រូវផ្តោតគោលដៅ និងត្រូវទាក់ទាញ FDI ដោយរបៀបណានៅក្នុងឧស្សាហកម្មទាំងនោះ និងជម្រុញកំណើននាំចេញព្រោះខ្លួនមិនអាចក្តាប់បានអោយណែនអំពីតថភាពពិភពលោក នៅក្នុងឧស្សាហកម្មទាំងនេះ។ នេះបាននាំអោយមានកង្វះខាតប្រសិទ្ធភាព និងសង្គតភាព ដូចដែលបានលើកឡើងតាមទស្សនៈនៃការខិតខំប្រឹងប្រែងទាក់ទាញ FDI នៅក្នុងគោលនយោបាយក្នុងវិស័យទាំងឡាយដូចជា ការវិនិយោគបរទេស ពាណិជ្ជកម្ម ហេដ្ឋារចនសម្ព័ន្ធ និងការងារ។ លើសពីនេះទៅទៀត វាមានកង្វះខាតតម្លាភាព និងសង្គតភាពនៅក្នុងតំណាក់កាលនៃការអនុវត្តយុទ្ធសាស្ត្រ ហើយនេះគឺជាឧបសគ្គយ៉ាងធំបំផុតចំពោះសកម្មភាពសាជីវកម្មក្នុងស្រុក និងបរទេស។ ដើម្បីអំពាវនាវអោយ FDI ចូលមកប្រទេសកម្ពុជាត្រូវតែផ្តល់នូវរបបវិនិយោគមួយដែលមានលក្ខណៈបើកចំហរ និងស្ថេរភាព ដែលបរទេសចង់បាន ដែលជាហេតុអនុញ្ញាតអោយមានការកាត់បន្ថយថ្លៃធុរៈកិច្ចនៅគ្រប់ទិដ្ឋភាពទាំងអស់។ ដើម្បីបង្កើតអោយមានរបបបែបនេះផងដែរ រដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំនូវផែនការមេមួយ ដែលមានជំនួយពីសហគមន៍ធុរៈកិច្ច បង្ហាញនូវចក្ខុវិស័យសម្រាប់ការវិវត្តន៍ឧស្សាហកម្ម និងចែករំលែកនូវទិសដៅសម្រាប់ជំរុញក្រុមហ៊ុនក្នុងស្រុក និងបរទេសនៅក្នុងពេលអនាគត។

ក្នុងចំណោមឧស្សាហកម្មដែលសង្ឃឹមថាបានជោគជ័យ រដ្ឋាភិបាលត្រូវតែរៀបចំនូវផែនការមេមួយដែលផ្តោតលើឧស្សាហកម្មជាក់លាក់តាំងពីដំបូង សម្រាប់វិស័យកាត់ដេរ និងសម្ភារៈពាក់នៅជើង ដែលជាវិស័យមានការកសាងឧស្សាហកម្មរួចហើយ (ឬស្ថិតនៅក្នុងដំណើរការបង្កើត) ជាពិសេសដោយក្រុមហ៊ុនបរទេស។ អនុវត្តដូចគ្នានេះដែរចំពោះឧស្សាហកម្មកសិផល ជលផល និងកែច្នៃម្ហូបអាហារ ដែលទាមទារអោយមានការសំរបសំរួលយុទ្ធសាស្ត្រក្នុងចំណោម ក្រសួងនិងភ្នាក់ងារជាច្រើន រួមបញ្ចូលទាំងសង្គតភាពជាមួយនឹងយុទ្ធសាស្ត្រលើវិស័យកសិកម្ម និងកសិករក្នុងស្រុក បើទោះបីជាមានការពឹងផ្អែកយ៉ាងខ្លាំងលើ FDI ក៏ដោយ។ រដ្ឋាភិបាលកម្ពុជាត្រូវតែកសាងចក្ខុវិស័យឧស្សាហកម្ម មួយដែលអាចធ្វើជាគោលការណ៍ណែនាំសំរាប់ការវិនិយោគសាជីវកម្ម។ សំរាប់គោលបំណងនេះខ្លួនត្រូវតែប្រមូល នូវពត៌មានពីស្ថានចុងក្រោយបំផុតស្តីពីនិន្នាការនៅក្នុងទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលបង្កើតបានជាមូលដ្ឋាន នៃចក្ខុវិស័យ កសាងចក្ខុវិស័យមួយ (ផែនការមេ) ដើម្បីបំពេញមុខងារជាគោលការណ៍ណែនាំ ក្នុងខណៈ

ដែល ធ្វើការតាមដានត្រួតពិនិត្យទៅលើសកម្មភាពទាំងឡាយក្នុងចំណោមសហគ្រាសឯកជនក្នុងស្រុក និងបរទេស និងរៀបចំនូវយុទ្ធសាស្ត្រឧស្សាហកម្មត្រឹមត្រូវមួយសមស្របនឹងចក្ខុវិស័យនេះ។ នៅក្នុងវិស័យអេឡិកត្រូនិក/អេឡិកត្រូនិក (ការតម្លើងធម្មតា) និងឧស្សាហកម្មដែលប្រើម៉ាស៊ីនធម្មតាការចូលរួមរបស់មូលធនបរទេស ហាក់ដូចជាគ្មានទាល់តែសោះ។ អាស្រ័យហេតុនេះ គួរផ្តល់អាទិភាពដល់ការកែលំអរហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងយុទ្ធនាការជម្រុញការទាក់ទាញ FDI ។ វាហាក់ដូចជាលឿនពេកក្នុងការសិក្សាសំរាប់រៀបចំផែនការមេសំរាប់ពួកវា។

ខាងក្រោមនេះគឺជាទម្រង់នៃផែនការមេ (ក្របខ័ណ្ឌ) :

**(i) បរិយាកាសវិនិយោគពិភពលោក**

ទស្សនវិស័យរយៈពេលមធ្យម និងវែងសម្រាប់ទីផ្សារពិភពលោក

សមាហរណកម្មសេដ្ឋកិច្ច និងការបែងចែកការងារផលិតកម្ម នៅអាស៊ី

គោលបំណងនៃការបោះទីតាំងនៅកម្ពុជា ក្នុងចំណោមការចាប់បារម្ភបរទេស

**(ii) ការកំណត់កាលៈទេសៈជាក់ស្តែងនៅកម្ពុជា**

ប្រភេទនៃការកសាងឧស្សាហកម្មនៅក្នុងវិស័យចំបងនីមួយៗ

យុទ្ធសាស្ត្រពាក់ព័ន្ធ និង ការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ

ការវិភាគកត្តាទាំងឡាយដែលមិនលើកទឹកចិត្តដល់វិនិយោគ

**(iii) ការរៀបចំចក្ខុវិស័យរយៈពេលមធ្យម និងវែង**

ការស្រាវជ្រាវលើករណីដែលបានកើតឡើងមុនៗ នៅក្នុងប្រទេសដែលបានដើរមុននៅអាស៊ី

ការវិភាគទៅលើសក្តានុពលរបស់ប្រទេសកម្ពុជាសម្រាប់ការអភិវឌ្ឍន៍ និងអត្ថប្រយោជន៍ប្រៀបធៀប

សេណារីយ៉ូសំរាប់ការកើនឡើងនៅពេលអនាគត និងចក្ខុវិស័យរយៈពេលមធ្យម និងវែង

**(iv) ការកសាងផែនការសកម្មភាពដើម្បីសំរេចអោយបាននូវចក្ខុវិស័យរយៈពេលមធ្យមនិងវែង**

ការបង្កើតឡើងនូវស្ថាប័នពាក់ព័ន្ធ និង ការបែងចែកសមត្ថភាព និងតួនាទី

ការត្រួតពិនិត្យឡើងវិញនូវច្បាប់និងគោលនយោបាយពាក់ព័ន្ធ

ការកែលំអរឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ

ផែនការសម្រាប់យុទ្ធនាការជម្រុញការទាក់ទាញ FDI

ផែនការដើម្បីថែទាំនូវកំណើន SI និង SMEs

ការធ្វើផែនការអភិវឌ្ឍន៍ធនធានមនុស្ស

**(v) គម្រោងការសំរាប់ជំនួយពីរដ្ឋាភិបាលបរទេស**

# ជំពូកទី ៥
# ឧស្សាហវិស័យ និងអនុសាសន៍ស្តីអំពីឱកាសវិនិយោគ សំរាប់ការទាក់ទាញ ឧស្សាហកម្មកាត់ដេរបរទេសមកកាន់កម្ពុជា

## ៥.១ លក្ខណៈនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា

### ៥.១.១ ការប្រៀបធៀបជាអន្តរជាតិនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់

- និយាយជាទូទៅ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ក្នុងប្រទេសកម្ពុជាមានច្រើនប្រភេទរួមមាន ផលិតផលសំលៀកបំពាក់ ស្បែកជើង ស្រោមជើង ស្រោមដៃ មួក ស្រោមខ្នើយ ស្រោមពូក កន្សែងពោះគោ កំរាលពូក វាំងនន កន្សែងដៃត្រូវបានគេយកទៅប្រើប្រាស់ជាកន្សែងចំហុយ ក្រណាត់តង់ ថង់ កំរាលព្រំ និង មង/សំណាញ់។ល។ ក្រៅពីផលិតផលទាំងនេះ ដោយសារប្រទេសកម្ពុជាកាន់តែមានការកើនឡើងនៃជំនាញក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើងនោះ ផែនការរបស់ក្រុមសិក្សាយើងនឹងគ្របដណ្តប់ទៅលើវិស័យទាំងនេះ។
- ប្រទេសកម្ពុជាបានចាប់ផ្តើមប្រតិបត្តិការនាំសំលៀកបំពាក់ចេញទៅក្រៅប្រទេសនៅឆ្នាំ១៩៩៥។ ដូចដែលបានសន្យាជាមួយសហរដ្ឋអាមេរិកដោយគោរពទៅតាមស្តង់ដារបស់អង្គការពលកម្មអន្តរជាតិ (ILO) កម្ពុជាបានក្លាយជា ប្រទេសមួយដែលមានអត្រានាំចេញនូវសំលៀកបំពាក់ទៅក្រៅប្រទេសខ្ពស់បំផុតនៅលើពិភពលោកក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ទោះបីកម្ពុជាពុំធ្លាប់មានប្រវត្តិនាំចេញសំលៀកបំពាក់កាលពីពេលមុន និងពុំមានជំនាញបច្ចេកទេស លើវិស័យនេះខ្ពស់ជាងប្រទេសវៀតណាម និងបង់ក្លាដែសក៏ដោយ។ ដូច្នេះ ឧស្សាហកម្មសំលៀកបំពាក់ចាក់បាន ដំណើរការយ៉ាងល្អក្នុងអំឡុងកាលកន្លងទៅនេះ ដោយសារការចំណាយទៅលើគ្រឿងម៉ាស៊ីនមានតំលៃទាប ហើយ ដំណើរផលិតកម្មទៀតសោត ក៏នៅមានលក្ខណៈសាមញ្ញជាងឧស្សាហកម្មតម្បាញដែលជាគុណសម្បត្តិស្របទៅនឹង ស្ថានភាពប្រាក់បៀវត្សទាប និង កំលាំងពលកម្មដែលមានជំនាញទាបនៅក្នុងប្រទេសកម្ពុជា។

**តារាង ៥-១-១ និន្នាការនៃការនាំចេញផលិតផលកាត់ដេរ**

| | Cambodia | Vietnam | China | India | Bangladesh | LAO PDR |
|---|---|---|---|---|---|---|
| 1980 | 0 | 0 | 1,625 | 673 | 2 | 0 |
| 1981 | 0 | 0 | 1,930 | 755 | 5 | 0 |
| 1982 | 0 | 0 | 2,140 | 625 | 11 | 0 |
| 1983 | 0 | 0 | 2,320 | 694 | 21 | 0 |
| 1984 | 0 | 0 | 2,755 | 831 | 77 | 0 |
| 1985 | 0 | 0 | 2,450 | 930 | 168 | 0 |
| 1986 | 0 | 0 | 4,050 | 1,061 | 236 | 0 |
| 1987 | 0 | 0 | 5,790 | 1,402 | 416 | 0 |
| 1988 | 0 | 33 | 6,990 | 1,508 | 416 | 0 |

| | Cambodia | Vietnam | China | India | Bangladesh | LAO PDR |
|---|---|---|---|---|---|---|
| 1989 | 0 | 52 | 8,165 | 2,060 | 440 | 3 |
| 1990 | 0 | 72 | 9,669 | 2,530 | 643 | 12 |
| 1991 | 0 | 117 | 12,245 | 2,527 | 840 | 25 |
| 1992 | 0 | 190 | 16,704 | 3,099 | 1,042 | 31 |
| 1993 | 0 | 239 | 18,441 | 2,970 | 1,307 | 49 |
| 1994 | 0 | 476 | 23,731 | 3,701 | 1,479 | 58 |
| 1995 | 26 | 431 | 24,049 | 4,110 | 1,969 | 76 |
| 1996 | 106 | 1,150 | 25,034 | 4,217 | 2,218 | 64 |
| 1997 | 224 | 1,384 | 31,803 | 4,343 | 2,688 | 91 |
| 1998 | 355 | 1,302 | 30,048 | 4,782 | 3,786 | 70 |
| 1999 | 653 | 1,622 | 30,078 | 5,153 | 3,348 | 72 |
| 2000 | 970 | 1,821 | 36,071 | 6,178 | 3,907 | 92 |
| 2001 | 1,143 | 1,867 | 36,650 | 5,483 | 4,261 | 99 |
| 2002 | 1,313 | 2,633 | 41,302 | 6,037 | 3,947 | 105 |
| 2003 | 1,600 | 3,555 | 52,061 | 6,625 | 4,461 | 105 |
| 2004 | 1,981 | 3,982 | 61,856 | 6,526 | 4,442 | 108 |

(1) Source: Compiled by JICA Study Team based on yearly statistical data base by WTO

**Figure 5-1-1 Past Growth Performance (Colour Chart)**




(2) Note: Unit= US$ Million
(3) Source: Compiled yearly statistical data base by WTO

- ប្រទេសកម្ពុជា ពុំមានរោងចក្រកាត់ដេររបស់រដ្ឋទេ។ ក្រៅពីនេះ អ្នកផលិតសំលៀកបំពាក់ម្ចាស់ស្រុកមានលក្ខណៈទន់ខ្សោយ ប្រតិបត្តិការនៃសាខាក្រុមហ៊ុនបរទេសទាំងមូល ត្រូវបានអនុញ្ញាត្តិចាប់តាំងពីបើកដំបូង

មកម៉្លេះ។ ជាលទ្ធផល ផលិតកម្ម និងការនាំចេញផលិតផលសំលៀកបំពាក់ បានត្រូវអនុវត្តដោយក្រុមហ៊ុនបរទេស។

- ប្រភេទផលិតផលមួយ ក្នុងចំណោមផលិតផលទាំងអស់របស់ប្រទេសកម្ពុជា បានផ្តុំទៅលើប្រភេទផលិតផលចាក់។ ផលិតផលចាក់មិនតំរូវអោយមានការវិនិយោគទុនច្រើន និងតំលៃសំរាប់ដឹកជញ្ជូនមានតំលៃថោក ដោយសារផលិតផលទាំងនេះមានទំងន់ស្រាល។ ជាបន្ថែម ប្រសិទ្ធភាពផលិតកម្មនៃផលិតផលប្រភេទចាក់កាន់តែមាន ការកែលំអយ៉ាងឆាប់រហ័ស ថ្វីត្បិតតែគេមិនតំរូវអោយមានជំនាញកំរិតខ្ពស់ក៏ដោយ។ និយាយជាទូទៅ ប្រសិទ្ធភាពផលិតកម្មនៃផលិតផលចាក់មានប្រមាណជា ១០ ភាគរយ ខ្ពស់ជាងកំរិតនៃផលិតផលពីក្រណាត់តម្បាញ។ ប្រទេស បង់ក្លាដែសមានលក្ខណៈស្រដៀងគ្នានឹងប្រទេសកម្ពុជា ដោយសារនៅក្នុងប្រទេសទាំងពីរនេះផលិតផលកាត់ដេរមាន ចំនួនប្រហែល ៨០ ភាគរយ នៃចំនួននាំចេញសរុប និងការនាំចេញដែលមានតំលៃទាប។ តែទោះជាយ៉ាងណាក៏ដោយ ឧស្សាហកម្មសំលៀកបំពាក់ក្នុងប្រទេសបង់ក្លាដែស មានបទពិសោធន៍ច្រើនជាងប្រទេសកម្ពុជាជាង១០ឆ្នាំ នៅពេល បច្ចុប្បន្ននេះប្រទេសបង់ក្លាដែសកំពុងពង្រីកផលិតកម្មពីផលិតផលប្រភេទចាក់អោយទៅជាផលិតផលក្រណាត់តម្បាញ ដែលផលិតផលប្រភេទនេះមានតំលៃបន្ថែមខ្ពស់ជាង។ នៅក្នុងឆ្នាំសារពើពន្ធ ២០០៤/២០០៥ ផលិតផលក្រណាត់ តម្បាញមានចំនួនប្រមាណជា ៧០ ភាគរយនៃការនាំចេញផលិតផលកាត់ដេរក្នុងប្រទេសបង់ក្លាដែស។ ផ្ទុយទៅវិញ ការនាំចេញផលិតផលក្រណាត់តម្បាញរបស់ប្រទេសកម្ពុជាមានចំនួនប្រមាណជា ៣០ ភាគរយ នៃការនាំចេញផលិត ផលកាត់ដេរនៅក្នុងឆ្នាំ២០០៥។ នាពេលអនាគត ការពង្រីកផលិតផលក្រណាត់តម្បាញ ដែលមានតំលៃខ្ពស់ជាង ផលិតផលប្រភេទចាក់នឹងដំណើរការជាបន្តទៀត។ រោងចក្រកាត់ដេរសំលៀកបំពាក់ នឹងទទួលយកនូវការបង្កើនប្រាក់បៀវត្សជាបណ្តើរៗ ក្នុងប្រទេសកម្ពុជា តាមរយៈការកែលំអរនូវតម្លៃផលិតផលកាត់ដេរក្នុងមួយឯកតាដោយផលិតផលក្រណាត់តម្បាញវិញ។

- នាបច្ចុប្បន្ននេះ ផលិតផលកាត់ដេរចំនួន ៨០ ភាគរយ ពីប្រទេសកម្ពុជាត្រូវបាននាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងតិចឬច្រើន ២០ ភាគរយ នៃផលិតផលនេះត្រូវបាននាំទៅកាន់ទីផ្សារសហគមអឺរ៉ុប។ ដើម្បីជំរុញការនាំចេញផលិតផលសំលៀកបំពាក់ទៅកាន់ទីផ្សារជប៉ុននៅពេលអនាគតដ៏ខ្លីខាងមុខ ប្រទេសកម្ពុជាចាំបាច់ត្រូវពង្រីកផលិតផលប្រភេទចាក់ (ដូចជាខោអាវទ្រនាប់ សំលៀកបំពាក់ដំណេក អាវចាក់ ស្រោមជើងកុមារ និងសំលៀកបំពាក់ ទារក) ទៅផលិតផលក្រណាត់តម្បាញ (ដូចជា សំលៀកបំពាក់ធ្វើការ និងសំលៀកបំពាក់សំរាប់ ការងារការិយាល័យ និងសំរាប់ជាផ្លូវការ) ដែលក្រុមហ៊ុនជប៉ុនមួយចំនួនមានការចាប់អារម្មណ៍ក្នុងការផលិតនូវផលិតផលទាំងនេះនៅក្នុង ប្រទេសកម្ពុជា។

- ប្រភេទទីពីរនៃផលិតផលកាត់ដេររបស់ប្រទេសកម្ពុជា ក្រៅពីផលិតផលសំលៀកបំពាក់ទាំងបីប្រភេទមានៈ សំលៀកបំពាក់ខាងក្រៅ (សំលៀកបំពាក់ឯកសណ្ឋាន សំលៀកបំពាក់សំរាប់ប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល អាវកាក់ ខោជើងវែង និងសំពត់) សំលៀកបំពាក់ប្រភេទកណ្តាល (សំលៀកបំពាក់ដំណេក អាវយឺត

អាវសឺមិ និងអាវរងា) និងសំលៀកបំពាក់ក្នុង (ខោអាវក្នុង) ប្រទេសកម្ពុជាបានចាប់ផ្តើមផលិតនូវផលិតផលសំលៀកបំពាក់ក្នុង ដែលមាន លក្ខណៈងាយស្រួលក្នុងការផលិត ហើយពុំតំរូវអោយមានកំរិតគុណភាពខ្ពស់ ហើយក្រោយមកទៀតបានផ្លាស់ប្តូរទៅ ផលិតសំលៀកបំពាក់កំរិតកណ្តាល និងសំលៀកបំពាក់ក្រៅ។ ក្រៅពីសំលៀកបំពាក់ខាងក្រៅខាងលើ ប្រទេសកម្ពុជា ពុំទាន់មានជំនាញគ្រប់គ្រាន់សំរាប់ផលិតសំលៀកបំពាក់ប្រើប្រាស់ជាផ្លូវការនៅឡើយ។ រហូតមកដល់ពេលនេះ រោងចក្រជាច្រើនមានឯកទេសក្នុងការផលិតខោអាវទ្រនាប់ និងសំលៀកបំពាក់កំរិតកណ្តាល។

- ប្រសិនបើប្រទេសកម្ពុជានៅតែអនុវត្តទៅតាមស្តង់ដារបស់អង្គការពលកម្មអន្តរជាតិនោះ កម្ពុជាអាចទទួលបានការបញ្ជាទិញពីសហរដ្ឋអាមេរិកនូវប្រភេទផលិតផលតិច ប៉ុន្តែ បរិមាណច្រើន។ ដោយសារការបញ្ជាទិញសំរាប់ទីផ្សារសហគមអ៊ឺរ៉ុបនៅប្រភេទផលិតផលច្រើន ប៉ុន្តែ បរិមាណតិច ទើបស្តង់ដាត្រួតពិនិត្យគុណភាពនៅសហគមអ៊ឺរ៉ុប ក៏ដូច ជាសហរដ្ឋអាមេរិកពុំសូវមានភាពតឹងរ៉ឹងបើប្រៀបធៀបទៅនិងប្រទេសជប៉ុន ថ្វីបើដូចនេះក៏ដោយ ក៏បរិមាណនាំទំនិញទៅកាន់ទីផ្សារសហគមអឺរ៉ុបពីប្រទេសកម្ពុជាមានចំនួនតិចតួច។ ផ្ទុយទៅវិញ ទោះបីជាការនាំចេញផលិតផលកាត់ដេរពីប្រទេសកម្ពុជាទៅទីផ្សារប្រទេសជប៉ុន មានបរិមាណតិចតួចបំផុតក៏ដោយ ក៏ប្រទេសជប៉ុននៅមានការត្រួតពិនិត្យស្តង់ដាតឹងរឹង ហើយត្រូវបានគេអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ន។
- វិនិយោគិនបរទេសដែលផលិតសំលៀកបំពាក់នៅក្នុងប្រទេសកម្ពុជា បានប្រឹងប្រែងធ្វើអោយប្រាក់ចំណេញបានជាអតិបរមា តាមរយៈការផលិតច្រើនយ៉ាងនៅទំនិញមូលដ្ឋានកំរិតទាបដោយប្រើប្រាស់កំលាំងពលកម្មដ៏សម្បូរ បែបនិងមានតំលៃទាប។ ដោយសារការបញ្ជាទិញទំនិញក្នុងបរិមាណតិចមិនធ្វើឱ្យក្រុមហ៊ុនទទួលប្រាក់ចំណេញជាអតិបរមា ថ្វីបើផលិតផលក្នុងបរិមាណតិចនេះតំរូវឱ្យធ្វើការងារច្រើនក៏ដោយ ក៏វិនិយោគិនបរទេសផលិតសំលៀកបំពាក់ ក្នុងប្រទេសកម្ពុជាពុំមានបំណងផលិតនូវផលិតផលដែលមានបរិមាណតិចពីសម្ភារៈផលិតប្រណិតដែលមានកំរិតខ្ពស់នេះទេ។ ត្រង់ចំណុចនេះ បានបញ្ជាក់ពីភាពខុសគ្នារវាងឱកាសជំនួញនៃឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា និងយុទ្ធសាស្ត្រធុរៈកិច្ចសំរាប់ក្រុមហ៊ុនកាត់ដេរជប៉ុន។ ការពិតក្រុមហ៊ុនជប៉ុនបានធ្វើការផលិតទំនិញក្នុងបរិមាណ ច្រើនពីទំនិញជាមូលដ្ឋានកំរិតទាបនៅក្នុងប្រទេសចិន និងធ្វើការផលិតទំនិញក្នុងបរិមាណតិចពីសម្ភារៈផលិតប្រណិត កំរិតខ្ពស់នៅក្នុងប្រទេសវៀតណាម។
- ប្រទេសកម្ពុជាពឹងផ្អែកលើការនាំចូលនូវតំរូវការសំភារៈគ្រឿងបន្លាស់ និងសម្ភារៈជំនួយសំរាប់ផ្គត់ផ្គង់ការផលិតដោយសារមានការខ្វះខាតខាងវិស័យផ្គត់ផ្គង់ (ដែលត្រូវផលិតអំបោះ និងក្រណាត់) និងឧស្សាហកម្មគាំទ្រ (ដែលផលិតគ្រឿងបន្លាស់ និងសម្ភារៈជំនួយ)នៅក្នុងប្រទេស។ ជាលទ្ធផល ទោះបីជាផលិតកម្មក្នុងប្រទេសកម្ពុជា បានទទួលផលប្រយោជន៍ច្រើនពីការចំណាយទាបទៅលើប្រាក់បៀវត្ស ក៏មានការចំណាយយ៉ាងច្រើនទៅលើការដឹកជញ្ជូនតាមផ្លូវទឹកក្នុងការនាំចូលនូវផលិតផលសំរាប់ផលិតសំភារៈ គ្រឿងបន្លាស់និងសំភារៈជំនួយទាំងអស់។ បន្ទាប់ពីមានការពិនិត្យទៅលើកត្តាទាំងពីរនេះ ចំនួននៃប្រាក់ចំណេញត្រូវបានកំណត់ដោយ

ប្រសិទ្ធភាពផលិតកម្ម។

- ដោយសារមានបញ្ហាលំបាកនៅក្នុងការទិញសំភារៈសំរាប់ការផលិត និងការឆ្លើយតបឱ្យទាន់ពេលវេលា សំរាប់ទីផ្សារផលិតផល ដំណើរការកាត់ដេរក្នុងប្រទេសកម្ពុជាត្រូវធ្វើឡើងជាសំខាន់ទៅលើការផលិតសំលៀកបំពាក់យកកំរៃជើងសារពីមុខទំនិញដែលមានផ្លាកយីហោពីប្រទេសអាមេរិក។ ជាលទ្ធផល មានការវិនិយោគតិចតួចក្រោមផែនការផលិត-និង-នាំចេញដែលក្រុមហ៊ុនមួយចំនួនតូចនោះទិញផលិតផលសំរាប់ផលិតដោយប្រុងប្រយ័ត្ន រកទីផ្សារ ដោយប្រើប្រាស់ផ្លាកយីហោពាណិជ្ជកម្ម និងបង្កើតម៉ូដសំលៀកបំពាក់ផ្សេងៗដោយខ្លួនឯង។
- នៅក្នុងប្រទេសវៀតណាម អត្រាផលធៀបនៃផលិតផលកាត់ដេរនាំចេញសរុបមានកំរិតប្រហាក់ប្រហែលគ្នាជាមួយនឹងប្រទេសកម្ពុជា និងប្រទេសបង់ក្លាដែស។ ប្រទេសវៀតណាម និងបង់ក្លាដែសមានបទពិសោធន៍ ២០ ឆ្នាំ មុនចាប់តាំងពីប្រទេសទាំងពីរនេះបានចាប់ផ្តើមផលិតសំលៀកបំពាក់នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០។ ជាលទ្ធផល ប្រទេសទាំងពីរមានវិស័យផលិតអំបោះចាក់ និងតំបាញក្រុងស្រុក និងជ្រលក់ពណ៌ ដែលជាចំណុចសំខាន់ខុសពីប្រទេសកម្ពុជា។ លើសពីនេះទៀត នៅប្រទេសវៀតណាម ក្រុមហ៊ុនជប៉ុនមានការចាប់អារម្មណ៍ទៅលើហត្ថកោសល្យ និងទេពកោសល្យកែច្នៃម៉ូដរបស់ប្រជាជនវៀតណាម ដោយប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងរោងចក្រតាមបែបប្រទេសជប៉ុន ដែលកម្មករវៀតណាមអាចទទួលយកបាន។ វិធីសាស្ត្រនេះនាំឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ទៅលើកំរិតនៃ ជំនាញផ្សេងៗហើយ ក្រុមហ៊ុនជប៉ុនកំពុងផលិតនូវផលិតផលច្រើនប្រភេទក្នុងបរិមាណតិចពីសម្ភារៈផលិតប្រណិត កំរិតខ្ពស់ (សំលៀកបំពាក់កំផ្លេរបស់ស្ត្រីបុរស សំលៀកបំពាក់របស់ក្មេងៗ និងអាវបុរស) សំរាប់នាំទៅទីផ្សារប្រទេសជប៉ុន។ ផ្ទុយទៅវិញ នៅក្នុងប្រទេសបង់ក្លាដែសករណីនៃជំនួញកាត់ដេរយកកំរៃជើងសារ ឬគំរោងវិនិយោគដែល ទទួលធ្វើដោយក្រុមហ៊ុនជប៉ុនមានតិចតួចប៉ុណ្ណោះ ដោយសារប្រទេសនេះជាប្រទេសស្ថិតនៅក្នុងតំបន់កាន់សាសនាឥស្លាម និងជាប្រទេសដែលងាយស្រួលកើតឡើងនៅអំពើកូដកម្ម។ ក្រុមហ៊ុនជប៉ុនមួយចំនួនតូចដែលកំពុងធ្វើវិនិយោគ ក្នុងប្រទេសនេះនាំចេញផលិតផលភាគច្រើនដែលមានតំលៃទាបទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមអឺរ៉ុប។
- នៅក្នុងចំណោមផលិតផលសំលៀកបំពាក់ដែលផលិតក្នុងប្រទេសកម្ពុជា ផលិតផលដែលមានកំរិតខ្ពស់ដូចជាខោខូវប៊យ ត្រូវប្រកួតប្រជែងជាមួយនឹងផលិតផលមកពីប្រទេសចិន និងឥណ្ឌា។ ប្រទេសទាំងពីរនេះ មានវត្ថុធាតុដើម កប្បាស រោងចក្រត្បាញអំបោះ រោងចក្រចាក់ត្បាញ និងចាក់អំបោះ រោងចក្រចាក់សរសៃអំបោះសំយោគ និងតម្បាញ ។ល។ និងអាចទិញសម្ភារៈផ្សេងៗនៅក្នុងស្រុក។ ប្រទេសទាំងពីរនេះមានលក្ខណៈដូចគ្នាត្រង់ថា ប្រទេសទាំងពីរមាន កំលាំងពលកម្មច្រើន និងអាចផលិតបញ្ចូលគ្នានូវផលិតផលសំលៀកបំពាក់រួមទាំងសម្ភារៈផ្សេងៗទៀត។ ដោយមាន សមត្ថភាពក្នុងការបង្កើតម៉ូដសំលៀកបំពាក់ និងមានផ្លាកយីហោល្បីប្រទេសទាំងពីរនេះ បានលក់ផលិតផលសំលៀក បំពាក់របស់គេក្នុងតំលៃមួយខ្ពស់ជាងផលិតផលពីប្រទេសកម្ពុជា និងបង់ក្លាដែស ទោះបីផលិតផលដូចគ្នាក៏ដោយ។ បើពិនិត្យទៅលើផលិតផលសំលៀកបំពាក់កំពូលពីរដែលមានចំណាត់ថ្នាក់លេខ១ និងលេខ២ ក្នុងការនាំចេញ ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកនាឆ្នាំ២០០៥

បានឱ្យឃើញថាប្រទេសឥណ្ឌា និងប្រទេសចិនបានប្រកួតប្រជែងគ្នាលើ សំលៀកបំពាក់ចាក់អំបោះ អាវចាក់អំបោះរបស់ស្ត្រី សំពត់ចាក់អំបោះរបស់ស្ត្រីជាដើម។ ជាលទ្ធផល ប្រទេសឥណ្ឌា បានក្លាយជាប្រទេសទទួលផលប្រយោជន៏ជាច្រើនលើផលិតផលតម្បាញ បន្ទាប់ពីការដាក់បទបញ្ញាត្តិនៃវិធានការសុវត្ថិភាព ដោយសហរដ្ឋអាមេរិក និងអឺរ៉ុបលើប្រទេសចិនកាលពីខែឧសភា ឆ្នាំ២០០៥។ តារាងខាងក្រោមបង្ហាញ ពីភាពខុសគ្នាមួយចំនួនរវាងឧស្សាហកម្មកាត់ដេររបស់ប្រទេសឥណ្ឌា និងប្រទេសចិន។ ជារួម ទោះបីប្រទេសឥណ្ឌា មានភាពល្អប្រសើរខាងវត្ថុធាតុដើមកូតុង និង ម៉ូដសំលៀកបំពាក់ក៏ដោយ ក៏ប្រទេសចិននៅមានភាពល្អប្រសើរជាងប្រទេសឥណ្ឌានូវធនធានអំបោះផ្សំជាតិគីមី និងផ្លាកយីហោ។ តារាងខាងក្រោមនេះគឺជាការផ្តល់ព័ត៌មានទាក់ទងនឹងឱកាសវិនិយោគនៃប្រទេសទាំងពីរ ដែលជាប្រទេសប្រកួតប្រជែងគ្នាសំរាប់ធ្វើការប្រៀបធៀបជាមួយនឹងឱកាសវិនិ យោគក្នុងប្រទេសកម្ពុជា។

**តារាង ៥-១-២ ការប្រៀបធៀបឧស្សាហកម្មនៅចិន និងឥណ្ឌា**

| China | India |
|---|---|
| 1. While the numerical quotas for the U.S. and the European markets remained unchanged so far, China focused on raising unit prices and upgrading its garment products, and successfully developed non-quota markets, especially Japan.<br>2. In addition to privatized enterprises, large township and village enterprises, foreign companies export garment of even quality in large quantities. Therefore, the export ratio to the US is high. Obsolete equipment is being replaced.<br>3. In the 1980, large amounts of foreign investments including Japan were made in Nantong City and Ningbo City, etc., primarily in synthetic fiber plants, making China a major synthetic fabric supplier.<br>4. Successfully established Chinese brands (Shanshan, Yangar, Matsuoka, etc).<br>5. Marked improvement in garment-manufacturing skills, such as from men's shirts to women's dress shirts and ensembles.<br>6. A characteristic of China's garment products is an extensive product line, from low-priced, basic items to high-priced, luxury items. In recent years, technology transfer from Japan has made progress in weaving technology (e.g., shrink-proof, loose-yarn proof) and garment-making skills (e.g., careful sewing), further upgrading products to high-priced, luxury items. In addition, about 2000 Japanese garment companies run businesses in China. However, general speaking, compared with luxury items from | 1. As exports have increased steadily thanks to about 10 percent increases annually in numerical quotas to the US and the EU so far, India has not made much effort in raising prices and upgrading its products. It is weak in developing non-quota markets, including Japan.<br>2. Exports consisted mostly of small-lot exports by SMEs of products in different designs and colors. The export ratio to the EU is high. It has been slow in replacing obsolete equipment. Production efficiency is lower than China and other south Asian countries.<br>3. However, there is strong US and EU demand for shirts, blouses, trousers and skirts made of soft Indian cotton, and India is highly competitive. In the US, India's women's cotton woven-fabric blouses and cotton dresses occupy the first and second place, respectively, in their categories. In men's cotton woven-fabric shirts, India has the third largest share in the US. These products are also strong in the EU market. In both markets, export amounts of these products are the same or double those of China.<br>4. Soft cotton Madras plaid pants, made of fine gauge cotton fabric for exports, are unrivalled.<br>5. As India has depended on Western buyers, it has been rather slow in establishing own company brands.<br>6. It has some accumulation of skills in making light garments, such as sari, but not in heavy garments, such as coats and suits.<br>7. India's production efficiency is the lowest among the four South Asian countries. In 2005, it was approximately 70% that of Bangladesh and an estimated 60% that of China, though India aims at |

Poland, Romania, Morocco and Tunisia, which have traditionally exported to the EU market, which traditionally has had rich culture and high fashion sense, unit prices of luxury items from China are 25% to 10% lower. Further improvements, therefore, are required.

7. In addition to the improvement in products, China has made the following administrative reforms in the 1990s.
8. The Ministry of Spinning and Weaving Industry of the central government, which controls enterprises run by the central government, scaled down into the Bureau of Spinning and Weaving Industry and placed under the State Economic and Trade Commission, to change its role from mainly administrative guidance to primarily industrial policy.
9. The government has abolished the divisions of Spinning and Weaving Industry of local governments, which controls regional state-run enterprises, and reorganized them into the Textile and Garment Associations. The Associations, as semi-governmental trade associations under the central federation of associations, provide market information, support for new product development and management guidance to their member firms.  They also encourage voluntary regulation by the industry.

improving it. Pro-labor labor laws and the lingering practice of not wanting to work with people from lower castes stand in the way of productivity improvement.

8. As many low-productivity shuttle spinners are used, the government, in anticipation of the abolition of the MFA in 2005, encouraged the shift to jet spinners with financial and fiscal measures.
9. The Ministry of Textiles presented New Textile Policy 2010 and made the following proposals:

i) For technology modernization in the textile industry, an interest subsidy of 5% a year will be extended to plant and equipment investment through 2004. To authorize a 50% accelerated depreciation for plant and equipment investment in the textile and garment-making industries. For the textile sector, other than knitted products, 100% foreign-owned companies are to be authorized. Import tariffs on equipment to be used in the production of textiles and garment products for exports are to be reduced from 15% to 5%.

ii) A sales tax exemption has been granted to smaller enterprises, such as handicraft-type dyeing plants and also non-integrated dyeing plants. As this has hampered the improvement of dyeing technology, and because the government is aware that the dyeing sector is the sector that lags most, it abolished these tax incentives that hamper technology advancement.

iii) There is no change in the policy that earmarks cotton materials for exports and chemical and synthetic materials for domestic demand.

iv) Apparel parks, apparel international marts and other facilities for export promotion should be established.

Source: Compiled by JICA Study Team

- ទោះបីប្រទេសកម្ពុជានៅពេលបច្ចុប្បន្ននេះពុំមានក្រុមហ៊ុនកាត់ដេរជប៉ុនក៏ដោយ ក៏សហគ្រាសជប៉ុន មួយចំនួនកំពុងពិនិត្យមើលលទ្ធភាពចាប់ផ្តើមដំណើរការធុរៈកិច្ច "កាត់ដេរស៊ីកំរៃជើងសារ" ចំពោះទំនិញមូលដ្ឋាននៅ ក្នុងប្រទេសកម្ពុជា នៅពេលមានការកែលំអរបរិដ្ឋានវិនិយោគទុននៅក្នុងប្រទេសតាមរយៈកិច្ចខិតខំប្រឹងប្រែងពីក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដោយសារកំណើនឈ្នួលពលកម្ម និងការកើនឡើង រូបិយវត្ថុនៅក្នុងប្រទេសថៃ និងចិន កំណើនឈ្នួលពលកម្ម ការលំបាកក្នុងការជ្រើសរើសកំលាំងពលកម្ម និងការចាក ចេញជាច្រើនពីឧស្សាហកម្មកាត់ដេររបស់និយោជិក ដែលមានទេពកោសល្យនៅក្នុងប្រទេសវៀតណាម ។ ការអង្កេត តាមរយៈបទសម្ភាសធ្វើឡើងដោយក្រុមសិក្សា JICA បានឱ្យដឹងថា

ការកាត់ដេរស៊ីកំរៃជើងសារសំរាប់ការនាំចេញទៅ កាន់ប្រទេសជប៉ុននៃប្រភេទមុខទំនិញនានាមានលក្ខណៈ វិនិច្ឆ័យ ដែលគួរឱ្យទាក់ទាញដូចខាងក្រោម :

- ទំនិញដែលមិនត្រូវការក៏រិតជំនាញខ្ពស់ ។
- តំរូវការមិនសូវប្រែប្រួលខ្លាំង ។
- ពុំមានការកែប្រែរចនាបថ (ស្ទីល) និង
- ស្តង់ដាគុណភាពពុំមានភាពស្មុគស្មាញ ។ ផលិតផលទាំងនោះរួមមានសំលៀកបំពាក់សំរាប់ធ្វើការ ងារ សំលៀកបំពាក់ឯកសណ្ឋាន អាវ សំរាប់ការងារការិយាល័យ អាវធំ និងអាវស្វូត្រ (ប៉ូឡូ) អាវយឺត ខោជើងវែង ស្រោមជើង សំលៀកបំពាក់ក្នុង និងសំលៀកបំពាក់ដំណេក ។

### ៥.១.២ ការវិភាគ SWOT (ភាពខ្លាំង ភាពខ្សោយ ឱកាស និងគ្រោះគំរាម) នៃផលិតផលកាត់ដេរប្រទេសកម្ពុជា

**តារាង ៥-១-៣ ការវិភាគ ចំណុចខ្លាំង ខ្សោយ កាលានុវត្តន៏ភាព និងគំរាមកំហែង**

| | Strengths | Weaknesses | Opportunities | Threats |
|---|---|---|---|---|
| **Sales** | · Leveraged by low wages to meet US demand for low-priced items, it is strong as a production base of small-variety, large-lot orders.<br>· Although the profit ratio before income tax is an average of 5-6%, the abundance of orders can maximize the amount of profits.<br>· Since it abided by the ILO standards even before the abolition of MFA, US quotas have increased by an average 15% per annum. | · As 90% of orders are via Western buyers or agents, a few Cambodian firms have their own sales channels. Sales are primarily sewing-on-commission and there is very little develop-and-export schemes.<br>· As production sites are far from export markets, it is difficult to make quick deliveries in response to changes in fashion. | · If the garment industry establishes antenna shops in major overseas markets and builds its own sales channels, markets will develop.<br>· Against the backdrop of rising wages, labor shortages and strong local currencies, some Japanese garment makers in China, Vietnam and Thailand are contemplating starting sewing-on- commission in Cambodia for exports to Japan. If they enter Cambodia, it will provide quality improvements and market diversification. | · Future rivals to some extent are Bangladesh, which makes similar items, Vietnam after 2007 (WTO accession), and China after 2009 (removal of safeguards).<br>· When the safeguards against China are removed in Jan. 2009, if the Chinese yuan currency is not depreciated soon, garment exports from Cambodia may face challenge. |

| | Strengths | Weaknesses | Opportunities | Threats |
|---|---|---|---|---|
| Production | • Cambodia has an accumulation of garment-making skills for more than 250 foreign firms, which are bigger than those of Lao PDR.<br>• In China, Vietnam and Thailand, talented workers go to the auto or electrical machinery and electronics industries, not going to garment industry which pass by its peak. However, in Cambodia, since the garment industry is the largest exporter, it is easy to recruit talented workers, comparatively.<br>• Although Cambodia's garment industry is only half as old as that in Bangladesh and Vietnam, its production efficiency is up to 90% of Bangladesh and Vietnam. Though its productivity is lower at 90% level than China, it is higher than Laos, which does not have the accumulation of skills.<br>• Labor cost is lower than in Thailand, China and Vietnam. | • Since exports center on simple knitted products, in many items, unit prices are below the world average import unit prices in the Western markets, resulting in low added-value. At a minimum, it is necessary to upgrade to woven-fabrics products.<br>• Cambodia must import all materials due to the absence of the upstream sectors, such as knit yarn spinning plants, fabric weaving plants and the dyeing sector.<br>• Lead-time for material imports and product exports is long, and shipping costs are high. As infrastructure cost is high due to its under-development, low wages are considerably offset by such costs, partly. | • The introduction of Japanese quality control standards should contribute to increase unit prices of exports.<br>• If offshore oil, which is under development, is used for electric power, power rates, which are in excess of 15 cents, should be reduced.<br>• In the medium and long terms, if an East-West corridor is built in the South Indo-China, it will enable purchases of Japanese firm-made, high quality materials from Thailand via land. Inspection institutes at Ho Chi Minh and exports from HCM to the US, the EU and Japan are a possibility. | • Due to the long lead-time, it is difficult to quickly respond to fashion changes in the Western markets.<br>• The imminent problem is the increase in the minimum wage. Though unions are demanding the increase from $45/mo. To $80/mo., it is likely to be settled at around $60. As this will be the same as in Vietnam, production efficiency needs to be improved further. However, it is getting more and more difficult to find garment workers in Vietnam. |

| | Strengths | Weaknesses | Opportunities | Threats |
|---|---|---|---|---|
| Government policy | • An improvement of investment circumstances in Cambodia great efforts by CDC/CIB<br>• Honoring the ILO standards is linked to US orders.<br>• Due to GSP for the Western countries, import tariffs to these countries are low.<br>• Business management in the garment industry is not interrupted as in Myanmar to be an insecure position, where ultra-legal changes in laws are frequent. | • The number of legal holidays (national holidays and paid vacation) is one of the largest countries in Asia. | • As the garment industry will remain as the largest export industry, if infrastructure is developed and the upstream sectors and supporting industrial sectors introduced, Cambodia's competitiveness will be enhanced further.<br>• The government should continue to attract foreign firms that have new markets, new technology and new designs. | • It is undeniable that under a pro-labor law, employee discontent tends to emerge as labor strikes. |

Source: Compiled by JICA Study Team

## ៥.២ ទស្សនវិស័យសំរាប់ឧស្សាហកម្មកាត់ដេរកម្ពុជា: ការប្រែប្រួលក្នុងបរិស្ថានអន្តរជាតិ និងសេណារីយោ អនាគតសំរាប់ការអភិវឌ្ឍន៍រយៈពេលមធ្យម និងវែង ដែលត្រូវសិក្សាក្នុងអណត្តិ៧ឆ្នាំ ។

ទស្សនៈវិស័យសំរាប់ឧស្សាហកម្មកាត់ដេររបស់កម្ពុជា អាចត្រូវបានសិក្សាជា ៦ រយៈពេលដូចខាងក្រោម :

### ៥.២.១ ផលប៉ះពាល់ពីការដកចេញនូវកិច្ចព្រមព្រៀង MFA នៅខែមករា ឆ្នាំ២០០៥

(១) មុននឹងមានការលុបបំបាត់កិច្ចព្រមព្រៀង MFA (Multi-Fibre Agreement) (ខែធ្នូ ឆ្នាំ២០០៤) ឧទារហរណ៍ ការនាំទំនិញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប នៃផលិតផលកាត់ដេរប្រទេសចិនបានរងនូវភាពរាំងស្ទះ ។

**តារាង ៥-២-១ អត្រាកំណើននៃកូតាមូលដ្ឋានរបស់សហរដ្ឋអាមេរិក សំរាប់គូរប្រជែងនៅអាស៊ីសំខាន់ៗ**

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 (4) first half |
|---|---|---|---|---|---|---|---|---|---|---|---|
| Bangladesh | 8.1 | 8.1 | 8.1 | 10.2 | 10.2 | 10.2 | 10.2 | 12.9 | 12.9 | 12.9 | 21.5 |
| China | - | - | 1.7 | 0.1 | 1.7 | 1.7 | 1.7 | 0.4 | 2.4 | 2.0 | 94.3 |
| India | 6.7 | 6.7 | 6.7 | 8.4 | 8.4 | 8.4 | 8.4 | 10.6 | 10.6 | 10.6 | 34.4 |
| Indonesia | 6.2 | 6.2 | 5.5 | 7.7 | 7.7 | 7.7 | 7.7 | 8.3 | 9.8 | 9.8 | 15.1 |
| Pakistan | 7.6 | 11.9 | 7.6 | 9.2 | 9.4 | 9.5 | 9.5 | 14.9 | 12.0 | 12.0 | 6.9 |
| Sri Lanka | 6.1 | 6.2 | 6.2 | 7.7 | 7.7 | 7.7 | 7.7 | 6.3 | 9.7 | 9.7 | 16.4 |
| Thailand | 6.1 | 6.1 | 6.1 | 6.0 | 7.6 | 7.6 | 7.6 | 7.6 | 9.6 | 9.6 | 6.4 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| Vietnam | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | 6.0 | -0.9 |
| CIB | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | n.q. | 1.2 |
| Mexico | | | | | | | | | | | -9.4 |
| World | | | | | | | | | | | 9.5 |

Note: n.q. = non-quota. The Anti-China Safeguard is another quota system, only for China, that commenced in the second half of 2005. Table shows the percentage change per year.
Source: Compiled from OTEXA

**(២)** បន្ទាប់ពីការលុបចោលនូវកិច្ចព្រមព្រៀង MFA តំរូវការសំរាប់ផលិតផលដែលផលិតនៅក្នុងបណ្តាប្រទេសតំបន់ពាណិជ្ជកម្មសេរី អាមេរិកខាងជើង (NAFTA) ជាពិសេសបណ្តាប្រទេសស្ថិតនៅតំបន់សមុទ្រការ៉ាបៀន (CBITA : ច្បាប់ដៃគូពាណិជ្ជកម្មនៃអាងសមុទ្រការ៉ាបៀន) និងក្នុងករណីទីផ្សារសហគមអឺរ៉ុបពីអាហ្វ្រិកខាងជើង អឺរ៉ុបខាងកើត និងកណ្តាល (ប្រទេសដែលមានពាណិជ្ជកម្មកែច្នៃសំរាប់នាំចេញ OPT Countries: Outward Processing Trade) បានងាកទៅរកតំរូវការផលិតផលដែលផលិតនៅក្នុងប្រទេសអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍រួមទាំងប្រទេសកម្ពុជាផងដែរ ។

*(i)* យោងតាមគោលការណ៍ NAFTA សំលៀកបំពាក់ដែលផលិតនៅក្នុងប្រទេសអាមេរិកឡាទីនដោយប្រើប្រាស់វាយនភ័ណ្ឌសហរដ្ឋអាមេរិកបាននាំចូលទៅក្នុងទីផ្សារសហរដ្ឋអាមេរិកដោយគ្មានកូតា និងពុំមានបង់ពន្ធនាំចូល ។ យោងតាមគោលការណ៍ពាណិជ្ជកម្មកែច្នៃសំរាប់នាំចេញ (OPT) សំលៀកបំពាក់ដែលផលិតនៅអាហ្វ្រិកខាងជើង និងសហគមអឺរ៉ុបកណ្តាល និងខាងកើត ដែលប្រើប្រាស់វាយនភ័ណ្ឌសហគមអឺរ៉ុប ត្រូវបាននាំចូលទៅកាន់ទីផ្សារសហគមអឺរ៉ុបដោយគ្មានកូតា និងពុំមានបង់ពន្ធនាំចូល ។ បណ្តាប្រទេស ដែលស្ថិតក្រោមគោលការណ៍នេះ បានបាត់បង់ផលប្រយោជន៍យ៉ាងច្រើនពីស្ថានភាពគ្មានកូតា បន្ទាប់ពីការលុបចោលកិច្ចព្រមព្រៀង MFA ។ ជាលទ្ធផល តំរូវការរបស់ទីផ្សារសហរដ្ឋអាមេរិក និងសហគមអឺរ៉ុប ចំពោះផលិតផលសំលៀកបំពាក់ដែលបានផលិតនៅក្នុងបណ្តាប្រទេសស្ថិតនៅតំបន់សេដ្ឋកិច្ចសេរីអាមេរិកខាងជើង ឬប្រទេសដែលមានពាណិជ្ជកម្មកែច្នៃសំរាប់នាំចេញ (OPT) (ដែលតំលៃសំលៀកបំពាក់នៅបណ្តាប្រទេសទាំងនោះមានតំលៃខ្ពស់ជាងបណ្តាប្រទេសនៅអាស៊ី) អាចត្រូវជំនួសដោយតំរូវការសំលៀកបំពាក់ដែលផលិតនៅក្នុងបណ្តាប្រទេសអាស៊ី និងប្រទេសផ្សេងៗទៀតដែលស្ថិតនៅក្រៅគោលការណ៍ខាងលើហើយមានតំលៃថោក ។ ហេតុដូច្នេះហើយ ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង សហគមអឺរ៉ុបពីតំបន់អាស៊ីបានមានការប្រែប្រួលយ៉ាងខ្លាំង ។

**តារាង ៥-២-២ អត្រានាំចូលរបស់សហរដ្ឋអាមេរិក តាមតំបន់**

| | 1995 | 2000 | 2004 | 2005 |
|---|---|---|---|---|
| Asia | 63.8 | 55.0 | 60.2 | Increasing |
| Middle and South America | 22.4 | 30.2 | 15.7 | Decreasing |
| Western Europe | 6.8 | 5.9 | 5.9 | Stable |
| North America | 2.2 | 3.0 | 11.5 | Decreasing |
| Middle East | 2.1 | 2.2 | 2.7 | Stable |
| Africa | 1.8 | 2.0 | 3.2 | Stable |

| | | | | |
|---|---|---|---|---|
| Central Europe, East Europe and Russia | 1.0 | 1.2 | 0.8 | Stable |
| Total | 100.0 | 100.0 | 100.0 | 100.0 |

Note: No available figures for 2005. Unit: %.
Source: Compiled by JICA Study Team based on WTO International Statistics

### តារាង ៥-២-៣ អត្រានាំចេញរបស់សហរដ្ឋអាមេរិក តាមតំបន់

| | 1995 | 2000 | 2004 | 2005 |
|---|---|---|---|---|
| Western Europe | 51.7 | 47.4 | 50.8 | Stable |
| Asia | 30.1 | 32.4 | 35.8 | Increasing |
| Central Europe, East Europe and Russia | 8.3 | 10.3 | 5.8 | Decreasing |
| Africa | 6.9 | 7.7 | 6.3 | Stable |
| Middle East | 1.2 | 0.9 | 0.5 | Decreasing |
| North America | 1.1 | 0.7 | 0.5 | Decreasing |
| Central Europe, East Europe and Russia | 0.5 | 0.4 | 0.3 | Stable |
| Total | 100.0 | 100.0 | 100.0 | 100.0 |

Note: No available figures for 2005. Unit: %
Source: Compiled by JICA Study Team based on WTO International Statistics

*(ii)* ការថយចុះនូវបរិមាណវិភាគទៅលើផលប៉ះពាល់នៃការនាំចេញផលិផលសំលៀកបំពាក់ពីបណ្តាប្រទេសជាច្រើននៅអាស៊ីទៅកាន់ទីផ្សារសហរដ្ឋអាមេរិកដោយប្រើប្រាស់វិបរិណាមមិនពិត ដែលយក MFA ជាអាញ្ញតិតំណាងបង្ហាញថា MFA ឆ្នាំ២០០៥ មានមានផលប៉ះពាល់ជាវិជ្ជមានច្បាស់លាស់ទៅលើប្រទេសចិន (*"LnChinagarex = 22.59 + 1.24 MFA"*)[១] និងទៅលើប្រទេសឥណ្ឌា (*"LnIndiagarexp = 21.47 + 0.78 MFA"*)[2]។ ការវិភាគនេះ ក៏បានបញ្ជាក់ផងដែរថា ផលប៉ះពាល់នៃកិច្ចព្រមព្រៀង MFA ឆ្នាំ២០០៥ ក៏មានផលជាវិជ្ជមានទៅលើប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមិនទាន់អភិវឌ្ឍន៍មួយចំនួន ដែលប្រទេសទាំងនោះមានឧស្សាហកម្មផលិតសំលៀកបំពាក់ខ្លាំងជាងប្រទេសគ្មានការអភិវឌ្ឍន៍ផ្សេងៗទៀត ដូចជាប្រទេសកម្ពុជា (*"LnCamgarexp = 17.08 + 4.19 MFA"*)[3] និង បង់ក្លាដែស (*"LnBanglagarexp = 21.09 + 0.53 MFA"*)[4]។ ហេតុនេះ អាចបកស្រាយបានថាផលប៉ះពាល់នៃកិច្ចព្រមព្រៀង MFA ឆ្នាំ២០០៥

---

1 LnChinaexp តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់ចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង MFA គឺជាអថេរដាំមី តំណាងឱ្យឥទ្ធិពល MFA ឆ្នាំ២០០៥។

2 LnIndiagarexp តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់ឥណ្ឌាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង MFA តំណាងឱ្យឥទ្ធិពល MFA ឆ្នាំ២០០៥។

3 LnCamgarexp តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង MFA គឺជាអថេដាំមី តំណាងឱ្យឥទ្ធិពល MFA ឆ្នាំ២០០៥។

4 LnBanglagarexp តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់បង់ក្លាដែសទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង MFA គឺជាអថេរដាំមី តំណាងឱ្យឥទ្ធិពល MFA ឆ្នាំ២០០៥។

ពុំមានផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រទេសកម្ពុជាទេ ដោយសារកម្ពុជាមានឧត្តមភាពប្រៀបធៀបខ្ពស់ខាងផលិតផលកាត់ដេរសំលៀកបំពាក់។ ភស្តុតាងមួយបង្ហាញថា ការនាំផលិតផលសំលៀកបំពាក់ពីប្រទេសចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានកើនឡើងប្រមាណ ៥3% នៅឆ្នាំ២០០៥ ហើយការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានកើនឡើងគិតជាតំលៃចំនួន ២០%។

### ៥.២.២ ផលប៉ះពាល់នៃវិធានការណ៍ការពារសុវត្ថិភាពទៅលើផលិតផលសំលៀកបំពាក់ធ្វើនៅប្រទេសចិនចាប់ពីខែមិថុនា ឆ្នាំ ២០០៥

ដោយសារលំហូរចូលដ៏ច្រើនលើសលប់នូវវាយនភ័ណ្ឌ និងផលិតផលកាត់ដេរពីប្រទេសចិនក្នុងអំឡុងពេលនៃកាលុបចេញនូវកិច្ចព្រមព្រៀង MFA សហរដ្ឋអាមេរិក និងសហគមនអឺរ៉ុបបានចាប់ផ្តើមដាក់បំរាមការនាំសំលៀកបំពាក់ចេញពីប្រទេសចិន។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ សហរដ្ឋអាមេរិកចាប់ផ្តើមដាក់បំរាមលើប្រទេសចិននូវការនាំចូលអាវបុរស និង ស្ត្រីធ្វើពីកំណាត់កូតុង ខោជើងវែងកូតុង ខោធម្មតា និងខោខ្លី និងសំលៀកបំពាក់ក្នុងកូតុង និងធ្វើពី MFF ផលិតក្នុងប្រទេសចិន។ នៅថ្ងៃទី២៧ ខែឧសភា សហអាមេរិកបានដាក់កំរិតលើការនាំចូលនូវអំបោះកូតុង និងអាវ (មិនមែនចាក់)របស់បុរស និងក្មេងប្រុស ផលិតពីកូតុង និង អាវបុរស និងស្ត្រីផលិតពី MMF និងខោផលិតពី MMF ។ បំរាមនេះបង្ហាញថា ប្រភេទសំលៀកបំពាក់ផ្សេងៗដែលរងនូវការហាមឃាត់គឺជាប្រភេទសំលៀកបំពាក់ដែលកូតាមានការតឹងរឹងបំផុតក្នុងរបប ATC។ បន្ទាប់ពីមានវិធានការទាំងនេះ និងសំណើរបន្ថែមឱ្យមានសកម្មភាពសុវត្ថិភាព សហរដ្ឋអាមេរិក និងចិនបានឯកភាពគ្នាទៅលើកិច្ចព្រមព្រៀងដ៏ទូលំទូលាយមួយនៅខែវិច្ឆិកា ឆ្នាំ២០០៥។ ដើម្បីធានាការចូលទៅដល់ទីផ្សារសហរដ្ឋអាមេរិក ប្រទេសចិនបានឯកភាពជាមួយសហរដ្ឋអាមេរិកលើការកំរិតការនាំចេញសំលៀកបំពាក់ចំនួន ៣៤ ប្រភេទ សំរាប់រយៈពេល ៣ ឆ្នាំ ដែលមានចំនួនប្រមាណជា ៤៦% នៃការនាំចេញវាយនភ័ណ្ឌ និងសំលៀកបំពាក់ចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលជាហេតុធ្វើឱ្យការនាំចេញសំលៀកបំពាក់នៅឆ្នាំ២០០៦ មិនមានកំណើនច្រើនជាង ១០ ភាគរយ (ជាមធ្យម) បើប្រៀបទៅនឹងឆ្នាំកន្លងទៅ និងមិនលើស១២,៥ ភាគរយ (ជាមធ្យម)នៅឆ្នាំ២០០៧ និងមិនលើស ១៧ ភាគរយ (ជាមធ្យម) នៅឆ្នាំ ២០០៨។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ សហគមន៍អឺរ៉ុប និងប្រទេសចិន ក៏បានរៀបចំអនុសាសន៍យល់ដឹងមួយទាក់ទងនឹងការនាំចូលផលិតផល ១០ ប្រភេទពីប្រទេសចិន ការកំណត់កំរិតកូតាសំរាប់រយៈពេលនៅសល់នៃឆ្នាំ២០០៥ និងឆ្នាំ២០០៦ និងឆ្នាំ២០០៧ ដែលអនុញ្ញាតអោយមានកើនឡើងក្នុងការនាំចេញប្រមាណជា ១០ ភាគរយក្នុង ១ ឆ្នាំៗ។

### តារាង ៥-២-៤ និន្នាការនៃការនាំចូលផលិតផលកាត់ដេររបស់សហរដ្ឋអាមេរិក

| 1.1 | Jan. –May 2006 (Value) | | Jan.-May 2006 (Unit volume) | |
|---|---|---|---|---|
| | million $ | Y-o-y increase | Million m2 | Y-o-y increase |
| World | 25749 | -0.9 | 8134 | -3.0 |
| China | 5051 | -8.1 | 1788 | -12.6 |
| Mexico | 2128 | -14.1 | 617 | -14.0 |
| Pakistan | 4711 | 6.0 | 252 | 14.5 |
| South Korea | 372 | -14.6 | 127 | 0.2 |
| India | 1549 | 19.5 | 395 | 13.4 |
| Indonesia | 1370 | 24.7 | 392 | 16.8 |
| Honduras | 919 | -14.2 | 431 | -14.2 |
| Bangladesh | 1074 | 25.1 | 499 | 17.9 |
| Thailand | 724 | 4.5 | 225 | 8.1 |
| Vietnam | 1222 | 28.9 | 359 | 24.9 |
| El Salvador | 498 | -26.9 | 250 | -29.8 |
| Hong Kong | 1094 | 20.9 | 196 | 20.0 |
| Dominican Republic | 617 | -18.9 | 238 | -20.3 |
| Cambodia | 767 | 30.0 | 309 | 32.3 |
| The Philippines | 769 | 16.1 | 236 | 23.1 |
| Sri Lanka | 766 | 1.1 | 182 | -0.6 |

Source: 'Trade Data: U.S. Imports and Exports of Textiles and Apparel', (Department of Commerce in the US, July 2006).

ការវិភាគស្ថិតិរីក្រេស៊ិនទៅលើការនាំសំលៀកបំពាក់ចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដោយប្រើបរិណាមមិនពិតដោយយកផលប៉ះពាល់នៃវិធានការសុវត្ថិភាពមុខទំនិញ ឆ្នាំ២០០៦ ជាអញ្ញត្តិ (*"LnChinagarexpQ = 21.78 – 1.25 D"*)[5] បង្ហាញពីទំនាក់ទំនង អវិជ្ជមានសំរាប់ការនាំសំលៀកបំពាក់ចិន ប៉ុន្តែមានផលវិជ្ជមានចំពោះការនាំសំលៀកបំពាក់ចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិករបស់កម្ពុជា (*"LnCamgarexpQ = 17.14 + 6.41 D"*)[6] ។ ការវិភាគស្ថិតិនេះបង្ហាញថា វិធានការសុវត្ថិភាពទំនិញដែលសហរដ្ឋអាមេរិកបានបង្កើតឡើងមានផលប៉ះពាល់អវិជ្ជមានមួយចំនួនទៅលើការនាំផលិតផលកាត់ដេរចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ប៉ុន្តែមានផលប៉ះពាល់វិជ្ជមានទៅលើការនាំផលិតផលសំលៀកបំពាក់របស់កម្ពុជា ទោះបីផលប៉ះពាល់ទាំងនោះមិនបង្ហាញឱ្យឃើញជាក់ស្តែងនៅគ្រប់ករណីក៏ដោយ ។ ផលប៉ះពាល់នេះបង្ហាញថា តំរូវការផលិតផលប្រទេសចិនមួយផ្នែកអាចត្រូវជំនួសដោយផលិតផលផ្សេងៗផលិតក្នុងប្រទេសកម្ពុជា[៧] និងប្រទេសផ្សេងៗទៀត ។

---

5 *LnChinagarexpQ* តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង D គឺជាអថេរដាំមី ដោយយកវិធានការការពារទំនិញ ដែលបានបង្កើតឡើងដោយសហរដ្ឋអាមេរិក ឆ្នាំ ២០០៦ ។

6 *LnCamgarexpQ* តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និងបង្ហាញពីទំនាក់ទំនង វិជ្ជមាន ។

7 ការវិភាគស្ថិតិរីក្រេស៊ិនត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រស្ថិត Minitab និង Sgwin

### ៥.២.៣ ការប្រែប្រួលក្នុងវិស័យឧស្សាហកម្ម និងផលប៉ះពាល់នៃការប្រែប្រួលទាំងនោះ : ការឡើងប្រាក់ឈ្នួល អត្រាឈប់ធ្វើការងារខ្ពស់របស់កម្មករ និងកង្វះខាតកំលាំងពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរក្នុងប្រទេស ចិន វៀតណាម និងថៃ និងការឡើងនៃតំលៃរូបិយវត្ថុក្នុងស្រុករបស់ប្រទេសចិន និងថៃ

**(1)** នៅក្នុងប្រទេសចិន វៀតណាម និងថៃ រចនាសម្ព័ន្ធឧស្សាហកម្មកំពុងមានការប្រែប្រួល ពោលគឺ ឧស្សាហកម្មផលិតសំលៀកបំពាក់ដែលជាឧស្សាហកម្មដ៏ធំនៅក្នុងប្រទេសទាំងនេះត្រូវចូលមកជំនួសដោយឧស្សាហកម្ម អគ្គិសនី គ្រឿងអេឡិចត្រូនិច និងឧស្សាហកម្មរថយន្ត ហើយការប្រែប្រួលនេះបានចេញជារូបរាងយ៉ាងច្បាស់ចាប់តាំង ពីដើមឆ្នាំ២០០៦។ ជាលទ្ធផល ការកើនឡើងនូវប្រាក់ឈ្នួល អត្រាឈប់ពីការងារមានកំរិតខ្ពស់ និងកង្វះខាតកំលាំង ពលកម្មក្នុងឧស្សាហកម្មផលិតផលសំលៀកបំពាក់នៅក្នុងប្រទេសទាំងបីនេះកាន់តែមានភាពធ្ងន់ធ្ងរ នៅពេលដែលមាន ការឡើងតំលៃរូបិយវត្ថុក្នុងស្រុក។ ជាឧទាហរណ៍ នៅក្នុងប្រទេសចិន កាលពីខែឧសភា លោក Su Hai Nan នាយក នៃវិទ្យាស្ថានសំរាប់ការសិក្សាស្តីកំលាំងពលកម្ម និងប្រាក់ឈ្នួលនៃក្រសួងការងារ និងសន្តិសុខសង្គមបានអះអាងថា "តំលៃឈ្នួលពលកម្មនៅក្នុងប្រទេសចិនអាចកើនឡើងថែមទៀត។ ទោះជាយ៉ាងណា ក៏ការធ្វើផែនការអភិវឌ្ឍន៍រយៈ ពេលវែងមិនគួរពឹងផ្អែកទៅលើការកើតឡើងនូវការប្រកួតប្រជែងដែលបានមកពីប្រាក់បៀវត្សទាបនោះទេ"។ លោក Su Hai Nan បានជំទាស់ចំពោះការកើនឡើងតំលៃបន្ថែមនៃឧស្សាហកម្មទាំងនេះ ដោយបានអះអាងថា "ប្រព័ន្ធ សំរាប់ការលក់ដូរអាវដែលមានចំនួន ១,២កោដិ គួរផ្លាស់ប្តូរទៅជាប្រពន្ធ័សំរាប់ការផលិតយន្តហោះ Jumbo មួយ គ្រឿងវិញ"។

*(i)* ការវិភាគបង្ហាញថា ការធ្លាក់ចុះតួលេខនៃការនាំចេញផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋ អាមេរិកដោយប្រើប្រាស់កំរិតប្រាក់ឈ្នួលរយៈពេលផ្សេងៗនៃកំរិតប្រាក់ឈ្នួលនៅក្នុងប្រទេសចិន (ពោលគឺ *"Camexpgrowth = 8.66 + 50.40 Chinawage"*)[8] បង្ហាញថា កំណើនប្រាក់ឈ្នួលនៅក្នុងវិស័យកម្មន្តសាល ក្នុងប្រទេសចិនមានប្រវត្តិទាក់ទងគ្នាជាវិជ្ជមានទៅនឹងកំណើននៃការនាំចេញក្នុងវិស័យសំលៀកបំពាក់កម្ពុជាកាល ពីអតីតកាល ទោះបីទំនាក់ទំនងនេះពុំមានសារៈសំខាន់ជាស្ថិតិក៏ដោយ។ មានន័យថា ការនាំចេញសំលៀកបំពាក់ ខ្មែរអាចមានកំណើន នៅពេលកំរិតប្រាក់បៀវត្សក្នុងប្រទេសចិនមានការកើនឡើង។ កំណើនប្រាក់ឈ្នួលនៅក្នុង ប្រទេសចិនអាចជំរុញឱ្យឧស្សាហកម្មផលិតសំលៀកបំពាក់មួយចំនួនប្តូរពីប្រទេសចិនមកប្រទេសកម្ពុជាដែល បណ្តាលមកពីកំណើននៃការនាំចេញសំលៀកបំពាក់ពីប្រទេសកម្ពុជា។

*(ii)* នៅក្នុងប្រទេសវៀតណាម ក្រឹត្យរបស់នាយករដ្ឋមន្ត្រីលេខ 03/2006/ ND-CP បានស្នើអោយតម្លើង

ហើយប្រភពទិន្នន័យគឺក្រសួងពាណិជ្ជកម្មរបស់ សហរដ្ឋអាមេរិក។

8 Camexgrowth គឺជាកំណើននៃការនាំសំលៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង Chinawage គឺជាកំរិតប្រាក់ឈ្នួលចិនក្នុងវិស័យ កាត់ដេរ។

ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករគ្មានជំនាញ និងហត្ថករបំរើការនៅតាមសហគ្រាសបរទេស។ កាលពីមុន មុនក្រឹត្យច្បាប់នេះ ប្រាក់ឈ្នួលប្រចាំខែរបស់កម្មករមានចំនួនប្រហែល ៥០០.០០០ ដុង (៣១.៦ ដុល្លារអាមេរិក) ដែលផ្តល់អោយដោយក្រុមហ៊ុនតៃវ៉ាន់ភាគច្រើន ហើយចំនួនជាង ៧០០.០០០ ដុង (៤៤.៣៥ ដុល្លារអាមេរិក) ផ្តល់អោយដោយក្រុមហ៊ុនជប៉ុន ហើយចំនួន ៨០០.០០០ ដុង (៥០.៦ ដុល្លារអាមេរិក) ផ្តល់អោយដោយក្រុមហ៊ុនមកពីសហគមអឺរ៉ុប[9]។ បូកផ្សំនឹងប្រាក់កំរៃផ្សេងៗទៀត កម្មករភាគច្រើនមានប្រាក់ឈ្នួលប្រចាំខែចំនួន ១ លានដុង (៦៣ ដុល្លារអាមេរិក) ក្នុងមួយខែៗ។ នៅពេលនេះ ក្រឹត្យច្បាប់បានប្រកាសបង្កើនតំលើងប្រាក់ឈ្នួលអប្បបរមាពី ៤៥ ដុល្លារអមេរិក ទៅ ៥៥ ដុល្លារអាមេរិក ក្នុងមួយខែ នៅតាមតំបន់ក្នុងទីក្រុងហាណូយ និងហូជីមីញ ពី៤០ ដុល្លារអាមេរិក ទៅ៥០ ដុល្លារអាមេរិក នៅតាមតំបន់ជាយក្រុងធំៗ និងនៅក្នុងទីក្រុងសំខាន់ៗ និងទីក្រុងជាប់កំពង់ផែ និងពី៣៥ ដុល្លារអាមេរិក ទៅ ៤៥ ដុល្លារអាមេរិក នៅតាមទីតំបន់ផ្សេងៗទៀត។ រួមផ្សំនឹងប្រាក់កំរៃផ្សេងៗទៀត កម្មករនឹងទទួលបានប្រាក់ខែប្រមាណជា ១០០ ដុល្លារអាមេរិក ដែលចំនួននេះគឺជាកំណើនយ៉ាងខ្ពស់។ ក្រសួងការងារ អតីតយុទ្ធជន និងសង្គមកិច្ច (Molisa) ប៉ាន់ស្មានថា ក្រឹត្យច្បាប់ថ្មីនេះនឹងនាំឱ្យមានកំណើនប្រមាណជា ៤០ ភាគរយ។ កំណើនដូច នេះអាចជំរុញឱ្យការធ្វើសេចក្តីសំរេចរបស់អ្នកវិនិយោគបរទេសលើការផលិតសំលៀកបំពាក់ ដែលត្រូវការកំលាំងពលកម្មច្រើនក្នុងប្រទេសវៀតណាម ផ្លាស់ប្តូរទៅប្រទេសដ៏ទៃផ្សេងៗទៀតដែលមានកំរិតប្រាក់ឈ្នួលទាបជាងប្រទេសវៀតណាម។

(2) ជាលទ្ធផល ឧស្សាហាករផលិតសំលៀកបំពាក់ជប៉ុនក្នុងប្រទេសចិន វៀតណាម និងថៃកំពុងគិតគូរផ្លាស់ប្តូរ ផលិតកម្មរបស់ពួកគេទៅកាន់ប្រទេសឡាវ និងកម្ពុជា ដែលជាប្រទេសមានប្រាក់ឈ្នួលទាប សម្បូរកំលាំងពលកម្ម និងមានការកែលំអរនូវឱកាសវិនិយោគ។

## ៥.២.៤ ផលប៉ះពាល់នៃការដកចេញកូតាលើប្រទេសវៀតណាម (នៅខែមករា ២០០៧) ជាលទ្ធផល ដែលបានពីការចូលជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក

(១) ការដកចេញបរិមាណកូតាចេញពីប្រទេសវៀតណាម ត្រូវបានរំពឹងថានឹងនាំឱ្យមានកំណើនយ៉ាងខ្លាំងលើការនាំចេញសំលៀកបំពាក់ផលិតក្នុងប្រទេសវៀតណាមទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។

(២) ទោះជាយ៉ាងណា ក៏ការប្រកួតប្រជែងក្នុងការនាំចេញ ចំពោះផលិតផលដូចគ្នាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង សហគមន៍អឺរ៉ុបរវាងកម្ពុជា និងវៀតណាមពុំមានលក្ខណៈស្រួចស្រាវទេ ដោយសារតែប្រទេសកម្ពុជា និង វៀតណាមមានឧត្តមភាពប្រៀបធៀបលើប្រភេទមួយចំនួននៃផលិតផលកាត់ដេរដែលមានលក្ខណៈមិនដូចគ្នា។ ជាឧទាហរណ៍ ប្រទេសកម្ពុជាមានឧត្តមភាពប្រៀនធៀបនៃការនាំចេញខ្លាំងជាងប្រទេសវៀតណាមទៅលើប្រភេទ

---

[9] ប្រភព : ការបូកសរុបវិស័យវិនិយោគទុនវៀតណាម (៩-១៥ មករា ២០០៦)

មុខទំនិញ ៣៤១ ( អាវបុរស/ ស្ត្រីដែលពុំមានផលិតចេញពីកំណាត់កូតុង) ប្រភេទមុខទំនិញ ៣៤២ ( សំពត់កូតុង) ប្រភេទមុខទំនិញ ៣៤៨ ( ខោជើងវែង/ខោជើងខ្លីរបស់ស្ត្រី/ក្មេងស្រីផលិតពីកូតុង) ប្រភេទមុខទំនិញ ៣៥១ ( សំលៀកបំពាក់យប់/សំលៀក បំពាក់ដេកធ្វើពីកូតុង) និង ប្រភេទមុខទំនិញ ៦៥១ ( សំលៀកបំពាក់យប់/ សំលៀក បំពាក់ដេកធ្វើពី MMF) ។ ម្យ៉ាងវិញទៀត ដោយសារភាពខុសគ្នានៃកំរិតឯកទេសកម្មទៅលើប្រភេទសំលៀកបំពាក់ផ្សេងៗគ្នា ប្រទេសកម្ពុជា នឹងមិនទទួលរងការប៉ះពាល់ធ្ងន់ធ្ងរពីការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសវៀតណាម ដែលបានធ្វើឡើងនៅឆ្នាំ២០០៦ ។ នេះហើយគឺជាមូលហេតុដែលក្រុមហ៊ុនកាត់ដេរបរទេសជាច្រើនធ្វើការបែងចែក ប្រភេទមុខទំនិញសំរាប់ផលិតផ្សេងៗគ្នា តាមរយៈការពិនិត្យការវិនិយោគទុននៅក្នុងប្រទេសនិមួយៗ ។

**តារាង ៥-២-៥ ការប្រៀបធៀបឧត្តមភាពប្រជែងឈ្នះរបស់វៀតណាម និងកម្ពុជា ក្នុងផលិតផលកាត់ដេរផ្សេងគ្នា**

| Year | RCA-338 M/B Cotton Knit Shirt Vietnam | RCA-338 M/B Cotton Knit Shirt Cambodia | RCA-339 W/G Cotton Knit Shirt Vietnam | RCA-339 W/G Cotton Knit Shirt Cambodia | RCA-340 M/B Cotton Woven Shirt Vietnam | RCA-340 M/B Cotton Woven Shirt Cambodia |
|---|---|---|---|---|---|---|
| 1997 | 1.14 | 2.80 | 1.41 | 5.83 | 6.59 | 1.12 |
| 1998 | 1.70 | 9.80 | 0.73 | 25.90 | 5.07 | 2.06 |
| 1999 | 2.30 | 10.36 | 1.47 | 19.51 | 8.00 | 7.96 |
| 2000 | 2.01 | 10.97 | 1.80 | 14.48 | 7.49 | 14.70 |
| 2001 | 2.12 | 11.23 | 1.70 | 17.82 | 4.87 | 10.19 |
| 2002 | 9.90 | 9.55 | 11.29 | 12.88 | 5.90 | 8.38 |
| 2003 | 12.36 | 9.03 | 18.56 | 10.92 | 7.59 | 10.53 |
| 2004 | 12.50 | 8.53 | 17.55 | 12.05 | 10.41 | 9.50 |
| 2005 | 8.92 | 8.13 | 14.25 | 7.86 | 10.84 | 12.77 |

| Year | RCA-341 W/G Cotton Blouse Vietnam | RCA-341 W/G Cotton Blouse Cambodia | RCA-342 Cotton Skirts Vietnam | RCA-342 Cotton Skirts Cambodia | RCA-347 M/B Cotton Pants/Shorts Vietnam | RCA-347 M/B Cotton Pants/Shorts Cambodia |
|---|---|---|---|---|---|---|
| 1997 | 0.23 | 0.04 | 0.06 | 0.27 | 0.11 | 9.81 |
| 1998 | 0.24 | 0.13 | 0.08 | 2.49 | 0.09 | 22.05 |
| 1999 | 0.11 | 2.49 | 0.20 | 11.30 | 0.07 | 26.93 |
| 2000 | 0.05 | 11.20 | 0.03 | 34.75 | 0.39 | 24.01 |
| 2001 | 0.17 | 12.60 | 0.03 | 51.67 | 0.16 | 15.11 |
| 2002 | 3.45 | 8.05 | 5.71 | 38.07 | 6.90 | 13.88 |
| 2003 | 5.18 | 8.71 | 12.69 | 48.03 | 12.97 | 14.37 |
| 2004 | 3.68 | 14.19 | 5.35 | 51.98 | 7.55 | 10.74 |
| 2005 | 3.86 | 14.09 | 4.43 | 49.81 | 6.17 | 8.92 |

| Year | RCA-348 W/G Cotton Pants/Shorts Vietnam | RCA-348 W/G Cotton Pants/Shorts Cambodia | RCA-351 Cotton Nightwear & Pajamas Vietnam | RCA-351 Cotton Nightwear & Pajamas Cambodia | RCA-651 MMF Nightwear & Pajamas Vietnam | RCA-651 MMF Nightwear & Pajamas Cambodia |
|---|---|---|---|---|---|---|
| 1997 | 0.45 | 4.09 | 0.00 | 3.62 | 0.06 | 0.53 |
| 1998 | 0.23 | 12.24 | 0.00 | 4.46 | 0.10 | 1.39 |
| 1999 | 0.20 | 16.69 | 0.00 | 22.10 | 0.20 | 3.37 |
| 2000 | 0.38 | 19.84 | 0.00 | 48.81 | 0.23 | 14.68 |
| 2001 | 0.30 | 14.12 | 0.01 | 70.06 | 0.15 | 53.34 |
| 2002 | 10.30 | 16.56 | 3.23 | 74.27 | 4.96 | 82.02 |
| 2003 | 15.18 | 22.70 | 4.52 | 100.53 | 5.30 | 85.10 |
| 2004 | 11.73 | 20.08 | 1.61 | 101.56 | 3.28 | 116.38 |
| 2005 | 11.81 | 22.26 | 4.19 | 105.48 | 3.17 | 128.12 |

Source: RCA calculation based on data acquired from the US Department of Commerce

### ៥.២.៥ ផលប៉ះពាល់នៃការដកការការពារទំនិញទៅលើសំលៀកបំពាក់ផលិតក្នុងប្រទេសចិនបន្ទាប់ពី ខែមករាឆ្នាំ២០០៩

នៅពេលមានការដកចេញនូវការកំណត់បរិមាណទៅលើសំលៀកបំពាក់ផលិតក្នុងប្រទេសចិន ការនាំចេញផលិតផលចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបនឹងអាចមានកំណើនយ៉ាងច្រើន។ ទោះជាយ៉ាងណាក៏ដោយ ក៏ការប្រកួតប្រជែងក្នុងការនាំចេញចំពោះផលិតផលដូចគ្នាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបរវាងកម្ពុជា និងចិនពុំមានលក្ខណៈស្រួចស្រាវខ្លាំងឡើយដោយសារមូលហេតុដូចតទៅ។ ការវិភាគស្ថិតិរីគ្រេសិន *"LnCamgarexp = 17.08 + 4.19 MFA"*[10] បង្ហាញថាផលប៉ះពាល់នៃកិច្ចព្រមព្រៀង MFA នៅឆ្នាំ២០០៥ ពុំមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរទៅលើការនាំចេញសំលៀកបំពាក់ពីប្រទេសកម្ពុជាឡើយ បើទោះបីជាផលប៉ះពាល់នោះពុំមានក៏រិតច្បាស់លាស់ ១០០ ភាគរយ ក៏ដោយ។ម្យ៉ាងវិញទៀត រចនាសម្ព័ន្ធនៃមុខទំនិញនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមិនត្រូវបានទទួលរងផលប៉ះពាល់ ដោយសាររចនាសម្ព័ន្ធចិនលើមុខទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកទេបន្ទាប់ពីការបំបាត់ចោលកិច្ចព្រមព្រៀង MFA នៅឆ្នាំ២០០៥ ទេ។ ការនេះដោយសារភាពផ្សេងៗគ្នានៃប្រភេទសំលៀកបំពាក់ដែលផលិតនៅក្នុងប្រទេសកម្ពុជានិងចិន។ ការនាំសំលៀកបំពាក់ចេញពីកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋ អាមេរិកបានកើនឡើងចំនួន ២០% នៅឆ្នាំ២០០៥ និង ៣០% ពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០០៦ ដោយឡែកការ នាំសំលៀកបំពាក់ចេញរបស់ចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានកើនឡើងចំនួន ៥៣% នៅឆ្នាំ២០០៥ ប៉ុន្តែធ្លាក់ ចុះពីខែមករា ដល់ខែមិថុនា ឆ្នាំ២០០៦ ដោយសារកំណើនយ៉ាងកំហុកនៅឆ្នាំ២០០៥ ក្រោមការកំណត់វិធានការ ការពារទំនិញរបស់សហរដ្ឋអាមេរិច។ ក្រុមហ៊ុនកាត់ដេរបរទេសមួយចំនួនមានទំនុកចិត្តថាឱកាសវិនិយោគក្នុង ប្រទេសកម្ពុជានឹងមានការកែលំអរហើយធ្វើការសំរេចចិត្តបង្វែរទីតាំងរោងចក្រពីប្រទេសចិន

[10] *LnCamgarexp* តំណាងឱ្យមេដំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង MFA គឺជាអថេដាំមីដំណាងដោយ ឥទ្ធិពល MFA ឆ្នាំ២០០៥។

ដែលមានកំរិតប្រាក់បៀវត្សខ្ពស់មកកាន់ប្រទេសកម្ពុជា។

### ៥.២.៦ ផលប៉ះពាល់នៃការបង្កើនល្បឿនលើការវាយតំលៃរូបិយវត្ថុចិនឡើងវិញបន្ទាប់ពីខែមករា ឆ្នាំ២០០៩

នៅពេលបំបាត់ការរឹតត្បឹតបរិមាណនៃផលិតផលកាត់ដេរផលិតក្នុងប្រទេសចិន គេសន្និដ្ឋានបានថា សហរដ្ឋអាមេរិកនឹងជំរុញឱ្យពន្លឿនការវាយតំលៃប្រាក់យ៉ន់ចិនឡើងវិញ។ នៅពេលនោះ តំរូវការផលិតផលពីប្រទេសកម្ពុជានឹងត្រូវប្រើជំនួសតំរូវការផលិតផលពីប្រទេសចិន។ ដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការវាយតំលៃរូបិយវត្ថុចិនឡើងវិញ ជាដំបូងគេគួរតែវិភាគពីផលប៉ះពាល់នៃការវាយតំលៃរូបិយវត្ថុឡើងវិញរបស់ចិននៅខែកក្កដា ឆ្នាំ២០០៥ ដែលមានទំនាក់ទំនងនឹងការនាំសំលៀកបំពាក់កម្ពុជា។ ដោយសារក្រុមសិក្សាយកចិត្តទុកដាក់តែលើឧស្សាហកម្មសំលៀកបំពាក់ក្រុមសិក្សានឹងធ្វើការវិភាគតែទៅលើផលប៉ះពាល់នៃការ វាយតំលៃរូបិយវត្ថុចិនលើកទីមួយទៅលើការនាំចេញសំលៀកបំពាក់របស់កម្ពុជា និងចិនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ បើពិនិត្យផលប៉ះពាល់នៃការវាយតំលៃរូបិយវត្ថុចិនឡើងវិញជាលើកដំបូងទៅលើការនាំចេញសំលៀកបំពាក់នោះ កំណើនប្រចាំខែលើការនាំចេញនៃបរិមាណសំលៀកបំពាក់ពីប្រទេសចិនគឺមានការធ្លាក់ចុះ បើផ្ទៀងផ្ទាត់ជាមួយនឹងអថេរដាំមីដោយយកការវាយតំលៃរូបិយវត្ថុដំបូងឡើងវិញនៅខែកក្កដា ឆ្នាំ២០០៥ ជាអញ្ញត្តិតំណាង។ ការវិភាគស្ថិតិរីក្រេស៊ិនិ *"Chinagarexp = 0.12 – 0.11 D"*[11] បង្ហាញថា ការវាយតំលៃរូបិយវត្ថុយ៉ាន់ឡើងវិញនេះមានផលប៉ះពាល់អវិជ្ជមានទៅលើបរិមាណនាំសំលៀកបំពាក់ចេញរបស់ប្រទេសចិន។ ផ្ទុយទៅវិញ ការវាយតំលៃរូបិយវត្ថុឡើងវិញរបស់ចិននេះហាក់បីដូចជាមានផលប៉ះពាល់វិជ្ជមានទៅលើកំណើននៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា *"Camgarexp = 0.03 + 0.01 D"*[12]។ ការវិភាគស្ថិតិរីក្រេស៊ិនខាងលើបង្ហាញថា ការវាយតំលៃឡើងវិញដំបូងនៃរូបិយវត្ថុចិននៅខែកក្កដាឆ្នាំ២០០៥ មានផលប៉ះពាល់អវិជ្ជមានទៅលើកំណើននៃការនាំចេញសំលៀកបំពាក់ចិន ផ្ទុយទៅវិញ មានផលប៉ះពាល់វិជ្ជមានទៅលើកំណើននៃការនាំសំលៀកបំពាក់ចេញរបស់កម្ពុជា។ ដូចនេះ ការវាយតំលៃរូបិយវត្ថុចិនឡើងវិញអាចនាំទៅរកការជំនួសតំរូវការផលិតផលចិនដោយតំរូវការផលិតផលកម្ពុជា។ម្យ៉ាងទៀត ការពន្លឿនយ៉ាងលឿននៃការវាយតំលៃរូបិយវត្ថុចិនឡើងវិញបន្ទាប់ពីឆ្នាំ២០០៩ ក៏នឹងអាចមានផលប៉ះពាល់ទៅលើកំណើននៃការនាំចេញសំលៀកបំពាក់ ដូចពេលនេះដែរដែលជាប្រការធ្វើឱ្យចំណេញ ដល់ការនាំចេញនៃផលិតផលសំលៀកបំពាក់របស់កម្ពុជា។

### ៥.២.៧ ការព្យាករណ៍បរិមាណវិនិយោគទុនក្នុងប្រទេសកម្ពុជាដោយក្រុមហ៊ុនបរទេសរហូតដល់ឆ្នាំ២០២០

**(១) ការវិភាគនិន្នាការ**

---

[11] *LnChinagarexpQ* តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង D គឺជាអថេដាំមី ដំណាងដោយការវាយតំលៃរូបិយវត្ថុចិនឡើងវិញ នៅខែកក្កដា ឆ្នាំ ២០០៥។

[12] *LnChinagarexpQ* តំណាងឱ្យមេជំរឿននៃការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្នុងបរិមាណច្រើន និង D គឺជាអថេដាំមី ដំណាងដោយការវាយតំលៃរូបិយវត្ថុចិនឡើងវិញ នៅខែកក្កដា ឆ្នាំ ២០០៥។

១៩៩៦-១៩៩៨ : រយៈពេលគ្មានកូតា

១៩៩៨-២០០១ : រយៈពេលមានកូតា (រយៈពេលច្បាស់លាស់គឺ ១៩៩៩-២០០១) ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈកូតានេះ កម្ពុជាមានកំណើនប្រមាណជា ១៥ ភាគរយ ដោយសារការគោរពទៅតាមមាត្រារបស់ ILO ។

**Figure 5-2-1**




Source: Chart based on GMAC materials

២០០២-២០០៥ : ការចរចាដើម្បីចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក និងរយៈពេលផ្លាស់ប្តូរទៅរកស្ថានភាពគ្មានកូតា បន្ទាប់ពីបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ។

២០០៦-២០០៨ : រយៈពេលនៃការការពារមុខទំនិញទៅលើផលិតផលចិន (ការចាប់ផ្តើមប្រតិបត្តិរបស់សហគ្រាសជប៉ុន) ។

២០០៩ - : ការដកចេញនៃការការពារទំនិញប្រឆាំងនឹងប្រទេសចិន ប៉ុន្តែក៏ជារយៈពេលនៃការឡើងតំលៃនៃប្រាក់យ័ន់ចិន (ប្រតិបត្តិការនៃសហគ្រាសជប៉ុនមានការកើនឡើងថែមទៀត) ។

### (២) ការព្យាករណ៍តំលៃ និងបរិមាណវិនិយោគទុនរហូតដល់ឆ្នាំ២០២០

នៅពេលដាក់បញ្ចូលគ្នានូវការព្យាករណ៍បរិវិស័យដែលបានលើកឡើងខាងលើ និងការព្យាករណ៍ដែលទាក់ទងទៅនឹងកត្តាគុណវិស័យអន្តរជាតិ ពោលគឺអំឡុងពេលពីឆ្នាំ២០០៥-២០០៩ ឱ្យដឹងថា និន្នាការនៃការវិនិយោគបរទេសចូលក្នុងវិស័យផលិតសំលៀកបំពាក់កម្ពុជាអាចមានលក្ខណៈដូចតទៅ ។ ការព្យាករណ៍គុណវិស័យដែលតំណាងដោយបន្ទាត់មួយនៅក្នុងក្រាហ្វិកខាងលើ ពិនិត្យទៅលើផលប៉ះពាល់អន្តរជាតិ ដែលបានកើតមានឡើងនៅពេលអនាគតទៅលើវិស័យកាត់ដេរក្នុងប្រទេសកម្ពុជា ។ ការបញ្ចូលគ្នារវាងការព្យាករណ៍បរិវិស័យ ដែលពិនិត្យទៅលើផលប៉ះពាល់បរិ

វិស័យជាប្រវត្តិសាស្ត្រទៅលើវិស័យកាត់ដេរ និងការព្យាករណ៍គុណវិស័យ ដែលពិនិត្យទៅលើកត្តាអត្តនោម័តអាចទទួលបានលទ្ធផលដែលមានការិតជិតនឹងនិន្នាការជាក់ស្តែងនៅពេលអនាគត។ វិធីសាស្ត្រមួយនៃការពិនិត្យសំរាប់ការវិនិយោគទុនផ្ទាល់ពីបរទេសទៅលើវិស័យកាត់ដេរកម្ពុជានឹងមានពន្យល់លំអិតនៅក្នុងរបាយការណ៍ចុងក្រោយ បើទោះបីការព្យាករណ៍ត្រូវបានធ្វើចប់រួចរាល់នៅក្នុងពេលនៃរបាយការណ៍បណ្តោះអាសន្ននេះហើយក្តី។

**Figure 5-2-2 FDI in the Garment Industry of Cambodia(Colour Chart)**




Source: (1) FDI garment data (Actual): Council of the Development of Cambodia
(5) (2) FDI fitted data generated by the cross-sectional econometric model

សហគ្រាសផលិតសំលៀកបំពាក់ជប៉ុនបានធ្វើការវិនិយោគទុនលើ ៤០ ករណីក្នុងប្រទេសវៀតណាម ប្រហែលជា ៦០ ករណីក្នុងប្រទេសថៃ និងប្រហែល ៦១០ ករណីក្នុងប្រទេសចិន។ នៅក្នុងចំណោមសហគ្រាសផលិតទាំងនេះ ទីប្រឹក្សាម្នាក់ដែលទទួលបន្ទុកនៃក្រុមសិក្សា JICA បានធ្វើការសម្ភាសន៍លើករណីក្រុមហ៊ុនវៀតណាមប្រមាណជា ៧០ ភាគរយ ករណីក្រុមហ៊ុនថៃប្រហែល ៦០ ភាគរយ និងករណីក្រុមហ៊ុនចិនប្រហែល ១០ ភាគរយ តាមរយៈការអង្កេតជាបន្តបន្ទាប់កាលពីពេលកន្លងទៅនេះ។ ការអង្កេតដោយការសម្ភាសន៍នេះបង្ហាញថា អ្នកផលិតសំលៀកបំពាក់ជប៉ុនដែលអាចផលិតសំលៀកបំពាក់ដោយស៊ីកំរៃ ជើងសារ ឬធ្វើវិនិយោគក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេល ៥ឆ្នាំខាងមុខប្រហែលជាមាន ៥ ករណីមកពីប្រទេសវៀតណាម ៥ ករណីមកពីប្រទេសថៃ និងប្រហែលជា ២០ ករណី មកពីប្រទេសចិន មានន័យថាក្នុងមួយឆ្នាំៗជាមធ្យមមានករណីប្រហែលជា ៦ ត្រូវបានព្យាករណ៍។ ប្រសិនបើបរិមាណវិនិយោគជាមធ្យមក្នុងមួយករណីមានតំលៃ ៥០០ពាន់ដុល្លារអាមេរិក នោះករណីមួយឆ្នាំៗនឹងត្រូវមានទឹកប្រាក់ចំនួន

៣ លានដុល្លារ ជាមធ្យម។

គោលដៅបន្ទាប់នៃការធ្វើវិនិយោគរបស់ក្រុមហ៊ុនជប៉ុន ក្រៅពីប្រទេសកម្ពុជាអាចប្តូរមកជាប្រទេសឡាវ ភូមា និងបង់ក្លាដេស ដែលក្រុមហ៊ុនជប៉ុនយកមកធ្វើការពិចារណា។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រទេសនីមួយៗមានបញ្ហាដែលត្រូវប្រឈម ដូចជាកំណើនជំនាញតិចតួចរបស់កម្មកររោងចក្រក្នុងប្រទេសឡាវ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសភូមារបស់សហរដ្ឋអាមេរិក និងការលំបាកក្នុងការដោះស្រាយជំលោះការងាររបស់ក្រុមហ៊ុនជប៉ុនក្នុងប្រទេសបង់ក្លាដែស។ ជាលទ្ធផល ការលើកកំពស់ឱកាសវិនិយោគក្នុងប្រទេសកម្ពុជានឹងធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាមូលដ្ឋានផលិតកម្មដ៏ធំរបស់អ្នកផលិតសំលៀកបំពាក់ជប៉ុន។

## ៥.៣ ការវាយតំលៃនិងទស្សនវិស័យនៃការប្រកួតប្រជែងជាអន្តរជាតិនៃឧស្សាហកម្មកាត់ដេរកម្ពុជា

### ៥.៣.១ ទស្សនវិស័យលើការចំណាយសំរាប់ផលិតកម្ម និងប្រសិទ្ធភាពផលិតកម្ម

### (១) ប្រសិទ្ធភាព និងការប្រកួតប្រជែងនៃការផលិតទំនិញសំលៀកបំពាក់សំខាន់ៗរបស់កម្ពុជា

នៅពេលប្រភេទទំនិញ ៣៤១ (អាវស្ត្រី W/G)គឺជាទំនិញមួយប្រភេទក្នុងចំណោមទំនិញរបស់កម្ពុជា ដែលមានកំរិតប្រកួតប្រជែងខ្ពស់ ដែលបាននាំទៅកាន់ទីផ្សារសហរដ្ឋអាមេរិកច្រើនឡើងៗ ដូចនេះយើងចាំបាច់ធ្វើការវិភាគដោយផ្អែកទៅលើការប្រៀបធៀបពីការប្រកួតប្រជែងតំលៃនៅក្នុងទីផ្សារសហរដ្ឋអាមេរិក ដែលមានទំនិញនាំចូលពីប្រទេសប្រកួតប្រជែងផ្សេងៗទៀត។ គួរចាំថា ការប្រៀបធៀបតំលៃទំនិញក្នុងប្រទេសប្រើប្រាស់ទំនិញមានភាពប្រាកដប្រជាជាងការប្រៀបធៀបតំលៃ FOB (មិនគិតឈ្នួលមកដល់នាវា)ក្នុងប្រទេសផលិតទំនិញពីព្រោះគេត្រូវធ្វើការប្រៀបធៀបការប្រកួតប្រជែងក្នុងទីផ្សារលក់រាយក្នុងទីតាំងលក់ទំនិញនាំចូលនោះដើម្បីវាយតំលៃការប្រកួតប្រជែងក្នុងការនាំចេញ។ តាមទស្សនៈនេះ តំលៃ FOB ក្នុងប្រទេសកម្ពុជាមានការប្រកួតប្រជែងតំលៃខ្លាំងជាងប្រទេសប្រកួតប្រជែងផ្សេងៗទៀត។ ប៉ុន្តែតំលៃទិញនៅកន្លែងលក់រាយនៃទំនិញរបស់កម្ពុជា ពុំមានការប្រកួតប្រជែងតំលៃខ្លាំងជាងច្រើន បើប្រៀបធៀបទៅនឹងទំនិញដូចគ្នានាំចូលពីប្រទេសផ្សេងៗទៀត។

**តារាង ៥-៣-១ ថ្លៃប្រជែងឈ្នះនៃអាវស្ត្រីកូតុងនាំចូលទៅក្នុងទីផ្សារសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៥**

| Exporting country | Cambodia | Thailand | China | Vietnam | Myanmar |
|---|---|---|---|---|---|
| Raw materials (including Transportation) | 2.7 | 2.2 | 2.0 | 2.5 | 2.7 |
| Labor cost | 0.6 | 1.4 | 1.3 | 0.8 | 0.3 |
| Sub-total | 3.3 | 3.6 | 3.3 | 3.3 | 3.0 |
| Power charges | 0.5 | 0.3 | 0.3 | 0.3 | 0.4 |
| Depreciation | 0.4 | 0.5 | 0.5 | 0.5 | 0.4 |
| Overhead cost | 0.4 | 0.7 | 0.6 | 0.6 | 0.4 |
| Total production costs | 4.7 | 5.1 | 4.7 | 4.7 | 4.2 |
| Profits | 0.3 | 0.5 | 0.4 | 0.5 | 0.3 |
| FOB price | 4.9 | 5.6 | 5.1 | 5.2 | 4.5 |

| Exporting country | Cambodia | Thailand | China | Vietnam | Myanmar |
|---|---|---|---|---|---|
| Shipping cost | 2.7 | 2.2 | 2.1 | 2.2 | 2.6 |
| Import tariff | 0.2 | 0.4 | 0.4 | 0.4 | 0.4 |
| Purchasing price | 7.8 | 8.2 | 7.6 | 7.8 | 7.5 |
| Sales price | 15.0 | 15.0 | 15.0 | 15.0 | 15.0 |
| Profit on sales | 7.2 | 6.8 | 7.4 | 7.2 | 7.4 |

Note: (US$/piece)
Source: Compiled by JICA Study Team from various sources

តំលៃ FOB ជាមធ្យមរវាងផលិតផលកម្ពុជា និងចិនមានកំរិតប្រហាក់ប្រហែលគ្នា ពោលគឺមានភាពខុសគ្នាប្រមាណតែ ២០សេន ប៉ុណ្ណោះ។ ការសរុបតំលៃ FOB និងតំលៃទំនិញមិនបង្ហាញពីភាពខុសគ្នាខ្លាំងនៅតាមប្រទេសនានាដែលបានលើកឡើងខាងលើលើកលែងតែប្រទេសថៃ និងប្រទេសភូមា។ ភាពខុសគ្នាទាំងនេះភាគច្រើនដោយសារការចំណាយទាក់ទងនឹងការនាំចូលសម្ភារៈ មិនទាន់កែច្នៃ និងតំលៃពលកម្ម ដែលជាចំណែកយ៉ាងធំក្នុងការចំណាយលើការផលិត។ ការចំណាយទៅលើសម្ភារៈមិនទាន់កែច្នៃមានចំនួនប្រមាណជា ៦០ភាគរយ នៃតំលៃ FOB ក្នុងប្រទេសកម្ពុជាដោយសារប្រទេសកម្ពុជានាំសម្ភារៈទាំងនេះមកពីប្រទេសផ្សេងៗ ជាពិសេសប្រទេសចិន តៃវ៉ាន់ កូរ៉េ ឥណ្ឌូនេស៊ី ម៉ាឡេស៊ីជាដើម ចំណែកឯប្រទេសចិនមានសម្ភារៈមិនទាន់កែច្នៃតំលៃទាបសំរាប់បំរើសេចក្តីត្រូវការឧស្សាហកម្មកាត់ដេរចិនដែលមានចំនួនតែ ៤០ភាគរយ នៃតំលៃ FOB ដោយសារចិនអាចផលិតសម្ភារៈមិនទាន់កែច្នៃទាំងនោះនៅក្នុងស្រុកបាន។ ថ្លៃកណាម៉ាស៊ីនត្រជាក់ដំណើរការរហូតសំរាប់ម៉ាស៊ីនកាត់ដេរ ចិនប្រើភ្លើងតែ ៣% ប៉ុណ្ណោះ នៃតំលៃ FOB ។

បើប្រៀបធៀបតំលៃពលកម្មវិភាគពីផលិតភាព (តារាងខាងក្រោម) តំលៃពលកម្មជាមធ្យមប្រចាំខែក្នុងប្រទេសកម្ពុជាមានចំនួនតិចជាងតំលៃពលកម្មជាមធ្យមនៅក្នុងប្រទេសវៀតណាម ចិន និងថៃ ប៉ុន្តែផលិតភាពជាមធ្យមនៃកម្មករកម្ពុជាមានកំរិតទាបជាងប្រទេសវៀតណាម ចិន និងថៃ ដែលការនេះធ្វើឱ្យការចំណាយទៅលើពលកម្មសំរាប់ផលិតទំនិញមួយៗ ពុំមានភាពខុសគ្នាខ្លាំងរវាងប្រទេសទាំងនោះឡើយ ប្រសិនបើគិតគូរពីការចំណាយទៅលើកំលាំងពលកម្មទាបរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាធំបំផុតសំរាប់ក្រុមហ៊ុនវិនិយោគទុនបរទេសនោះគឺថាឧស្សាហកម្មកាត់ដេរក្នុងប្រទេសវៀតណាម ចិន និង ថៃពុំមែនជាឧស្សាហកម្មដែលមានការទាក់ទាញខ្លាំងក្នុងចំណោមកម្មករដែលមានទេពកោសល្យទៀតទេ។ ជាលទ្ធផល ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង ប្រទេសកម្ពុជាមានសក្តានុពលសំរាប់ការអភិវឌ្ឍន៏ព្រោះឧស្សាហកម្មកាត់ដេរនេះមានបញ្ហាកំលាំងពលកម្មតិចតួចប៉ុណ្ណោះ។

**តារាង ៥-៣-២ ការប្រៀបធៀបនៃសមិទ្ធផលថ្លៃពលកម្មនៃសំលៀកបំពាក់កូតុងមួយ (One-Piece W/G Cotton Blouse) នៅឆ្នាំ ២០០៥**

| | Myanmar | Vietnam | Thailand | China (Shanghai) | Cambodia |
|---|---|---|---|---|---|
| Production Pieces/ Per one person day (one day=9 hours) | 6 pieces | 9 pieces | 9 pieces | 10 pieces | 7 pieces |

| | | | | | |
|---|---|---|---|---|---|
| Labor Cost/ month (U.S.$) | US$ 35 | US$ 100 | US$ 200 | US$ 180 | US$ 70 |
| Labor Cost Performance (U.S.$ labor cost/piece) | US$ 0.23 | US$ 0.44 | US$0.88 | US$ 0.72 | US$ 0.40 |

Source: Compiled by the study team from data from various factories

## (២) ការវិភាគដើម្បីជ្រើសរើសមុខទំនិញ ដែលកម្ពុជាមានការប្រកួតប្រជែងលើការនាំចេញ

ការជ្រើសរើសមុខទំនិញ ដែលមានលក្ខណៈសមស្របសំរាប់ផលិតក្នុងប្រទេសកម្ពុជាគឺជាលក្ខខណ្ឌមុនដំបូងដ៏ចាំបាច់សំរាប់បង្កើតគំរោងវិនិយោគទុន ពីព្រោះក្រុមហ៊ុនផលិតសំលៀកបំពាក់ជប៉ុនមិនអាចបង្កើតផែនការធុរៈកិច្ច (គំរោងកាត់ដេរស៊ីកំរៃជើងសារ គំរោងផលិត និងនាំចេញ គំរោងវិនិយោគជាដើម) បានឡើយ ប្រសិនបើគ្មានការកំណត់មុខទំនិញដែលមានលក្ខណៈសមស្របសំរាប់ផលិតទេនោះ។ ក្រុមហ៊ុននានានឹងចាប់ផ្តើមប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាបន្ទាប់ពីធ្វើជំរើសមុខទំនិញដែលត្រូវផលិត។

### *(i)* ការព្យាករណ៍ ឧត្តមភាពប្រៀបធៀប RCA (រហូតដល់ឆ្នាំ២០២០)

*(a)* ដោយសារផលិតផលកាត់ដេររបស់កម្ពុជាជាង ៨០ភាគរយ ត្រូវនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ការនាំចេញផលិតផលសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកគឺផ្តោតជាសំខាន់។ នៅក្នុងចំណោមប្រភេទផលិតផលកាត់ដេរដែលកម្ពុជាបាននាំទៅកាន់ទីផ្សារសហរដ្ឋអាមេរិក មានមុខទំនិញ ៦ ប្រភេទ ត្រូវបានរកឃើញថាមានបរិមាណនាំចេញខ្ពស់ (ច្រើនជាង ៥ ភាគរយ)។ មុខទំនិញទាំង ៦ ប្រភេទនោះរួមមានប្រភេទមុខទំនិញ ៣៣៨ (អាវបុរស/ក្មេងប្រុសផលិត ពីកូតុងសូត្រ) ប្រភេទមុខទំនិញ ៣៣៩ (អាវ/អាវស្ត្រីផលិតពីកូតុងសូត្រ) ប្រភេទមុខទំនិញ ៣៤៧ (ខោជើងវែង/ ខោជើងខ្លីកូតុង បុរស/ក្មេងប្រុស) ប្រភេទមុខទំនិញ ៣៤៨ (ខោជើងវែង/ ជើងខ្លីស្ត្រី/កុមារីកូតុង) និងប្រភេទមុខទំនិញ ៣៥១ (សំលៀកបំពាក់យប់/ សំលៀកបំពាក់ដេកធ្វើពីកូតុង) និងប្រភេទមុខទំនិញ ៦៥១ ( សំលៀកបំពាក់យប់/ សំលៀកបំពាក់ដំណេកធ្វើពី MMF)។ តារាងខាងក្រោម បង្ហាញពីបរិមាណនៃប្រភេទមុខទំនិញនីមួយៗ រហូតដល់ឆ្នាំ២០០៥។

**តារាង ៥-៣-៣ ការប្រៀបធៀបតម្លៃពលកម្មនៃអាវស្ត្រីកូតុង១ឯកតា នៅឆ្នាំ២០០៥**

| Category | 2003 | | 2004 | | 2005 | |
|---|---|---|---|---|---|---|
| | Exports to US (US$ mil) | Export share | Exports to US (US$ mil) | Export share | Exports to US (US$ mil) | Export share |
| 334 | 6.97 | 1% | 11.51 | 1% | 13.11 | 1% |
| 335 | 7.88 | 1% | 10.26 | 1% | 28.00 | 2% |
| 336 | 11.89 | 1% | 8.31 | 1% | 6.39 | 0% |
| 338 | 85.78 | **7%** | 91.08 | **7%** | 122.16 | **7%** |
| 339 | 113.63 | **9%** | 151.40 | **11%** | 246.09 | **15%** |
| 340 | 40.09 | 3% | 46.31 | 3% | 44.14 | 3% |

| Category | 2003 | | 2004 | | 2005 | |
|---|---|---|---|---|---|---|
| | Exports to US (US$ mil) | Export share | Exports to US (US$ mil) | Export share | Exports to US (US$ mil) | Export share |
| 341 | 22.89 | 2% | 41.88 | 3% | 43.94 | 3% |
| 342 | 59.87 | 5% | 87.66 | 6% | 64.16 | 4% |
| 345 | 5.41 | 0% | 8.87 | 1% | 6.17 | 0% |
| 347 | 134.97 | **11%** | 111.16 | **8%** | 131.39 | **8%** |
| 348 | 260.67 | **22%** | 262.05 | **19%** | 347.85 | **21%** |
| 349 | 2.43 | 0% | 2.02 | 0% | 0.75 | 0% |
| 350 | 8.79 | 1% | 15.06 | 1% | 24.61 | 1% |
| 351 | 156.60 | **13%** | 171.41 | **12%** | 128.64 | **8%** |
| 352 | 17.62 | 1% | 21.84 | 2% | 31.57 | 2% |
| 354 | 0.00 | 0% | 0.04 | 0% | 0.04 | 0% |
| 359 | 18.13 | 1% | 22.50 | 2% | 25.48 | 2% |
| 634 | 22.90 | 2% | 15.57 | 1% | 25.52 | 2% |
| 635 | 2.46 | 0% | 2.88 | 0% | 6.92 | 0% |
| 636 | 7.67 | 1% | 7.79 | 1% | 4.55 | 0% |
| 638 | 6.46 | 1% | 15.31 | 1% | 18.83 | 1% |
| 639 | 32.44 | 3% | 46.54 | 3% | 62.55 | 4% |
| 640 | 10.67 | 1% | 6.49 | 0% | 5.26 | 0% |
| 641 | 8.94 | 1% | 15.38 | 1% | 14.57 | 1% |
| 642 | 29.38 | 2% | 34.57 | 2% | 17.21 | 1% |
| 643 | 1.75 | 0% | 1.34 | 0% | 1.65 | 0% |
| 644 | 9.04 | 1% | 7.56 | 1% | 3.64 | 0% |
| 645 | 0.03 | 0% | 0.00 | 0% | 0.00 | 0% |
| 646 | 1.41 | 0% | 1.17 | 0% | 1.64 | 0% |
| 647 | 3.96 | 0% | 5.28 | 0% | 23.19 | 1% |
| 648 | 9.01 | 1% | 6.58 | 0% | 24.89 | 1% |
| 549 | 1.78 | 0% | 3.49 | 0% | 6.48 | 0% |
| 650 | 10.47 | 1% | 8.09 | 1% | 18.39 | 1% |
| 651 | 69.04 | **6%** | 107.87 | **8%** | 125.25 | **7%** |
| 652 | 2.37 | 0% | 1.14 | 0% | 4.77 | 0% |
| 653 | 0.00 | 0% | 0.02 | 0% | 0.03 | 0% |
| 654 | 0.31 | 0% | 0.67 | 0% | 1.11 | 0% |
| 659 | 26.86 | 2% | 44.62 | 3% | 39.27 | 2% |
| 653 | 0.00 | 0% | 0.00 | 0% | 0.00 | 0% |
| Total | 1210.57 | 100% | 1395.72 | 100% | 1670.21 | 100% |

(6) Source: Compiled by JICA Study Team based on data from US Department of State

*(b)* និន្នាការនាំចេញនៃមុខទំនិញនីមួយៗនៃផលិតផលសំលៀកបំពាក់ពីប្រទេសកម្ពុជា ទៅកាន់សហរដ្ឋអាមេរិក

ក្នុងរយៈពេល១០ឆ្នាំកន្លងទៅមានបង្ហាញនៅក្នុងគំនូសដូចខាងក្រោម ។

*(c)* បើពិនិត្យទៅលើភាពខ្លាំងរបស់កម្ពុជាក្នុងប្រភេទមុខទំនិញកាត់ដេរនីមួយៗ ដែលមានបរិមាណនាំចេញខ្ពស់ជាងការនាំចេញសំលៀកបំពាក់សរុបរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិកក្នុងរយៈពេល ៣ឆ្នាំ កន្លងទៅ ឧត្តមភាពប្រៀបធៀបដ៏ខ្លាំងខ្លា (Dynamics of RCA) តាមប្រភេទមុខទំនិញនីមួយៗមានការវិភាគនៅក្នុងតារាងដូចខាងក្រោម ។ ការវិភាគឧត្តមភាពប្រៀបធៀបដ៏ខ្លាំងខ្លាបង្ហាញថា ប្រទេសកម្ពុជាមានភាពខ្លាំងជាងមុនលើផលិតផលសំលៀកបំពាក់យប់ធ្វើពីកូតុង និងសូត្រផលិតដោយដៃ (ប្រភេទទំនិញ ៣៥១ និង ៦៥១) បើប្រៀបធៀបទៅនិងមុខផលិតផលសំលៀកបំពាក់ផ្សេងៗទៀត ។

**តារាង ៥-៣-៤ ឧត្តមភាពប្រៀបធៀប (RCA) របស់កម្ពុជា ក្នុងប្រភេទផ្សេងៗ**

| Year | RCA-338 | RCA-339 | RCA-347 | RCA-348 | RCA-351 | RCA-651 |
|---|---|---|---|---|---|---|
| 1997 | 2.80 | 5.83 | 9.81 | 4.09 | 3.62 | 0.53 |
| 1998 | 9.80 | 25.90 | 22.05 | 12.24 | 4.46 | 1.39 |
| 1999 | 10.36 | 19.51 | 26.93 | 16.69 | 22.10 | 3.37 |
| 2000 | 10.97 | 14.48 | 24.01 | 19.84 | 48.81 | 14.68 |
| 2001 | 11.23 | 17.82 | 15.11 | 14.12 | 70.06 | 53.34 |
| 2002 | 9.55 | 12.88 | 13.88 | 16.56 | 74.27 | 82.02 |
| 2003 | 9.03 | 10.92 | 14.37 | 22.70 | 100.53 | 85.10 |
| 2004 | 8.53 | 12.05 | 10.74 | 20.08 | 101.56 | 116.38 |
| 2005 | 8.13 | 7.86 | 8.92 | 22.26 | 105.48 | 128.12 |

(7) Source: Calculated by JICA Study Team based on data from the US Department of Commerce

*(d)* យើងគួរពិនិត្យមើលច្រើនទៀតទៅលើសេណារីយ៉ូ/និន្នាការនៃឧត្តមភាពប្រៀបធៀប (RCA) កម្ពុជានាពេលអនាគតទាក់ទងទៅនឹងប្រភេទមុខទំនិញទាំង ៩ រួមទាំងមុខទំនិញ ៣ប្រភេទ ផ្សេងទៀត ដែលមានឧត្តមភាពប្រៀបធៀប (RCA) ខ្ពស់ បើទោះបីជាប្រភេទមុខទំនិញទាំងបីនោះទាបជាង ៥ ភាគរយ ក៏ដោយ ។ គួរកត់សំគាល់ថា ការព្យាករណ៍ដូចនេះត្រូវបានធ្វើឡើងដោយការពិនិត្យទៅលើនិន្នាការអតីតកាល និង វឌ្ឍធម្មជាតិនៃប្រទេសកម្ពុជា និង និន្នាការនាំចេញរបស់ពិភពលោក និងតាមរយៈការពិនិត្យទៅលើភាពមិនលំអៀងនៃផលប៉ះពាល់គុណភាពនាពេលអនាគតលើវិស័យកាត់ដេរសំលៀកបំពាក់របស់ប្រទេសកម្ពុជា និងពិភពលោក។ ការព្យាករណ៍គុណភាពនៃឧត្តមភាពប្រៀបធៀប (RCA) របស់កម្ពុជាតាមប្រភេទផលិតផលសំលៀកបំពាក់នីមួយៗដែលមានបរិមាណនាំចេញខ្ពស់ជាងការនាំចេញសំលៀកបំពាក់សរុបមានបង្ហាញនៅក្នុងតារាងដូចខាងក្រោម ។

## តារាង ៥-៣-៥ ឧត្តមភាពប្រៀបធៀប (RCA) របស់កម្ពុជា (ត)

| Year | RCA-338 | RCA-339 | RCA-340 | RCA-341 | RCA-342 | RCA-347 | RCA-348 | RCA-351 | RCA-651 |
|---|---|---|---|---|---|---|---|---|---|
| 1997 | 2.80 | 5.83 | 1.12 | 0.04 | 0.27 | 9.81 | 4.09 | 3.62 | 0.53 |
| 1998 | 9.80 | 25.90 | 2.06 | 0.13 | 2.49 | 22.05 | 12.24 | 4.46 | 1.39 |
| 1999 | 10.36 | 19.51 | 7.96 | 2.49 | 11.30 | 26.93 | 16.69 | 22.10 | 3.37 |
| 2000 | 10.97 | 14.48 | 14.70 | 11.20 | 34.75 | 24.01 | 19.84 | 48.81 | 14.68 |
| 2001 | 11.23 | 17.82 | 10.19 | 12.60 | 51.67 | 15.11 | 14.12 | 70.06 | 53.34 |
| 2002 | 9.55 | 12.88 | 8.38 | 8.05 | 38.07 | 13.88 | 16.56 | 74.27 | 82.02 |
| 2003 | 9.03 | 10.92 | 10.53 | 8.71 | 48.03 | 14.37 | 22.70 | 100.53 | 85.10 |
| 2004 | 8.53 | 12.05 | 9.50 | 14.19 | 51.98 | 10.74 | 20.08 | 101.56 | 116.38 |
| 2005 | 8.13 | 7.86 | 12.77 | 14.09 | 49.81 | 8.92 | 22.26 | 101.47 | 116.43 |
| 2006 | 7.50 | 10.94 | 9.63 | 12.24 | 45.80 | 7.69 | 24.91 | 100.26 | 110.64 |
| 2007 | 6.46 | 6.71 | 9.66 | 11.26 | 41.21 | 6.16 | 25.08 | 88.03 | 98.13 |
| 2008 | 5.84 | 9.45 | 13.16 | 9.81 | 38.32 | 5.51 | 27.39 | 89.17 | 99.53 |
| 2009 | 5.56 | 6.55 | 10.06 | 10.11 | 39.15 | 5.13 | 30.08 | 89.32 | 95.88 |
| 2010 | 4.61 | 8.61 | 10.24 | 8.20 | 34.16 | 4.41 | 29.60 | 79.51 | 86.23 |
| 2011 | 4.34 | 6.00 | 14.15 | 8.44 | 35.38 | 4.25 | 31.52 | 81.66 | 88.67 |
| 2012 | 4.01 | 8.87 | 10.97 | 7.70 | 35.02 | 4.24 | 33.68 | 82.95 | 86.62 |
| 2013 | 3.48 | 5.74 | 11.32 | 7.35 | 34.14 | 3.92 | 32.20 | 74.88 | 78.99 |
| 2014 | 3.19 | 8.49 | 15.85 | 6.72 | 34.24 | 4.04 | 33.26 | 77.99 | 82.38 |
| 2015 | 3.08 | 6.16 | 12.46 | 7.19 | 37.97 | 4.32 | 34.43 | 80.34 | 81.61 |
| 2016 | 2.61 | 8.45 | 13.04 | 6.12 | 35.81 | 4.26 | 31.86 | 73.56 | 75.49 |
| 2017 | 2.52 | 6.13 | 18.54 | 6.55 | 40.36 | 4.70 | 31.83 | 77.71 | 79.86 |
| 2018 | 2.38 | 9.40 | 14.78 | 6.27 | 43.26 | 5.37 | 31.83 | 81.21 | 80.25 |
| 2019 | 2.12 | 6.31 | 15.70 | 6.22 | 46.01 | 5.66 | 28.43 | 75.43 | 75.30 |
| 2020 | 1.99 | 9.67 | 22.63 | 5.98 | 50.07 | 6.65 | 27.39 | 80.85 | 80.82 |

Source: Calculated by JICA Study Team based on data from the US Department of Commerce

**Figure 5-3-1 Forecast of Cambodian RCA in Major Garment Categories in the US Market (Colour Chart)**




Source: Calculation based on data from the US Department of Commerce

*(e)* ខាងក្រោមនេះគឺជាលទ្ធផលនៃការព្យាករណ៍គុណភាពដែលបានលើកឡើងខាងលើ

ឧត្តមភាពប្រៀបធៀប (RCA) របស់កម្ពុជាក្នុងប្រភេទសំលៀកបំពាក់ ៣៥១ និង៦៥១ (សំលៀកបំពាក់យប់) នឹងមានការធ្លាក់ចុះជាបន្តបន្ទាប់ ដោយសារវិស័យកាត់ដេរកម្ពុជាមានការរីកចំរើនពីសំលៀកបំពាក់ក្នុងទៅរកប្រភេទសំលៀកបំពាក់កណ្តាល និងប្រភេទសំលៀកបំពាក់ក្រៅ ដែលមានការចាប់អារម្មណ៍ខ្ពស់ដូចជាប្រភេទសំលៀកបំពាក់ ៣៤២ (សំពត់កូតុង) និងប្រភេទសំលៀកបំពាក់ ៣៤០ (អាវបុរស/ក្មេងប្រុសផលិតពីកូតុងត្បាញ)។ នៅពេលអនាគត ការពង្រីកការផលិតទៅរកផលិតផលក្រណាត់ត្បាញដែលមានតំលៃខ្ពស់ជាងតំលៃនៃផលិតចាក់នឹងត្រូវធ្វើជាចាំបាច់ ពីព្រោះរោងចក្រកាត់ដេរត្រូវតែខិតខំប្រែង ដើម្បីឆ្លើយតបទៅនឹងការឡើងថ្លៃប្រាក់បៀវត្សនៅក្នុងប្រទេសកម្ពុជា តាមរយៈការកើនតំលៃក្នុងមួយឯកតានៃផលិតផលផលិតពីក្រណាត់ត្បាញ។

- ឧត្តមភាពប្រៀបធៀប (RCA) របស់កម្ពុជាទៅលើប្រភេទមុខទំនិញផ្សេងៗទៀត នឹងរក្សាក៏រិតថេរ បើទោះបីជាប្រទេសកម្ពុជានឹងត្រូវប្រឈមមុខ នឹងការប្រកួតប្រជែងកាន់តែតឹងរឹងឡើងនៅលើឆាកអន្តរជាតិបន្ទាប់ពីឆ្នាំ២០០៥ ក៏ដោយ។ ទោះបីមានការប្រកួតប្រជែងតឹងរឹងនៅលើឆាកអន្តរជាតិក៏ដោយ ក៏ប្រសិទ្ធភាពក្នុងការប្រកួតប្រជែងរបស់កម្ពុជាជារួមនឹងមិនធ្លាក់ចុះឡើយ ដោយសារភាពខុសគ្នានៃប្រភេទសំលៀកបំពាក់របស់កម្ពុជា និង ចិនដូចបានធ្វើការវិភាគពីមុន។

## ៥.៣.២ គំរូជាលទ្ធភាពនៃផលិតកម្មនៅកម្ពុជា (គំរូធុរៈកិច្ច)

### (i) ឧទាហរណ៍ផ្សេងៗនៃលទ្ធផលពីការអង្កេតតាមរយៈការសម្ភាសន៍

ដើម្បីនឹងបង្កើតផែនការសកម្មភាពសំរាប់ទាក់ទាញអ្នកផលិតសំលៀកបំពាក់ជប៉ុនចូលមកប្រទេសកម្ពុជា ជំនាញការម្នាក់នៃក្រុមសិក្សា JICA បានធ្វើការអង្កេតដោយសម្ភាសន៍ជាមួយក្រុមហ៊ុនកាត់ដេរចំនួនជាង ១០០ ក្រុមហ៊ុន ដែលក្នុងនោះមាន សាខាក្រុមហ៊ុនសំលៀកបំពាក់ជប៉ុន ២៥ ក្នុងប្រទេសថៃ ប្រហែល ៣៥ ក្រុមហ៊ុនក្នុងប្រទេសវៀតណាម ក្រុមហ៊ុនសំលៀកបំពាក់ជប៉ុនចំនួនប្រហែល ១០ ក្រុមហ៊ុន ក្នុងស្នាក់ការកណ្តាល និងក្រុមហ៊ុនសំលៀកបំពាក់បរទេស ដែលពុំមែនជាសាខាក្រុមហ៊ុនជប៉ុនចំនួនប្រហែលជា ៣០ នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល (មុខទំនិញ និងក្រុមហ៊ុនដែលមានការចាប់អារម្មណ៍) នៃការអង្កេតដោយបទសម្ភាសន៍មានដូចខាងក្រោម។

(a) ឯកសណ្ឋានការងារ (ក្រុមហ៊ុនដែលមានការចាប់អារម្មណ៍ : ក្រុមហ៊ុន M ក្នុងប្រទេសថៃ ក្រុមហ៊ុន Y ក្នុងទីក្រុងហូជីមិញ ក្រុមហ៊ុន M ក្នុងការិយាល័យកណ្តាលជប៉ុន) ។

**មូលហេតុ**

ផលិតផលទាំងនេះមិនតំរូវការកំរិតជំនាញខ្ពស់ ឬស្តង់ដាត្រួតពិនិត្យខ្ពស់ ។

តំរូវការពុំមានការប្រែប្រួលទៅតាមរដូវកាល ។

ពុំមានការប្រែប្រួលស្ទីល (ម៉ូដ) ។

(b) អាវចាក់ អាវយឺតចាក់ និងខោជើងវែង (ក្រុមហ៊ុន U ក្នុងការិយាល័យកណ្តាលជប៉ុន)

**មូលហេតុ**

ផលិតផលទាំងនេះមិនតំរូវការកំរិតជំនាញខ្ពស់ ឬស្តង់ដាត្រួតពិនិត្យខ្ពស់ ។

កំរិតបច្ចេកទេសខ្ពស់។ ៣) ដោយសារការព្រួយបារម្ភអំពីការវាយតំលៃប្រាក់យ៉ាន់ចិនឡើងវិញ ក្រុមហ៊ុននេះ មានផែនការបន្ថយការពឹងផ្អែកលើការផលិតទំនិញនៅក្នុងប្រទេសចិនពីបច្ចុប្បន្ន ៩០ ភាគរយ ទៅ ៦០ ភាគរយ នៅឆ្នាំ២០១០ ដោយបង្កើនការផលិតនៅអាស៊ីអាគ្នេយ៍។

(c) អាវធម្មតា និងអាវសំរាប់ពាក់ធ្វើការផលិតពីក្រណាត់ត្បាញ (ក្រុមហ៊ុនដែលចាប់អារម្មណ៍ : ក្រុមហ៊ុន Y ក្នុងប្រទេសថៃ)

**មូលហេតុ**

កំណើនតំលៃពលកម្មក្នុងប្រទេសថៃ ។

ការឡើងនូវតំលៃរូបិយវត្ថុថៃ ។ និង

ផលិតភាពទាបក្នុងរោងចក្រដែលឡាវគ្រប់គ្រង។

(d) ស្រោមជើងកុមារ (ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ : ក្រុមហ៊ុន L ក្នុងទីក្រុងហូជីមិញ)

**មូលហេតុ**

ក្រុមហ៊ុនមានបញ្ហាទិញទំនិញក្នុងបរិមាណច្រើន ដែលជាមុខទំនិញធម្មតាមានតំលៃទាបពីសហរដ្ឋអាមេរិក។ ទោះជាយ៉ាងនេះក៏ដោយ ដោយសារកំរិតប្រាក់ចំណេញទាបពេកក្រុមហ៊ុនមិនអាចផលិតសំលៀកបំពាក់ប្រភេទទំនិញនេះក្នុងប្រទេសថៃឡើយ។ ដូចនេះ ក្រុមហ៊ុនកំពុងតែពិចារណាផ្លាស់ទីតាំងមកផលិតក្នុងប្រទេសកម្ពុជា ដែលមានកំរៃប្រាក់ឈ្នួលទាបវិញ។

បុរេលក្ខខណ្ឌ គឺមានក្រុមហ៊ុនដេរប៉ាក់ដ៏រឹងមាំក្នុងប្រទេសកម្ពុជា (មានក្រុមហ៊ុនដេរប៉ាក់ Liya ជាក្រុមហ៊ុនបុរាណមួយ ដែលបានចាប់ផ្តើមប្រតិបត្តិការនៅខែតុលា ឆ្នាំ១៩៩៩ ប្រើប្រាស់ម៉ាស៊ីនប៉ាក់ Tajima IC ចំនួន ៣០ គ្រឿង។

(e) សំលៀកបំពាក់ក្នុង សំលៀកបំពាក់យប់ សំលៀកបំពាក់ដេក សំលៀកបំពាក់ទារក (ក្រុមហ៊ុនដែលចាប់អារម្មណ៍ : ក្រុមហ៊ុន S ក្នុងការិយាល័យកណ្តាលរបស់ជប៉ុន លក់ទំនិញដុំ)

**មូលហេតុ**

- ជាក់ស្តែង ឧស្សាហកម្មសំរាប់ផលិតសម្ភារៈផលិត និងសម្ភារៈជំនួយមិនទាន់មានការរីកចំរើនក្នុងប្រទេសកម្ពុជា និងថាបរិយាកាសដឹកជញ្ជូនទៅបរទេសរបស់កម្ពុជាពុំសូវអំណោយផលនោះ សំលៀកបំពាក់ក្នុងដែលមិនត្រូវការសម្ភារៈផលិត និងសំភារៈជំនួយច្រើនអាចមានឧត្តមភាពប្រៀបធៀបក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន S ក្នុងក្រុងហូជីមិញកំពុងសិក្សាពីការផ្គត់ផ្គង់សម្ភារៈផលិត និងសម្ភារៈជំនួយក្នុងប្រទេសកម្ពុជា។ ប្រសិនបើមានសម្ភារៈទាំងនោះ ស្ថានភាពនឹងមានភាពប្រសើរច្រើន។

(f) ស្រោមដៃសំរាប់កីឡាហ្គុលហ្វ៍ (ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ : ក្រុមហ៊ុន K និង Y ក្នុងប្រទេសថៃ)

**មូលហេតុ**

- អត្រាលើការចំណាយទៅលើកំលាំងពលកម្មសំរាប់ផលិតក្នុងប្រទេសថៃ មានកំរិតខ្ពស់ជាងប្រទេសកម្ពុជាប្រមាណជា២០ភាគរយ ហើយការដេរស្រោមដៃប្រភេទនេះត្រូវការពេលវេលា និងការងារច្រើន។

(ii) **ផែនការជំនួញសំរាប់អ្នកផលិតសំលៀកបំពាក់ជប៉ុន ដែលអាចចាប់ផ្តើមដំណើរការក្នុងប្រទេសកម្ពុជា**

ទីប្រឹក្សាម្នាក់នៃក្រុមសិក្សា JICA បានធ្វើអង្កេតដោយការសម្ភាសជាមួយក្រុមហ៊ុនសំលៀកបំពាក់ជប៉ុន និងសាខាក្រុមហ៊ុនកាត់ដេរជប៉ុននៅក្នុងប្រទេសជប៉ុនដូចបានរៀបរាប់ខាងលើ។ ផែនការធុរៈកិច្ចសំរាប់អ្នកផលិតសំលៀកបំពាក់ជប៉ុន ដែលអាចចាប់ផ្តើមដំណើរការក្នុងប្រទេសកម្ពុជាមានបង្ហាញនៅក្នុងតារាងដូចខាងក្រោម :

**តារាង ៥-៣-៦ ផែនការធុរៈកិច្ចសំរាប់អ្នកផលិតសំលៀកបំពាក់ ដែលអាចចាប់ផ្តើមប្រតិបត្តិការនៅកម្ពុជា**

| | Y Company (Thailand) |
|---|---|
| Product | ・ Production and exports of dress shirts |
| Export | ・ 100% export to Japan, the E.U. |
| Ratio of labor cost | ・ Labor cost/production cost is approximately 15 percent. |
| Raw material | ・ 60% Domestic purchasing |
| Problems in operation | ・ Increasing labor cost and appreciating forex. both in Thailand |

| | Y Company (Thailand) |
|---|---|
| Solutions | · Outsourcing or relocation <Invested already in Bandung (Indonesia), Shanghai, Bangkok and Chitagon (Bangladesh) , Lao PDR> <Outsourcing in China and Vietnam. |
| Conditions for future operation at other sites | · Japanese garment factories do not have a favorable impression of Cambodia due to high electricity costs, corruption, and the past civil war. Top management worries that these negative impressions will result in lowered export prices for Cambodian garments in the Japanese market.<br>· Location outside of a SEZ is desirable due to keeping a certain level wages and avoiding workers easily drawn out to other industries. In the case of location inside of a SEZ, a SEZ should be categorized as specializing in garment and footwear, etc. for keeping the same level of wages.<br>· The cheap unit site prices (below US$10/sqm as seen recently in Bangladesh <US$7/sqm> and Lao PDR <US$2/sqm>) are favorable due to low margin of business |
| Possibilities of operation in Cambodia | · Future possibility of outsourcing or relocation to Cambodia due to increasing labor cost and appreciating forex in Thailand. GSP in Cambodia is very attractive. |
| Business Potentiality (3~5 years decision) | · Y Company has just started up a factory invested in Lao PDR. However, productivity is lower than expected.<br>· After five years, Company Y thinks of Cambodia as a candidate of future production bases. However, before five years Company Y hopes to try sewing-on-commission with its technical support in Cambodia. Y Company would like collect the list of shirt makers in Cambodia (focusing on mainly pure Cambodian factories, Taiwanese affiliated factories, Malaysian affiliated factories). |

| | H Company (Thailand) |
|---|---|
| Product | · Production and exports of down quilts and lamb carpets |
| Export | · 100% exports to Japan |
| Ratio of labor cost | · Labor cost/production cost is approximately 10 percent. |
| Raw material | · Imports from Australia and then imports to Thailand after partial processing in New Zealand. |
| Problems in operation | · Because of a sharp increase in Thai labor cost (at the Thai factory, an average of $250/month, including fringe benefits), started sewing-on-commission in Vientiane, Laos PDR, in October 2004. (Problems in Laos: Female workers did not wash their hands; they did not have the custom of taking shower; and productivity is low.) |
| Solutions | · The use of inexpensive, high-productivity labor force. |
| Conditions for future operation at other sites | · Good ports (for raw materials imports and product exports).<br>· Whether Japan's GSP could be applied in exports to Japan. |
| Possibilities of operation in Cambodia | · Use land transport to a point close to the Thai border (e.g., Poipet) and have the products made on commission there.<br>· If anything should happen to full-scale operation in Cambodia, the Thai plant may transfer to Sihanouk Ville SEZ. |
| Business Potentiality (3~5 years decision) | · Company H will examine the possible application of GSP to its products in the case of production in Cambodia.<br>· If it's OK, Company H will have its products processed sewing-on commission at Thai border by way of trial.<br>· If it will be successful, H Company will think of Cambodia as a candidate of future production bases. |

| | W Company (Thailand) |
|---|---|
| Product | • Production of special uniforms |
| Export | • 100% supply to Japanese affiliated companies in Thailand |
| Ratio of labour cost | • n.a. |
| Raw material | • General materials : Purchasing from Thailand, Special materials : Import from Japan |
| Problems in operation | • A sharp increase in Thai labor cost |
| Solutions | • Due to high profitability special uniforms, a problem is not serious. |
| Conditions for future operation at other sites | • Abundant and inexpensive worker. |
| Possibilities of operation in Cambodia | • Production on commission has been stated from 2005 in Lao PDR. However, productivity is lower than expected.<br>• Production in Cambodia is attractive. Because, there are over 250 foreign factories which have accumulation of garment skills. |
| Business Potentiality (3~5 years decision) | • It may be suitable in Cambodia to produce standard work uniforms.<br>• The reasons are as follows. These products do not require high skill levels or high quality control standards. There are no seasonal fluctuations in demand. There is no change in style.<br>• In order to export to Japan, it may be necessary for three Japanese technicians, for example, enough to provide technical guidance and quality control to workers. It is better to select and bring Thai materials into the Cambodian factory. |

| | U Company (Vietnam) |
|---|---|
| Product | • Production of high-quality women's uniforms including JAL cabin crew |
| Export | • Export ratio is 90 percent, of which 90 percent are for Japan and 10 percent for the U.S. |
| Ratio of labour cost | • Labour cost/production cost is approximately 100 percent due to CMP bases Production. |
| Raw material | • The materials of Vietnam are not useful to High-quality women's uniforms. All of them are imported, of which 60 percent of materials are from Thailand and 40 percent from Japan, Korea, China and Indonesia. |
| Problems in operation | The minimum wage reached to US$60 per month in Ho Chi Min City. The advantage of labour cost is diminishing in Vietnam. |
| Conditions for future operation at other sites | • If Cambodia's infrastructure is developed, its import and export procedures are simplified; it may operate there due to the availability of skilful labour. |
| Possibilities of operation in Cambodia | • A little possibility. Products in Cambodia may be suitable to little modification items in design and no short delivery items among high-quality women's uniforms, if they are not difficult to produce. |
| Business Potentiality (3~5 years decision) | • Not yet |

| | S Company (Vietnam) |
|---|---|
| Product | • Suppliers of various kind of sub-materials to Japanese garment-makers in Vietnam |
| Export | • Sales to Japanese garment makers in Vietnam, |
| Ratio of labour cost | • n.a. |

| | |
|---|---|
| Raw material | • Import items from China, Korea and self-production items |
| Problems in operation | • Nothing particular |
| Conditions for future operation at other sites | • Sales expansion to Japanese garment-makers in overseas |
| Business Potentiality (3~5 years decision) | • Not yet |

| | **S Company (Japan)** |
|---|---|
| Product | • Production of under-wears, knit shirts, woven shirts, children wears |
| Export | • Almost above products are made by own Qingdao factory in China and export to Japan |
| Ratio of labour cost | • n.a. |
| Raw material | • Using Chinese materials mainly |
| Problems in operation | • Qingdao factory being in the red due to a wage increase and a shortage of workforce |
| Conditions for future operation at other sites | • Starting from production on commission somewhere among Vietnam, Cambodia, Myanmar, Lao PDR, and Bangladesh.<br>• Site selection somewhere wage level meets with productivity |
| Business Potentiality (3~5 years decision) | • Form a hasty conclusion |

Source: Compiled by JICA Study Team

### (iii) គំរូធុរៈកិច្ចដែលអាចមានសំរាប់អ្នកផលិតសំលៀកបំពាក់ជប៉ុននៅកម្ពុជា

ផ្អែកលើការអង្កេតដោយកិច្ចសម្ភាសន៍ ដូចបានរៀបរាប់ខាងលើ គំរូធុរៈកិច្ចដែលអាចមានសំរាប់អ្នកផលិតសំលៀកបំពាក់នៅកម្ពុជា អាចត្រូវបានគិតដូចខាងក្រោម:

**តារាង ៥-៣-៧ គំរូធុរៈកិច្ចដែលអាចមានសំរាប់អ្នកផលិតសំលៀកបំពាក់ជប៉ុននៅកម្ពុជា**

| បញ្ហារាំងស្ទះនៅកម្ពុជា | ប្រភេទធុរៈកិច្ចដែលអាចមាន | ប្រភេទទំនិញសមស្រប |
|---|---|---|
| ការបញ្ជាទិញប្រើពេលយូរពី ជប៉ុន និងបញ្ជូនទៅជប៉ុន | ប្រភេទទំនិញមិនក្នុងរដូវ និងមិនទាន់សម័យ | ឯកសណ្ឋានការងារ អាវយឺត |
| ខ្វះខាតការទិញអនុវត្តនៅកម្ពុជា | ប្រភេទទំនិញប្រើប្រាស់បច្ចេកវិទ្យាបោកគក់ | ស្រោមជើងកុមារ ខោអាវ |
| | ប្រភេទទំនិញប្រើប្រាស់អនុ-វត្តនៅកម្ពុជា | ខោស្លីប សំលៀកបំពាក់រាត្រី |
| ភាពខ្សោយនៃកម្មករសំរាប់ដំណើរការស្មុគស្មាញ | ប្រភេទទំនិញជាមួយដំណើរការធម្មតា ប៉ុន្តែធ្វើឡើងវិញ | ស្រោមដៃវាយកូនហ្គោល |

## ៥.៤ អនុសាសន៍ក្នុងការលើកកំពស់ការវិនិយោគផ្ទាល់ទៅក្នុងឧស្សាហកម្មកាត់ដេរ

រហូតដល់ពេលនេះ សមាគមន៍ផលិតសំលៀកបំពាក់កម្ពុជាបានដាក់ចេញនូវអនុសាសន៍មួយចំនួនជូនសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់បន្ថយ ឬលុបបំបាត់កត្តាដែលរាំងស្ទះដល់ការទាក់ទាញវិនិយោគសំខាន់គឺការធ្វើឱ្យមានលក្ខណៈងាយស្រួលចំពោះនីតិវិធីពាណិជ្ជកម្មដោយផ្អែកលើមូលដ្ឋានជាបន្តបន្ទាប់។ អនុសាសន៍ជាបន្ទាន់ដែលបានលើកឡើងនៅថ្ងៃ៥ ខែមិថុនា ឆ្នាំ ២០០៦ នេះគឺជាឧទាហរណ៍មួយ។ ឧបសគ្គទាំងនេះគឺជាបញ្ហារួមរបស់ ក្រុមហ៊ុនកាត់ដេរជប៉ុនដែលបានត្រៀមខ្លួន ហើយជាស្រេចក្នុងការធ្វើវិនិយោគទុនក្នុងប្រទេសកម្ពុជានាពេលអនាគតដ៏ខ្លីខាងមុខ។ បញ្ហាទាំងនោះនឹងលើកឡើងនៅក្នុងជំពូកខាងក្រោយដោយមានការបង្កើតផែនការសកម្មភាពសំរាប់ទាក់ទាញអ្នកផលិតសំលៀកបំពាក់ជប៉ុនចូលមកប្រទេសកម្ពុជា។ ជាងនេះទៀត នៅពេលកត្តាអវិជ្ជមានជាច្រើននៃប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាត្រូវបានដោះស្រាយជាបន្តបន្ទាប់ហើយនោះ បញ្ហាជាច្រើនទៀតនៃប្រព័ន្ធរដ្ឋបាលគួរតែត្រូវបានដោះស្រាយតាមជាមួយប្រព័ន្ធច្បាប់ ទាំងនេះផងដែរ។

បន្ថែមទៅនឹងអនុសាសន៍ខាងលើ ក្រុមសិក្សា JICA ដាក់ចេញអនុសាសន៍នានាដូចខាងក្រោមទាក់ទងនឹងការលើកកំពស់ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកាត់ដេរក្នុងប្រទេសកម្ពុជា ដោយពិនិត្យទៅលើទស្សនវិស័យរយៈពេលមធ្យម និងវែង ដែលផ្អែកលើលទ្ធផលនៃការអង្កេតដោយការសម្ភាសន៍ជាមួយក្រុមហ៊ុនកាត់ដេរជប៉ុនកំពុងដំណើរការក្នុងប្រទេសជិតខាងកម្ពុជា។ អនុសាសន៍ទាំងនេះមិនមានន័យដើម្បីបំបាត់ចោលកត្តាអវិជ្ជមានផ្សេងៗទាំងស្រុងទេ ប៉ុន្តែសំរាប់អភិវឌ្ឍន៍គោលនយោបាយជំរុញការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសចូលក្នុងឧស្សាហកម្មកាត់ដេរ។

### (1) **កំណែលំអផលិតភាពក្នុងរយៈពេលខ្លី**

មិនមានសុវត្ថិភាពដែលនិយាយថា ផលិតភាពនៃឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជាមានកំរិតខ្ពស់ជាង ផលិតភាពរបស់ប្រទេសផ្សេងៗទៀតទេ។ រោងចក្រសំលៀកបំពាក់របស់ចិនដីគោកមួយចំនួនដែលបានធ្វើវិនិយោគនៅក្នុង ប្រទេសកម្ពុជាចង្អុលបង្ហាញថាគុណភាពរបស់កម្មករកម្ពុជាគួរតែត្រូវបានធ្វើអោយប្រសើរឡើងដើម្បីពង្រីកផលិតភាព។ រហូតដល់បច្ចុប្បន្ន ជំនាញការជប៉ុនដែលបញ្ជូនមកម្នាក់ បានបង្រៀនបច្ចេកទេសដេរជាមូលដ្ឋាននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលកាត់ដេរកម្ពុជា។ ទោះបីជាយ៉ាងនេះក៏ដោយ តាមរយៈតែប្រព័ន្ធនៅក្នុងមជ្ឈមណ្ឌលនេះ វាមិនគ្រប់គ្រាន់ដើម្បីនាំចេញទៅកាន់ជប៉ុន ដែលបទដ្ឋានគុណភាពគឺខ្ពស់បំផុត។ អាស្រ័យហេតុនេះ ក្រុមសិក្សា JICA បានចាត់បញ្ជូនជំនាញការដែលមានបទពិសោធន៍ខ្ពស់ក្នុងការត្រួតពិនិត្យគុណភាព និងកំណែលំអផលិតភាពខាងផលិតសំលៀកបំពាក់ជប៉ុនមួយរូប ទៅកាន់សមាគមន៍កាត់ដេរកម្ពុជា（GMAC）។ ដើម្បីធ្វើការនាំចេញសំលៀកបំពាក់ទៅកាន់ប្រទេសជប៉ុន អ្នកជំនាញការគួរ ជួបរោងចក្រនានារបស់ GMAC ដើម្បីផ្តល់ការណែនាំ ជាពិសេសទៅលើការវិភាគដំណើរការផលិតកម្ម និងការកំណត់ស្តង់ដា ដំណើរការផលិតការរៀបចំគ្រឿងយន្តឱ្យបានល្អប្រសើរ និងការគ្រប់គ្រងផលិតភាព ព្រមទាំងស្វែងយល់ប្រការផ្សេងៗដើម្បីកែលំអរផលិតភាព។ ការកែលំអរផលិតភាពគឺជាលក្ខខណ្ឌ

មួយក្នុងចំណោមលក្ខខណ្ឌសំខាន់ៗ ដើម្បីជំរុញឱ្យក្រុមហ៊ុនផលិតសំលៀកបំពាក់ជប៉ុនធ្វើការផលិតដោយស៊ីកំរៃជើងសារ និងធ្វើវិនិយោគក្នុងប្រទេសកម្ពុជា។ ជាបន្ថែម ដូចជាបញ្ហានៃទិសដៅអនាគត ការបណ្តុះបណ្តាល គួរតែចាប់ផ្តើមពីកម្មវិធី ដើម្បីផ្តោតលើការពង្រឹងបច្ចេកវិទ្យាដេរ និងការគូសថ្នែម៉ូដ។

(2) **ការពង្រីកពិពដ្ឍកម្មទីផ្សារនាំចេញក្នុងរយៈពេលខ្លី**

ទីផ្សារសំរាប់ការនាំផលិតផលសំលៀកបំពាក់កម្ពុជាទៅកាន់សហរដ្ឋអាមេរិកមានទំហំយ៉ាងធំរហូតដល់ ៨០ ភាគរយនៃការនាំចេញសំលៀកបំពាក់ទាំងអស់។ ដើម្បីពង្រីកទីផ្សារនាំចេញរបស់ប្រទេស ទីផ្សារកម្ពុជាគួរតែត្រូវបានធ្វើពិពិធកម្ម ដោយរាប់បញ្ចូលទាំងទីផ្សារប្រទេសជប៉ុន រុស្ស៊ី និងមជ្ឈិមបូព៌ា។ បង្កើតឱ្យមានវគ្គបណ្តុះបណ្តាលមួយស្តីពីការត្រួតពិនិត្យគុណភាព CGTC បង្កើតដើម្បីលើកកំពស់ការប្រកួតប្រជែងលើការនាំចេញទៅកាន់សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប និងជាពិសេសនាំទៅកាន់ប្រទេសជប៉ុន។

**(៣) បង្វែរទៅធ្វើការផលិត-និង-នាំចេញក្នុងរយៈពេលខ្លី និងមធ្យម**

ដើម្បីពន្លឿនការផ្លាស់ប្តូរពីការកាត់ដេរដោយស៊ីកំរៃជើងសារទៅការផលិត-និង-នាំចេញ ការប្រមូលថវិកាសំរាប់ទិញសម្ភារៈផលិត និងហិរញ្ញប្បទានទៅលើរោងចក្រ និងធនធានផលិតគឺជាបុរេលក្ខខណ្ឌសំរាប់ការផលិត-និង-ការនាំចេញ។

**(៤) ការបង្កើតឱ្យមានមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្នុងរយៈពេលមធ្យម**

ចាំបាច់ត្រូវបង្កើតឱ្យមានមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយ（Central Bonded Warehouse-CBW）ដើម្បីបន្ថយពេលវេលាដែលត្រូវចំណាយសំរាប់ធ្វើការនាំចូលនូវសម្ភារៈ/វត្ថុធាតុដើម។ ឃ្លាំងទំនិញរួចពន្ធគយៈ ផែនការថ្មៃប្រឌិតថ្មីដែលជាដំណោះស្រាយបញ្ហាការប្រើរយៈពេលយូរនោះគឺការបង្កើតមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយ។ ជាទស្សនាទានមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយមានលក្ខណៈស្រដៀងគ្នាទៅនឹងឃ្លាំងទំនិញរួចពន្ធគយផ្សេងៗ ដែលរោងចក្រផលិតទំនិញសំរាប់នាំចេញទីមួយៗទទួលបានសិទ្ធិស្តុកសម្ភារៈ/វត្ថុធាតុដើមដែលបាននាំចូលដោយមិនបាច់បង់ពន្ធ។ លក្ខណៈខុសគ្នានោះត្រង់ថា ក្រុមហ៊ុនអាចបង្កើតឃ្លាំងទំនិញរួចពន្ធគយហើយការនាំចូលដោយរួចពន្ធនៃ RMG និងវត្ថុធាតុដើមវាយនភ័ណ្ឌនឹងមិនត្រូវភ្ជាប់លក្ខខណ្ឌទៅនឹងលិខិតបញ្ជាក់គុណសម្បត្តិឡើយ LCs ។ អ្នកប្រតិបត្តិឃ្លាំងទំនិញរួចពន្ធគយ គួរមានសិទ្ធិស្តុកសម្ភារៈ/វត្ថុធាតុដើម T & C ច្រើនប្រភេទ ដូចជាសរសៃសំរេច និង សរសៃប្រផេះ គ្រឿងជំនួយ ថ្នាំជ្រលក់សំពត់ និងសារធាតុគីមី អំបោះ គ្រឿងចក្រ វាយនភ័ណ្ឌ និង RMG និងគ្រឿងបន្លាស់ទៅតាមចំនួនណាមួយ។ អ្នកផលិតសំលៀកបំពាក់អាចទិញសម្ភារៈ/វត្ថុធាតុដើមរួចពន្ធទាំងនោះ ផ្ទាល់ពីឃ្លាំងទំនិញរួចពន្ធគយ។ ប្រព័ន្ធចាំបាច់មួយចំនួនត្រូវតែបង្កើតឡើង （ដូចជាការកំណត់ទីតាំងឃ្លាំងទំនិញរួចពន្ធ គយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសជាដើម） ដើម្បីធានាថា សម្ភារៈ/វត្ថុធាតុដើមសំរាប់ឧស្សាហកម្មត្រូវបានយកទៅប្រើប្រាស់ជាក់ស្តែងសំរាប់

ផលិតទំនិញដើម្បីនាំចេញ។ ម្យ៉ាងទៀត ដើម្បីការពារផលប្រយោជន៍នៃឧស្សាហកម្មដែលមានសមត្ថភាពប្រកួតប្រជែងក្នុងស្រុក គេអាចធ្វើការដាក់បំរាមមួយចំនួនទៅលើមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយដែលទាក់ទងទៅនឹងលំដាប់បរិមាណ និងប្រភេទនៃសម្ភារៈ/ វត្ថុធាតុដើម ដែលមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយអាចផ្ទុកបាន។

ថ្វីបើដូចនេះក៏ដោយ ក៏ដំណើរការនៃមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយដោយសហគ្រិនឯកជនអាចពាក់ព័ន្ធទៅនឹងការចំណាយមួយចំនួន។ សន្និធិដ៏ធំនៃធាតុចូលផលិតកម្មត្រូវតែរក្សាទុក ប្រសិនបើចង់ឱ្យប្រព័ន្ធឃ្លាំងទំនិញរួចពន្ធគយដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការនេះមានជាប់ពាក់ព័ន្ធទៅនឹងការចំណាយហិរញ្ញប្បទាន។ សហគ្រិនត្រូវតែទទួលបាននូវរង្វាន់លើកទឹកចិត្តសមស្របជាមួយប្រាក់ចំណេញខ្ពស់ដើម្បីបន្តក្នុងធុរៈកិច្ចរបស់ពួកគេ។ ការផ្តល់នូវរង្វាន់លើកទឹកចិត្តនេះនឹងត្រូវបន្ថែមទៅលើតំលៃធាតុចូលផលិតកម្ម។ ការផ្លាស់ប្តូរទំនិញពីរដង និងលក្ខខណ្ឌនៃការទូទាត់ ក៏ជំរុញឱ្យមានកំណើនតំលៃផងដែរ។ អ្នកផលិត RMG នឹងទិញពីមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយដរាបណាតំលៃនៃធាតុចូលផលិតកម្ម ដែលត្រូវផ្គត់ផ្គង់ពីមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយថោកជាងតំលៃផ្គត់ផ្គង់ដូចគ្នាដែលគេបញ្ជាទិញពីបរទេស តាមរយៈការបញ្ចុះតំលៃពីឃ្លាំងទំនិញរួចពន្ធគយសំរាប់បន្ថយការចំណាយពេលវេលាបញ្ជូនទំនិញ។ ប្រសិនបើមិនអាចធានាឱ្យមានតំលៃទាបទេនោះ មូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយមិនអាចមានចីរភាពបានទេ។ ប្រសិនបើសហគ្រិនមើលឃើញលទ្ធផលដូចនេះ ពួកគេនឹងមិនវិនិយោគទៅលើធុរៈកិច្ចមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយឡើយ បើទោះបីពួកគេមានការអនុញ្ញាតពីរាជរដ្ឋាភិបាលក៏ដោយ។ ម្យ៉ាងទៀត បើពួកគេបានវិនិយោគមិនត្រឹមត្រូវហើយក្តី ក៏ពួកគេនឹងបោះបង់ចោលវិនិយោគនោះភ្លាម។ ពុំមានមូលនិធិសារណៈដែលត្រូវបានគេប្រើសំរាប់បង្កើតមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយឡើយ។

សហគ្រិនទាំងនោះអាចរកបាននូវវត្ថុធាតុដើមរបស់គេដូចជា អំបោះ កំណាត់ប្រផេះ ថ្នាំជ្រលក់កំណាត់ និងសារធាតុគីមីជាដើមពីមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយ។ ពួកគេក៏អាចទិញវត្ថុធាតុដើមដែលមូលដ្ឋានឃ្លាំងទំនិញរួចពន្ធគយ បានទិញក្នុងបរិមាណដ៏ច្រើនក្នុងតំលៃទាប និងអាចបញ្ជាទិញពីក្រុមហ៊ុនសំលៀកបំពាក់ក្នុងស្រុកដោយមិនបាច់ ចំណាយពេលវេលាច្រើនក្នុងការដឹកជញ្ជូន ឬក្នុងការនាំចូលវត្ថុធាតុដើមទាំងនោះ។ ឃ្លាំងរួចពន្ធគយកណ្តាល អាចចូលរួមយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពមិនច្បាស់លាស់នៃការនាំសម្ភារៈ/វត្ថុធាតុដើមពីបរទេស។ ដូចបានដឹងស្រាប់ហើយថាការនាំសម្ភារៈ/វត្ថុធាតុដើមពីបរទេស អាចជួបប្រទះទៅភាពយឺតយ៉ាវក្នុងការដឹកជញ្ជូន ពេលវេលាដឹកជញ្ជូនការផ្លាស់ប្តូរក្នុងការដឹកជញ្ជូន ឬការជញ្ជូនចេញពីផែកប៉ាល់។ ការពន្យាណាមួយគឺជាការចំណាយ ដ៏សំខាន់របស់ម្ចាស់សហគ្រាស/រោងចក្រដែលផលិតទំនិញសំរាប់នាំចេញ ពីព្រោះថាពួកគេមានពេលវេលាតិចសំរាប់ផលិតទំនិញ និងអាចបញ្ជូនផលិតផលបង្ហើយតាមយន្តហោះ ដែលត្រូវចំណាយយ៉ាងខ្ពស់។ ការយឺតយ៉ាវក៏អាចបណ្តាលឱ្យមានការលុបចោលការបញ្ជាទិញ។ ករិតនៃប្រាក់កំរៃអាចធ្លាក់ចុះ ឬបាត់បង់ទាំងស្រុង ដោយសារតែបញ្ហាយឺតយ៉ាវនេះ។

(5) **ការទាក់ទាញដើមទុនបរទេសសំរាប់ផលិតធនធានផ្គត់ផ្គង់ផលិតកម្ម និងឧស្សាហកម្មគាំទ្រក្នុងរយៈពេលមធ្យម និងវែង**

បញ្ហាមួយក្នុងចំណោមបញ្ហានានាដែលឧស្សាហកម្មកម្ពុជាជួបប្រទះគឺថា ប្រទេសកម្ពុជាមានធនធានផលិតកម្មផ្ទាក់

កណ្តាល (ផ្នែកផលិតកម្ម) ពោលគឺមានពលកម្មសម្បូរបែប និងមានកំរៃឈ្នួលទាប ប៉ុន្តែពុំមានធនធានសំរាប់ផ្គត់ផ្គង់ផលិតកម្ម (ផ្នែករវៃ ចាក់ និងត្បាញ) ឬវិស័យទ្រទ្រង់ឧស្សាហកម្ម (គ្រឿងបន្លាស់ និងសម្ភារៈជំនួយ)។ អាស្រ័យហេតុនេះ កម្ពុជាចាំបាច់ធ្វើការទាក់ទាញដើមទុនបរទេសសំរាប់វិស័យផលិតធនធានសំរាប់ផ្គត់ផ្គង់ និងឧស្សាហកម្មគាំទ្រឱ្យចូលមកក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផលិតធនធានសំរាប់ផ្គត់ផ្គង់ទាំងនោះនៅក្នុងស្រុកនិងដើម្បីកាត់បន្ថយពេលវេលាពីចាប់ផ្តើមដល់បង្ហើយការ។ នៅពេលអនាគតដ៏ខ្លីខាងមុខ ដើមទុនបរទេសគួរប្រើប្រាស់សំរាប់វិស័យផលិតធនធានផ្គត់ផ្គង់ ដូចជាការរវៃអំបោះចាក់ ការត្បាញកំណាត់កូតុង និងការជ្រលក់ពណ៌ ដែលការផលិតធនធានទាំងនេះពុំតំរូវឱ្យមានការវិនិយោគទុនច្រើនឡើយ។ ដើម្បីជំរុញឱ្យមានការផលិតធនធានសំរាប់ផ្គត់ផ្គង់ទាំងនេះ កម្ពុជាត្រូវប្រើប្រាស់វិធានការពិសេសចាំបាច់ផ្សេងៗ ដូចជា ការកាត់ពន្ធលើការវិនិយោគការបញ្ចុះតំលៃពិសេសទៅលើគ្រឿងចក្រ និងឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត។

# ជំពូក ៦
# ទស្សនៈវិស័យ និងអនុសាសន៍ស្តីពីឱកាសវិនិយោគ សំរាប់ការទាក់ទាញ ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផលមកកម្ពុជា

## ៦.១ ចរិកលក្ខណៈនៃកសិ-ឧស្សាហកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា

កម្ពុជា សម្បូរទៅដោយធនធានជលផល និងកសិកម្ម។ អត្រាផលធៀបនៃវិស័យកសិកម្ម និងជលផល មានចំនួន៣២,៩% នៃផលិតផលសរុបក្នុងស្រុក (GDP) ក្នុងឆ្នាំ ២០០៤ (ផ្នែកសូចនាករសំខាន់ៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុង ឆ្នាំ 2006)។ នៅក្នុងឯកសារឆ្នាំដដែល អត្រាផលធៀបនៃកំលាំងពលកម្មក្នុងវិស័យនេះ មានទំហំធំជាងរហូតដល់ ៦០,៣%។ នៅក្នុងកាលៈទេសៈបែបនេះ គេអាចនិយាយបានថា កំណើនសេដ្ឋកិច្ចដែល គេបានរំពឹងទុក គឺអាស្រ័យទៅលើការជំរុញនូវវិស័យកសិ-ឧស្សាហកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហារ។ ទ្រង់ទ្រាយនៃវិស័យកសិ-ឧស្សាហកម្ម និងជលផលកម្ពុជា នឹងត្រូវលើកយកមក បង្ហាញ ដូចខាងក្រោម :

### ៦.១.១ ផលិតកម្មស្រូវ

- ដីប្រកបដោយជីវជាតិដែលលាតសន្ធឹងតាមបណ្តោយដងទន្លេមេគង្គមានលក្ខណៈអំណោយផលយ៉ាងខ្លាំងដល់ការដាំដុះដំណាំស្រូវ ហើយផ្ទៃដី ដាំដំណាំប្រមាណជា ៥០% នៅកម្ពុជា ដែលមានទំហំ ២,៣៤៣,000 ហិចតា ត្រូវបានប្រើប្រាស់សំរាប់ដំណាំស្រូវនេះ[1]។ អាស្រ័យដោយមានស្ថេរភាពនយោបាយ ដែលបានសម្រេច បានពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ និងការបោះឆ្នោតជាសកលឆ្នាំ ១៩៩៣ បានជំរុញឱ្យទិន្នផលស្រូវមានការកើនឡើងជាលំដាប់ស្របគ្នានឹងការ កើនឡើងជាបន្តបន្ទាប់នូវផ្ទៃដីដាំដុះ។
- តាមពិត បរិមាណផលស្រូវមានការកើនឡើងពីចំនួនប្រមាណ២ លានតោន ទៅ៣,៤៥ លាន តោនក្នុងឆ្នាំ១៩៩៥ ហើយបន្ថមកដល់ពេលនេះមានចំនួនប្រមាណ៤ លានតោន។ អាស្រ័យដោយកត្តាអាកាសធាតុមានលក្ខណៈអំណោយផល ហើយទិន្នផលស្រូវនៅកម្ពុជាមានការកើនឡើង ៤៤% ដែលជាហេតុនាំអោយបរិមាណផលស្រូវសរុបនៅឆ្នាំ ២០០៥ មានរហូតដល់៥,៩៩ លានតោន។
- ការកើនឡើងនៃបរិមាណផលស្រូវនេះ ធានាដល់ការផ្គត់ផ្គង់បានគ្រប់គ្រាន់នៅក្នុងប្រទេស និងបាននាំចេញបរិមាណផលស្រូវដែលលើសពីតម្រូវការប្រើប្រាស់ទៅទីផ្សារបរទេសទៀតផង។

  ទោះជាយ៉ាងណាមានការកត់សំគាល់ឃើញថា ការប្រមូល ទិន្នផលស្រូវក្នុងមួយហិចតានៅកម្ពុជា មានទិន្នផលស្រូវប្រមាណ ជា២ តោន ក្នុងមួយហិចតា ដែលមានទំហំតិចជាងគេបំផុត បើប្រៀបធៀបទៅនឹងទិន្នផលស្រូវនៅតាមបណ្តាប្រទេសនៅក្នុងតំបន់ចិន។ បើប្រៀបធៀបទិន្នផល ស្រូវជាមួយប្រទេសវៀតណាម

[1] *MAFF, "Agricultural Statistics 2004-2005*

ឃើញថា ប្រទេសវៀតណាម ផលិតស្រូវបានចំនួនប្រមាណជា ៥ តោនក្នុងមួយហិកតា។

**តារាង ៦-១-១ ផលិតកម្មស្រូវ**

| | 1995 | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| តំរូវការ | 2,481 | 3,095 | 2,997 | 3,081 | 3,027 | 2,978 | 3,146 |
| ផលិតកម្ម | 3,448 | 4,026 | 4,099 | 3,823 | 4,711 | 4,170 | 5,986 |

កំណត់សំគាល់ : ឯកត្តា = ១,000តោន

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ស្ថិតិកសិកម្ម"

- អាស្រ័យដោយប្រព័ន្ធធារាសាស្ត្រនៅមិនទាន់មានការអភិវឌ្ឍន៏ល្អនៅកម្ពុជា (មានការប៉ាន់ស្មានថាប្រព័ន្ធធារាសាស្ត្រកម្ពុជាមានអត្រាប្រមាណជា ២០%ប៉ុណ្ណោះ) ការផលិតស្រូវត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងលើអាកាសធាតុនៅក្នុងប្រទេសកម្ពុជា ពិសេសគឺការពឹងផ្អែកលើទឹកភ្លៀង។ ប្រសិនបើធ្វើការប្រៀបសមមាត្រនៃប្រព័ន្ធធារាសាស្ត្ររបស់ប្រទេសកម្ពុជា ទៅនិងបណ្តាប្រទេសជិតខាង ឃើញថាប្រទេសទាំងនោះមានសមមាត្រខ្ពស់ជាង ដូចជានៅប្រទេសថៃមានអត្រា ៣១% ហើយនៅប្រទេសវៀតណាម[២] មានអត្រា ៤៥%។
- ផ្ទៃដីនៅប្រទេសកម្ពុជាមានលក្ខណៈរាបស្មើ អាស្រ័យហេតុនេះ នាំអោយមានការលំបាកចំពោះការណែនាំក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្ថានភាពខុសគ្នានៃរយៈកម្ពស់បើធៀបទៅនឹងសមុទ្រ។
- ថ្វីត្បិតតែគុណវិបត្តិនៃសណ្ឋានដីខាងលើ ការអភិវឌ្ឍន៏ប្រព័ន្ធធារាសាស្ត្រ នៅតែជាកត្តាសំខាន់ជាទីបំផុតក្នុងការធានាអោយបាននូវប្រសិទ្ធិភាពខ្ពស់នៃការផលិតស្រូវ។ មានមូលហេតុមួយក្នុងបណ្តាមូលហេតុជាច្រើនដែលបណ្តាលឱ្យផលិតកម្មស្រូវនៅកម្ពុជា នៅមានគុណភាព អាស្រ័យដោយមានកំរិតសំណើមតិច និងប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេសនេះ នៅមានស្ថានភាពទន់ខ្សោយ។
- គួបផ្សំនិងកត្តាមួយចំនួនទៀត ដូចជាភាពយឺតយ៉ាវក្នុងការអនុម័តច្បាប់ភូមិបាល កង្វះខាតបច្ចេកវិទ្យាកសិកម្ម ជី និងប្រព័ន្ធធារាសាស្ត្រ ដែលមានលក្ខណៈទ្រុឌទ្រោម ជាមូលហេតុនាំអោយទិន្នផលស្រូវនិងដំណាំដទៃទៀតមានបរិមាណទាប អាស្រ័យហេតុនេះ កត្តាទាំងនេះគួរតែត្រូវបានធ្វើការកែលំអ ដើម្បីសំរេចអោយបាននូវកំណើនទិន្នផលស្រូវនិងដំណាំដ៏ទៃទៀត។

## ៦.១.២ ផលិតផលកសិកម្មដទៃទៀត

- បន្ថែមទៅលើដំណាំស្រូវ ដំណាំពោត ដំឡូងឈើ ដំឡូងជ្វា សណ្តែកបាយ បន្លែបង្កា សណ្តែកដី សណ្តែកសៀងអំពៅ ល្ង និងថ្នាំជក់ ត្រូវបានគេដាំជាផលិតផលចម្បង ប៉ុន្តែទំហំនៃការដាំដុះនៅមានទ្រង់ទ្រាយតូច។
- លើសពីនេះទៀត តំលៃពាណិជ្ជកម្មនៃផលដំណាំ នៅមានតំលៃទាបដោយសារតែកសិករមិនទាន់ចេះប្រើ

[2] *EIC, "Cambodia Agriculture Development Report", June 2006*

ប្រាស់ដីឱ្យមានប្រសិទ្ធិភាពខ្ពស់ ដូចជាការបំផ្លាញចោលស្មៅឥតប្រយោជន៏ និងកត្តាចង្រៃផ្សេងទៀត ។

- ក្នុងចំណោមផលិតផលកសិកម្មខាងលើ ផលិតផលដំឡូងមីមានចំនួនកើនឡើងគួរឱ្យកត់សំគាល់ ដោយសារតែកំណើនតំរូវការម្សៅមី ។ បរិមាណដ៏ច្រើននៃដំឡូងមីត្រូវបានគេលួចរត់ពន្ធទៅលក់នៅក្នុងប្រទេសថៃ និងវៀតណាម ។ ក្រុមហ៊ុន កំពុងតែសកម្មក្នុងការដាំដំឡូងមីក្នុងប្រទេសកម្ពុជា មានដូចជា ក្រុមហ៊ុនអភិវឌ្ឍន៏ដំណាំកសិកម្ម T.T.Y. និងក្រុមហ៊ុន សហប្រតិបត្តិការ Imex និង Cambodia CJ ។ ក្រុមហ៊ុនសហប្រតិបត្តិការ Imex និង Cambodia CJ គឺជាសាខាក្រុមហ៊ុនកូរ៉េខាងត្បូងមួយ ដែលជាក្រុមហ៊ុនធ្វើការនាំចេញម្សៅមីដែលធ្វើការដាំនៅកម្ពុជាទៅកាន់រោងចក្រក្នុងប្រទេសឥណ្ឌូនេស៊ីដើម្បីផលិតប៊ីចេង ។
- សម្រាប់ផលិតផលដូងប្រេង មានក្រុមហ៊ុនតែមួយប៉ុណ្ណោះ ដែលរកស៊ីដាំដំណាំនេះនៅកម្ពុជា គឺ ក្រុមហ៊ុន ម៉ុង ឫទ្ធី ។ អត្រានៃផលិតកម្មដូងប្រេងនៅកម្ពុជា គឺមានបរិមាណចំនួន៥តោន ក្នុងមួយម៉ោង ដែលជាចំនួនមានទំហំទាបជាងការផលិតនៅម៉ាឡេស៊ី ដោយគេអាចទាញយកផលបានដល់ទៅ ៥០ តោនក្នុងមួយម៉ោង ។ ក្រុមហ៊ុន ម៉ុង ឫទ្ធី បានអោយក្រុមហ៊ុនម៉ាឡេស៊ីជាអ្នកចំហុយផលិតផលដូងប្រេងទាំងអស់ ហើយបាននាំចូលផលិតផលសម្រេចមកលក់នៅកម្ពុជាវិញ ។
- កសិករមិនដាំបន្លែជាទ្រង់ទ្រាយធំសម្រាប់គោលដៅពាណិជ្ជកម្មទេ ប៉ុន្តែគេផលិតដំណាំសម្រាប់ចិញ្ចឹមគ្រួសារគេរៀង១ខ្លួន ។ បន្លែ ស្ទើរតែទាំងអស់ដែលគេប្រើប្រាស់នៅតាមភោជនីយដ្ឋាន ឬសណ្ឋាគារ នៅប្រទេសកម្ពុជា អាចនាំចូលមកពីប្រទេសថៃ និងប្រទេសវៀតណាម ។

**តារាង ៦-១-២ ផលិតកម្មនៃផលិតផលកសិកម្មដទៃទៀត**

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| Cassava | 148 | 142 | 122 | 331 | 362 | 536 |
| Maize | 157 | 186 | 149 | 315 | 257 | 248 |
| Yellow coan | 122 | 158 | 117 | 287 | 224 | 192 |
| Vegetable | 196 | 185 | 143 | 140 | 179 | 172 |
| Sugar cane | 164 | 169 | 209 | 173 | 130 | 118 |
| Soybean | 28 | 25 | 39 | 63 | 110 | 179 |
| Sesame | 10 | 9 | 10 | 22 | 55 | 90 |
| Mung bean | 15 | 17 | 24 | 32 | 45 | 45 |
| Sweet potato | 28 | 26 | 32 | 35 | 35 | 39 |

កំណត់សំគាល់ : ឯកត្តា = ១,000តោន

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ស្ថិតិកសិកម្ម"

## ៦.១.៣ ផ្លែឈើនៅតំបន់ត្រូពិច

- ប្រទេសកម្ពុជា បានផ្តល់លក្ខខណ្ឌធម្មជាតិដ៏សំបូរបែប ដែលជាកត្តានាំអោយផ្លែឈើនៅក្នុងតំបន់ត្រូពិច អាច

ដុះលូតលាស់បាន ជាការពិតណាស់នៅក្នុងប្រទេសនេះ មានឈើស៊ីផ្លែនៅតំបន់ត្រូពិចដុះលូតលាស់ពាសពេញផ្ទៃប្រទេស។ ប៉ុន្តែ ដោយសារគ្មានទីផ្សារដើម្បីទទួលយកសំរាប់ទីក្រុងធំៗនោះ ទើបផ្លែឈើទាំងនោះមិនត្រូវបានធ្វើការនាំចេញដោយគ្រាន់តែត្រូវបានគេប្រើប្រាស់សំរាប់ក្នុងស្រុក ហើយគ្រាន់តែមានផលិផលមួយចំនួនដូចជា គ្រាប់ស្វាយចន្ទីត្រូវបានគេដាំដុះសំរាប់គោលដៅពាណិជ្ជកម្មទ្រង់ទ្រាយធំ។

- អាស្រ័យដោយឈើហូបផ្លែភាគច្រើនត្រូវបានដាំដោយក្រុមកសិករក្នុងទ្រង់ទ្រាយតូច អាចនិយាយបានថាផលិតផលផ្លែឈើជួបប្រទះនូវបញ្ហា ដូចជាមានគុណភាពអន់ និងការផ្គត់ផ្គង់គ្មានស្ថេរភាព។ មូលហេតុទាំងនេះបណ្តាលមកពីទីផ្សារសំរាប់ផលិតផលផ្លែឈើមានតំលៃទាប។
- តួលេខស្តីពីចំពោះផលិកម្មផ្លែឈើត្រូពិចនៅកម្ពុជានៅពុំទាន់មានការអភិវឌ្ឍន៍។ ដោយយោងទៅតាមការចងក្រងតួលេខដោយអង្គការ FAO ការនាំចេញរបស់កម្ពុជានូវផលិផលកសិផលមានចំនួនត្រឹមតែ ០,០០៩១ ភាគរយ នៅក្នុងតួលេខ នាំចេញផលិផលកសិកម្មពិភពលោកក្នុងឆ្នាំ ២០០៤។ ចំនួនសមមាត្រនៃការនាំចេញផ្លែឈើតំបន់ត្រូពិចរបស់កម្ពុជា (រួមមានបន្លែផងដែរ) មានចំនួនតែ ០,០០១១% តិចជាងចំនួនតួលេខនាំចេញនូវផលិត ផលផ្លែឈើត្រូពិចរបស់ពិភពលោកក្នុងឆ្នាំនេះ[៣]។ ម្យ៉ាងទៀត ផលិផលផ្លែស្វាយនៅក្នុងប្រទេសកម្ពុជាមាន ចំនួន ០,១៤% ក្នុងផលិកម្មផ្លែស្វាយរបស់ ពិភពលោកក្នុងឆ្នាំ ២០០៤ ដែលត្រូវបានគេយល់ឃើញថាមានបរិមាណខ្ពស់[៤]។
- ចំពោះផលិតកម្មផ្លែម្នាស់និងផ្លែក្រូចដែលធ្វើក្នុងស្រុកមិនអាចបំពេញតម្រូវការទីផ្សារក្នុងស្រុកបានឡើយ ហើយ ថែមទាំងធ្វើការនាំចូលនូវផលិតផលទាំងនោះពីប្រទេសវៀតណាមនិងប្រទេសថៃថែមទៀតផង។ ទន្ទឹមនឹងនោះ ផលិតផលផ្លែស្វាយត្រូវបានគេនិយាយថាមានការរត់ពន្ធចេញទៅប្រទេសជិតខាងដូចជាប្រទេសវៀតណាម។
- ចំពោះផលិតផលស្វាយចន្ទី អាក្រូស្តា ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីកសិករដែលមានចំនួន ១០ នាក់ បានដំណើរការដាំដុះឈើហូបផ្លែដែលមានទ្រង់ទ្រាយធំលើផ្ទៃដីចាប់ពី២០០០ ហិចតា។ លើសពីនេះ ផលិតផល កសិកម្មនៅក្នុងប្រទេសកម្ពុជា មានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនិងឧស្សាហកម្មវេចខ្ចប់និងកែច្នៃនូវគ្រាប់ស្វាយចន្ទីសំរាប់ធ្វើការនាំចេញ។

**តារាង ៦-១-៣ ផលិតកម្មនៃផ្លែឈើត្រូពិក**

| Item | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| Cashew nut | 15,653 | 37,673 | 36,285 | 37,140 | 52,809 | 60,874 |
| Banana | 30,726 | 34,489 | 30,151 | 26,630 | 29,583 | 29,980 |
| Coconut | 31,621 | 33,950 | 14,664 | 27,054 | 28,399 | 28,424 |
| Mango | 21,533 | 27,004 | 9,903 | 14,068 | 13,740 | 13,701 |
| Jack fruit | 25,408 | 27,567 | 3,100 | 4,370 | 4,177 | 4,123 |
| Custard apple | 5,670 | 5,831 | 2,274 | 2,417 | 2,833 | 2,902 |

[3] *EIC, "Cambodia Agriculture Development Report", June 2006*
[4] *FAO, "Current Situation and Medium-term Outlook for Tropical Fruits"*

| | | | | | | |
|---|---|---|---|---|---|---|
| Orange | 1,856 | 1,979 | 1,756 | 2,371 | 2,528 | 2,624 |
| Longan | 24,840 | 24,990 | 713 | 1,185 | 2,263 | 2,306 |
| Guava | 221 | 322 | 1,343 | 1,731 | 2,062 | 2,100 |
| sapodilla | 3,720 | 4,027 | 1,100 | 2,153 | 1,536 | 1,565 |
| Milk fruit | 739 | 1,172 | 769 | 1,297 | 1,273 | 1,291 |
| Durian | 587 | 911 | 1,060 | 994 | 1,238 | 1,268 |

កំណត់សំគាល់ : ផលិតផលដែលតំបន់ផលិតកម្ម គឺប្រមាណជា ១,០០០ ហិកតា ឬច្រើនជាងនេះ នៅឆ្នាំ ២០០៤

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ស្ថិតិកសិកម្ម"

### ៦.១.៤ ការកែច្នៃម្ហូបអាហារ

- ឧស្សាហកម្មកែច្នៃម្ហូបអាហារនៅកម្ពុជាកំពុងស្ថិត ក្នុងដំណាក់ការដំបូងនៃការអភិវឌ្ឍន៍។ ជាឧទាហរណ៍ ដំណាំចេក ស្វាយ និងសារម៉ៅ ត្រូវបានគេប្រមូលផលក្នុងប្រទេសហើយធ្វើការនាំចេញទៅលក់នៅ ប្រទេសថៃ និងវៀតណាម ដើម្បីធ្វើការកែច្នៃជាទឹកផ្លែឈើ ជាអាហារកំប៉ុង និងជាដំណាប់ក្រៀមជាដើម ហើយផលិតផលសម្រេចទាំងនេះ ត្រូវបាននាំមកលក់នៅកម្ពុជាវិញ។ ព្រមពេលជាមួយគ្នានេះដែរ ផលិតផលកសិកម្មដទៃទៀត ដូចជា មៀ្យាដំឡូងមី (មៀ្យាមី) ក៏ត្រូវបានគេយកទៅផលិតនៅក្នុងប្រទេសជិតខាង ហើយធ្វើការនាំចូលមកកម្ពុជាវិញ។
- ទន្ទឹមនិងនេះ គួរកត់សំគាល់ផងដែរថា ការនាំចូលអាហារកែច្នៃមកកម្ពុជាមានការកើនឡើង ស្របពេលដែលកម្ពុជាបានអនុវត្តន៏នូវនយោបាយសេដ្ឋកិច្ចទីផ្សារសេរី ហើយតំលៃបន្ថែមពីផលិតផលទាំងនេះគួរតែត្រូវបានធ្វើការកែច្នៃនៅប្រទេសកម្ពុជា តែបែរជាប្រទេសដែលនៅជិតខាងកម្ពុជា ជាអ្នកទទួលបាននូវផលប្រយោជន៏ពីការកែច្នៃនេះទៅវិញ។

### ៦.១.៥ ឧស្សាហកម្មជលផល

- មានបរិមាណផលនេសាទទឹកសាបនិងសមុទ្រជាច្រើនដែលត្រូវបានគេប្រមូលពីដងទន្លេមេគង្គ ទន្លេសាប បឹងទន្លេសាបនិងពីសមុទ្រកម្ពុជាដែលជាប់ឈូងសមុទ្រថៃ ។
- ទិន្នផលនេសាទដែលប្រមូលបាន មានការធ្លាក់ចុះចាប់តាំងពីពាក់កណ្តាលនៃទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារការនេសាទហួសកំរិត ហើយការអភិវឌ្ឍន៏នានាក៏បានបណ្តាលអោយមានការខូចខាតដល់បរិស្ថាន ។ល។ ការធ្លាក់ចុះនៃទិន្នផលនេសាទដែលប្រមូលបាន ពិសេសចំពោះត្រីមានខ្នាតធំ ក្នុងតំបន់នេសាទទឹកសាបឈានដល់កំរិតមួយគួរអោយបារម្ភ ។
- ទិន្នផលនេសាទទឹកសាបដែលប្រមូលបាន បានធ្លាក់ចុះមកត្រឹម ២៥០,០០០ តោន គឺស្មើនឹង ១៩% ធៀបនឹងឆ្នាំកន្លងទៅ ហើយនៅ តាមតំបន់ទឹកប្រៃក៏បានធ្លាក់មកនៅត្រឹម ៥០,០០០ តោន គឺស្មើនឹង ៨៦% ធៀបនឹងឆ្នាំ២០០៤ កន្លងទៅដែរ ។ ការកើតមានបាតុភូតអាក្រក់ក្នុងឆ្នាំ២០០៤ គឺកំរិតកម្ពស់ទឹកទាប ដោយសារមានភ្លៀងមិនគ្រប់គ្រាន់ ដែលបណ្តាលអោយទិន្នផលនេសាទដែលប្រមូលបានមានការធ្លាក់ចុះយ៉ាងគំហុក។ ថ្វីបើយ៉ាងនេះក្តី ក៏ទិន្នផលនេសាទត្រីទឹកសាបមានការកើនឡើងបន្តិចបន្តួច ដែលមានបរិមាណដល់ ៣២៤,០០០ តោន ហើយ

ផលនេសាទសមុទ្រមានបរិមាណកើនឡើងចំនួន ៦០,០០០ តោន ក្នុងឆ្នាំ២០០៥នេះ។ ផលិផលកែច្នៃផលនេសាទទឹកសាបនិងសមុទ្រមានបរិមាណ៥២,០០០តោន ត្រូវបាននាំចេញទៅលក់នៅប្រទេស ជិតខាងក្នុងឆ្នាំដដែលនេះ។

- ក្នុងចម្លើយតបចំពោះការធ្លាក់ចុះនៃការប្រមូលផលនេសាទ មានការជំរុញលើកទឹកចិត្តឱ្យចិញ្ចឹមត្រី ពិសេសការចិញ្ចឹមត្រីនិងបង្គាទៅតាមលក្ខណៈធម្មជាតិ។ នៅកម្ពុជា មានការនិយមចិញ្ចឹមត្រីទឹកសាប។ ផលិតភាពនៃការចិញ្ចឹមត្រីមានបរិមាណកើនឡើងចំនួនប្រមាណ ១ ភាគ ១០ នៃផលនេសាទក្នុងប្រទេសសរុប ដោយសារការបង្កើន បច្ចេកវិទ្យាទំនើប និង ដោយមានការបង្កាត់ពូជសមស្រប។ បរិមាណត្រី និងបង្គា ដែលគេចិញ្ចឹមបានកើនឡើងដល់ ២៦,០០០ តោន គឺស្មើនឹង ២៥% កើនលើសឆ្នាំកន្លងទៅ។ ចំនួននៃការចិញ្ចឹមក្រពើ ក៏មានការកើនឡើង ប្រមាណពាក់កណ្តាលផងដែរ គឺមានចំនួនរហូតដល់ ១២០,០០០ ក្បាល ។

**តារាង ៦-១-៤ ការចាប់ត្រីទឹកសាប**

| | | 2004 | | 2005 | |
|---|---|---|---|---|---|
| | | **Planned** | **Actual** | **Planned** | **Actual** |
| Total | | 295,000 | 250,000 | 350,000 | 324,000 |
| | Commercial | 80,000 | 68,100 | 100,000 | 94,500 |
| | Fishing families | 135,000 | 106,400 | 150,000 | 137,700 |
| | Others | 80,000 | 75,500 | 100,000 | 91,800 |

កំណត់សំគាល់ : ឯកត្តា គិតជា តោន

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ស្ថិតិកសិកម្ម"

## ៦.១.៦ ការកែច្នៃផលិផលនេសាទសមុទ្រ

- តាមការប៉ាន់ស្មានឃើញថា ៤០% នៃទិន្នផលនេសាទដែលប្រមូលបាននៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើការកែច្នៃជាម្ហូបអាហារ។ អាហារកែច្នៃភាគច្រើន គឺត្រីងៀត ប្រហុក ផ្អក ត្រីឆ្អើរ និងទឹកត្រី។ គួរកត់សំគាល់ផងដែរថា បរិមាណនៃអាហារកែច្នៃមិនអាចប៉ាន់ស្មានបានសុក្រិតទេ អាស្រ័យដោយមានការខ្វះខាតនូវតួលេខដែលអាចយកជាការបាន។
- ដោយសារមានការខ្វះខាតរោងចក្រកែច្នៃទឹកត្រីនៅកម្ពុជា វត្ថុធាតុដើមពាក់កណ្តាលសំរេចមួយចំនួនត្រូវបានគេនាំទៅប្រទេសថៃ ដើម្បីកែច្នៃធ្វើជាផលិតផលសម្រេច ដោយសារកង្វះខាតរោងចក្រសំរាប់ធ្វើការកែច្នៃផលិផលទឹកត្រីនៅប្រទេសកម្ពុជា។
- ជាទូទៅ ការកែច្នៃផលនេសាទធ្វើឡើងដោយអ្នកនេសាទសម្រាប់ទុកប្រើប្រាស់ ប៉ុន្តែក៏ត្រូវបានធ្វើដោយក្រុមហ៊ុនកែច្នៃផងដែរក្នុងគោលដៅពាណិជ្ជកម្ម។ សាខាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនរបស់ហុងកុងនៅកម្ពុជាឈ្មោះ Sun Wah Cambodia Ltd បានធ្វើការកែច្នៃ និងក្លាសេនូវផលិតផលសមុទ្រ (៩០% ជាប្រភេទបង្គា និងមួយចំនួន ទៀតមានក្រែង ត្រីមឹក ។ល។) ដែលមានទីតាំងនៅក្រុងព្រះសីហនុ បានធ្វើការនាំចេញនូវ

ផលិតផលទាំងអស់នោះ ។

- និយាយជារួម ផលនេសាទសមុទ្រទាំងអស់ត្រូវតែទិញផ្ទាល់ពីអ្នកនេសាទ ។ អ្នកនេសាទតែងតែព្យាយាម លក់ផលនេសាទរបស់ខ្លួនក្នុងតម្លៃមួយខ្ពស់ ហើយបញ្ហានេះធ្វើឱ្យមានការលំបាកក្នុងការធានានូវស្ថិរភាពតម្លៃនៃផលិផលសមុទ្រទាំងនេះ ។ លើសពីនេះទៀត បរិមាណនៃទិន្នផលនេសាទមានការប្រែប្រួលផងដែរ ដោយសារបរិមាណចាប់មានការប្រែប្រួលទៅតាមរដូវកាលនេសាទ ។ ទិន្នផលនេសាទ មានការធ្លាក់ចុះយ៉ាងគំហុកក្រៅពីនៅចន្លោះខែឧសភាដល់ខែសីហា ដែលជារដូវនេសាទត្រីមិនសូវបានផល ហើយជាហេតុធ្វើអោយរោងចក្រមិនមានដំណើរការផងដែរ ។

### ៦.១.៧ ការវិភាគ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៏ភាព និងភាពគំរាមកំហែង នៃផលិតផលកែច្នៃម្ហូបអាហារ នេសាទ និងកសិកម្មរបស់កម្ពុជា

ផលិតផលកែច្នៃម្ហូបអាហារ ជលផល និងកសិផលរបស់កម្ពុជា ត្រូវបានពិចារណាថាមានភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៏ភាព និងភាពគំរាមកំហែងដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម :

**តារាង ៦-១-៥ ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៏ភាព និងការគំរាមកំហែងនៃផលិតផលកែច្នៃម្ហូបអាហារ ជលផល និងកសិផលរបស់កម្ពុជា**

| | |
|---|---|
| <u>**ភាពខ្លាំង**</u> : <br>- សំបូរធនធាននេសាទ និងកសិកម្ម<br>- ដីមានជីជាតិតាមដងទន្លេមេគង្គ<br>- ជលផលមហាសាលនៅក្នុងទន្លេមេគង្គ ទន្លេសាប និងឈូងសមុទ្រ<br>- អតិរេកផលស្រូវ ដែលអាចធ្វើការនាំចេញ | <u>**ភាពខ្សោយ**</u> : <br>- ប្រព័ន្ធធារាសាស្ត្រមិនល្អ ដែលត្រូវការកំណែលំអ<br>- មានការយឺតយ៉ាវក្នុងការអភិវឌ្ឍន៍ច្បាប់ដីធ្លី<br>- ការគ្រប់គ្រងគ្មានប្រសិទ្ធភាពរបស់កសិករចំពោះ ជី និងថ្នាំសំលាប់សត្វល្អិត<br>- គ្មានទីផ្សារស្រាប់លើកលែងតែទីក្រុងធំៗ<br>- ការផ្គត់ផ្គង់មិនមានស្ថេរភាព និងគ្មានគុណភាពចំពោះផលិតផលនេសាទ និងកសិកម្ម<br>- ខ្វះខាតប្រព័ន្ធក្លាសេ<br>- ពឹងផ្អែកច្រើនពេកទៅលើលក្ខខណ្ឌបរិយាកាសធម្មជាតិ<br>- ខ្វះភ្នាក់ងារអធិការកិច្ចនិងបទដ្ឋានវាយតម្លៃម្ហូបអាហារ<br>- មិនទាន់មានការអភិវឌ្ឍន៍ប្រព័ន្ធសហករណ៍ |
| <u>**កាលានុវត្តន៏ភាព**</u> : <br>- កំណើនក្នុងតំរូវការសំរាប់កសិផលសរីរាង្គ<br>- ទាញយកផលប្រយោជន៍ពីប្រព័ន្ធ GSP ដើម្បីនាំចេញទៅកាន់ប្រទេសអភិវឌ្ឍន៍<br>- កំណើនក្នុងតំរូវការនៃផលិតផលកែច្នៃម្ហូបអាហារ | <u>**ភាពគំរាមកំហែង**</u> : <br>- លំហូរចូលនៃទំនិញកសិផលពីវៀតណាមចូលមកកម្ពុជា<br>- កំណើនក្នុងការនាំចូលនៃម្ហូបអាហារកែច្នៃរួចពីប្រទេសជិតខាង |

| | |
|---|---|
| ផលផល និងកសិផលនៅក្នុងសណ្ឋាគារ និងភោជ នីយដ្ឋាន | |

ប្រភព : ក្រុមសិក្សា **JICA**

## ៦.២ ទស្សនៈវិស័យសំរាប់វិស័យកសិ-ឧស្សាហកម្ម ជលផល និងវិស័យឧស្សាហកម្មកែច្នៃរបស់កម្ពុជា : ការផ្លាស់ប្តូរចំពោះបរិស្ថានអន្តរជាតិនិងសេណារ្យូសំរាប់ការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម និងសំរាប់រយៈពេលវែង

### ៦.២.១ ការផ្លាស់ប្តូរចំពោះបរិស្ថាន

#### (1) ផលប៉ះពាល់ពីអង្គការពាណិជ្ជកម្មពិភពលោក/តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (WTO/AFTA)

ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផលនៅកម្ពុជា កំពុងរងនូវការគំរាមកំហែង ដោយមានការប្រកួតប្រជែងដ៏ស្រួចស្រាវក្នុងទីផ្សារពិភពលោក ដើម្បីឆ្លើយតបទៅនិងការកើនឡើងសេដ្ឋកិច្ចដែលពឹងផ្អែកគ្នាទៅវិញទៅមកនៅក្នុងតំបន់អាស៊ីនេះ។

ដំបូងបំផុត ប្រទេសកម្ពុជាតម្រូវអោយកាត់បន្ថយអត្រាពន្ធលើផលិតផលកសិកម្ម។ ប្រទេសកម្ពុជា បានទទួលនូវការអនុគ្រោះពន្ធនាំចូល GSP ដែលផ្តល់អោយដោយបណ្តាប្រទេសជាសមាគមអាស៊ាន សហរដ្ឋអាមេរិក សាធារណៈរដ្ឋប្រជាមានិតចិន និងសហគមន៏អ៊ឺរ៉ុប ដែលបានកំណត់អត្រាយកពន្ធទាបទៅលើផលិតផលកសិកម្មកម្ពុជា នាំចេញទៅបណ្តាប្រទេសទាំនោះ។ លើសពីនេះ ប្រទេសកម្ពុជា បានធ្វើការទំលាក់តារាងពន្ធយ៉ាងទាបទៅលើផលិផលកសិកម្ម ហើយដែលត្រូវបានចែកចេញជាបួនប្រភេទដែលមានអត្រា ៧% ១៥% ៣៥% និង៥0% សំរាប់ការចូលជាសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មអន្តរជាតិកាលពីខែតុលាឆ្នាំ២00៤។ អត្រាពន្ធជាមធ្យមរបស់កម្ពុជា លើផលិតផលកសិកម្មនិងផលិតផលសមុទ្រគឺ ១៩,៥% ទាបជាអត្រាពន្ធលើ ផលិតដូច គ្នារបស់ បណ្តាប្រទេសអ្នកនាំចេញផលិតផលកសិកម្មធំៗក្នុងពិភពលោកដូចជា ប្រទេសថៃ មានអត្រា(២៩,៦%) អាហ្សង់ទីន (៣៣%) និងវៀតណាម (២៤,៥%)។ ក្រៅពីនេះ នៅសហរដ្ឋអាមេរិក អូស្ត្រាលី និងណូវែលហ្ស៊ីឡង់មានការឧបត្ថម្ភទុន សំរាប់ការនាំចេញផលិតផលកសិកម្មទោះជាតាមរូបភាពផ្ទាល់ក្តី រឺរូបភាពប្រយោលក្តី ហើយស្របពេលដែលកម្ពុជាបានលុបចោលនូវជំនួយឧបត្ថម្ភពីរដ្ឋាភិបាលសំរាប់ការចូលជាសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក[5]។ យោងកត្តាខាងលើ នេះបានបញ្ជាក់ថាការនាំចូលផលិតកសិកម្មក្នុងប្រទេសកម្ពុជានឹងបន្តកើនឡើង។

បែទេសកម្ពុជាបានសម្រេចបញ្ចប់កិច្ចព្រមព្រៀង AFTA ប៉ុន្តែមិនទាន់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាមួយប្រទេសណាមួយនៅឡើយ។ គេមានការព្រួយបារម្ភចំពោះផលិតផលកសិកម្មដែលមានតម្លៃដ៏ថោកពីប្រទេសវៀតណាម លើកលែងតែជ្រូករស់ មាន់ ត្រីរស់ និងបន្លែមួយចំនួន ដូចជា ប៉េងប៉ោះ និងខ្ទឹមបារាំង ដែលត្រូវលើកលែងចេញពីបញ្ជីផលិតផលកសិកម្មដែលមានលក្ខណៈរសើប នឹងត្រូវហូរចូលមកទីផ្សារក្នុងប្រទេស បន្ទាប់ពីការអនុវត្តន៏ផែនការ CEPT ក្នុងឆ្នាំ២00៧។

[5] *Economic Institute of Cambodia*

### (2) ការផ្លាស់ប្តូរការវិនិយោគបរទេសផ្ទាល់ ដោយឧស្សាហកម្មកែច្នៃម្ហូបអាហារជប៉ុន នៅក្នុងតំបន់អាស៊ី

បរិមាណវិនិយោគក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់ប្រទេសជប៉ុននៅតំបន់អាស៊ីបូព៌ា (ប្រទេសជាសមាគមន៍អាស៊ាន ចិន និងសាធារណរដ្ឋកូរ៉េ) មានចំនួន ៤១១,៥ កោដិយ៉េននៅចន្លោះឆ្នាំ១៩៨៩ និងឆ្នាំ២០០៤ (ប្រភពពីក្រសួងសេដ្ឋកិច្ចជប៉ុន)។ ប្រទេសស្ថិតនៅក្នុងលំដាប់ខ្ពស់ដែលស្រូបបានទុនវិនិយោគជប៉ុនលើស ពី៥០កោដិយ៉េននៅក្នុងកំឡុងពេលនោះ មានប្រទេសចិន (រួមទាំងកោះហុងកុង) (ទទួលបានគំរោងវិនិយោគចំនួន ៣១៨ គំរោង ដោយមានទុនវិនិយោគចំនួន ១២៨,៥ កោដយ៉េន) ប្រទេសហ្វិលីពីន (ទទួលបានគំរោងវិនិយោគចំនួន ១២គំរោង ដោយមានទុនវិនិយោគចំនួន ៩១ កោដយ៉េន) ប្រទេសសង្ហបូរី (ទទួលបានគំរោងវិនិយោគចំនួន ១៩ គំរោង ដោយមានទុនវិនិយោគចំនួន ៦៩,៧ កោដយ៉េន) និងប្រទេសថៃ (ទទួលបានគំរោងវិនិយោគចំនួន ១៤៤ គំរោង ដោយមានទុនវិនិយោគចំនួន ៥៤,៣ កោដយ៉េន)។

**តារាង ៦-២-១ ការវិនិយោគរបស់ជប៉ុន ធ្វើឧស្សាហកម្មកែច្នៃម្ហូបអាហារនៅអាស៊ីបូព៌ា (អាស៊ាន ចិន កូរ៉េខាងត្បូង) (១៩៩៨-២០០៤: គោលការណ៏កំណត់សំគាល់)**

| Ranking | Country Name | Accumulating Total of Investments (JPY 100 mil.) | Number of Investments |
|---|---|---|---|
| 1 | China (in which, Hong Kong alone) | 1,285 (273) | 318 (42) |
| 2 | Philippines | 910 | 12 |
| 3 | Singapore | 697 | 19 |
| 4 | Thailand | 543 | 144 |
| 5 | Malaysia | 257 | 13 |
| 6 | Indonesia | 192 | 37 |
| 7 | South Korea | 157 | 20 |
| 8 | Vietnam | 74 | 9 |
| Others | Brunei, Cambodia, Laos, Myanmar | 0 | - |
| Total | | 4,115 | 572 |

Note: This table excludes investments less than 100 million yen.
Source: The Japan Research Institute, Ltd. compiled materials provided by the Ministry of Finance, Japan "Outward and Inward Foreign Direct Investment".

ទុនវិនិយោគភាគច្រើនសំរាប់ប្រទេសដែលមានលំដាប់លេខ ២ និងលេខ ៣ គឺប្រទេសហ្វីលីពិន និងប្រទេសសឹង្ហបូរី ធ្វើទៅបានតាមរយះការទិញយកភាគហ៊ុនក្នុងស្រុកនិងការចូលហ៊ុនដោយក្រុមហ៊ុន Suntory Ltd និងក្រុមហ៊ុន Kirin Brewery Co.,Ltd នៅពេលដែលក្រុមហ៊ុនជប៉ុនដទៃទៀត បានចូលរួមក្នុងការវិនិយោគដ៏ច្រើននៅក្នុងប្រទេសទាំងនេះ។ ក្នុងចំណោមសាខាក្រុមហ៊ុនជប៉ុនទាក់ទងនឹងផលិតផលម្ហូបអាហារនៅក្នុងតំបន់អាស៊ី ប្រទេសចិនស្រូបយកបានវិនិយោគចំនួន ៥០% នៃទុនសរុបនៃចំនួនក្រុមហ៊ុន១៨២ ដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម ពេលដែលប្រទេសថៃស្រូបបាន១៧% ដែលមានចំនួន ៦២ ក្រុមហ៊ុន។ ម្យ៉ាងវិញទៀត ពុំទាន់ឃើញមានសាខាក្រុមហ៊ុនជប៉ុនក្នុងវិស័យម្ហូបអាហារធ្វើការវិនិយោគនៅប្រទេសកម្ពុជានៅឡើយទេ។

**តារាង ៦-២-២ ការវិនិយោគដោយក្រុមហ៊ុនពាក់ព័ន្ធនឹងម្ហូបអាហារជប៉ុននៅអាស៊ី**

| | Food Processing Company | Food Wholesaler | Total |
|---|---|---|---|
| Thailand | 53 | 9 | 62 |
| Singapore | 14 | 11 | 25 |
| Malaysia | 13 | 1 | 14 |
| Philippines | 7 | 1 | 8 |
| Indonesia | 17 | 0 | 17 |
| Vietnam | 8 | 0 | 8 |
| China | 170 | 12 | 182 |
| Hong Kong | 11 | 7 | 18 |
| Korea | 8 | 1 | 9 |
| Taiwan ROC | 14 | 9 | 23 |
| Sub Total | 315 | 51 | 366 |

Note 1: Share of Japanese capital is 10% or more.
Note 2: Excludes food retailers and food service companies such as Japanese restaurants.
Source: Toyo Keizai Inc. "Directory of Japanese Companies Abroad"(Research conducted in Nov., 2004)

ការវិនិយោគផ្ទាល់ពីបរទេសលើវិស័យកែច្នៃម្ហូបអាហាររបស់ក្រុហ៊ុនជប៉ុនបានផ្តោតការយកចិត្តចំពោះការវិនិយោគនៅក្នុងប្រទេសចិន ដោយរួមទាំងកោះហុងកុង និងប្រទេសថៃ ដោយមិនរាប់បញ្ចូលប្រភេទពិសេសនៃ FDI ធ្វើតាមរយៈ ការទិញក្រុហ៊ុន រឺក៏ការចូលហ៊ុនជាមួយក្រុមហ៊ុនហ្វីលីពីន និងសង្ហបូរី ។

ទោះជាយ៉ាងណា ក្នុងប៉ុន្មានឆ្នាំថ្មីនេះប្រទេសគោលដៅសំរាប់ FDI ជប៉ុនមានការប្រែប្រួលខ្លះ។ ដោយយត្រឡប់ទៅពិនិត្យមើល FDI ជប៉ុន កាលពីពេលកន្លងទៅក្នុងតំបន់អាស៊ីខាងកើត ជប៉ុនបានដាក់វិនិយោគដ៏ច្រើននៅក្នុងប្រទេសថៃ នៅចុងទសវត្សឆ្នាំ ១៩៨0 និង ឆ្នាំ១៩៩១ ហើយបន្ទាប់មកគឺនៅប្រទេសចិន។ ប៉ុន្មានឆ្នាំថ្មី១នេះ ជប៉ុនបានផ្លាស់ប្តូរការ ការយកចិត្តទុកដាក់ក្នុងការវិនិយោគទៅលើសម្ព័ន្ធមិត្តចាស់របស់ខ្លួន គឺប្រទេសថៃ និងទិសដៅវិនិយោគថ្មីនៃប្រទេស វៀតណាម។ នេះបង្ហាញអោយឃើញថា ប្រទេសថៃនិងវៀតណាមបាន ផ្តោតការយកចិត្ត ទុកដាក់ ក្នុងការកាត់បន្ថយ ហានិយភ័យ ដោយការវិនិយោគតែនៅក្នុងប្រទេសមួយ គឺប្រទេសចិន។

ជាការពិតនៅក្នុងឆ្នាំ ២00៣ និងក្រោយមកទៀត វិនិយោគជប៉ុននៅក្នុងប្រទេសវៀតណាមមានការកើនឡើងយ៉ាងគំហុក។ ជាពិសេស ការវិនិយោគនៅក្នុងប្រទេសវៀតណាមតំលៃពលកម្មមានតំលៃថោក ហើយកម្មករមានភាពឆ្លាតវៃ ហើយវៀតណាមជាប្រទេសដែលមានសក្តានុពលទីផ្សារដោយមានចំនួនប្រជាជន ៨0 លាននាក់។ អាស្រ័យហេតុនេះ មានការប្រមើលឃើញថា វិនិយោគជប៉ុននៅប្រទេសវៀតណាមនិងបន្តកើនឡើងជាបន្តទៀត។

ផ្ទុយទៅវិញ មានការចង្អុលបង្ហាញអោយឃើញថា ហេដ្ឋារចនាសម្ព័ន្ធរបស់វៀតណាមនៅមានលក្ខណៈទន់ខ្សោយ ប្រព័ន្ធច្បាប់មិនទាន់មានការកែលំអរ ហើយឧស្សាហកម្មគាំទ្រនូវមានលក្ខណៈទន់ខ្សោយ បើប្រៀបធៀបនិងការចាប់ផ្តើមនៃបណ្តាប្រទេសជាសមាជិកអាស៊ានរឺប្រទេសចិន។ ចំពោះហេតុផលពេលនេះ FDI ជប៉ុន ហាក់ដូចជាពុំសូវមានការផ្តោតខ្លាំងក្លាទៅលើប្រទេសវៀតណាម ប៉ុន្តែបានរក្សានូវកំណើវិនិយោគថេរនៅក្នុងប្រទេសនេះដើម្បីផ្គត់ផ្គង់ដល់វិនិយោគជប៉ុននៅក្នុងប្រទេសចិននិងថៃ ជា ចិនបូកមួយ រឺក៏ថៃបូកមួយ។

### ៦.២.២ សេណារីយ៉ូអភិវឌ្ឍន៍សំរាប់រយៈពេលមធ្យម និងរយៈពេលវែង

#### (1) សេណារីយ៉ូអភិវឌ្ឍន៍សំរាប់ពេលខ្លី : ការពង្រីកការនាំចេញផលិតផលកសិកម្ម

ប្រទេសកម្ពុជាធ្លាប់មានប្រវត្តិល្បីល្បាញក្នុងការនាំចេញផលិតផលកសិកម្ម និងជលផល ព្រមទាំងបានផ្តល់ធនធានផលិតដ៏សម្បូររបស់ខ្លួនទៅឱ្យប្រទេសជិតខាងទៀតផង។ នាពេលបច្ចុប្បន្ន ផលិតផលកសិកម្ម និងជលផលនៅបន្តនាំចេញដោយខុសច្បាប់ ទន្ទឹមនិងពេលមានកានាំចូលដោយគេចពន្ធនូវផលិតផលកែច្នៃម្ហូបអាហារ។ កិច្ចការចម្បងដែលកម្ពុជាត្រូវសំរេចអោយបាន នោះគឺការប្រែក្លាយការធ្វើពាណិជ្ជកម្មខុសច្បាប់ទាំងនេះឱ្យទៅជាមានលក្ខណៈស្របច្បាប់វិញ។ ពិតមានដែលអាចជឿទុកចិត្តបាន ស្តីពីនីហរ័ណនិងអហរ័ណត្រូវប្រមូលចងក្រងដោយមានការបង្កើនពិតមានស្តីពីពាណិជ្ជកម្មផ្លូវការ។

កាន់តែមានសារៈសំខាន់ថែមទៀត ក្នុងការចងក្រងនូវទិន្នន័យអាកាសធាតុ និងធនធានធម្មជាតិសំរាប់រដ្ឋាភិបាលកម្ពុជាក្នុងការបន្តគោលនយោបាយកសិកម្មប្រកបដោយប្រសិទ្ធិភាព។

បន្ទាប់មក កម្ពុជាគួរផ្តោតយកចិត្តទុកដាក់ទៅលើទីផ្សារអាស៊ានជាទិសដៅសំខាន់សំរាប់ការនាំចេញរបស់ខ្លួន។ ដើម្បីសំរេចបានគោលដៅនេះ ការកសាងប្រព័ន្ធផ្គត់ផ្គង់ផលិតផលជាមួយក៏រិតនៃគុណភាព ជាកត្តាសំខាន់បំផុត។

#### (2) សេណារីយ៉ូអភិវឌ្ឍន៍សំរាប់ពេលមធ្យម : ការផលិតជំនួសការនាំចូលនូវផលិតផល កែច្នៃកសិកម្ម/ការពង្រីកផលិតផលសំរាប់ការនាំចូល

ការពង្រីកផលិតផលសំរាប់នាំចេញដើម្បីបំពេញតម្រូវការរបស់ប្រទេសជិតខាង និងជប៉ុនគឺជាគោលដៅសំខាន់ក្នុងសេណារីយ៉ូនេះ។ នៅពេលដែលកសិ-ឧស្សាហកម្ម គ្មានសមមាត្រទៅលើការធ្វើដំណាំស្រូវ គឺតម្រូវអោយមានការបង្កើនមុខផលិតផលដែលមានតំលៃបន្ថែមខ្ពស់ រួមមាន ដំណាំផ្តល់រូបិយវត្ថុ ជាពិសេស ការពង្រីកនូវផលិកម្មផ្លែឈើនិងបន្លែបង្កា មិនគ្រាន់តែជំរុញការនាំចេញប៉ុណ្ណោះទេថែមទាំងជួយជំរុញដល់ការផលិតជំនួសការនាំចូល។

លើសពីនេះ កម្ពុជាត្រូវប្រឹងប្រែងធ្វើការកែប្រែពីឧស្សាហកម្មកែច្នៃម្ហូបអាហារតាមលក្ខណៈគ្រួសារទៅជាផលិតកម្មតាមបែបឧស្សាហកម្មទំនើប។ មិនតែប៉ុណ្ណោះ កម្ពុជាត្រូវរៀបចំផែនការបង្កើតប្រព័ន្ធផ្គត់ផ្គង់ដោយរួម ទាំងប្រព័ន្ធធ្វើឱ្យត្រជាក់ផងដែរ ។ ឆ្លងកាត់កិច្ចខិតខំប្រឹងប្រែងនេះ ឧស្សាហកម្មកែច្នៃម្ហូបអាហារដោយប្រើប្រាស់ធនធានភាគច្រើនរបស់កម្ពុជា នឹងត្រូវបានពង្រីក ដើម្បីនាំផលិតផលចេញទៅលក់ទៅប្រទេសជិតខាង។

វាត្រូវបានប៉ាន់ស្មានថា លំហូរ FDI មកកម្ពុជា រួមទាំប្រទេសជប៉ុនផងនោះ នឹងមានការកើននាពេលបច្ចុប្បន្ននេះ។ ដើម្បីទៅដល់ដំណាក់ការនេះ កម្ពុជាត្រូវបំពេញលក្ខ័ណ្ឌមួយចំនួន ១- ការកសាងហេដ្ឋារចនាសម្ព័ន្ធផលិតកម្មមានគុណភាពខ្ពស់ និងតំលៃផលិតទាប។ ចំពោះលក្ខខណ្ឌ១ ជាទូទៅ សមីប្រទេស ចាំបាច់ត្រូវធ្វើកំណែទំរង់ហេដ្ឋារចនាសម្ព័ន្ធទូលំទូលាយ ដូចជាឧស្សាហកម្មកែច្នៃម្ហូបអាហារដែលពឹងផ្អែកលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មច្រើនជាង បណ្តាប្រទេសដទៃទៀត ដែលផលិតកម្មរបស់ប្រទេសទាំងនេះពឹងផ្អែកជាសំខាន់ទៅលើគ្រឿង ម៉ាស៊ីន។ កត្តា នេះ អាស្រ័យដោយលក្ខណៈពិសេសនៃការវិនិយោគលើការកែច្នៃម្ហូបអាហារ ត្រូវប្រើប្រាស់ទឹកនិងអគ្គិសនីច្រើនសំរាប់ក្លាសេនិងបង្កក តែទោះជាយ៉ាងណា បើប្រៀបធៀបជាមួយឧស្សាហកម្មដ៏ទៃទៀត ផ្អែកផលិតកម្មនិង

តំលៃផលិតកម្មនៅមានកំរិតទាប។ ចំពោះលក្ខខណ្ឌ ២ ទោះជាឧស្សាហកម្មកែច្នៃម្ហូបអាហារជាឧស្សាហកម្មប្រើប្រាស់កំលាំងពលកម្មច្រើន ក៏តម្រូវអោយផលិផលមានគុណភាពប៉ុន្តែកំលាំងពលកម្មមានតំលៃទាបដែលជាកត្តាទាក់ទាញវិនិយោគ។

**(3) សេណារីយ៉ូអភិវឌ្ឍន៏សំរាប់ពេលវែង : ការលើកកំពស់ភាពប្រកួតប្រជែងនៃផលិតផលកម្ពុជា**

គោលដៅចម្បងមួយនៃសេណារីយ៉ូនេះគឺធ្វើយ៉ាងណាដើម្បីជំរុញកំណើនឧស្សាហកម្មកែច្នៃម្ហូបអាហារប្រកបដោយបច្ចេកទេសជំនាញកំរិតខ្ពស់។ លើសនេះទៀត កម្ពុជាមានគោលបំណងលើកកំពស់គុណភពនៃភាពប្រកួត ប្រជែងតាមរយៈការរក្សាឧត្តមភាពតម្លៃ និងបង្កើតផ្លាកសញ្ញាល្បីឈ្មោះ ទាំងនៅក្នុងទីផ្សារក្នុងស្រុក និងទីផ្សារ អន្តរជាតិ។ សម្រាប់ផលិតផលកសិកម្ម និងជលផល កត្តាទាំងនេះនឹងត្រូវតែពង្រឹង ដោយការបង្ហាញពីភាពផ្សេងគ្នារវាងផលិតផលក្នុងស្រុក និងផលិតផលនៃបណ្តាប្រទេសនៅអាស៊ី ដូចជា តាមរយៈការលើកទឹកចិត្តដល់ផលិតផលកសិកម្មសរីរាង្គជាដើម ។

## ៦.២.៣ ការព្យាករណ៍នៃបរិមាណវិនិយោគនៅកម្ពុជា ដោយក្រុមហ៊ុនបរទេសនៅឆ្នាំ ២០២០

### (1) ការវិភាគនិន្នាការ

ឧស្សាហកម្មកែច្នៃម្ហូបអាហារនៅកម្ពុជា មិនទាន់មានការអភិវឌ្ឍន៏នៅឡើយ។ ដោយសារទំហំនៃទីផ្សារក្នុងស្រុក និងបរិស្ថានវិនិយោគរបស់ខ្លួននៅមានកំរិត ការវិនិយោគបរទេសផ្ទាល់ទៅក្នុងឧស្សាហកម្មនេះ មានភាពស្ទាក់ស្ទើរអល់ឯកនៅឡើយ។ ដូចបានបង្ហាញនៅក្នុងរូបភាពខាងក្រោម លំហូរចូលនៃការវិនិយោគបរទេសផ្ទាល់ ទៅក្នុងឧស្សាហកម្មនេះ ប្រែប្រួលរៀងរាល់ឆ្នាំ។ ជាបន្ថែម ដូចជាករណី ក្រុមហ៊ុន Nestle Dairy (Cambodia) Ltd. បានបង្ហាញថាក្រុមហ៊ុនមួយចំនួន បានត្រូវដកចេញពីទីផ្សារកម្ពុជា ដោយសារតែបរិស្ថានធុរៈកិច្ចនៅកម្ពុជាមានភាពយ៉ាប់យ៉ឺនបន្ទាប់ពីធ្វើការវិនិយោគនៅទីនោះ។ ជាលទ្ធផលបរិមាណនៃការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហារគឺត្រូវបានរំពឹងទុកថាមានភាពតិចតួចនៅឡើយ។

**រូបភាពទី ៦-២-១ លំហូរការវិនិយោគបរទេសផ្ទាល់ទៅក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា**




Source: CDC/CIB

**តារាង ៦-២-៣ សាខាក្រុមហ៊ុនបរទេសក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា**

| Company | Product Item | Location | Source of Investment |
|---|---|---|---|
| Sun Wah Fisheries Co., Ltd. | Frozen shrimp | Sihanouk Ville | China (Hong Kong) |
| Cambodia Hainin Group | Various farm products | Kampong Speu | China |
| Godkin Meat Processing Pl. | Sausage | Takeo | Taiwan ROC |
| Asia Flour Mill | Flour | Phnon Penh | France |
| L.Y.S. Pte. Ltd. | Fruits | Phnon Penh | Singapore |
| Taiwan Food Product | Biscuit, Jelly | Phnon Penh | Taiwan ROC |
| Nestle Dairy (Cambodia) Ltd. | Dairy products | Phnon Penh | Thailand |
| Sui Fen Beverage-Food | (1) Soy milk | Phnon Penh | China |
| Cambodia Breve Ltd. CBL | “Tiger brand” Beer | Kandal | Netherland |
| Angkor Brewery | Beer “Angkor brand” | Sihanouk Ville | Malaysia |

Source: Promar Japan, MOC, and JICA Study Team

### (2) ការព្យាករណ៍នៃការវិនិយោគបរទេសផ្ទាល់រហូតដល់ឆ្នាំ២០២០

វាត្រូវបានរំពឹងថា ការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា នឹងកើនកើនឡើងនៅពេលអនាគត ជាទីផ្សារក្នុងស្រុកនៃការពង្រីកឧស្សាហកម្ម និងឧស្សាហនូបនីយកម្មនៅក្នុងប្រទេសជិតខាង។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ដើម្បីនឹងទាក់ទាញការវិនិយោគបរទេសផ្ទាល់ លក្ខខណ្ឌដូចជា (i) ធានាការផ្គត់ផ្គង់វត្ថុធាតុដើមនៃគុណភាពជាឯកសណ្ឋាន ដែលត្រូវតំរូវដោយឧស្សាហកម្មកែច្នៃម្ហូបអាហារ, (ii) អភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ដែលជាកត្តាសំខាន់សំរាប់ឧស្សាហកម្ម និង (iii) បង្កើតភ្នាក់ងារអធិការកិច្ច និងវាយតម្លៃប្រភេទទំនិញនៅក្នុងប្រទេស។ ដូច្នេះ វាជាការលំបាកដើម្បីព្យាករណ៏នូវបរិមាណត្រឹមត្រូវនៃលំហូរ ចូលនៃការវិនិយោគបរទេសផ្ទាល់នៅក្នុងឧស្សាហកម្មនេះ។

ក្នុងបទពិសោធន៏ដែលបានសិក្សាខាងលើ ក្រុមសិក្សា បានព្យាករណ៏បរិមាណលំហូរចូលវិនិយោគរវាងឆ្នាំ ២០០៦ និង ២០២០ ហើយមានបង្ហាញជាលទ្ធផលនៅក្នុងតារាងខាងក្រោម។ តារាង មានបុរេវិនិច្ឆ័យថាអត្រានៃការវិនិយោគក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហារជាសរុបនៅកម្ពុជា កើនឡើងពី ២.៥% នៅឆ្នាំ ២០០៦ និង ៤.0% នៅឆ្នាំ ២០២០២ ក្នុងសមាមាត្រទៅនឹងបរិមាណនាំចេញ លើបរិមាណនាំចេញសរុបរបស់ប្រទេស ផ្អែកលើទិន្នន័យពី (i) បរិមាណពិតនៃលំហូរវិនិយោគ ដែលធ្វើក្នុងឧស្សាហកម្មនេះ រវាងឆ្នាំ ១៩៩៥ និង ២០០៤ ហើយ (ii) ការព្យាករណ៏នៃលំហូរចូលការវិយោគសរុបក្នុងប្រទេសរវាងឆ្នាំ ២០០៥ និង ២០២០២ មានរៀបរាប់នៅក្នុងជំពូកទី២។

**រូបភាព ៦-២-២ ការទស្សន៍ទាយនៃការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា**




Note: 2000 year price

Source: JICA Study Team

ការពិចារណាខាងលើ បរិមាណនៃការនាំចេញ និងផលប៉ះពាល់ផ្សេងៗក្នុងរយៈពេល ខ្លី មធ្យម និងវែង ត្រូវបានព្យាករណ៍យ៉ាងល្អិតល្អន់ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម :

**តារាង ៦-២-៤ FDIs and their Ripple Effects ក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហាររបស់កម្ពុជា**

| | Short-term (around 2010) | Medium-term (around 2015) | Long-term (around 2020) |
|---|---|---|---|
| FDI | US$ 15 million | US$ 25 million | US$ 35 to 40 million |
| Export | US$ 110 to 120 million | US$ 200 to 220 million | US$ 300 to 350 million |
| Ripple Effect | Not expected | Import substitution, Job creation | Job creation, Foreign currency earnings |

(2) Source: JICA Study Team

## ៦.៣ ការវាយតម្លៃ និងទស្សនៈវិស័យសំរាប់ភាពប្រកួតប្រជែងជាអន្តរជាតិក្នុងវិស័យកសិ-ឧស្សាហកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហារ របស់ប្រទេសកម្ពុជា

### ៦.៣.១ ការវិភាគលើតម្លៃផលិតកម្មនិងភាពប្រកួតប្រជែងការនាំចេញ

ឧស្សាហកម្មកសិកម្មនិងជលផលនៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមជាមួយបញ្ហាជាច្រើនទាំងក្នុងផលិតកម្ម និងការងារទីផ្សារដែលធ្វើអោយការក្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិមានកំរិតទាបនៅក្នុងឧស្សាហកម្មនេះ ។

ជាពិសេសដោយមានការខ្វះខាតនូវគ្រាប់ពូជ បច្ចេកវិជ្ជា និងពិតមាន ហើយឥណទាននៅមានកំរិក្នុងផលិតកម្ម នៅពេលដែលពុំមានពិតមានស្តីពីទីផ្សារគ្រប់គ្រាន់ តំលៃដឹកជញ្ជូននិងសេវាខ្ពស់ខ្វះទំនាក់ទំនង ការជឿទុកចិត្តរវៀង កសិករនិងឈ្មួញជាកត្តាមួយនៃការងារទីផ្សារ ។ ក្រៅពីនេះ ការនាំចេញផលិតផលកសិកម្មភាគច្រើនធ្វើឡើងដោយគ្មានការកែច្នៃក្នុងស្រុក ដោយសារឧបករណ៍កែច្នៃផលិផលកសិ-ឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចតួច ។

ចំពោះផលិផលនាំចេញដ៏ទៃទៀតប្រឈមនឹងការចំណាយក្រៅផ្លូវការខ្ពស់នៅតាមច្រកព្រំដែន[6] ។ អាស្រ័យហេតុនេះ នាំអោយមានការលំបាកក្នុងការវាយតំលៃអោយបានត្រឹមត្រូវចំពោះភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិចំពោះកសិ-ឧស្សាហកម្ម ជលផល និងឧស្សាហកម្មកែច្នៃរបស់ប្រទេសកម្ពុជា។ ការពិចារណារទៅលើកត្តាខាងលើ តំលៃផលិតកម្មដំឡូងឈើ គួរតំណាងអោយដំណាំកសិផលកម្ពុជា ដោយប្រៀបធៀបដំណាំទាំងនោះជាមួយប្រទេសវៀតណាមនិងថៃដោយផ្អែកលើការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៏កម្ពុជា។

ដំបូង លទ្ធភាពចំណេញនៃផលិតកម្មដំឡូងឈើត្រូវបានកំណត់។ ដូចដែលបានបង្ហាញ នៅតារាងខាងក្រោម ផលិតភាព(ទិន្នផលជាមធ្យមក្នុងមួយហិចតា)នៅក្នុងប្រទេសកម្ពុជាមានបរិមាណទាបជាងបណ្តាប្រទេសទាំពីរនោះ។ ម្យ៉ាងវិញទៀត តំលៃផលិតកម្មសរុបនៅក្នុងប្រទេសកម្ពុជាមានកំរិតទាបជាងបណ្តាប្រទេសទាំពីរនោះ ជាការប្រសើរណាស់ដែលប្រទេសកម្ពុជាប្រើប្រាស់ជី ថ្នាំសំលាប់សត្វល្អិតនិងថ្នាំដ៏ទៃទៀតមានកំរិតតិចតួចក្នុងការដាំដុះ។ ជាលទ្ធផលប្រាក់ចំណូលក្នុងមួយហិចតានៅក្នុងប្រទេសទាំបីមានកំរិតប្រហាក់ប្រហែលគ្នា។

**តារាង៦-៣-១ ភាពទទួលបានប្រាក់ចំណេញនៃផលិតកម្មដំឡូងមី**

| | កម្ពុជា | វៀតណាម | ថៃឡង់ដ៏ |
|---|---|---|---|
| ទិន្នផលមធ្យម (តោន/ហ.ត) | ៨.៩៦ | ៣០.៣៤ | ១៩.២៩ |
| ចំណាយផលិតកម្មសរុប (ដុល្លា/ហ.ត) | ១១៧ | ៦៧៧ | ៣២៥ |
| ប្រាក់ចំណូលដុល (ដុល្លា/ហ.ត) | ២២០ | ៧៨៧ | ៤៤៩ |
| ប្រាក់ចំណូលសុទ្ធ (ដុល្លា/ហ.ត) | ១០៣ | ១១០ | ១២៤ |

ប្រភព : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កម្ពុជា "ការពិនិត្យឡើងវិញនូវការអភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៤-៥"

ទន្ទឹមនឹងនេះ ថ្លៃដឹកជញ្ជូន ចំនួនអតិបរមានៃកម្ចីនិងអត្រាការប្រាក់នៃមីក្រូហិរញ្ញវត្ថុមានភាពខុសគ្នាយ៉ាងច្រើនរវៀងប្រទេសកម្ពុជានិងបណ្តាប្រទេសទាំងពីរនោះដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ នៅក្នុងប្រទេសកម្ពុជាកម្ចីអតិប្បរិមាគឺមានចំនួនតិចហើយថែមទាំងមានអត្រាការប្រាក់ខ្ពស់។ ជាលទ្ធផល ផលិតកម្មដំឡូងឈើនៅក្នុងប្រទេសកម្ពុជានូវមានភាពខ្វះខាតក្នុងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ បើទោះបីជាផលិតកម្មនេះប្រកបដោយសក្តានុពលក៏ដោយ។ កត្តានេះបង្ហាញថា ការនាំចេញនូវផលិតផលដំឡូងឈើអាចកើនឡើងបាន លុះត្រាតែបញ្ហាប្រឈមទាំងអស់ត្រូវបានដោះស្រាយ។

**តារាង ៦-៣-២ ចំណាយដឹកជញ្ជូនតាមផ្លូវគោក (ដុល្លា/តោន/១០០គ.ម)**

| | កម្ពុជា | វៀតណាម | ថៃឡង់ដ៏ |
|---|---|---|---|
| ចំណាយ (ដុល្លា/តោន/១០០គ.ម) | ១០-១១ | ៤-៥ | ២.៥ |

កំណត់សំគាល់ : ចំណាយប្រេង និងកំរៃឈ្នួលរថយន្តតែប៉ុណ្ណោះ

[6] *Cambodian Development Institute, "The Competitiveness of Cambodian Agriculture", Annual Development Review 2004-05.*

ប្រភព : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កម្ពុជា "ការពិនិត្យឡើងវិញនូវការអភិវឌ្ឍន៏ប្រចាំឆ្នាំ២០០៤-៥"

**តារាង ៦-៣-៣ ការប្រាក់ និងកំចី**

| | កម្ពុជា | វៀតណាម | ថៃឡង់ដ៏ |
|---|---|---|---|
| អត្រាប្រចាំឆ្នាំ (%) * | ៣៦-៦០ | ១២-១៣.៨ | ៧-៨ |
| កំចីអប្បបរិមា (ដុល្លា) | ២០ | ៣១៨ | ៧៥០ |
| កំចីអតិបរិមា (ដុល្លា) | ២០០ | ៦៣៧ | ២,៥០០ |

* កំណត់សំគាល់ : សមាគមន៏ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ

ប្រភព : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កម្ពុជា "ការពិនិត្យឡើងវិញនូវការអភិវឌ្ឍន៏ប្រចាំឆ្នាំ២០០៤-៥"

### ៦.៣.២ ការកំណត់ប្រភេទផលិតផលជាមួយភាពប្រកួតប្រជែងការនាំចេញនៅក្នុងប្រទេសកម្ពុជា

ចំពោះការជ្រើសរើសផលិតផលជាមួយសក្តានុពលនៃការប្រកួតប្រជែងទីផ្សារអន្តរជាតិនៃកសិ-ឧស្សាហកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហារ ប្រភេទផលិផលពីរគួរត្រូវធ្វើការពិនិត្យ: (១) មុខផលិតផលដែលបាននាំចេញរួច ហើយនិង (២) មុខផលិតផលដែលមិនធ្លាប់បាននាំចេញ តែផលិតផលនេះមានសក្តានុពលចំពោះតម្រូវការសកលនៅ ពេលបច្ចុប្បន្ននេះ និងក្នុងពេលអនាគត់។ លើសពីនេះទៀត វាជាការប្រសើរក្នុងការពិចារណានូវកំរិតនៃតំលៃបន្ថែម និងការបង្កើតការងារជាលក្ខ័ណ្ឌ។

ការពិចារណាទៅលើចំណុចខាងលើ ក្រុមជំនាញការសិក្សាស្រាវជ្រាវរបស់ JICA បានជ្រើសរើសមុខផលិតផលជាមួយការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ដែលបានពិពិណនាដូចខាងក្រោម។

#### (1) ការនាំចូលនិងនាំចេញនូវផលិតផលកសិកម្ម ជលផល និងផលិតផលកែច្នៃម្ហូបអាហារ

ចំនួនសមមាត្រនៃផលិតផលកសិកម្ម ផលិតផលសមុទ្រសំរាប់នាំចេញរបស់កម្ពុជានៅមានបរិមាណទាប ដោយមានចំនួនប្រហែល៣%។ ចំពោះចំនួននៃការនាំចេញនេះ មិនសូវមានភាពជឿនលឿនក្នុងការឆ្លើយតបទៅនិងតម្រូវការដោយមិនគ្រាន់តែពិចារណាទៅលើគុណភាព តំលៃ និងស្ថេរភាពផ្គត់ផ្គង់ផលិតផលផង ប៉ុន្តែត្រូវពិចារណាទៅលើការបង្កើតបណ្តាញចែកចាយ និងប្រព័ន្ធអធិការកិច្ចនិងប្រតិវេទគយ។

ក្រៅពីនេះ បរិមាណនៃការនាំចេញ និងនាំចូលរបស់កម្ពុជាត្រូវបានធ្វើឡើងតាមលក្ខណៈមិនផ្លូវការ ដោយមិនមានមូលដ្ឋានស្ថិតិណាច្បាស់លាស់បញ្ជាក់ទេ[៧]។ ជាមួយនឹងការប្រឈមនេះ ស្ថិតិក្នុងការនាំចេញ-នាំចូលជាផ្លូវការរបស់កម្ពុជា បង្ហាញអោយឃើញថា ការនាំចូលផលិតផលទាក់ទងវិស័យកសិកម្ម (HS01-24, 40-43) មានប្រមាណជា ៣ ដងលើសបរិមាណនៃការនាំចេញ ក្នុងឆ្នាំនីមួយៗនៅចន្លោះពីឆ្នាំ២០០០ និង២០០៤។ នៅក្នុងឆ្នាំ២០០៤ ការនាំចេញផលិតផលទាក់ទងវិស័យកសិកម្មមានចំនួន ៧១,៦៦៣ លានដុល្លារអាមេរិក ចំពេលដែលមានការនាំចូលមាន

[7] *According to the World Bank "Toward A Private Sector-Led Growth Strategy for Cambodia: Value Chain Analysis", June 2003, shortage of rice milling facilities in Cambodia leads to illegal exports of rice into Vietnam and Thailand*

ចំនួន ១៩៧,៧១៨ លាន ដុល្លារអាមេរិក ដែលនាំអោយមានឱនភាពពាណិជ្ជកម្ម[៨] ដោយមានទឹកប្រាក់ចំនួន ១២៦,០៥៥ លានដុល្លារអាមេរិក។

តែទោះជាយ៉ាងណា មានផលិតផលខ្លះ ដូចជាកៅស៊ូ/ផលិតផលកៅស៊ូ (HS40) និងត្រី (HS03) ត្រូវបានគេកត់ត្រា ថាមានការនាំចេញលើស ដែលជាហេតុឱ្យគេយល់ថា ផលិតផលទាក់ទងវិស័យកសិកម្មមួយចំនួននៅកម្ពុជាមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិបាន។ លើសពីនេះ ការអង្កេតដោយការសំភាសន៍មួយ ដែលធ្វើឡើងដោយក្រុមសិក្សារបស់ JICA ក្នុងបណ្តាប្រទេសជិតខាង និងប្រទេសជប៉ុនបង្ហាញថា មានផលិតផលជាច្រើនដូចជាស្រូវ ដំឡូងមី (ម្សៅមី) ផលិតផលកសិកម្មសរីរាង្គ ស្វាយចន្ទី ម្រេច កាហ្វេ និងត្រី មានសក្តានុពលក្នុងការនាំចេញ ដែលនាំឱ្យក្រុមហ៊ុនកែច្នៃម្ហូបអាហាររបស់ជប៉ុនបង្ហាញនូវចំណាប់អារម្មណ៍វិនិយោគក្នុងវិស័យនេះ។

**តារាង ៦-៣-៤ ការនាំចូល និងនាំចេញនៃមុខទំនិញជលផល និងកសិផលសំខាន់នៅកម្ពុជា**

(US$ 1,000)

| HS | Items | | 2000 | 2001 | 2002 | 2003 | 2004 |
|---|---|---|---|---|---|---|---|
| 03 | Fish & Crustaceans | Export | 5,903 | 6,065 | 4,222 | 2,841 | 13,122 |
| | | Import | 38 | 54 | 32 | 31 | 9,736 |
| 10 | Cereals | Export | 958 | 2,393 | 4,457 | 704 | 5,776 |
| | | Import | 11,067 | 7,392 | 12,871 | 11,058 | 11,651 |
| 40 | Rubbers & Articles Thereof | Export | 31,993 | 25,857 | 29,741 | 34,731 | 38,284 |
| | | Import | 9,364 | 10,543 | 12,434 | 13,997 | 14,466 |
| Others | | Export | 8,868 | 11,763 | 8,237 | 8,318 | 14,481 |
| | | Import | 143,944 | 152,899 | 153,040 | 141,415 | 161,865 |
| Total | | Export | 47,722 | 46,078 | 46,657 | 46,594 | 71,663 |
| | | Import | 164,413 | 170,888 | 178,377 | 166,501 | 197,718 |

Note: Items in the table are limited to those of which export amounts in 2004 exceed US$ 5 million.
Source: Department of Foreign Trade, MoC

### (2) ការកំណត់ប្រភេទផលិតផល

#### (i) *ដំឡូងឈើ (ម្សៅដំឡូងមី)*

ដំឡូងឈើជាដំណាំមួយប្រភេទក្នុងចំណោមដំណាំផ្តល់រូបិយវត្ថុរបស់ប្រទេសកម្ពុជា ហើយបរិមាណផលិតកម្មបានកើនឡើងក្នុងការឆ្លើយតបទៅនិងតំរូវការម្សៅមីដែលចេះតែមានការកើនឡើង។ ម្សៅចំឡូងមីត្រូវបាននាំចេញទៅប្រទេសថៃនិងវៀតណាម(ពាក់កណ្តាលនៃម្សៅដំឡូងជាផលិផលរត់គយ) ក្នុងទ្រង់ទ្រាយជាម្សៅដំឡូងដែលមិនទាន់បានកែច្នៃរឺក៏កែច្នៃរួចហើយ។ ក្រុមហ៊ុនសាខាកូរេ CJ Corp បានវិនិយោគលើការ ដាំដុះដើមដំឡូងឈើ ហើយនាំចេញទៅកាន់រោងចក្រគ្រឿងផ្សំនៅប្រទេសឥណ្ឌូនេស៊ី។

ចំពោះម្សៅដំឡូង មិនគ្រាន់តែសំរាប់ប្រើប្រាស់ធ្វើជាម្ហូបអាហារប៉ុណ្ណោះទេ តែត្រូវប្រើប្រាស់សំរាប់ធ្វើប្រេងសរីរាង្គ ដែលជាផលិតផលដែលអាចសំរេចបានសំរាប់ធ្វើការនាំចេញ។ ផលិតផលប្រេងសរីរាង្គ រួមមានសារធាតុ

---

[8] *Department of Foreign Trade, Ministry of Commerce*

អាល់កុលនិង ឧស្ម័នសំយោគដ៏ទៃទៀតដើម្បីផលិតថាមពលដោយជីវម៉ាស ហើយប្រើប្រាស់ជាសំខាន់ធ្វើប្រេងសំរាប់រថយន្តផ្សេងទៀត។ តាមពិត ក្រុមហ៊ុនកូរេកំពុងធ្វើផែនការសាងសង់រោងចក្រលើកទី១ នៅក្នុងប្រទេសកម្ពុជា ដើម្បីផលិត អាល់កុលអេទីឡែនដែលផលិតពីម្សៅដំឡូងមី។ ក្រៅពីនេះ ក្រុមហ៊ុនកូរេនិងជប៉ុនដ៏ទៃទៀតបានកំពុងអនុវត្តគំរោងដាំដុះ សាកល្បង នៅកន្លែងចំណាំទាំងនេះដូចជា Jatrophas និងដូងប្រេងត្រូវដាំដុះសំរាប់ផលិតកម្មប្រេងសិរីរាង្គ។

*(ii) **ផលិតកម្មដូងប្រេង***

ក្រុមហ៊ុនម៉ុង រិទ្ធី ជាក្រុមហ៊ុនតែមួយគត់ដែលបានដាំដុះដំណាំដូងប្រេងនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុននេះមានផ្ទៃដីសំរាប់ការដាំដុះដំណាំដូងប្រេងប្រមាណ ៥,000 ហិចតា តូចជាងផ្ទៃដីដែលត្រូវបានដាំដុះនៅក្នុងប្រទេសមាឡេស៊ីដែលមានវិសាលភាពធំទូលាយ។ គុណភាពដូងប្រេងកម្ពុជាស្ថិតនៅក្នុងលំដាប់មធ្យម។ ដោយការខ្វះខាតនូវរោងចក្រដែលមានលក្ខណៈសមស្រប ក្រុមហ៊ុនម៉ុង រទ្ធី ត្រូវចម្រេញប្រេងដូងធម្មជាតិដោយក្រុមហ៊ុនក្នុងស្រុកនៅប្រទេសម៉ាឡេស៊ី ហើយនាំចូលនូវផលិតផលសំរេចមកលក់នៅក្នុងប្រទេសកម្ពុជាវិញ។

*(iii) **ផលិតផលក្លាសេកែច្នៃពីផលនេសាទ***

មានចំនួនក្រុមហ៊ុនបីដែលបានធ្វើការកែច្នៃនិងបង្កកផលិតផលសមុទ្រហើយធ្វើការនាំចេញផលិតផលនេះ។ ក្រុមហ៊ុន ទាំងនេះ បានដំណើរការធុរៈកិច្ចនៅក្នុងក្រុងព្រះសីហនុ។ ផលិតផលស្ថិតក្នុងលំដាប់ខ្ពស់ គឺផលិតផលបង្គាគ្រុម/ងាវ ត្រី (ត្រីដីរ៍)និងមឹក។ ផលិតផលសមុទ្រភាគច្រើនត្រូវបានទិញផ្ទាល់ពីអ្នកនេសាទ អាស្រ័យហេតុនេះនាំអោយមាន ការលំបាកដល់ការធានាការផ្គត់ផ្គង់អោយបានទៀងទាត់។ លើសពីនេះ បរិមាណផលិតផលមានការប្រែប្រួលមិនទៀងទាត់ទៅតាមរដូវកាលនេសាទនីមួយៗ។

*(iv) **ផលិតផលផ្លែឈើតំបន់ត្រូពិច***

ដំណាំហូបផ្លែកំបន់ត្រូពិចនៅកម្ពុជាត្រូវបានដាំដុះដោយកសិករដែលមានទ្រងលទ្រាយតូច។ កសិករដែលដាំដំណាំហូបផ្លែដូចជា ក្រូច ធូរេន ម្នាស់បញ្ចូលគ្នាដើម្បីកង្កើតជាតំបន់ដាំដុះដើម្បីអោយមានវិសាលភាពដីធំទូលាយ[9]។ គុណភាពនៃផលិតផលផ្លែឈើនេះ ត្រូវបានដាំដោយកសិករដែលមានលក្ខណៈខុសគ្នាហើយផលិតកម្មផ្លែឈើទាំងនេះពុំមានស្ថេរភាពឡើយ។ ផលិតផលឈើហូបផ្លែមួយចំនួន ដូចជា ផ្លែស្វាយ ត្រូវបានដាំដុះតែដោយសារមានការញ្ជាទិញពីក្រុមហ៊ុនវៀតណាម ហើយភាគច្រើននៃកសិកទាំងនោះ មិនបានចែកចាយផលិតផលនៅក្នុងប្រទេសទេប៉ុន្តែធ្វើការចែកចាយនៅក្នុងប្រទេសវៀតណាម។ អាស្រ័យហេតុនេះ មានការសន្មតថាផលិតផលផ្លែឈើទាំងអស់ច្បាស់ជាធ្វើការនាំចេញផ្ទាល់ទៅបណ្តាប្រទេសឯទៀតប្រសិនបើធ្វើការបង្កើនគុណភាពនិងរក្សាអោយបាននូវស្ថេរភាពនៃការផ្គត់ផ្គង់ដោយមានការគាំទ្រពីរដ្ឋាភិបាលក្នុងការផ្តល់នូវគោលការណ៏ណែនាំពីវិធីសាស្ត្រ បច្ចេកទេសដាំដុះដល់កសិករ។

[9] *JICA, "Present Situation of Cambodian Agricultural and Marine Products, and Basic Data for Development", 2003 (revised)*

ចំពោះបរិមាណផលិតកម្ម ផលិតផលផ្លែស្វាយមានបរិមាណច្រើនបំផុតដែល មានចំនួន ៣៦% នៃផលិតផលសរុប ហើយដែលផលិតផលម្នាស់និងល្ហុងស្ថិតនៅលំដាប់បន្ទាប់។ ក្នុងចំណោមផលិតផលផ្លែឈើទាំងនេះ ស្វាយជាផលិតផលត្រូវបានដាំ ច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ ជាការពិត ផលិតផលផ្លែស្វាយរបស់កម្ពុជា មានចំនួន ០,១៤ % នៃផលិតផលស្វាយរបស់ពិភពលោកនៅក្នុងឆ្នាំ ២០០៤ នេះ អាស្រ័យហេតុនេះ កម្ពុជា ជាប្រទេសដែលមានសក្តានុពលនាំចេញនូវផលិតផលផ្លែស្វាយ ។

**តារាង ៦.៣.៥ ផលិតកម្មនៃផ្លែឈើត្រូពិក (២០០៤)**

| ប្រភេទ | ផលិតកម្ម (០០០តោន) | សន្ទស្សន៍ (%) |
|---|---|---|
| ផ្លែស្វាយ | ២៤,៣៣៧ | ៣៥.៩ |
| ផ្លែម្នាស់ | ១៥,៤៨០ | ២២.៩ |
| ផ្លែល្ហុង | ៨,៥០៥ | ១២.៦ |
| ផ្លែអាវ៉ូកាដូ | ៣,២៧៦ | ៤.៨ |
| ផ្សេងៗ | ១៦,១០២ | ២៣.៨ |
| ផលិតកម្មសរុប | ៦៧,៧០១ | ១០០ |

ប្រភព : អង្គការ FAO "ស្ថានភាពបច្ចុប្បន្ន និងទស្សនវិស័យរយៈពេលមធ្យមសំរាប់ផ្លែឈើតំបន់ត្រូពិក"

**(v) ដំណាំកៅស៊ូ**

ដំណាំកៅស៊ូ ដែលត្រូវបានកែច្នៃជាផលិតកម្មកៅស៊ូត្រូវបានគេដាំដុះធ្វើជាផលិតផលនាំចេញសំខាន់ តាំងពីសម័យបារាំងធ្វើជាអាណាព្យាបាលខ្មែរ។ នៅពេលដែលបរិមាណផលិតកម្មកៅស៊ូមានការកើនឡើង បន្ទាប់ពីមានការធ្លាក់ចុះយ៉ាងខ្លាំង ក្នុងសម័យប៉ុលពត ផលិតផលនេះត្រូនបានមើលឃើញថាមិនសូវមានភាពជឿនលឿនប៉ុន្មានទេក្នុងកំឡុងពេលថ្មីៗនេះ។

ដោយសារផលិតភាពកៅស៊ូនៅមានកំរិតទាបក្រោមប្រព័ន្ធបច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាបានផ្ទេរសហគ្រាសទាំង ៧ របស់រដ្ឋអោយទៅវិស័យឯកជនកាន់កាប់ដោយមានកិច្ចគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ វិស័យប្រមូលផលកៅស៊ូមានការថយចុះដោយសារដំណាំកៅស៊ូទាំងនោះមានអាយុកាលចាស់នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ បច្ចុប្បន្ននេះ ចំនួនប្រមាណ ៩៥% នៃផលិតផលកៅស៊ូក្នុងស្រុករបស់កម្ពុជាត្រូវបានធ្វើការនាំចេញ។ នៅពេលដែលរដ្ឋាភិបាលកម្ពុជា មិនទាន់បានបង្កើតនូវប្រព័ន្ធវិញ្ញាបនប័ត្រ ផលិតផលកៅស៊ូកម្ពុជាត្រូវបានធ្វើការនាំចេញដោយពុំមានវិញ្ញាបន័ត្រទទួលស្គាល់ជាអន្តរជាតិ។ ជាលទ្ធផល ភាពប្រកួតប្រជែងរបស់កម្ពុជា នៅមានលក្ខណៈទន់ខ្សោយអាស្រ័យដោគុណភាព ហើយផលិតផលទាំងនោះ ត្រូវបានគេអោយតំលៃទាប ដោយផលិតផលកៅស៊ូខ្លះចុះតំលៃដល់ទៅ ២០%។

**តារាង ៦-៣-៦ ផលិតកម្ម និងការនាំចេញកៅស៊ូធម្មជាតិនៅកម្ពុជា**

| | Unit | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| Production Volume | tons | 42,007 | 38,492 | 32,385 | 32,383 | 25,928 | 20,382 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Export Volume | tons | 40,067 | 35,673 | 37,136 | 32,764 | 26,029 | 21,071 |
| Export Ratio* | % | 95.4 | 92.7 | 114.7 | 101.2 | 100.4 | 103.4 |
| Export Value | US$ mil. | 22.3 | 17.8 | 23.7 | 31.1 | 30.6 | 29.3 |
| Export Unite Value | US$/tons | 556.6 | 499.0 | 638.2 | 949.2 | 1,175.6 | 1,390.5 |

Note: Export ratios of certain years exceed 100% due to statistical problems.
Source: MAFF

***(vi) ផលិផលស្រូវ***

សមត្ថភាពនាំចេញនូវផលិតផលស្រូវរបស់កម្ពុជាត្រូវបានរំពឹងទុកនាពេលអាណាគត ដោយសារទិន្នផលស្រូវបានឆ្លើយតបទៅនិងតម្រូវការក្នុងស្រុក ហើយចំពោះទិន្នផលស្រូវមួយផ្នែកទៀតត្រូវបានរត់ពន្ធចូលទៅកាន់ ប្រទេសថៃ និងវៀតណាម ។

គ្រប់ប្រភេទអង្កររស្មើរ តែទាំងអស់មានប្រភេទ អ៊ីនឌីកា (Indica-type) មានដាក់លក់នៅលើទីផ្សារក្នុងស្រុក។ តាមការពិចារណាពីប្រភេទស្រូវយ៉ាប៉ូនីកា (Japonica-type) ឱ្យដឹងថាស្រូវប្រភេទយ៉ាប៉ូនីកានេះអាចដាំដុះ នៅក្នុងប្រទេសជិតខាងដូចជាវៀតណាម ហើយក៏អាចដាំដុះក្នុងអាកាសធាតុក្នុងប្រទេសកម្ពុជាផងដែរ។ បញ្ហាក្នុងការដាំដំណាំស្រូវប្រភេទនេះ អោយបានគុណភាពខ្ពស់គឺមិនមែនដោយសារអាកាសធាតុទេ ប៉ុន្តែគឺដោយសារបច្ចេកវិទ្យាក្នុងការដាំដុះនិងប្រព័ន្ធធារាសាស្ត្រដ៏មានកំរិតទាបក្នុងកម្ពុជា។ ស្រូវដែលដាំដុះបានបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា មានតម្លៃស្មើរតែដូចគ្នាទៅនឹងតំលៃស្រូវនៅក្នុងប្រទេសថៃ និងវៀតណាម ទោះបីជាមានការប្រែប្រួលទៅតាមប្រភេទស្រូវ និងរដូវកាលដែលមានលក្ខណៈខុសផ្លែកពីគ្នា។

***(vii) ផលិផលកសិកម្មសរីរាង្គ***

រដ្ឋាភិបាលកម្ពុជាធ្វើការជំរុញយ៉ាងសកម្មចំពោះផលិតកម្មកសិកម្មសរីរាង្គ រដ្ឋាភិបាលបង្កើតផែនការសកម្មភាពដែលមាន ១២ ចំណុច ស្ថិតនៅក្រោម (គំរោងសកម្មភាពថ្នាក់ជាតិស្តីពីកសិកម្មដែលមិនប្រើសារធាតុគីមី) យោងទៅតាមគំរោងផែនការសកម្មភាពនេះ ការផលិតដំណាំសរីរាង្គដូចជា ស្រូវ បន្លែបង្កា ផ្លែឈើ តិណជាតិ និងផលិតផលស្វាយច័ន្ទី ត្រូវបានដាំ ហើយរដ្ឋាភិបាលមានគំរោងធ្វើគំរោងផលិតកម្មផ្សេងៗចំពោះផលិតផលនេះ នាពេលអនាគត។ បើទោះជានៅពេលបច្ចុប្បន្ន បរិមាណផលិតផលកសិកម្មសរីរាង្គនៅកម្ពុជានៅមានកំរិតទាបក៏ដោយ ក៏ភាគច្រើននៃផលិផលនេះ បានផ្គត់ផ្គង់ដល់អ្នកទេសចរណ៏ក្នុងស្រុក ហើយមានសក្តានុពលទូលំទូលាយសំរាប់នាំចេញទៅបរទេសនាពេលអនាគត។ ជីនិងថ្នាំសំលាប់សត្វល្អិត កម្រត្រូវបានគេប្រើប្រាស់សំរាប់ការដាំដុះលើផលិតផលដូចជាដំណាំល្ងម្រេច ត្រូវបានគេលក់ក្នុងតំលៃទាបនៅក្នុងប្រទេស។ តែផ្ទុយទៅវិញ ជំរុញអោយកម្ពុជាអាចធ្វើការនាំចេញផលិតផលទាំងនេះជាផលិតផលសរីរាង្គ រឺក៏ផលិតផលដែលគ្មានសារធាតុគីមី។

ទន្ទឹមនិងនេះ ក្រសួងពាណិជ្ជកម្មនិងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេ សាទបានខិតខំបង្កើតឡើងនូវបទដ្ឋានអោយ មានការទទួលស្គាល់ជាអន្តរជាតិនូវផលិតផល ដែលគ្មានជាតិគីមីរបស់កម្ពុជាដោយមានការឧបត្ថម្ភគាំទ្រប្រកប

ដោយលក្ខណៈទូលំទូលាយពីស្ថាប័ននានានិងអង្គការអភិវឌ្ឍន៏ជាតិដូចជាអង្គការ GTZ សហគមន៏អ៊ឺរ៉ុប និងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ សិក្ខាសាលាស្តីពីផលិតផលកសិកម្មគ្មានជាតិគីមីបានត្រូវប្រារព្ធធ្វើឡើង កាលពីខែឧសភាឆ្នាំ ២០០៥ ដោយមានការចូលរួមពីស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ហើយផលិតផលដែលអាចចូលទីផ្សារបានត្រូវបានកំណត់ឡើងដូចដែលបានចុះនៅក្នុងតារាងខាងក្រោម។ ផលិតផលសរីរាង្គមួយចំនួនដែលមិនបានដាក់បញ្ចូលនៅក្នុងតារាង ដូចជាបន្លែបង្កផលិតផលសមុទ្រ( ត្រីអណ្តែង បង្គា និងសារាយសមុទ្រ ) និងផលិតផលសត្វ ( មាន់ទា) ត្រូវបានអោយតំលៃចពោះការលក់នៅក្នុងទីផ្សារក្នុងស្រុក។

**តារាង ៦.៣.៧ ទស្សនអនាគតរបស់ផលិតផលកសិកម្មសរីរាង្គ**

| | ផលិតផល | ទីផ្សារសំខាន់ៗ ( អនាគត : ក្នុង៣ឆ្នាំ) | |
|---|---|---|---|
| | | តំបន់ | អន្តរជាតិ |
| គ្រាប់ធញ្ញជាតិលីង (Cereals) | rice, maize (as fodder for animals) | rice | rice |
| ផ្លែឈើ (Fruits) | mango, durian, orange, citron, papaya, jackfruit, passion fruit, rambutan, banana | mango, citrus, durian, banana | mango |
| គ្រាប់សណ្តែក | cashew, coconut, peanut | cashew, peanuts | cashew |
| ផលិតផលដូងប្រេង (Palm Products) | palm wine, granulated palm sugar | palm wine, granulated palm sugar | palm wine, granulated palm sugar |
| គ្រឿងទេសហិរ (Spices) | pepper, chilli | pepper | pepper |
| ប្រេងធញ្ញជាតិ (Essential Oil) | castor oil, lemon oil | | castor oil, lemon oil |
| ប្រេងផ្លែឈើ | Sesame | sesame | |
| ផ្សេងៗ (Others) | cassava/tapioca, soybeans, mung beans, coffee, tea, sugarcane, cotton | soybeans, mung beans | |

ប្រភព : ទិន្នន័យចងក្រងដោយក្រុមសិក្សា JICA នៃ "សិក្ខាសាលាជាតិស្តីពីកសិកម្មសរីរាង្គ ២០០៥"

### (viii) *ផលិតផលកសិកម្មដ៏ទៃទៀត*

ដូចដែលបានពោលផលិតផលកសិកម្មសរីរាង្គមានសក្តានុពលនាំចេញខ្ពស់ប្រសិនជាគេអាចបែងចែកវាអោយដាច់ស្រឡះពីផលិតផល ដែលមានលក្ខណៈប្រកួតប្រជែង។ ក្រុមហ៊ុនពាណិជ្ជកម្មមួយ ក្នុងចំណោមក្រុមហ៊ុនជប៉ុនតាមរយៈ ការសំភាសដោយក្រុសិក្សា ស្រាវជ្រាវ បានលើកសំណើរឡើងចំពោះផលិតផលសរីរាង្គដូចជា ម្រេច កាហ្វេ និងល្ង អាចលក់បាននៅក្នុងទីផ្សារជប៉ុន ដូចជាហាងគ្រឿងទេសដែលមិនសូវសំខាន់ ដែលនេះមានន័យថាបរិមាណដ៏ច្រើននៃការលក់មិនត្រូវបានគេរំពឹងទុកទេ ប៉ុន្តែការលក់នៅក្នុងតំលៃខ្ពស់នឹងអាចសំរេចបាន។ ដោយយោងទៅតាមអង្កេតផលិតផលផ្លែឈើដូចជាស្វាយចន្ទី និងស្វាយក៏មានសក្តានុពលនាំចេញផងដែរ ប្រសិនបើគេបង្កើតនូវហាងលក់គ្រឿងទេសបន្ថែមទៀត។ ក្នុងចំណោម ផលិតផលនេសាទនិងផលិតផលសមុទ្រ ទឹកត្រីត្រូវបានទទួលស្គាល់ថាជា

ផលិតផលគ្រឿងទេសមិនសំខាន់ ដែលអាចមានឱកាសក្នុងការដាក់លក់នៅក្នុងទីផ្សារអន្តរជាតិ។ នៅពេលដែលផលិតផលទាំងនេះ ត្រូវបានដាក់លក់ជាគ្រឿងទេសមិនសំខាន់ចំពោះបញ្ហាដែលត្រូវលើកឡើង គឺថាតើត្រូវបង្កើតផ្លាកយីហោកម្ពុជាយ៉ាងដូចម្តេច។ នៅពេលដែលផ្លាកសញ្ញារបស់ផលិតផលកម្ពុជាត្រូវបានបង្កើត នោះផលិតផលកម្ពុជានឹងមានស្ថេរភាព។ ជាឧទាហរណ៍ ភាគច្រើននៃគ្រាប់កាហ្វេដែលបានផលិតនៅតាមខេត្តដែលជាប់ព្រំប្រទល់ប្រទេសវៀតណាម ត្រូវបានគេគិតថាផលិតផលនេះ នឹងនាំចេញទៅប្រទេសវៀតណាម ហើយត្រូវបានលក់ជាផលិតផលកាហ្វេរបស់វៀតណាម នៅក្នុងទីផ្សារអន្តរជាតិទៀតផង។ កម្ពុជាអាចមានលទ្ធភាពនាំចេញនូវផលិតផលកាហ្វេដោយផ្ទាល់ទៅទីផ្សារបរទេស ប្រសិនបើគុណភាពនិងការផ្គត់ផ្គង់ត្រូវបានគេធ្វើអោយប្រសើរថែមទៀត ជាមួយនិងកិច្ចគាំទ្រពីរដ្ឋាភិបាលក្នុងការផ្តល់នូវគោលការណ៍បច្ចេកទេសដល់កសិករ។

**៦.៣.៣ លទ្ធភាពចំពោះផលិតផលនាំចេញទៅប្រទេសជប៉ុន**

យោងតាមស្ថិតិពាណិជ្ជកម្មជប៉ុន បរិមាណផលិតផលនាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនមានតំលៃសរុប ១០,៨ កោដិយេន នៅឆ្នាំ ២00៤ ដែលក្នុងនោះ បរិមាណម្ហូបអាហារកែច្នៃកសិកម្ម និងជលផលដែលមានបរិមាណតិចតួច ពោលគឺតិចជាង ៤0 លានយេន (បង្កង: ៣0,៩ លានយេន គ្រាប់កាហ្វេ: 0,៨២ លានយេន និងស្រាបៀរ: 0,៧៥ លានយេន)។ បរិមាណនាំចេញផលិតផលថ្មីៗផ្សេងៗទៀតនៅឆ្នាំ ២000 រួមមានក្តាមត្រីកែច្នៃ ល្ង ត្រីទូណា និងមឹក ក៏មានបរិមាណតិចតួចផងដែរ។ទោះបីជាប្រទេសកម្ពុជាធ្វើការនាំផលិតផលកសិកម្មនិងជលផលភាគច្រើនទៅកាន់ប្រទេសជប៉ុន ដោយគ្មានបង់ពន្ធក្តី ហើយទាញយកផលប្រយោជន៏ពីការអនុគ្រោះពន្ធក្នុងឋានៈជាប្រទេសដែលមានការអភិវឌ្ឍន៏តិចតួច (LDC) ក៏តំរូវការនាំចេញពីប្រទេសកម្ពុជា នៅមានចំនួនតិចតួចដោយសារសមត្ថភាពក្នុងការផ្គត់ផ្គង់របស់កម្ពុជានៅមានកំរិត។

របាយការណ៏នេះនឹងធ្វើការពិនិត្យមើលថាតើកម្ពុជាមានមុខផលិតផលសំខាន់អ្វីខ្លះ ដែលអាចនាំចូលទៅក្នុងប្រទេសជប៉ុនដោយចាប់ផ្តើមពិនិត្យពីផលិតស្រូវដែលជាដំណាំដ៏សំខាន់របស់កម្ពុជា។ ក៏ប៉ុន្តែ ផលិតផលស្រូវ កម្ពុជានៅមានគុណភាពទាបពេកដែលមិនអាចនាំយកទៅលក់នៅក្នុងទីផ្សារក្នុងប្រទេសជប៉ុនបាន។ ប្រការនេះ បណ្តាលមកពីប្រភេទស្រូវដែលផលិតក្នុងប្រទេសកម្ពុជា និងកង្វះខាតប្រព័ន្ធធារាសាស្ត្រ ដែលជាបញ្ហាត្រូវដោះស្រាយសំរាប់ទស្សនៈវិស័យរយៈពេលមធ្យ និងវែង។ ផលិតដ៏ទៃទៀតសំរាប់ពេលអណាគត ដូចជា ប្រេងដូង កៅស៊ូ កាហ្វេ និងស្វាយចន្ទី ដែលបានធ្វើការដាំដុះត្រូវឆ្លើយតបទៅស្តង់ដាអន្តរជាតិទាំងគុណភាពនិងតំលៃសំរាប់នាំចេញ។ ចំពោះបញ្ហាចុងក្រោយត្រូវធ្វើការកែលំអរនូវហេដ្ឋារចនាសម្ព័ន្ធដើម្បីកាត់បន្ថយតំលៃ
ហើយត្រូវបង្កើតប្រព័ន្ធអធិការកិច្ចសំរាប់ការនាំចេញជាកត្តាសំខាន់។

ចំណែកឯផលិតផលសមុទ្រវិញ កម្ពុជាជួបការលំបាកក្នុងការបង្កើនបរិមាណនាំចេញរបស់ខ្លួនទៅកាន់ទីផ្សារជប៉ុនក្នុងរយៈពេលខ្លីអាស្រ័យដោយមានការកង្វះខាតប្រព័ន្ធវារីវប្បកម្ម និងកង្វះខាត គំរោងការដើម្បីធានាដល់ការផ្គត់ផ្គង់ផលិតផលឱ្យមានស្ថិរភាព។ ចំណែកបន្លែវិញ ប្រទេសកម្ពុជាត្រូវតែបង្កើត ស្ថប័នធូបទកម្មដើម្បីធានាដល់គុណភាពផលិតផល ដែលអាចឆ្លើយតបទៅនឹងប្រព័ន្ធគុណភាពជប៉ុន។

ក្រៅពីបញ្ហាដែលបានរៀបរាប់ខាងលើ សមត្ថភាពផ្គត់ផ្គង់នៃផលិតផលកសិកម្ម ជលផល និងផលិតផលកែច្នៃពីប្រទេសកម្ពុជានៅមានកំរិតទាបយ៉ាងខ្លាំងដែលជាហេតុធ្វើឱ្យកម្ពុជាមិនអាចពង្រីកការនាំចេញឱ្យដល់កំរិតមួយដែលអាចឆ្លើយតបទៅនឹងតំរូវការទីផ្សារក្នុងប្រទេសជប៉ុន។

## ៦.៤ អនុសាសន៍ដើម្បីជំរុញ FDI ទៅក្នុងវិស័យកសិកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហារ

### ៦.៤.១ ការរៀបចំផែនការធុរៈកិច្ចសំរាប់ក្រុមហ៊ុនជប៉ុនធ្វើវិនិយោគប្រទេសកម្ពុជា

មានការវិនិយោគបីប្រភេទដែលជំរុញអោយក្រុមហ៊ុនកែច្នៃម្ហូបអាហាររបស់ជប៉ុនដាក់ទុនវិនិយោគក្នុងប្រទេសកម្ពុជា ដូចមានរៀបរាប់ខាងក្រោម ចំណែកឯផែនការវិនិយោគនេះមាន លក្ខណៈខុសប្លែកគ្នាអាស្រ័យដោយប្រភេទនៃការធ្វើវិនិយោគទុន។

#### (1) ការវិនិយោគសំដៅរកប្រភពធនធាន

ការធ្វើវិនិយោគប្រភេទនោះមានគោលបំណងស្វែងរកធនធានដ៏សម្បូរបែបរបស់កម្ពុជានិងនាំចេញធនធានទាំងនោះ ជាវត្ថុធាតុដើម ឬកែច្នៃធនធានទាំងនោះឱ្យទៅជាផលិតសំរេចក្នុងប្រទេសកម្ពុជា ទៅកាន់ទីផ្សារនៅប្រទេសផ្សេងៗ នៅអាស៊ី និងជប៉ុន។

**តារាង ៦-៤-១ ឧទាហរណ៍នៃគំរូធុរកិច្ចដែលរកឃើញនៅក្នុងការអង្កេតតាមក្រុមហ៊ុន**

| A Company | |
|---|---|
| **Product** | **Seasonings** |
| Business in Cambodia | Production and sales of beverage |
| Business type & schedule of production in Cambodia<br>Phase 1:<br>Phase 2: | Phase 1: Production of tapioca and export to ASEAN countries within 3-5 years<br>Phase 2: Production of seasonings made of tapioca, and sell them in Cambodia within 5-10 years |
| Investment amount | Not yet decided |
| Economic effects | Import substitution, job creation, and foreign currency earning |

Source: The JICA Study Team

#### (2) ការវិនិយោគស្វែងរកពលកម្មថោក

ការវិនិយោគប្រភេទនេះបានផ្តោតទៅលើកំលាំងពលកម្មដែលមានវ័យក្មេងក្នុងប្រទេសកម្ពុជាដើម្បីធ្វើការងារផលិតកម្មអោយវិនិយោគរបស់ពួកគេ។ មូលហេតុដែលនាំឱ្យមានការជ្រើសរើសកំលាំងពលកម្មវ័យក្មេងនៅកម្ពុជាអាស្រ័យដោយមានការលំបាកក្នុងការជ្រើសរើសកម្មករក្មេងៗនៅក្នុងប្រទេសជប៉ុន ដូចជានៅក្នុងឧស្សាហកម្មកែច្នៃកម្មករក្មេងៗ ពុំមានចំណាប់អារម្មណ៍លើឧស្សាហកម្មប្រភេទនេះទៀតហើយ។ ជាលទ្ធផល ឧស្សាហកម្ម កែច្នៃម្ហូបអាហារ នៅក្នុងប្រទេសជប៉ុន អាចជួបប្រទះ នឹងបញ្ហាកង្វះពលកម្ម ។ ឧស្សាហកម្មវាយនភ័ណ្ឌ និងគ្រឿងអេឡិចត្រូនិចជប៉ុនបានដាក់ទីតាំងវិនិយោគជាថ្មីសំរាប់ធ្វើផលិកម្មនៅតាម បណ្តាប្រទេសនៅអាស៊ីអគ្នេយ៍ នៅចន្លោះទសវត្សឆ្នាំ១៩៦០ និង ១៩៧០ ដើម្បីស្វែងរកពលកម្មដែលមាន តំលៃថោក ហើយចំពោះឧស្សាហកម្មកែច្នៃម្ហូបអាហារក្នុង

រយៈពេល៣០ឆ្នាំនៅពេលក្រោយមក។ គួរកត់សំគាល់ផងដែរ ចំពោះកំលាំងពលកម្មតម្រូវអោយមានសមត្ថភាពក៏ដូចជាតំលៃថោកផងដែរ។ បើមិនដូច្នេះទេ តំលៃពលកម្មថោក និងសមត្ថភាពការងារអាចនាំអោយមានការខ្វាស់គ្នាទៅវិញទៅមក រួមទាំងអ្នកគ្រប់គ្រង ក៏រិតមធ្យមនិងវិស្វករ។ អាស្រ័យហេតុនេះ មានភាពចាំបាច់ណាស់សំរាប់រដ្ឋាភិបាលកម្ពុជាដើម្បីលើកកម្ពស់ គុណភាពកំលាំពលកម្មរបស់ខ្លួន។

**(3) ការវិនិយោគស្វែងរកទីផ្សារ**

វិនិយោគប្រភេទនេះនឹងធ្វើការរកទីផ្សារនៅក្នុងប្រទេសកម្ពុជាដើម្បីលក់ផលិតផលរបស់គេផ្ទាល់។ នៅក្នុងប្រទេសជប៉ុនមានការប៉ាន់ស្មានថា ទីផ្សារសំរាប់ម្ហូបអាហារកែច្នៃពុំមានការរីកធំធាត់ទៀតទេ ប៉ុន្តែបែរជាបណ្តាលអោយមានការធ្លាក់ចុះទៅវិញ ដោយសារការធ្លាក់ចុះអត្រាកំណើតមានការធ្លាក់ចុះ ហើយកាន់តែមានការកើនឡើងនូវមនុស្សវ័យចាស់នៅក្នុងសង្គម និងមានការកើនឡើងនូវការយល់ដឹងពីបញ្ហាសុខភាពក្នុងចំណោមប្រជាពលរដ្ឋទូទៅ។ ជាឧទារហរណ៍ ការទិញយកក្រុមហ៊ុនក្នុងស្រុកដោយក្រុមហ៊ុន Kirin Brewery nig ក្រុមហ៊ុន Suntory ដែលបានពោលខាងលើ បានត្រូវធ្វើឡើងដោយពុំមានការនាំយកផលិតផលសំរេចទៅកាន់ប្រទេសជប៉ុន តែនាំយកទៅកាន់ទីផ្សារនៅតំបន់អាស៊ី។ ក្រុមហ៊ុនកែច្នៃម្ហូបអាហារជប៉ុន ដែលបានដាក់វិនិយោគនៅក្នុងប្រទេសចិននៅពាក់កណ្តាលទសវត្សឆ្នាំ ១៩៩០ ដំបូងត្រូវបានទទួលស្គាល់ថាជាកន្លែងផលិកម្ម ប៉ុន្តែនៅពេលនេះ ត្រូបានគេមើលឃើញថាប្រទេសចិនជាកន្លែងផលិកម្មផង ហើយជាកន្លែងទីផ្សារសំរាប់លក់ផលិតផលផងដែរ។

ដូចគ្នាដែរ ក្រុមហ៊ុនមួយដែលបានផ្តល់ការសំភាសក្នុងការសិក្សាស្រាវជ្រាវនេះ គឺក្រុមហ៊ុនផលិតស្រាបៀរកំពុងមានផែនការធ្វើវិនិយោគដើម្បីធនានូវភាគហ៊ុនរបស់ខ្លួននៅក្នុងទីផ្សាររបស់ប្រទេសកម្ពុជា។

និយាយជាទូទៅ ផលិកម្មភេសជ្ជៈ ត្រូវបានធ្វើនៅក្នុងតំបន់ដែលមានការប្រើប្រាស់ច្រើន ដោយសារមានចំណាយដឹកជញ្ជូនខ្ពស់ក្នុងការនាំចេញ។ តំរូវការសំរាប់ភេសជ្ជៈ មានការពាក់ព័ន្ធយ៉ាងជិតស្និទទៅនឹងចំណូល GDP per capita. តំរូវការ នឹងកើនឡើងយ៉ាងឆាប់រហ័ស ប្រសិនបើ GDP per capita ចាប់ពី US$3,000 to US$5,000 វានឹងថយចុះមកវិញ ប្រសិនបើតម្លៃខាងលើ តិចជាង US$1,000. នេះបង្ហាញថាតំរូវការសំរាប់ភេសជ្ជៈនៅកម្ពុជានៅមានក៏រិតតិចតួចនៅឡើយ។ ម្យ៉ាងវិញទៀត per capita GDP នៅភ្នំពេញ បានខិតទៅជិតដល់ US$1,000, វាអាចត្រូវបានសន្មត់ថា ឧស្សាហកម្មភេសជ្ជៈ នឹងរីកចំរើននៅកម្ពុជា ពេលអនាគតដ៏ខ្លីខាងមុខនេះ។

**តារាង ៦-៤-២ ឧទាហរណ៍នៃផែនការធុរកិច្ចដែលរកឃើញនៅក្នុងការអង្កេតតាមក្រុមហ៊ុន**

| B Company | |
|---|---|
| Product | Beverage |
| Business in Cambodia | Production and sales of beverage |
| Spread of site | 10 hectares to be needed |
| Schedule of factory construction | Starts in 2007 |
| Schedule of production and sales | Starts in 2009 |
| Investment amount | US$30 million |
| Economic effects | Import substitution |

Source: The JICA Study Team

### ៦.៤.២ វិធានការអភិវឌ្ឍន៍សំរាប់ធនាការផ្គត់ផ្គង់សំភារៈវត្ថុធាតុដើម

ចង្វាក់ផ្គត់ផ្គង់ដែលទាក់ទងទៅនិងឧស្សាហកម្មកសិកម្មនិងជលផលនៅក្នុងប្រទេសកម្ពុជា ទំនាក់ទំនងក្នុងចំណោមផលិតករក្នុងផលិតផលកសិកម្មនិងផលិតផលសមុទ្រក្រុមហ៊ុនកែច្នៃម្ហូបអាហារនិងបណ្តាញក្រុហ៊ុនចែកចាយផលិតផលកែច្នៃនៅមានសភាពទន់ខ្សោយ ។

វិស័យអាទិភាពនៃក្រុមហ៊ុនបរទេសដែលចូលមកធ្វើវិនិយោគលើវិស័យកសិកម្ម ជលផល និងកែច្នៃម្ហូបអាហារគឺដើម្បីធនានាដល់ស្ថេភាពនៃការផ្គត់ផ្គង់សំភារៈដែលមានគុណភាពដូចគ្នា។ ទោះជាយ៉ាងណា បញ្ហាជាច្រើនដែលបានរៀបរាប់ខាងក្រោមនាំអោយមានការលំបាកក្នុងការផ្គល់ផលិផលកសិកម្ម ផលិតផលនិងផលិតផល សមុទ្រ ដើម្បីអោយឆ្លើយតបទៅនិងស្តង់ដានិងគុណភាពដែលតម្រូវដោយឧស្សាហកម្មកែច្នៃម្ហូបអាហារ។ ដូច្នេះ បញ្ហាចំបងគឺកង្វះខាតទំនាក់ទំនងរវៀងផលិតករនិងក្រុមហ៊ុនកែច្នៃនៅក្នុងវិស័យកសិកម្មនិងជលផលដែលជាហេតុនាំអោយមានការស្ទាក់ស្ទើរដល់ក្រុមហ៊ុនបរទេសក្នុងការធ្វើវិនិយោគនៅកម្ពុជា។ ដូច្នេះ វាមានសារៈសំខាន់ណាស់ចំពោះរាជរដ្ឋាភិបាលកម្ពុជាលើកឡើងពីបញ្ហាទាំងនេះដើម្បីទាក់ទាញវិនិយោគពីបរទេស ។

គួរធ្វើការកត់សំគាល់ផងដែរ ទោះបីជាមានការកើលឡើនូវបរិមាណនៃផលិតផលកសិកម្មនិងផលិតផលសមុទ្រជាការប្រសើរណាស់ចំពោះការដកចេញនូវបញ្ហាទាំនេះ ដែលនាំឱ្យមានការពង្រីកការផ្គត់ផ្គង់ ដែលធ្វើឱ្យហានិភ័យកាន់តែមានលក្ខណៈអាក្រក់ឡើងនាំអោយមានការប្រែប្រួលតំលៃនៅក្នុងទីផ្សារ។ ដូច្នេះចាំបាច់ត្រូវបង្កើតឡើងនូវប្រព័ន្ធផ្តល់ពតិមានក្នុងស្រុកស្តីពីផលិតផលកសិកម្ម និងផលិផលសមុទ្រជូនដល់បណ្តាផលិតករទាំងអស់ ដែលអាចជួយកាត់បន្ថយបាននូវហានីភ័យ ។ ចំពោះទស្សនះវិស័យខាងលើ គោលនយោបាយជាមូលដ្ឋានត្រូវបានបង្កើតឡើង ។

#### (1) ការពង្រឹងសហករណ៏កសិកម្ម និងជលផល

ប្រព័ន្ធសហករណ៏តាមរបៀបសហជីពកសិករ និងនេសាទពុំទាន់មានភាពមូលដ្ឋានរឹងមាំ ហើយប្រទេសកម្ពុជាក៏មិនទាន់មាន សហករណ៏កសិកម្ម និងសហករណ៏នេសាទនៅឡើយ។ ប្រការនេះ បានធ្វើការឆ្លុះបញ្ចាំងពីអារម្មណ៏មិនសប្បាយចិត្តចំពោះការបង្កើតសហករណ៏នេះ ដែលត្រូវបានគេជំរុញលើកទឹកចិត្តអោយបង្កើតឡើងកាលពីសម័យប៉ុលពត ហើយប្រជាពលរដ្ឋនៅមានអារម្មណ៏ស្ទាក់ស្ទើរស្តីពីការបង្កើឡើងនូវសហករណ៏នេះ។ អាស្រ័យហេតុនេះចំពោះឧស្សាហកម្មកែច្នៃកសិកម្មនិងជលផល ចាំបាច់ត្រូវទទួលយកសំភារៈពីកសិករ អ្នកនេសាទ បុគ្គលិកគោលដៅវឹអ្នកសំរបសំរួល ក្នុងការដើរតួនាទីស្រដៀងមេដឹកនាំសហជីព ដែលត្រូវការចំណាយពេលវេលានិងថវិកា។

រដ្ឋាភិបាលកម្ពុជាគួរធ្វើការពិនិត្យនូវប្រព័ន្ធសហករណ៏កសិកម្មនិងជលផលនេះអោយបានឆាប់រហ័ស។ សហករណេបទាំងនេះ មិនគ្រាន់តែចូលរួមវិភាគទានក្នុងការធានាស្ថេរភាពផ្គត់ផ្គង់ក្នុងវិស័យទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែសហករណ៏អាចដើរតួនាទីសំខាន់ជាអ្នកអប់រំណែនាំដល់កសិករនិងអ្នកនេសាទទៀតផង។

ដោយអនុវត្តមាត្រាទូទៅស្តីពីសហករណ៏កសិកម្មឆ្នាំ ២០០១ និងអនុក្រឹត្យស្តីពីកម្មវិធីអភិវឌ្ឍន៏វិស័យកសិកម្មដែលរួមបញ្ចូលទាំងគំរូអនុសារណៈសំរាប់ដៃគូ និងដោយច្បាប់ក្នុងឆ្នាំ ២០០៣នេះ មានចំនួនសហករណ៏ ៩ ដែលត្រូវបានគេបង្កើតឡើងនៅចន្លោះឆ្នាំ២០០៣និង២០០៤។ ទោះជាយ៉ាងណា ពុំមានសហករណ៏ណាមួយមាន

សកម្មភាពឡើយ។ បញ្ហាដែលធ្ងន់ធ្ងរជាងនេះទៀតនោះ គឺថារដ្ឋាភិបាលកម្ពុជាបានផ្តល់ជំនួយហិរញ្ញវត្ថុដែលមានចំនួនតិចតួចណាស់ដល់សហករណ៍ទាំងនេះ ដោយសារតែមានកង្វះខាតខាងហិរញ្ញវត្ថុ។

**(2) ការគាំទ្រគោលការណ៍ណែនាំ និងការបណ្តុះបណ្តាលសំរាប់កសិករ និងអ្នកនេសាទ**

មានកសិករតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានចំណេះដឹងនិងជំនាញនិងវិធីគ្រប់គ្រង/ប្រើប្រាស់ថ្នាំសំលាប់កត្តាចង្រៃ ជីធម្មជាតិ និងការលើកកំពស់ គុណភាពផលិតផល។ បញ្ហានេះ កើតមានឡើងដោយសារកង្វះខាតនូវគោលការណ៍ណែនាំឬការអប់រំដល់កសិករ។ ជាការពិត ដោយការត្រួតពិនិត្យគុណភាពនៅមានកំរិតទាប (ទំហំទំងន់ ភាពស្រស់ កត្តាចង្រៃ និងការប្រើប្រាស់ សារធាតុគីមីក្នុងកសិកម្ម) នាំឱ្យមានការធ្លាក់ចុះដល់តំលៃពាណិជ្ជកម្មនៃបន្លែបង្កា ដែលភាគច្រើន ត្រូវបានផលិត សំរាប់ប្រើប្រាស់ដោយកសិករខ្លួនឯង ដែលជាហេតុធ្វើឱ្យមានការធ្លាក់ចុះនូវបរិមាណសំរាប់លក់ក្នុងទីផ្សារ។ ដូច្នេះ បន្លែភាគច្រើនដែលអ្នកទីក្រុងប្រើប្រាស់ត្រូវនាំចូលពីប្រទេសផ្សេងៗ។ ត្រូវផ្តល់នូវឱកាសសំរាប់ការណែនាំ និងបណ្តុះបណ្តាលកសិករគឺជាការងារសំខាន់និងចាំបាច់។ ទោះជាយ៉ាង កន្លែងសំរាប់ធ្វើការពិសោធន៏ ដែលមាន តួនាទីយ៉ាងសំខាន់សំរាប់អ្នកអប់រំនៅមានចំនួនតិចតួច។ បញ្ហាដែលធ្ងន់ធ្ងរជាងនេះទៀតនោះ គឺថាសកម្មភាពនៃ កន្លែងពិសោធន៏ទាំងនោះ លើកលែងតែកន្លែងពិសោធន៏មួយដែលបានទទួលការគាំទ្រពីទីភ្នាក់ងារអន្តរជាតិដែល ដំណើរការសកម្មភាពយឺតយ៉ាវ អាស្រ័យដោយសារកង្វះខាតធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលជាកត្តា នាំអោយមានការរាំងស្ទះដល់ការពង្រីកអោយបានទូលំទូលាយនូវបច្ចេកវិទ្យានិងគោលការណ៍ណែនាំដល់កសិករ។

ជាឧទាហរណ៍ មានការដាក់បន្ថែមមន្ត្រីប្រមាណ ជា ៥00 នាក់សំរាប់កសិករចំនួន ២លានគ្រួសារ នៅក្នុងប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត មានសមាជិកចំនួន៤000គ្រួសារក្នុងមន្ត្រីម្នាក់ដែលមានចំនួន៣ដងធំស្មើនិងប្រទេសវៀតណាម ដែលមានចំនួន (១៣៤0 គ្រួសារក្នុងមន្ត្រីម្នាក់)[១០] ។

នាយកដ្ឋានមួយនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (នាយកដ្ឋានក្សេត្រសាស្ត្រ និងការលើកំពស់ដីកសិកម្ម) បានប្រារព្ធធ្វើកម្មវិធីបណ្តុះ បណ្តាល (Long Famer's Field School) ដើម្បីបណ្តុះបណ្តាលកសិករពីរបៀបដាំដុះក្នុងវិស័យកសិកម្ម។ ដូចគ្នាដែរ គោលការណ៍បច្ចេកទេស រឺក៏គោលការណ៍ណែនាំដល់កសិករពុំទាន់បានធានាបានគ្រប់ជ្រុងជ្រោយ ពីកម្មវិធីបណ្តុះបណ្តាលនេះទេ។ ការបង្កើនឡើងនូវប្រព័ន្ធអប់រំបណ្តុះបណ្តាលទៅដល់កសិករ គឺជាបំណងប្រាថ្នាដ៏ចាំ បាច់ដែលត្រូវតែធ្វើឡើង។

**(3) ការអភិវឌ្ឍន៏នូវហេដ្ឋារចនាសម្ព័ន្ធកសិកម្ម (ការកែលំអប្រព័ន្ធ ធារាសាស្ត្រ)**

ភាពយឺតយ៉ាវក្នុងការលើកកំពស់គុណភាពប្រព័ន្ធធារាសាស្ត្របណ្តាលអោយមានផលប៉ះពាល់ដល់គុណភាពផលិតកម្មកសិកម្ម ជលផល និងផលិតផលកសិកម្ម។ ប្រទេសកម្ពុជា មានសកម្មភាពមមាញឹកក្នុងការកសាងប្រព័ន្ធធារា សាស្ត្រចាប់តាំងពីទទួលបានឯករាជភាពពីបារាំងនៅក្នុងឆ្នាំ ១៩៥៣ ប៉ុន្តែប្រព័ន្ធទាំងនេះ ត្រូវបានខូចខាតយ៉ាងដំណាំក្នុង

[10] *Economic Institute of Cambodia (EIC)*

សម័យ សង្គ្រាមស៊ីវិលក្នុងស្រុកជាបន្តបន្ទាប់។ ប្រព័ន្ធប្រឡាយទឹកដែលបានកសាងឡើងក្នុងរបបប៉ុលពតត្រូវបានមើលឃើញថានៅមានបញ្ហាបច្ចេកទេស។ យោងទៅលើការសិក្សាជាក់ស្តែងលើលក្ខ័ណ្ឌនៃប្រព័ន្ធធារា សាស្ត្រដែលបានសិក្សាដោយគណៈកម្មការជាតិទន្លេមេគង្គពីកំឡុងឆ្នាំ ១៩៩៣ - ១៩៩៤ ឃើញថាភាគរយនៃ ប្រព័ន្ធធារាសាស្ត្រ ដែលអាចដំណើរការបាន មានប្រហែល ២១% ប៉ុណ្ណោះ ក្នុងចំនួនសរុបទាំងអស់ ៨៤១[១១]។

ចំពោះការសិក្សានេះត្រូវបានធ្វើឡើយដោយវិទ្យាស្ថានស្រាវជ្រាវឯកជនកាលពីឆ្នាំ២០០៥ ហើយបាន បង្ហាញថាការខ្វះខាតចំពោះការផ្គត់ផ្គង់ទឹកគឺជាបញ្ហាចំបង ដែលជាលទ្ធផលបង្ហាញអោយឃើញនូវបញ្ហាប្រឈម ដ៏សំខាន់ចំពោះផលិតកម្មកសិកម្មនិងជលផលរបស់កម្ពុជាដែលមានដូចខាងក្រោមៈ ១-កង្វះខាតចំពោះការផ្គត់ផ្គង់ទឹក (អត្រាឆ្លើយតបៈ កសិករចំនួន ៨៤%)២- កង្វះខាតមាស៊ីនសំរាប់ធ្វើកសិកម្ម (អត្រាឆ្លើយតបៈ កសិករចំនួន ២៩%) ៣-កង្វះខាតជីនិងថ្នាំសំលាប់កត្តាចង្រៃ (អត្រាឆ្លើយតបៈ កសិករចំនួន ១៨%) ៤- កង្វះខាត ផ្ទៃដីសំរាប់ធ្វើកសិកម្ម (អត្រាឆ្លើយតបៈ កសិករចំនួន ៥%)៥- កង្វះខាតផ្នែកបច្ចេកទេសសំរាប់ធ្វើកសិកម្ម (អត្រាឆ្លើយតបៈ កសិករចំនួន ៤%)[១២]។

ការលើកកំពស់នូវប្រព័ន្ធធារាសាស្ត្រនឹងអាចនាំមកនូវគុណប្រយោជន៏យ៉ាងច្រើនៈ ១- នាំអោយមានស្ថេរភាពក្នុងការធ្វើកសិកម្ម និងបង្កើនឡើងនូវបរិមាណផលិតកម្មជាបន្តបន្ទាប់ ២- កាត់បន្ថយបានចំពោះការធ្វើផលិកម្មច្រើនមុខដោយត្រូវបានគេឃើញនៅតាមបណ្តាខេត្តមួយចំនួន ដោយផ្លាស់ទៅធ្វើដំណាំបន្ទាប់បន្សំជំនួសស្រូវនៅក្នុងរដូវធ្លាក់ភ្លៀង ហើយ ៣-កាត់បន្ថយចំណាយប្រចាំគ្រួសារ ក្នុងការធ្វើកសិកម្មនិងលើកកម្ពស់អាហារបំប៉នចំពោះកសិករ[១៣]។

រដ្ឋាភិបាលកម្ពុជាបានបង្កើតនូវស្ថាប័នរដ្ឋបាលឯករាជ្យមួយ គឺក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីបង្កើនការធ្វើកំណែទំរង់ប្រព័ន្ធធារាសាស្ត្រ។ រហូតមកទល់ បច្ចុប្បន្ននេះ ក្រសួងទើបតែបានដំណើរការជួសជុលនិងថែរក្សាចំពោះប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ប៉ុន្តែ ក្រសួងសង្ឃឹមថា នឹងពង្រីកបង្រើកនូវតួនាទីរបស់ខ្លួនបន្ថែមទៀត។

### ៦.៤.៣ វិធានការអភិវឌ្ឍន៏សំរាប់ការទាក់ទាញវិនិយោគ

#### (1) ការផ្តល់អំណាច និងការលើកំពស់នូវស្តង់ដារវាយតំលៃចំណីអាហារនិងស្ថាប័នអធិការកិច្ចនៅក្នុងប្រទេស

ប្រទេសកម្ពុជាពុំទាន់មានស្តង់ដារវាយតំលៃម្ហូបអាហារ និងទីភ្នាក់ងារអធិការកិច្ចម្ហូបអាហារនៅឡើយ ហើយកម្ពុជាក៏ពុំទាន់មានគោលការណ៏ណែនាំអ្វីដល់ឧស្សាហកម្មកែច្នៃម្ហូបអាហារដែរ ។ទោះជាយ៉ាងណា ប្រទេសកម្ពុជាមានវិទ្យាស្ថានជាតិមួយគត់ឈ្មោះ មជ្ឈមណ្ឌលមន្ទីរពិសោធន៏កម្ពុជា (ILCC)ដែលស្ថិតនៅក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានតួនាទីត្រួតពិនិត្យរបបអាហារ និងឧស្សាហកម្មម្ហូបអាហារ ប៉ុន្តែបុគ្គលិកមជ្ឈមណ្ឌលនេះធ្វើការងារភាគច្រើនជាមួយរោងចក្រដោយធ្វើការបណ្តុះបណ្តាលកម្មករពីសង្វាក់ផលិតកម្ម។

ដោយមានក្តីព្រួយបារម្ភថា ម្ហូបអាហារមានផលប៉ះពាល់ផ្ទាល់ជាមួយសរីរាង្គរបស់មនុស្ស ពិភពលោកកំពុង

---

[11] *Ministry of Foreign Affairs, Japan "Japan's Country Assistance Program for Cambodia 2002"*
[12] *Economic Institute of Cambodia (EIC)*
[13] *International Development Centre of Japan, "Farming Village Support for Cambodia"(March 2001)*

បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាសុខភាព ដោយបានធ្វើការពង្រឹងច្បាប់ត្រួតពិនិត្យក្នុងប្រទេសដែលនាំចូល។ ជាឧទាហរណ៍ ដើម្បីនាំផលិតផលម្ហូបអាហារទៅកាន់ប្រទេសជប៉ុន អ្នកនាំចូលផលិតផលចាំបាច់បញ្ជូនមកជាមួយនូវបញ្ជីវត្ថុធាតុដើមបញ្ជីលាយគ្រឿងផ្សំ ឯកសារបញ្ជាក់ពីដំណើរការផលិតលិខិតបញ្ជាក់ពីអនាម័យ និងការត្រួតពិនិត្យសុវត្ថិភាពដោយផ្អែកលើច្បាប់អនាម័យម្ហូបអាហារដែលអាចធ្វើឡើងក្នុងករណីមួយចំនួន។

*ជាដំបូង រដ្ឋាភិបាលកម្ពុជាគួរង្រឹងនៅមុខនាទីរបស់អាជ្ញាធរដែលមានការពាក់ព័ន្ធទៅនិងអានាម័យម្ហូបអាហារ។ នៅពេលនោះ ត្រូវធ្វើការក្រលំអរចំពោះស្តង់ដារសុវត្ថភាពសំរាប់ម្ហូបអាហារកែច្នៃ។ ក្នុងគោលដៅការពារផែទាំសុខភាពរបស់អ្នកប្រើប្រាស់និងធានាចំពោះដល់ការអនុវត្តកិច្ចការពាណិជ្ជកម្មប្រកបដោយលក្ខណៈយុត្តិធមិនៅក្នុងពាណិជ្ជកម្មចំណីអាហារសាកល ស្ថាប័ន CODEX ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៣ ដោយអង្គការ FAO ហើយនិងអង្គការសុខភាពពិភពលោក (WHO) ដែលអង្គការទាំងនេះ មានតួនាទីសំខាន់ក្នុងការបង្កើស្តង់ដាម្ហូបអាហារដូច ជាស្តង់ដា របស់ CODEX ។*

*ស្តង់ដារបស់ CODEX ពុំមានឥទ្ធិពលក្នុងការបង្ខិតបង្ខំឡើយ ប៉ុន្តែវាអាចប្រើប្រាស់ បានជាស្តង់ដា សំរាប់ថ្លឹងថ្លែងក្នុងការដោះស្រាយទំនាស់ដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មម្ហូបអាហារ។ អាស្រ័យហេតុនេះ មានការស្នើឡើងដល់រដ្ឋាភិបាលកម្ពុជាគួរធ្វើសុខដមកម្មស្តង់ដាម្ហូបអាហាររបស់ខ្លួនតាមស្តង់ដារ របស់ CODEX ។*

**(2) បង្កើតកន្លែងស្តុកមានសីតុណ្ហភាពទាប ឃ្លាំងក្លាសេ និងប្រព័ន្ធដឹកជញ្ជូនបំពាក់ដោយ ឧបករណ៍ក្លាសេ**

ចំពោះកង្វះខាតកន្លែងស្តុកមានសីតុណ្ហភាពទាប ឃ្លាំងក្លាសេ និងប្រព័ន្ធដឹកជញ្ជូនបំពាក់ដោយឧបករណ៍ក្លាសេធ្វើឱ្យកម្ពុជាមិនអាចដឹកជញ្ជូនត្រីទឹកសាបពីបឹងទន្លេសាប និងត្រីសមុទ្រដោយរក្សានូវភាពស្រស់របស់ត្រីបានទេ។ ម្យ៉ាងទៀត ផលិតផលនេសាទដែលធ្លាក់គុណភាពភាគច្រើនត្រូវបានបោះចោលជា ហេតុនាំទៅដល់ការខ្ជីខ្ជាធនធាន។ ចំពោះការកសាងកន្លែងក្លាសេគឺជាបំណងប្រាថ្នារបស់ប្រទេសកម្ពុជា។ នៅក្នុងប្រទេសជប៉ុន ទីកន្លែងនិងប្រព័ន្ធសំរាប់ស្តុកក្លាសេផលិតផលត្រូវបានបង្កើតឡើងដោយការធ្វើ វិនិយោគរួមគ្នារវាងរដ្ឋ និងឯកជន។ ការធ្វើយ៉ាងនេះ នាំអោយប្រទេសកម្ពុជាអាចលើកកំពស់បាននូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនក្នុងទីផ្សារអន្តរជាតិ ទោះម្បីជាប្រព័ន្ធ និងសំភារៈទាំនោះ មិនមានការជួយអន្តរាគមន៍ខ្លាំងពីរដ្ឋាភិបាល ប៉ុន្តែការវិនិយោគបានធ្វើឡើង ដោយវិស័យឯកជនដែលស្របទៅតាមយន្តការទីផ្សារ។

**(3) ពង្រឹងការជំរុញវិនិយោគ (លើកកំពស់សម្ថភាពក្នុងការផ្តល់ពិតមាន)**

នៅក្នុងប្រទេសកម្ពុជា នៅមានការលំបាកមួយចំនួនសំរាប់ក្រុហ៊ុនបរទេសក្នុងវិស័យកែច្នៃម្ហូបអាហារដែលស្វះស្វែងរកកិច្ចគាំទ្រអោយបានគ្រប់គ្រាន់ក្នុងការមកបន្ដាក់ទុននៅក្នុងប្រទេសនេះ។ ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា គឺជាស្ថាប័នដំបូង គេក្នុងការផ្តល់សេវាកម្មអោយបានទូលំទូលាយ ដល់ក្រុមហ៊ុនបរទេសដែលមានគោលបំណងមកធ្វើការបន្តាក់ទុន ក្នុងវិស័យកែច្នៃកសិកម្ម ជលផល និងឧស្សាហកម្មកែច្នៃម្ហូបអាហារ ការផ្តល់សេវា

កម្មនេះរាប់បញ្ចូលទាំងការជួយជ្រើស រើសទីតាំងវិនិយោគ ពន្យល់ពីនីតិវិធីនិងច្បាប់ស្តីពីវិនិយោគ ការសិក្សាលទ្ធភាពរបស់គំរោង កំលាំងពលកម្ម និងការផ្តល់នូវហិរញ្ញវត្ថុសំរាប់ការវិនិយោគ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ជាស្ថាប័នមួយ ដែលគួរ ត្រូវបានគេពង្រឹងដើម្បីអោយបំពេញនូវកិច្ចការទាំងនេះ។

ហើយជាបន្ទាប់មក ត្រូវមានកិច្ចគាំទ្រដល់ក្រុមហ៊ុនបរទេសដែលជួបការលំបាកក្នុងការស្វែរកនូវប្រភពពិតមាននៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែរកពិតមានសំខាន់ៗស្តីពី ដែលទាក់ទងនិងឧស្សាហកម្មដែលទាក់ទងទៅនិងម្ហូបអាហារ។ ជាពិសេសទៀត ចំពោះពិតមានទាំងនេះ ដូបជាច្បាប់ បទបញ្ញត្តិ ពិតមានទីផ្សារ ការដេញថ្លៃសំភារៈ ហើយនិងពិតមានស្តីពីដៃគូរប្រកួតប្រជែងដែលមានសារៈសំខាន់សំរាប់វិនិយោគិន។ ការលើកកំពស់សេវ៉ាផ្តល់ពិតមានពីស្ថាប័នរដ្ឋាភិបាល/ស្ថាប័នសាធារណៈ រួមទាំងក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ត្រូវបានគេផ្តល់អនុសាសន៏អោយរៀបចំ ដំណើរការឡើងក្នុងគោលដៅសំរួលដល់វិនិយោគ។

**(4) ការធ្វើអោយប្រសើរដល់មូលដ្ឋានគ្រឹះដ៏ទៃទៀត**

តម្រូវការនៃការកែលំអរ វិស័យដ៏ទៃទៀត គឺការកែទំរង់នូវមូលដ្ឋាន គ្រឹះដើម្បីធានាអោយបាននូវនិរន្តរភាពផលិកម្មកសិកម្ម។ ជាដំបូង រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវកសាងសមត្ថភាពក្នុង ការបង្កើតឡើងនូវគោលនយោបាយកសិកម្ម ព្រមទាំងធ្វើការអនុវត្តប្រកបដោយប្រសិទ្ធិភាព។ វិសាលភាពនៃវិធាន ការនានាក្នុងការពង្រាងផែនការអភិវឌ្ឍន៏កសិកម្មដើម្បីវិភាគទៅលើស្ថិតិដែលមានការពាក់ព័ន្ធ។ កក្តាគន្លឹះដ៏ទៃទៀត គឺការប្តេជ្ញាពង្រឹងបន្ថែមនូវគោលនយោបាយជំរុញការនាំចេញ។ ចំពោះវិធានការចាំបាច់ ចុងក្រោយ រួមមានការកសាង សមត្ថភាពក្នុងការធ្វើនយោបាយពង្រីកការនាំចេញ ធ្វើការសិក្សាទៅលើផែនការនាំចេញ លើកកំពស់ភាពប្រកួត ប្រជែង និងផ្តល់សិទ្ធដល់ស្ថាប័នដែលមានការពាក់ព័ន្ធក្នុងការងារជំរុញការនាំចេញ (ឧទារហរណ៏ៈ ការប្រមូលទិន្ន័យ ស្តីពីទីផ្សារបរទេស)។

## ៦.៤.៤ ការអភិវឌ្ឍន៏ នៃឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ដោយការទាក់ទាញការវិនិយោគបរទេស

Deleted: 6.4.4 The Development of Agricultural, Fishery and Food Processing Industries by Luring Foreign Investment

គំនូសបំព្រួញខាងក្រោម បង្ហាញថា ការអភិវឌ្ឍន៏នៃឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ដោយការទាក់ការវិនិយោគបរទេស ដែលត្រូវបានគ្រោងទុកដោយក្រុមសិក្សាតាមរយៈគំរោងនេះ។

Formatted: Indent: First line: 1.18 cm

ក្រុមហ៊ុនកែច្នៃម្ហូបអាហារនៅអាស៊ី នឹងចាប់ផ្តើមធ្វើលទ្ធកម្មនៃវត្ថុធាតុដើមពីកម្ពុជា មុនពេលគេធ្វើការវិនិយោគ ដោយផ្ទាល់ ទោះបីជាបរិស្ថានវិនិយោគរបស់កម្ពុជា ត្រូវការមានការកែលំអនាពេលបច្ចុប្បន្ន ដើម្បីទាក់ទាញារវិនិយោគបរទេសក៏ដោយ។ មុខទំនិញសក្តានុពលនាពេលអនាគតដើម្បីធ្វើការទិញពីកម្ពុជា រួមមានដំឡូងមី ផ្លែឈើត្រូពិក ម្រេច ល្ង និងកាហ្វេ។

ជាការចាប់ផ្តើម អ្នកកែច្នៃម្ហូបអាហារ នឹងទិញវត្ថុធាតុដើមនៅតាមទីផ្សារ។ ពេលនោះពួកគេនឹងចាប់ផ្តើមចុះកិច្ចសន្យាជាមួយកសិករកម្ពុជាក្នុងការដាំដុះ ដើម្បីធានាបាននូវការផ្គត់ផ្គង់មួយមានស្ថេរភាព។ ការផ្តល់កិច្ចសន្យាប្រើធនធានក្រៅទាំងនេះ អាចផ្តល់ផលដល់ការគ្រប់គ្រងកសិដ្ឋានក្នុងស្រុក ដោយក្រុមហ៊ុនបរទេស ជាមួយនឹងការដាក់ទុនក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ វាជាការសំខាន់ណាស់ ដើម្បីបង្កើតប្រភេទសំរាប់ការវាយតម្លៃម្ហូបអាហារនៅកម្ពុជា ដើម្បីធ្វើប្រត្យក្សកម្មការធ្វើលទ្ធកម្មខាងលើ។

ឧស្សាហកម្មកែច្នៃម្ហូបអាហារ នឹងរីកចំរើនស្របពេលជាមួយនឹងកំណើននៃប្រព័ន្ធធានាបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមដែលមានស្ថេរភាព។ ការបង្កើតចង្វាក់ត្រជាក់ ដែលគួរតែពង្រឹងចង្វាក់តម្លៃរវាងអ្នកផលិត (កសិករ និងអ្នកនេសាទ) ឧស្សាហកម្មកែច្នៃផលនេសាទ និងកសិផល និងអ្នកចែកចាយ អាចត្រូវបានដឹកនាំមុខការអភិវឌ្ឍន៍។

រូបភាព ៦-៤-១ គំរូធុរកិច្ចសំរាប់ការអភិវឌ្ឍន៍នៃឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល
(ការអភិវឌ្ឍន៍នៃឧស្សាហកម្មដោយការទាក់ទាញវិនិយោគបរទេស)




**[Development Scenario]**

| | Short-Term | Medium-Term | Long-Term |
|---|---|---|---|
| Objectives | - Expansion of agricultural product exports | - Import substitution of agricultural processing products<br>- Diversification of export items | - Competitiveness enhancement of Cambodian products |
| Agricultural and Fishery Industries | - System building to steadily supply products with a given level of quality<br>- Export promotion within the Asian market | - Diversification of export items to meet the needs of surrounding countries and Japan | - Differentiating home products from those of other Asian countries, e.g. through encouraging the production of organic agricultural items<br>- Building brand strength |
| Food Processing Industry | - Procurement of raw materials by the food processing industry of neighbouring countries (obtaining from market, outsourcing of cultivation, etc.) | - Transformation of the system of the food processing industry from household to modern industrial manufacturing | - Fostering the food processing industry with higher value added<br>- Building brand strength |

Source: JICA Study Team

# ជំពូកទី ៧

## ឧស្សាហកម្មនិងការវិនិយោគ និងអនុសាសន៍ ស្តីពីឱកាសវិនិយោគ

## សំរាប់ការទាក់ទាញឧស្សាហកម្មផលិតស្បែកជើងមកកម្ពុជា

### ៧.១ ចរិតលក្ខណៈឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា

### ៧.១.១ ការប្រៀបធៀបជាអន្តរជាតិនៃឧស្សាហកម្មស្បែកជើង

ដូចជាឧស្សាហកម្មកាត់ដេរដែរ ឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា បាននាំចូលវត្ថុធាតុដើមស្ទើរតែគ្រប់ប្រភេទទាំងអស់និងជាប្រភេទឧស្សាហកម្មអតិពលកម្ម ដោយមានការចំណាយថោកក្នុងដំណើរការផលិតកម្ម។ ឧស្សាហកម្មផលិតស្បែកជើង បាននាំមកនូវផលប្រយោជន៍ច្រើន។ អត្ថប្រយោជន៍ទាំងនេះ រួមមានការផ្គត់ផ្គង់កំលាំងពលកម្មថោក ការលើកទឹកចិត្តដែលផ្តល់ដោយច្បាប់ស្តីពីវិនិយោគ និងសិទ្ធិស្របច្បាប់របស់កម្ពុជា សំរាប់ការនាំចេញផលិតផលទៅកាន់ទីផ្សារនៅប្រទេសអភិវឌ្ឍន៍ (ជប៉ុន សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប) ដោយប្រព័ន្ធអនុគ្រោះទូទៅ។ គិតត្រឹមដំណាច់ឆ្នាំ ២០០៤ ក្រុមហ៊ុនបរទេសជាច្រើន (រួមបញ្ចូលទាំងក្រុមហ៊ុនប្រហែលជា ២០ ដែលបានផលិតសំភារៈបរិក្ខារបន្ទាប់បន្សំ និងផ្នែកផ្សេងៗនៃស្បែកជើង) បានមកបោះទីតាំងនៅកម្ពុជា។ វត្តមាននៃក្រុមហ៊ុន បរទេសបាននាំមុខដោយក្រុមហ៊ុនមកពីកោះតៃវ៉ាន់ ដែលសំបូរទៅដោយអ្នកមានបទពិសោធន៍ និងបច្ចេកវិទ្យា ទាក់ទងនឹងការផលិតស្បែកជើង។ បាតុកម្មជាញឹកញាប់រវាងកម្មករ និងអ្នកគ្រប់គ្រង ដែលបណ្តាលមកពីកត្តាផ្សេងៗ ជាច្រើននោះ បានធ្វើអោយចំនួនក្រុមហ៊ុនធ្លាក់ចុះអស់ជាងពាក់កណ្តាលមកនៅត្រឹមតែ ៩ ក្រុមហ៊ុនប៉ុណ្ណោះ គិតត្រឹម ចុងឆ្នាំ ២០០៥។

**តារាង ៧-១-១ បញ្ជីឈ្មោះក្រុមហ៊ុនស្បែកជើងបរទេសនៅកម្ពុជា**

| Company Name | Nationality | Capital (1000 US$) | Employee (person) | Production (1000 piece/M) | Abstract |
|---|---|---|---|---|---|
| Chain Hwey Shoes | Taiwan | 2,028 | 2,000 | NA | · |
| Focus Footwear | Taiwan | 1,312 | 1,200 | 100 | · Leather shoes, sandals, sneakers, various other<br>· 50% to the EU, 50% to Japan |
| Intech Footwear | Taiwan | 1,026 | 630 | 100 | · 100% sports shoes (20% leather)<br>· Almost all exported to the EU<br>· Increase from 2 to 3 production lines |
| Global Footwear | Taiwan | 1,004 | 735 | n.a | · Investment application filed in 2004; preparations now under way for plant operation |
| Magnate Footwear | Taiwan | 5,000 | 2,300 | n.a | · |
| Ming Da Footwear | Taiwan | 3,250 | 2,300 | 300 | · Sports shoes and leather shoes<br>· 70% to the EU, 30% to Japan |
| New Star Shoes | Taiwan | 5,115 | 3,000 | 320 | · Sited near Sihanoukville; 90% leather shoes<br>· Consigned production for Regal and Japanese firms<br>· 90% to Japan, 10% to the EU |
| Shoes Premier | Macau | 1,000 | 2,800 | NA | |
| Sky Star Footwear | Taiwan | 2,000 | 800 | NA | |

Source: JICA Study Team

ការនាំចេញពីឧស្សាហកម្មស្បែកជើងរបស់កម្ពុជា បានកើនឡើងជាលំដាប់ ហើយវាបានកើនលើសពី ២០០លានដុល្លា

នៅឆ្នាំ២០០៣ និង ២០០៤ ប៉ុន្តែបានធ្លាក់ចុះមកវិញនៅត្រឹម ១៨០លានដុល្លាក្នុងឆ្នាំ២០០៥ ហើយការធ្លាក់ចុះនេះបណ្តាលមកពីបាតុកម្មជាញឹកញាប់ ដែលនាំអោយមានការបិទរោងចក្របរទេសមួយចំនួន។ ការនាំចេញភាគច្រើនឆ្ពោះទៅកាន់ទីផ្សារនៅអឺរ៉ុប។ ទំនិញមួយចំនួនដែលបាននាំចេញ ដូចជាស្បែកជើងកីឡា និងស្បែកជើងមានទ្រនាប់គ្រប់ប្រភេទ គឺជាប្រភេទស្បែកជើងស្បែកដែលត្រូវបានគេផលិតច្រើនជាងគេ។ ថ្មីៗនេះ មានការកើនឡើងទីផ្សារនៅតាមបណ្តាប្រទេសផ្សេងៗទៀត ក្រៅពីទីផ្សារអឺរ៉ុប ដូចជាជប៉ុនគឺជាប្រទេសមួយ ដែលនាំចូលស្បែកជើងធ្វើពីស្បែកមកពីកម្ពុជា ដែលជាការនាំចេញផ្តល់ផលប្រយោជន៍ខ្ពស់។ ទៅថ្ងៃអនាគតទីផ្សារនៅអឺរ៉ុបកាន់តែចង្អៀតសំរាប់កម្ពុជា ដោយសារកំណើនការផលិតនៅប្រទេសចិន និងប្រទេសវៀតណាម។

**តារាង ៧-១-២ និន្នាការនៃការនាំចេញផលិតផលស្បែកជើងកម្ពុជា (Million US$ %)**

| | 2001 | 2002 | 2003 | 2004 | 2005 | Influence factor for future change |
|---|---|---|---|---|---|---|
| EU | 118 | 113 | 111 | 106 | 80 | An anti-dumping problem of leather shoes export to EU from China and Vietnam |
| Japan | 62 | 75 | 84 | 86 | 92 | Leather shoes trust production for Japanese companies increases |
| Others | 6 | 7 | 9 | 11 | 10 | |
| Total | 186 | 195 | 204 | 203 | 182 | |

Source:JICA Study Team estimation based on the material of MOC, UN and the Japanese import statistics

**តារាង ៧-១-៣ ការនាំចូលផលិតផលស្បែកជើងពីប្រទេសអាស៊ាន/ចិន នៅទីផ្សារជប៉ុន/អាមេរិក/អឺរ៉ុប និងចំណែកនៃការផ្គត់ផ្គង់របស់កម្ពុជា**

(Billion US$, %)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| Import from World(Exc.US、EU、Japan)(A) | 34.47 | 36.37 | 39.10 | 43.46 | 48.03 | 53.32 |
| Import from ASEAN+China(B) | 18.12 | 18.97 | 20.09 | 22.00 | 24.43 | 26.81 |
| Import from Cambodia(C) | 0.17 | 0.19 | 0.20 | 0.20 | 0.20 | 0.18 |
| Ratio:Import from Cambodia/(A)*100 | 0.95 | 0.98 | 0.97 | 0.93 | 0.83 | 0.68 |
| Ratio:Import from Cambodia/(A)*100 | 0.50 | 0.51 | 0.50 | 0.47 | 0.42 | 0.34 |

Source:JICA Study Term estimation based on the UN Commodity Trade Statistics

## ៧.១.២ ការវិភាគ SWOT (ភាពខ្លាំង ភាពខ្សោយ ឱកាស និងគ្រោះគំរាម) នៃផលិតផលស្បែកជើងនៅកម្ពុជា

លទ្ធផល SWOT នៃការវិភាគនៃផលិតផលស្បែកជើងនៅកម្ពុជា ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម :

**តារាង ៧-១-១ ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៍ភាព និងភាពគំរាមកំហែងនៃផលិតផលស្បែកជើង (ឧស្សាហកម្មស្បែកជើងរបស់កម្ពុជា)**

| Strengths | Weaknesses |
|---|---|
| ・ Low-waged labour with reasonable level of quality could still be one of the strengths of Cambodia making its sales prices more competitive.<br>・ An improvement of investment circumstances in Cambodia great efforts by CDC/CIB<br>・ Honoring the ILO standards is linked to US orders. | ・ Cambodian footwear exports/ sales are mainly concentrated in very few markets that are Japan and Germany.<br>・ Frequent interventions of labour unions should be improved<br>・ Labor strife and management failures in recent |

| Strengths | Weaknesses |
|---|---|
| • Due to GSP for the Western countries, import tariffs to these countries are low. | years have triggered a withdrawal by foreign firms and induced a phase of stagnation |
| **Opportunities** | **Threats** |
| • Anti-dumping measures against footwear industries in China and Vietnam are expected to force them to relocate in Cambodia leading to increased sales and exports.<br>• Rising costs in other countries such as China, Vietnam, etc., are expected to force footwear industries there to relocate to a lower cost country like Cambodia leading to increased sales and exports | • Minimum wage is increased from $45/mo to $50/mo effective from January 2007. |

Source: Compiled by JICA Study Team

## ៧.១.៣ លក្ខណៈពិសេសក្នុងឧស្សាហកម្មស្បែកជើង និងឧស្សាហកម្មស្បែកជើងរបស់កម្ពុជា

ឧស្សហកម្មផលិតស្បែកជើង មានលក្ខណៈពិសេសដោយសារសំភារៈបន្ទាប់បន្សំសំរាប់ការផលិតមានច្រើន និងដំណើរការផលិតកម្មមានលក្ខណៈច្រើនយ៉ាង និងស្មុគស្មាញ (ដោយរួមបញ្ចូលទាំងការបិតបង្ហើយផ្នែកខាងលើការដាក់ឬបិតទ្រនាប់ដោយប្រើកាវ)។ ដូចបានប្រៀបធៀបទៅនឹងឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មផលិតស្បែកជើង បានពង្រីកឥទ្ធិពលច្រើន ទាក់ទិននឹងការងារ ការវិនិយោគ និងបច្ចេកវិទ្យា។ រោងចក្រ មានកម្មករចំនួន ៥០០ នាក់ ក្នុងមួយខ្សែសង្វាក់ផលិតកម្ម សំរាប់ដំណើរការផលិតស្បែកជើងស្បែក និង ៧០០ នាក់ សំរាប់ការផលិតស្បែកជើងកីឡា/ស្បែកជើងមានទ្រនាប់។ ការវិនិយោគដើម្បីអោយមានខ្សែសង្វាក់ផលិតកម្មមួយ (មិនគិតទាំងអាគារ) ត្រូវចំណាយប្រហែល ០.៥ លានដុល្លារអាមេរិក សំរាប់ស្បែកជើងស្បែក ដោយសន្មត់ថាបំពាក់គ្រឿងឧបករណ៍ និងសំភារៈបរិក្ខារ ដែលគេបានប្រើរួចហើយ (តាមការប៉ាន់ស្មានមានតំលៃប្រហែល ៨០% នៃតំលៃសរុបរបស់ សំភារៈបរិក្ខារថ្មី)។ ការចំណាយសំរាប់ឧស្សហកម្មផលិតស្បែកជើង ច្រើនជាងការចំណាយសំរាប់ឧស្សហកម្មកាត់ដេរ។ បើសិនជាប្រើប្រាស់សំភារៈបរិក្ខារថ្មីសុទ្ធទាំងអស់ ការចំណាយអាចកើនឡើងចំនួន ៣ ដង ពោលគឺរហូតដល់ ១.៥ លានដុល្លារអាមេរិក។ ការចំណាយសំរាប់បង្កើតរោងចក្រផលិតស្បែកជើងកីឡា អាចអស់ប្រហែល ៨០% នៃរោងចក្រផលិតស្បែកជើងស្បែកទូទៅ។

ការផលិតស្បែកជើងគឺជាការផលិតដែលមានច្រើនផ្នែក និងប្រើប្រាស់សំភារៈផលិតកម្មច្រើនមុខ មានន័យថាការផលិតស្បែកជើង នឹងនាំមកនូវខ្សែសង្វាក់ផលិតកម្មច្រើននៅក្នុងរោងចក្រនីមួយៗ។ គ្រាន់តែផ្នែកខាងលើនៃស្បែកជីងរួមមានខ្សែស្បែកកែច្នៃ និងស្បែកធម្មជាតិ។ ប្រហាក់ប្រហែលគ្នានេះដែរ គេត្រូវបំលែងស្បែកសត្វអោយទៅជាស្បែកជ្រលក់ពណ៌ និងដំណើរការផ្សេងៗទៀត មុននឹងគេអាចយកទៅដេរជាស្បែកជើងបាន។ មានផ្នែកផ្សេងទៀតរបស់ស្បែកជើង (ដូចជារន្ធសំរាប់ដោតខ្សែ ខ្សែ និងទ្រនាប់ខាងក្នុងជាដើម) ដែលផ្នែកនីមួយៗនេះ ទាមទារនូវដំណើរការផលិតខុសៗគ្នា។ សំភារៈសំរាប់ផលិតទ្រនាប់ រួមមានស្បែក ជ័រ និងប្លាស្ទិក (PVA ។ល។) ទាមទារនូវដំណើរការផលិតច្រើនយ៉ាងដែលរួមបញ្ចូលទាំងការដាក់ផ្លាកសញ្ញា ចោះប្រហោង និងការចាក់ពុម្ព។ ការបិតផ្នែកខាងលើ និងទ្រនាប់ ក៏ជាដំណើរការ

មួយដ៏សំខាន់ដែរ។ ដំណើរការដោយប្រើពុម្ពដែក និងប្លាស្ទិក តំរូវការនូវទុនវិនិយោគជាច្រើន ចំណាយលើឧបករណ៏ និងអ្នកបច្ចេកទេសជាន់ខ្ពស់។ ទោះបីជាឧស្សាហកម្មផលិតស្បែកជើង ទាមទារកំលាំងពលកម្មច្រើន ដូចជាឧស្សាហកម្មកាត់ដេរដែរ ក៏ឧស្សាហកម្មផលិតស្បែកជើងមានផលល្អច្រើន ដោយសារឧស្សាហកម្មផលិតស្បែកជើង មានផ្នែកដែលត្រូវផលិតមានច្រើន ត្រូវការសំភារៈច្រើន និងដំណើរការផលិតក៏ច្រើនដែរ។

ក្នុងចំណោមដំណើរការដែលបានលើកឡើងខាងលើ ដំណើរការមួយចំនួនបានប្រែក្លាយទៅជាឧស្សាហកម្មផលិត នៅក្នុងបណ្តាប្រទេសនានា ត្រូវបានយកមកគ្រប់គ្រងដោយផលិតករផលិតស្បែកជើងនៅកម្ពុជា។ តំបន់ ហ្វ៊ូណាននៅប្រទេសចិនជាតំបន់ឧស្សាហកម្មផលិតស្បែកជើង មានសកម្មភាពឧស្សាហកម្មយ៉ាងខ្លាំង។ ឧស្សាហករ ផលិតស្បែកជើងជនជាតិតៃវ៉ាន់ដែលមានទីតាំងនៅហ្វ៊ូណាន ត្រូវបានចូលរួមដោយឧស្សាហកម្មខ្នាតតូច និងមធ្យម ដើម្បីដំណើរការផលិតផ្នែកនានារបស់ស្បែកជើង ក្រុមហ៊ុនរបស់ប្រទេសចិនក៏មានចូលរួមដែរ។ ជាទូទៅឧស្សាហករផលិតស្បែកជើងមួយ មានក្រុមហ៊ុនតូចៗចំនួន ១០ បានសហការគ្នាដើម្បីផលិតផ្នែកផ្សេងៗនៃស្បែកជើង។ នៅប្រទេសកម្ពុជាក៏ដូចនេះដែរ ក្រុមហ៊ុនផលិតតូចៗ អាចទៅបោះទីតាំងនៅជាមួយនឹងក្រុមហ៊ុនផលិតស្បែកជើងធំៗ។ បច្ចុប្បន្ននេះ ឧស្សាហករស្បែកជើងមានចំនួនប្រហែលជា ១០ ប៉ុណ្ណោះ បានបោះទីតាំងនៅក្បែរក្រុមហ៊ុនផលិតតូចៗ (ដែលមានចំនួនប្រហែល ៥ ប៉ុណ្ណោះ)។ ការពិតគឺថាឧស្សាហករផលិតស្បែកជើង ត្រូវបានគេតំរូវអោយកាត់បន្ថយសង្វាក់ផលិតកម្មអតិពលកម្មនៅក្នុងរោងចក្ររបស់ខ្លួន។

## ៧.២ ទស្សនៈវិស័យសំរាប់ឧស្សាហកម្មស្បែកជើងរបស់កម្ពុជា: ការផ្លាស់ប្តូរក្នុងបរិស្ថានអន្តរជាតិ និងសេណារីយោមួយសំរាប់ការអភិវឌ្ឍន៍រយៈពេលមធ្យម និងរយៈពេលវែង

### ៧.២.១ ការផ្លាស់ប្តូរបរិស្ថានវិនិយោគនៃឧស្សាហកម្មស្បែកជើងរបស់កម្ពុជា

ទោះបីជាឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា មានសក្តានុពលពង្រីកឱ្យកាន់តែធំដោយការវិនិយោគបរទេសផ្ទាល់ក៏ដោយ ការធ្វើបាតុកម្មរបស់កម្មករ និងភាពមិនប្រក្រតីនៃការគ្រប់គ្រងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានធ្វើឱ្យក្រុមហ៊ុនបរទេសមួយចំនួនដកថយវិញ និងធ្វើអោយមានភាពនឹងថ្កល់មិនមានការរីកចំរើនខាងវិស័យនេះទេ។ ទោះបីជាយ៉ាងនេះក្តី ក៏មានសញ្ញានៃធ្លាក់ចុះការធ្វើកូដកម្មរបស់កម្មករ ហើយបរិយាកាសនៃការវិនិយោគលើវិស័យឧស្សាហកម្មផលិតស្បែកជើង ហាក់ដូចជាកំពុងតែមានដំណើរការរីកចំរើនទៅមុខវិញជាបណ្តើរៗហើយ។ បរិស្ថាននៅប្រទេសចិន និងប្រទេសវៀតណាមកំពុងតែធ្លាក់ចុះ ដោយបញ្ហាការប្រឆាំងនឹងការចោលកាកសំណល់ និងកំណើនប្រាក់បៀវត្សរ៍ ហើយលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា កំពុងតែកើនឡើងយ៉ាងឆាប់រហ័ស។ សកម្មភាពផលិតកម្មកំពុងតែកើនឡើង។ កត្តាខាងក្រោមនេះ ត្រូវបានគេលើកឡើងថាជាកត្តាអំណោយផលដល់ការអភិវឌ្ឍន៍ លើវិស័យឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា។

*(1) បរិស្ថានវិនិយោគនៅប្រទេសចិន និងវៀតណាម កាន់តែអាក្រក់ទៅ*

ក្រុមហ៊ុនផលិតស្បែកជើងតៃវ៉ាន់ និងកូរ៉េបានបោះទីតាំងនៅប្រទេសចិន។ តំបន់ហ៊ូណាន់ និងហ៊ូដុងមានការរីកចំរើនខាងវិស័យឧស្សាហកម្មផលិតស្បែកជើង ហើយក្លាយជាទីតាំងសំរាប់ផលិតស្បែកជើង។ ទោះបីជាក្រុមហ៊ុនបរទេសទាំងនេះធ្លាប់តែគ្របដណ្តប់លើការនាំចេញ ក៏ក្រុមហ៊ុនក្នុងស្រុករបស់ចិនកំពុងតែក្លាយជាដៃគូប្រកួតប្រជែងក្នុងការនាំចេញដែរ។ លើសពីនេះទៀត ផ្នែកនានារបស់ស្បែកជើង និងសំភារៈបន្ទាប់បន្សំ អាចផលិតបាននៅក្នុងស្រុក ដែលធ្វើអោយការប្រកួតប្រជែងកាន់តែមានភាពស្រួចស្រាវ។ ជាលទ្ធផលនៃការរីកចំរើនផ្នែកសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់ចិន ការចំណាយសំរាប់កម្មករមានការកើនឡើង។ ទន្ទឹមនឹងនេះដែរ ចំណាប់អារម្មណ៍លើវិស័យឧស្សាហកម្ម ដែលផ្អែកលើធនធាន និងចំណេះដឹងបច្ចេកវិទ្យា និងឧស្សាហកម្មយានយន្តបានធ្វើអោយការរើសបុគ្គលិក កម្មករ ដែលមានថ្លៃឈ្នួលទាប សំរាប់ឧស្សាហកម្មផលិតស្បែកជើងកាន់តែលំបាក។ នៅក្នុងបរិបទនៃផែនការរយៈពេល មធ្យម និងយូរអង្វែង សំរាប់ការជំរុញវិស័យឧស្សាហកម្ម រដ្ឋាភិបាលចិនមិនបានយកចិត្តទុកដាក់ដល់ឧស្សាហកម្មផលិតស្បែកជើង ដែលទាមទារអោយមានការប្រើប្រាស់កំលាំងពលកម្មធ្ងន់ធ្ងរនោះទេ។ បរិយាកាសវិស័យឧស្សាហកម្ម នៅប្រទេសចិនអាចកាន់តែធ្ងន់ធ្ងរ សំរាប់ក្រុមហ៊ុនតៃវ៉ាន់ និងក្រុមហ៊ុនបរទេសផ្សេងៗទៀត។ ជាការឆ្លើយតប ក្រុមហ៊ុនតៃវ៉ាន់មួយចំនួន បានងាកទៅរកប្រទេសជិតខាងដូចជាប្រទេសវៀតណាមជាដើម។

ក្រុមហ៊ុនតៃវ៉ាន់ និងក្រុមហ៊ុនបរទេសដទៃទៀត បានព្រួយបារម្ភពីវិមជ្ឈការលើសលុបនៃការវិនិយោគនៅប្រទេសចិន។ ហេតុដូចនេះ ពួកគេបានបង្ហាញពីការចាប់អារម្មណ៍ក្នុងការបោះទីតាំងនៅប្រទេសវៀតណាម។ នៅប្រទេសវៀតណាម ក្រុមហ៊ុនរបស់រដ្ឋ និងក្រុមហ៊ុនក្នុងស្រុក ផ្តោតការយកចិត្តទុកដាក់លើការផលិតស្បែកជើង ហើយឧស្សាហកម្មនេះកំពុងតែប្រមូលផ្តុំនៅទីក្រុងហូជីមិញ និងទីក្រុងហាណូយ ដោយការវិនិយោគក្នុងស្រុក និងបរទេស ដែលនេះគឺជាការពង្រីកបន្ថែមពីឧស្សាហកម្មកាត់ដេរ។ ប៉ុន្តែការផលិត ត្រូវពឹងផ្អែកលើការនាំចូលវត្ថុធាតុដើមពីប្រទេសចិន និងពីប្រទេសផ្សេងៗទៀត ហើយវត្ថុធាតុដើមដែលអាចរកបាននៅក្នុងស្រុកមានប្រហែលតែ ២០% ប៉ុណ្ណោះ។ នៅដើមឆ្នាំ ២០០៦ ប្រាក់ខែជាអប្បបរិមាសំរាប់កម្មករនៅទីក្រុងមានចំនួន ៦០ ដុល្លារអាមេរិក ដែលធ្វើអោយការប្រកួតប្រជែងក្នុងការនាំចេញមានការលំបាក។ លើសពីនេះទៀត ដូចជានៅប្រទេសចិន ប្រទេសវៀតណាម ត្រូវបានគេចោទប្រកាន់ពីការចោលកាកសំណល់ ដែលសល់ពីការផលិតស្បែកជើងស្បែក សំរាប់ការនាំចេញទៅអឺរ៉ុប។ ដោយមានការកែលំអនៃការវិនិយោគនៅពេលថ្មីៗនេះ ការវិនិយោគផ្ទាល់ពីបរទេសកំពុងតែមានការចាប់អារម្មណ៍លើវិស័យជាច្រើន។ រដ្ឋាភិបាលវៀតណាម កំពុងតែបង្ហាញនិន្នាការរឹងមាំមួយ ដើម្បីសង្កត់ធ្ងន់ទៅលើឧស្សាហកម្ម ដែលប្រើប្រាស់ចំណេះដឹង និងវិស័យអតិហេដ្ឋារចនាសម្ព័ន្ធ (facility-intensive) ដូចជាបច្ចេកវិទ្យាពត៌មាន និងឧស្សាហកម្មយានយន្ត នៅក្នុងការជំរុញឧស្សាហកម្មរបស់ខ្លួន។ វាហាក់ដូចជាមិនមានការរំពឹងទុកថានឹងមានការជំរុញចំពោះឧស្សាហកម្មផលិតស្បែកជើងអតិពលកម្មនោះ

ទេ។

(2) *ការពិន័យលើការលក់ទំនិញក្នុងតម្លៃថោកជាងតម្លៃទីផ្សារ (Anti-Dumping) ចំពោះការនាំចេញ នៃផលិតផលស្បែកជើងស្បែកទៅអឺរ៉ុប*

កម្ពុជា បានទទួលជំនួយអន្តរជាតិសំរាប់ស្តាបនាប្រទេសឡើងវិញ ហើយការនាំចេញផលិតផលស្បែកជើង និងផលិតផលផ្សេងទៀតទៅកាន់ប្រទេសអភិវឌ្ឍន៍ នឹងបន្តមានសិទ្ធទទួលបាននូវការអនុវត្តន៍ប្រព័ន្ធអនុគ្រោះទូទៅនាថ្ងៃអនាគត។ ផ្ទុយទៅវិញប្រទេសចិន និងវៀតណាម ដែលមានការនាំចេញផលិតផលស្បែកជើងប្រកបដោយការប្រកួតប្រជែងខ្ពស់ចំពោះទីផ្សារអឺរ៉ុប ត្រូវបានពិន័យដោយការលក់ទំនិញក្នុងតម្លៃថោកជាងតំម្លៃទីផ្សារក្នុងស្រុក នៃស្បែកជើងស្បែកនាំចេញទៅអឺរ៉ុប ពីខែមេសា ដល់ខែកញ្ញាឆ្នាំ ២០០៦។ ជាពិសេសទៅទៀត ពន្ធគយនាំចូលដែលបញ្ចាទិញនាបច្ចុប្បន្នមានចំនួន ៤% នឹងកើនឡើងដល់ ១៩.៤% សំរាប់ប្រទេសចិន និង ១៦.៨% សំរាប់ប្រទេស វៀតណាម ក្នុងរយៈពេល ៥ខែ គិតដល់ដំណាច់ខែកញ្ញា ឆ្នាំ២០០៦។ ទោះបីជាមានការតម្លើងថ្លៃបែបនេះក្តី ក្រុមហ៊ុនចិន និងវៀតណាម ក៏មិនជួបបញ្ហាក្នុងការប្រកួតប្រជែងដែរ ពីព្រោះប្រភពនៃការបញ្ចាទិញច្រើននៅមានកំរិត។ ទោះជាយ៉ាងនេះក្តី ឧស្សាហករផលិតស្បែកជើងស្បែកមួយចំនួន ដែលមានទីតាំងនៅប្រទេសចិន និងវៀតណាម អាចនឹងផ្លាស់មកកម្ពុជាវិញ ដែលផ្តល់ផលប្រយោជន៍នៃការមិនយកពន្ធនាំចេញ។ ហើយនឹងអាចមានឱកាសច្រើននៃការបោះទីតាំងរបស់ក្រុមហ៊ុនវៀតណាម ក្នុងតំបន់ឧស្សាហកម្ម សំរាប់ការអភិវឌ្ឍន៍តាមព្រំដែរជាមួយកម្ពុជា។

(3) *ការកើនឡើងនៃផលិតកម្មប្រើប្រាស់ធនធានក្រៅ (OUTSOURCE) សំរាប់ក្រុមហ៊ុនជប៉ុន*

ជប៉ុនបានអនុវត្តន៍ទំរង់ការកូតាពន្ធគយចាប់តាំងពីឆ្នាំ ១៩៨៦ សំរាប់ការនាំចូលស្បែកជើងស្បែក។ កូតាទី១ ត្រូវកំណត់សំរាប់ស្បែកជើងចំនួន ១២ លានគូរ ដែលតំរូវអោយបង់ពន្ធចំនួន ២១.៦%។ សំរាប់កូតាទី២ ច្បាប់បានកំណត់អោយបង់ពន្ធចំនួន ៣០% ឬ ៤,៣០០ យេន ដោយយកមួយណាក៏បាន ឱ្យតែវាមានតំលៃខ្ពស់ជាង។ សំរាប់ការផលិតស្បែកជើងផ្សេងទៀត ក្រៅពីស្បែកជើងស្បែកពុំមានកូតាសំរាប់ការនាំចូលទេ ប៉ុន្តែឧបសគ្គនៃការនាំចូល ក៏ខ្ពស់គួរសមដែរ (ពន្ធនាំចូលចំនួន ៨%)។ ទោះបីជាពន្ធនាំចូលខ្ពស់ក៏ដោយ ការផលិតដោយប្រើធនធានក្រៅ កំពុងតែកើនឡើងក្នុងបណ្តាក្រុមហ៊ុនជប៉ុន ហើយនិន្នាការនេះឆ្លុះបញ្ចាំងតាមរយៈការនាំចូលស្បែកជើងកីឡា កាន់តែច្រើនឡើងៗមកពីប្រទេសចិន។ នៅក្នុងស្ថានភាពបែបនេះ ការនាំចូលពីប្រទេសដែលមានឋានៈជាប្រទេសទទួលបានការអនុគ្រោះច្រើនជាងគេបង្អស់ (ដូចជាកម្ពុជា ភូមា និងឡាវ) ត្រូវបានគេលើកលែងពីការបង់ពន្ធ ដោយសារតែប្រព័ន្ធអនុគ្រោះជាទូទៅ (GSP)។ ការនាំចូលស្បែកជើងស្បែកពីកម្ពុជា មានការកើនឡើងយ៉ាងឆាប់រហ័សដែលប្រកៀកប្រកើយនឹងការនាំចូលពីប្រទេសចិន ដែលជាដៃគូប្រកួតប្រជែងប៉ុន្តែត្រូវកំណត់ដោយកូតានាំចូល។ វិញ្ញាបនប័ត្រប្រភពដើមរបស់ប្រទេសនីមួយៗ ត្រូវបានគេអនុវត្តដោយតឹងរឹងបំផុត ប៉ុន្តែបច្ចុប្បន្ន កម្ពុជា អាចឆ្លើយតបទៅនឹងការតំរូវនានា ហើយការនាំចេញទៅជប៉ុន កំពុងតែកើនឡើង។

**រូបទី ៧-២-១ និន្នាការនាំចូលស្បែកជើងស្បែកសត្វជប៉ុននៅត្រីមាសទី១ និងទី២**

(TQ2)




(TQ1+TQ2)




Source: MOF in Japan

ការវិនិយោគបរទេស ដោយឧស្សាហកម្មផលិតស្បែកជើងរបស់ជប៉ុននៅមានការកំណត់ ប៉ុន្តែផលិតកម្មដែលប្រើធនធានក្រៅ (ការផលិតរួចផ្ញើរទៅអោយ) ទៅអោយក្រុមហ៊ុនតៃវ៉ាន់នៅកម្ពុជាអាចនឹងត្រូវពង្រីកទៅថ្ងៃអនាគត។ ការចំណាយលើការផលិតនៅខាងក្រៅក្នុងប្រទេសចិនមានការកើនឡើងជាបន្តបន្ទាប់ ហើយប្រទេសកម្ពុជា មានតំលៃអាចប្រកួតប្រជែងបានសំរាប់ស្បែកជើងស្បែក ដែលជាផលិតផលមានការតឹងរឹងក្នុងការ នាំចូលទៅកាន់ប្រទេសជប៉ុន ដោយសារប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដ៏រាបណាកម្ពុជានៅតែត្រូវបានគេចាត់ទុកថាជាប្រទេសដែលមានសិទ្ធិក្នុងការផលិត។ តាមពិតទៅក្រុមហ៊ុនជប៉ុនចំនួន ១០ រួមបញ្ចូលទាំងក្រុមហ៊ុនផលិតស្បែកជើងធំៗ ក្រុមហ៊ុនពាណិជ្ជកម្ម និងបណ្តាញចែកចាយ សុទ្ធតែជាក្រុមហ៊ុនដែលផ្តល់សិទ្ធិផលិតទៅអោយក្រុមហ៊ុនតៃវ៉ាន់ ដែលមានទីតាំងនៅកម្ពុជា (ក្រុមហ៊ុន New Star Shoes និងក្រុមហ៊ុន Chain Hwey Shoes)។ ចំនួននៃការនាំចេញពីកម្ពុជាទៅកាន់ប្រទេសជប៉ុន កំពុងតែមានការកើនឡើង។ ប្រទេសចិននៅតែនាំមុខក្នុងការនាំផលិតស្បែកជើងនាំចូលប្រទេសជប៉ុន ប៉ុន្តែកម្ពុជាកំពុងតែប្រកួតប្រជែងជាមួយចិន ជាពិសេសផលិតផលស្បែកជើងស្បែក។

### ៧.២.២ ជំហររបស់ការវិនិយោគបរទេសផ្ទាល់នៃកម្ពុជាក្នុងឧស្សាហកម្មស្បែកជើង

ក្រុមហ៊ុនផលិតស្បែកជើងរបស់ចិន កូរ៉េ និងជប៉ុន មានចំណែកយ៉ាងធំនៅក្នុងទីផ្សារនៃឧស្សហកម្មផលិតស្បែកជើងកំរិតទាប និងមធ្យម នៅក្នុងសហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក និងជប៉ុន។ ក្រុមហ៊ុនអាស៊ីទាំងនេះ បានមកបោះទីតាំងរោងចក្រនៅក្នុងប្រទេសចិន ដែលជាកន្លែងគេអាចទាក់ទាញអ្នកបញ្ជាទិញមកពីប្រទេសអភិវឌ្ឍន៍ ជ្រើសរើសបានពលកម្មដែលមានតម្លៃថោក និងងាយស្រួលក្នុងការធ្វើលទ្ធកម្មនូវផ្នែកនានារបស់ស្បែកជើង និងសំភារៈបន្ទាប់បន្សំ។ ប៉ុន្តែថ្មីៗនេះមានក្រុមហ៊ុនមួយចំនួន បានធ្វើការផ្ទេរសង្វាក់ផលិតកម្មមកប្រទេសជិតខាងវិញ ដូចជាប្រទេសវៀតណាម ដើម្បីគេចចេញពីហានិភ័យនៃការប្រមូលផ្តុំច្រើនលើសលុបនៅប្រទេសចិន ព្រមទាំងការពិន័យចំពោះ Anti-Dumping ដោយសហគមន៍អឺរ៉ុប។ ការផ្គត់ផ្គង់ស្បែកជើងកំរិតទាប និងមធ្យមគ្រប់ប្រភេទ (ដូចជា ស្បែកជើងស្បែក ស្បែកជើងកីឡា និងស្បែកជើង

មានទ្រនាប់គ្រប់ប្រភេទ) ទៅប្រទេសអភិវឌ្ឍន៍ នឹងនៅតែបន្តរហូតជាពិសេសការនាំចេញពីប្រទេសចិន និងបណ្តាប្រទេសអាស៊ីដទៃទៀត។ តំលៃផលិតផលស្បែកជើងនៅក្នុងប្រទេស ចិនមានការកើនឡើង ស្របពេលជាមួយដែលសេដ្ឋកិច្ចមានការរីកចំរើន ដែលអាចធ្វើអោយផលិតកម្មស្បែកជើងនៅ ប្រទេសចិននឹងងាកទៅរកប្រទេសផ្សេងៗទៀត ដែលមានចំណូលទាប ដូចជាប្រទេសកម្ពុជា និងវៀតណាម ។

**តារាង ៧-២-១ ការព្យាករណ៍នៃការនាំចូលនូវផលិតផលស្បែកជើងពីតំបន់អាស៊ាន និងចិនក្នុងទីផ្សារជឿនលឿន**

(Billion US$, %)

| | | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2010 | 2015 | 2020 |
|---|---|---|---|---|---|---|---|---|---|---|
| Country | US | 15.0 | 15.9 | 17.0 | 17.8 | 18.8 | 20.1 | 27.4 | 34.4 | 43.3 |
| | EU | 16.7 | 17.6 | 19.3 | 22.8 | 26.2 | 30.0 | 41.0 | 52.0 | 63.0 |
| | Japan | 2.8 | 2.8 | 2.7 | 2.9 | 3.0 | 3.2 | 3.6 | 4.2 | 5.0 |
| Type | Leather footwear | 21.4 | 22.4 | 23.9 | 26.5 | 29.1 | 32.5 | 44.0 | 55.0 | 68.0 |
| | Other footwear | 13.1 | 14.0 | 15.2 | 17.0 | 18.9 | 20.8 | 28.0 | 35.6 | 43.3 |
| Total | | 34.5 | 36.4 | 39.1 | 43.5 | 48.0 | 53.3 | 72.0 | 90.6 | 111.3 |
| | Ratio of import from ASEAN +China in case of the whole import | 52.6 | 52.1 | 51.4 | 50.6 | 50.9 | 50.3 | 53.2 | 57.3 | 63.2 |

Source: JICA Study Team (Forecast based on United Nations Statistics Division, Commodity Trade Statistics)

**(2) សេណារីយ៉ូសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា**

***(i) រយៈពេលខ្លី (ដល់ឆ្នាំ2010)***

ក្រុមហ៊ុន (ភាគច្រើនជារបស់តៃវ៉ាន់) មានទីតាំងនៅប្រទេសចិន និងវៀតណាម នឹងផ្លាស់មកកម្ពុជាដើម្បីគេចចេញពីការផាកពិន័យចំពោះ Anti-Dumping ដែលនៅតែបន្តចំពោះការនាំចេញផលិតផលស្បែកជើងស្បែកទៅកាន់ទីផ្សារអឺរ៉ុប ។

ទាក់ទងនឹងការប្រគល់សិទ្ធិឱ្យផលិត ក្រុមហ៊ុនផលិតស្បែកជើងរបស់ជប៉ុន អាចផ្លាស់ពីប្រទេសចិន (ដែលការនាំចេញទៅជប៉ុន គឺស្ថិតក្រោមការត្រួតពិនិត្យ) ទៅកម្ពុជាវិញ (រោងចក្រតៃវ៉ាន់) ដែលការនាំចេញ បានទទួលនូវប្រព្រឹត្តិកម្មប្រព័ន្ធអនុគ្រោះទូទៅ ។

ជាលទ្ធផល ការនាំចេញស្បែកជើងស្បែក ដោយក្រុមហ៊ុនបរទេស (ក្រុមហ៊ុនតៃវ៉ាន់ជាពិសេស) នៅកម្ពុជា ទៅកាន់សហគមន៍អឺរ៉ុប និងប្រទេសជប៉ុន មានការកើនឡើងជាលំដាប់ ។

***(ii) រយៈពេលមធ្យម (ពីឆ្នាំ ២០១០-២០១៥)***

បច្ចុប្បន្ននេះ ទីតាំងនៃក្រុមហ៊ុនផលិតស្បែកជើងមកពីតៃវ៉ាន់ និងប្រទេសផ្សេងៗទៀត ត្រូវបានផលិតផ្នែកនានារបស់ស្បែកជើង និងសំភារៈបន្ទាប់បន្សំសំរាប់ផលិតស្បែកជើងខ្លួនឯង ប៉ុន្តែមាននិន្នាការនៃការបន្តកិច្ចសន្យាទៅឱ្យក្រុមហ៊ុនបរទេស (ផលិតសំភារៈបន្ទាប់បន្សំសំរាប់យកទៅផលិតស្បែកជើង) ដោយការស្នើសុំរបស់ក្រុមហ៊ុនបរទេសទាំងនោះ ។

ដំណើរការផលិតពីដំបូងមានតែស្បែកជើងស្បែកប៉ុណ្ណោះ ដែលស្បែកជើងបែបនេះមានលទ្ធភាពក្នុងការប្រកួតប្រជែងនៅទីផ្សារអឺរ៉ុប និងជប៉ុន។ ដោយមានការរីកចំរើនខាងបច្ចេកវិទ្យា និងតំលៃប្រកួតប្រជែងក្នុងរយៈពេលមធ្យម

កម្ពុជា នឹងទទួលបាននូវឧត្តមភាពដែលចាំបាច់សំរាប់ការនាំចេញផលិតផលស្បែកជើង ដែលធ្វើពីស្បែកធម្មជាតិ និងស្បែកកែច្នៃ ព្រមទាំងសំភារៈបន្ទាប់បន្សំសំរាប់ផលិតផ្សេងៗជាច្រើនទៀត។

***(iii) រយៈពេលវែង (២០១៥-២០២០)***

ការកើនឡើងនៃឧស្សាហកម្មផលិតស្បែកជើងនៅប្រទេសចិននិងវៀតណាម ធ្វើអោយមានការធ្លាក់ចុះនូវតំលៃប្រកួតប្រជែង ជាពិសេសនៅពេលដែលសេដ្ឋកិច្ចមានការរីកចំរើន។ ក្រុមហ៊ុនតៃវ៉ាន់ និងក្រុមហ៊ុនមកពីប្រទេសផ្សេងៗទៀតបានងាកចេញទៅរកបណ្តាប្រទេសផ្សេងៗ ដូចជាប្រទេសកម្ពុជា ដែលមានតំលៃបៀវត្សរ៍ពលកម្មថោកជាងជាដើម។ ការបោះទីតាំងរបស់ក្រុមហ៊ុនបរទេស អាស្រ័យដោយការរីកចំរើនផ្នែកបច្ចេកវិទ្យានៅកម្ពុជាផង និងការពង្រីកកាលានុវត្តន៍ភាពនៃការនាំចេញផង។ ជាការឆ្លើយតប រោងចក្រដើមមួយចំនួននៅកម្ពុជាបានប្រែក្លាយទៅជាអ្នកផលិតនូវផ្នែកនានារបស់ស្បែកជើង និងសំភារៈបន្ទាប់បន្សំសំរាប់ផលិតស្បែកជើងវិញ។

**(3) ទស្សនវិស័យសំរាប់ចំណែកផ្គត់ផ្គង់នៅក្នុងឧស្សាហកម្មស្បែកជើងរបស់កម្ពុជា**

បច្ចុប្បន្ននេះ ចំណែករបស់កម្ពុជានៅក្នុងទីផ្សារអន្តរជាតិ សំរាប់ការនាំចេញផលិតផលស្បែកជើងមានតែ 0.១% ប៉ុណ្ណោះ។ ស្ថានភាពនេះ នឹងមិនមានការប្រែប្រួលប៉ុន្មានទេ ដរាបណាប្រទេសចិននៅតែជាប្រទេសដ៏ធំ ក្នុងការនាំចេញផលិតផលស្បែកជើង។ ប៉ុន្តែឧស្សាហកម្មផលិតស្បែកជើងនៅកម្ពុជា អាចកំណត់ទិសដៅនាំចេញ អោយបាន 0.៤% នៅឆ្នាំ ២០២០ ដោយផ្អែកលើសេណារីយ៉ូដែលបានរៀបរាប់ខាងលើសំរាប់ការអភិវឌ្ឍន៍។ ដោយពិចារណាពីផលចំណេញដែលអាចបានមកពីការវិនិយោគនៅកម្ពុជា ការកំណត់គោលដៅត្រឹម 0.៤% ជាគោលដៅដែលពិតជាអាចសំរេចបាន។ នៅក្នុងផ្នែកនៃការផលិតស្បែកជើងកីឡាវិញ វាជាការលំបាកសំរាប់កម្ពុជាដែលត្រូវធានាអោយបាននូវតំលៃប្រកួតប្រជែងជាមួយប្រទេសចិន។ ចំណែកស្បែកជើងស្បែកវិញ កម្ពុជាបានផ្តល់នូវអត្ថប្រយោជន៍ច្រើនដល់អ្នកវិនិយោគ ដូចជាការរួចខ្លួនពីការត្រួតពិនិត្យលើការនាំចូលទៅកាន់ប្រទេសអភិវឌ្ឍន៍ ដែលស្ថានភាពបែបនេះ អាចជួយអោយកម្ពុជាមានចំណែកធំនៅលើទីផ្សារអន្តរជាតិ។

**រូបទី ៧-២-២ ការនាំចូលផលិតផលស្បែកជើងពីប្រទេសអាស៊ាន/ចិន ក្នុងទីផ្សារជប៉ុន/ស.រ.អ/អឺរ៉ុប និងទស្សនវិស័យនៃចំណែករបស់ការផ្គត់ផ្គង់របស់កម្ពុជា**




Source: JICA Study Team (forecast based on United Nations Statistics Division, Commodity Trade Statistics)

### (4) ការប៉ាន់ស្មានមាត្រដ្ឋាននៃការវិនិយោគបរទេសផ្ទាល់ និងផលប៉ះពាល់សេដ្ឋកិច្ច

ដោយសន្មត់ថា កម្ពុជានឹងសំរេចបាននូវចំណុចគោលដៅខាងលើ នៅក្នុងឧស្សាហកម្មផលិតស្បែកជើងសកល ដូចនេះ ប្រាក់ចំណូលដែលបានមកពីការនាំចេញផលិតផលស្បែកជើងនឹងកើនឡើងដល់ ៤២០ លានដុល្លារអាមេរិក នៅឆ្នាំ ២០២០។ ចំនួននេះ គឺស្មើនឹង ២០% នៃការនាំចេញផលិតផលសំលៀកបំពាក់នៅពេលបច្ចុប្បន្ន។ គិតត្រឹម ឆ្នាំ២០២០ ការវិនិយោគផ្ទាល់ពីបរទេសអាចនឹងមានរហូតដល់ ១០០ លានដុល្លារអាមេរិក ហើយរួមមានក្រុមហ៊ុន ប្រហែល ១០០ នឹងមកបោះទីតាំងនៅកម្ពុជា និងមានបុគ្គលិកចំនួន ១៥០,០០០ នាក់បំរើការងារ។

**តារាង ៧-២-២ ការព្យាករណ៍ការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មផលិតស្បែកជើង និងផលប៉ះពាល់ធំទៅៗ**

| | 2006 | 2010 | 2015 | 2020 |
|---|---|---|---|---|
| Number of foreign firms | 12 | 30 | 50 | 100 |
| Number of line | 20 | 60 | 100 | 200 |
| Cumulative FDI ( million US$ ) | 10 | 30 | 50 | 100 |
| Employee ( 1000persons ) | 20 | 50 | 80 | 150 |
| Export ( million US$ ) | 50 | 120 | 210 | 420 |
| Global share ( % ) | 0.09 | 0.16 | 0.23 | 0.38 |

Source: JICA Study Team

## ៧.៣ ការវាយតំលៃ និងទស្សនវិស័យនៃភាពប្រជែងឈ្នះជាអន្តរជាតិ នៃឧស្សាហកម្មផលិតស្បែកជើងរបស់កម្ពុជា

### ៧.៣.១ ការវិភាគថ្លៃដើមផលិតកម្ម

បណ្តាក្រុមហ៊ុនតៃវ៉ាន់ដែលបានបោះទីតាំងនៅកម្ពុជា ដើម្បីផលិតស្បែកជើងស្បែក មានការចំណាយខ្ពស់លើសំភារៈបន្ទាប់បន្សំ ដែលតាមការប៉ាន់ប្រមាណប្រហែលជា ៧០-៨០% នៃការចំណាយសរុប ជាមួយនេះការចំណាយលើបុគ្គលិកកម្មករមានចំនួន ១០-២០% និងការចំណាយផ្សេងៗ (ដូចជា ការរំលោះ របស់របរប្រើប្រាស់ និងបញ្ហាឯកសារផ្សេងៗ) មានចំនួនប្រហែលជា ១០-២០% ទៀត។ ការចំណាយលើបុគ្គលិកកម្មករក្នុងឧស្សាហកម្មផលិតស្បែកជើង មានលក្ខណៈខ្ពស់ជាងការចំណាយលើសំភារៈបរិក្ខារបន្សំ នៅក្នុងឧស្សាហកម្មផលិតសំភារៈអគ្គិសនី ដូចនេះទាំងឧស្សាហកម្មប្រើប្រាស់កំលាំងពលកម្មដោយផ្ទាល់ និងឧស្សាហកម្មដែលប្រើប្រាស់សំភារៈបរិក្ខារបន្សំជាមូលដ្ឋាននោះ អាចចាត់ទុកថាជាឧស្សាហកម្មដែលចំណាយច្រើនជាងគេ ហើយការចំណាយលើបុគ្គលិកកម្មករមិនខ្ពស់ខ្លាំងប៉ុន្មាននោះទេ។ សំភារៈបរិក្ខារបន្សំភាគច្រើនដែលត្រូវប្រើប្រាស់សំរាប់ផលិតកម្មស្បែកជើងគឺផលិតនៅប្រទេសចិន ហើយសំភារៈបរិក្ខារទាំងនោះគេគិតតំលៃជាសំរាប់ៗតែម្តង។ គ្រឿងឧបករណ៍ទូទៅដែលប្រើប្រាស់ក្នុងផលិតកម្ម រួមមានម៉ាស៊ីនដេរ និងឧបករណ៍ដទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលនេះ ឧបករណ៍ទាំងនេះមិនត្រូវការប្រើប្រាស់ថាមពលអគ្គិសនីច្រើននោះទេ។ កត្តាសំខាន់ ដែលធ្វើឱ្យមានការឡើងចុះតំលៃដើម គឺអាស្រ័យលើការចំណាយលើបុគ្គលិកកម្មករ ទោះបីការចំណាយនោះមិនមានលក្ខណៈច្រើនក៏ដោយ។ បណ្តាក្រុមហ៊ុនផលិតស្បែកជើងបានងាកទៅរកការធ្វើផលិតកម្មនៅក្នុងបរិយាកាសវិនិយោគ ដែលផ្តល់មកនូវតំលៃពលកម្មថោកសមរម្យដែលអាចទទួលយកបាន។

តំលៃពលកម្មធម្មតានៅក្នុងប្រទេសកម្ពុជាទាបជាងនៅក្នុងប្រទេសចិន ដែលធ្វើអោយឧស្សាហកម្មផលិតស្បែកជើងមានច្រើននៅកម្ពុជា ឯនៅប្រទេសវៀតណាមវិញ ថ្មីៗនេះផលិតកម្មស្បែកជើងក៏មានការកើនឡើងច្រើននោះដែរ។ ទោះបីជាយ៉ាងនេះក្តី កម្ពុជាមិនត្រូវបានគេចាត់ទុកថាជាប្រទេសដែលផ្តល់នូវការប្រកួតប្រជែង សំរាប់ឧស្សាហកម្មផលិតស្បែកជើង ច្រើនជាងបណ្តាលប្រទេសផ្សេងៗនោះទេ បញ្ហាសំខាន់ស្ថិតនៅត្រង់ថា កម្ពុជានាំចូលវត្ថុធាតុដើមទាំងស្រុង មានបញ្ហាលើការងារឯកសារផ្សេងៗ លទ្ធភាពផលិតកម្មខាងក្រៅនៅមានកំរិត និងសមត្ថភាពកម្មករនៅទាប។ នៅចំពោះមុខនេះ ភាពប្រជែងឈ្នះរបស់កម្ពុជាគួរតែកំណត់យកនូវការផលិតផ្នែកណាមួយនៃស្បែកជើង ដែលអាចមាឱកាស សំរាប់ផ្គត់ផ្គង់ទៅសហគមន៍អឺរ៉ុប និងជប៉ុន។ បញ្ហាថាតើកម្ពុជាអាចមានលទ្ធភាពធ្វើជាមូលដ្ឋានរឹងមាំ សំរាប់ឧស្សាហកម្ម ផលិតស្បែកជើងទាំងស្រុងបានដែរឬទេ តាមរយៈការផលិតផ្នែកណាមួយនៃស្បែកជើង ដែលនឹងមានឱកាសប្រកួតប្រជែង ហើយអាចក្លាយទៅជាតំបន់ប្រកួតប្រជែងផលិតផលស្បែកជើងគ្រប់ប្រភេទយ៉ាងធំទៅថ្ងៃអនាគត។

### ៧.៣.២ គំរូធុរៈកិច្ចក្នុងឧស្សាហកម្មស្បែកជើងរបស់កម្ពុជា

ដោយសារបញ្ហាប្រឆាំងការលក់ទំនិញថោកជាងថ្លៃដើមជាមួយអឺរ៉ុប ក្រុមហ៊ុនតៃវ៉ាន់ចំនួន ដែលបានបោះទីតាំងនៅចិន និងវៀតណាម សង្ឃឹមថានឹងប្តូរទីតាំងមកកម្ពុជាវិញ។ ក្រុមហ៊ុនតៃវ៉ានជាច្រើនអាចបោះទីតាំងនៅកម្ពុជា ផងដែរ។ សំរាប់ការបោះទីតាំង នៅកម្ពុជា ការពិន័យចំពោះបញ្ហាប្រឆាំងការលក់ទំនិញថោកជាងថ្លៃដើមលើប្រទេសចិន និងវៀតណាម លែងជាបញ្ហាទៀតហើយ ប្រការកាន់តែអាក្រក់ទៅនៃបរិស្ថានវិនិយោគត្រូវបានចង្អុលបង្ហាញដោយក្រុមហ៊ុនតៃវ៉ាន់នៅចិន។ កាលានុវត្តន៏ភាពសំរាប់ការវិនិយោគនៅក្នុងឧស្សាហកម្មស្បែកជើងរបស់កម្ពុជា មើលទៅមានសក្តានុពលបំផុត។ ក្រុមហ៊ុនសំខាន់ៗ បានកំពុងវិនិយោគក្នុងផលិតកម្ម នៅកម្ពុជា គឺជាក្រុមហ៊ុនតៃវ៉ាន់ ហើយពួកគេចង់គេចចេញពីហានិភ័យដែលពួកគេកំពុងជួបប្រទះនៅក្នុងការបោះទីតាំងនៅចិន (Dongguan).

ក្រៅពីក្រុមហ៊ុនតៃវ៉ាន់ មានសក្តានុពលមួយសំរាប់ការវិនិយោគក្នុងផលិតកម្មនេះនៅកម្ពុជា ដោយក្រុមហ៊ុន មកពី កូរ៉េ ហុងកុង និងចិន ដែលបានបោះទីតាំងនៅប្រទេសចិន និងវៀតណាម ដោយសារថា ផលប៉ះពាល់នៃវិធានការប្រឆាំងការលក់ថ្លៃថោកជាងតម្លៃដើម ដែលធ្វើឡើងដោយអឺរ៉ុប។ វិធានការទាំងនេះ អនុវត្តចំពោះតែស្បែកជើងស្បែកប៉ុណ្ណោះ សំរាប់អ្វីដែលកម្ពុជា នាំចេញទៅកាន់ទីផ្សារជប៉ុន ហើយបានទទួលប្រព្រឹត្តកម្មជាភាពអនុគ្រោះ។ នេះ បានស្នើឡើងថា ការវិនិយោគភាគច្រើននៅកម្ពុជា នឹងមកពីក្រុមហ៊ុនតៃវ៉ានក្នុងផលិតកម្មស្បែកជើងផលិតពីស្បែក។ ផលិតកម្មសំរេច (ជាមួយ នឹងការកែច្នៃក្នុងស្រុកនៃផ្នែករបស់ស្បែកជើង) គួរតែបន្តគ្របដណ្តប់លើគ្រប់ពេលវេលា ប៉ុន្តែមានលទ្ធភាពដ៏ល្អមួយនៃការបោះ ទីតាំងដោយអ្នកស៊ីឈ្នួលជាអ្នកស្ថាបនារោងចក្រស្បែកជើង។ ក្រុមហ៊ុនតៃវ៉ាន់ បានស្នើសុំក្រុមហ៊ុនដែលកំពុងធ្វើការផ្តល់កិច្ចសន្យាកែច្នៃនៅខាងក្រៅសំរាប់ពួកគេដើម្បីបោះទីតាំងនៅប្រទេសចិន ដែលអភិវឌ្ឍន៍ផលិតកម្មរបស់ពួកគេនៅទីនោះ។ គំរូប្រភេទនេះ អាចរំពឹងថានឹងកើតមាននៅកម្ពុជាផងដែរនាពេលអនាគត។

**តារាង ៧-៣-១ កម្រិតនៃទស្សនៈអនាគតសំរាប់ការវិនិយោគនៅកម្ពុជា ដោយក្រុមហ៊ុនស្បែកជើង**

| Investing firms | Siting Possibility | Pattern of production | Siting factors | Type of footwear |
|---|---|---|---|---|
| Taiwanese firms | Quite high | Investment for construction of production lines | • Increase in costs in China<br>• Problem with anti-dumping penalties in the EU | Mainly leather shoes |
| Korean firms | Low | Investment for construction of production lines | • Increase in costs in China<br>• - Problem with anti-dumping penalties in the EU | Mainly leather shoes |
| Chinese firms | High | Investment for construction of production lines | • Increase in costs in China<br>• Problem with anti-dumping penalties in the EU | Leather shoes |
| Vietnamese firms | Low | Investment for construction of production lines | • Problem with anti-dumping penalties in the EU | Leather shoes |
| Japanese firms | Low | Mainly consignment of production to Taiwanese firms, etc. | • Controls on import in Japan (advantages of import from Cambodia) | Leather shoes |

Source: JICA Study Team

ទុកជាអ្នកផលិតស្បែកជើងជប៉ុនធំៗ ក៏ខ្វះខាតបទពិសោធន៍សំរាប់ការវិនិយោគ ក៏ដូចជាធុរកិច្ចសកលដែរ (ការលក់របស់ពួកគេត្រូវបានកំរិតព្រំដែនទាំងស្រុងចំពោះទីផ្សារជប៉ុន) សកម្មភាពក្រៅប្រទេសរបស់ពួកគេ គឺដូចជាកំពុងបន្តផ្តោតលើការប្រើប្រាស់ធនធានខាងក្រៅ ការប្រគល់កិច្ចសន្យាផលិតកម្មទៅឱ្យក្រុមហ៊ុននៅប្រទេសចិន ដែលមានការអភិវឌ្ឍន៍ខ្ពស់ នៃឧស្សាហកម្មស្បែកជើង និងភាពប្រជែងឈ្នះនៃថ្លៃដើម។ ដូចការវិនិយោគបរទេសផ្ទាល់ដែរ ប៉ុន្តែ ការប្រគល់កិច្ចសន្យាផលិតអាចប្រឈមនឹងហានិភ័យ ដែលទាក់ទិនដល់ការប្រមូលផ្តុំនៅក្នុងប្រទេសចិន សូម្បីតែកំរិតតូចៗក៏ដោយ។ កត្តាគួរឱ្យពិចារណា ដូចជាអត្ថិភាពនៃអ្នកទទួលកិច្ចសន្យា ធនធាននៃបំណែក និងសម្ភារៈ និងភាពប្រជែងឈ្នះនៃតម្លៃដើម ក៏ដូចជាគោលនយោបាយរបស់ជប៉ុន ស្តីពីការនាំចូល ក្រុមហ៊ុនជប៉ុន នឹងគ្មានចំណេញពីការបោះទីតាំងនៅក្នុងប្រទេសផ្សេងក្រៅពីប្រទេសចិននោះទេ សំរាប់ផលិតផលស្បែកជើងកីឡា និងស្បែកជើងហាត់កីឡា។ ម្យ៉ាងវិញទៀត សំរាប់ស្បែកជើងធ្វើពីស្បែក នឹងមានឧត្តមភាពមួយក្នុងការបោះទីតាំងនៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ារ និងបង់ក្លាដេស ដែលអាចទទួលបានភាពអនុគ្រោះសំរាប់ពន្ធគយនាំចូល។ ទោះបីការត្រួតពិនិត្យលើការនាំចូលពីប្រទេសចិន អាចប្រែប្រួលក្នុងរយៈពេលវែង ឧត្តមភាពដែលយល់ស្របចំពោះកម្ពុជា និងប្រទេសអាស៊ានថ្មីផ្សេងទៀត គួរតែរក្សាកន្លែងសំរាប់ភាពអនុគ្រោះនេះមួយរយៈ។

ក្រុមហ៊ុនជប៉ុន បានគិតពីក្រុមហ៊ុនតៃវ៉ាន់ ដែលបោះទីតាំងនៅកម្ពុជា ថាជាទីដៅសំរាប់ផ្តល់កិច្ចសន្យានៃផលិតកម្ម

ស្បែកជើងផលិតពីស្បែក។ ទោះបី ការបញ្ជាទិញតិចតួចក៏ដោយ ក៏ក្រុមហ៊ុនតៃវ៉ាន សំឡឹងឃើញនូវទស្សនៈអនាគតក្នុងការទទួលយកកិច្ចសន្យាពីជប៉ុនថា ជាឱកាសដើម្បីបញ្ចប់ទំនាក់ទំនងដែលបន្តជាហូរហែរមក។ ក្នុងភ្នែករបស់ពួកគេ វាគឺជាកាលានុវត្តន៍ភាពមាស ដើម្បីលើកកំពស់កំរិតជំនាញរបស់ពួកគេតាមរយៈការបញ្ជូនបុគ្គលិកមកកម្ពុជាសំរាប់ណែនាំជាបច្ចេកទេស។ គេ បានលើកយកករណីដែលពិនិត្យឡើងវិញនូវការវិនិយោគផលិតកម្មនៅកម្ពុជា និងប្រទេសអាស៊ានថ្មីក្នុងក្រុមហ៊ុនស្បែកជើងជប៉ុន ជាករណីលើកលែង។

**តារាង ៧-៣-២ ឧទាហរណ៍នៃផែនការធុរៈកិច្ចសំរាប់ឧស្សាហកម្មស្បែកជើងនៅក្នុងការអង្កេតដល់ទីកន្លែង**

| | **M company (Japan)** |
|---|---|
| Object product | Steel-toed shoes |
| Current production style | Production site: only in Japan、production capacity : 6 million pairs per year |
| 0verseas investment plan | ・ Consistent production factory of steel-toed shoes for the Japanese market<br>・ Material procurement: Japan, China, Taiwan, Korea and others |
| Problem on the business | ・ In the footwear industry, steel-toed shoes manufacturing investment is large scale.<br>・ Securing of the workforce which is diligent and low in cost<br>・ Production process is composed of sewing construction, injection molding, and so on. |
| FDI condition | ・ Reliability of the politico-social system<br>・ To attempt investment collection, being short term, or to raise an operating rate, the 3-shift system is indispensable.<br>・ Physical distribution system for parts procurement from a wide range of countries<br>・ Proper cost and moreover the stable power supply |
| Investment possibility in Cambodia | It is during the investigation and reviewing in the investment place in Cambodia, Laos, and Myanmar with the GSP application for export to Japan. The schedule calls for selection of an investment site during the next one or two years. |
| Business plan (3-5 years ) | Investment scale: hundreds of millions of yen, production scale: 10,000 pairs/month, employees : 200 |

Source: JICA Study Team

គំរូធុរកិច្ចអំពីឧស្សាហកម្មស្បែកជើងនៅកម្ពុជា ត្រូវបានបង្ហាញនៅក្នុងរូបភាពខាងក្រោម។ ទុនរបស់តៃវ៉ាន់ ក្លាយទៅជាស្នូលក្នុងបច្ចុប្បន្នភាព ការនាំចេញបំណែកពីប្រទេសចិន វាធ្វើការស្ថាបនាការកែច្នៃ និងនាំចេញទៅអឺរ៉ុប អាមេរិក និងជប៉ុន។ ដូចក្រុមហ៊ុនជប៉ុន ការវិនិយោគភាគហ៊ុនដោយផ្ទាល់ ចូលរួមក្នុងទ្រង់ទ្រាយនៃផលិតកម្មតាមរូបភាពផ្តល់កិច្ចសន្យា។ ក្នុងរយៈពេលវែង គេរំពឹងថានឹងមានការកែច្នៃស្បែកនៅក្នុងស្រុក។

**រូបភាព ៧-៣-១ គំរូធុរៈកិច្ចនៃឧស្សាហកម្មស្បែកជើង (ស្បែក) នៅកម្ពុជា**




Source: JICA Study Team

## ៧.៤ អនុសាសន៍ ដើម្បីជំរុញការវិនិយោគផ្ទាល់ទៅក្នុងឧស្សហកម្មផលិតស្បែកជើង

### ៧.៤.១ គោលនយោបាយសំរាប់ផ្សព្វផ្សាយឧស្សាហកម្មផលិតស្បែកជើង

ឧស្សាហកម្មផលិតស្បែកជើងជាឧស្សាហកម្មដែលប្រើកំលាំងពលកម្ម ប៉ុន្តែជាឧស្សហកម្មដែលមានសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗច្រើនប្រភេទសំរាប់ផលិតស្បែកជើង និងមានខ្សែសង្វាក់ផលិតកម្មស្មុគស្មាញ ជាងឧស្សាហកម្មកាត់ដេរ។ ដោយហេតុផលបែបនេះ វាមានផលច្រើនទាំងអត្រាមានការងារធ្វើការវិនិយោគ បច្ចេកវិទ្យា និងការរកប្រាក់ចំណូលជារូបិយប័ណ្ណអន្តរជាតិ។ រដ្ឋាភិបាលកម្ពុជាគួរតែធ្វើការសិក្សាមួយអោយបានច្បាស់លាស់ស្តីអំពីការប្រែប្រួលនៃបរិស្ថានវិនិយោគលើវិស័យឧស្សាហកម្មផលិតស្បែកជើងនៅប្រទេសចិន វៀតណាម និងជប៉ុន ហើយ ផ្តល់អាទិភាព ខ្ពស់ដល់ឧស្សាហកម្មនេះ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបទេស ដូចជានៅក្នុងឧស្សាហកម្មកាត់ដេរដែរ។ ជាពិសេសទៅទៀត រដ្ឋាភិបាលត្រូវពិចារណាអំពីការផ្តួចផ្តើមគំនិតថ្មីៗ ដើម្បីអោយការលើកកំពស់ ក្នុងវិស័យនេះកាន់តែមានប្រសិទ្ធិភាព ជាពិសេសទាក់ទងនឹងលក្ខខណ្ឌការងារ ការអភិវឌ្ឍន៍ធនធានមនុស្ស និងរចនាសម្ព័ន្ធ ឧស្សាហកម្ម។

ការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិមានសារៈសំខាន់ណាស់ សំរាប់ការពង្រីកឧស្សាហកម្មផលិតផលស្បែកជើង។ កម្ពុជា គួរតែឆក់ឱកាសនៃការបំរែបំរួលនាពេលបច្ចុប្បន្ន នៅក្នុងបរិស្ថានវិនិយោគ ដើម្បីទាក់ទាញក្រុមហ៊ុនអោយមកបោះ

ទីតាំងនៅកម្ពុជា ទាំងក្រុមហ៊ុនផលិតស្បែកជើង និងក្រុមហ៊ុនផលិតសំភារៈបន្ទាប់បន្សំសំរាប់ផលិតស្បែកជើង។ នៅពេលនេះកម្ពុជា មិនទាន់មានលក្ខណៈងាយស្រួលនៅក្នុងការទាក់ទាញក្រុមហ៊ុនផលិតសំភារៈ បន្ទាប់បន្សំនៅឡើយទេ។ ទោះបីជាការផលិតអាស្រ័យលើសំភារៈបន្ទាប់បន្សំនាំចូលទាំងស្រុងក៏ដោយ វត្តមាននៃ ក្រុមហ៊ុនផលិតកម្មដែលមានលិខិតបញ្ជាក់របស់កម្ពុជាថា ជាប្រទេសដែលអាចផលិតសំភារៈបន្ទាប់បន្សំបាន នឹងអាចជួយអោយក្រុមហ៊ុនទាំងនោះទទួលបាននូវប្រព័ន្ធអនុគ្រោះជាទូទៅនៅក្នុងប្រទេសអភិវឌ្ឍន៍ និងធានាបាននូវតំលៃ ប្រកួតប្រជែង។ រដ្ឋាភិបាលត្រូវពិចារណាអំពីវិធានការសមស្រប ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស សំរាប់ផលិតសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើង ដូចជាវិធានការស្តីពីការលើកទឹកចិត្តខ្ពស់ចំពោះ ការវិនិយោគ និងការផ្តល់ទីកន្លែង (ទីកន្លែងប្រមូលផ្តុំនៅតំបន់ឧស្សាហកម្ម)។

### (២) ការរៀបចំសំរាប់អភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេស

ក្នុងការធ្វើបទសម្ភាសជាមួយក្រុមហ៊ុនតៃវ៉ាន់ ផលិតករផលិតស្បែកជើងតៃវ៉ាន់ដែលមានទីតាំងនៅកម្ពុជា បានចាត់ទុកកំរិតជំនាញបច្ចេកទេសរបស់កម្មករកម្ពុជានៅមានកំរិតទាបនៅឡើយ។ ពួកគេបានគិតថាប្រសិទ្ធភាពការងារនៅខ្សោយ ដោយហេតុថាកម្មករទាំងនោះទទួលការអប់រំចំណេះទូទៅមិនបានគ្រប់គ្រាន់ បើធ្វើការប្រៀបធៀបឃើញថាលទ្ធភាព ក្នុងការងារផលិតកម្មរបស់កម្មករខ្មែរ គឺមានតែប្រហែល ៣០%នៃកម្មករចិន និង ៧០%នៃកម្មករ វៀតណាម។ ជាទូទៅគេទទួលស្គាល់ថាកម្មករបានប្រឹងប្រែងអស់ពីសមត្ថភាពរបស់គេ ដើម្បីបំពេញការងារ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថាពួកគេមានការអប់រំតិចតួច និងមិនមានបទពិសោធន៍។ ក្រុមហ៊ុនត្រូវចំណាយពេល ២ ឬ ៣ ខែដើម្បីបណ្តុះបណ្តាលបុគ្គលិកជ្រើសរើសថ្មីក្នុងក្រុមហ៊ុន ប៉ុន្តែពួកគេហាក់ដូចជាមិនមានទិន្នាការធ្វើបែបនេះទេ នៅពេលប៉ុន្មានមកនេះ និងនៅពេលនេះ ក្រុមហ៊ុនទាំងនោះផ្តល់ការបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់នៅនឹងកន្លែង ចំនួន ១ សប្តាហ៍។ ដូចនេះ រដ្ឋាភិបាលត្រូវប្រឹងប្រែងដើម្បីផ្តល់ការអប់រំមូលដ្ឋានអោយបានកាន់តែទូលំទូលាយ ដើម្បីបង្កើនអត្រា និងកំរិតអក្ខរកម្មរបស់ពលរដ្ឋ ងាយស្រួលអោយពួកគេទទួលយកការអប់រំថ្មីពេលបំពេញការងារ។

**តារាង ៧-៤-១ ពត៌មានទូទៅស្តីពី CGTC**

- The GMAC set up a training center in 1999 with assistance from the Japanese METI and the Japan Overseas Development Corporation (JODC).
- The CGTC is housed in the Cambodia Chamber of Commerce and Industry. It has 7 instructors and has graduated an extended total of 2,200.
- Originally, the courses were designed mainly to groom those new hirees regarded as relatively talented to be supervisors in place of Chinese personnel (whose wages are five times as high as those of the Cambodians). There were also courses on quality control and business administration.
- For worker candidates coming from rural areas, courses consist mainly of instruction in basic stitching skills. The personnel take three courses in two months. Many of the graduates take jobs with garment firms. The companies give high marks to the courses, which make it unnecessary for them to start from the basics in their in-house education. An added benefit is that the program eliminates use of the services of sub quality brokers.
- The number of students ranges from 40 to 45 per month. Basically, students pay 5 dollars for food and lodging,

| |
|---|
| but scholarships are available, and students need not pay if the class is premised on hiring.<br>• Drawing on dues from members and financial aid from institutions including the ADB, the GMAC provides 5,000 dollars per month for the operation of the center. |

Source: CGTC, the Garment Industry Human Resource Development Centre, CMAC

ជាការឆ្លើយតបទៅនឹងការពិន័យនៃការចោលកាកសំណល់ ដែលកំហិតដោយសហគមន៍អឺរ៉ុបក្នុងការនាំផលិតផលពីប្រទេសចិន និងវៀតណាម វាជាឱកាសដ៏ល្អសំរាប់ក្រុមហ៊ុនតៃវ៉ាន់មកបោះទីតាំងនៅកម្ពុជា។ ការដែលក្រុមហ៊ុនតៃវ៉ាន់ផ្លាស់ទីតាំងមកកម្ពុជា អាចធ្វើអោយពួកគេបន្ថែមការវិនិយោគពង្រីកខ្សែសង្វាក់ផលិតកម្ម និងបង្កើនបុគ្គលិកបំរើការងារ។ ការផលិតផលស្បែកជើងត្រូវទាក់ទងនឹងបច្ចេកទេសក្នុងការដេរ ការផលិតសំភារៈបន្ទាប់បន្សំនិងផ្នែកផ្សេងៗ សំរាប់ធ្វើបាតស្បែកជើង ការកែច្នៃប្លាស្ទិក និងសំភារៈបន្ទាប់បន្សំឧស្សាហកម្មផ្សេងទៀត។ វាមានផលប៉ះពាល់រំខាន ច្រើនទាក់ទងទៅនឹងការផ្លាស់ប្តូរបច្ចេកវិទ្យា។ ក្រុមហ៊ុនមួយមិនអាចធ្វើការបណ្តុះបណ្តាលបុគ្គលិក អោយបានគ្រប់ជំនាញនោះទេ គេត្រូវសិក្សាពីលទ្ធភាពបណ្តុះបណ្តាលជំនាញទាំងនោះ នៅតាមស្ថាប័នសាធារណៈ។ ឧស្សាហកម្មផលិតស្បែកជើងនៅមិនទាន់បានពង្រីកអោយទូលំទូលាយនោះទេ ដូចនេះលទ្ធភាពនៃ ការបង្កើតស្ថាប័នបណ្តុះបណ្តាលជំនាញ សំរាប់ឧស្សាហកម្មផលិតស្បែកជើង វាជាការលំបាកនៅឡើយសំរាប់កម្ពុជា។ គេត្រូវពង្រឹងសមត្ថភាពឧស្សាហកម្មផលិតស្បែកជើងអោយបានរឹងមាំសិនមុននឹងពិចារណាពីលទ្ធភាពបង្កើតទំនាក់ទំនងជាមួយសមាគមន៍ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ដើម្បីធ្វើជាដៃគូរក្នុងឧស្សាហកម្មកាត់ដេរ។

### (៣) ការបង្កើតសមាគមន៍ឧស្សាហកម្មផលិតស្បែកជើងឡើងវិញ

សមាគមន៍ឧស្សាហកម្មផលិតស្បែកជើងបានលែងដំណើរការដោយសារគ្មានប្រធាន។ សមត្ថភាពរបស់សមាគមន៍មានសារៈសំខាន់ណាស់ ដើម្បីអោយរដ្ឋាភិបាលចាត់វិធានការផ្សេងៗ និងអោយក្រុមហ៊ុនស្បែកជើងលើកជាសំណើរគោលនយោបាយដល់រដ្ឋាភិបាលវិញ។ រដ្ឋាភិបាលត្រូវតែចូលរួមដោយសកម្មក្នុងការបង្កើតសមាគមន៍ឡើងវិញ ដើម្បីអោយវិស័យឧស្សាហកម្មនេះមានការរីកចំរើននៅកម្ពុជា ទោះបីការរីកចំរើនត្រូវពឹងពាក់ស្ទើរតែទាំង ស្រុងលើការវិនិយោគផ្ទាល់ពីបរទេសក៏ដោយ។ ករណីនៅប្រទេសវៀតណាម បង្ហាញថាសកម្មភាពរបស់សមាគមន៍ត្រូវរួមបញ្ចូល ទាំងការរៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រង និងបច្ចេកទេស រៀបចំកម្មវិធីបណ្តុះបណ្តាលសំរាប់អភិវឌ្ឍន៍ធនធានមនុស្ស រៀបចំវេទិកាសំរាប់តាំងពិពណ៌ (ដើម្បីបង្កើនការលក់) និងរៀបចំសន្និសិទថ្នាក់ជាតិ និងអន្តរជាតិ (សំរាប់ការទំនាក់ទំនង និងចំណងសាមគ្គីភាពរវាងបណ្តាក្រុមហ៊ុន រៀបចំសំណើគោលនយោបាយដើម្បីដាក់ជូនរដ្ឋាភិបាល ។ល។)។ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេស គឺជាសកម្មភាពសំខាន់របស់សមាគមន៍នៅក្នុងរយៈពេលវែង។ សំរាប់ពេលនេះ គេត្រូវយកចិត្តទុកដាក់លើកិច្ចសន្យាជាមួយនឹងតំណាងឧស្សាហកម្ម ដើម្បីអភិវឌ្ឍ គោលនយោបាយផ្លូវការក្នុងផ្នែកនានា ដូចជាប្រាក់ខែ វិវាទរវាងពលករ និងបញ្ហាសហជីពផ្សេងៗទៀត ក៏ដូចជាបញ្ហាវិញ្ញាបនប័ត្រផលិតកម្ម និងបញ្ហា

ជាអន្តរជាតិនានានៅជុំវិញប្រព័ន្ធអនុគ្រោះទូទៅ។

**(៤) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន**

នៅពេលក្រុមហ៊ុនបរទេសទទួលការបញ្ជាទិញផលិតផលស្បែកជើងពីអតិថិជនសំខាន់ៗ ដែលផលិតនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ជាទូទៅការចែកចាយត្រូវចំណាយពេលវេលាប្រហែលជា ៤ ខែ។ បញ្ជាក់អោយកាន់តែច្បាស់ គេត្រូវការពេលវេលាចំនួន ៤០-៥០ ថ្ងៃ ចំពោះប្រភពសំភារៈបន្ទាប់បន្សំ (យ៉ាងហោចណាស់ ក៏ ៣០ ថ្ងៃដែរ សំរាប់តែស្បែកមួយមុខ) ៣០ ថ្ងៃដើម្បីដឹកជញ្ជូនសំភារៈបន្ទាប់បន្សំ ១០ ថ្ងៃ សំរាប់ការផលិត និង ៣០ ថ្ងៃសំរាប់ការនាំចេញផលិតផល។ ការចំណាយពេលវេលាទាំងអស់មានពី ១១០-១២០ ថ្ងៃ។ ពេលវេលាដែលត្រូវការជាមុន មិនច្រើនដូចជានៅក្នុងឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិកទេ។ ក្រុមហ៊ុនអាចមានផែនការ ផលិតកម្ម ដោយផ្អែកលើការបញ្ជាទិញពីអតិថិជន ដោយមានកុងតឺន័រសំរាប់នាំចូលសំភារៈបន្ទាប់បន្សំ និងនាំចេញផលិតផលសំរេច។ បណ្តាញផ្គត់ផ្គង់ដែលមានតារាងពេលវេលាច្បាស់លាស់ ក្នុងរយៈពេល ៣-៤ ខែ គឺជាគំរោងពេលវេលា ដែលមានរយៈពេលគ្រប់គ្រាន់។

ការធានាអោយបានត្រឹមត្រូវនូវពេលវេលាដូចដែលបានលើកឡើងខាងលើ ដើម្បីអោយស្របនឹងពេលវេលា ផលិតកម្មទាមទារនូវការរៀបចំឡើងវិញនូវប្រព័ន្ធដឹកជញ្ជូនទំនិញនៅកម្ពុជា ដើម្បីអោយបណ្តាញដឹកជញ្ជូនកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។ ការងារនេះអាចធ្វើទៅបាន អាស្រ័យដោយរថយន្តដឹកទំនិញកាន់តែមានស្ថានភាពល្អប្រសើរនិងរៀបចំ ប្រព័ន្ធផ្លូវដឹកជញ្ជូនពីក្រុងព្រះសីហនុទៅភ្នំពេញអោយបានល្អ និងកសាងបណ្តាញសំរាប់ដឹកជញ្ជូនអន្តរជាតិដោយភ្ជាប់ពីភ្នំពេញ ទៅបាងកក និងហូជីមិញ។ ដោយហេតុថាសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើង ដែលត្រូវយកមកផលិតបាននាំចូលមកពីប្រភពខុសៗគ្នា ហើយទំនិញទាំងនេះត្រូវបានដឹកឆ្លងកាត់ច្រើនប្រទេស ដែលទាមទារអោយមានកំពង់ផែសំរាប់លើកដាក់ មានសំភារៈប្រើប្រាស់គ្រប់គ្រាន់ និងឃ្លាំងស្តុកទំនិញធំៗដូចជាឃ្លាំទំនិញ (Kaohsiung) នៅតៃវ៉ាន់ ហុងកុង និងសិង្ហបូរីជាដើម។

**(៥) ការធ្វើអោយសាមញ្ញនីតិវិធីនាំចេញ-នាំចូល**

ក្រុមហ៊ុនបរទេសដែលមានមូលដ្ឋាននៅកម្ពុជាក្នុងវិស័យឧស្សាហកម្មកាត់ដេរនិងផលិតស្បែកជើងត្រូវចំណាយពេលវេលាដ៏ច្រើនសំរាប់បំពេញសំណុំលិខិតនាំចេញ-នាំចូល និងបានទទួលការអនុញ្ញាតច្បាប់។ ទោះបីជាមានការបង់ប្រាក់ក្រៅក៏សំណុំឯកសារនាំចេញ មិនអាចអនុម័តឱ្យបានទាន់ពេលវេលា(តាមច្បាប់)ដែរ ហើយគេត្រូវការពេលវេលាអស់រហូតមួយសប្តាហ៍ដើម្បីបានអាជ្ញាប័ណ្ណ។ ក្រុមហ៊ុន ត្រូវអត់ធ្មត់ដើម្បីបង់ចំណាយក្រៅ សំរាប់ការអនុញ្ញាតនាំចេញ-នាំចូលដោយរលូន និងអ្នកគ្រប់គ្រងនៃការនាំចេញ និងនាំចូលនៅកំពង់ផែ។ ក្រុមហ៊ុនផលិតស្បែកជើងតៃវ៉ាន់ ដែលបានបោះទីតាំងនៅកម្ពុជារួចហើយ មិនមានបំណងកែលំអស្ថានភាពនេះទេ។ ក្រុមហ៊ុនជប៉ុន ក៏ជួបបញ្ហាបែបនេះនៅតាមបណ្តាប្រទេសនៅអាស៊ានដទៃទៀតផងដែរ ប៉ុន្តែក្រុមហ៊ុនជប៉ុនទាំងនោះបានប្រកាន់យកគោលជំហររឹងប៉ឹង ក្នុងការទប់ស្កាត់ស្ថានភាពខាងលើមិនឱ្យ

កើតមានឡើងតទៅទៀត។ ការប្រតិបត្តិនៃគំរោងគំរូមួយសំរាប់ការធ្វើសមញ្ញកម្មនិតិវិធីនៅកំពង់ផែក្រុងព្រះសីហនុ ត្រូវបានធ្វើកាលពីឆ្នាំកន្លងទៅ។ គំរោងនេះនឹងនាំអោយមានជោគជ័យដើម្បីទាក់ទាញការវិនិយោគថ្មី និងធ្វើអោយដំណើរការបានកាន់តែរលូន សំរាប់ក្រុមហ៊ុនដែលមានទីតាំងនៅកម្ពុជារួចហើយ។ នីតិវិធីនេះ ត្រូវតែអនុវត្តនៅតាមស្ថាប័នផ្សេងទៀត ដើម្បីសំរួលការងារនិងកែតំរូវរាល់ការបំពេញបែបបទដែលមិនត្រឹមត្រូវហើយតែងតំរូវអោយអ្នករកស៊ីបង់ប្រាក់ក្រៅនោះ។

**(៦) ការរៀបចំផែនការមេសំរាប់ឧស្សាហកម្មផលិតស្បែកជើង**

ដើម្បីលើកទឹកចិត្តអោយមានការវិនិយោគផ្ទាល់ពីបរទេស នៅក្នុងវិស័យឧស្សាហកម្មផលិតស្បែកជើង រដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំផែនការមេរបស់ខ្លួន ដោយកំណត់ចក្ខុវិស័យសំរាប់អភិវឌ្ឍន៍ឧស្សាហកម្មផ្នែកនេះ នូវគោលនយោបាយដែលត្រូវអនុវត្តដើម្បីអោយបានសំរេចចក្ខុវិស័យនេះ និងការកែលំអបរិយាកាសក្នុងការវិនិយោគ។ សំរាប់ពេលបច្ចុប្បន្ននេះ វិស័យឧស្សាហកម្មនឹងត្រូវពឹងផ្អែកលើការមកបោះទីតាំងរបស់ក្រុមហ៊ុនផលិតស្បែកជើង និងក្រុមហ៊ុនផលិតសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើង សំរាប់ផលិតស្បែកជើង មកពីតៃវ៉ាន់ ក៏ដូចជាការប្រគល់សិទ្ធិរបស់ក្រុមហ៊ុនជប៉ុនទៅអោយក្រុមហ៊ុនផ្សេងៗទៀតដើម្បីផលិត។ នៅក្នុងរយៈពេលយូរអង្វែង គេអាចបង្កើនការចូលរួមដោយការវិនិយោគទុនរបស់ក្រុមហ៊ុនក្នុងស្រុក នៅក្នុងការកែច្នៃវត្ថុធាតុដើមសំរាប់ផលិតស្បែកជើង ដែលការធ្វើបែបនេះនឹងជំរុញអោយវិស័យឧស្សាហកម្មចាក់រឹសរឹងមាំនៅកម្ពុជា។ ការរៀបចំការណែនាំសំរាប់អ្នកវិនិយោគ (ទាំងវិនិយោគិនក្នុងស្រុក និងមកពីបរទេស) និងអ្នករៀបចំគោលនយោបាយ ការរៀបចំអោយមានផែនការមេគឺ ជាការងារដែលមិនអាចខានបានទេ។ ផែនការមេនេះគួតែរៀបចំដោយអង្គភាពមួយ ដែលមានតួនាទីវិភាគរាល់ សកម្មភាព ឧស្សាហកម្មសំខាន់ៗ ដែលមាននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ អង្គភាពនេះត្រូវរៀបចំផែនការដែលមានលក្ខណៈជាប្រព័ន្ធសំរាប់ឧស្សាហកម្មផលិតស្បែកជើងអោយបានឆាប់រហ័សជាមួយនឹងអំណាចនៃមូលធនបរទេសក្នុងការបោះជំហានទៅមុខ។

**(៧) ការផ្គត់ផ្គង់សំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗពីក្រុមហ៊ុនក្នុងប្រទេស**

ឧស្សាហកម្មផលិតស្បែកជើង ត្រូវការចាំបាច់នូវសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើង សំរាប់ផលិតស្បែកជើង ដូចជាស្បែកសុទ្ធធម្មជាតិ ស្បែកកែឆ្នៃ កំណាត់សំរាប់ដេរខ្នងស្បែកជើង ស្បែកធម្មតា ជ័រកាវ បិតបាតស្បែកជើង កៅស៊ូកែច្នៃសំរាប់ធ្វើទ្រនាប់ ក្រដាស និងដែក។ និយាយអោយចំទៅ ការលើកកំពស់វិស័យនេះ ទាមទារនូវការផលិតក្នុងស្រុកអោយបានច្រើន ដើម្បីធានានូវការប្រកួតប្រជែងតំលៃ។ នៅពេលបច្ចុប្បន្ននេះ ឧស្សាហកម្មផលិតស្បែកជើងបាននាំចូលសំភារៈបន្ទាប់បន្សំដែលមានគុណភាពពីមធ្យមទៅខ្ពស់ ពីប្រទេសជប៉ុន កូរ៉េ និងតៃវ៉ាន់ ហើយសំភារៈបន្ទាប់បន្សំដែលមានគុណភាពទាបភាគច្រើន ត្រូវបាននាំចូលពីប្រទេសចិន។ នៅក្នុងស្ថានភាពបែបនេះ សូម្បីតែមានជំនួយពីបរទេសក៏ដោយ វានៅតែមិនមានភាពសមហេតុសមផលសំរាប់កម្ពុជាផលិត សំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើងទាំងអស់នេះបាននៅក្នុងស្រុកទេ។

គេមានសេចក្តីសង្ឃឹមថានឹងមានការបោះទីតាំងរោងចក្រកែច្នៃសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗរបស់ស្បែកជើងសំរាប់ផលិតស្បែកជើងនៅកម្ពុជា។ ដំណើរការនេះទាមទាអោយមានការយកចិត្តទុកដាក់ ជាពិសេសលើបញ្ហាបរិស្ថាន នឹងត្រូវចាត់វិធានការអោយបានម៉ត់ចត់ ដើម្បីការពារកុំអោយមានភាពកខ្វក់ដែលជាបញ្ហាដ៏លំបាកកំពុងមាន នៅប្រទេសចិន។ នៅប្រទេសវៀតណាម ការប្រើប្រាស់ផលិតផលស្បែកដែលធ្វើក្នុងស្រុកមានចំនួន ២០% ប៉ុណ្ណោះ ហើយពេលនេះគេកំពុងតែរកវិធីដើម្បីកែច្នៃស្បែកក្នុងស្រុកបន្ថែមទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ការហូរចូលបច្ចេកទេសពីបរទេស និងការកែច្នៃកាកសំណល់វាវមានតំលៃខ្ពស់ណាស់ហើយ ជំនួយបរទេសសំរាប់ការងារនេះ មានមិនច្រើនដូចដែលជាគេចង់បាននោះទេ។ ផ្ទុយទៅវិញ នៅប្រទេសបង់ក្លាដែសដែលមានសិទ្ធិទទួលប្រពន្ធ័អនុគ្រោះទូទៅដូចប្រទេសកម្ពុជាដែរនោះ គេមានផែនការរៀបចំទីតាំងកែច្នៃស្បែក ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ មកពីប្រទេសអ៊ីតាលី។ ក្នុងរយៈពេលវែងក្រុមហ៊ុនកែច្នៃស្បែកជាច្រើន ដែលបានកំពុងបោះទីតាំងនៅក្នុងតំបន់ជិតទីក្រុងបាងកកនៅថៃឡង់ដ៏ នឹងត្រូវបង្ខំចិត្តផ្ទេរទីតាំងផលិកម្មទៅកាន់តំបន់ផ្សេងទៀត ដោយសារកំណើននៃថ្លៃដើមផលិតកម្ម។

ដំណើរការកែច្នៃនេះ ទាមទារអោយមានបច្ចេកទេសទំនើបៗ និងសំភារៈប្រើប្រាស់មានតំលៃខ្ពស់ៗសំរាប់កែច្នៃកាកសំណល់វាវ។ លើសពីនេះទៀត ការកែច្នៃបែបនេះអាចនឹងត្រូវបញ្ចប់នៅប្រទេសចិន និងវៀតណាម និងនៅប្រទេសជប៉ុន កូរ៉េ និងតៃវ៉ាន់ផងដែរ។ លទ្ធភាពប្រកួតប្រជែងនៃឧស្សាហកម្មផលិតស្បែក ជើងនៅកម្ពុជា គឺជាការប្រកួតប្រជែងដែលមានប្រៀបខាងការផលិតស្បែកជើងស្បែក។ គេអាចពិចារណាលើការបង្កើតប្រពន្ធ័កែច្នៃស្បែកនៅកម្ពុជា ដោយប្រើប្រាស់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីជំនួយអភិវឌ្ឍន៍អន្តរជាតិ។ ការកែច្នៃស្បែកនឹងត្រូវនាំចូលស្បែកឆៅមកពីអាមេរិកខាងត្បូង និងតំបន់ផ្សេងៗទៀត។ ការផ្គត់ផ្គង់ស្បែកដែលកែច្នៃ ហើយនេះ មិនត្រឹមតែយកមកប្រើប្រាស់នៅប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងយកទៅបណ្តាប្រទេសក្នុងតំបន់ទៀតផង។

### ៧.៤.២ ផែនទីបង្ហាញផ្លូវអនាគត សំរាប់គោលនយោបាយការវិនិយោគបរទេសផ្ទាល់ ក្នុងឧស្សាហកម្មផលិតស្បែកជើង

ផ្នែកខាងលើ បានរៀបរាប់ពីវិធានការសំរាប់ទាក់ទាញការវិនិយោគ ដោយក្រុមហ៊ុនផលិតស្បែកជើងមកពីបរទេស។ សំរាប់ផែនការសកម្មភាព វិធានការទាំងអស់នេះត្រូវរៀបចំតាមលំដាប់លំដោយ ក្នុងពេលវេលាពីរយៈពេលមធ្យម ទៅរយៈពេលយូរអង្វែង (រហូតដល់ឆ្នាំ ២០២០)។ សំរាប់រយៈដ៏ខ្លីខាងមុខនេះ បរិយាកាសនៃការវិនិយោគក្នុងវិស័យឧស្សាហកម្មផលិតស្បែកជើងកំពុងតែផ្តល់អំណោយផលដល់កម្ពុជា ជាពិសេសការផលិតស្បែក ជើងស្បែក។ ដើម្បីទាញផលប្រយោជន៍ពីឱកាសនេះ រដ្ឋាភិបាលគួរតែផ្តល់អាទិភាពដល់ឧស្សាហកម្មផលិតស្បែកជើង ហើយចាត់វិធានការសំខាន់ៗដើម្បីលើកកំពស់វិស័យនេះ ដោយរួមទាំងការលើកទឹកចិត្តក្នុងការវិនិយោគ ការផ្តល់អាទិភាពដល់ក្រុមហ៊ុនបរទេស ដើម្បីអោយគេមកបោះទីតាំងនៅកម្ពុជា ផលិតសំភារៈបន្ទាប់បន្សំ និងផ្នែកផ្សេងៗ របស់ស្បែកជើងសំរាប់ផលិតស្បែកជើង។ លើសពីនេះទៀត សមាគមន៏ឧស្សាហកម្មផលិតស្បែកជើង ត្រូវតែសើរើឡើងវិញ និងចាប់ផ្តើមដំណើរការ

ដើម្បីជាមធ្យោបាយសំរាប់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងអ្នកវិនិយោគនៅ ក្នុងឧស្សាហកម្មនេះ។

នៅក្នុងរយៈពេលមធ្យម រដ្ឋាភិបាលត្រូវតែកំនត់ និងអនុវត្តផែនការសាធារណៈនៅក្នុងផ្នែកនានា ដូចជាការអភិវឌ្ឍន៍ធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ នៅពេលដែលផែនការមេកំពុងត្រូវបានគេរៀបចំ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គួរតែរៀបចំក្រុមជំនាញរបស់ខ្លួនអោយបានកាន់តែឆាប់រហ័សជាទីបំផុត ហើយចាប់ផ្តើមពិនិត្យឡើងវិញនូវផែនការមេសំរាប់ផលិតស្បែកជើងអោយបានស៊ីជំរៅជាទីបំផុត ដោយការងារនេះត្រូវមានជំនួយពីជំនាញការបរទេស។ នៅក្នុងរយៈវែង គេគួរតែពិចារណាអំពីការអភិវឌ្ឍន៍កន្លែងកែច្នៃស្បែកក្នុងស្រុក ដើម្បីផលិតជាស្បែក សំរាប់ផលិតស្បែកជើង។ ចំពោះប្រពន្ធ័ផ្គត់ផ្គង់ ដែលពេលនេះកំពុងត្រូវបានគេដាក់លក្ខ័ខ័ណ្ឌ ដែលជាផ្នែក មួយសំរាប់ជួយលើកកំពស់ឧស្សាហកម្មកាត់ដេរ ជាពិសេសពាក់ព័ន្ធទៅនឹងការរៀបចំកំពង់ផែ និងសំភារៈបរិក្ខារដែល ប្រើប្រាស់នៅកំពង់ផែក្រុងព្រះសីហនុ និងការកែលំអថែមទៀតនៃបណ្តាញផ្លូវគមនាគមន៍ពីទីក្រុងព្រះសីហនុ ទៅភ្នំពេញ។

**រូបភាព ៧-៤-១ ផែនទីបង្ហាញផ្លូវអនាគតសំរាប់គោលនយោបាយ FDI ក្នុងឧស្សាហកម្មផលិតស្បែកជើង**

| | 2007-2010 | 2011-2015 | 2015-2020 |
|---|---|---|---|
| Policy on foreign capital | Determination and execution of measures for promotion of the footwear industry | | |
| | Simplification of import-export procedures | Preparation of a master plan | |
| Industrial organization | **Reconstruction of the Footwear association** | | Domestic tanning |
| HRD | | Establishment of an HRD organization and execution of skill training programs | |
| Infrastructural conditioning | Conditioning of the logistics infrastructure | | |

Source: JICA Study Team

# ជំពូកទី ៨

# ទស្សនៈវិស័យ និងអនុសាសន៍ ស្តីពីលក្ខខណ្ឌវិនិយោគ សំរាប់ការទាក់ទាញឧស្សាហកម្ម គ្រឿងអគ្គិសនី/អេឡិចត្រូនិកបរទេស មកកម្ពុជា

## ៨.១ ចរិតលក្ខណៈនៃការតំឡើងធម្មតា និងឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គិសនីរបស់កម្ពុជា

### ៨.១.១ ការប្រៀបធៀបជាអន្តរជាតិនៃឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គីសនី និងឧស្សាហកម្មតម្លើងធម្មតា

ទោះបីឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិក មិនទាន់ត្រូវបានអភិវឌ្ឍន៍នៅកម្ពុជាក៏ដោយ ក៏មានសក្តានុពលជាច្រើន សំរាប់ការអភិវឌ្ឍន៍លើវិស័យឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិកនេះ។ ក្រុមហ៊ុនជប៉ុនមួយចំនួនដែលបានដំណើរការផលិតកម្មលើវិស័យនេះ នៅក្នុងបណ្តាប្រទេសជិតខាង ដូចជាប្រទេសថៃ និងម៉ាឡេស៊ី បានបង្ហាញនូវការចាប់អារម្មណ៍ចំពោះប្រទេសកម្ពុជា ដើម្បីពង្រីកវិសាលភាពការវិនិយោគ ឬផ្ទេរទីតាំង ក្រុមហ៊ុនទាំងនោះមក កម្ពុជាដើម្បីនឹងទទួលយកនូវផលប្រយោជន៍តំលៃពលកម្មថោកពីកម្ពុជា។ ជាលទ្ធផល វិស័យឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិកកម្ពុជា នឹងឈានចូលក្នុងដំណាក់កាលចាប់ផ្តើមនៃការអភិវឌ្ឍន៍របស់ខ្លួន ក្នុងពេលដែលផលិតកម្មបរិក្ខារអគ្គិសនីអតិពលកម្មជាមូលដ្ឋាន នឹងចាប់ផ្តើមឡើង។

រូបនៅខាងក្រោមនេះបង្ហាញពីការបែងចែកជាមូលដ្ឋាននៃផលិតផលនៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកទាក់ទងទៅនឹងកំរិតបច្ចេកទេស និងទំហំនៃការវិនិយោគ។ ការវិនិយោគលើវិស័យនេះ នឹងក្លាយទៅជាការវិនិយោគដែលកាន់តែមានលក្ខណៈបច្ចេកទេស ដែលត្រូវការជាមូលដ្ឋាននូវសំភារៈច្រើន នៅពេលដែលការវិនិយោគខិតទៅរកផ្នែកស្តាំខាងលើនៃរូបភាព។ ផ្នែកនេះគឺជាផ្នែកដែលមានការវិនិយោគច្រើន ដោយក្រុមហ៊ុនសំខាន់របស់ជប៉ុន និងប្រទេសអភិវឌ្ឍន៍នានា ដែលមានការប្រកួតប្រជែងគ្នាខ្លាំង (ប្រូសេសផ្ទៃក្រៅសំរាប់ប្រដាប់ចំលងភ្លើង និងផលិតផល LCD)។ ផ្នែកខាងឆ្វេងក្រោមនៃតារាងគឺជាការវិនិយោគដែលត្រូវការកំលាំងពលកម្ម និងជាចំណុចចាប់ផ្តើមនៃការអភិវឌ្ឍន៍ របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាប្រទេសមានតំលៃកំលាំងពលកម្មទាប។ ផលិតផលដែលត្រូវផលិតមានបរិក្ខារអគ្គិសនីជាពិសេសបរិក្ខារដែលទាមទារអោយមានការតំឡើង ជាទ្រង់ទ្រាយតូចៗ ដូចជាដំណរសំរាប់ភ្ជាប់ខ្សែភ្លើង រមូលរំ ប្រដាប់ទប់ភ្លើង និងម៉ូទ័រ។ ត្រូវយកប្រទេសថៃ និងម៉ាឡេស៊ីធ្វើជាគំរូ សំរាប់ឧស្សាហកម្មនៅប្រទេសអាស៊ាន ដែលកំពុងមានការរីកចំរើនដល់ដំណាក់កាលនេះ។

**រូបភាព ៨-១-១ សេណារីយោសំរាប់ការវិវត្តន៍ថ្មីដោយដំណាក់កាលនៃឧស្សាហកម្មគ្រឿងអគ្គីសនី និងអេឡិកត្រូនិក**




Note: IC-Integrated Circuit, PC-Personal Computer, CTV-Color Television
Source: JICA Study Team

បរិក្ខារតម្លើងធម្មតា មានផលប៉ះពាល់យ៉ាងមហិមាសំរាប់ស្រូបយកកំលាំងពលកម្ម និងធ្វើឱ្យរីកសាយភាយនូវបច្ចេកវិទ្យា ជាមួយនឹងកំរិតមួយនៃការវិនិយោគ ដែលប្រែប្រួលទៅតាមដំណាក់កាលនៃការវិវត្តន៍ថ្មី។ ពួកគេមានអំណាចច្រើនជាងវិស័យផ្សេងទៀតសំរាប់បណ្តុះនូវវដ្តនៃគុណប្រយោជន៍ ដែលទទួលបាននូវរូបិយវត្ថុបរទេស និងកំណើនសេដ្ឋកិច្ច។ ជាប្រវត្តិសាស្ត្រ ប្រទេសជប៉ុន និងប្រទេសអាស៊ានមួយចំនួន បានបង្ហាញពីជោគជ័យបែបនេះ។ នៅប្រទេសវៀតណាម មានរោងចក្រតម្លើងបរិក្ខារបែបនេះមានទីតាំងនៅទីក្រុងហូជីមិញដែលជាមជ្ឈមណ្ឌលស្នូលក្នុងការទ្រទ្រង់ដល់ការរីកចំរើនវិស័យឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក។ ទោះបីជាពេលវេលា និងសេដ្ឋកិច្ចសង្គមខុសគ្នាក៏ដោយ កម្ពុជានិងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ពិតជាអាចយកគំរូបែបនេះ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិកបាន។

នៅក្នុងវិស័យបរិក្ខារអគ្គិសនីនេះ ក្រុមហ៊ុនជប៉ុនគឺជាក្រុមហ៊ុន ដែលដើរតួនាទីសំខាន់ក្នុងការចែកចាយបរិក្ខាររហូតដល់ចំនួន ៦០% នៅលើទីផ្សារពិភពលោក និងជាអ្នកដែលបានចូលរួមលើសគេដល់ឧស្សាហូបនីយកម្មនៅអាស៊ាន ដូចជាសិង្ហបូរី ម៉ាឡេស៊ី និងថៃ។ ការតំឡើងបរិក្ខារអតិពលកម្ម ដែលបានគាំទ្រឱ្យមានដំណាក់កាលដំបូង នៃការជឿនលឿនក្នុងប្រទេសជួរមុខនៅអាស៊ាន ដែលកំពុងតែបាត់បង់នូវភាពប្រកួតប្រជែង ក្នុងប្រទេសម៉ាឡេស៊ី ជាដើម។ ប្រទេសចិនគឺជាប្រទេសដែលខ្លាំងជាងគេបង្អស់ក្នុងការប្រកួតប្រជែងលើវិស័យបរិក្ខារអគ្គិសនីនេះ។ ហានិភ័យដែលទាក់ទងជាមួយការប្រមូលផ្តុំការវិនិយោគនៅប្រទេសចិន កំពុងតែពង្រីក ហើយការវិនិយោគនៅវៀតណាម កំពុងតែស្ថាបនាដើម្បីជៀស

វាំងហានិភ័យទាំងនោះ។ ទោះបីគេមិនអាចជំនួសបាននូវភាពប្រកួតប្រជែងតម្លៃរបស់ចិន ប្រទេសមិនទាន់អភិវឌ្ឍន៍នៅអាស៊ានមានភាពខ្លាំងក្នុងការរក្សាបាននូវអតិថិជនដែលមានស្រាប់សំរាប់គ្រឿងអគ្គិសនី/អេឡិកត្រូនិកនៅប្រទេសជិតខាងរបស់គេ។ សំរាប់បរិក្ខារអគ្គិសនី តំលៃគឺជាកត្តាកំណត់ភាពប្រកួតប្រជែង ប៉ុន្តែការចំណាយពេលវេលាសំរាប់ដឹកជញ្ជូនក៏ជាកត្តាសំខាន់ណាស់ដែរ។ កម្ពុជា អាចមានប្រៀបជាងប្រទេសចិន ត្រង់ថាកម្ពុជាមានទីតាំងភូមិសាស្ត្រជិតប្រទេសម៉ាឡេស៊ី និងប្រទេសថៃ ដែលជាប្រទេសមានការរីកចំរើនឧស្សាហកម្មបរិក្ខាអគ្គិសនី ហើយកម្ពុជាអាចមានសក្តានុពលនៅក្នុងការផ្គត់ផ្គង់ផលិផល ដល់ប្រទេសទាំងពីរនេះបានលឿនជាង ប្រទេសចិន។

### ៨.១.២ ការវិភាគ SWOT នៃផលិតផលគ្រឿងអគ្គិសនី/អេឡិចត្រូនិកនៅកម្ពុជា

ដោយឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ពុំទាន់មាននៅក្នុងប្រទេសកម្ពុជានៅឡើយ ដូចនេះមិនចាំបាច់ធ្វើការវិភាគតាមវិធាន **SWOT** ទេ។

### ៨.១.៣ លំអានដែលអាចសំរេចបាននៃផលិតកម្មនៅកម្ពុជា

គេត្រូវកត់សំគាល់ថា មិនមែនក្រុមហ៊ុនទាំងអស់ កំពុងពិចារណាលើការធ្វើនីតិសម្បទា និងងាកឆ្ពោះទៅរកការបែងចែកពលកម្មជាអន្តរជាតិ នឹងជ្រើសរើសបោះទីតាំងក្នុងប្រទេសវៀតណាមទាំងអស់នោះទេ។ កម្ពុជា ក៏អាចមានឱកាសច្រើនណាស់ដែរ។ ក្នុងការកសាងរោងចក្រថ្មីៗ អ្នកវិនិយោគ (ក្រុមហ៊ុន) ត្រូវធ្វើការពិនិត្យយ៉ាងម៉ត់ចត់អំពីបរិស្ថាន វិនិយោគនៅក្នុងប្រទេស ដែលគេត្រូវជ្រើសរើស (ដូចជាវៀតណាម កម្ពុជា ភូមា និងឡាវ) និងជ្រើសរើសប្រទេសដែលល្អប្រសើរជាងគេបង្អស់។ កម្ពុជាពិតជាអាចទាក់ទាញក្រុមហ៊ុនជប៉ុន ខាងវិស័យឧស្សហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក បើសិនជាបរិស្ថានវិនិយោគត្រូវបានគេវាយតំលៃខ្ពស់។ ទោះបីវៀតណាមកំពុងតែនាំមុខនៅក្នុងការកែលំបរិស្ថានទាំងនេះ កម្ពុជា ត្រូវបានគិតថាឈរក្នុងឱកាសល្អមួយនៃការទាក់ទាញការបោះទីតាំងរបស់ ក្រុមហ៊ុនប្រភេទនេះ បើសិនកម្ពុជាអាចកែលំអបរិស្ថានវិនិយោគអោយបានល្អប្រសើរនោះ។

គេប៉ាន់ស្មានថា មានគំរូ ៥ យ៉ាង នៃការមកដាក់ទីតាំងផលិតកម្មនៅកម្ពុជា ដូចបានបង្ហាញខាងដើម ទាក់ទងទៅនឹងលទ្ធភាពនៃការដាក់ទីតាំងក្រុមហ៊ុនឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិករបស់ជប៉ុន នឹងបង្ហាញនៅក្នុងតារាងខាងក្រោម (ផ្អែកលើកត្តាមួយចំនួន រួមបញ្ចូលទាំងល័ក្ខខ័ណ្ឌមូលដ្ឋាននៃការបោះទីតាំង សំរាប់ការផលិតឧបករណ៍អគ្គិសនី/អេឡិចត្រូនិក និន្នាការក្នុងការបែងចែកសង្វាក់ផលិតកម្មក្នុងចំណោមប្រទេសនៅអាស៊ាន ដោយផ្អែក លើលទ្ធផលនៃបទសម្ភាសន៍ជាមួយក្រុមហ៊ុននៅប្រទេសម៉ាឡេស៊ី ថៃ និងនិន្នាការថ្មីៗក្នុងការមកបោះទីតាំង ដោយក្រុមហ៊ុនឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកនៅប្រទេសវៀតណាម)។ ចំណែកការវិនិយោគលើការផលិត ដំណសំរាប់ភ្ជាប់ខ្សែភ្លើងរមូលរំ និងឧបករណ៍ទុបភ្លើង គេបានគិតថាក្រុមហ៊ុននឹងមានផលប៉ះពាល់ក្នុងការបែងចែកសង្វាក់ផលិតកម្ម ជាមួយនឹងរោងចក្រដែលមានស្រាប់នៅក្នុងប្រទេសម៉ាឡេស៊ី ដែលកំពុងតែបាត់លទ្ធភាពប្រកួតប្រជែង។ ការផ្គត់ផ្គង់នឹងធ្វើដោយ

ផ្ទាល់ទៅបណ្ដាទីផ្សារនៅអាស៊ាន និងមានការនាំចេញមួយចំនួនទៅកាន់តំបន់ផ្សេងទៀត។ ផលិតផលអគ្គិសនីតូចៗទំនិញដែលផលិតមិនទាន់រួចរាល់ (ដូចជា CCD សំរាប់ម៉ាស៊ីនថតរូប BLUs, និងប្រព័ន្ធផ្ដល់ភ្លើង) និងទំនិញសំរាប់ទំនាក់ទំនងព័តិមាន នឹងនាំចេញទៅកាន់ទីផ្សារមិនមែនអាស៊ាន ដូចជាជប៉ុន ចិន អឺរ៉ុប និងអាមេរិកខាងជើង។ ការវិនិយោគលើផលិតផលទាំងនេះ មិនកំណត់ថាត្រូវតែធ្វើដោយរោងចក្រដែលមាន នៅអាស៊ាននោះទេ។ វាអាចមានលទ្ធភាពខ្លាំងចំពោះការវិនិយោគដោយផ្ទាល់មកពីប្រទេសជប៉ុន ពីព្រោះថាវាតែងតែ ជាករណីចាំបាច់ដែលគេត្រូវតែទប់ទល់នឹងការរីកសាយទីផ្សារថ្មីៗ ដែលរួមបញ្ចូល :

- ការតំឡើងដំណសំរាប់ភ្ជាប់ខ្សែភ្លើង ។
- ការតំឡើងរមូលរំ និងឧបករណ៍ទុបភ្លើង ។
- ការតំឡើងឧបករណ៍អគ្គិសនីតូចៗ ។
- ការតំឡើងឧបករណ៍ដែលផលិតរួចតែពាក់កណ្ដាល ដូចជា CCD សំរាប់ម៉ាស៊ីនថតរូប BLUs, និងប្រព័ន្ធផ្ដល់ភ្លើង ។ និង
- ការតំឡើងបរិក្ខារទំនាក់ទំនងព័តិមាន (ព្រីនធឺ និងទូរស័ព្ទចល័ត) ។

**តារាង ៨-១-១ លទ្ធភាពនៃការបោះទីតាំងរបស់ FDI នៅកម្ពុជា ពីការប្ដូរទីតាំងផលិតកម្ម តំរូវការក្នុងឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក**

| | | Main Product (Example) | Production Geographical Condition | | | | Cambodia Opportunity |
|---|---|---|---|---|---|---|---|
| | | | Domestic Market | Labor | Component or Material | Production Facility | |
| Electric & Electronics Equipment | Audio & Visual Equipment | TV<br>CD Player<br>Car Stereo | ○ | ○ | ◎ | ○ | × |
| | Information Equipment | Main Frame<br>PC | △ | △ | ◎ | ○ | × |
| | | Monitor<br>Printer<br>Copy Machine | △ | ◎ | ◎ | ○ | △ |
| | Communication Equipment | Radar<br>Switching Equipment | ○ | △ | ○ | ○ | × |
| | | Hand Phone<br>Facsimile | △ | ○ | △ | ○ | △ |
| | Home Electric Appliances | Refrigerator<br>Washing Machine<br>Microwave Oven | ◎ | ○ | ◎ | ◎ | × |
| | | Hair dryer<br>Lighting Equipment | △ | ◎ | △ | △ | ○ |
| | Others | Medical<br>Control<br>Instrumentation | ○ | △ | △ | ○ | × |
| Electric & Electronics Component | Active Component | Semiconductor<br>Display Device | △ | △ | △ | ◎ | × |
| | Passive Component | Resistor<br>Condenser | ○ | ◎ | △ | ○ | × |
| | | Coil<br>Trans | ○ | ◎ | △ | △ | ○ |

| | | Main Product ( Example ) | Production Geographical Condition | | | | Cambodia Opportunity |
|---|---|---|---|---|---|---|---|
| | | | Domestic Market | Labor | Component or Material | Production Facility | |
| | Sub Assemble | Wire Harness<br>High Frequency Module<br>CCD Module<br>Power Supply | △ | ◎ | △ | △ | ○ |

Note: ◎extremely important ○important △always not important ×not important
Source: JICA Study Team

## *(១) ការតម្លើងប្រព័ន្ធដំណភ្ជាប់ខ្សែភ្លើងរបស់យានយន្ត*

ដំណភ្ជាប់ខ្សែភ្លើងរបស់យានយន្ត គឺជាខ្សែរបរិក្ខារអគ្គិសនីរាងដូចសំណាញ់សំរាប់ភ្ជាប់ប្រព័ន្ធសៀគ្វី និងគ្រឿងអគ្គិសនី/អេឡិចត្រូនិកនៅក្នុងឧស្សាហកម្មយានយន្ត។ រចនាសម្ព័ន្ធ និងលក្ខណៈពិសេសរបស់វាខុស១គ្នា អាស្រ័យលើអ្នកផលិត និងប្រភេទផលិតផល ហើយការផលិតមានលក្ខណៈសំបូរបែបណាស់។ តំរូវការសំភារៈបែបនេះ មាននៅក្នុងឧស្សាហកម្មយានយន្ត ប៉ុន្តែដំណភ្ជាប់ខ្សែភ្លើងក៏ត្រូវបានគេយកទៅប្រើប្រាស់ធ្វើជាគ្រឿងអគ្គិសនីសំខាន់១ សំរាប់ភ្ជាប់ក្នុងប្រព័ន្ធសៀគ្វី និងគ្រឿងអគ្គិសនី/អេឡិចត្រូនិកផ្សេងទៀតផងដែរ។ ការរុំជាបាច់ដោយមានប្រវែងខ្សែ និងកំរាស់ខុស១គ្នាធ្វើឱ្យសមស្របទៅនឹងប្រភេទផលិតផលនោះ កំពុងក្លាយជាការលំបាកដោយហេតុថាភាពខុស ប្លែកគ្នារបស់ផលិតផលកំពុងតែកើនឡើងលើគ្រប់ប្រភេទផលិតផលទាំងអស់។ ទោះបីការប្រើប្រាស់មានលក្ខណៈទូលំទូលាយក៏ដោយការផលិតដំណភ្ជាប់ខ្សែភ្លើងពិតជាត្រូវការកំលាំងពលកម្មច្រើនក្នុងផលិតកម្ម។

ក្រុមហ៊ុនយ៉ាហ្សាគីសូក្យូ (Yazaki Sogyo) ដែលជាក្រុមហ៊ុនឈានមុខគេក្នុងឧស្សាហកម្មបែបនេះ ការផលិតដំណភ្ជាប់ខ្សែភ្លើងភាគច្រើន សំរាប់ប្រើក្នុងឧស្សាហកម្មយានយន្ត និងម៉ូតូម៉ាកស្លូទ័រ។ នេះជាក្រុមហ៊ុនដំបូងគេ ដែលបានបោះទីតាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ាន ដូចជានៅវៀតណាម និងឡាវ ដើម្បីស្វែងរកពលកម្ម ដែលមានប្រាក់បៀវត្សរ៍ថោក និងមានទេពកោសល្យការងារល្អ។ នៅប្រទេសវៀតណាម ក្រុមហ៊ុននេះមានរោងចក្រមួយចំនួន ដែលផលិតនាំចេញទៅប្រទេសជប៉ុន និងអាមេរិកខាងជើង។ ក្រុមហ៊ុននេះបានកំពុងតែពិចារណាក្នុងការពង្រីកទីតាំងផលិតកម្មរបស់ខ្លួន។ ដោយពិនិត្យឃើញនូវតំរូវការប្រើប្រាស់ដំណសំរាប់ភ្ជាប់ខ្សែភ្លើងនៅ ក្នុងឧស្សាហកម្មយានយន្តនាពេលបច្ចុប្បន្ន សមត្ថភាពផលិតកម្មបរិក្ខារទាំងនេះនឹងមិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ទេ នៅថ្ងៃអនាគតដ៏ខ្លីខាងមុខនេះ។ ទោះបីក្រុមហ៊ុនយ៉ាហ្សាគីរក្សាប្រទេសវៀតណាមជាទីតាំងសំខាន់ក៏ដោយ ក៏ក្រុមហ៊ុនកំពុងតែសំលឹងមើលប្រទេសជិតខាង ដើម្បីពង្រីកផលិតកម្មរបស់ខ្លួន។

ដំណសំរាប់ភ្ជាប់ខ្សែភ្លើង ក៏ជាសំភារៈដែលគេត្រូវការយកមកផលិតឧបករណ៍ប្រើប្រាស់នៅតាមផ្ទះ និងលិតផលអគ្គិសនី /អេឡិចត្រូនិកផ្សេងទៀតដែរ។ រោងចក្រសំខាន់១របស់ជប៉ុនដែលផលិតម៉ាស៊ីនត្រជាក់មានទីតាំងនៅប្រទេសថៃកំពុងតែពិចារណាយកមកតំឡើងនៅប្រទេសវៀតណាម (ទីក្រុងហាណូយ) ដើម្បីកាត់បន្ថយការចំណាយលើការផលិត

ដំណនេះ។ នៅប្រទេសថៃការផលិតទំនិញស (ដូចជាទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនកំដៅម្ហូប ម៉ាស៊ីនលាងចាន ។ល ។) កំពុងតែមានការកើនឡើង ហើយឧស្សាហកម្មយានយន្តក៏នឹងអាចមានការរីកចំរើនយ៉ាងឆាប់រហ័សដែរ នៅពេលអនាគតដ៏ខ្លីខាងមុខ។ យ៉ាងណាមិញប្រាក់ខែជាអប្បបរិមានៅទីក្រុងបាងកកគឺប្រហែល ១២០ ដុល្លារអាមេរិក ហើយចំនួនប្រាក់ខែនេះអាចឡើងដល់ ២០០ ដុល្លារអាមេរិក បើបូកបញ្ចូលទាំងប្រាក់ថែមម៉ោងផង។ ដូចនេះប្រទេសថៃនឹងជួបការលំបាកនៅក្នុងឧស្សាហកម្មដំណខ្សែភ្លើង ដោយសារតែការកើនឡើងនៃតំលៃផលិតកម្ម។ ស្ថានភាពបែបនេះបង្ហាញអោយឃើញពីលទ្ធភាពនៃការប្តូរទិសមកផលិតនៅកម្ពុជាវិញ ដោយសារកំលាំងពលកម្មថោកជាង។ ទាំងក្រុមហ៊ុនថៃ និងក្រុមហ៊ុនជប៉ុនបានបង្ហាញពីឆន្ទៈបោះទីតាំងរោងចក្រផលិតដំណខ្សែភ្លើង នៅតំបន់ឧស្សាកម្ម តាមព្រំដែនកម្ពុជាថៃ។

*(២) ដំណើរការរុំដុំភ្លើង និងប្រដាប់ទប់ភ្លើង*

ផលិតផលអគ្គិសនី/អេឡិចត្រូនិកភាគច្រើន ប្រើប្រាស់គ្រឿងបរិក្ខារដែលផលិតដោយដំណើរការរុំ ដូចជា ដុំភ្លើង ប្រដាប់ទុបភ្លើង តំរង់ ប្រដាប់បំលែង និងម៉ាស៊ីនរំញ័រជាដើម។ តំរូវការគ្រឿងបរិក្ខារបែបនេះ កំពុងតែមានការកើនឡើងជាបន្តបន្ទាប់។ គេអាចប្រែក្លាយដំណើរការរុំនេះ អោយទៅជាដំណើរការរុំដោយស្វ័យប្រវត្តិ ប៉ុន្តែវិធីដែលអស់តំលៃថោកជាងគេបង្អស់នៅក្នុងប្រទេសអាស៊ាន គឺជាការរួមគ្នារវាងម៉ាស៊ីនសំរាប់រុំ និងអ្នកប្រើម៉ាស៊ីនម្នាក់។ ការរួមគ្នានេះទាមទារអោយមានពលករដែលមានទេពកោសល្យ និងថ្លៃឈ្នួលថោក។ ក្រុមហ៊ុននាំមុខរបស់ជប៉ុននៅក្នុងឧស្សាហកម្មបែបនេះ ដូចជាក្រុមហ៊ុន Mabuchi, Nidec និង Tokin មានរោងចក្រនៅប្រទេសចិន និងវៀតណាម។ រោងចក្រជប៉ុនដំបូងគេបង្អស់ ក្នុងការផលិតដុំភ្លើង និងប្រដាប់ទប់ភ្លើងបានមកបោះទីតាំងនៅប្រទេសសិង្ហបូរី។ នៅពេលដែលតំលៃពលកម្មនៅប្រទេសសិង្ហបូរីមានការកើនឡើង ការផលិតបានបង្វែរមកប្រទេសម៉ាឡេស៊ី និងថៃវិញ។ នាពេលថ្មីៗនេះ រោងចក្រជាច្រើនត្រូវបានសាងសង់នៅប្រទេសចិន។ បំលាស់ប្តូរនេះបណ្តាលមកពីការប្រែប្រួល សំខាន់ៗនៃការប្រើប្រាស់បរិក្ខារអគ្គិសនី ពោលគឺពីបរិក្ខារ **AV** ទៅជាបរិក្ខារទំនាក់ទំនងព័ត៌មាន។ ទន្ទឹមនឹងនេះ ទីតាំងផលិតកម្មនៅអាស៊ាន និងប្រទេសចិន បន្តពង្រីកស្របពេលជាមួយនឹងតំរូវការនៅក្នុងស្រុក។

ក្រុមហ៊ុនជប៉ុនមួយចំនួនដែលផលិតបរិក្ខារ **AV** និងឧបករណ៍ទប់ភ្លើង ដែលមានទីតាំងនៅប្រទេស ម៉ាឡេស៊ី កំពុងតែសិក្សាពីជំរើសទីតាំងថ្មីៗដែលអាចកាត់បន្ថយការចំណាយលើបុគ្គលិក។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុង ក្រោយនេះ ក្រុមហ៊ុនបានផ្តល់សិទ្ធិតំឡើងទៅអោយក្រុមហ៊ុននៅប្រទេសភូមា។ ទំហំផលិតកម្មនៅប្រទេសនេះ កំពុងតែមានការកើនឡើង ដែលប្រទេសជប៉ុនកំពុងតែពិចារណាសាងសង់រោងចក្ររបស់ខ្លួននៅទីនោះ។ ដោយគិតពីកត្តាផ្គត់ផ្គង់ ពលករ ប្រទេសដែលត្រូវពិចារណា រួមមានវៀតណាម ភូមា និងកម្ពុជា។ ក្រុមហ៊ុនជាច្រើនបានបោះទីតាំង នៅវៀតណាមរួចហើយ ហើយពួកគេកំពុងតែសង្ស័យថាការចំណាយលើការផលិត នៅប្រទេសវៀតណាមនឹងមានការកើនឡើងទៅថ្ងៃអនាគត។ នៅប្រទេសភូមា មានក្រុមហ៊ុនជាច្រើន បានចាប់អារម្មណ៍លើការវិនិយោគនៅទីនោះ ប៉ុន្តែហានិភ័យក៏មានខ្ពស់

ដែរ ជាពិសេសការផ្គត់ផ្គង់បរិក្ខារ និងស្ថេរភាពនយោបាយ។ ចំណែកឯកម្ពុជាវិញ ក្រុមហ៊ុនទាំង នោះមិនទាន់បានធ្វើការសិក្សាស្វែងយល់អោយបានស៊ីជំរៅនៅឡើយទេ ហើយពួកគេទទួលបានពតិមានតែមួយចំនួនតូចប៉ុណ្ណោះ។ និយាយឱ្យចំទៅ ក្រុមហ៊ុនទាំងនោះមិនទាន់បានសំរេចថា តើកម្ពុជាគឺជាប្រទេសសមរម្យសំរាប់ផលិតកម្មនៅឡើយទេ។

ក្រុមហ៊ុនធំល្បីមផលិតដុំភ្លើងរបស់ជប៉ុន បានមកបោះទីតាំងនៅប្រទេសឡាវ នៅជាយទីក្រុងវៀងច័ន្ទ បន្ទាប់ពីការចំណាយនៅប្រទេសថៃចេះតែកើនឡើង។ គេបានបង្វែរការផលិតគ្រឿងបរិក្ខារមួយចំនួន (ដូចជាដុំភ្លើង) ពីរោងចក្រនៅប្រទេសថៃទៅរោងចក្រនៅប្រទេសឡាវ។ ឡាវគឺជាប្រទេសដែលមានប្រព័ន្ធអគ្គិសនីគ្រប់គ្រាន់ ដែលផ្តល់ដោយថាមពលវារីអគ្គិសនី ក៏ប៉ុន្តែថាមពលនេះមិនគ្រប់គ្រាន់ទេនៅពេលរោងចក្រដំណើរការដំបូង។ ជាលទ្ធផល ក្រុមហ៊ុនទាំងនោះជួបការលំបាកជាច្រើននៅក្នុងដំណើរការបង្កើនផលិតកម្មរបស់ខ្លួន។ កម្ពុជាក៏អាចទាក់ទាញអ្នកវិនិយោគទាំងនោះបានដែរ បើសិនជាកម្ពុជាអាចកែលំអបរិស្ថានវិនិយោគអោយបានល្អ។

*(៣) ការតំឡើងផលិតផលអគ្គិសនីតូចៗ*

ផលិតផលប្រភេទនេះ រួមមានផលិតផលសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដូចជាប្រដាប់សំងួតសក់ និងផលិតផលតូចៗផ្សេងទៀតដែលទាក់ទងនឹងពន្លឺភ្លើង។ បរិក្ខារទាំងអស់នេះមានតំលៃថោកៗ អាចប្រកួតប្រជែងជាមួយប្រទេស ចិន ដែលកំពុងតែមានច្រើនឡើងៗនៅលើទីផ្សារអន្តរជាតិ។ ដូចនេះ ផលិតករកំពុងតែសំលឹងមើលប្រទេសណា ដែលមានការចំណាយលើកំលាំងពលកម្មថោកជាងក្នុងផលិតកម្ម។ ក្រុមហ៊ុនជប៉ុន (ដែលមានទីតាំងភាគច្រើននៅប្រទេសថៃ) និងក្រុមហ៊ុនរបស់អាស៊ាន (ថៃ និងម៉ាឡេស៊ី) អាចនឹងបែងចែកទំហំផលិតកម្មរបស់ខ្លួន មកក្នុងប្រទេសជិតខាងខ្លះទៀត។ ផលិតផលទាំងនេះមានប្រើប្រាស់ដែក និងប្លាស្ទិកសំរាប់ផលិត ហើយចាំបាច់ត្រូវតែមានការវិនិយោគ លើបរិក្ខារដែលមានជាតិអំបោះ ដូចជាកុងតាក់សំរាប់បិទបើក និងពុម្ពសំរាប់ចាក់។ ការផលិតសំភារៈទាំងនេះត្រូវមានថាមពលអគ្គិសនីគ្រប់គ្រាន់ ដើម្បីអោយដំណើរការផលិតកម្មប្រព្រឹត្តទៅបានល្អ។

នាពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនឧស្សាហកម្មទាំងអស់ គួរតែធ្វើការផលិតបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំនៅក្នុងរោងចក្រជាមួយគ្នា។ ថ្វីបើលទ្ធភាពនៃដំណើរការកែច្នៃនូវបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំ នៅក្នុងរោងចក្រនៅខាងក្រៅមានភាពរលូនក្តី ដូចជានៅប្រទេសថៃ និងប្រទេសផ្សេងទៀត (ប្រសិទ្ធិភាពនៃការនាំចូលសំភារៈបរិក្ខារ) វានឹងក្លាយជាកត្តាសំខាន់សំរាប់ការសំរេចជ្រើសរើសទីតាំង។ ដើម្បីរក្សាការចំណាយអោយនៅទាបសំរាប់រយៈពេលវែង ចាំបាច់ត្រូវតែមានរោងចក្រនៅតាមមូលដ្ឋាន ដែលអាចដើរតួនាទីក្នុងការផ្គត់ផ្គង់សំភារៈបរិក្ខារ ដល់ដំណើរការផលិតកម្ម (ទោះបីជារោងចក្ររបស់ប្រទេសនោះក្តី ឬជាសាខារោងចក្របរទេសក៏ដោយ) ដើម្បីកាត់បន្ថយការនាំចូលសំភារៈបន្ទាប់បន្សំនិងបរិក្ខារផ្សេងៗសំរាប់ផលិតកម្ម។ ដូចនេះ ចំណុចសំខាន់ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ នៅក្នុងឧស្សាហ

កម្មនេះ គឺការរៀបចំអោយមានតំបន់ឧស្សាហកម្ម ដែលមានភ្លើងអគ្គិសនី ដំណើរការគ្រប់គ្រាន់ និងតំបន់អាទិភាពសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធល្អសំរាប់ដឹកជញ្ជូនកុងតឺន័រ និងលទ្ធភាពនៃការរៀបចំជាកំរង ក្រុមហ៊ុនឧស្សាហកម្មទ្រទ្រង់ទៅថ្ងៃអនាគត។

*(៤) ការតំឡើងផលិតផលពាក់កណ្តាលសំរេច (ម៉ូឌុលសំរាប់ម៉ាស៊ីនថតរូប BLUs និងប្រដាប់ផ្គត់ផ្គង់ភ្លើង)*

គេស្គាល់ជារួមថា ឧបករណ៍ពតិមានឌីជីថល (digital) ដូចជា ទូរទស្សន៍អិលស៊ីឌី ទូរស័ព្ទចល័ត ម៉ាស៊ីនថតរូបឌីជីថល និងម៉ាស៊ីនចាក់សំលេងឌីជីថល គឺជាឧបករណ៍ដែលមានតំរូវការកើនឡើងនៅទូទាំងពិភពលោក។ ផលិតផលទាំងនេះ មានសៀគ្វីនិងប្លុកជាសម្ព័ន្ធដើម្បីបំពេញតួនាទីច្រើន ដែលបានបង្កើតជាម៉ូឌុលផ្សេងៗ ដូចជា ម៉ូឌុលម៉ាស៊ីនថត (CCD), BLUs និងឧបករណ៍ផ្គត់ផ្គង់ភ្លើង។ ការផលិតគ្រឿងម៉ូឌុលទាំងនេះគឺជាការផលិតដែលពិបាកធ្វើដោយស្វ័យប្រវត្តិណាស់ ដោយសារតែវាមានច្រើនប្រភេទ និងចំនួនច្រើន។ ជាក់ស្តែង គេត្រូវការកំលាំងពលកម្មច្រើនក្នុងផលិតកម្ម ពិសេសនៅពេលដែលមានតំរូវការផលិតផលបែបនេះកាន់តែច្រើនឡើង។ ការផ្គត់ផ្គង់ មិនទាន់បានគ្រប់គ្រាន់ទេ ដោយសារការលំបាកក្នុងការរកទីតាំងដើម្បីដំណើរការផលិតកម្ម។ ផលិតករកំពុងតែសាង សង់រោងចក្របន្ថែមនៅប្រទេសចិន និងប្រទេសមួយចំនួននៅអាស៊ាន ហើយលើសពីនេះទៀតគេបានផ្តល់ទៅអោយក្រុមហ៊ុនខាងក្រៅ ដែលផលិតឧបករណ៍អគ្គិសនី/អេឡិចត្រូនិកផ្សេងទៀត ឱ្យជួយផលិត។

ទោះបីជាការដឹកជញ្ជូនតាមផ្លូវទឹក គឺជាមធ្យោបាយដែលគេនិយមប្រើសំរាប់ការនាំចេញសំភារៈបរិក្ខារ និង គ្រឿងអគ្គិសនីក៏ដោយការដឹកទៅអោយអ្នកប្រើប្រាស់ (ផលិតករដែលត្រូវផលិតបង្ហើយ) ច្រើនតែធ្វើឡើងដោយយន្តហោះ(យន្តហោះសំរាប់ដឹកទំនិញអន្តរជាតិ) ព្រោះវាមានតំរូវការខ្លាំង ដើម្បីធ្វើការចែកចាយអោយបានឆាប់រហ័ស។ ប្រព័ន្ធចែកចាយរបស់កម្ពុជាបច្ចុប្បន្ន មិនអាចឆ្លើយតបទៅនឹងតំរូវការបែបនេះបានទេ ដែលជាចំណុចអវិជ្ជមានមួយមិនអាចទាក់ទាញការវិនិយោគបរទេសផ្ទាល់បាន។ ប៉ុន្តែ ការសាងសង់តំបន់ឧស្សាហកម្ម ដែលបំពាក់ដោយមុខងារនៃតំបន់កែច្នៃនាំចេញ (តំបន់សេដ្ឋកិច្ចពិសេស) និងការកែលំអរភស្តុភារអន្តរជាតិ ក្រុមហ៊ុនទាំងនោះ អាចបោះទីតាំងរោងចក្រនៅកម្ពុជាបានយ៉ាងប្រសើរ ជាមួយនឹងឧត្តមភាពនៃតំលៃពលកម្មថោក ដូចជាតំរូវការជាសកលបន្តពង្រីក។

*(៥) ការតម្លើងឧបករណ៍ទំនាក់ទំនងពតិមាន (ព្រីនធឺ ទូរស័ព្ទចល័ត ។ល។)*

តំរូវការសំរាប់ឧបករណ៍ទំនាក់ទំនងពតិមាន រួមទាំងឧបករណ៍ដ៏ទៃទៀតដែលគេស្គាល់ជារួមថា ឧបករណ៍ពតិមានឌីជីថល កំពុងតែមានតំរូវការច្រើននៅក្នុងប្រទេសអភិវឌ្ឍន៍ និងទីផ្សារដែលកំពុងតែលេចធ្លោរ ដូចជានៅ ប្រេស៊ីល សូវៀត និង ឥណ្ឌា និងចិន (BRICs)។ នៅក្នុងដំណើរការនេះ ទីផ្សារអន្តរជាតិកំពុងតែរីកធំឡើង។ ហេតុផលនេះ បានធ្វើអោយក្រុមហ៊ុនពាក់ព័ន្ធនឹងបន្តរកទីតាំងផលិតកម្ម ដែលធ្វើអោយផលិតផលគេអាចប្រកួតប្រជែងបានក្នុងការតំឡើង ទោះបីជាគ្រឿងសំខាន់ៗត្រូវផ្តល់មកពីប្រទេសផ្សេងទៀតក៏ដោយ។ ហើយប្រាកដណាស់ថា ទីតាំងទាំងនោះនឹងមិនស្ថិតនៅក្នុង

ប្រទេសចិនទៀតទេ។ ផលិតកម្មផ្នែកខ្លះអាចនឹងត្រូវបង្វែរទៅប្រទេស វៀតណាម និងទៅប្រទេសនៅអាស៊ានផ្សេងទៀត និង BRICs។ នៅក្នុងដំណើរការនេះ ប្រទេសកម្ពុជាអាចនឹងក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានទីតាំងសំរាប់ផ្គត់ផ្គង់។

ជាតួយ៉ាងការបោះទីតាំង អាចនឹងឃើញមាននៅតំបន់ហ៊ួណាន និងហ៊្គួដុងនៃប្រទេសចិន ប៉ុន្តែផលិតកម្មរបស់គេក៏បានផ្លាស់ទៅប្រទេសវៀតណាមដែរ (ដូចជាតំបន់ឧស្សាហកម្មថាំងឡុង នៅហាណូយជាដើម) នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ និយាយអោយចំទៅ មានក្រុមហ៊ុនកាណុងបានមកបោះទីតាំងនៅប្រទេសវៀតណាម ដើម្បីផលិតព្រីនធឺដែលមានតំលៃថោក និងបានសាងសង់រោងចក្រចំនួន ៣ តែក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ។ ក្រៅពីការបង្កើន ការងារ និងការនាំចេញ ផលិតផលនេះបានមាន ឥទ្ធិពលយ៉ាងខ្លាំងក្នុងការទាក់ទាញក្រុមហ៊ុនផ្សេងទៀត ដែលផលិត ផ្នែកផ្សេងៗ និងសំភារៈបន្ទាប់បន្សំ។ CANNON បានសំរេចបោះទីតាំងនៅវៀតណាម ទោះបីជាមានរោងចក្រដ៏ធំនៅ ប្រទេសចិន និងថៃហើយក៏ដោយ។ ការសំរេចបែបនេះ ធ្វើឡើងដោយកាណុងត្រូវបន្ថែមទីតាំងផលិតកម្មរបស់ខ្លួន នៅពេលមុខជំនួញមានការរីកចំរើន និងដោយកត្តាផ្សេងៗជាច្រើនទៀត។ កត្តាទាំងនេះរួមមានស្ថិរភាពនយោបាយនៅក្នុងប្រទេស ការកែលំអទំនាក់ទំនងជាមួយនឹងមហាអំណាចសេដ្ឋកិច្ច ដូចដែលបានបង្ហាញតាមរយៈសមាគមន៍ ពាណិជ្ជកម្មសេរីនៅអាស៊ី កិច្ចព្រមព្រៀងជាមួយសហរដ្ឋអាមេរិក និងការបានចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក។ CANNON ក៏ត្រូវបានគេលើកទឹកចិត្ត ដោយការរីកចំរើនក្នុងការអភិវឌ្ឍន៍តំបន់ឧស្សហកម្ម និងបណ្តាញដឹកជញ្ជូន និងការកែលំអច្បាប់ និងនីតិវិធីវិនិយោគសំរាប់ការនាំចេញ-នាំចូល។

ប្រទេសកម្ពុជាយឺតយ៉ាវក្នុងការសាងសង់តំបន់ឧស្សាហកម្ម ដែលបំពាក់ដោយបណ្តាញអគ្គិសនី ឧបករណ៍ទំនាក់ទំនងគ្រប់គ្រាន់ និងមុខងាររបស់ EPZ (SEZ)។ ហេតុផលនេះ បានធ្វើអោយកម្ពុជាលំបាកទាក់ទាញការមកបោះទីតាំងរបស់រោងចក្រធំៗសំរាប់តំឡើងឧបករណ៍ទំនាក់ទំនងពតិមាន។ នៅប្រទេសវៀតណាម គេត្រូវការពេលវេលាជាច្រើនដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធទន់ (ដូចជាច្បាប់/គោលនយោបាយធនធានមនុស្ស) និងហេដ្ឋារចនាសម្ព័ន្ធរឹង (ដូចជា ផ្លូវដឹកជញ្ជូន/បណ្តាញទឹក ភ្លើង)។ គេត្រូវការពេលវេលាចំនួន ៥ឆ្នាំ បន្ទាប់ពីការបោះទីតាំងរបស់ក្រុមហ៊ុនផលិតដុំភ្លើង និងប្រដាប់ទប់ភ្លើង ហើយដែលអាចទាក់ទាញក្រុមហ៊ុនកាណុង មកតំឡើងឧបករណ៍ទំនាក់ទំនងព័តិមាននេះ។ ដូចនេះ ទោះបីកម្ពុជាអាចបំពេញនូវល័ក្ខខ័ណ្ឌនានាបានក៏ដោយ ក៏កម្ពុជាមិនត្រូវសង្ឃឹមថានឹងអាចទាក់ទាញក្រុមហ៊ុនទាំងនេះមក នៅមុនឆ្នាំ ២០១០ ឬ ២០១៥ នោះដែរ។

## ៨.២ ទស្សនៈវិស័យសំរាប់ឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិកនៅកម្ពុជា : ការផ្លាស់ប្តូរនៅក្នុង បរិស្ថានវិនិយោគអន្តរជាតិ (សំខាន់វិនិយោគិនជប៉ុន) និងសេណារីយ៉ូសំរាប់ការអភិវឌ្ឍន៍រយៈពេលមធ្យម និងវែង

### ៨.២.១ ការផ្លាស់ប្តូរបរិស្ថានវិនិយោគនៃឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គីសនី

**(១) និន្នាការនៃការវិនិយោគបរទេសផ្ទាល់នៅអាស៊ាន**

រហូតមកដល់ដើមទសវត្សរ៍ទី ៨០ ក្រុមហ៊ុនជប៉ុនបានធ្វើការវិនិយោគលើការផលិតគ្រឿងអគ្គិសនីនៅតាមផ្ទះ និងគ្រឿងបរិក្ខារផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយផលិតជំនួសការនាំចូល នៅក្នុងចំណោមប្រទេសអាស៊ានដែលមានការរីកចំរើនជាងគេ។ ក្រុមហ៊ុនជប៉ុនទាំងនេះបានបង្វែរការនាំចេញផលិតផល និងគ្រឿងបរិក្ខារទៅ អឺរ៉ុប និងអាមេរិកខាងជើង បណ្តាលមកពីមានការប្រែប្រួលនៃគោលនយោបាយឧស្សាហកម្មរបស់ប្រទេសអាស៊ាន ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស សំរាប់លើកកំពស់ការនាំចេញ និងការធ្លាក់ចុះនៃការប្រកួតប្រជែងជាអន្តរជាតិនៃផលិតផលនៅក្នុងប្រទេសជប៉ុន ដោយសារមានការចំណាយច្រើនទៅលើកំលាំងពលកម្ម និងការប្រែប្រួល នៃការប្តូរប្រាក់ដុល្លារអាមេរិក-យេន។ កិច្ចព្រមព្រៀងផ្លាហ្សាឆ្នាំ ១៩៨៥ បានធ្វើអោយតំលៃលុយយេនឡើងថ្លៃ។ ដើម្បីរក្សាការប្រកួតប្រជែងតំលៃ ក្រុមហ៊ុនជប៉ុនបានផ្លាស់ប្តូរការផលិតរបស់គេមកនៅប្រទេសអាស៊ាន ដែលក្រុមហ៊ុនទាំងនោះបានធ្វើការវិនិយោគរួចមកហើយ ដូចជានៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ។ ទន្ទឹមនឹងនេះដែរ ប្រទេសអាស៊ានបានខិតខំប្រឹងប្រែងដើម្បីរៀបចំច្បាប់ស្តីពីមូលធនបរទេសនិងហេដ្ឋារចនាសម្ព័ន្ធ។ ទង្វើបែប នេះបានប្រែក្លាយប្រទេសម៉ាឡេស៊ី អោយទៅជាមជ្ឈមណ្ឌលដ៏ធំមួយសំរាប់ផលិតកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិច និងគ្រឿងបរិក្ខារ និងការកែច្នៃផ្សេងៗទៀត ភាគច្រើនជាគំនិតច្នៃប្រឌិតរបស់ក្រុមហ៊ុនជប៉ុន។

**រូបភាព ៨-២-១ ការវិនិយោគរបស់ជប៉ុននៅប្រទេសអាស៊ានសំរាប់ឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក (គិតដល់ឆ្នាំ ២០០៤)**



Source: MOF in Japan

គ្រឿងបរិក្ខារអគ្គិសនីជាច្រើនប្រភេទត្រូវបានគេដាក់លក់នៅទីផ្សារអាស៊ាន។ នេះគឺជាលទ្ធផលនៃការបង្កើតរោងចក្រតំឡើងឧបករណ៍ទំនាក់ទំនងពត៌មាន (ជាពិសេសហាតឌីស HDDs និងឧបករណ៍បន្ទាប់បន្សំផ្សេងៗទៀត) និងគ្រឿងអគ្គិសនីប្រើប្រាស់ក្នុងផ្ទះផងដែរ។ ការបោះទីតាំងនៅក្នុងប្រទេសអាស៊ានបានរីកដុះដាល ចាប់ផ្តើមពីប្រទេសសិង្ហបូរី ទៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ ហើយបន្ទាប់មកទៀតប្រទេស ឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម។ វាមានបញ្ហាលំបាកមួយចំនួន ក្នុងការជ្រើសរើសពលករដែលមានតំលៃថ្លៃឈ្នួលថោកនៅប្រទេសសិង្ហបូរី ម៉ាឡេស៊ី និងថៃ។ ចំណែកឥណ្ឌូនេស៊ី និងហ្វីលីពីន មានបញ្ហាអសន្តិសុខនយោបាយសង្គម។ ថ្មីៗនេះ ការវិនិយោគនៅប្រទេសចិនក៏មានហានិភ័យ

ច្រើនដែរ។ នៅក្នុងបរិយាកាសបែបនេះ ក្រុមហ៊ុនជប៉ុនបានចាប់ផ្តើមធានានូវភាពប្រកួតប្រជែងរបស់គេដោយសារការពង្រីកសាខាផលិតកម្មដែលប្រើប្រាស់ទាំងទុន និងបច្ចេកទេស ដែលគេបាន វិនិយោគនៅអាស៊ាន។

**(២) ការរីករាលដាលនៃហានិភ័យដែលភ្ជាប់ទៅនឹងប្រពលភាពវិនិយោគនៅចិន**

ទាក់ទងនឹងហានិភ័យនៃការវិនិយោគនៅប្រទេសចិន ក្រុមហ៊ុនជប៉ុនចាប់ផ្តើមកំណត់ទីតាំងដើម្បីប្រគល់សិទ្ធិផលិត នៅក្នុងតំបន់ហ៊ូណាន ដែលពីដំបូងតាមរយៈទីក្រុងហុងកុង។ កាលដើមពាក់កណ្តាលទសវត្សរ៍ទី៩០ ក្រុមហ៊ុនជប៉ុនបានចាប់ផ្តើមផ្លាស់ទីតាំងក្នុងទ្រង់ទ្រាយធំទៅកាន់តំបន់សេដ្ឋកិច្ចពិសេស អោយស្របទៅនឹងបំរែបំរួលរបស់ចិនឆ្ពោះ ទៅកាន់សេដ្ឋកិច្ចទីផ្សារសេរី។ ការវិនិយោគដោយក្រុមហ៊ុនជប៉ុននៅប្រទេសចិនមានការរីកចំរើនខ្លាំង នៅពេលដែលប្រទេសចិន បានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅដើមទសវត្សរ៍ទី២០ និងការខិតជិតមកដល់នៃកីឡាអូឡាំពិកនៅទីក្រុងប៉េកាំងនៅឆ្នាំ ២០០៨។ ទោះបីជាយ៉ាងនេះក៏ដោយ ហានិភ័យទាក់ទងទៅនឹងការវិនិយោគមានការកើនឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការវិវត្តនានា ដែលរួមមានការគំរាមកំហែងដោយ ជំងឺសារ និងគ្រុនផ្តាសាយបក្សី កង្វះថាមពលអគ្គិសនី ការបិទការហូរចូលប្រាក់យ៉ាន់ (Yuan) ការតវ៉ាប្រឆាំងនឹងជប៉ុន ដែលកើតឡើងពីការសង្ស័យអំពីវិប្បសារីរបស់ជប៉ុនលើសង្គ្រាម (ការតវ៉ានេះបណ្តាលមកពីដំណើរទស្សនៈកិច្ចរបស់ នាយករដ្ឋមន្ត្រី ជប៉ុនកូអ៊ីហ្សូមីទៅកាន់ប្រាសាទយ៉ាស៊ូគូនី) ការប្រឆាំងនឹងការចង់ចូលរបស់ជប៉ុន ជាសមាជិកក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ទំនាស់ពលករដែលបណ្តាលមកពីការទាមទារសុំអោយមានល័ក្ខខ័ណ្ឌការងារកាន់តែប្រសើរ និងការកែតំរូវគោលនយោបាយវិនិយោគបរទេសផ្ទាល់ (ការកាត់បន្ថយការលើកទឹកចិត្តក្នុងការវិនិយោគ)។ សំរាប់ក្រុមហ៊ុនជប៉ុន ហានិភ័យនៅប្រទេសចិន អាចនឹងមានការកើនឡើងជាបន្តបន្ទាប់។ ជាពិសេសការធ្លាក់ចុះនៃល័ក្ខខ័ណ្ឌការងារ និងបញ្ហាទាក់ទងការទទួលខុសត្រូវ កាលពីសម័យសង្គ្រាម (ដែលបញ្ហានេះមានតែសំរាប់ក្រុមហ៊ុន ជប៉ុនប៉ុណ្ណោះ) អាចក្លាយទៅជាបញ្ហានយោបាយសង្គមកាន់តែធ្ងន់ធ្ងរទៅៗ។

នៅដើមទសវត្សរ៍ទី ២០ ហានិភ័យ ដែលទាក់ទងទៅនឹងការវិនិយោគធំៗរបស់ជប៉ុននៅប្រទេសចិន បានចាប់ផ្តើមប្រាកដឡើង។ ដើម្បីជាការឆ្លើយតប ក្រុមហ៊ុននាំចេញមួយចំនួនដែលបានវិនិយោគដ៏ច្រើននៅប្រទេសចិនបានបង្វែរទិសដៅនៃការពង្រីកផលិតកម្មបន្ថែមទៅបណ្តាប្រទេសក្នុងតំបន់អាស៊ានដើម្បីកាត់បន្ថយហានិភ័យ។

ប្រទេសវៀតណាមជាប្រទេសដែលក្រុមហ៊ុននាំចេញមានទីតាំងក្នុងប្រទេសចិនមានការចាប់អារម្មណ៍ជាពិសេសក្នុងចំណោមក្រុមហ៊ុនជប៉ុនតែម្តង។ ការវិនិយោគនៅក្នុងប្រទេសវៀតណាមអាចនឹងមានការរីកចំរើន អាស្រ័យទៅលើកំរិតនៃហានិភ័យដែលកើតមានឡើងជាក់ស្តែងនៅប្រទេសចិន។ នៅក្នុងដំណើរការនេះ ប្រទេសវៀតណាមអាចប្រែក្លាយទៅជាមជ្ឈមណ្ឌលនៃផលិតកម្ម ក្នុងចំណោមបណ្តាប្រទេសអាស៊ាន ជាពិសេសនៅពេលដែល ក្រុមហ៊ុនជប៉ុនពង្រីកការិយាល័យពលកររបស់គេក្នុងតំបន់។

## (៣) ការពង្រីកការបែងចែកពលករសំរាប់ផលិតកម្មជប៉ុនក្នុងតំបន់អាស៊ាន

ឈរលើមូលដ្ឋាននៃការកើនឡើងមិនឈប់ឈរ ការវិនិយោគនៅក្នុងបណ្តាប្រទេសអាស៊ានអាចមានច្រើនជាងការវិនិយោគនៅប្រទេសចិន ដោយគិតទាំងចំនួនទឹកប្រាក់ និងចំនួនគំរោងវិនិយោគ។ ការវិនិយោគនេះបានបង្កើតជាស្តុកនៃទ្រព្យសម្បត្តិដ៏ច្រើនមហិមា។ លើសពីនេះទៀត ការបោះទីតាំងបានចាប់ផ្តើមពីដំបូង ហើយការចំណាយលើសំភារៈបរិក្ខារសំរាប់ផលិតជាច្រើន ត្រូវបានសងរំលោះជាបណ្តើរៗរួចហើយ។ ដោយគិតពីការលេចឡើងនៃទីផ្សារនៅអាស៊ានការដកថយរបស់ក្រុមហ៊ុនទាំងនេះគឺជាអ្វីដែលគេនឹកស្មានមិនដល់។ ការដកថយនេះគឺបណ្តាលមកពីហានិភ័យដែលចេះតែកើនឡើងមិនឈប់ឈរនៅប្រទេសចិន។ ក្នុងចំណោមបណ្តាប្រទេសអាស៊ានទាំងអស់ ប្រទេសសិង្ហបុរី និងម៉ាឡេស៊ីមានក្រុមហ៊ុនផលិតឧបករណ៍អេឡិចត្រូនិច និងព័ត៌មានវិទ្យាជាច្រើន ហើយថ្មីៗនេះ ការបោះទីតាំងរបស់ក្រុមហ៊ុនទាំងនោះ នៅប្រទេសថៃក៏មានការកើនឡើងច្រើនដែរ។ និន្នាការនេះលើសពីការហូរ ចូលផលិតកម្មពីប្រទេសម៉ាឡេស៊ីទៅប្រទេសថៃ ឬការវិនិយោគបន្ថែមនៅប្រទេសថៃ។ ការផ្លាស់ប្តូរនេះត្រូវបានគេធ្វើឡើងដើម្បីបែងចែកកំលាំងពលកម្មផលិតនៅក្នុងតំបន់ដោយប្រើប្រាស់ស្តុកដែលមានស្រាប់។ លើសពីនេះទៀត ការបែងចែកនេះ ត្រូវបានគេរៀបចំឡើងដើម្បីបង្កើតទីតាំងអភិវឌ្ឍសមត្ថភាព និងដំណើរការ VA ខ្ពស់នៅប្រទេសម៉ាឡេស៊ី និងការពង្រីកទ្រង់ទ្រាយធំនៃសំភារៈមេកានិចនៅប្រទេសថៃ។

**រូបភាព ៨-២-២ វិនិយោគជប៉ុនចំពោះប្រទេសចិន/អាស៊ាន/ឥណ្ឌា សំរាប់ឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក**




មានការវិនិយោគយ៉ាងច្រើននៅប្រទេសថៃ នៅប៉ុន្មានឆ្នាំចុងក្រោយនេះក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក។ ប្រទេសថៃបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសំរាប់ការវិនិយោគដែលផ្តល់ផលប្រយោជន៍មកវិញធ្វើឱ្យប្រទេសថៃមានចំណាត់ថ្នាក់ខ្ពស់សំរាប់ការវិនិយោគ។ ប្រទេសម៉ាឡេស៊ីមានចំនួនប្រជាជនតិចជាង ហើយរក្សានូវគោលនយោបាយដែលលំអៀងទៅជនជាតិម៉ាឡេស៊ី។ ដូចនេះប្រទេសម៉ាឡេស៊ី ត្រូវពឹងផ្អែកលើកម្មករបរទេស។ ផ្ទុយទៅវិញ ប្រទេសថៃមានចំនួនប្រជាជនច្រើនជាង ហើយអាចមានលទ្ធភាពក្នុងការផ្តល់ពលករដែលមានថ្លៃឈ្នួលទាប។ លើសពីនេះទៀត ប្រទេសថៃបានរក្សាគោលនយោបាយនៃការវិនិយោគផ្ទាល់ពីបរទេស អោយនៅស៊ីសង្វាក់គ្នា មានមូលដ្ឋានគ្រឹះរឹងមាំសំរាប់

ឧស្សាហកម្មគ្រឿងចក្រ ដែលមានទំនាក់ទំនងជាមួយប្រទេសជប៉ុន និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលអាចដំណើរការបានល្អ។ ដូចនេះ ប្រទេសថៃមានសក្តានុពលខ្លាំងក្នុងការវិវត្តន៍ទៅមុខ ប៉ុន្តែ ប្រទេសថៃក៏មានការលំបាកក្នុងការជ្រើសរើសវិស្វករដែលមានទេពកោសល្យខ្ពស់ និងបុគ្គលិកផ្សេងទៀត ដើម្បីបំរើការងារនៅក្នុងក្រុមហ៊ុនឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ពីព្រោះតែការរីកចំរើនឧស្សាហកម្មយានយន្តនៅប៉ុន្មានឆ្នាំ ចុងក្រោយនេះ។

ដើម្បីឈ្នះក្នុងការប្រកួតប្រជែងតំលៃនៅប្រទេសចិន ក្រុមហ៊ុនជប៉ុនដែលមានទីតាំងនៅបណាប្រទេសអាស៊ាន ត្រូវតែរៀបចំឡើងវិញនូវការបែងចែកពលករ ដោយការប្រមូលស្តុកពីការវិនិយោគដែលគេបានសន្សំនៅក្នុងតំបន់នេះ។ ការបង្កើតអោយមានការបែងចែកពលកម្ម ត្រូវគេរំពឹងថានឹងបន្តទៅទៀត ដោយសារការកើនឡើងនៃទីផ្សាររួមគ្នានៅតំបន់ពាណិជ្ជកម្មសេរីនៅអាស៊ាន។ ការកាត់បន្ថយពន្ធនៃការនាំចូល នៅក្នុងអន្តរតំបន់ពង្រឹងលទ្ធភាពលំហូរទុនពីប្រទេស ដែលមានតំលៃពលកម្មខ្ពស់ ទៅប្រទេសដែលមានតំលៃពលកម្មទាបសំរាប់សកម្មភាពផលិតកម្ម។ ការវិនិយោគនៅប្រទេសថៃបានកើនឡើងកាលពីពេលថ្មីៗនេះ ប៉ុន្តែប្រទេសដែលមានសក្តានុពលបំផុតនៅឆ្នាំខាងមុខគឺប្រទេសវៀតណាម។ នៅក្នុងការទំនាក់ទំនងជាមួយជប៉ុន ប្រទេសវៀតណាមបានកែលំអបរិយាកាសវិនិយោគយ៉ាងខ្លាំង ជាពិសេសចាប់តាំងពីការអនុវត្តគំរោងផ្តួចផ្តើមគំនិតរួមគ្នារវាងជប៉ុន និងវៀតណាម ដែលចាប់ផ្តើមតាំងពីឆ្នាំ ២០០០។ និន្នាការនេះនឹងបន្តទៅទៀតជាមួយនឹងការក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោករបស់ វៀតណាម នៅឆ្នាំ ២០០៦។ ប្រហាក់ប្រហែលគ្នានេះដែរ វៀតណាមបានអនុម័តកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយនឹងសហរដ្ឋអាមេរិក ហើយកំពុងតែដំណើរការនាំចេញទៅកាន់សហរដ្ឋអាមេរិក។ ក្នុងប្រទេសវៀតណាម ទីផ្សារក្នុងស្រុក នឹងចាប់ផ្តើមដំណើរការដោយខ្លួនឯង ប៉ុន្តែការរីកចំរើននៃឧស្សាហកម្មនាំចេញគឺជាអាទិភាព ដែលរដ្ឋាភិបាលកំពុងតែ យកចិត្តទុកដាក់។ ការវិនិយោគដោយក្រុមហ៊ុនជប៉ុន ជាពិសេសនៅក្នុងវិស័យឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិច ត្រូនិកកំពុងតែរីកដុះដាល ដូចដែលបង្ហាញអោយឃើញការសាងសង់រោងចក្រថ្មីសំរាប់ផលិតគ្រឿងអគ្គិសនីប្រើប្រាស់ នៅក្នុងផ្ទះ បរិក្ខារទំនាក់ទំនង និងគ្រឿងអគ្គិសនីផ្សេងទៀតដោយឧស្សាហកម្មអគ្គិសនីម៉ាស៊ូស៊ីតា និងការបោះទីតាំង ដោយក្រុមហ៊ុនចែកចាយគ្រឿងបន្លះម៉ាស៊ីន ទៅអោយរោងចក្រម៉ាស៊ីនបោះពុម្ពម៉ាកកាណុង។ ការវិនិយោគដោយ ក្រុមហ៊ុនផ្សេងក្រៅពីក្រុមហ៊ុនជប៉ុន (ដូចជាសាំស៊ុង និងក្រុមហ៊ុនកូរ៉េផ្សេងទៀត និងក្រុមហ៊ុនទូរស័ព្ទដូចជា Intel) ក៏កំពុងតែទទួលបាននូវការយកចិត្តទុកដាក់ខ្លាំងដែរ។

និន្នាការនៃការបង្កើតអោយមានការបែងចែកកំលាំងផលិតនៅតំបន់អាស៊ានដោយក្រុមហ៊ុនជប៉ុន កំពុងតែដំណើរការទៅមុខយ៉ាងឆាប់ដោយការហូរចូលនៃការវិនិយោគពីប្រទេសសិង្ហបូរីនិងប្រទេសម៉ាឡេស៊ីទៅប្រទេសថៃនិងក្រោយមកទៅប្រទេសវៀតណាម។ បរិយាកាសនៃការវិនិយោគនៅប្រទេសឥណ្ឌូណេស៊ី និងហ្វីលីពីនក៏ជាប្រទេស ដែលគេបានយកចិត្តទុកដាក់តាំងពីទសវត្សរ៍ទី ៨០ ហើយក៏មានការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងប្រទេសទាំងនេះដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពអសន្តិសុខនយោបាយសង្គមគឺជាឧបសគ្គនៅក្នុងការបែងចែកកំលាំង ពលកម្មផលិតដោយក្រុមហ៊ុន

ជប៉ុន។ ប្រទេសភូមាក៏មានសក្តានុពលច្រើនដែរ សំរាប់ការអភិវឌ្ឍទៅថ្ងៃអនាគត ប៉ុន្តែវត្តមាននៃរបបយោធា និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ដោយប្រទេសលោកខាងលិចគឺជាការបន្ទុចបង្អាក់មិនអោយ មានការបោះទីតាំងវិនិយោគដោយក្រុមហ៊ុនបរទេស។ ចំណែកឯប្រទេសកម្ពុជា និងឡាវវិញ គេនៅដឹងមិនទាន់ច្បាស់ នៅឡើយអំពីតួនាទីដែលប្រទេសនេះ ត្រូវបំពេញនៅក្នុងការបែងចែកកំលាំងពលកម្មផលិតកម្ម។ ដោយមានចំនួន ប្រជាជនតិចតួច ប្រទេសឡាវមានសក្តានុពលតិចតួចណាស់នៅក្នុងការអភិវឌ្ឍន៏។ ប្រទេសកម្ពុជាស្ថិតនៅចន្លោះ រវាងថៃ និងវៀតណាម ហើយអាចបំពេញនូវល័ក្ខខ័ណ្ឌដែលទាមទារ ដោយក្រុមហ៊ុនឧបករណ៏អគ្គិសនី/អេឡិចត្រូនិក ជប៉ុន សំរាប់ការបែងចែកកំលាំងផលិតកម្មនេះដរាបណាបរិយាកាសនៃការវិនិយោគមានការកែលំអអោយកាន់តែ ប្រសើរឡើង។

តារាង ៨-២-១ ចរិតលក្ខណៈនៃក្រុមហ៊ុនផលិតគ្រឿងអគ្គីសនី/អេឡិកត្រូនិកនៅអាស៊ាន

| | **Status of the Japanese industrial build up in major countries** | | | | **Characteristics of the build up of Japanese firms** |
|---|---|---|---|---|---|
| | Singapore | Malaysia | Thailand | Vietnam | |
| Audio & Visual Equipment | × | ◎ | ○ | △ | ・ Largest build-up in Malaysia<br>・ Much siting by component as well as set firms in Malaysia<br>・ Shift to China for production of low-cost audio products<br>・ Japanese firms in Vietnam taking aim at the Vietnamese market（TV） |
| Information Equipment | ○ | ◎ | ○ | △ | ・ Malaysia has a build-up of mass-production plants in fields enabling application of the store of technology for CD audio products, such as CD-ROMs and DVD-ROMs.<br>・ Production in Thailand is led by mechanical products such as HDDs. The country has replaced Malaysia as the world's biggest site of HDD production. |
| Communication Equipment | ○ | ○ | △ | △ | ・ Siting of plants for production of mobile telephones mainly in Malaysia.<br>・ Build up of plants by Nokia, Motorola, and EMS rather than Japanese firms |
| Home Electric Appliance | × | △ | ◎ | △ | ・ Build up of plants in Thailand under a strategy of selection and concentration after the economic crisis (rearrangement and consolidation in shift of orientation from import replacement to export)<br>・ Firms sited in Vietnam are currently selling to the domestic market and exporting to Japan (possibility of eventual growth into a huge production center for white goods). |
| Active Component | ○ | ○ | ○ | × | ・ For semiconductors, Japanese firms (like European and North American firms) have sited back-end processes (assembly) in Singapore, Malaysia, and Thailand.<br>・ Malaysia and Thailand have CRT plants, but the demand for these is shrinking along with the trend toward FPDs. |

| | Status of the Japanese industrial build up in major countries | | | | Characteristics of the build up of Japanese firms |
|---|---|---|---|---|---|
| | Singapore | Malaysia | Thailand | Vietnam | |
| Passive Component | △ | ◎ | ◎ | △ | ・ Malaysia has a build-up of production for all kinds of components, and mainly resistors, condensers, coils, connectors, and switches (for both the domestic market and export mainly to other ASEAN countries).<br>・ Thailand has many component firms, but they generally produce items for export (PCBs, switches, transformers, etc.). |
| Cumulative number of FDI projects in the electric/ electronics industry | 346 | 395 | 373 | 47 | ・ Foreign firms (major and semi-major) that have sited in Malaysia and Thailand number about 1,000 each. There are about 5 times as many smaller firms. |

Note: ◎advancing fairly ○advancing △not advancing too much ×advancing hardly

Source: JICA Study Team

## ៨.២.២ ការបោះទីតាំងនៃការវិនិយោគបរទេសផ្ទាល់របស់កម្ពុជានៅក្នុងឧស្សាហកម្មគ្រឿងអគ្គិសនី/ អេឡិចត្រូនិក

### (១) ទស្សនវិស័យស្តីពីតំរូវការ និងការផ្គត់ផ្គង់នៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក

នៅឆ្នាំ ២០០៥ ប្រាក់ចំណូលដែលបានពីការលក់ផលិតផលអគ្គិសនី/អេឡិចត្រូនិកនៅទីផ្សារពិភពលោកមាន ចំនួន ១.៤៧ កោដិដុល្លារអាមេរិក។ ហើយការកើនឡើងត្រូវបានគេរំពឹងថានឹងមានជាមធ្យមចំនួន ៤-៥% ក្នុងមួយ ឆ្នាំៗ។ តួលេខខាងក្រោម បង្ហាញពីការទស្សទាយនៃការពង្រីកទីផ្សារអន្តរជាតិនៅឆ្នាំ ២០១០, ២០១៥ និងឆ្នាំ ២០២០។ នៅតំបន់អាស៊ានមានចំនួនតិចជាង ១១% នៃការផលិតនៅឆ្នាំ ២០០៥ ប៉ុន្តែនឹងមានការកើនឡើងចំនួន ១៣% នៅឆ្នាំ ២០២០។ ការកើនឡើងនេះនឹងបណ្តាលមកពីកំណើននៃការផលិត ដែលមានតំលៃបន្ថែមនិងការបែងចែកកំលាំងផលិតកម្ម។

**រូបភាព ៨-២-៣ ទីផ្សារសកល និងការព្យាករណ៍ចំណែកផលិតកម្មអាស៊ាននៃឧស្សាកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក**



### (២) សេណារីយ៉ូសំរាប់អោយមានការរីកចំរើនឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកនៅកម្ពុជា

តារាងបន្ទាប់បង្ហាញពីសេណារីយ៉ូឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកក្នុងរយៈពេលខ្លី មធ្យម និងយូរអង្វែង (ដល់ឆ្នាំ ២០២០)។ សេណារីយ៉ូនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើការប្រែប្រួលនៃការវិនិយោគនៅប្រទេសអាស៊ាន និងល័ក្ខខ័ណ្ឌហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ ការវិនិយោគនៅប្រទេសថៃ និងវៀតណាម នឹងបន្តការរីកចំរើនមួយរយៈទៀត មុនពេលមានការធ្លាក់ចុះវិញ។ នៅក្នុងដំណើរការបែបនេះ ការវិនិយោគរបស់ក្រុមហ៊ុនជប៉ុននៅកម្ពុជា ត្រូវបានគេសង្ឃឹមថានឹងអាចមានឡើងឆាប់រហ័ស ដោយមានល័ក្ខខ័ណ្ឌថាសួនឧស្សាហកម្មនឹងត្រូវបានសាងសង់ ហើយប្រព័ន្ធផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវបានគេកែលំអ។ ក្រុមហ៊ុនជប៉ុនដែលមានទីតាំងនៅបណ្តាប្រទេសអាស៊ាន កំពុងតែសិក្សាពីលទ្ធភាពនៃការបែងចែកផលិតកម្មនៅក្នុងតំបន់នេះ ដែលហេតុផលមួយផ្អែកគឺ ដោយសារការវាយលុករបស់ភាគីចិន។ កម្ពុជាអាចរៀបចំសេណារីយ៉ូសំរាប់ការអភិវឌ្ឍន៍អោយទៅជាប្រទេសផលិត ដើម្បីឆ្លើយតបទៅនឹងនិន្នាការនៅក្នុងតំបន់។

**តារាង ៨-២-២ សេណារីយោសំរាប់ការអភិវឌ្ឍន៍នៃឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិកនៅកម្ពុជា**

| | 2006-2010 | 2010-2015 | 2015-2020 |
|---|---|---|---|
| Changes in the ASEAN investment climate | • Promotion of AFTA among the more-developed countries<br>• Tapering off of FDI in Malaysia and Thailand | • Promotion of AFTA including the less-developed countries<br>• Extensive FDI (from Japan, US, and European firms) in Vietnam | • Promotion of FTA with countries inside and outside the ASEAN region<br>• Tapering off of FDI in Vietnam |
| Infrastructural conditioning in Cambodia | • Construction of industrial parks with EPZ functions (Sihanoukville SEZ, PPSEZ, etc.)<br>• Strengthening of organizations to promote FDI and fuller OSS capabilities | • Conditioning of the logistics infrastructure (Sihanoukville port, network of international road transport with BKK and HCMC)<br>• Conditioning of public service infrastructures (power, communications, etc.) | • Construction of additional SEZs<br>• Conditioning of the international logistics network (air cargo)<br>• Preparation of organizational capabilities for HRD and skill training |
| Prospects for siting by Japanese firms | • Assemblers of wire harnesses and coils/transformers | • Assemblers of small electric products and half-finished goods (camera modules, power sources, etc.) | Assemblers of information-communications equipment (printers, mobile telephones, etc.) and firms processing related parts and materials |

Source：JICA Study Team

### (៣) ទស្សនវិស័យអំពីលទ្ធភាពនៃការចូលរួមរបស់កម្ពុជានៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក

បច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានក្រុមហ៊ុនអគ្គិសនី/អេឡិចត្រូនិកនៅឡើយទេ។ ដោយសន្មត់ថា ការបែងចែកការផលិតនឹងចេះតែបន្តនៅក្នុងអាស៊ាន ហើយបរិយាកាសនៃការវិនិយោគនៅកម្ពុជា ការវិនិយោគផ្ទាល់ដោយក្រុមហ៊ុនជប៉ុន និងក្រុមហ៊ុនដទៃទៀត អាចនឹងបង្កើតអោយមានឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកនៅកម្ពុជា។ ជាការពិតណាស់ គ្មាននណាអាចកំណត់ពីបរិមាណផលិតកម្មដោយក្រុមហ៊ុនទាំងនេះបានទេ។ ផលិតកម្មនៅប្រទេសវៀតណាមកាលពីឆ្នាំ ២០០៥ បានកើនឡើងរហូតដល់ ២ កោដិដុល្លារអាមេរិក (ប្រហែល ០,៥% នៃចំនួនសរុបនៅអាស៊ាន)។ ហើយចំនួននេះ អាចចាត់ទុកជាចំនួនដែលកម្ពុជាត្រូវសំរេចអោយបាននៅឆ្នាំ ២០២០។ វាជាការ ប្រសើរណាស់បើកម្ពុជា

អាចទទួលបានចំណែក ១% ដូចជាប្រទេសវៀតណាម។ ចំណែកឯ 0.៥% នៅក្នុងរយៈពេល ២០ ឆ្នាំខាងក្រោយ ទើបអាចចាត់ទុកថាសមរម្យ បើពិនិត្យមើលលើស្ថានភាពកម្ពុជានាពេលបច្ចុប្បន្ន។ គេគត់សំគាល់ឃើញថា ការនាំចេញដែលមានតំលៃស្មើ ២ កោដិដុល្លារអាមេរិក គឺជាចំនួនប្រហាក់ប្រហែលនឹងការនាំចេញ នៃឧស្សាហកម្មកាត់ដេរកម្ពុជានៅឆ្នាំ ២០០៤។

**តារាង ៨-២-៣ ចំណែកផលិតកម្មក្នុងទីផ្សារសកល អាស៊ាន និងកម្ពុជា ក្នុងឧស្សាហកម្មគ្រឿង អគ្គិសនី/អេឡិកត្រូនិក**

| | 1995 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2010 | 2015 | 2020 |
|---|---|---|---|---|---|---|---|---|---|---|
| Global Market (B US$) | 984 | 1.422 | 1.367 | 1.188 | 1.275 | 1.402 | 1.470 | 1.800 | 2.210 | 2.770 |
| Asean Production (B US$) | 94 | 141 | 119 | 122 | 130 | 147 | 160 | 205 | 268 | 345 |
| Asean Production Share (% | 9.5 | 9.9 | 8.7 | 10.2 | 10.2 | 10.5 | 10.9 | 11.4 | 12.1 | 12.4 |
| Cambodia production (B US$) | | - | - | - | - | - | - | 0 | 0.5 | 1.7 |
| Cambodia Production Share (% | | - | - | - | - | - | - | 0 | 0.2 | 0.5 |

Source: JICA Study Team (Prediction on the basis of document by Reed Research Institute)

### (៤) ការគណនាទំហំនៃការវិនិយោគផ្ទាល់ពីបរទេស និងផលប៉ះពាល់សេដ្ឋកិច្ចដែលរីកសាយ

បើសិនជាឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក កម្ពុជាអាចធ្វើការនាំចេញបានដូចការប៉ាន់ស្មានខាងលើនោះ គេអាចទស្សន៍ទាយថាការវិនិយោគផ្ទាល់ពីបរទេស សរុបដោយក្រុមហ៊ុនជប៉ុន និងក្រុមហ៊ុនផ្សេងទៀតអាចកើនឡើងរហូតដល់ ១០០ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៥ និង ៣៤០ លានដុល្លារអាមេរិក នៅឆ្នាំ ២០២០។ នៅក្នុងករណីនេះ ក្រុមហ៊ុននឹងមានចំនួនពី ១៥-២០ នៅឆ្នាំ ២០១៥ និងពី ៦០-៧០ នៅឆ្នាំ ២០២០។ បុគ្គលិកអាច មានពី ២៥.០០០-៣០.០០០ នាក់ និងពី ៨០.០០០-៩០.០០០ នាក់។ ទោះបីជាការវិនិយោគមានទ្រង់ទ្រាយតូចជាង ការវិនិយោគនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ក៏ការវិនិយោគនៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកជួយបង្កើនដល់ការនាំចេញដែរ។ តារាងខាងក្រោយ បង្ហាញពីការវិនិយោគផ្ទាល់ពីបរទេស និងការនាំចេញ នៅប្រទេសវៀតណាម និងហ្វីលីពីន ដែលត្រូវបានប្រើប្រាស់ធ្វើជាទិន្នន័យយោងសំរាប់ការទស្សន៍ទាយ។

**តារាង ៨-២-៤ ការព្យាករណ៍ការវិនិយោគបរទេសផ្ទាល់របស់កម្ពុជា ក្នុងឧស្សាហកម្ម អគ្គិសនី/អេឡិកត្រូនិក និងផលប៉ះពាល់រីកសាយភាយ**

| | | 2010 | 2015 | 2020 |
|---|---|---|---|---|
| Cumulative FDI Company | Number | 3-5 | 15-20 | 60-70 |
| Cumulative FDI | Million US$ | 20 | 100 | 340 |
| Number of Employee | 1,000 | 3-5 | 25-30 | 80-90 |
| Export Value | Million US$ | -100 | 500 | 1,700 |

Source: JICA Study Team

## ៨.៣ ការវាយតំលៃ និងទស្សនៈវិស័យនៃភាពប្រជែងឈ្នះជាអន្តរជាតិ នៃឧស្សាហកម្មអគ្គិសនី/អេឡិចត្រូនិកនៅកម្ពុជា

### ៨.៣.១ ការវិភាគថ្លៃដើមផលិតកម្ម

នៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសថៃ តំលៃផលិតកម្មរបស់ក្រុមហ៊ុនជប៉ុន (និងក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុនជប៉ុន) លើការផលិតបរិក្ខារផ្សេងៗ នៅក្នុងវិស័យអគ្គិសនី/អេឡិចត្រូនិកនេះ មានការចំណាយខ្ពស់លើសំភារៈបន្ទាប់បន្សំ ដែលតាមការប៉ាន់ប្រមាណប្រហែលជា ៧០-៨០% នៃការចំណាយសរុប ហើយជាមួយគ្នានេះដែរ ការចំណាយលើបុគ្គលិកកម្មករមានចំនួន ៥-១៥% និងការចំណាយលើរបស់របរផ្សេងៗទៀត (ដូចជា តំលៃរំលោះលើឧបករណ៍ប្រើប្រាស់ និងការចំណាយលើទឹកភ្លើងទូរស័ព្ទ។ល។) មានចំនួនប្រហែលជា ១០-២០%។ ចំពោះបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំ ដែលត្រូវប្រើប្រាស់សំរាប់ក្នុងផលិតកម្មនោះ គឺមានប្រភពមកពីប្រទេស មួយចំនួននៅក្នុងតំបន់ និងមកពីប្រទេសជប៉ុន ដែលធ្វើអោយតំលៃផលិតកម្មមានការចំណាយខ្ពស់។ ផ្ទុយមកវិញ ការចំណាយលើបុគ្គលិកកម្មករ បើប្រៀបធៀបទៅឃើញថាទាបជាង ទោះជាមានកម្មករមួយចំនួនធំដែលគេបានជួលក៏ដោយ ពីព្រោះថាការងារផលិតកម្មសំខាន់ ផ្អែកលើការងារដំឡើងជាធម្មតានេះ។ ដូចគ្នា នៅក្នុងឧស្សាហកម្ម អគ្គិសនី/អេឡិចត្រូនិក ការចំណាយលើបុគ្គលិកកម្មករ ជាធម្មតាទាបជាងគេ។ នៅក្នុងករណីរោងចក្រផលិតកម្ម ដែលមានទុនវិនិយោគច្រើននោះ ការចំណាយលើតំលៃរំលោះក៏ច្រើនដែរ ហើយការចំណាយលើសំភារៈបន្ទាប់បន្សំ កាន់តែច្រើនថែមទៀត។

នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា តំលៃពលកម្មអប្បរមាចំនួន ៤៥ ដុល្លារអាមេរិក ក្នុងមួយខែ គឺប្រហែលជា ១/៤ នៃតំលៃពលកម្មនៅក្នុងប្រទេសថៃ។ ការប្រៀបធៀបនេះបង្ហាញថា កម្ពុជាពិតជាមានកំរិតតំលៃពលកម្មថោក ដែលអាចផ្តល់ឧកាសអោយកម្ពុជាអាចរក្សាតំលៃប្រកួតប្រជែងបាន។ ក្រុមហ៊ុនជប៉ុនមួយចំនួនធំ បានលើកឡើងថា ករណីកំរិតតំលៃពលកម្មថោក ពុំមិនមែនជាអតិ្តភាពចំបងរបស់ពួកគេនោះទេ។ ពីព្រោះថាក្រុមហ៊ុនធន់ធ្ងន់ត្រូវបានគេបំពាក់ដោយសំភារៈបន្ទាប់បន្សំនៅក្នុងតំលៃខ្ពស់ ដូចនេះអ្វីដែលគេចាត់ទុកជាការសំខាន់នោះ គឺប្រសិទ្ធភាពក្នុងការផ្គត់ផ្គង់បរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំ។ ក្រុមហ៊ុនទាំនោះបានចាត់ទុកអតិ្តភាពជាចំបង ចំពោះបញ្ហាដែលស្មុគ្រស្មាញនោះ រួមមានការដឹកជញ្ជូនផលិតផលសំរេចទៅអោយអតិថិជន។ គេគួរតែកែសំរួលអោយមានចំណុចខុសគ្នា តិចតួចបានហើយ ក្នុងការប្រៀធៀបកំរិតតំលៃពលកម្មទូទៅនៅក្នុប្រទេសនីមួយៗ។ គេបានគិតទុកជាមុនថា តំលៃពលកម្មអាចនឹងកើនឡើង ស្របពេលជាមួយការរីកចំរើននៃសេដ្ឋកិច្ច។ ជាមួយគ្នានេះនៅមានបញ្ហាពីផលិតភាពផងដែរ។ កំរិតការអប់រំនៅទាប និងប្រសិទ្ធភាពការងារធ្លាក់ចុះ ធ្វើអោយតំលៃពលកម្មកើនឡើងដោយស្មានមិនដល់។ ដូចជាការលើកឡើងនេះអញ្ចឹង ការរៀបចំរបស់ប្រទេសដែលមិនទាន់អភិវឌ្ឍន៍ សំរាប់ការផ្គត់ផ្គង់អន្តរជាតិ និង កំរិតអប់រំនៅទាបរបស់កម្មករកម្ពុជានោះ

គឺជាឧបសគ្គដ៏ធំចំពោះការមកបោះទីតាំងវិនិយោគរបស់ក្រុមហ៊ុននានា នៅ ក្នុងវិស័យឧស្សាហកម្មអគ្គិសនី/អេឡិចត្រូនិក នេះ។ ជាការពិតណាស់ ក្រុមហ៊ុនទាំងនេះមិនបានចាត់ទុកតំលៃពលកម្ម ថោកគឺជាអត្ថប្រយោជន៍ដ៏ធំសំរាប់ការមកបោះទីតាំងវិនិយោគនោះទេ។

### ៨.៣.២ គំរូធុរកិច្ចក្នុងឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គីសនី

មានសាខាក្រុមហ៊ុនជប៉ុនជាច្រើន ដែលអាចធ្វើឱ្យជឿនលឿនជាសក្តានុពលទៅក្នុងឧស្សាហកម្មគ្រឿងអេឡិកត្រូនិក/គ្រឿងអគ្គីសនី ពីប្រទេសមួយចំនួន (ម៉ាឡេស៊ី ថៃ និងវៀតណាម) នៅអាស៊ាន។ ពួកគេតំណាងឱ្យដូចខាងក្រោម ចំពោះឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គីសនី វាប្រមូលផ្តុំទស្សនៈទូទៅនៃគំរូធុរកិច្ច ដូចក្នុងតារាងខាងក្រោម ទាក់ទិនទៅនឹងវិស័យធុរកិច្ចជាសក្តានុពលទាំង ៥។

**តារាង ៨-៣-១ ឧទាហរណ៍នៃគំរូធុរកិច្ចសំរាប់ ឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក ដែលបានរកឃើញក្នុងការអង្កេតតាមក្រុមហ៊ុន**

| | **T company (Malaysia)** |
|---|---|
| Object product | Electric/electronic component ( transformer for the audio visual ) |
| Current production Style | In ASEAN, producing various transformers at the two factories in Malaysia. Also, it is part consignment production in Myanmar company. The main supply place is ASEAN within the region and a European and American area. |
| Overseas investment Plan | In ASEAN except Malaysia, it has begun to search for a new production site for labor-intensive transformers. |
| Problem with the business | In Malaysia, the personnel expenses have risen and it is difficult to secure labor. (Dependence on foreign workers is growing. ). |
| FDI condition | ・ Securing a workforce which is diligent and low cost<br>・ Physical distribution infrastructure to procure material and to deliver product. |
| Possibility of investment in Cambodia | Vietnam and Myanmar are candidates. As for Cambodia, there was little information on the investment environment, and it was outside the assumption as the producing country. |
| Business plan ( 3-5 years ) | Undecided |

| | **Y company (Thailand/Vietnam)** |
|---|---|
| Object product | Electric/electronic components (wire harnesses for automobiles) |
| Current production style | In ASEAN, there are many factories in Thai, Vietnam and other countries. It also has production plants in Laos, etc.. The main supply place is ASEAN within the region, Japan and the U.S. |
| Overseas investment plan | In ASEAN, it is production system reinforcement in Vietnam at present. It is reviewing the construction of a 3rd factory and wire factory construction from the present 2-factory system. |
| Problem with the business | Rise of the personnel expenses and the difficulty of securing labourers |
| FDI condition | ・ Securing a workforce which is diligent and low cost (2 shifts)<br>・ Physical distribution infrastructure to procure materials and to deliver product.<br>・ It doesn't want to site a factory in a serviced industrial park (To secure |

| | |
|---|---|
| | workforce ). |
| Possibility of investment in Cambodia | A company executive remarks that it hopes for factory construction anywhere except Vietnam in the future. Also, when assuming the strategy of stepping forward in ASEAN, there is possibility of advancing into Cambodia in the near future. |
| Business plan ( 3-5 years ) | Undecided. But the company's factory will employ 3,000 to 4,000 workers |

Source: JICA Study Team

តារាង ៨-៣-២ គំរូធុរកិច្ចនៃឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិកនៅកម្ពុជា

| Promising Assembly Process | Assumed main foreign capital | Place of the procurement of the part and material | Major exportation place | Characteristic for production form |
|---|---|---|---|---|
| Assembly of wire harnesses | Japanese | ASEAN, China | Thailand, US | labor intensive work |
| Assembly of coils and transformers | Japanese, Korea, Taiwan | Japan, ASEAN, China | ASEAN, China | labor intensive work accompanied by the automatic machine |
| Assembly of small electric products | Japanese, Taiwan, ASEAN | Japan, ASEAN, China | EU, US, Japan | Inner production of plastic parts and metal component |
| Assembly of half-finished goods (camera modules, BLUs, power supplies, etc.) | Japanese, Taiwan | Japan, ASEAN, China | Japan, ASEAN, China | Introduction of the advanced assemble equipment |
| Assembly of information-communications equipment (printers, mobile telephones, etc.) | Japanese | Japan, ASEAN, China | EU, US | Introduction of the advanced assemble equipment, Inner production of plastic parts and metal component |

Source: JICA Study Team

## ៨.៤ អនុសាសន៍ ដើម្បីជំរុញការវិនិយោគផ្ទាល់ទៅក្នុងឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិក

### ៨.៤.១ អនុសាសន៍សំរាប់ការទាក់ទាញការវិនិយោគបរទេសផ្ទាល់ ក្នុងឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិក

លក្ខណៈវិនិច្ឆ័យដែលគេយកមកប្រើប្រាស់ សំរាប់សំរេចជ្រើសរើសទីតាំងរបស់ក្រុមហ៊ុនជប៉ុន នៅក្នុងឧស្សាហកម្មឧបករណ៏អគ្គិសនី/អេឡិចត្រូនិក គិតទៅលើការវិនិយោគដែលមានទ្រង់ទ្រាយធំ ប្រភពនៃការជួយផ្គត់ផ្គង់ និងគោលដៅដែលត្រូវនាំចេញច្រើន និងការប្រើប្រាស់ពេលវេលាខ្លី ទាំងអស់នេះជាលទ្ធផលនៃវដ្តកិច្ចសន្យា។ លក្ខណៈវិនិច្ឆ័យជាក់ស្តែង រួមមានស្ថិរភាពនយោបាយសង្គម ការលើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ពីបរទេសសំរាប់ផលិតកម្ម តំលៃឈ្នួលពលកម្មទាបប៉ុន្តែឧស្សាព្យាយាម សួនឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ បណ្តាញផ្គត់ផ្គង់អន្តរជាតិ ដែលអាចសំរួលដល់ការគ្រប់គ្រងនៃការផ្គត់ផ្គង់តាមសាខា（SCM）ដែលត្រូវការពេលវេលាតិច និងបរិយាកាសរស់នៅល្អ ដើម្បីធ្វើអោយបុគ្គលិកអាចរស់នៅដោយសុវត្ថិភាព និងផាសុខភាព។ ទន្ទឹមនឹងពលករដែលមានថ្លៃឈ្នួលថោក និងអាចយកជាការបាននោះ

តំរូវការដ៏ចាំបាច់បំផុតគឺសួនឧស្សាហកម្មដែលមានការផ្គត់ផ្គង់ប្រព័ន្ធទឹកភ្លើងល្អ និង មុខងាររបស់ EPZ (SEZ) បណ្តាញចែកចាយអន្តរជាតិសំរាប់ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស។ តារាងបន្ទាប់បង្ហាញពីភាពខុសគ្នា រវាងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដែលជាឧស្សាហកម្មមានក្រុមហ៊ុន វិនិយោគបរទេសជាច្រើននៅក្នុងប្រទេសរួចហើយ និងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកជាឧស្សាហកម្ម ថ្មីមិនទាន់មានក្រុមហ៊ុនបរទេសនៅឡើយទេ។

បច្ចុប្បន្ន កម្ពុជាមានស្ថិរភាពនយោបាយសង្គម ការលើកទឹកចិត្តសំរាប់អោយមានការវិនិយោគផ្ទាល់ពីបរទេស និងពលករមានតំលៃឈ្នួលថោក ប៉ុន្តែផ្នែកផ្សេងទៀតពុំទាន់បានបំពេញល័ក្ខខ័ណ្ឌ ដែលក្រុមហ៊ុនជប៉ុនចង់បាននៅឡើយទេ។ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង អវត្តមានសួនឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងបណ្តាញដឹកជញ្ជូនអន្តរជាតិដែលទាក់ទងគ្នារលូននៅគ្រប់ទីដៅទាំងអស់ទាំងនៅក្នុង និងក្រៅប្រទេស គឺជាកង្វះខាតដ៏ធ្ងន់ធ្ងរនៅកម្ពុជា។ ហេតុដូចនេះ ក្នុងករណីឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ផែនការសកម្មភាពដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសពិសេសពីជប៉ុន ត្រូវតែយកចិត្តទុកដាក់លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ទាំងនេះ។ តាមរយៈការពិនិត្យដោយម៉ត់ចត់ ដោយផ្អែកលើលទ្ធផលពីបទសំភាសន៍ជាមួយក្រុមហ៊ុនជប៉ុន និងស្ថាប័នពាក់ព័ន្ធនានានៅក្នុងប្រទេសជិតខាង ក្រុមសិក្សាJICA បានធ្វើការសិក្សាស្រាវជ្រាវ ដើម្បីពិនិត្យមើលការលើកទឹកចិត្តដល់ការវិនិយោគបរទេសផ្ទាល់ និងផែនការសកម្មភាព ដើម្បីជាអនុសាសន៏ដល់រដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញការមក បោះទីតាំងរបស់ឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក។ ផ្នែកបន្ទាប់មកទៀត លើកឡើងអំពីលទ្ធផលនៃការ សិក្សាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ"ជារូបវ័ន្ត" (hard infrastructure) (សួនឧស្សាហកម្ម ការផ្គត់ផ្គង់អគ្គិសនី បណ្តាញ ដឹកជញ្ជូនអន្តរជាតិ) និងហេដ្ឋារចនាសម្ព័ន្ធ"ជាខួរក្បាល" (soft infrastructure) (ការរៀបចំគោលនយោបាយការវិនិយោគ ផ្ទាល់ពីបរទេស សកម្មភាពលើកកំពស់ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ការបណ្តុះបណ្តាលជំនាញ និងការអភិវឌ្ឍន៏ធនធានមនុស្ស និងល័ក្ខខ័ណ្ឌការងារ)។

តារាង ៨-៤-១ ភាពខុសគ្នារវាងឧស្សាហកម្ម អគ្គីសនី/អេឡិកត្រូនិក និងកាត់ដេរសំរាប់ការតំរូវឱ្យដាក់ទីតាំង

| | Garment industry | Electric/electronics industry (especially Japanese firms) |
|---|---|---|
| Labor | Wages should be as low as possible | Wages must be at low levels, but high productivity is even more important |
| Export markets | GSP application for export to Western markets is a big benefit | Finished products are often exported direct to Western markets, but indirect export from other countries inside and outside the region is the norm for components. GSP is not applied to such export |
| FDI incentives | Incentives (e.g., deductions/exemptions for the corporation tax and tariff on import of producer goods) are a big benefit. | Incentives (e.g., deductions/exemptions for the corporation tax and tariff on import of producer goods) are a big benefit. |
| One-stop services | The production process is comparatively simple, and there is little need to apply for permits from many different agencies. | The production process is complex and utilizes a variety of producer goods. There is also a need to apply for permits from many different agencies in regard to indirect export and environmental regulations. |

| | | |
|---|---|---|
| Industrial parks | Firms do not necessarily desire to site in industrial parks (in many cases, plants are constructed on sites provided by private-sector investors. | Precedence is accorded to siting in industrial parks run by the host-country public sector (public corporations etc.) or Japanese trading firms. |
| Power supply | A stable supply is preferable but not a must | A stable supply of power is indispensable (the more facility-intensive the production is, the more outages lower the working rate and yield). |
| Logistics infrastructure | Material import and product export can basically be done with international container carriers. | Material import and product export can basically be done with international container carriers, but users frequently prefer international air cargo transport for high-tech and small components. |
| Labor conditions | The required scale of investment is relatively low, and one or two shifts is the norm. | The required scale of investment may be high due to shorter lead times and higher degrees of mechanization.  In such cases, a three-shift setup is the norm for earlier recovery of investment. |

Source: JICA Study Team

ស្ថានភាពបច្ចុប្បន្ននៅកម្ពុជា គឺមានលក្ខណៈគួរជាទីពេញចិត្តទាក់ទិនទៅនឹងស្ថេរភាពសង្គមនយោបាយ ការលើកទឹកចិត្តចំពោះការវិនិយោគបរទេសផ្ទាល់ និងតម្លៃពលកម្មថោក ប៉ុន្តែនេះស្រេចតែលើតំរូវការរបស់ក្រុមហ៊ុនជប៉ុនចំពោះទិដ្ឋភាពផ្សេងទៀត។ បើទុកជាប្រៀបធៀបជាមួយប្រទេសជិតខាង កង្វះខាតសួនឧស្សាហកម្មជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធល្អ និងបណ្តាញភស្តុភាជាមួយនឹងការតភ្ជាប់ក្នុងចំណោមចំណុចខាងក្រៅ និងខាងក្នុងប្រទេស គឺមិនមានភាពងាយស្រួលនៅឡើយ។ ដូចនេះ ក្នុងករណីឧស្សាហកម្មអេឡិកត្រូនិក/គ្រឿងអគ្គីសនី ផែនការសកម្មភាពដើម្បីទាក់ទាញការវិនិយោគបរទេសជាពិសេសពីជប៉ុន ត្រូវតែផ្តោតលើសេចក្តីត្រូវសំរាប់ការស្ថាបនានៃធាតុរបស់ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានស្ទើតែទាំងអស់។

តាមរយៈនៃការត្រួតពិនិត្យផ្សេងៗ ផ្អែលើរបកគំហើញនៃការសម្ភាសន៏ជាមួយក្រុមហ៊ុនជប៉ុន និងស្ថាប័នសាធារណៈពាក់ព័ន្ធនានានៅក្នុងប្រទេសជិតខាង ក្រុមសិក្សាចៃកា បានធ្វើការសិក្សាដើម្បីកំណត់នូវគំនិតផ្តួចផ្តើមនៃការវិនិយោគ បរទេសផ្ទាល់ និងការស្នើជាអនុសាសន៏ជាគោលនយោបាយពាក់ព័ន្ធ ចំពោះរដ្ឋាភិបាលកម្ពុជា ដើម្បីទាក់ទាញការបោះទីតាំងក្នុងឧស្សាហកម្មនេះ។ ផ្នែកខាងក្រោម បានធ្វើការចង្អុលទិសជាដំបូន្មានសំរាប់ការសិក្សាទិដ្ឋភាព ហេដ្ឋារចនាសម្ព័ន្ធ "រឹង" (សួនឧស្សាហកម្ម ការផ្គត់ផ្គង់ថាមពល និងភស្តុភាអន្តរជាតិ) និងហេដ្ឋារចនាសម្ព័ន្ធ "ទន់ជាខួរក្បាល" (ការចាត់ចែងគោលនយោបាយការវិនិយោគបរទេសផ្ទាល់ សកម្មភាពជំរុញការវិនិយោគសំរាប់ការទាក់ទាញវិនិយោគបរទេសផ្ទាល់ ការអភិវឌ្ឍន៏ធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញ និងលក្ខខណ្ឌការងារ)។

### (១) លក្ខ័ខ័ណ្ឌហេដ្ឋារចនាសម្ព័ន្ធរឹង

*(i) សួនឧស្សាហកម្ម*

នៅក្នុងព្រឹត្តិការណ៏នៃការបោះទីតាំងរបស់ក្រុមហ៊ុនអគ្គិសនី/អេឡិចត្រូនិចជប៉ុន វាជាការលំបាករបស់ក្រុមហ៊ុនទាំង

នេះ ក្នុងការស្វែងរកបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំនៅកម្ពុជា ធម្មតាផលិតកម្មទាមទារអោយមានការនាំចូលគ្រឿងបរិក្ខារ និងសំភារៈបន្ទាប់បន្សំសំរាប់ផលិត និងការនាំចេញ។ បើប្រៀបធៀបនឹងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ខុសគ្នា សូម្បីការផលិតដ៏តូចមួយក៏ទាមទារអោយមានការវិនិយោគលើសំភារៈបរិក្ខារទាំងនោះដែរ (រាប់រយលានយ៉េនសំរាប់ខ្សែសង្វាក់ផលិតកម្មមួយ បើប្រៀបធៀបទៅនឹងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់វិញ មានតែរាប់សិបលានយ៉េនប៉ុណ្ណោះ)។ ចំនួនការវិនិយោគកាន់តែមានច្រើនឡើង បើសិនជាគេត្រូវការសាងសង់រោងចក្រផលិតបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំថែមទៀតនោះ (ដូចជាពុម្ព)។ លើសពីនេះទៀត ការកែលំអជាបន្តបន្ទាប់ នៃដំណើរការផលិតកម្ម ដើម្បីឱ្យមានការចំណាយតិច និងគុណភាពខ្ពស់ ទាមទារអោយមានជំនាញវិស្វកម្ម ដែលត្រូវប្រមែលប្រមូលក្នុងរយៈពេលជាច្រើនឆ្នាំ។

ដោយហេតុផលនេះ នៅពេលដែលក្រុមហ៊ុនជប៉ុនជ្រើសរើសទីតាំងភ្លាម ពួកគេបានរៀបចំសំភារៈផលិតកម្មសំរាប់រយៈពេលយូរអង្វែង។ ជាពិសេស ពួកគេកែលំអដំណើរការជាបន្តបន្ទាប់ ពង្រីកសមត្ថភាពកម្ម ដំណើរការផលិតបរិក្ខារផ្សេងៗ និងសំភារៈបន្ទាប់បន្សំ ឬអាចបន្ថែមសមត្ថភាពផលិតក្នុងក្នុងរយៈពេលយូរអង្វែង។ ដូចនេះ ក៏រិតនៃការទាមទារឱ្យមានតំបន់ឧស្សាហកម្ម ពិតជាខ្ពស់ណាស់ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង។ ដូច្នេះហើយបានជា ក្រុមហ៊ុនទាំងនោះច្រើនតែបោះទីតាំងនៅក្នុងសួនឧស្សាហកម្ម ដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងមុខងាររបស់ EPZ (SEZ) ដូចជាការសំរួលដល់ការនាំចេញ។ នៅប្រទេសម៉ាឡេស៊ី ថៃ និងវៀតណាម ក្រុមហ៊ុនជប៉ុនជាច្រើនជាអ្នកកាន់ កាប់សួនឧស្សាហកម្ម ដែលគ្រប់គ្រងដោយសារជីវកម្មសាធារណៈ ឬស្ថាប័នសាធារណៈដ៏ទៃទៀត ដែលគេមានសេចក្តីទុកចិត្ត ហើយមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅអ្វីដែលគេចង់បានដូចបានបង្ហាញនៅទំព័រខាងក្រោយ ។

ក្នុងករណីមុនៗក្នុងប្រទេសជិតខាង គេចង់អោយការរៀបចំសួនឧស្សាហកម្ម ធ្វើឡើងដោយសារជីវកម្មសាធារណៈ រដ្ឋាភិបាលមូលដ្ឋាន ឬក្រុមហ៊ុនជំនាញ (ដូចជាក្រុមហ៊ុនពាណិជ្ជកម្ម) ជាជាងការរៀបចំដោយស្ថាប័នរដ្ឋ។ នៅប្រទេសថៃ សារជីវកម្មសាធារណៈជាអ្នកបង្កើត និងគ្រប់គ្រងសួនឧស្សាហកម្មទូទាំងប្រទេស ហើយអាចធ្វើអោយក្រុមហ៊ុនបរទេសមានទំនុកចិត្តជាង។ នៅប្រទេសវៀតណាម ក្រុមហ៊ុនជប៉ុនជាច្រើន និងក្រុមហ៊ុនបរទេសដទៃទៀត បានបោះទីតាំងនៅក្នុងសួនឧស្សាហកម្ម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការប្រជាជនខេត្ត ឬគ្រប់គ្រងដោយក្រុមហ៊ុនជប៉ុន។ និន្នាការទូទៅសំរាប់ក្រុមហ៊ុនជប៉ុន គឺការចាត់ទុកសួនឧស្សាហកម្មដែលគ្រប់គ្រង ដោយស្ថាប័នសាធារណៈរបស់ប្រទេសជាម្ចាស់ ឬក្រុមហ៊ុនពាណិជ្ជកម្មជំនាញដែលដឹងច្បាស់លាស់ពីស្ថានភាពនៅក្នុងតំបន់ ដែលធ្វើអោយការបោះទីតាំងរបស់គេប្រកបដោយទំនុកចិត្ត។ គុណប្រយោជន៏មួយទៀតនៃការមានសួនឧស្សា ហកម្មដែលគ្រប់គ្រងដោយភាគីទីបី ឬក្រុមហ៊ុនពាណិជ្ជកម្មជប៉ុន គឺថាអ្នកគ្រប់គ្រងនេះអាចចូលរួមយ៉ាងសកម្មនៅគ្រប់សកម្មភាព ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ និងផ្តល់អោយនូវសេវាសព្វបែបយ៉ាងដល់ក្រុមហ៊ុន ដើម្បីអោយដំណើរផលិតកម្មរបស់គេប្រព្រឹត្ត

ទៅបានល្អ ។

**តារាង ៨-៤-២ ការរៀបចំ និងការគ្រប់គ្រងសួនឧស្សាហកម្មនៅប្រទេសជិតខាង និងការដាក់ទីតាំងផលិតរបស់ក្រុមហ៊ុនអគ្គីសនី/អេឡិកត្រូនិក ជប៉ុន**

| Country | Park preparation and management | Parks with siting mainly by Japanese electric/electronics firms |
|---|---|---|
| Malaysia | There is no national agency for development of industrial parks on the national level. Park preparation and management are performed by the state economic development corporations (SEDC) and regional development agencies (RDA) on the state level. In addition, there are some industrial parks that were developed by private firms. | Industrial parks under the SEDCs and RDAs on the state level |
| Thailand | Thailand makes a distinction between industrial estates and industrial parks. The former are managed and operated either directly by the Industrial Estate Authority of Thailand (IEAT) or jointly by the IEAT and a private firm which developed it in line with IEAT standards. The latter are run by private firms. Nationwide, there are about 100 estates and parks. | Industrial estates managed and operated either directly by the Industrial Estate Authority of Thailand (IEAT) or jointly by the IEAT and a private firm which developed it in line with IEAT standards |
| Philippines | The Philippines Economic Zone Authority (PEZA) certifies industrial parks developed by the private sector as special economic zones (about 100 nationwide) and encourages export-oriented FDI in them. Apart from those under PEZA jurisdiction, EPZs are being developed on the sites of former US military bases (Subic and Clark). PEZA is a public entity under the Department of Trade and Industry (DTI), but its EPZ management is autonomous in respect of income, for example, PEZA engages in activities developed from the investor's standpoint, for smooth promotion of investment, including application procedures, one-stop services, and promotional campaigns. | Industrial parks under PEZA jurisdiction |
| Vietnam | There are many (about 100) industrial parks managed and operated by the boards of management (BOMs) attached to the people's committees in areas such as Hanoi and HCMC. There are also a few private parks that were developed and operated by Japanese firms (Sumitomo Corporation and Nomura Securities). The BOMs are delegated the authority to screen and approve FDI projects by the MPI. The major BOMs are the HCMC Export Processing & Industrial Zone Authority (HEPZA) and the Dana (Dong Nai) Export Processing & Industrial Zone Authority). | Parks developed and operated by foreign parties (Japanese firms, Singaporean government, etc.) and parks under the subcommittees for running industrial parks in the people's committees |

Source: JICA Study Team

បច្ចុប្បន្ន កម្ពុជាមានសួនឧស្សាហកម្មប្រហែល ១០ ដែលកំពុងត្រូវបានរៀបចំដោយផ្នែកឯកជន សំរាប់រកប្រាក់ចំណេញផ្ទាល់ខ្លួន។ ភាគច្រើននៃសួនឧស្សាហកម្មស្ថិតនៅតាមព្រំដែនថៃ និងវៀតណាម។ បើប្រៀបធៀបទៅសួនឧស្សាហកម្មក្នុងបណ្តាប្រទេសជិតខាង ដែលក្រុមហ៊ុនជប៉ុនបានបោះទីតាំង គេឃើញថាសួនឧស្សាហកម្មនៅកម្ពុជា មានបញ្ហាជាច្រើនដូចជាសិទ្ធិកាន់កាប់ដីធ្លី ការធានាអោយមានការកាន់កាប់យូរអង្វែង និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធរឹង (ដូចជា ទឹក ភ្លើង និងបណ្តាញដឹកជញ្ជូន) ។

ចំណុចខាងក្រោមនេះគឺជាអ្វីដែលក្រុមហ៊ុនជប៉ុនសង្ឃឹមថាមាននៅក្នុងសួនឧស្សាហកម្ម :

- គ្រប់គ្រង និងដំណើរការដោយស្ថាប័នសាធារណៈ ឬស្ថាប័នរបស់ប្រទេសអភិវឌ្ឍន៍ (រដ្ឋាភិបាលសិង្ហបុរី) ឬក្រុមហ៊ុន (ក្រុមហ៊ុនពាណិជ្ជកម្មជប៉ុន) ។
- ធានាអោយបានទំនុកចិត្ត និងការបន្តការគ្រប់គ្រង និងប្រើប្រាស់រយៈពេលយូរអង្វែង ។
- លទ្ធភាព EPZ (SEZ) (ការលើកទឹកចិត្តសំរាប់ការផលិតសំរាប់នាំចេញ ការធ្វើអោយងាយស្រួលនូវការបំពេញបែបបទ និងរបាយការណ៍សំរាប់ការនាំចេញ និងនាំចូល) ។
- ប្រព័ន្ធអគ្គិសនីគ្រប់គ្រាន់ និងទៀងទាត់ (អាចប៉ះពាល់ដល់ការបំពេញការងារ និងផលិតផលដែលអាចសំរេចបាន) ។
- ប្រព័ន្ធទឹកគ្រប់គ្រាន់ (មិនមានគំលាតរវាងរដូវប្រាំង និងរដូវវស្សា) និងរោងចក្រប្រព្រឹត្តិកម្មទឹក (សំរាប់ BOD មួយមិនលើសពី ២០ PPM) ។
- សំភារៈបរិក្ខារទំនាក់ទំនង (ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតមានល្បឿនលឿន សំរាប់ទំនាក់ទំនងអន្តរជាតិ) ។ និង
- បរិយាកាសរស់នៅ (ផ្ទះសំបែងចំណីរអាហារ) សមស្របសំរាប់បុគ្គលិកមកពីជប៉ុន និងសេវាខ្សែជីវិតផ្សេងៗ ទៀត (ដូចជាសាលារៀន និងមន្ទីរពេទ្យ ។ល ។ ) ។

សង្ឃឹងថាមុខងារដែលបានរៀបរាប់ខាងលើ នឹងត្រូវបានសាងសង់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងទីក្រុងព្រះសីហនុ ដែលត្រូវបានគេរៀបចំក្រោមជំនួយឧបត្ថម្ភពីរដ្ឋាភិបាលជប៉ុន ហើយដែលការរៀបចំនេះនឹងត្រូវបានចប់សព្វគ្រប់នៅក្នុងរយៈពេល ២-៣ ឆ្នាំខាងមុខនេះ និង ភ្នំពេញ SEZ នៅក្រៅទីក្រុងភ្នំពេញ ដែលមានការចូលរួមវិនិយោគពីក្រុមហ៊ុនជប៉ុន។ តំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងព្រះសីហនុ ដែលនឹងត្រូវបញ្ចប់នៅឆ្នាំ ២០០៩ និងមានរៀបចំ ស្តង់ដារសំរាប់បំពេញមុខងារ EPZ និងការរៀបចំផ្នែកផ្សេងទៀត ដូចជាហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ដែលមានភ្លើង អគ្គិសនី ទឹក និងកន្លែងធ្វើប្រព្រឹត្តកម្មទឹក។ ស្តង់ដាសួនឧស្សាហកម្មគួរតែរៀបចំទៅតាមស្តង់ដា ដែលមាននៅក្នុងសួនឧស្សាហកម្មនៃបណ្តាប្រទេសក្នុងតំបន់។ ទន្ទឹមនឹងនេះ សួនឧស្សាហកម្មបន្ថែមទៀត ដែលនឹងត្រូវសាងសង់នៅ ថ្ងៃអនាគត គួរតែធ្វើអោយបានទៅតាមស្តង់ដា ដែលកំណត់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ។ មានន័យថា កម្ពុជាត្រូវតែលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធសំរាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ការផ្គត់ផ្គង់ភ្លើងអគ្គិសនី ប្រព័ន្ធទំនាក់ទំនង ទឹក និងរោងចក្រប្រព្រឹត្តកម្មទឹក នៅក្នុងសួនឧស្សាហកម្មត្រូវតែធ្វើតាមស្តង់ដារអន្តរជាតិ។ ក្រុមហ៊ុនទាំងឡាយបានទាមទារយ៉ាងខ្លាំងអោយមានប្រព័ន្ធអគ្គិសនី។ ការដាច់ភ្លើងញឹកញាប់ គឺជាទង្វើរដែលពួកគេមិនអាចទទួលយកបាន។ ជារៀងរាល់ពេលដែលដំណើរការផលិតកម្មផលិតសំភារៈបរិក្ខារ មិនដំណើរការដោយសារដាច់ចរន្តអគ្គិសនីនោះ ការផលិតនានាមិនបានលទ្ធផលទេ។ នៅក្នុងដំណើរការ កែច្នៃប្លាស្ទិក ការដាច់ភ្លើងក៏បណ្តាលអោយខូចផលិតផលដែរ។ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រព័ន្ធភ្លើងអគ្គិសនីនៅកម្ពុជា នៅពុំទាន់គ្រប់

គ្រាន់នៅឡើយ។ នៅក្នុងសួនឧស្សាហកម្ម ការផ្គត់ផ្គង់ភ្លើងអគ្គិសនីបានមកពី IPPs។ ក្រៅពីការមានភ្លើងអគ្គិសនីទៀងទាត់ និងគ្រប់គ្រាន់ហើយ កត្តាសំខាន់មួយទៀតគឺតំលៃភ្លើង។ កម្ពុជាគួរតែផ្តល់តំលៃ ដល់ការពង្រីកភាពអោយមានការងារធ្វើ និងប្រាក់ចំណូលបរទេសដែលបានមកពីការនាំចេញ ដោយក្រុមហ៊ុនដែល មានទីតាំងនៅកម្ពុជា ហើយកំណត់ឱ្យមានការលើកលែងពន្ធថាមពលអគ្គិសនី ដែលតមកពីប្រទេសជិតខាង។ ជាជាងការស្វែងរកដំណោះស្រាយឥតខ្ចោះសំរាប់បញ្ហានីមួយៗ (ដូចជាកង្វះភ្លើងអគ្គិសនី) កម្ពុជាគួរតែពិចារណាឱ្យមានការមកបោះទីតាំងរបស់ក្រុមហ៊ុនបរទេស និងដំណើរការតំបន់សេដ្ឋកិច្ចពិសេស ដោយមើលពីគ្រប់ជ្រុង ជ្រោយ ដើម្បីធានាអោយបានលទ្ធផលជាអតិបរមា។

***(ii) បណ្តាញភស្តុភា (ដឹកជញ្ជូន និងការចែកចាយ) អន្តរជាតិ***

នៅក្នុងបរិយាកាសនៃការវិនិយោគ ក្រុមហ៊ុនអគ្គិសនី/អេឡិចត្រូនិក សង្កត់ធ្ងន់លើវត្តមានសួនឧស្សាហកម្ម ដែលមានមុខងារ EPZ និងហេដ្ឋារចនាសម្ព័ន្ធល្អ រួមបញ្ចូលទាំងបណ្តាញដឹកជញ្ជូនចែកចាយអន្តរជាតិ ដែលធ្វើអោយការនាំចូលសំភារៈបន្ទាប់បន្សំ និងគ្រឿងបរិការផលិតកម្មពីប្រទេសដទៃទៀត និងការនាំចេញផលិតផលមានប្រសិទ្ធភាព។ ដោយសារលក្ខខណ្ឌទាំងអស់នេះ តំរូវអោយមានការចំណាយដ៏សន្ធឹកសន្ធាប់ កម្ពុជាត្រូវពឹងអាស្រ័យលើជំនួយអភិវឌ្ឍន៍បរទេស។ ជាមួយនឹងជំនួយពីរដ្ឋាភិបាលជប៉ុន ការងារកែលំអកំពង់ផែ និងបណ្តាញដឹកជញ្ជូនផ្លូវថ្នល់ នឹងបានប្រសើរឡើងនៅឆ្នាំ ២០១០។ កម្ពុជាគួរតែធ្វើអោយបានលឿនជាងនេះ ដើម្បីធ្វើអោយការងារទាំងនេះបានចប់មុនពេលកំណត់។

បើនិយាយជារួមនៅក្នុងការផលិតបរិក្ខារអគ្គិសនី/អេឡិចត្រូនិក និងគ្រឿងបរិការសំរាប់បំណងពិសេសណាមួយនោះ សំភារៈបន្ទាប់បន្សំ និងគ្រឿងបរិការផលិតកម្មនឹងត្រូវបានគេនាំយកមកភ្លាម បន្ទាប់ពីមានការបញ្ជាទិញ ពីអតិថិជន គេត្រូវការពេលវេលា ១ ខែ ដើម្បីទិញសំភារៈបន្ទាប់បន្សំ និងគ្រឿងបរិការផលិតកម្ម និង ១ ទៅ ២ ខែ ដើម្បីទិញឧបករណ៍ចំលង/ទប់កំដៅ និង ១ ទៅ ២ ខែ ដើម្បីដំណើរការដំឡើង និង ១ ទៅ ១.៥ ខែ ដើម្បីនាំចេញតាមផ្លូវទឹក។ ប្រទេសថៃ និងម៉ាឡេស៊ី មានសេវាកម្មកំពង់ផែល្អ ដូចនេះគេប្រើប្រាស់ពេលវេលាចាប់តាំងពីការទទួល ការបញ្ជាទិញរហូតដល់ការចែកចាយមានរយៈពេលតែ ៣ ខែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ការប្រើប្រាស់កំពង់ផែនៅទីក្រុងព្រះសីហនុ មានរយៈពេល ១ ខែ យូរជាង (សរុប ៤ ខែ ) ដោយសារតែត្រូវផ្លាស់ប្តូរកាប៉ាល់នៅសិង្ហបូរី។ ដូចនេះ កម្ពុជាត្រូវតែរៀបចំផែនការអោយបានត្រឹមត្រូវ ដើម្បីកែលំអកំពង់ផែក្រុងព្រះសីហនុ ដោយមានជំនួយឧបត្ថម្ភពី ធនាគារអភិវឌ្ឍន៍អន្តរជាតិរបស់ជប៉ុន និងជួយសំរួលដល់ដំណើរការនាំចេញ និងនាំចូល។ កម្ពុជាគួររៀបចំផែនការ សំរាប់ការត្រួតពិនិត្យគយ ទៅតាមប្រទេសម៉ាឡេស៊ី និងថៃ ព្រោះប្រទេសទាំងពីរនេះមានបទពិសោធន៍លើការងារ នេះច្រើនឆ្នាំមកហើយ។ ការងារប្រចាំថ្ងៃនៃការត្រួតពិនិត្យឯកសារ ត្រូវបានគេបំពេញដោយគ្មានការយឺតយ៉ាវ និង គ្មានឧបសគ្គ ដើម្បីជួយសំរួលដល់សកម្មភាពផលិតកម្ម និងការនាំចេញ-នាំចូល។ ការពន្យាពេលវេលាពី ១ ទៅ ២ សប្តាហ៍ សំរាប់បំពេញបែបបទ និងសុំការអនុញ្ញាតនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ត្រូវតែដោះស្រាយអោយបានឆាប់បំផុត។

នៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិកទំនើបៗ ការគិតគូរអំពីការគ្រប់គ្រង និងការចែកចាយតាមសាខា (SCM) ទាមទារអោយមានពេលវេលាកាន់តែខ្លី ក្នុងការចែកចាយទៅអោយដល់អ្នកប្រើប្រាស់។ រយៈពេលនៃការចែកចាយខុសគ្នា ទៅតាមប្រភេទសំភារៈបរិក្ខារ។ សំរាប់វត្ថុប្រើប្រាស់ស្រាលៗសំរាប់គោលបំណងទូទៅ ដែលគេប្រើប្រាស់ក្នុងវិស័យទំនាក់ទំនងព័ត៌មាន គេត្រូវការពេលវេលាប្រហែល ១ សប្តាហ៍ (ចាប់តាំងពីការបញ្ជាទិញរហូតដល់ការចែកចាយសំភារៈទៅអោយអ្នកទិញ) នៅអាស៊ី។ មានន័យថា ទំនិញទាំងនោះត្រូវតែធ្វើការ ចែកចាយមិនហួសពី ២ ថ្ងៃ បន្ទាប់ពីផលិតរួច។ ដូចជាការនាំចេញពីប្រទេសអាស៊ានទៅប្រទេសជប៉ុន ទំនិញត្រូវតែដឹក ជញ្ជូនតាមយន្តហោះទៅព្រលានយន្តហោះណារីតាតាមជើងយន្តហោះពេលយប់ និងបញ្ជូនអោយទៅអតិថិជននៅប្រទេសជប៉ុន ដោយក្រុមហ៊ុនដឹកជញ្ជូនទំនិញនៅព្រឹកបន្ទាប់ ហើយទំនិញនេះនឹងទៅដល់ទីដៅនៅល្ងាចថ្ងៃដដែល។ ពេលវេលាដូចគ្នានេះ គួរតែត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការចែកចាយទៅអោយអតិថិជននៅក្នុងបណ្តាប្រទេសអាស៊ាន។ មានន័យថា គេត្រូវសាងសង់បណ្តាញសំរាប់ដឹកជញ្ជូនតាមយន្តហោះ និងផ្លូវគោកជាអន្តរជាតិ។ ដោយសន្មត់ថា កម្ពុជានឹងខិតខំប្រឹងប្រែងដើម្បីទាក់ទាញការ មកបោះទីតាំងដោយក្រុមហ៊ុនជប៉ុននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅ ទីក្រុងព្រះសីហនុ និងភ្នំពេញទៅថ្ងៃអនាគត គំរោងសាងសង់ព្រលានយន្តហោះតូចមួយនៅជាប់តំបន់សេដ្ឋកិច្ចពិសេស នឹងអាចអោយយន្តហោះដឹកទំនិញអន្តរជាតិអាចចុះចត និងហោះឡើងបាន។

គេបានគិតថា រោងចក្រនៅកម្ពុជានឹងត្រូវនាំចូលសំភារៈបន្ទាប់បន្សំ និងគ្រឿងបរិការផលិតកម្ម ពីប្រទេសមួយចំនួន (ដូចជា ជប៉ុន និងចិន) និងប្រទេសក្នុងតំបន់មួយចំនួនទៀត (ដូចជា ម៉ាឡេស៊ី និងថៃ)។ ដូចគ្នានេះដែរ ផលិតផលនិងសំភារៈបរិក្ខារដែលផលិតរួចហើយ អាចនឹងត្រូវនាំចេញទៅប្រទេសឆ្ងាយៗ និងប្រទេសជិតខាង។ ក្នុង ការដឹកជញ្ជូនទាំងសំរាប់ការនាំចេញ និងការនាំចូលទៅកាន់ប្រទេសឆ្ងាយៗ ការដឹកជញ្ជូនតាមកុងតឺន័រគឺជា មធ្យោបាយនៃការដឹកជញ្ជូនដែលមានការចំណាយតិច។ សំរាប់ការដឹកទំនិញស្រាល អតិថិជនចង់អោយមានការដឹក ជញ្ជូនដោយប្រើមធ្យោបាយដែលមានរយៈពេលខ្លី ដូចនេះហើយបានជាការដឹកជញ្ជូនតាមជើងយន្តហោះកំពុងតែមាន ការកើនឡើង។ លើសពីនេះទៀត ទំនិញជាច្រើនដែលបានផលិតរួចត្រូវបានគេដឹកជញ្ជូនទៅកាន់ប្រទេសជិតខាង។ នៅក្នុងការដឹកជញ្ជូនបែបនេះ មធ្យោបាយនៃការដឹកជញ្ជូនច្រើនតែធ្វើឡើងតាមផ្លូវគោក។ ដូចនេះគេត្រូវតែកែលំអឡើងវិញនៅច្រកចេញចូលជាមួយក្រុងហូជីមិញ និងបាងកក (ដើម្បីធ្វើអោយការដឹកជញ្ជូនមានរយៈពេលតែ 0.៥ ទៅ ១ ថ្ងៃ) និងការកែលំអមុខងារកំពង់ផែនៅទីក្រុងព្រះសីហនុ។

**តារាង ៨-៤-៣ លក្ខខណ្ឌនៃបណ្តាញភស្តុភារអន្តរជាតិ-ការដឹកនាំ និងការងារ**

| | Orientations | Tasks |
|---|---|---|
| Marine transport | • Augmentation of facilities and functions of the port of Sihanoukville (to be completed by 2009) | • Transshipment of container cargo at Singapore in long-distance transport<br>• Streamlining of customs clearance work (OSS for import/export applications) |

| | | |
|---|---|---|
| Overland transport | • Conditioning of the network of roads linking Phnom Penh with Bangkok and Ho Chi Minh<br>• Conditioning of the network of roads between Phnom Penh and Sihanoukville | • Mutual international truck service (to be achieved by the end of 2006)<br>• Study of prospects for conditioning the railway network |
| Air transport | • Conditioning of international air cargo functions at Phnom Penh airport<br>• Expansion of the small airport in the vicinity of Sihanoukville | • Use of the adjacent airport built under the Pol Pot regime<br>• Prospects for use for passenger transport for the time being |

Source: JICA Study Team

### (២) លក្ខខណ្ឌនៃហេដ្ឋារចនាសម្ព័ន្ធ "ទន់ ជាខួរក្បាល"

#### *(i) សកម្មភាពជំរុញសំរាប់ការទាក់ទាញការវិនិយោគបរទេសផ្ទាល់*

ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ទាមទារអោយមានការជំរុញគ្រប់មធ្យោបាយអំពីឧត្តមភាព ដែលផ្តល់ជូនដោយកម្ពុជា និងបរិស្ថានវិនិយោគ នៅពេលដែលកម្ពុជាកំពុងតែធ្វើដំណើរឆ្ពោះទៅរកភាពកាន់តែល្អប្រសើរឡើង ។ និយាយឱ្យចំទៅសកម្មភាពដែលជាអនុសាសន៍ (ដែលសកម្មភាពទាំងនេះសមស្របសំរាប់ឧស្សាហកម្ម ផ្សេងៗក្រៅពីអគ្គិសនី/អេឡិចត្រូនិច) រួមបញ្ចូលការរៀបចំសិក្ខាសាលា ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ដែលរៀបចំដោយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ការរៀបចំសិក្ខាសិលាស្តីពីការវិនិយោគ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា នៅប្រទេសជប៉ុន និងប្រទេសជិតខាងការបង្កើតឡើងនូវ "ការិយាល័យជប៉ុន" (Japan Desk) (រួមបញ្ចូលទាំងការបញ្ជូនជំនាញការ JICA) មានគោលបំណងទាក់ទាញការវិនិយោគមានប្រភពពីជប៉ុន ការរៀបចំរចនាសម្ព័ន្ធអោយបានល្អប្រសើរ ដើម្បីលើកទឹកចិត្តការវិនិយោគបរទេសផ្ទាល់នៅកម្ពុជា ទំនាក់ទំនងការទូតដើម្បីដឹកនាំមន្ត្រីតាមក្រសួងអោយចេះទាក់ទាញការវិនិយោគ ការធ្វើអោយមានទំនាក់ទំនងរវាងកម្ពុជា និងបរទេស ក្នុងការធ្វើយុទ្ធនាការទាក់ទាញការវិនិយោគ និងការបោះពុម្ពសៀវភៅណែនាំស្តីពីការវិនិយោគ (ជាភាសាជប៉ុន) ។ សកម្មភាពផ្សព្វផ្សាយត្រូវតែឆ្លុះបញ្ចាំងនូវការយល់ដឹងច្បាស់លាស់ អំពីឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ការផលិតដោយក្រុមហ៊ុនជប៉ុននៅក្នុងប្រទេសជិតខាងនិងការបែងចែកផលិតកម្មរបស់ជប៉ុន ។ ដើម្បីសំរេចគោលបំណងនេះចាំបាច់ត្រូវបណ្តុះបណ្តាលមន្ត្រី ក.អ.ក"គ.វ.ក" នូវសមត្ថភាពក្នុងការវិភាគស្ថានភាពឧស្សាហ កម្មសំខាន់ៗ ។

#### *(ii) ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញ*

នៅក្នុងក្រសែភ្នែកនៃក្រុមហ៊ុនឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ការចំណាយថោកលើកំលាំងពលកររបស់ កម្ពុជាគឺជាការទាក់ទាញដ៏សំខាន់មួយ ក្នុងការអោយក្រុមហ៊ុនបរទេសមកបោះទីតាំង ប៉ុន្តែវាពុំមែនជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់នោះទេ ។ ល័ក្ខខ័ណ្ឌផ្សេងៗទៀត ទាក់ទងនឹងពលករ រួមមានលទ្ធភាពក្នុងការផ្តល់កម្មករអោយបានជាប់លាប់ ហើយមានចំនួនពីរាប់រយនាក់ ទៅរាប់ពាន់នាក់សំរាប់រោងចក្រមួយ មានទឹកចិត្តខ្លាំងក្នុងការបំពេញការងារ និងមិនសូវស្វែងរកការងារថ្មី

អត្រាការចេះអាននិងសរសេរខ្ពស់(សមត្ថភាពក្នុងការអាននិងយល់ការណែនាំនានាក្នុងដំណើរការផលិតកម្ម) ការប៉ិនប្រសព្វគិតលេខជាមូលដ្ឋាននិងការត្រៀមខ្លួនដើម្បីធ្វើការលើសម៉ោងនិងធ្វើការពេលយប់ដើម្បីបង្កើនចំនួនការផលិត(អាស្រ័យលើប្រភេទផលិតផល)។ សមត្ថភាពផលិតកម្មនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នៅទាប ហើយត្រូវបានគេប៉ាន់ស្មានថាមានប្រហែលតែ ៣០% នៃសមត្ថភាពផលិតកម្មនៅក្នុងប្រទេសចិន។ ភារកិច្ចជាដំបូងទាក់ទងនឹងបញ្ហានេះ គឺការចាត់វិធានការដើម្បីពង្រឹងគុណភាពអប់រំនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ ដើម្បីបង្កើនអត្រាអ្នកចេះដឹង និងផ្សព្វផ្សាយចំណេះដឹងមូលដ្ឋាន នៅក្នុងវិស័យវិទ្យាសាស្ត្រ។ ទោះបីការផលិតក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក គឺជាការផលិតដែលទាមទារកំលាំងពលកម្មធ្ងន់ធ្ងរ ក៏ដោយ រោងចក្រនីមួយៗត្រូវតែបំពាក់គ្រឿងសំភារៈបរិក្ខារផលិតកម្មឱ្យបានគ្រប់គ្រាន់ ហើយការផលិត និងដំណើរការនានា ត្រូវតែគ្រប់គ្រង និងត្រួតពិនិត្យមើលយ៉ាងតឹងរឹងជាទីបំផុត។ បន្ថែមទៅលើកម្មករដែលមានសមត្ថភាពដ៏ប្រសើរនោះ វាជាការសំខាន់ណាស់ដែលកម្ពុជាត្រូវតែមានអ្នកបច្ចេកទេស និងវិស្វករពូកែៗ។ វាជាការចាំបាច់ក្នុងការបង្កើត និងពង្រឹងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងសាកលវិទ្យាល័យដែលត្រូវយកចិត្តទុកដាក់លើជំនាញវិទ្យាសាស្ត្រ និងវិស្វកម្ម។

*(iii) លក្ខខណ្ឌពលកម្ម*

ច្បាប់ការងារបានចែងជាបញ្ញត្តិរយៈពេលនៃការងារគឺ មិនឱ្យលើសពី ៨ម៉ោងក្នុងមួយថ្ងៃ និង៤៨ម៉ោងក្នុងមួយសប្តាហ៍។ តាមច្បាប់ ការធ្វើការលើសម៉ោងមិនអាចលើសពី ២ម៉ោងឡើយ ប៉ុន្តែការពិភាក្សាខាងដើមនៃកម្មករ និងអ្នកគ្រប់គ្រង វាមានលទ្ធភាពអាចទទួលយកបានស្មើឬលើសពី ២ម៉ោងនៃការធ្វើការលើសម៉ោង។ ប៉ុន្តែ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង កម្ពុជា មានការទូទាត់សំរាប់ថ្ងៃឈប់សំរាកច្រើនជាងគេ។ ជាឧទាហរណ៍ មាត្រាទី ១៦៦ បានចែងថានិយោជិត មានសិទ្ធិទទួលបាន ១.៥ថ្ងៃសំរាក ក្នុង១ខែ និង ១៨ថ្ងៃក្នុងមួយឆ្នាំ ហើយចំនួននេះ ត្រូវកើនឡើង១ថ្ងៃរៀងរាល់បីឆ្នាំ។ មានប្បញ្ញត្តិបន្ថែសំរាប់ការឈប់សំរាកពិសេស (មាត្រាទី ១៧១) ជាឧទាហរណ៍ និយោជិត ត្រូវបានអនុញ្ញាតិឱ្យឈប់សំរាកមើលថែទាំសមាជិកគ្រួសារឈឺ និងសំរាលកូន សំរាប់រយៈពេល ៩០ថ្ងៃ ដោយទទួលបានការទូទាត់ជាប្រៀវត្ស ៥០% ជាប្រចាំ។

ក្រុមហ៊ុនបរទេស ដែលពិចារណាលើការវិនិយោគនៅកម្ពុជា ដោយហេតុថាការផលិតមានការប្រកួតប្រជែងខាងការចំណាយជួលកម្មករដែលមានកំរិតតំលៃពលកម្មទាបតែឧស្សាហ៍ព្យាយាម បទបញ្ជាតាមវេន និងបទបញ្ញត្តិ សំរាប់ការចំណាយលើសលុបពេលឈប់សំរាក អាចនឹងមានអារម្មណ៍មិនចង់វិនិយោគ។ គេក៏បានលើកឡើងដែរថាការកែលំអត្រូវតែធ្វើឡើងទាក់ទងទៅនឹងបញ្ហាជាមួយសហជីពកម្មករដែលកំពុងតែមានជំលោះនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស នៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិក ភាគីកម្ពុជាគួរតែពិចារណាអំពីការអនុញ្ញាតសំរាប់រយៈពេលធ្វើការ និងការរៀបចំថ្ងៃឈប់សំរាកមានប្រាក់ខែ ដូចគ្នានឹងប្រទេសជិតខាង និងការ

រៀបចំសហជីពកម្មករដែលមានទំនុកចិត្តជាមួយគណៈគ្រប់គ្រង ។

## ៨.៤.២ ផែនទីបង្ហាញផ្លូវ សំរាប់គោលនយោបាយការវិនិយោគបរទេសផ្ទាល់ នៅក្នុងឧស្សាហកម្មគ្រឿងអគ្គិសនី/អេឡិចត្រូនិក

ខ្លឹមសារនៅផ្នែកខាងដើម១ បានលើកឡើងអំពីលក្ខខ័ណនៃហេដ្ឋារចនាសម្ព័ន្ធ "រូបវ័ន្ត" និង"ជាខួរក្បាល" ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់នៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/អេឡិចត្រូនិច ។ ខ្លឹមសារក្នុងផ្នែកនេះលើកឡើងពីវិធានការជាក់ស្តែងសំរាប់បំពេញល័ក្ខខ័ណ្ឌទាំងនេះ ដែលរៀបតាមលំដាប់ពេលវេលាពីរយៈមធ្យមទៅរយៈពេលវែងរហូតដល់ឆ្នាំ ២០២០ ។

នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ "ជារូបវ័ន្ត" គួរចាត់វិធានការដើម្បីរៀបចំតំបន់សេដ្ឋកិច្ចពិសេស SEZ, PPSEZ ដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០១០។ តំបន់ទាំងពីរនេះ នឹងក្លាយជាសួនឧស្សាហកម្មគំរូ សំរាប់ការសាងសង់សួនឧស្សាហកម្មផ្សេងៗទៀត ។ ចំណែកការរៀបចំបណ្តាញដឹកជញ្ជូនអន្តរជាតិ ល័ក្ខខ័ណ្ឌកំពង់ផែ និងបណ្តាញដឹកជញ្ជូនផ្លូវគោកគួរតែអាចដំណើរការបានក្នុងឆ្នាំ ២០១០ ប៉ុន្តែបណ្តាញផ្លូវថ្នល់ត្រូវតែពង្រីកអោយបានកាន់តែច្រើនទៅតាមតំរូវការជាក់ស្តែង ។ កម្ពុជាគួរតែបំពេញល័ក្ខខ័ណ្ឌដឹកជញ្ជូនផ្លូវគោក សំរាប់ការដឹកជញ្ជូនទំនិញជាអន្តរជាតិ តាមផែនការយូរ អង្វែងដែលគេបានកំណត់រួមគ្នាយូរហើយ ។

នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ "ទន់ជាខួរក្បាល" ផែនការរយៈពេលខ្លីចំបង គឺការរៀបចំនីតិវិធីទាក់ទងទៅនឹងរបាយការណ៍វិនិយោគ និងការនាំចេញនាំ-ចូលអោយកាន់តែងាយស្រួល និងមានប្រសិទ្ធភាពដើម្បីត្រួសត្រាយអោយមានសេវាចេញចូលនៅមួយកន្លែង ។ នៅក្នុងរយៈពេលខ្លី ភាគីកម្ពុជាគួរតែពិចារណាធ្វើការកែសំរួលល័ក្ខខ័ណ្ឌការងារផ្សេងៗទៀតឱ្យដូចគ្នានឹងប្រទេសក្នុងតំបន់។ ជាមួយនឹងល័ក្ខខ័ណ្ឌដែលមាន លក្ខណៈជាប្រព័ន្ធ សំរាប់ទាក់ទាញការវិនិយោគបរទេសផ្ទាល់ វាជាការប្រសើរណាស់ក្នុងការបង្កើតអោយមានស្ថាប័ន ដើម្បីផ្សព្វផ្សាយ និងធ្វើយុទ្ធនាការឃោសនាអោយបានទូលំទូលាយ ។ ដោយសារកង្វះខាតថវិកា មន្ត្រីថ្នាក់ខ្ពស់របស់រដ្ឋាភិបាលចាំបាច់ធ្វើការផ្សព្វផ្សាយអោយបានសកម្ម និងផ្តល់ព័ត៌មាននៅក្នុងឱកាសផ្សេងៗ ដូចជាដំណើរទស្សនៈកិច្ច ទៅកាន់ប្រទេសដទៃជាដើម ។ ក្នុងរយៈពេលវែង ស្ថាប័ននេះគួរតែរៀបចំដើម្បីអភិវឌ្ឍន៏ធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញ ។ វាគឺជាការមិនអាចខ្វះ បានក្នុងការរៀបចំអោយមានស្ថាប័នក្រៅក្រុមហ៊ុន ដើម្បីបណ្តុះបណ្តាលអ្នកបច្ចេកទេស វិស្វករ និងបុគ្គលិកដទៃទៀត ដែលត្រូវបំរើការងារនៅក្នុងឧស្សាហកម្មឧបករណ៍អគ្គិសនី/ អេឡិចត្រូនិក ។

## តារាង ៨-៤-១ ផែនទីបង្ហាញផ្លូវសំរាប់គោលនយោបាយ FDI នៃឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិចត្រូនិក

| | 2007-2010 | 2011-2015 | 2016-2020 |
|---|---|---|---|
| Conditioning of the "hard" infrastructure | Conditioning of industrial parks with EPZ functions (Sihanoukville SEZ etc.) | Second round of conditioning SEZ industrial parks | |
| | Preparation of the power supply setup | | |
| | Conditioning of the logistics infrastructure (international container carrier transport, international truck transport, international air cargo) | | |
| Conditioning of the "soft" infrastructure | Simplification of procedural requirements related to investment reports and import/export | | |
| | Studies with a view to revising labor conditions | Establishment of organizations for HRD and skill training (vocational schools, colleges of science and engineering) | |
| | Promotional organization and activities for FDI attraction | | |

Source: JICA Study Team

# ជំពូកទី ៩

# ឧស្សាហៈវិស័យ និងអនុសាសន៍ ស្តីពីលក្ខខណ្ឌវិនិយោគ សំរាប់ការទាក់ទាញ ឧស្សាហកម្មគ្រឿងម៉ាស៊ីនបរទេស មកកម្ពុជា

## ៩.១ ចរិតលក្ខណៈនៃឧស្សាហកម្មម៉ាស៊ីនរបស់កម្ពុជា

### ៩.១.១ ស្ថានភាពបច្ចុប្បន្ន នៃឧស្សាហកម្មម៉ាស៊ីន

ឧស្សាហកម្មគ្រឿងម៉ាស៊ីននៅកម្ពុជា មិនទាន់មានការអភិវឌ្ឍន៍នៅឡើយ។ ផ្អែកតាមទិន្នន័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានរោងចក្រកម្មន្តសាលទាំងអស់ប្រមាណ ៣៧២ ដែលត្រូវបានចុះបញ្ជីតាំងពីឆ្នាំ ១៩៩៤ រហូតដល់ចុងឆ្នាំ២០០៣នៅកម្ពុជា។ ក្នុងចំណោមនោះ មានតែ ១២រោងចក្រប៉ុណ្ណោះ ដែលជាឧស្សាហកម្មគ្រឿងម៉ាស៊ីន (រោងចក្រផលិតលោហៈ)។ រោងចក្រទាំង ១២ នេះ គឺរោងចក្រ ៤ កែច្នៃបន្ទះដែកថែប រោងចក្រ ៣ ទៀត ផលិតម៉ូតូ ក្រៅពីនេះគឺជារោងចក្រផលិត គ្រឿងសំណង់ ឧបករណ៍ផ្ទះបាយ ស៊ីទែនទឹក ទូរទស្សន៍ និងម៉ាស៊ីនកុំព្យូទ័រ និងប្រដាប់ផ្សារ។ នៅក្នុងប្រទេសពុំទាន់មានការផលិត យានយន្ត គ្រឿងអេឡិចត្រូនិច និងអគ្គិសនី ហើយសូម្បីតែ ផលិតផលកម្មន្តសាលមិនមានបច្ចេកវិទ្យាខ្ពស់ ដូចជាឆ្នាំងអ៊ុត និងកង្ហារអគ្គិសនី ក៏មិនទាន់មាននៅឡើយដែរ។

ក្រុមហ៊ុនបរទេសដែលមានសកម្មភាពការងារលើផ្នែកឧស្សាហកម្ម គ្រឿងម៉ាស៊ីននៅមានចំនួនតិចតួចណាស់។ មានសាខាក្រុមហ៊ុនជប៉ុនតែពីរប៉ុណ្ណោះ ដែលកំពុងប្រតិបត្តិការផលិតនៅកម្ពុជា គឺសាជីវកម្មម៉ូតូស៊ុយហ្សុយគី (Suzuki Motor Corporation) ដែល ផលិតម៉ូតូ និងឧស្សាហកម្មសង្កសីបូពា ជាអ្នកកែច្នៃសន្លឹកសង្កសី (ដែលបានវិនិយោគមួយចំណែកនៃសាជីកម្មស៊ុយមីតូម៉ូ)។ ស្ទើរតែគ្មានការវិនិយោគលើផ្នែកឧស្សាហកម្មគ្រឿងម៉ាស៊ីន ដែលមានប្រភពមកពីប្រទេសជប៉ុនទេ។

### ៩.១.២ ស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មគាំទ្រ

ចំនួនរោងចក្រតម្លើងតិចតួចមួយ បានរារាំងការអភិវឌ្ឍន៍នៃឧស្សាហកម្មគាំទ្រ។ លទ្ធផលនៃការសិក្សាតាមរោងចក្រមួយចំនួន របស់ក្រុមសិក្សាចៃកា ចង្អុលបង្ហាញថា ស្ទើរតែគ្រប់វត្ថុធាតុដើមទាំងអស់សុទ្ធតែនាំចូលពីបរទេស ចាប់ពីបន្ទះដែករហូតដល់ខ្មៅមួល។ ជាក់ស្តែង សាជីវកម្មម៉ាស៊ីនម៉ាកស៊ុយហ្សុយ គឺនាំចូលពីសាខារបស់ខ្លួននៅប្រទេសថៃ នូវគ្រប់បំណែកនៃម៉ូតូ (ធុន១១០ និង១២៥ សេះ) ដែលត្រូវផលិតនៅកម្ពុជា។ ក្រុមហ៊ុនសង្កសីបូពាក៏ធ្វើលទ្ធកម្មស្ទើរគ្រប់សម្ភារៈបំរើការផលិតទាំងអស់ពីបរទេស រួមទាំងបន្ទះលោហៈ ដែកសសៃ និងបន្ទះស័ង្កសី ដើម្បីប្រើប្រាស់ក្នុងផលិតកម្ម។

ការវិនិយោគបរទេសផ្ទាល់លើឧស្សាហកម្មគ្រឿងម៉ាស៊ីន នៅក្នុងប្រទេសកម្ពុជា មិនមានដំណើរការធំដុំទេ ដោយសារទីផ្សារក្នុងស្រុកតូច និងបរិស្ថានវិនិយោគមិនអំណោយផល។ វិស័យនេះ ត្រូវរង់ចាំការពន្លឿននៃកិច្ច

អភិវឌ្ឍន៍ឧស្សាហកម្មគាំទ្រ។

### ៩.១.៣ លក្ខខណ្ឌធុរកិច្ចនៃក្រុមហ៊ុនបរទេស ឬក្នុងស្រុកសំខាន់ៗ

ក្រុមហ៊ុនផលិតម៉ូតូទាំងពីររបស់ជប៉ុន មានចំណែកលើសលប់នៅក្នុងទីផ្សារកម្ពុជា បើទោះ ពួកគេ ត្រូវបានប្រឈមមុខទៅនឹង ការប្រកួតប្រជែងតម្លៃខ្ពស់បណ្ដាលមកពីទំនិញនាំចូលជាច្រើនដែលរួមទាំងទំនិញជជុះ និងទំនិញគេចពន្ធមកពី ប្រទេសចិន វៀតណាម និងថៃ ក៏ដោយ។ ក្រុមហ៊ុនទាំងពីរនេះ អាចរក្សាតម្លៃទំនិញទាបដោយសារថាអត្រាពន្ធនាំចូលបំណែកម៉ូតូ ដែលត្រូវតម្លើងនៅក្នុងប្រទេសមាន ចំនួន ៩៦ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយគ្រឿង ចំណែកពន្ធលើម៉ូតូនាំចូល មានចំនួនរហូតដល់ ១៩២ ដុល្លារសហរដ្ឋអាមេរិកក្នុង មួយគ្រឿង។ យ៉ាងណាក៏ដោយ បើសិនជាមានការនាំចូលទំនិញគេចពន្ធច្រើននោះ ក្រុមហ៊ុនទាំងពីរនេះនឹងបាត់បង់នូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនមិនខាន។

### ៩.១.៤ ការវិភាគ SWOT នៃឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា

ឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា ត្រូវបានពិចារណាថាមានភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៍ភាព និងភាពគំរាមកំហែងដូចក្នុងតារាងខាងក្រោម :

**តារាង ៩-១-១ ការវិភាគ SWOT នៃឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា**

| <u>***ភាពខ្លាំង:***</u> | <u>***ភាពខ្សោយ:***</u> |
|---|---|
| - កំលាំងពលកម្មមានភាពប្រជែងឈ្នះខ្លាំងនៅក្នុងតំបន់អាស៊ី<br>- ទីតាំងយុទ្ធសាស្ត្រល្អជិត ថៃឡង់ដ៏ និងវៀតណាម<br>- កំណើននៃសេចក្ដីត្រូវការទំនិញមានគុណភាពល្អជាមួយកំណើនប្រាក់ចំណូល | - មិនទាន់អភិវឌ្ឍន៍បានល្អនូវហេដ្ឋារចនាសម្ព័ន្ធ<br>- ថ្លៃថាមពលខ្ពស់ ជាពិសេសថ្លៃអគ្គីសនី<br>- អវត្តមានរបស់ឧស្សាហកម្មគាំទ្រ<br>- នីតិវិធីនាំចេញ-ចូល មានភាពមិនរលូន<br>- មិនទាន់មានការអភិវឌ្ឍន៍សួនឧស្សាហកម្មត្រឹមត្រូវ |
| <u>***កាលានុវត្តន៍ភាព :***</u> | <u>***ភាពគំរាមកំហែង :***</u> |
| - កំណើនពាណិជ្ជកម្មនៅអាស៊ាន<br>- ឈានមុខក្នុងការបែងចែកពលកម្មនៅអាស៊ាន<br>- សមាច័យក្នុងផ្នែករថយន្ត និងអេឡិកត្រូនិកនៅថៃឡង់ដ៏<br>- ថ្លៃពលកម្មកើនឡើងនៅថៃឡង់ដ៏ និងវៀតណាម<br>- ឥទ្ធិពលនៃការខ្វះ និងចំរាញ់ប្រេងកាត និងឧស្ម័ន<br>- វឌ្ឍនភាពនៃយន្តការនីយកម្មក្នុងវិស័យកសិកម្ម | - លំហូរចូលទំនិញថ្លៃថោកគេចពន្ធច្រើន<br>- ការកាត់បន្ថយពន្ធគយក្រោមទំរង់ការ AFTA |

ប្រភព : ក្រុមសិក្សារបស់ JICA

## ៩.២ ទស្សនៈវិស័យសំរាប់ឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា : ការប្រែប្រួលបរិស្ថានអន្តរជាតិ និង សេណារីយោសំរាប់ការអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម និងវែង

### ៩.២.១ ការប្រែប្រួលបរិស្ថានអន្តរជាតិ

បរិយាកាសជុំវិញឧស្សាហកម្មគ្រឿងម៉ាស៊ីននៅក្នុងប្រទេសកម្ពុជាកំពុងមានការប្រែប្រួលយ៉ាងខ្លាំង។ ស្របទៅនឹងវឌ្ឍនកិច្ចក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៃប្រទេសជាសមាជិកអាស៊ាន នៅក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់អាស៊ាន ត្រូវបាននឹងកំពុងពន្លឿន។

**(1) *កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការអនុវត្តន៍តំបន់ពាណិជ្ជកម្មសេរីអាស៊ាន***

អាស៊ានបានដាក់ចេញនូវកម្មវិធីដ៏ទូលំទូលាយមួយ ស្តីពីការកាត់បន្ថយអត្រាពន្ធគយ ក្រោមទំរង់ផែនការពន្ធគយអនុគ្រោះ (CEPT)។ ប្រទេសជាស្ថាបនិកទាំង ៦ បានចាប់ផ្តើមអនុវត្តការបញ្ចុះអត្រាពន្ធគយនេះចាប់តាំងពីខែមករា ឆ្នាំ២០០៣ តាមពិត ពន្ធគយលើទំនិញពាណិជ្ជ (លើកលែងទំនិញជាក់លាក់មួយចំនួន) ក្នុងទីផ្សាផ្ទៃក្នុងអាស៊ាន ត្រូវបានកាត់បន្ថយមកនៅត្រឹមតែពី 0 ទៅ ៥ % ប៉ុណ្ណោះ។ ប្រទេសជា សមាជិកអាស៊ាន ៤ ផ្សេងទៀតក៏បានឯកភាពទៅនឹងការកាត់បន្ថយអត្រាពន្ធទំនិញនាំចូលអោយមកនៅត្រឹមតែពី 0 ទៅ ៥ % នេះដែរ ដោយកំណត់ឆ្នាំ ២០០៦ សំរាប់ប្រទេស វៀតណាម ២០០៨ សំរាប់ប្រទេសឡាវ និងភូមា និង២០១០ សំរាប់ប្រទេសកម្ពុជា។ ប្រទេសជាសមាជិកទាំងអស់ ទាមទាឱ្យកាត់បន្ថយពន្ធគយ នូវគ្រប់មុខទំនិញ និងបង្កើតទីផ្សារសមាហរណកម្មមួយនៅត្រឹមឆ្នាំ ២០១៥ ជាគោលដៅចុងក្រោយ។ ពាណិជ្ជកម្មនៅក្នុងទីផ្សារអាស៊ាន ត្រូវបានរំពឹងថានឹងកើនឡើងយ៉ាងលឿនស្របទៅនឹងការបន្ថយពន្ធគយជាបណ្តើៗនៅក្នុងតំបន់។

ប្រសិនបើកម្មវិធី AFTA ត្រូវបានអនុវត្តតាមផែនការគ្រោងទុក ប្រភេទឧស្សាហកម្មគ្រឿងម៉ាស៊ីននៅក្នុងប្រទេសកម្ពុជា នឹងមានការរីកចំរើនដោយសារតែកំណើនពាណិជ្ជកម្ម ដែលបានលើកឡើងខាងលើ ដោយស្របទៅនឹងការលូតលាស់នៃការបែងចែកការងារ។ លើសពីនេះទៀត ការធ្វើសមាហរណកម្មទីផ្សារនឹងផ្តល់ឱកាសអោយប្រទេសកម្ពុជា នឹងផ្តល់កាលានុវត្តន៍ភាពសំរាប់កម្ពុជា មិនត្រឹមតែដើម្បីបង្កើនពាណិជ្ជកម្មទេ ថែមទាំងសំរេចបាននូវតុល្យភាពសេដ្ឋកិច្ច ដែលនឹងទាក់ទាញការវិនិយោគបរទេសផ្ទាល់ និងផ្ទេរបច្ចេកវិទ្យាចាំបាច់សំរាប់ការអភិវឌ្ឍន៍ចិរភាព។

**(2) *ការប្រមូលផ្តុំឧស្សាហកម្មគ្រឿងម៉ាស៊ីន (ឧស្សាហកម្មបរិក្ខារដឹកជញ្ជូន) នៅប្រទេសថៃ***

ចំណុចសំខាន់មួយនៃចលនានៅក្នុងអាស៊ាន គឺសមាច័យឧស្សាហកម្មក្នុងវិស័យផ្សេងៗនៃឧស្សាហកម្មយានយន្ត និងគ្រឿងអគ្គិសនីនៅប្រទេសថៃ ដែលបានក្លាយជាមជ្ឈមណ្ឌលផលិតកម្ម និងលក់នៅក្នុងទីផ្សារអាស៊ាន។ បរិមាណផលិតកម្មយានយន្តនៅឆ្នាំ ២០០៥ មានចំនួន ១.១២២ ពាន់គ្រឿង ដែលកើនឡើង ២១ % បើប្រៀបទៅនឹងឆ្នាំមុន។ ក្នុងនោះយានយន្តចំនួន ៤៤១ ពាន់គ្រឿងត្រូវបាននាំចេញ ដែលកើនឡើង ៣៣ % បើប្រៀបទៅនឹងការនាំចេញនៅឆ្នាំមុន ដែលមានន័យថាឧស្សាហកម្មយានយន្ត បានក្លាយជាឧស្សាហកម្មនាំចេញមួយដ៏សំខាន់នៅក្នុងប្រទេសថៃ។

**តារាង ៩-២-១ : ផលិតកម្មយានយន្តនៅប្រទេសអាស៊ីសំខាន់ៗ**

| ***Country*** | **Year** | | | | | | |
|---|---|---|---|---|---|---|---|
| | 2000 | **2001** | **2002** | **2003** | **2004** | **2005** | **yr/yr (%)** |
| Thailand | 411,721 | 459,283 | 584,897 | 742,062 | 928,081 | 1,122,395 | 20.9 |
| Malaysia | 359,195 | 428,701 | 456,822 | 424,107 | 471,975 | 563,408 | 19.4 |
| Philippines | 68,832 | 62,460 | 75,119 | 86,067 | 78,531 | 71,212 | (-9.3) |
| Indonesia | 299,514 | 279,187 | 296,509 | 322,044 | 422,099 | 500,710 | 18.6 |
| Vietnam | 13,956 | 19,556 | 26,873 | 42,556 | 40,141 | 35,264 | (-12.1) |
| China | 2,069,423 | 2,347,616 | 3,286,804 | 4,443,686 | 5,070,527 | 5,707,688 | 12.6 |
| Korea | 3,114,998 | 2,946,329 | 3,147,584 | 3,177,870 | 3,469,464 | 3,699,350 | 6.6 |
| Taiwan | 372,613 | 271,704 | 333,699 | 386,686 | 430,821 | 446,345 | 3.6 |
| India | 896,733 | 840,259 | 924,463 | 1,173,467 | 1,521,487 | 1,643,670 | 8.0 |
| Total | 4,384,344 | 4,058,292 | 4,405,746 | 4,738,023 | 5,421,772 | 5,789,365 | 6.8 |

Notes: Figures for the Philippines and Indonesia are estimates.
Source: FOURIN's monthly report on the global automotive industry (Original source: automobile manufacturers associations in each country)

ចាប់តាំងពីដំណាច់ទសវត្សរ៍ឆ្នាំ ១៩៩០ ដោយផ្អែកលើយុទ្ធសាស្ត្រនៃសកលភាវូបនីយកម្មរបស់ខ្លួន ក្រុមហ៊ុនតម្លើងយានយន្តរបស់ប្រទេសជប៉ុនជាច្រើនបានធ្វើការវិនិយោគទុនដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងប្រទេសថៃ។ ជាមួយការពង្រីកនៃក្រុមហ៊ុនផលិតយានយន្ត នៅអឺរ៉ុប និងនៅអាមេរិក ការប្រមូលផ្តុំនៃឧស្សាហកម្មយានយន្ត បានរីកចំរើនយ៉ាងឆាប់រហ័សនៅប្រទេសថៃ ជាពិសេសនៅជុំវិញទីក្រុងបាងកក ដែលត្រូវបានហៅថា "Detroit of Asia" ។ បរិមាណការវិនិយោគបរទេស ដែលមានប្រភពពីប្រទេស ជប៉ុន នៅឆ្នាំ ២០០៤ ក្នុងតំបន់អាស៊ានមានចំនួន ២៩៦,៨ កោដិយេន ក្នុងនោះមួយភាគបួន ១២៧,៣ កោដិយេន ត្រូវបានវិនិយោគនៅក្នុងប្រទេសថៃ។ ហើយការវិនិយោគទៅលើឧស្សាហកម្មផលិតយានយន្តមានបរិមាណច្រើន។

លើសពីនេះទៀត ក្រុមហ៊ុនតូយ៉ូតា ដែលមានលំដាប់ថ្នាក់ខ្ពស់ជាងគេបង្អស់ និងក្រុមហ៊ុនអ៊ីស៊ុយហ្សុយ ដែលមានលំដាប់ថ្នាក់ខ្ពស់ជាងគេទីពីរនៅក្នុងទីផ្សារយានយន្តប្រទេសថៃមានមូលដ្ឋានផលិតកម្មរបស់ខ្លួននៅក្នុងខេត្តសាមុតប្រាកាន ដែលជាខេត្តមួយជិតទីក្រុងបាងកក។ ចំណែកក្រុមហ៊ុន AutoAlliance（រួមគ្នារវាង Mazda និង Ford）ក្រុមហ៊ុន General Motors ក្រុមហ៊ុន BMW និងក្រុមហ៊ុន Mitsubishi មានរោងចក្រតម្លើងនៅខេត្តរ៉ាយ៉ង។ រោងចក្រផលិតគ្រឿងបន្លាស់យានយន្តចំនួនប្រមាណ ២,០០០ ក៏បានប្រមូលផ្តុំនៅទីក្រុងបាងកកដើម្បីបំពេញការងារដែលបែងចែកដោយក្រុមហ៊ុនទាំងនេះ។

ព្រឹត្តិការណ៍សំខាន់គួរឱ្យកត់សំគាល់មួយនៅក្នុងប្រធានបទនេះ គឺថាក្រុមហ៊ុនតូយ៉ូតា បានជ្រើសរើសយកប្រទេសថៃជាទីតាំងផលិតកម្មសំរាប់សកលលោកនៃរថយន្ត Pickup ក្រោមកម្មវិធីយានយន្តពហុបំណងនៃការប្រឌិតថ្មីជាអន្តរជាតិ（IMV）។ បន្ទាប់ពីក្រុមហ៊ុនតូយូតាបានធ្វើការវិនិយោគទ្រង់ទ្រាយធំនេះរួចមក រោងចក្រផលិតគ្រឿងបំណែករយន្តចំនួនជាង ៥០ បានធ្វើការវិនិយោគ ហើយការផលិតរថយន្ត Pickup បានចាប់ផ្តើមនៅចុងឆ្នាំ ២០០៤។

តាមប្រភពព័ត៌មានពីអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (JETRO)[43] ក្រុមហ៊ុន Nissan Motor Co, Ltd កំពុងរៀបចំផែនការបណ្តាក់ទុនដ៏ច្រើននៅប្រទេសថៃ ដើម្បីចាប់ផ្តើមផលិតរថយន្ត Pickup តូចៗនៅចុងឆ្នាំ ២០០៦។

ដូចបានលើកឡើងខាងលើ ឧស្សាហកម្មបំណែកយានយន្ត ដោយរួមមានទាំងក្រុមហ៊ុនតម្លើងគាំទ្រ ក៏បានចាប់ផ្តើមបង្កើតធុរកិច្ចរបស់គេក្នុងប្រទេសថៃផងដែរ។ យោងតាមវិទ្យាស្ថានយានយន្តរបស់ថៃ មានក្រុមហ៊ុនតម្លើងប្រមាណ ១៦ និងក្រុមហ៊ុនផលិតម៉ូតូប្រមាណ៥ កំពុងប្រតិបត្តិការនៅប្រទេសថៃ ក្រុមហ៊ុនទាំងអស់នោះសុទ្ធតែជាសាខាក្រុមហ៊ុនបរទេសទាំងអស់ ដូចមានបង្ហាញជូនក្នុងគំនូរខាងក្រោម។ ក្រុមហ៊ុនតម្លើងទាំងនេះ ត្រូវបានគាំទ្រដោយក្រុមហ៊ុនចំនួន ៧០៩ ក្រុមហ៊ុននៅក្នុងឧស្សាហម្មផលិតគ្រឿងបំណែកយានយន្ត ដែលកំពុងបំរើជាអ្នកស៊ីឈ្នួលបឋម (Tier 1)។ ក្នុង ចំណោម ក្រុមហ៊ុនថ្នាក់ទាបបំផុត មានក្រុមហ៊ុនក្នុងស្រុករបស់ថៃប្រមាណជា ១,២០០ កំពុងធ្វើការជាអ្នកស៊ីឈ្នួលបន្ត (Tiers 2 and 3)[44]។

**រូបភាព ៩-២-១ : រចនាសម្ព័ន្ធនៃឧស្សាហកម្មបរិក្ខាដឹកជញ្ជូននៅថៃឡង់ដ៏**




ទន្ទឹមនឹងនេះ ចំនួនសរុបនៃក្រុមហ៊ុនផលិតដែលត្រូវបានវិនិយោគដោយក្រុមហ៊ុនសមាជិក (៤៥៨ ទាំងមូល

---

[43] *JETRO "FTA policy of BRICs and ASEAN Countries and Strategies of Japanese Companies" December 2005*

[44] *JETRO "FTA policy of BRICs and ASEAN Countries and Strategies of Japanese Companies" December 2005*

គិតត្រឹមខែមេសា ឆ្នាំ ២០០៥) នៃសមាគមន៍ឧស្សាហកម្មបំណែកយានយន្តជប៉ុននៅអាស៊ាន គឺ ៣៧៣។ ស្ទើរពាក់កណ្ដាលនៃក្រុមហ៊ុនទាំងអស់ ត្រូវបានដាក់ទីតាំងនៅប្រទេសថៃ ទាំងអស់ ១៨៦ ក្រុមហ៊ុន។ ខណៈដែលចំនួនសរុបនៃក្រុមហ៊ុនផលិតបំណែកដែលមានសាខាបរទេស ត្រូវបានគណនាប្រមាណជា ៣៩៥ ផ្អែកតាមទិន្នន័យដែលផ្ដល់ដោយ វិទ្យាស្ថានយានយន្តថៃ វាអាចសន្និដ្ឋានបានថា ភាគច្រើននៃក្រុមហ៊ុនផលិតទាំងនោះនៅប្រទេសថៃ គឺជាក្រុមហ៊ុនជប៉ុន។

**តារាង ៩-២-២ : សាខាក្រុមហ៊ុនផលិតបំណែកយានយន្តជប៉ុននៅអាស៊ី**

| Country/Region | | | Production | Sales | Technology Agreement | Others |
|---|---|---|---|---|---|---|
| | ASEAN | Thailand | 186 | 19 | 40 | 6 |
| | | Indonesia | 84 | 4 | 28 | 0 |
| | | Philippines | 43 | 1 | 5 | 6 |
| | | Malaysia | 34 | 4 | 39 | 1 |
| | | Vietnam | 18 | 0 | 3 | 1 |
| | | Singapore | 8 | 23 | 0 | 5 |
| | | Sub total | 373 | 51 | 115 | 19 |
| | Other Asia | China | 294 | 17 | 25 | 12 |
| | | Hong Kong | 3 | 19 | 0 | 2 |
| | | Taiwan | 66 | 6 | 69 | 1 |
| | | Korea | 55 | 6 | 79 | 5 |
| | | India | 55 | 1 | 36 | 2 |
| | | Pakistan | 3 | 0 | 13 | 0 |
| | | Sub total | 476 | 49 | 222 | 22 |
| Asia (total) | | | 849 | 100 | 337 | 41 |
| Oceania | | | 9 | 16 | 14 | 3 |
| North America | | | 310 | 69 | 42 | 58 |
| Latin America | | | 77 | 12 | 29 | 3 |
| Europe | | | 166 | 72 | 53 | 29 |
| Others | | | 17 | 2 | 19 | 1 |
| Total | | | 1,428 | 271 | 494 | 135 |

Source: Japan Auto Parts Industries Association (surveyed in April 2005)

### (3) វឌ្ឍនភាពនៃប្រព័ន្ធភស្តុភា

កម្មវិធីមហាអនុតំបន់មេគង្គ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មទីផ្សារក្នុងប្រទេសជាសមាជិកអាស៊ាន និងរវាងក្រុមប្រទេសអាស៊ាន និងប្រទេសចិន ក្នុងន័យតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ គំរោងនេះគឺជាទំរង់ផែនការឆ្លងកាត់ព្រំដែនមួយ ដើម្បីអភិវឌ្ឍន៍អនុតំបន់មេគង្គ (ប្រទេសវៀតណាម កម្ពុជា ថៃ ភូមា ឡាវ និងខេត្តយូណានប្រទេសចិន) ក្រោមគំនិតផ្តួចផ្តើមនៃធនាគារអភិវឌ្ឍន៍អាស៊ី។ ការផ្តោតជាសំខាន់នៃគំរោងគឺដើម្បីកែលំអបណ្តាញផ្លូវ នៃទីផ្សារក្នុងតំបន់ (ប្រវែងផ្លូវសរុបប្រមាណ ៤៥០០ គីឡូម៉ែត្រ) និងផ្តល់កិច្ចសម្រួល

ភស្តុភា តាមរយៈការថែរទាំផ្លូវសំខាន់ៗ ដូចជារបៀងសេដ្ឋកិច្ចត្បូង-ជើង និងរបៀងសេដ្ឋកិច្ចលិច-កើត ។

ប្រទេសជប៉ុន ក៏បានផ្ដល់ការគាំទ្រជាច្រើនផ្នែកដល់គំរោង GMS នេះដែរ ដោយផ្ដោតទៅលើរបៀងសេដ្ឋកិច្ច លិច-កើត ទាំងពីរដំណាក់កាល (ពីវៀតណាមទៅភូមា ដោយកាត់តាមប្រទេសកម្ពុជា និងថៃ) ។ ក្រៅពីនេះ ផ្នែកឯកជនជប៉ុន ដែលជាតួអង្គពិត បានចាប់ផ្ដើមសហប្រតិបត្តិការជាមួយនឹងគំរោង GMS តាមរយៈការជំរុញវិនិយោគ និងពាណិជ្ជកម្មចូលក្នុងតំបន់ ។

វាងាយស្រួលក្នុងការយល់ដឹងពីសារសំខាន់នៃកំណែទំរង់ហេដ្ឋារចនាសម្ព័ន្ធភស្តុភាស្ដីពីគំរោង GMS ណាស់ ជាឧទាហរណ៍ ការដឹកជញ្ជូនពីបាងកក ទៅទីក្រុងហូជីមិញ ឬខេត្តដាណាំង ប្រសិនបើដឹកជញ្ជូនតាមផ្លូវគោកនៃរបៀងសេដ្ឋកិច្ចលិច-កើត គឺត្រូវប្រើពេលវេលាត្រឹមតែ ៣ថ្ងៃប៉ុណ្ណោះ ធៀបទៅនឹងពេលមុននិងបច្ចុប្បន្ន ដែលត្រូវដឹកជញ្ជូនតាមផ្លូវទឹកហើយប្រើពេលរហូតដល់ទៅ១សប្ដាហ៍ ព្រមទាំងឆ្លងកាត់នីតិវិធីប្រតិវេទ៍គយនៅក្នុងប្រទេសឆ្លងកាត់ផង ។ ដូចគ្នានេះដែរ ក្រុមហ៊ុនមួយនៅក្នុងមហាអនុតំបន់មេគង្គនេះ នឹងមានលទ្ធភាពអាចនាំចេញគ្រឿងបំណែកពីប្រទេសថៃ រួចតម្លើងជាផលិតផលសំរេចនៅប្រទេសកម្ពុជា ឬវៀតណាម ។

ប៉ុន្តែគេគួរកត់សំគាល់ថា ពេលវេលាដឹកជញ្ជូននឹងមិនត្រូវកាត់បន្ថយដូចរំពឹងទុកទេ ផ្អែកតាមតួលេខក្នុងតារាងខាងក្រោម ដែលបង្ហាញនូវលទ្ធផលនៃការពិសោធន៍របស់ក្រសួងសេដ្ឋកិច្ច ឧស្សាហកម្ម និងពាណិជ្ជកម្មជប៉ុន ។ ទីមួយ បើទោះជាប្រទេសកម្ពុជា វៀតណាម និងថៃ មានផែនការណែនាំនូវប្រព័ន្ធដឹកជញ្ជូន ដែលគ្របដណ្ដប់ប្រទេសទាំងបីក្ដី ក៏ប្រទេសនៃចំណុចឆ្លងកាត់ បានត្រៀមលក្ខណៈតិចតួចណាស់ក្នុងការអនុវត្តន៍ផែនការនេះ ។ ពិសេសលើសនេះទៀត ការហាមប្រាមស្ដីពីការឆ្លងកាត់នៃអ្នកបញ្ជូន ដើម្បីផ្ទេរមុខទំនិញទៅកាន់ប្រទេសដទៃទៀត (មិនឆ្លងកាត់និតិវិធីប្រតិវេទ៍គយនាំចូល) ក្នុងប្រទេសកម្ពុជា បានបង្ខំអោយអ្នកដឹកជញ្ជូន ត្រូវនាំចូលសិន រួចទើបនាំចេញ ដែលតម្រូវឱ្យមានការឆ្លងកាត់នីតិវិធីប្រតិវេទ៍គយនាំចូល និងការបង់ថ្លៃពន្ធគយកើនឡើងទ្វេដង ។ មូលហេតុផ្សេងទៀត គឺការដឹកជញ្ជូនពីប្រទេសថៃទៅប្រទេសវៀតណាមដោយឆ្លងកាត់តាមប្រទេសកម្ពុជា តម្រូវអោយធ្វើដំណើរតាមផ្លូវវាងតាមស្ពានគីហ្សូណា ដែលមានចំងាយ ៨០ គីឡូម៉ែត្រ ឆ្ងាយជាងផ្លូវកាត់ដោយសារមិនទាន់មានស្ពានឆ្លងកាត់ផ្សេងទៀតតាមទន្លេមេគង្គនៅច្រករបៀងលិច-កើតទីពីរ និងសេវាកម្មសាឡាងមិនគ្រប់គ្រាន់ ព្រោះសាឡាងឆ្លងតែពេលថ្ងៃប៉ុណ្ណោះ ។ បើសិនជាមានការដោះស្រាយបញ្ហានេះ ការបែងចែកការងារជាពិសេសចំពោះឧស្សាហកម្មអតិពលកម្មរវាងថៃ និងកម្ពុជា នឹងត្រូវបានជំរុញ ហើយនេះគឺជាក្ដីរំពឹងក្នុងការពន្លឿនការប្រមូលផ្ដុំនៃការស៊ីឈ្នួលនៅក្នុងប្រទេសថៃ ។

**តារាង ៩-២-៣ : ការសាកល្បងជាគំរូនៃការដឹកជញ្ជូន (រវាងបាងកក និងហូជីមិញ**

| Mode | Route | Distance (km) | Period | Transport Cost (US$) |
|---|---|---|---|---|
| Land | Bangkok - Ho Chi Minh | 913 | Min. 2 days | 1,390 |
| Sea | Bangkok – Saigon | - | 2 to 3 days | 580 |

កំណត់សំគាល់ : ការដឹកជញ្ជូនតាមផ្លូវគោកប្រើប្រាស់រថយន្តដឹក ១០តោន ។ ការដឹកជញ្ជូនតាមផ្លូវទឹកប្រើប្រាស់ កុងទែនើរ ២០ហ្វីត

ប្រភព: ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុន

តំបន់ឧស្សាហកម្មពីរ បានត្រូវអភិវឌ្ឍន៍រួចរាល់ហើយនៅជិតព្រំប្រទល់រវាងកម្ពុជា និងថៃឡង់ដ៏ ឆ្លុះបញ្ចាំងនូវការបង្កើតនៃបណ្តាញផ្លូវនៅក្នុងអាស៊ាន។ នាងកុក និងកោះកុង សុទ្ធតែស្ថិតនៅចំងាយប្រមាណពីរគីឡូម៉ែត្រពីព្រំដែនប្រទេសថៃ ត្រូវបានកំណត់ជាតំបន់ឧស្សាហកម្មនាពេលអនាគត ហើយបច្ចុប្បន្ននៅតំបន់ទាំងនេះកំពុងមានការកែទំរង់ហេដ្ឋារចនាសម្ព័ន្ធ។ ការអភិវឌ្ឍន៍ ផ្លូវគមនាគមន៍ភ្ជាប់ទៅកាន់ប្រទេសថៃ ធ្វើអោយប្រជាជននៅទីនោះអាចទៅកាន់កំពង់ផែឡាមឆាបាង ដោយចំណាយពេលតែបីម៉ោងប៉ុណ្ណោះ។ ការបញ្ជូនចរន្តអគ្គិសនីពីប្រទេសថៃមកកាន់តំបន់ឧស្សាហកម្មទាំងនេះ នឹងចាប់ផ្តើមនាពេលឆាប់ៗខាងមុខ។ ប្រសិនបើសាខាក្រុមហ៊ុនឧស្សាហកម្មអតិពលកម្មថៃ ប្រតិបត្តិការធុរកិច្ចរបស់ខ្លួននៅក្នុងតំបន់ឧស្សាហកម្មទាំងនេះ ពួកគេនឹងទទួលបាននូវប្រព័ន្ធអនុគ្រោះពន្ធជាទូទៅ ដែលត្រូវផ្តល់ជូនដល់កម្ពុជាបច្ចុប្បន្ននេះ។

ជាបន្ថែម វិបុលកម្មកំពង់ផែ ការជួសជុលនៃអាគារដែលមានស្រាប់ និងកែលំអកន្លែងដាក់កុងទែន័រនៅក្រុងព្រះសីហនុ ត្រូវបានកំពុងអនុវត្តន៍ដោយជំនួយតាមរយៈកំចីជាប្រាក់យេនជប៉ុន និងហិរញ្ញប្បទានរបស់ ADB។ ការចាក់ដីពង្រីកផ្លូវ ឧ.ហ: ផ្លូវជាតិលេខ ១ (ភ្នំពេញ-ស្វាយរៀង-បាវិត : ១៦៧ គ.ម) និងផ្លូវជាតិលេខ ៥ (ភ្នំពេញ-បាត់ដំបង-ស៊ីសុផុន-ប៉ោយប៉ែត :៤០៨ គ.ម) នៅកម្ពុជា កំពុងត្រូវបានធ្វើឡើងដោយមានការគាំទ្រជាអន្តរជាតិ។ ទន្ទឹមនឹងនោះ នៅមានកំណាត់ផ្លូវមួយចំនួន ត្រូវបានពន្យាក្នុងការស្ថាបនា ដែលត្រូវរង់ចាំការដោះស្រាយមួយចំនួនជាមុនសិន[៤៥]។

**(4) តម្លៃពលកម្មកើនឡើងនៅប្រទេសថៃ និងវៀតណាម**

ការបែងចែកការងារ ជាពិសេសចំពោះឧស្សាហកម្មអតិពលកម្ម ត្រូវបានពន្លឿននៅក្នុងប្រទេសជាសមាជិកអាស៊ានថ្មី ដោយសារតែកំណើនតម្លៃកំលាំងពលកម្ម (ប្រាក់ឈ្នួល និងតម្លៃដី) នៅប្រទេសថៃ កំណើនតម្លៃប្រាក់បាតដែលបណ្តាលមកពីការលូតលាស់សេដ្ឋកិច្ចជាលំដាប់ និងតម្រូវការក្នុងការកាត់បន្ថយការចំណាយដើម្បីប្រឈមការប្រកួតប្រជែងជាមួយកំណើនផលិតផលមកពីប្រទេសចិន។

ដោយសារសាខាក្រុមហ៊ុនជប៉ុននៅក្នុងផ្នែកគ្រឿងម៉ាស៊ីនដឹកជញ្ជូន ចាត់ទុកប្រទេសថៃ ជាមូលដ្ឋានផលិតកម្មចំបងមួយ ក្រុមហ៊ុនទាំងនោះកំពុងជំរុញការបែងចែកការងារខ្សែបណ្តោយ ដើម្បីកាត់បន្ថយការចំណាយផលិតកម្មតាមរយៈទំនាក់ទំនងបំពេញគ្នាទៅវិញទៅមក រវាងក្រុមរោងចក្ររបស់ខ្លួន ឬរោងចក្រផលិតគ្រឿងបំណែក ដែលមានទីតាំងនៅពាសពេញប្រទេសជាសមាជិកអាស៊ាន។

ក្នុងចំណោមប្រទេសទាំង ៤ ប្រទេសវៀតណាម ដោយសារមានការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធគ្រាន់បើត្រូវបាននឹងកំពុងធ្វើសមាហរណកម្មបញ្ចូលទៅក្នុងបណ្តាញបែងចែកការងារនេះ។ ទីតាំងផលិតកម្មមួយចំនួនដែលប្រើ

---

[45] Overseas Agriculture Development Association "The Study Report on the Investment Promotion for Overseas Agricultural and Forestry Industry" March 2003

កំលាំងពលកម្មច្រើន ដូចជាដំណរសំរាប់ភ្ជាប់ខ្សែភ្លើង (Wire Harness) បានផ្លាស់ទីតាំងទៅប្រទេសឡាវ។

តម្លៃពលកម្ម ក៏បានកើនឡើងនៅប្រទេសវៀតណាមដែរ ដោយសារតែកង្វះខាតកំលាំងពលកម្មដែលបណ្តាលមកពីកំណើនការវិនិយោគលឿនពេក។ នៅខែកុម្ភៈ ឆ្នាំ ២០០៦ ប្រាក់ឈ្នួលអប្បបរមាសំរាប់និយោជិតក្រុមហ៊ុនអន្តរជាតិ និងអង្គការ ឬស្ថាប័នអន្តរជាតិបានកើនឡើង។ ជាក់ស្តែង ប្រាក់ឈ្នួលអប្បបរមាសំរាប់និយោជិតនៅក្រុងហាណូយ និងហូជីមិញបានកើនឡើងពី ៦២៦ ពាន់ទៅ ៨៧០ ពាន់ដុង។ បើទោះជាកំណើនប្រាក់ឈ្នួលនេះមិនមានផលប៉ះពាល់ច្បាស់ចំពោះសាខាក្រុមហ៊ុនជប៉ុន ក៏ក្រុមហ៊ុនមួយចំនួននៅក្នុងឧស្សាហកម្មអតិពលកម្ម បានទទួលការប៉ះពាល់យ៉ាងខ្លាំងដោយសារតែកំរិតប្រាក់ឈ្នួលខ្ពស់នេះ។ មូលដ្ឋានផលិតកម្ម នឹងផ្លាស់ប្តូរពីប្រទេសវៀតណាមមកប្រទេសកម្ពុជា ស្របទៅនឹងការកែលំអនៃបរិយាកាសវិនិយោគរបស់កម្ពុជា។

**តារាង ៩-២-៤ កំណើនប្រាក់បៀវត្សរ៍នៅវៀតណាម (ប្រសិទ្ធភាពចាប់ពីថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០០៦)**

| **តំបន់** | **ប្រាក់បៀវត្សរ៍អប្បបរិមា** | | កំណើនភាគរយ |
|---|---|---|---|
| | ពីមុន | ក្រោយមក | |
| ហាណូយ ហូជីមិញ | 626,000 | 870,000 (approx. $55) | 39% |
| ទីក្រុងផ្សេងទៀត | 556,000 | 790,000 (approx. $50) | 42% |
| ផ្សេងៗ | 487,000 | 710,000 (approx. $45) | 46% |

Note: Currency = Vietnamese Don
Source: MPI, Vietnam

### (5) ការបែងចែកស៊ីជំរៅពលកម្មរវាងប្រទេសថៃ និងប្រទេសវៀតណាម

ក្រោមកាលៈទេសៈដែលប្រទេសថៃ មានតួនាទីជា "ប្រទេសចិនបូកមួយ" វាគឺជាលក្ខខណ្ឌល្អបំផុតមួយសំរាប់ឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា ដើម្បីទទួលបន្ទុកផ្នែកខ្លះនៃតួនាទីខាងលើនេះ ក្នុងនាមជាសមាជិកមួយនៃក្រុមសេដ្ឋកិច្ចប្រទេសថៃ។ ជាពិសេស កម្ពុជា នឹងចាប់យកការងារនៅក្នុងវិស័យឧស្សាហកម្មផលិតរថយន្ត ដែលរីកលូតលាស់ ជាពិសេសនៅប្រទេសថៃ។

ការអង្កេតដោយប្រើកំរងសំណួរធ្វើឡើងនៅឆ្នាំ ២០០៥ ដោយធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JBIC) ឧ.ហ: ការអង្កេតឆ្នាំ២០០៥ : ទស្សនៈវិស័យសំរាប់ការវិនិយោគបរទេសផ្ទាល់ជប៉ុន (ការអង្កេតប្រចាំឆ្នាំលើកទី១៧) -"ប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុជប៉ុនឆ្នាំ២០០៥" បានចំណាត់ថ្នាក់ប្រទេសថៃជាប្រទេសទីពីរបន្ទាប់ពីចិនដែលមានភាពអនុគ្រោះសំរាប់ពង្រីកប្រតិបត្តិការជំនួញនៅក្រៅប្រទេសរបស់ខ្លួន សំរាប់អនាគតរយៈពេលមធ្យម (៣ ឆ្នាំក្រោយ)។ មូលហេតុសំខាន់ៗ ដែលធ្វើអោយប្រទេសថៃបានទទួលការពេញនិយមគឺ :

- កំលាំងពលកម្មថោក (៥០,៣ %)
- សក្តានុពលភាពក្នុងការពង្រីកទីផ្សារ (៤៦,២ %) និង

- ស្ថេរភាពភាពនយោបាយ និងសង្គម (៤៣,៤ %)។ ប្រទេសថៃ មិនត្រឹមតែជាទីតាំងផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាទីផ្សារដ៏ល្អ និងជាប្រភពដើម្បីធ្វើលទ្ធកម្មវត្ថុធាតុដើមយ៉ាងសំខាន់។ វិនិយោគិនជប៉ុន នឹងធ្វើការវិនិយោគនៅក្នុងតំបន់អាស៊ាន ដោយផ្តោតការយកចិត្តទុកដាក់តែមួយគត់ចំពោះប្រទេសថៃ។

**តារាង ៩-២-៥ ប្រទេសដែលអាចនឹងជោគជ័យសំរាប់ក្រុមហ៊ុនជប៉ុនក្នុងការពង្រីកប្រតិបត្តិការធុរកិច្ច**

| | 2005 | | 2004 | | 2002 | | 2000 | |
|---|---|---|---|---|---|---|---|---|
| | Country | (%) | Country | (%) | Country | (%) | Country | (%) |
| 1 | China | 82 | China | 91 | China | 89 | China | 65 |
| 2 | India | 36 | Thailand | 30 | Thailand | 28 | U.S. | 41 |
| 3 | Thailand | 31 | India | 24 | U.S. | 26 | Thailand | 24 |
| 4 | Vietnam | 27 | Vietnam | 22 | Indonesia | 15 | Indonesia | 15 |
| 5 | U.S. | 20 | U.S. | 20 | Vietnam | 15 | Malaysia | 12 |
| 6 | Russia | 13 | Russia | 10 | India | 13 | Taiwan | 11 |
| 7 | Korea | 11 | Indonesia | 10 | Korea | 8 | India | 10 |
| 8 | Indonesia | 9 | Korea | 9 | Taiwan | 8 | Vietnam | 9 |
| 9 | Brazil | 7 | Taiwan | 8 | Malaysia | 8 | Korea | 9 |
| 10 | Taiwan | 7 | Malaysia | 6 | Brazil | 5 | Philippines | 8 |

Note: Figures are for the next 3 years.
Source: Japan Bank for International Cooperation

**(6) ឥទ្ធិពលស្តីពីឧស្សាហកម្មគ្រឿងម៉ាស៊ីន ពាក់ព័ន្ធនឹងការខួងអណ្តូងប្រេង និងការចំរាញ់ឧស្ម័នធម្មជាតិ**

ការខួងពិសោធន៍អណ្តូងប្រេង និងឧស្ម័នធម្មជាតិនៃឈូងសមុទ្រថៃ បានបង្ហាញនូវភាពជោគជ័យ។ ប្រសិនបើការខួងអណ្តូងប្រេង និងការចំរាញ់ឧស្ម័នធម្មជាតិ ត្រូវប្រកាសអនុវត្តជាលក្ខណៈពាណិជ្ជកម្ម នឹងមានសេចក្តីត្រូវការសំរាប់គ្រឿងម៉ាស៊ីនផ្សេងៗដូចជាសំរាប់សង់រោងចក្រជាដើម។ ជាឧទាហរណ៍ គ្រឿងម៉ាស៊ីនសំរាប់សាងសង់កន្លែងផ្ទុក LNG បំពង់ប្រេង ឬឧស្ម័ន ។ល។ នឹងត្រូវការជាចាំបាច់។

## ៩.២.២ សេណារីយ៉ូអភិវឌ្ឍន៍រយៈពេលខ្លី-រយៈពេលមធ្យម និងរយៈពេលវែង

ឧស្សាហកម្មគ្រឿងម៉ាស៊ីននៅកម្ពុជា គឺនៅមានភាពក្មេងខ្ចីនៅឡើយ ដោយសារតែជួបប្រទះនូវកង្វះខាតបច្ចេកវិទ្យា និងដើមទុនសំរាប់ធ្វើការអភិវឌ្ឍន៍។ ដូច្នេះ ឧស្សាហកម្មប្រភេទនេះ ត្រូវតែម្រូវអោយមានការដាក់ដើមទុន និងបច្ចេកវិទ្យាពីការវិនិយោគបរទេសផ្ទាល់ ក្នុងគោលបំណងសំរាប់ការលូតលាស់នៃឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា។

បើពិនិត្យទៅលើប្រវត្តិនៃឧស្សាហកម្មគ្រឿងម៉ាស៊ីន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍របស់អាស៊ាន គេបានប្រើប្រាស់ការផ្ទេរបច្ចេកវិទ្យា ក៏ដូចជាការវិនិយោគបរទេសផ្ទាល់ ជាកំលាំងចលករសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម របស់ពួកគេ។ ប្រទេសទាំងនោះ បានប្រកាសនូវឧស្សាហកម្មជំនួសការនាំចូលដំបូង ហើយពេលនោះបានអភិវឌ្ឍឧស្សាហកម្មបំរើការនាំចេញដើម្បីធ្វើខ្លួនឱ្យក្លាយជាអ្នកនាំមុខនៅក្នុងសេដ្ឋកិច្ចអាស៊ី។

ខណៈដែលកម្ពុជា ត្រូវបានសន្មត់ថាអនុវត្តតាមផែនការអភិវឌ្ឍន៍នេះ ដែលបានលើកមកធ្វើដោយប្រទេសកំពុងអភិវឌ្ឍន៍របស់អាស៊ានក៏ដោយ ក្រុមហ៊ុនបរទេស អាចនឹងមិនស្វែងរកទីផ្សារតូចរបស់កម្ពុជាទេ ប៉ុន្តែដើម្បីទាញយកផលប្រយោជន៍នៃតម្លៃពលកម្មថោក ដើម្បីផលិត និងនាំចេញ។

ទន្ទឹមនឹងនេះ កម្ពុជា មានផលប្រយោជន៍ភូមិសាស្ត្រមួយ ដែលនៅចន្លោះប្រទេសថៃ និងវៀតណាម។ កម្ពុជាអាចទាញយកផលប្រយោជន៍ពីលក្ខណៈភូមិសាស្ត្រនេះជាសេណារីយោអភិវឌ្ឍន៍សំខាន់មួយ។ ដោយសារ ហេដ្ឋារចនាសម្ព័ន្ធសំរាប់ការដឹកជញ្ជូនតាមផ្លូវគោកនៅតណ្ឌចិន ត្រូវបានកែទំរង់យ៉ាងឆាប់រហ័សនោះ ទំរង់ការដើម្បីធ្វើឱ្យកម្ពុជាទៅជាចំណុចប្រសព្វជាគន្លឹះមួយនៃពាណិជ្ជកម្មរវាងថៃ និងវៀតណាម គួរតែត្រូវបានអនុវត្តក្រោមសេណារីយោអភិវឌ្ឍន៍ដូចបង្ហាញជូនក្នុងរូបភាពខាងក្រោម:

**រូបភាព ៩-២-២ សេណារីយោនៃការអភិវឌ្ឍន៍កម្ពុជា ដែលប្រើប្រាស់លក្ខខណ្ឌភូមិសាស្ត្ររបស់ខ្លួន**




**ប្រភព: ក្រុមសិក្សា JICA**

តបតាមន័យដូចមានចែងខាងលើ ភាពជឿនលឿននៃបច្ចេកវិទ្យាផលិត និងការបន្ថែមនៃប្រភេទថ្មីនៃផលិតផល ដែលបានរៀបរាប់រួចមក ត្រូវបានពិចារណាដើម្បីធ្វើការជំរុញក្នុងជំហានទាំងបី : សេណារីយោរយៈពេលខ្លី-រយៈពេលមធ្យម និងរយៈពេលវែង។

**(1) សេណារីយោរយៈពេលខ្លី (២០០៦ ដល់ ២០១០)**

ការផ្តោតត្រូវបានដាក់លើការងារអតិពលកម្មក្នុងរង្វង់ការបែងចែកបណ្តាញពលកម្មនៅអាស៊ី។ វានឹងជាការសមរម្យណាស់សំរាប់កម្ពុជា ដើម្បីទទួលបន្ទុកនៃឧស្សាហកម្មផលិតគ្រឿងម៉ាស៊ីននៃការដឹកជញ្ជូន ជាពិសេស ផលិតកម្មគ្រឿងបំណែក ដែលត្រូវការកំលាំងពលកម្មច្រើន។ កម្ពុជា នឹងនាំចូលនូវគ្រប់សម្ភារៈនិងគ្រឿងបំណែកចាំបាច់ទាំងអស់ ព្រោះថានៅកម្ពុជា មិនទាន់មានក្រុមហ៊ុនក្នុងស្រុកដែលមានបច្ចេកវិទ្យាទំនើបគ្រប់គ្រាន់អាចបំពេញការងារ

ដែលផ្តល់ជូនដោយក្រុមហ៊ុនបរទេសនៅឡើយ ព្រមទាំងស្វែងរកផលិតកម្ម CKD (Completely Knock Down) ដោយប្រើប្រាស់ពលកម្មក្នុងស្រុក ដែលមានតម្លៃទាប ។

**(2) សេណារីយោរយៈពេលមធ្យម (២០១១ ដល់ ២០១៥)**

ក្នុងរយៈពេលនេះ កម្ពុជានឹងចាប់ផ្តើមផលិតកម្មក្នុងស្រុកនៃសម្ភារៈបរិក្ខារ និងបំណែកផ្សេងៗ។ ផលិតកម្ម SKD (Semi Knock Down) នឹងត្រូវអនុវត្តដោយស្វ័យប្រវត្តិជាមួយនឹងការប្រើប្រាស់បំណែក ដែលបានផលិតដោយក្រុមហ៊ុនជឿនលឿនបរទេសនៅកម្ពុជា ក៏ដូចជាសម្ភារៈបរិក្ខារនិងបំណែកដែលនាំចូលផងដែរ ។ ក្រុមហ៊ុនកម្ពុជាខ្លះនឹងធ្វើសមាច័យបច្ចេកវិទ្យា ហើយចាប់ផ្តើមផលិតមុខទំនិញ ដែលមានតម្លៃខ្ពស់ជាងនេះ ។

**(3) សេណារីអូរយៈពេលវែង (ចាប់ពីឆ្នាំ ២០១៦ ទៅមុខ)**

ការប្រមូលផ្តុំឧស្សាហកម្ម នឹងត្រូវបានជំរុញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាហេតុបណ្តាលឱ្យមានផលិតផលជាច្រើនប្រភេទ រួមទាំងបរិក្ខារម៉ាស៊ីន និងបំណែកដែលមានតម្លៃបន្ថែមខ្ពស់ ។ នៅក្នុងក្រប

ខ័ណ្ឌតំបន់ពាណិជ្ជកម្ម សេរីអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរី កម្ពុជានឹងអាចក្លាយជាអ្នកនាំចេញសំខាន់មួយ ។ ការសិក្សាស្តីពីបច្ចេកវិទ្យា សំខាន់ៗ ដូចជាការចាក់ពុម្ព និងស្មិតដែក នឹងត្រូវចាប់ផ្តើមស្របគ្នានឹងការអភិវឌ្ឍន៍នៃប្រភេទឧស្សាហកម្មគាំទ្រ ។

**តារាង ៩-២-៦ គំរូធុរកិច្ចសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មម៉ាស៊ីន**

| Time | Promising Item | Potential Source of Country | Procurement of Parts/Material | Sales Target | Production |
|---|---|---|---|---|---|
| **Present** | Vehicle assembling | Japan | Import (Japan, ASEAN, etc.) | Domestic | CKD, Simple assembling |
| **Short-term** | Transportation equipment (simple parts) | Japan, Korea | Import (Japan, Korea, ASEAN, etc.) | Domestic, Export (Thailand, Vietnam, etc.) | CKD, Simple assembling |
| **Medium-term** | Transportation equipment (important parts) | Japan, Korea, Taiwan | Domestic, Import (Japan, Korea, ASEAN, China, etc.) | Domestic, Export (ASEAN, China, etc.) | SKD (increase value added) |
| **Long-term** | Agro-machinery | Japan, Korea, U.S. | Domestic, Import (Japan, ASEAN, India, China, etc.) | Domestic, Export (ASEAN, China, etc.) | SKD (development of key technology) |

Source: JICA Study Team

## ៩.២.៣ ការព្យាករណ៍នៃបរិមាណវិនិយោគនៅកម្ពុជា ដោយក្រុមហ៊ុនបរទេស រហូតដល់ឆ្នាំ ២០២០

**(១) ការវិភាគនិន្នាការ**

**(១) ការវិភាគនិន្នាការ**

ឧស្សាហកម្មម៉ាស៊ីននៅកម្ពុជា ត្រូវបានស្ថិតក្រោមការអភិវឌ្ឍន៍តិចតួចបំផុត លើកលែងតែសំរាប់អ្នកតម្លើងមួយចំនួនប៉ុណ្ណោះ។ ដោយសារទីផ្សារក្នុងស្រុកតូច និងបរិស្ថានវិនិយោគមិនសូវអំណោយផល ក្រុមហ៊ុនបរទេសមិនមានបំណងវិនិយោគក្នុងឧស្សាហកម្មម៉ាស៊ីន របស់កម្ពុជាទេ។ ជាការពិត គ្មានការវិនិយោគបរទេស នៅក្នុងគ្រប់ផ្នែកនៃគ្រឿងម៉ាស៊ីនតាំងពីឆ្នាំ ២០០២ មកម្លេះ។

**រូបភាពទី ៩-២-៣ លំហូរវិនិយោគក្នុងឧស្សាហកម្មម៉ាស៊ីនរបស់កម្ពុជា**




Source: CDC/CIB

**(២) ការព្យាករណ៍នៃការវិនិយោគរហូតដល់ឆ្នាំ ២០២០**

គេរំពឹងថា ក្រុមហ៊ុនបរទេសរាប់បញ្ចូលទាំងក្រុមហ៊ុនជប៉ុន នឹងមកធ្វើការវិនិយោគនៅកម្ពុជា ក្នុងឧស្សាហកម្មម៉ាស៊ីនដូចជាសេចក្តីត្រូវការក្នុងស្រុកនៃគ្រឿងម៉ាស៊ីន បានពង្រីក ហើយការបែងចែកកំលាំងពលកម្មនៅក្នុងតំបន់អាស៊ាន មានការជឿនលឿនដោយយកប្រទេសថៃជាដើរិល។

ឧស្សាហកម្មម៉ាស៊ីន ដែលបរិមាណវិនិយោគធំ គឺរំពឹងថាជាការតម្លើងម៉ូតូ ដែលសំដៅឆ្ពោះទៅរកទីផ្សារក្នុងស្រុករបស់កម្ពុជា។ ម្យ៉ាងវិញទៀត នាពេលបច្ចុប្បន្ន សេចក្តីត្រូវសំរាប់ឧស្សាហកម្មរថយន្ត នៅក្នុងប្រទេសកម្ពុជា គឺត្រូវបានពិចារណាថានៅមានកំរិតតិចតួច ប៉ុន្តែប្រសិនបើ GDP per capita របស់កម្ពុជា បានលើសពី ៣,០០០ដុល្លាទៅនោះនឹងមានសេចក្តីត្រូវការសំរាប់ឧស្សាហកម្មរថយន្តជាក់ជាមិនខាន។

សេចក្តីត្រូវការម៉ូតូនៅកម្ពុជា ក្នុងឆ្នាំ ២០០៥ មានប្រមាណជា ៦៥ពាន់គ្រឿង ដែលស្មើនឹង ៤.៧គ្រឿងក្នុងមនុស្ស ១,០០០នាក់។ អត្រានៃកំណើននៃសេចក្តីត្រូវការម៉ូតូ គឺត្រូវបានពិចារណាថាមានទំនាក់ទំនងជិតស្និទទៅនឹងកំណើនសេដ្ឋកិច្ចក្នុងមនុស្សម្នាក់។ ពេលនោះ ដោយផ្អែកលើទិន្នន័យពី (i) ទំនាក់ទំនងនៃតួរលេខនៃប្រទេសជិតខាងទាំងពីរនេះ និង (ii) ការព្យាករណ៍នៃកំណើនសេដ្ឋកិច្ចក្នុងមនុស្សម្នាក់នៅកម្ពុជា រវាងឆ្នាំ ២០០៥ និង ២០២០

ដែលបានគណនាក្នុងជំពូកទី ២ តំរូវការសំរាប់ម៉ូតូនៅក្នុងប្រទេសកម្ពុជា រវាងឆ្នាំ ២០០៥ និង ២០២០ ត្រូវបានព្យាករណ៍ ដូចបង្ហាញក្នុងតារាងខាងក្រោម :

**រូបភាព ៩-២-៤ តំរូវការម៉ូតូនៅកម្ពុជា**




Source: JICA Study Team

ជាបន្ថែមចំពោះការវិនិយោគនៅក្នុងឧស្សាហកម្មបរិក្ខារដឹកជញ្ជូន ដែលមានគោលដៅសំរាប់ទីផ្សារក្នុងស្រុករបស់កម្ពុជា គេបានរំពឹងថាអ្នកទទួលកិច្ចសន្យាតម្លើង ដែលបានបោះទីតាំងនៅប្រទេសថៃ និងវៀតណាម នឹងបង្កើតរោងចក្រនៅកម្ពុជា។ ប៉ុន្តែទោះបីជាយ៉ាងនេះ ដើម្បីនឹងឱ្យក្រុមហ៊ុនបរទេស មកវិនិយោគក្នុងឧស្សាហកម្មម៉ាស៊ីនរបស់កម្ពុជា រដ្ឋាភិបាលគួរតែដោះស្រាយឱ្យបានរួចរាល់នូវបញ្ហារាំងមួយចំនួន ដូចជាហេដ្ឋារចនាសម្ព័ន្ធ ថ្លៃថាមពលខ្ពស់ និងឧស្សាហកម្មគាំទ្រ។ ដូច្នេះ វាមានការលំបាកក្នុងពេលបច្ចុប្បន្ន ដើម្បីធ្វើការព្យាករណ៍នូវបរិមាណត្រឹមត្រូវនៃលំហូរវិនិយោគនៅក្នុងឧស្សាហកម្មម៉ាស៊ីននេះ។ ជាបន្ថែម លំហូរវិនិយោគ មកកម្ពុជា អាចមិននៅទ្រឹងមិនទៅមុខក្នុងឆ្នាំ ២០១០ ហើយបន្ទាប់ពីឆ្នាំ ២០១៥ ដោយសារលទ្ធភាពនៃការកើនឡើងយ៉ាងខ្ពស់ក្នុងការនាំចូលម៉ាស៊ីន ក្រោមទំរង់ការតំបន់ពាណិជ្ជកម្មសេរីអាស៊ាន។ ដើម្បីជាការជាក់លាក់ អត្រាពន្ធគយនៃការនាំចូល ត្រូវបានបញ្ចុះមកត្រឹម ៥% ឬតិចជាងនេះ នៅឆ្នាំ ២០១០ និង 0% បន្ទាប់ពីឆ្នាំ ២០១៥។

ការពិចារណាខាងលើ លំហូរនៃការវិនិយោគបរទេសផ្ទាល់ និងនិន្នាការនៃការនាំចេញ ត្រូវបានព្យាករណ៍ត្រួសៗ ក្នុងបីរយៈពេលផ្សេងគ្នាដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម :

**តារាង ៩-២-៧ ការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មម៉ាស៊ីនរបស់កម្ពុជា**

| | Short-term (around 2010) | Medium-term (around 2015) | Long-term (around 2020) |
|---|---|---|---|
| **FDI** | US$ 4 to 6 million | US$ 8 to 10 million | US$ 15 to 20 million |
| **Field of FDI** | Transportation equipment | Transportation equipment, Agricultural machinery, Infrastructure related machinery | Transportation equipment, Agricultural machinery, Infrastructure related machinery |
| **Export to Assemblers in Neigboring Countries** | Very small amount | Gradual increase (transportation equipment, etc.) | Rapid expansion (transportation equipment, etc.) |

Source: JICA Study Team

## ៩.៣ ការវាយតំលៃ និងទស្សនៈវិស័យនៃភាពប្រកួតប្រជែងជាអន្តរជាតិនៃឧស្សាហកម្មគ្រឿងម៉ាស៊ីននៅកម្ពុជា

### ៩.៣.១ ការវិភាគលើថ្លៃផលិតកម្ម និងភាពប្រកួតប្រជែងនាំចេញ

ឧស្សាហកម្មគ្រឿងម៉ាស៊ីន គឺស្ថិតក្នុងដំណាក់កាលដំបូង ហើយភាពប្រកួតប្រជែងរបស់វា គឺមិនទាន់មាននៅឡើយក្នុងពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ វាមានសមត្ថភាពលូតលាស់សក្តានុពល។ ភាពប្រកួតប្រជែងរបស់វា នឹងត្រូវបានពង្រឹងដោយការកែលំអនៃគុណភាព និងតម្លៃនៃកំលាំងពលកម្ម ដើម្បីបំពេញតំរូវការរបស់ក្រុមហ៊ុនបរទេស ស្របជាមួយកំណែទំរង់នៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ប្រសិនបើឧស្សាហកម្មនេះ អាចទាញប្រយោជន៍បានពីលក្ខខណ្ឌភូមិសាស្ត្ររបស់វា។

(1) តម្លៃពលកម្ម

ប្រាក់ឈ្នួលអប្បបរិមានៃឧស្សាហកម្មគ្រឿងម៉ាស៊ីន គឺស្ទើរតែប្រហាក់ប្រហែលនឹងឧស្សាហកម្មកាត់ដេរ គឺ ៤៥ដុល្លា ក្នុង មួយខែនៅកម្ពុជា។ ដោយបានធ្វើការអង្កេតតាមការសម្ភាសន៍ នៃក្រុមហ៊ុនក្នុងស្រុក ក្រុមសិក្សាបានបង្ហាញថា ប្រាក់ឈ្នួលជាមធ្យមនៃកម្មករក្នុងសាខាក្រុមហ៊ុនឧស្សាហកម្មបរទេសគឺប្រមាណជា ១២០-១៤០ដុល្លាក្នុង១ខែ (រាប់បញ្ចូលទាំងប្រាក់ឧបត្ថម្ភដូចជាធានារ៉ាប់រងសង្គម)។

ដូចមានបង្ហាញក្នុងតារាងខាងក្រោម ចំពោះការវិភាគប្រៀបធៀបនៃប្រាក់ឈ្នួលពលកម្មនៅអាស៊ី ដែលបង្ហាញថាប្រាក់ឈ្នួលពលកម្មនៅប្រទេសកម្ពុជា មានកំរិតទាបជាងប្រាក់ឈ្នួលនៅ ប្រទេសថៃ និងម៉ាឡេស៊ី។ លើសពីនេះទៀត តម្លៃពលកម្មនៅកម្ពុជា មានកំរិតទាប បើប្រៀបជាមួយប្រទេសវៀតណាម និងចិន។

**តារាង ៩-៣-១ ការប្រៀបធៀបនៃប្រាក់ឈ្នួលពលកម្មនៅអាស៊ី**

| | Bangkok | Kuala Lumpur | Hanoi | Ho Chi Minh |
|---|---|---|---|---|
| កម្មករ (Worker) | 146 | 205 | 80 – 163 | 111 – 185 |

| | | | | | |
|---|---|---|---|---|---|
| វិស្វករ (Engineer) | | 316 | 790 | 201 – 385 | 249 – 373 |
| អ្នកគ្រប់គ្រង (Manager) | | 584 | 1,643 | 451 – 661 | 572 – 1,054 |
| Statutory Minimum Wage | | 4.40/day | - | 54.84/mo. | 54.84/mo. |
| ប្រាក់រង្វាន់ (Bonus) | | 2.6 months | 1.8 months | 1 - 2 months | 1 - 2 months |
| Social Security | Employer | 5% | 12% | 17% | 17% |
| | Employee | 5% | 11% | 6% | 6% |

Note: US$/month

ប្រភព : JETRO, "Investment Cost Comparison of Asian Major Cities (Nov. 2005)"

### តារាង ៩-៣-២ បៀវត្សរ៍កម្មករនៅចិន

| | | Peking | Shanghai | Shenzhen |
|---|---|---|---|---|
| កម្មករ (Worker) | | 84 – 164 | 172 - 301 | 100 – 247 |
| វិស្វករ (Engineer) | | 223 – 470 | 334 - 593 | 186 – 620 |
| អ្នកគ្រប់គ្រង (Manager) | | 334 - 1,769 | 772 – 1,521 | 496 – 991 |
| Statutory Minimum Wage | | 71.73/mo. | 85.50/mo. | 85.51/mo. |
| ប្រាក់រង្វាន់ (Bonus) | | 1.9 months x 2 | 1 - 3 months | 1 mo. +/- 10% |
| Social Security | Employer | 30.5 - 32.7% | 44.0% | 33.0 - 34.0% |
| | Employee | 10.5% | 18.0% | 7.0% |

Note: US$/month

ប្រភព : JETRO, "Investment Cost Comparison of Asian Major Cities (Nov. 2005)"

**(2)** តម្លៃអគ្គិសនី

ការផ្គត់ផ្គង់មានស្ថេរភាពនៃអគ្គិសនីដែលមានគុណភាពហើយមិនថ្លៃ គឺជាប្រការចាំបាច់សំរាប់ឧស្សាហកម្មគ្រឿងម៉ាស៊ីន។ ដោយសារតែកង្វះខាតអគ្គិសនី ផលិតករ មានជំរើសជាច្រើន ថាតើត្រូវប្រើប្រាស់ម៉ាស៊ីនភ្លើងផ្ទាល់ខ្លួនភ្ជាប់ទៅហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីឯកជន ឬក៏ពឹងផ្អែកលើការផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជា។ តម្លៃអគ្គិសនីសំរាប់អគ្គិសនីកម្ពុជា គឺថ្លៃខ្ពស់ ប្រហែលជា ០,១៨ដុល្លា ក្នុងមួយ KWh ខណៈពេលដែលតម្លៃអគ្គិសនីនៅហាណូយ ត្រឹមតែ ០,០៧ដុល្លា នៅបាងកក ត្រឹមតែ ០,០៤ ដុល្លា គូឡាឡាំពួរ ០,០៥ដុល្លា ចាការតា ០,០៤ ដុល្លា និងសឹង្ហបូរី ០,០៧ ដុល្លា។

## ៩.៣.២ ការកំណត់ប្រភេទទំនិញ ដែលមានភាពប្រកួតប្រជែងក្នុងការនាំចេញនៅកម្ពុជា

ប្រទេសកម្ពុជា ត្រូវចាំបាច់ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងធ្វើពិពិធកម្មតំបន់ឧស្សាហកម្មក្នុងគោលដៅធ្វើកំណែទំរង់រចនាសម្ព័ន្ធឧស្សាហកម្ម ដែលបច្ចុប្បន្នឧស្សាហកម្មកាត់ដេរសំលៀកបំពាក់មានអត្រាច្រើនលើសលប់។ យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយ សំរាប់សំរេចគោលដៅនេះ គឺការទាក់ទាញក្រុមហ៊ុនអតិពលកម្មកែច្នៃដោយគ្រឿងម៉ាស៊ីនពីប្រទេសថៃ ម៉ាឡេស៊ី និងវៀតណាម ដែលនៅប្រទេសទាំងនោះ ភាពប្រកួតប្រជែងពួកគេបានថយចុះ។ នេះក៏អាចជាគុណប្រយោជន៍សំរាប់ក្រុមហ៊ុនបរទេសដែលជាផ្នែកមួយនៃកលយុទ្ធ ដើម្បីចាប់ផ្តើមធ្វើ

ធុរកិច្ចនៅកម្ពុជា។

### (1) ឧស្សាហកម្មផលិតគ្រឿងបំណែកយានយន្ត

តម្លៃពលកម្មកើនឡើងនៅក្នុងឧស្សាហកម្មកម្មន្តសាលធុនស្រាល ធ្វើអោយប្រទេសថៃមានការលំបាកនៅក្នុងការរក្សាកំលាំងពលកម្មឱ្យនៅស្ថិតស្ថេរណាស់។ ឧស្សាហកម្មកម្មន្តសាលធុនស្រាលនៅប្រទេសថៃ បានរុករកទីកន្លែងផ្សេងទៀត ដើម្បីផ្ទេរការងារអតិពលកម្មពីបណ្តាប្រទេសជិតខាង ហើយបានចាត់ទុកប្រទេសកម្ពុជាជាប្រទេសដ៏សំខាន់មួយដែលតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានគ្រោងទុក និងបង្កើតឡើង ដើម្បីទទួលការវិនិយោគបរទេសផ្ទាល់។

នៅប្រទេសថៃ ឧស្សាហកម្មផលិតរថយន្តមានភាពអនុគ្រោះ ឧស្សាហកម្មប្រភេទនេះកំពុងអភិវឌ្ឍន៍យ៉ាងលឿន និងប្រមូលផ្តុំក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេស។ នេះអាចត្រូវបានអនុវត្តចំពោះឧស្សាហកម្មផលិតបំណែកយានយន្ត។ ទោះបីជារោងចក្រតម្លើងខ្លះ បានចាប់ផ្តើមប្តូរទីតាំងទៅកាន់ប្រទេសជិតខាង ឧស្សាហកម្មអតិពលកម្មផលិតបំណែកយានយន្ត អាចជ្រើសរើសកម្ពុជា ជាទីតាំងផលិតកម្មរបស់ខ្លួនក្នុងគោលបំណងកាត់បន្ថយការចំណាយដោយសារតម្លៃកំលាំងពលកម្មថោក។

ជាពិសេស មុខទំនិញដែលត្រូវការការងារអតិពលកម្មខ្ពស់ ប៉ុន្តែអាចត្រូវផលិតជាមួយនឹងកំរិតទាបនៃបច្ចេកវិទ្យាដូចជា"តួរថយន្ត និងគ្រឿងផ្គុំរាងរថយន្ត" និង"គ្រឿងសំភារៈអគ្គិសនី" ទូទៅ អាចត្រូវបានជ្រើសរើសចេញពីផ្នែកនៃការផលិតបំណែកយានយន្តសំរាប់រយៈពេលខ្លីនៃការប្តូរទីតាំងផលិតរបស់ក្រុមហ៊ុនទាំងអស់នេះ។ ក្រៅពីនេះ ទីតាំងប្រតិស្ឋកម្មនៃប្រភេទទំនិញដែលផលិតជាមួយនិងបច្ចេកវិទ្យាជឿនលឿន ដើម្បីធានាបាននូវកំរិតខ្ពស់នៃភាពច្បាស់លាស់ ប្រពលភាព និងភាពមិនសឹកងាយ ដូចជា "គ្រឿងម៉ាស៊ីន" "បំណែកសំរាប់ផ្នែកបើកបរ និងគ្រឿងប្រអប់លេខ (transmission component) និងឧបករណ៍ចង្កូត (steering device) " "បំណែកនៃគ្រឿងបន្ថយល្បឿន និងប្រព័ន្ធហ្វ្រាំង (suspension and braking device)" និងគ្រឿងអគ្គិសនីសំរាប់ជួយឱ្យមានចំហេះខាងក្នុង (internal combustion)" នឹងត្រូវប្តូរទីតាំងមកក្នុងប្រទេសកម្ពុជា ក្រោមយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម។ ជាក់ស្តែង សាខាក្រុមហ៊ុនផលិតបំណែកយានយន្ត នៅតែផលិតបំណែកភាគច្រើននៅប្រទេសជប៉ុនដដែលទេ[៤៦]។

**តារាង ៩-៣-៣ បំណែកយានយន្តសំខាន់ៗតាមប្រភេទ**

| Category | Major Parts |
|---|---|
| Engine Component | Piston, Piston ring, Valve, Metal bearing, Gasket, Fuel pump, Carburetor, Fuel injection Device, Radiator, etc. |
| Parts for Drive Unit, Transmission component, and Steering Device | Clutch, Automatic transmission, Universal joint, Propeller shaft, Steering device, etc. |
| Parts of Suspension and Braking Device | Shock absorber, Brake, etc. |
| Electrical Components for Internal Combustion | Generator, Starter, Distributor, Ignition coil, Spark plug, etc. |
| Chassis and Auto Body Component | Fuel tank, Exhaust pipe, Muffler, Window frame, Seat, |

[46] *Japan Finance Corporation for Small and Medium Enterprise, Research Institute, "Status quo and future direction of Japanese Automotive Part Industry" (JASME Report, August 26, 2006)*

| | |
|---|---|
| | Air bag, etc. |
| Other Electrical Components | Switch devices, Instrument panel, Windscreen wiper, Horn, Air conditioner, etc. |

Source: Japan Finance Corporation for Small and Medium Enterprise, Research Institute, "Status quo and future direction of Japanese Automotive Parts Industry" (JASME Report, August 26, 2006)

ក្រៅពីរោងចក្រផលិតគ្រឿងបំណែកយានយន្ត រោងចក្រផលិតប្រដាប់ក្មេងលេង ដែលប្រើកំលាំងពលកម្មច្រើនដែរ អាចនឹងជ្រើសរើសកម្ពុជា ជាទីតាំងសំរាប់ផ្ទេរការផលិតពីបណ្តាប្រទេសជិតខាង។ តារាងខាងក្រោមផ្តល់នូវផែនការធុរកិច្ចនៃក្រុមហ៊ុនមួយដែលមានបំណងវិនិយោគនៅកម្ពុជា ផ្អែកលើការសិក្សាជាក់ស្តែងដែលបានធ្វើឡើងនៅប្រទេសជិតខាង។ ក្រុមហ៊ុន A ផលិតបំណែកយានយន្តនៅវៀតណាម ហើយបញ្ជូនបំណែកនេះទៅតម្លើងនៅប្រទេសថៃ។ ក្រុមហ៊ុននេះ កំពុងតែត្រួតពិនិត្យមើលផែនការដើម្បីបង្កើតរោងចក្ររណបមួយនៅកម្ពុជា ដែលជាចំណុចកណ្តាលរវាងថៃ និងវៀតណាម ក្នុងគោលដៅកាត់បន្ថយតម្លៃផលិតកម្ម និងពេលវេលាបញ្ជូន។

**តារាង ៩-៣-៤ ឧទាហរណ៍នៃគំរូធុរកិច្ចដែលរកឃើញក្នុងការអង្កេតតាមរោងចក្រ**

| A Company | |
|---|---|
| Product | Automobile parts |
| Business in Cambodia | Production of automobile parts |
| Investment amount | Approximately US$3 million |
| Employment | 100 (at the beginning of the operation) |
| Sales amount | Approximately US$6 million per year |
| Sales targets | 100% export to automobile assemblers in Thailand |
| Economic effects | Job creation, and foreign currency earning |

ប្រភព : ក្រុមសិក្សារបស់ JICA

### (2) ឧស្សាហកម្មគ្រឿងម៉ាស៊ីនដែលទាក់ទងនឹងកសិកម្ម និងនេសាទ

កាលានុវត្តន៍ភាពធុរកិច្ចដែលផ្តល់ប្រាក់ចំណេញផ្សេងទៀតអាចត្រូវរកឃើញក្នុងកសិ-ធុរកិច្ច ដោយសារកម្ពុជាជាប្រទេសកសិកម្មដ៏សំខាន់មួយ។ ជាឧទាហរណ៍ ធុរកិច្ចពាក់ព័ន្ធនឹងគ្រឿងម៉ាស៊ីនកសិកម្ម និងកែច្នៃម្ហូបអាហារមានសក្តានុពលក្នុងការរីកលូតលាស់។ កម្ពុជាក៏អាចមានតំរូវការច្រើនចំពោះគ្រឿងម៉ាស៊ីន ដែលប្រើសំរាប់ការនេសាទ និងព្រៃឈើ ក្នុងការកែច្នៃធនធានធម្មជាតិ ដូចជាផលិតផលសមុទ្រ និងដើមឈើ។

បើពិនិត្យអោយជិតដល់ចំពោះគ្រឿងម៉ាស៊ីនកសិកម្ម គ្រឿងម៉ាស៊ីនសំរាប់ការច្រូតកាត់កសិកម្ម ដូចជាត្រាក់ទ័រនឹងជាតំរូវការសំខាន់ក្នុងវិស័យសិកម្ម។ ផលិតផលកសិកម្មដ៏សំខាន់គឺស្រូវ ដែលផ្ទៃដីដាំស្រូវគ្របដណ្តប់ពាក់កណ្តាលនៃផ្ទៃដីទាំងមូល។ ចំពោះទស្សនៈអនាគតសំរាប់ផ្ទៃដីដាំដុះស្រូវនេះ នៅតែមានទំហំធំនៅពេលអនាគត បើទោះជាផលិតកម្មកសិកម្ម ត្រូវបានធ្វើពិពិធកម្មក៏ដោយ ក៏ឧបករណ៍ដែលប្រើប្រាស់សំរាប់ផលិតកម្មស្រូវ នឹងនៅតែមានការពេញនិយមនៅក្នុងទីផ្សារគ្រឿងម៉ាស៊ីនកសិកម្មដដែល។

គ្រឿងម៉ាស៊ីនជាទស្សនៈអនាគតទី២ គឺពាក់ព័ន្ធនឹងប្រព័ន្ធធារាសាស្ត្រ។ ការផ្គត់ផ្គង់ទឹកជាការចាំបាច់សំរាប់

ការជាំដុះដំណាំសំរាប់រយៈពេលច្រើនខែ បន្ថែមទៅនឹងរដូវខ្យល់ម៉ូសុង ពីខែមិថុនារហូតដល់ខែកញ្ញា។ យោងតាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំបន់គ្របដណ្តប់ដោយប្រព័ន្ធធារាសាស្រ្តមានតែ២០ភាគរយប៉ុណ្ណោះ។ ដោយសារការបង្កើតប្រព័ន្ធធារាសាស្រ្ត គឺជាគោលនយោបាយសំខាន់បំផុត តំរូវការសំរាប់ឧបករណ៍ និងគ្រឿងម៉ាស៊ីន ដូចជា ម៉ូទ័របូម ទឹក ជាដើម នឹងមានការកើនឡើងនាពេលអនាគត។

## ៩.៤ អនុសាសន៍ដើម្បីជំរុញការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មគ្រឿងម៉ាស៊ីន

### ៩.៤.១ វិធានការអភិវឌ្ឍន៍សំរាប់ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម

កំលាំងពលកម្មជាមួយភាពប្រកួតប្រជែងខ្លាំងរបស់កម្ពុជា ដែលទទួលបានការកោតសរសើរនៅក្នុងទីផ្សារអាស៊ី នឹងគាំទ្រដល់ការអភិវឌ្ឍន៍ឧស្សាហកម្មអតិពលកម្មនៅក្នុងស្រុក។ ការដាក់មូលធន និងការផ្ទេរបច្ចេកវិទ្យាតាមរយៈការទទួលការវិនិយោគបរទេសផ្ទាល់ មានសារសំខាន់យ៉ាងខ្លាំង ក្នុងការជំរុញឧស្សាហានីយកម្មនៅកម្ពុជា។ ប៉ុន្តែថាមពលដែលមានតម្លៃខ្ពស់ លំហូរចូលនូវតវ៉ាន់គេចពន្ធដែលមានតម្លៃថោក ការកំហិតការនាំចូលលើសម្ភារៈ និងគ្រឿងម៉ាស៊ីនផលិតកម្ម នីតិវិធីសាំញ៉ាំក្នុងការនាំចេញ និងនាំចូល អវត្តមាននៃឧស្សាហកម្មគាំទ្រ បញ្ហាស្ថាប័នរាំងស្ទះផ្សេងៗ ព្រមទាំងតម្លៃផលិតកម្មខ្ពស់ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ បានបង្កជាឧបសគ្គរាំងដល់ការទទួលការវិនិយោគបរទេសផ្ទាល់។ ដូច្នេះរដ្ឋាភិបាល ចាំបាច់ត្រូវចាត់វិធានការផ្សេងៗ ដើម្បីលប់បំបាត់ឧបសគ្គទាំងនេះ ក្នុងគោលបំណងទាក់ទាញការវិនិយោគបរទេសផ្ទាល់ចូលមកកម្ពុជា។

ក្នុងចំណោះវិធានការទាំងនោះ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍នៃឧស្សាហកម្មគាំទ្រ និងវិធានការដើម្បីលុបបំបាត់បញ្ហាស្ថាប័នរាំងស្ទះផ្សេងៗ ត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធផ្ទាល់ទៅលើការអភិវឌ្ឍន៍ឧស្សាហកម្មគ្រឿងម៉ាស៊ីន ហើយត្រូវបានបរិយាយដូចខាងក្រោម :

#### (1) ការផ្គត់ផ្គង់ថាមពលអគ្គីសនី

ហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដែលបានរងការខូចខាតដោយសង្គ្រាមស៊ីវិលនៅកម្ពុជា បានត្រូវកែទំរង់ និងកែលំអចាប់តាំងពីសន្ធិសញ្ញាក្រុងប៉ារីសនៅឆ្នាំ ១៩៩១ មក ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធទាំងនោះភាគច្រើន នៅតែមានលក្ខណៈមិនល្អនៅឡើយ។ ជាពិសេស កង្វះខាតបណ្តាញផ្លូវគមនាគមន៍ និងអគ្គិសនី គឺជាឧបសគ្គចំបង ដល់ក្រុមហ៊ុនបរទេស ដោយសារតែកង្វះខាតនេះធ្វើអោយតម្លៃផលិតកម្មកើនឡើង។

បរិមាណថាមពលអគ្គិសនី ដែលបានផ្គត់ផ្គង់ជាក់ស្តែងនៅមានកំរិតទាបនៅឡើយ ហើយមានក្រុមហ៊ុនតិចតួចប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបាននូវការផ្គត់ផ្គង់ថាមពលអគ្គិសនីជាប់ជាប្រចាំ។ ការចំណាយទៅលើថាមពលអគ្គិសនីនៅកម្ពុជាមានតម្លៃខ្ពស់ជាងជិតពាក់កណ្តាលបើប្រៀបទៅនឹងប្រទេសវៀតណាម ដោយសារតែ ការពឹងផ្អែកទៅលើម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូតនិងបណ្តាញចែកចាយថាមពលមិនល្អ ហើយនេះជាឧបសគ្គដល់សកម្មភាពធុរកិច្ច។

ដើម្បីនឹងដោះស្រាយនូវកង្វះខាតថាមពលអគ្គិសនី ការអនុវត្តវិធានការទូលំទូលាយ ដូចជាការធ្វើកិច្ចព្រមព្រៀងទិញថាមពលពីប្រទេសជិតខាង និងការសាងសង់រោងចក្រផលិតថាមពលដោយក្រុមហ៊ុនបរទេស ក្រោមរូបភាព IPP គឺជាប្រការចាំបាច់។ IPP នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស គួរតែផលិតអគ្គីសនីនៅក្នុងតម្លៃមួយសមរម្យដើម្បី

ប្រកួតប្រជែងជាមួយសួនឧស្សាហកម្មនៅប្រទេសជិតខាង។

**(2) សួនឧស្សាហកម្ម**

ដូចគ្នានឹងការកែទំរង់ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតសួនឧស្សាហកម្ម គឺមានសារសំខាន់ក្នុងការទាក់ទាញឧស្សាហកម្មគ្រឿងម៉ាស៊ីនបរទេស។ មានតំបន់ឧស្សាហកម្មមួយចំនួននៅកម្ពុជា ដែលបង្កើតដោយក្រុមហ៊ុនឯកជនក្នុងស្រុក ប៉ុន្តែក្រុមហ៊ុនបរទេសមានការរារែកនៅឡើយដោយសារតំបន់ទាំងនេះមិនទាន់បានឆ្លើយតបទៅនឹងលក្ខខណ្ឌផ្សេងៗសំរាប់ដំណើរការធុរកិច្ចនៅឡើយដូចជាការផ្គត់ផ្គង់ថាមពលការធានានូវលទ្ធភាពដឹកជញ្ជូនទៅកំពង់ផែសំខាន់ៗ ការផ្គត់ផ្គង់ទឹកឧស្សាហកម្ម និងការកសាងបណ្តាញប្រែសណីយ៍។

តាមការរំពឹងទុក ចំនួនតំបន់ឧស្សាហកម្មដែលបង្កើតឡើងសំរាប់ធ្វើពាណិជ្ជកម្មជាមួយក្រុមហ៊ុនបរទេស នឹងកើនឡើងតាមរយៈការអនុម័តអនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស។ ការបង្កើតច្បាប់ និងអនុក្រឹត្យថែមទៀត ក្រោមគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល នឹងពន្លឿនការអភិវឌ្ឍន៍តំបន់ឧស្សាហកម្មទាំងនេះ។ ទាក់ទិនទៅនឹងការអភិវឌ្ឍន៍ជាក់ស្តែង ការងារគួរតែមិនត្រូវអនុវត្តដោយរដ្ឋាភិបាលទេ ប៉ុន្តែដោយផ្នែកឯកជន ដើម្បីធានាបាននូវការបញ្ចប់បានលឿន។

## ៩.៤.២ វិធានការនៃការអភិវឌ្ឍន៍សំរាប់ឧស្សាហកម្មគាំទ្រ

ឧស្សាហកម្មគ្រឿងម៉ាស៊ីនរបស់កម្ពុជា គឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ក្នុងទិដ្ឋភាពនៃទំហំផលិតកម្ម និងក្រុមហ៊ុន។ ខណៈពេលដែលចំនួនអ្នកតម្លើង គឺកំពុងតែពង្រីកជាបណ្តើៗ ជាពិសេសក្នុងផលិតកម្មម៉ូតូ និងកង់ ឧស្សាហកម្មគាំទ្រសំរាប់ក្រុមហ៊ុនទាំងនេះ មិនទាន់មានការរីកចំរើននៅឡើយ ដើម្បីក្លាយទៅជាអ្នកទទួលម៉ៅការបន្ត។ ការអភិវឌ្ឍន៍ឧស្សាហកម្មគាំទ្រសំរាប់រយៈពេលមធ្យម និងវែង ដើម្បីផ្គត់ផ្គង់អោយឧស្សាហកម្មផលិតម៉ូតូនូវ គ្រឿងបំណែក និងគ្រឿងបន្សំផ្សេងៗ និងការពង្រឹងការបែងចែកការងារជាមួយឧស្សាហកម្មផលិតម៉ូតូ និងយានយន្តនៅប្រទេសថៃ គឺជាកិច្ចការដ៏សំខាន់មួយ។ ដូច្នេះ ការបង្កើតនូវវិធានការគាំទ្រជាទូទៅសំរាប់ឧស្សាហកម្មគាំទ្រ ដែលដាក់ការយកចិត្តទុកដាក់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយសាខាក្រុមហ៊ុនបរទេស គួរតែអនុវត្តដោយមានការលើក ទឹកចិត្តចំពោះការដាក់ទុន និងបច្ចេកវិទ្យាតាមរយៈការទាក់ទាញក្រុមហ៊ុនផលិតបំណែកយានយន្តបរទេសមកកម្ពុជា។ វិធានការគាំទ្របែបនោះ ត្រូវរួមបញ្ចូលទាំងវិធានការដូចតទៅ : (១) រៀបចំគោលនយោបាយឱ្យទូលំទូលាយមួយសំដៅគាំពារឧស្សាហកម្មគាំទ្រ (២) ធ្វើឱ្យជឿនលឿននូវបច្ចេកវិទ្យាក្នុងឧស្សាហកម្មគាំទ្រ (៣) កែលំអជំនាញគ្រប់គ្រង និង (៤) អភិវឌ្ឍន៍ធនធានមនុស្ស។

## ៩.៤.៣ វិធានាការអភិវឌ្ឍន៍សំរាប់ទាក់ទាញការវិនិយោគបរទេសផ្ទាល់ (សកម្មភាពគាំទ្រចំពោះការវិនិយោគទាក់ទាញរបស់ក្រុមហ៊ុនបរទេស)

បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដើម្បីទប់ស្កាត់ការវិនិយោគបរទេសផ្ទាល់ចូលមកកម្ពុជា គឺការផ្តល់ពត៌មានពាក់ព័ន្ធនឹងការវិនិយោគទៅបរទេសមានភាពតិចតួចពេក។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែតំរូវឱ្យមានការផ្សព្វផ្សាយពត៌មានទាំងនោះទៅក្រៅឱ្យបានសកម្មបំផុត ជាពិសេសពត៌មានលំអិតនិយាយអំពីការលើកទឹកចិត្តដល់ការវិនិយោគ និន្នាការនៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងទិដ្ឋភាពទូទៅនៃឧស្សាហកម្មពាក់ព័ន្ធ។ រាជរដ្ឋាភិបាល គួរតែ

លើកវិធានការផ្សេងៗដើម្បីពង្រីកសកម្មភាពជំរុញការវិនិយោគ ។

មាតិកាពតិមានស្តីពីបរិស្ថានវិនិយោគសំរាប់អ្នកផលិតបំណែកយានយន្ត និងម៉ាស៊ីនបរទេស គឺជាប្រការខានមិនបានជាមួយនឹងការគាំទ្រជាក់លាក់សំរាប់ក្រុមហ៊ុន ដែលត្រូវធ្វើការវិនិយោគក្នុងផលិតកម្មនៃប្រភេទផលិតផលជាអាទិភាពដូចបានបង្ហាញជូនក្នុងរបាយការណ៍ស្រាប់ ។

# ផ្នែកទី ២
# ការជំរុញវិនិយោគ

# ជំពូកទី ១០

## ការវិភាគនៃមូលដ្ឋានសំរាប់ការជំរុញការវិនិយោគបរទេសផ្ទាល់នៅកម្ពុជា

### ១០.១ ក្របខ័ណ្ឌច្បាប់ និងការប្រតិបត្តិនូវបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការវិនិយោគ

### ១០.១.១ ស្ថានភាពបច្ចុប្បន្នខាងច្បាប់និងតុលាការ ក្នុងប្រទេសកម្ពុជា

ប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន ខ្វះខាតនូវបណ្តុំក្រមជាមូលដ្ឋាននិងទូលំទូលាយ និងពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រព័ន្ធច្បាប់ទូទៅ ដែលមានច្បាប់ពិសេស១រៀង១ខ្លួន។ ទោះបីជាការងារធ្វើព្រាងច្បាប់នៅតែបន្ត ដោយមានជំនួយឧបត្ថម្ភពីម្ចាស់ជំនួយនានាអស់រយៈពេលជាយូរមកហើយក្តី ក៏បណ្តុំក្រមសំខាន់១ដូចជា ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌនៅតែពុំទាន់ត្រូវបានអនុម័តដោយរដ្ឋសភាទេ។ ដំណើរការតាក់តែងច្បាប់យឺតយ៉ាវបែបនេះ គឺជាឧបសគ្គចម្បងមួយក្នុងចំណោមឧបសគ្គជា ច្រើន ដែល ធ្វើឱ្យប្រព័ន្ធច្បាប់កម្ពុជាមិនជាទីទុកចិត្ត និងពុំមានប្រសិទ្ធភាព។

មូលហេតុចំពោះការពន្យាពេលក្នុងការតាក់តែងច្បាប់ មានដូចខាងក្រោម :

- ពុំមានលទ្ធភាពធ្វើព្រាងច្បាប់ក្នុងជួរក្រសួងនានា
- ការិយាល័យរបស់គណៈវិនិច្ឆ័យ ពុំមានលទ្ធភាពធ្វើការសំរបសំរួលក្នុងចំណោមក្រសួងដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ ទៅលើភាពអនុលោមតាមច្បាប់ និងបទបញ្ញត្តិដទៃទៀត ព្រមទាំងអស់លទ្ធភាពរបស់ រដ្ឋសភា និងព្រឹទ្ធសភា ក្នុងការពិនិត្យមើលឡើងវិញ លៃតម្រូវ និងកែប្រែព្រាងច្បាប់នានា

ដោយសារតែការពន្យាពេលក្នុងដំណើរការតាក់តែងច្បាប់នេះ បទបញ្ញត្តិចាំបាច់នានាដែលនឹងចេញ ច្រើនតែមានទម្រង់ជាក្រឹត្យ ឬអនុក្រឹត្យ ដែលជាហេតុនាំឱ្យមានការផ្តោតអំណាចទៅលើមនុស្សមួយចំនួនតូច និងធ្វើឱ្យដំណើរការតាក់តែងច្បាប់ទៅជាមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព កាន់តែតិចទៅ១។ តាមបែបនេះ វាអាចនឹងពិបាកក្នុងការទប់ស្កាត់នូវការតាក់តែងច្បាប់ ដែលអាចធ្វើ ឡើង សម្រាប់ ជាផលប្រយោជន៍ដល់មនុស្ស ឬក្រុមមួយក្តាប់តូច។

ការប្រតិបត្តិច្បាប់និងបទបញ្ញត្តិមិនបានពេញលេញ ខ្សោយ ខុស ឬមិនត្រឹមត្រូវ គឺជាភាពងាយរងគ្រោះមួយទៀតនៃប្រព័ន្ធច្បាប់កម្ពុជា។ ជារឿយ១ បញ្ហានេះត្រូវបានបន្ទោសចំពោះចេតនាបំផ្លាញ ឬ ការមិនអើពើទៅនឹងខចែងនៃច្បាប់ និងបទបញ្ញត្តិនានា របស់នគរបាល មន្ត្រីរដ្ឋាភិបាល ឬចៅក្រម។

បញ្ហាផ្តល់សំណូកដល់ចៅក្រម និងបុគ្គលិកតុលាការ ក៏ត្រូវបានចង្អុលបង្ហាញ និងរាយការណ៍ជារឿយ១ផងដែរ។ នេះធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់ប្រជាជនទៅលើភាពថ្លៃថ្នូររបស់ច្បាប់ និងទៅលើ គោលការណ៍នៃច្បាប់។

ជារឿយ១ការកាត់ក្តីដោយតុលាការត្រូវបានប្រជាជនចោទប្រកាន់ថាមានភាពលំអៀង និងម្តងដូច្នេះ ម្តងដូច្នោះ។ មូលហេតុមួយក្នុងចំណោមជាច្រើន គឺមកពីមានចៅក្រម និងព្រះរាជអាជ្ញាដែលពុំមានគុណសម្បត្តិគ្រប់គ្រាន់។ "ការវាយ

តម្លៃលើផ្នែកច្បាប់និងតុលាការនៅកម្ពុជា" (ដែលបោះផ្សាយក្នុង ខែវិច្ឆិកា ឆ្នាំ២០០៣ ដោយធនាគារពិភពលោក) បានបញ្ជាក់ថា ក្នុងមជ្ឈដ្ឋានតុលាការ មានមន្ត្រីតែ២៣នាក់ប៉ុណ្ណោះ មានសញ្ញាបត្រច្បាប់ ដូចដែលបង្ហាញក្នុងតារាង ១០-១-១

ជាផលវិបាក វិធាននៃច្បាប់ត្រូវបានចាត់ទុកថាមិនពេញលេញក្នុងប្រទេសកម្ពុជា ពីព្រោះដូចដែល "ការវាយតម្លៃ" ខាងលើចង្អុលបង្ហាញថា " វិធាននៃច្បាប់នេះសំអាងត្រង់កន្លែងដែល :

រដ្ឋាភិបាលនោះឯងត្រូវបានកំណត់ព្រំដែនដោយច្បាប់

មនុស្សគ្រប់គ្នាក្នុងសង្គមត្រូវបានចាត់ទុកស្មើគ្នាចំពោះមុខច្បាប់

ភាពថ្លៃថ្នូរជាមនុស្សរបស់បុគ្គលម្នាក់ៗត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ និង

យុត្តិធម៌មានដល់មនុស្សគ្រប់គ្នា "

**តារាង ១០-១-១ ប្រវត្តិអប់រំរបស់តុលាការ គិតត្រឹមឆ្នាំ ១៩៩៩**

| កម្រិតអប់រំ | ចៅក្រមតុលាការខេត្តក្រុង[១] | ចៅក្រមតុលាការឧទ្ធរណ៍ | ចៅក្រមតុលាការកំពូល | ព្រះរាជអាជ្ញា | សរុប |
|---|---|---|---|---|---|
| បរិញ្ញាបត្រច្បាប់ (រយៈពេល ៤ឆ្នាំ) | ១១ | ៦ | ១ | ៥ | ២៣ |
| បរិញ្ញាបត្រច្បាប់ (មិនទាន់បញ្ចប់-រយៈពេល៣ឆ្នាំ) | ១ | 0 | 0 | 0 | ១ |
| ឌីប្លូមផ្នែកច្បាប់ (រយៈពេល២ឆ្នាំ) | ១១ | 0 | 0 | ៦ | ១៧ |
| អ្នកដែលគេតែងតាំង ឆ្នាំ១៩៩៨ (បរិញ្ញាប័ត្រ ឌីប្លូមផ្នែកច្បាប់) | ១១ | 0 | 0 | ៤ | ១៥ |
| ឌីប្លូមផ្នែកច្បាប់(មិនទាន់បញ្ចប់) | ៣ | 0 | ២ | ១ | ៦ |
| បរិញ្ញាបត្រ (មិនមែនច្បាប់) | ៣ | ១ | ១ | ១ | ៦ |
| វិទ្យាល័យ | ៣៦ | ១ | ២ | ១៤ | ៥៣ |
| អនុវិទ្យាល័យ | ៧ | 0 | ១ | ១0 | ១៨ |
| បឋមសិក្សា | ៧ | ១ | 0 | ៦ | ១៤ |
| វិញ្ញាបនបត្រខាងគ្រូបង្រៀន | 0 | 0 | ១ | ១ | ២ |
| បរិញ្ញាបត្រ (មិនទាន់បញ្ចប់) | ២ | 0 | 0 | ៤ | ៦ |

[១] រួមទាំងចៅក្រម ៨នាក់ នៅក្នុងក្រសួងយុត្តិធម៌ផង — ប្រភព : ក្រសួងយុត្តិធម៌

| កម្រិតអប់រំ | ចៅក្រម តុលាការ ខេត្តក្រុង[១] | ចៅក្រម តុលាការ ឧទ្ធរណ៍ | ចៅក្រម តុលាការ កំពូល | ព្រះរាជ អាជ្ញា | សរុប |
|---|---|---|---|---|---|
| ពុទ្ធិកសិក្សា | ៥ | ០ | ០ | ២ | ៧ |
| សាលាភូមិនរដ្ឋបាល | ០ | ០ | ១ | ០ | ១ |
| ការអប់រំដែលមិនដឹងច្បាស់ | ២ | ០ | ០ | ០ | ២ |
| សរុប | ៩៩ | ៩ | ៩ | ៥៤ | ១៧១ |

ប្រភព : " ការវាយតម្លៃលើផ្នែកច្បាប់និងតុលាការនៅកម្ពុជា" ខែវិច្ឆិកា ឆ្នាំ២០០៣ ដោយធនាគារពិភពលោក

### ១០.១.២ ច្បាប់ និងបទបញ្ញត្តិដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ចនៅកម្ពុជា

(១) **ស្ថានភាពនៃច្បាប់ និងបទបញ្ញត្តិដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ចនៅក្នុងប្រទេសកម្ពុជា រហូតដល់ឆ្នាំ ២០០៥**

ដើម្បីលើកកម្ពស់បរិស្ថានវិនិយោគ រក្សានូវពាក្យសន្យាកាលពីចូលអង្គការពាណិជ្ជកម្មពិភពលោក និងធ្វើឱ្យស្រប តាមបទបញ្ញត្តិរបស់ WTO រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងសង្កត់ធ្ងន់ទៅលើការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិ នានា និង,ឬណែនាំនូវច្បាប់ និងបទបញ្ញត្តិថ្មីៗ ក្នុងវិស័យវិនិយោគ ពាណិជ្ជកម្ម និងធុរកិច្ច ។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានច្បាប់សំខាន់ៗខ្លះ ដែលពុំទាន់ត្រូវបានអនុម័តក្នុងវិស័យច្បាប់ធុរកិច្ចនៅ ឡើយ ។ ច្បាប់ទាំងនោះមានដូចខាងក្រោម (ប៉ុន្តែមិនត្រូវបានដាក់កម្រិតទេ) :

ក្រមរដ្ឋប្បវេណី

ក្រមពាណិជ្ជកម្ម

ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម

ច្បាប់ស្តីពីការធានាប្រតិបត្តិការ

ច្បាប់ស្តីពីរដ្ឋបាលស៊ីវិល

ច្បាប់ស្តីពីអសាអភាព (ការក្ស័យធន)

ច្បាប់ ស្តីពី Anti-Dumping, Countervailing Duty និងវិធានការសុវត្ថិភាព

ច្បាប់ស្តីពីមជ្ឈត្តិកម្មពាណិជ្ជកម្មរបស់កម្ពុជា

ក្រមគយ

ច្បាប់ស្តីពីរោងចក្រ

ច្បាប់ស្តីពីបទដ្ឋានឧស្សាហកម្ម

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

ក្នុងចំណោមច្បាប់ទាំងនោះ ក្រមរដ្ឋប្បវេណីដ៏ទូលំទូលាយមួយត្រូវបានតម្រូវឱ្យអនុម័តមុនគេ។ បណ្តាប្រតិបត្តិការពាណិជ្ជកម្មនឹងមានការលំបាកណាស់ក្នុងការអនុវត្តដោយសុវត្ថិភាព បើពុំមានក្រមរដ្ឋប្បវេណីដ៏ទូលំទូលាយទេនោះ ពីព្រោះវាជាក់កម្រិតទៅលើទស្សនទានជាមូលដ្ឋាន និងវិធាននៃប្រតិបត្តិការដូចជា សិទ្ធិលើទ្រព្យសកម្មរូបិយនិងអរូបិយ, សិទ្ធិលើអំពើកម្មសិទ្ធិភាព ឬការផ្ទេរសិទ្ធិបែបនេះ, ទំនាក់ទំនងនៅ ក្នុងចំណោមម្ចាស់បំណុល និងកូនបំណុល ជាដើម។

ជាញឹកញាប់ណាស់ អំពើពុករលួយរបស់មន្ត្រីរដ្ឋាភិបាល ត្រូវបានចាត់ទុកជាឧបសគ្គសំខាន់ចំពោះប្រតិបត្តិការធុរកិច្ចក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីការបញ្ជូនត្រឡប់ទៅវិញជាលើកទីមួយនូវអ្នកពិគ្រោះយោបល់ ម្នាក់ផ្នែកប្រឆាំងអំពើពុករលួយក្នុងខែធ្នូ ឆ្នាំ២០០៤ អង្គការ UNDP បានអញ្ជើញគាត់ម្តងទៀតឱ្យមកកាន់ប្រទេសកម្ពុជា ជាលើកទីពីរ ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ ដើម្បីផ្តល់នូវជំនួយបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់កែប្រែថ្មីលើពង្រាងច្បាប់ដើមស្តីពីការប្រឆាំងនឹងអំពើពុករលួយ។ ទោះបីជាពង្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយនេះពុំទាន់ត្រូវបានអនុម័តយ៉ាងណាក៏ដោយ ក៏ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦ បានរំពឹងទុកថាពង្រាងច្បាប់នេះនឹងត្រូវបានអនុម័តឆាប់ៗដោយរដ្ឋសភា។

នីតិវិធីនាំទំនិញចេញដ៏ស្មុគស្មាញនិងធ្វើដដែលៗ ក៏ត្រូវបានកែប្រែខ្លះៗផងដែរ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានធ្វើអនុស្សរណៈមួយ (លេខ៤៨៧ ឧរថ បថឧ) ទៅកាន់ GMAC ដោយប្រាប់ថាខ្លួនបានលុបចោលនូវការតម្រូវឱ្យមានអធិការកិច្ច (មុនពេលផ្ទុក) និងការចេញវិញ្ញាបនបត្របញ្ជាក់ពីការ កែច្នៃ (Certificate of Processing).

គយក៏បានសម្រេចចិត្តអនុម័តនូវបែបបទប្រតិវេទន៍នាំចេញ នាំចូលតែមួយផងដែរ ដើម្បីធ្វើឱ្យនីតិវិធីនេះមានលក្ខណៈសាមញ្ញ និងកាត់បន្ថយឱកាសពុករលួយ។ គេនិយាយថា វាត្រូវបានប្រើប្រាស់ចាប់ពីខែមីនា ឆ្នាំ២០០៦។ អធិការកិច្ចផ្នែករូបសាស្ត្រក៏ត្រូវបានគេគ្រោងកាត់បន្ថយពី១០០%នៅពេលនោះ ចុះមកនៅ៥០% ត្រឹមចុងឆ្នាំ២០០៦ និង ២៥% ត្រឹមចុងឆ្នាំ២០០៧។ ដើម្បីពង្រឹងនិន្នាការរួចផុត និងធ្វើឱ្យសាមញ្ញនេះ ត្រូវតែ តម្រូវឱ្យមានការតាក់តែងជាបន្ទាន់នូវក្រមគយ និងឧបត្ថម្ភធន ដ៏ទូលំទូលាយមួយ។

នៅក្នុងខែកញ្ញា ឆ្នាំ២០០៥ បន្ទាប់ពីរយៈពេលពីរឆ្នាំកន្លះ ចាប់ពីការអនុម័តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការវិនិយោគមក រដ្ឋាភិបាលបានអនុម័តនូវ "អនុក្រឹត្យ លេខ ១១១អនក្រ.បក ស្តីពីការអនុវត្តន៍ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការវិនិយោគ" សំរាប់ផ្តល់នូវនិយមន័យនៃវាក្យស័ព្ទ និងពន្យល់ពីនីតិវិធីអនុម័តការវិនិយោគ ទោះបីជាវិធាន និងបទប្បញ្ញត្តិបែបនេះ ត្រូវបានអនុម័តជាការសំខាន់ នៅពេលប្រកាសឱ្យប្រើច្បាប់នេះក៏ដោយ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ "អនុក្រឹត្យ (លេខ ១៤៨អនក្រ បក) ស្តីពីការបង្កើត និងការគ្រប់-គ្រងតំបន់សេដ្ឋកិច្ចពិសេស" ត្រូវបានចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** រួមជាមួយនិង "អនុក្រឹត្យ (លេខ ១៤៧អនក បក) ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ក.អ.ក" ដែលជាអ្នកបង្កើតនូវ "គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា "គ.ស.ព" ប៉ុន្តែជាថ្មីម្តងទៀត ដោយពុំមានវិធាន និងបទបញ្ញត្តិឡើយ។ នៅពេលដែលច្បាប់មួយ ឬការតាក់តែងច្បាប់ម្តងមួយៗ មិនត្រូវបានអមមកជាមួយនូវវិធាននិងបទបញ្ញត្តិដ៏លំអិតទេនោះ ការអនុវត្តនិងការដាក់ឱ្យប្រតិបត្តិអាចនឹងក្លាយទៅជាទង្វើតាមអំពើចិត្ត។ នេះគឺជាបញ្ហាមួយ ក្នុងចំណោមបញ្ហាស្លាប់-រស់បំផុតជាច្រើន ដែលប្រព័ន្ធច្បាប់កម្ពុជាត្រូវប្រឈម។

### (២) ការបង្កើតក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ក្នុងឆ្នាំ២០០៦ ដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ចនៅកម្ពុជា

ក្នុងឆ្នាំ២០០៦ ច្បាប់សំខាន់ៗចំនួនបីត្រូវបានអនុម័ត ដូចជា "ច្បាប់ស្តីអំពីមជ្ឈត្តិកម្មពាណិជ្ជកម្ម" "ច្បាប់ស្តីពីការគ្រប់គ្រងលើរោងចក្រនិងសិប្បកម្ម" និង "ក្រមនីតិវិធីរដ្ឋប្បវេណី"។ លើសពីនេះទៀត គេក៏បានចេញអនុក្រឹត្យផ្សេងៗដែលមានផលប៉ះពាល់សំខាន់ទៅលើសកម្មភាពវិនិយោគនិងធុរកិច្ចផងដែរ។ ការបង្កើតបែបនេះ ត្រូវបានបង្ហាញដោយសង្ខេបក្នុងតារាង ១០-១-២ ដូចខាងក្រោម :

**តារាង ១០-១-២ ការវិវត្តន៍ថ្មីៗ នៃច្បាប់ និងបទបញ្ញត្តិធុរកិច្ចនៅកម្ពុជា**

| ច្បាប់ និងបទបញ្ញត្តិ | កាលបរិច្ឆេទចូលជាធរមាន |
|---|---|
| ប្រកាសលេខ ៦០៧ សហវ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋករ | សីហា ២០០៦ |
| អនុក្រឹត្យ លេខ៨៤ អនក្រ.បក ស្តីពីការបង្កើតអង្គភាពប្រឆាំងនឹងអំពើពុករលួយ | សីហា ២០០៦ |
| អនុក្រឹត្យ លេខ៦៤ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុវត្តច្បាប់ទាក់ទិននឹងម៉ាកឈ្មោះយីហោ និងអំពើនៃការប្រកួតប្រជែងមិនត្រឹមត្រូវ | កក្កដា ២០០៦ |
| ក្រមនីតិវិធីរដ្ឋប្បវេណី | មិថុនា ២០០៦ |
| អនុក្រឹត្យ លេខ៥៧ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង" | មិថុនា ២០០៦ |
| អនុក្រឹត្យ លេខ៧០៧ អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីនូវការរចនាប្លង់ឧស្សាហកម្ម | មិថុនា ២០០៦ |
| ច្បាប់ស្តីពីការគ្រប់គ្រងលើរោងចក្រ និងសិប្បកម្ម | មិថុនា ២០០៦ |
| ច្បាប់ស្តីពីមជ្ឈត្តិកម្មពាណិជ្ជកម្ម | ឧសភា ២០០៦ |
| ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ស្តីពីការបង្កើតអាជ្ញាធរជាតិ សម្រាប់ | កុម្ភៈ ២០០៦ |

| ច្បាប់ និងបទបញ្ញត្តិ | កាលបរិច្ឆេទចូលជាធរមាន |
|---|---|
| ការដោះស្រាយជម្លោះដីធ្លី | |

ប្រភព : DFDL Weekly Law Update និងក្រុមការងារសិក្សារបស់ JICA

"ច្បាប់ស្តីអំពីមជ្ឈត្តិកម្មពាណិជ្ជកម្ម" គឺដើម្បីបំពេញការប្តេជ្ញាចិត្តរបស់កម្ពុជា ចំពោះ WTO ហើយនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាជម្លោះនានា ដែលមិនទាន់មានមូលដ្ឋានច្បាប់ដ៏ប្ញងមាំ អស់រយៈពេលយូរណាស់មកហើយ នៅក្នុងប្រទេសកម្ពុជា។ ស្ថិតនៅក្រោមច្បាប់នេះ មជ្ឈមណ្ឌលជាតិមជ្ឈត្តិកម្មពាណិជ្ជកម្មនឹងត្រូវបានបង្កើតឡើង។ ច្បាប់នេះកំណត់ពីបណ្តានីតិវិធីសម្រាប់ការយោងជម្លោះនានា ចំពោះមជ្ឈត្តវិនិច្ឆ័យ និងការតែងតាំងក្រុមគណៈវិនិច្ឆ័យ នីតិវិធីសម្រាប់ការធ្វើមជ្ឈត្តវិនិច្ឆ័យ ទំនាក់ទំនងរវាងបណ្តឹង និងតុលាការមានសមត្ថកិច្ច នីតិវិធីសម្រាប់ការទទួលស្គាល់ និងការដាក់ឱ្យប្រតិបត្តិនូវង្វាន់វិនិច្ឆ័យជាដើម។ ជាមួយនិងការអនុម័តច្បាប់នេះ សង្គមនៃធុរកិច្ចនឹងអាចសង្ឃឹមលើការដោះស្រាយជម្លោះដែលទុក ចិត្តបាន និងមានតម្លាភាព។

"ច្បាប់ស្តីពីការគ្រប់គ្រងលើរោងចក្រ និងសិប្បកម្ម" ត្រួតត្រាលើរោងចក្រ និងសិប្បកម្មទាំងអស់នៅកម្ពុជា ហើយកំណត់ថា ត្រូវតែទទួលបានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់បង្កើតរោងចក្រ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់សេចក្តីសម្រេចចិត្តដល់អ្នកដាក់ពាក្យសុំបង្កើតរោងចក្រ ក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃធ្វើការ យ៉ាងយូរបំផុត ចាប់ពីថ្ងៃទទួលការដាក់ពាក្យ។ ស្ថិតនៅក្រោមច្បាប់នេះ ម្ចាស់រោងចក្រត្រូវបានតម្រូវឱ្យទទួលខុសត្រូវចំពោះសកម្មភាពទាំងអស់របស់រោងចក្រ និងចំពោះគុណភាពនៃ ផលិតផល។ មុននឹងចាប់ផ្តើមប្រតិបត្តិការ ម្ចាស់រោងចក្រត្រូវជូនដំណឹងដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល យ៉ាងហោចណាស់ ១៥ថ្ងៃ ជាមុន។ សម្រាប់ការពង្រីក ឬការប្តូរទីតាំង ត្រូវតែទទួលបានលិខិតអនុញ្ញាតពី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលផងដែរ។

"ក្រមនីតិវិធីរដ្ឋប្បវេណី" ចែងអំពីនីតិវិធីដាក់ពាក្យបណ្តឹង ដែលទាក់ទិននឹងសិទ្ធិពលរដ្ឋ។ ទោះបីជា "ក្រមរដ្ឋប្បវេណី" មិនទាន់ត្រូវបានអនុម័តយ៉ាងណាក៏ដោយ ក៏ការព្រមទទួលយកច្បាប់នេះគឺជាវឌ្ឍនភាពដ៏សំខាន់ឆ្ពោះទៅរកការបង្កើតមូលដ្ឋានប្រព័ន្ធច្បាប់ នៅក្នុងប្រទេសកម្ពុជាផងដែរ។

ស្ថិតនៅក្រោមកាលៈទេសៈរង់ចាំយូរដែល "ច្បាប់ប្រឆាំងនឹងអំពើពុករលួយ" មិនទាន់ត្រូវបានអនុម័ត នៅឡើយនោះ ការចេញ "អនុក្រឹត្យលេខ៨៤ អនក្រ.បក ស្តីពីការបង្កើតអង្គភាពប្រឆាំងនឹងអំពើពុករលួយ" គឺជាជំហានឆ្ពោះទៅមុខតូចបំផុតមួយ ដើម្បីលើកស្ទួយបរិយាកាសវិនិយោគរបស់កម្ពុជា តាមរយៈការបំពេញនូវកង្វះខាតច្បាប់។ អនុក្រឹត្យនេះបញ្ជាក់ថា អង្គភាពប្រឆាំងនឹងអំពើពុក រលួយនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

(i) ប្រមូលឯកសារ និងព័ត៌មានទាំងអស់ ដែលទាក់ទងនឹងអំពើពុករលួយ និងរក្សាទុកប្រភពព័ត៌មាន នោះជាសម្ងាត់ នៅពេលមានការកើតឡើងនូវអំពើពុករលួយ

(ii) ពិនិត្យមើលឡើងវិញ និងរៀបចំឯកសារ ដែលទាក់ទងនឹងការប្រឆាំងអំពើពុករលួយ

(iii) បង្កើតផែនការសកម្មភាព ដើម្បីប្រឆាំងអំពើពុករលួយ

(iv) ទទួល និងពិនិត្យមើលឡើងវិញនូវបណ្តឹងទាំងអស់ដែលទាក់ទិននឹងអំពើពុករលួយ

(v) តាមដាន អង្កេត ធ្វើអធិការកិច្ច ស្រាវជ្រាវ និងដាក់វិធានការទល់នឹងបទល្មើសពុករលួយ ក៏ដូចជាប្តឹងយោងតាមនីតិវិធីដែលអាចអនុវត្តបាន ហើយ

(vi) អនុវត្តវិធានការរបស់រដ្ឋាភិបាល តាមរយៈការអប់រំ ឃោសនា ការបោះពុម្ពផ្សាយ ការប្រុងប្រយ័ត្ន ការបង្ការ ការប្រតិបត្តិច្បាប់ និងការទប់ស្កាត់អំពើពុករលួយ ។

"ប្រកាសលេខ៦០៧សហវ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋករ" ក៏ត្រូវបានគិតថាជាជំហានស្លាប់រស់ សម្រាប់រដ្ឋាភិបាលឈានទៅដល់ដំណាក់កាលអនុវត្តន៍នូវអនុក្រិត្យស្តីពីការជួយសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងលើហានិភ័យ ។

(៣) អនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធច្បាប់ដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ច

ភាពងាយរងផលប៉ះពាល់មួយ ក្នុងចំណោមជាច្រើនទៀតនៃប្រព័ន្ធច្បាប់កម្ពុជា គឺកង្វះខាតនូវច្បាប់ និងបទបញ្ញត្តិនានាឱ្យបានគ្រប់គ្រាន់ ។ ទោះបីជារដ្ឋាភិបាលកម្ពុជាបាននិង កំពុងខិតខំប្រឹងប្រែង អនុម័តនូវបទបញ្ញត្តិនានាដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ចឱ្យបានរួសរាន់យ៉ាងណាក៏ដោយ ក៏នៅមានច្បាប់សំខាន់ៗជាច្រើនទៀតពុំទាន់ត្រូវបានអនុម័តនៅឡើយដែរ ។ ច្បាប់ទាំងនោះមានដូចខាងក្រោម (ប៉ុន្តែមិនដាក់កម្រិតទេ) :

(i) ក្រមរដ្ឋប្បវេណី

(ii) ច្បាប់ប្រឆាំងអំពើពុករលួយ

(iii) ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម

(iv) ច្បាប់ស្តីពីការធានាប្រតិបត្តិការ

(v) ច្បាប់ស្តីពីអសាអភាព (ការក្ស័យធន)

(vi) ច្បាប់ស្តីពី Anti-Dumping, Countervailing Duty និងវិធានការសុវត្ថិភាព

(vii) ច្បាប់ស្តីពីបទដ្ឋានឧស្សាហកម្ម

(viii) ក្រមគយ និង

(ix) ច្បាប់ស្តីពីរដ្ឋបាលស៊ីវិល ។

វាមានរយៈពេលជាងបីឆ្នាំមកហើយ តាំងពីពង្រាងក្រមរដ្ឋប្បវេណីលើកទី១ត្រូវបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងខែកក្កដា ឆ្នាំ២០០៣ មកម្លេះ ហើយពង្រាងនេះមិនទាន់ត្រូវបានធ្វើចប់នៅឡើយ។ ក្រមរដ្ឋប្បវេណីនេះ គឺជាប្រព័ន្ធបទបញ្ញត្តិជាមូលដ្ឋានបំផុត សម្រាប់កំណត់ និងការពារសិទ្ធិមនុស្សជាមូលដ្ឋានទាំងពី ធម្មជាតិ និងតាមផ្លូវច្បាប់ ហើយនិងទំនាក់ទំនងរបស់ពួកគេ។ គេតម្រូវយ៉ាងអន្ទះសារឱ្យរដ្ឋាភិបាលអនុម័តនូវក្រមនេះ ក្នុងឱកាសណាមួយដែលអាចធ្វើទៅបានយ៉ាងឆាប់បំផុត។

ទោះបីជា"អនុក្រិត្យលេខ៨៤អនក្រ.បក ស្តីពីការបង្កើតអង្គភាពប្រឆាំងនឹងអំពើពុករលួយ" ផ្តល់នូវមូលដ្ឋានមួយសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយយ៉ាងណាក៏ដោយ ក៏វានៅតែមិនខ្លាំងគ្រប់គ្រាន់ ដូចច្បាប់នោះដែរ។ "អនុក្រិត្យលេខ៩៦ អនក្រ.បក ស្តីពីការបង្កើតអង្គភាពដើម្បីធ្វើសកម្មភាពប្រឆាំងនឹងអំពើពុករលួយ" ត្រូវបានចេញម្តងហើយកាលពីក្នុងឆ្នាំ១៩៩៩ ប៉ុន្តែអនុក្រិត្យស្រដៀងគ្នានេះត្រូវតែត្រូវបានចេញម្តងទៀត។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវតែមានអានុភាពប្រតិបត្តិរឹងមាំបំផុត ដោយមានទោសបញ្ញត្តិ ដែលចែងយ៉ាងច្បាស់លាស់ចំពោះសកម្មភាពពុករលួយនោះ ត្រូវតែត្រូវបានអនុម័ត ក្នុងពេលអនាគតដ៏ខ្លី។

ពង្រាងច្បាប់ដែលទាក់ទិននឹងធុរកិច្ចទាំងបួនដែលនិយាយយោងខាងលើ ក៏សំខាន់យ៉ាងខ្លាំងផងដែរ ក្នុងការធានាឱ្យសកម្មភាពធុរកិច្ចល្អទៅបាន។ ពង្រាងទាំងនេះត្រូវបានរៀបចំរួចរាល់អស់រយៈពេលជាយូរមកហើយ ហើយគេសង្ឃឹមថារដ្ឋាភិបាលនឹងជំរុញដំណើរការតាក់តែងច្បាប់ឱ្យបានឆាប់។

ទោះបីជាមានកង្វះខាតធ្ងន់ធ្ងរនូវច្បាប់ចាំបាច់នានាក៏ដោយ ក៏គេមិនផ្តល់អនុសាសន៍ឱ្យចេញអនុក្រឹត្យ ជំនួសឱ្យច្បាប់ជាញឹកញាប់នោះដែរ។ នៅពេលដែលច្បាប់ត្រូវតែត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងត្រូវបានផ្តល់សច្ចានុម័តដោយព្រឹទ្ធសភានោះ អនុក្រឹត្យគ្រាន់តែអាចត្រូវបានចេញបន្ទាប់ពីការយល់ព្រមដោយកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រីប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាអនុក្រិត្យមិនមានមូលដ្ឋានរឹងមាំ ក្នុងចំណោមពលរដ្ឋ និងខ្វះខាតនូវបទដ្ឋាននីត្យានុកូលរឹងមាំដូចច្បាប់ឡើយ។ ដើម្បីធ្វើឱ្យស្ថានភាពនេះប្រសើរឡើង គេផ្តល់អនុសាសន៍ យ៉ាងខ្លាំងក្លាឱ្យបង្កើតនូវដំណើរការតាក់តែងច្បាប់ឱ្យកាន់តែប្រាកដនិយមថែមទៀត។

ភាពងាយរងផលប៉ះពាល់ជាតួយ៉ាងផ្សេងទៀត នៃប្រព័ន្ធច្បាប់កម្ពុជា គឺក្នុងការអនុវត្ត និងការដាក់ ឱ្យប្រតិបត្តិនូវច្បាប់ និងបទបញ្ញត្តិនានា។

ឧទាហរណ៍មួយគឺថា ដូចដែលការប្រើពាក្យនូវខចែងខ្លះក្នុងច្បាប់ការងារ មានលក្ខណៈមិនម៉ឺងម៉ាត់ និងមិនច្បាស់លាស់ ដែលពេលខ្លះការបកស្រាយច្បាប់ទៅជាធ្វើឡើងតាមសភាពបត់បែន ឬនិយាយដោយប្រុងប្រយ័ត្ន ទៅតាមសម្ទើរបស់ផ្នែកឯកជន។ ទោះបីជាទូទៅ គេមិនអាចបន្ទោសបានក្នុងការខិតខំឆ្លើយតបនឹងសម្ទើ របស់វិនិយោគិននេះក៏ដោយ

ក៏គេមិនឱ្យមានការបកស្រាយតាមសភាពបត់បែនបែបនេះដែរ ក្រៅតែពីអត្ថន័យដ៏ពិតប្រាកដនៃខចែងនានា ដែលធ្វើឱ្យខូចដល់ប្រព័ន្ធច្បាប់ ក្នុងរយៈពេលវែង។

ដើម្បីធានានូវការប្រតិបត្តិច្បាប់ និងបទបញ្ញត្តិនានា គេតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈឱ្យកាន់តែមានលក្ខណៈប្រព័ន្ធថែមទៀត។ យ៉ាងហោចណាស់ ក៏ច្បាប់ និងបទបញ្ញត្តិនានាដែលទាក់ទិននឹងធុរកិច្ច និង/ឬការវិនិយោគនេះត្រូវបានបកប្រែទៅជាភាសាអន្តរជាតិ ដូចជាភាសាអង់គ្លេសដែលគេចូលចិត្តជាង នៅក្នុង រយៈពេលខ្លីបំផុតដែលអាចធ្វើបានហើយរក្សាទុកនៅក្នុង គ.វ.ក នៅទីកន្លែងណាដែលបើកចំហរឱ្យសាធារណជន ប្រើប្រាស់ដោយសេរីជាពិសេសបណ្តាវិនិយោគិន និងអ្នកធ្វើជំនួញ។

**៤) ច្បាប់ និងបទបញ្ញត្តិសំខាន់ៗ ដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ច នៅកម្ពុជា**

ច្បាប់ និងបទបញ្ញត្តិសំខាន់ៗនានា ដែលទាក់ទិននឹងការវិនិយោគ ពាណិជ្ជកម្ម និងប្រតិបត្តិការធុរកិច្ច ត្រូវបានចុះក្នុងតារាង ១០-១-៣ ដូចខាងក្រោម។ អត្ថបទនៃច្បាប់ និងបទបញ្ញត្តិជាង៨០ ឬអត្ថបទពង្រាង ត្រូវបានប្រមូលដោយក្រុមការងារសិក្សា។

**តារាង ១០-១-៣ ច្បាប់ និងបទបញ្ញត្តិនានាដែលទាក់ទិននឹងការវិនិយោគ និងធុរកិច្ច នៅកម្ពុជា**

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ***រដ្ឋធម្មនុញ្ញ រដ្ឋសភាជាតិ*** | |
| ច្បាប់ស្តីពីវិសោធនកម្មចំពោះមាត្រាទី ២៨ នៃរដ្ឋធម្មនុញ្ញ | ១៩៩៤ |
| រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា | ១៩៩៣ |
| ***រដ្ឋាភិបាល*** | |
| អនុក្រិត្យស្តីពីនីតិវិធីដាក់ទណ្ឌកម្មខាងវិន័យទៅលើមន្ត្រីរាជការ | ១៩៩៧ |
| ***តុលាការ*** | |
| ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ១៩៩៤ |
| ***ទូទៅ*** | |
| ក្រមរដ្ឋប្បវេណី | ពង្រាង |
| ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ | ពង្រាង |
| ក្រមនីតិវិធីរដ្ឋប្បវេណី | ខែមិថុនា ឆ្នាំ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| អនុក្រិត្យលេខ ៨៤ អនក្រ.បក ស្តីពីការបង្កើតអង្គភាពប្រឆាំងនឹងអំពើពុករលួយ | ២០០៦<br>ខែសីហា ឆ្នាំ ២០០៦ |
| ***ការវិនិយោគ*** | |
| អនុក្រិត្យ លេខ២៧ ស្តីពីវិសោធនកម្មលើអនុក្រិត្យលេខ១៤៧អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២០០៦ |
| អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីសហប្រតិបត្តិការវិនិយោគរវាង ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី | ២០០៦ |
| អនុក្រិត្យ លេខ១១១ អនក្រ.បក ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា | ២០០៥ |
| អនុក្រិត្យ លេខ១៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២០០៥ |
| អនុក្រិត្យ លេខ១៧ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង | ២០០៥ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រហូឡង់ ស្តីពីការជំរុញ និងការការពារវិនិយោគ | ២០០៥ |
| ដូចខាងលើដែរ (សាធារណរដ្ឋសង្គមនិយមវៀតណាម) | ២០០៥ |
| ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា | ២០០៣ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋគុយបា ស្តីពីការជំរុញ និងការការពារវិនិយោគ | ២០០២ |
| ដូចខាងលើដែរ (សាធារណរដ្ឋក្រូអាត) | ២០០២ |
| អនុក្រិត្យ លេខ៣៣ ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៍ | ២០០១ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះអនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគ រវាងរដ្ឋ និង ពលរដ្ឋនៃរដ្ឋផ្សេងៗទៀត | ២០០១ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង អង្គការ OPEC និងអង្គការមូលនិធិអភិវឌ្ឍន៍អន្តរជាតិ ស្តីពីការជំរុញ និងការការពារវិនិយោគ | ២០០១ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ដូចខាងលើដែរ ( សាធារណរដ្ឋហ្វីលីពីន) | ២០០១ |
| ដូចខាងលើដែរ ( សាធារណរដ្ឋបារាំង) | ២០០១ |
| ដូចខាងលើដែរ ( សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់) | ២០០១ |
| អនុក្រិត្យស្តីពីការអភិវឌ្ឍន៍កំពង់ផែស្វ័យតក្រុងព្រះសីហនុ | ២០០០ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីពីការជំរុញ និងការការពារវិនិយោគ | ២០០០ |
| ដូចខាងលើដែរ ( សាធារណរដ្ឋកូរ៉េ) | ២០០០ |
| ច្បាប់ស្តីពីការយល់ព្រមចំពោះកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសឹង្ហបុរី ស្តីពីការជំរុញ និងការការពារវិនិយោគ | ១៩៩៩ |
| ដូចខាងលើដែរ ( សហព័ន្ធស្វីស) | ១៩៩៩ |
| ដូចខាងលើដែរ ( សាធារណរដ្ឋប្រជាមានិតចិន) | ១៩៩៩ |
| ដូចខាងលើដែរ ( ព្រះរាជាណាចក្រថៃឡង់ដ៏) | ១៩៩៧ |
| ដូចខាងលើដែរ ( ម៉ាឡេស៊ី) | ១៩៩៦ |
| អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស រវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា | ១៩៩៦ |
| អនុក្រិត្យ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មក្រុងព្រះសីហនុ | ១៩៩៥ |
| កិច្ចព្រមព្រៀងស្តីពីការលើកទឹកចិត្តវិនិយោគ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក | ១៩៩៥ |
| ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា | ១៩៩៤ |
| ***តំបន់សេដ្ឋកិច្ចពិសេស/ដីធ្លីសំរាប់ឧស្សាហកម្ម*** | |
| អនុក្រិត្យស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត "អូនាង" | ខែមិថុនា ឆ្នាំ២០០៦ |
| អនុក្រិត្យលេខ១៤៨ អនក្រ.បក ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស | ២០០៥ |
| អនុក្រិត្យ លេខ ១៤៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២០០៥ |
| អនុក្រិត្យ លេខ១០ អនក្រ.បក ស្តីពីការបង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង | ២០០២ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័តិ, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| អនុក្រិត្យ លេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៏ | ២០០១ |
| អនុក្រិត្យ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មក្រុងព្រះសីហនុ | ១៩៩៥ |
| ***ធុរកិច្ច និងឧស្សាហកម្ម*** | |
| ច្បាប់ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម | កំពុងរៀបចំ |
| ច្បាប់ប្រឆាំងនឹងការចាក់ចោលទំនិញចាស់ៗ ការទប់ទល់ពន្ធគយ និងការការពារ | កំពុងរៀបចំ |
| បទបញ្ញត្តិស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) | កំពុងរៀបចំ |
| ច្បាប់ស្តីពីបទដ្ឋានឧស្សាហកម្ម | កំពុងរៀបចំ |
| ច្បាប់ស្តីពីសមាគមន៏ សហករណ៏ធុរកិច្ច | កំពុងរៀបចំ |
| ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម | ពង្រាង |
| ច្បាប់ស្តីពីការជួលខាងពាណិជ្ជកម្ម | ពង្រាង |
| ច្បាប់ស្តីពីការជួលអចលនវត្ថុផ្ទាល់ខ្លួន | ពង្រាង |
| ច្បាប់ស្តីពីទីភ្នាក់ងារពាណិជ្ជកម្ម | ពង្រាង |
| ច្បាប់ស្តីពីភាពពុំអាចសងបំណុលបាន ( ការក្ស័យធន) | ពង្រាង |
| ច្បាប់ស្តីពីការធានាប្រតិបត្តិការ | ពង្រាង |
| ច្បាប់ស្តីពីវិទ្យាស្ថានបទដ្ឋានជាតិកម្ពុជា | ពង្រាង |
| ច្បាប់ស្តីពីការគ្រប់គ្រងលើរោងចក្រ និងសិប្បកម្ម | ខែមិថុនា ឆ្នាំ២០០៦ |
| ច្បាប់ស្តីពីមជ្ឈត្តការនៃពាណិជ្ជកម្ម | ខែឧសភា ឆ្នាំ ២០០៦ |
| ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម | ២០០៥ |
| ច្បាប់ស្តីពីឧបករណ៏ដែលអាចចរចាបាន និងប្រតិបត្តិការទូទាត់ | ២០០៥ |
| បទបញ្ញត្តិក្រសួងស្តីពីការទទួលខុសត្រូវរបស់នាយក អ្នកគ្រប់គ្រង ឬម្ចាស់សហគ្រាស ចំពោះកាតព្វកិច្ចបង់ពន្ធ អាករលើតម្លៃបន្ថែម និងការប្រាក់ | ២០០៥ |
| បទបញ្ញត្តិក្រសួងស្តីពីការកំណត់តម្លៃចុះបញ្ជីក្រុមហ៊ុន នៅក្រសួងពាណិជ្ជកម្ម | ២០០៤ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| បទបញ្ញត្តិក្រសួងស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល | ២០០៤ |
| អនុក្រិត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តក្រុង | ២០០៤ |
| ច្បាប់ស្តីពីការយល់ព្រម និងអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងការដាក់ឱ្យប្រតិបត្តិនូវរង្វាន់វិនិច្ឆ័យសម្រាប់បរទេស | ២០០១ |
| បទបញ្ញត្តិក្រសួងស្តីពីបទដ្ឋានឧស្សាហកម្មកម្ពុជា | ២០០១ |
| ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម | ២០០០ |
| បទបញ្ញត្តិក្រសួងស្តីពីសកម្មភាពពាណិជ្ជរបស់ក្រុមហ៊ុនពាណិជ្ជកម្ម | ២០០០ |
| ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីបទបញ្ញត្តិពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម | ១៩៩៩ |
| បទបញ្ញត្តិក្រសួងស្តីពីវិធានការប្រឆាំងនឹងផលិតផលចំណីអាហារដែលពុំមានស្លាកសញ្ញា វេចខ្ចប់ត្រឹមត្រូវ | ១៩៩៩ |
| អនុក្រិត្យស្តីពីបទដ្ឋានសម្ភារៈ | ១៩៩៨ |
| លក្ខន្តិកៈទូទៅស្តីពីក្រុមហ៊ុនសាធារណៈ | ១៩៩៦ |
| ច្បាប់ស្តីពីការដោះដូរអត្រាប្តូរប្រាក់បរទេស | ១៩៩៧ |
| ច្បាប់ស្តីពីសភាពាណិជ្ជកម្ម | ១៩៩៥ |
| អនុក្រិត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មភ្នំពេញ | ១៩៩៥ |
| លក្ខណៈទូទៅនៃច្បាប់ស្តីពីបទបញ្ញត្តិពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម | ១៩៩៥ |
| សារាចរ លេខ៦៣ ស្តីពីការយល់ព្រមចំពោះសេដ្ឋកិច្ចទីផ្សារសេរី | ១៩៩៤ |
| ប្រកាស លេខ៣៨ យោងទៅលើកិច្ចសន្យា និងការទទួលខុសត្រូវផ្សេងៗទៀត | ១៩៨៨ |
| ***ពន្ធដារ និងគណនេយ្យ*** | |
| បទបញ្ញត្តិក្រសួងស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម (VAT) សម្រាប់ឧស្សាហកម្មផ្គត់ផ្គង់ ឬសហគ្រិនម៉ៅការងារកាត់ដេរសម្លៀកបំពាក់ វាយនភ័ណ្ឌ និងគ្រឿងសម្រាប់ពាក់នៅជើង | ២០០៥ |
| បទបញ្ញត្តិក្រសួងស្តីពីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋានពន្ធដារ | ២០០៥ |
| បទបញ្ញត្តិក្រសួង ស្តីពីការទទួលខុសត្រូវរបស់នាយក អ្នកគ្រប់គ្រង ឬម្ចាស់សហគ្រាស ចំពោះកាតព្វកិច្ចបង់ពន្ធ អាករលើតម្លៃបន្ថែម និងការប្រាក់ ដែលនឹងត្រូវបង់ | ២០០៥ |
| បទបញ្ញត្តិក្រសួងស្តីពីពន្ធលើប្រាក់ចំណេញ (ដែលធ្វើវិសោធនកម្មរួចហើយ) | ២០០៣ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័តិ, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| បទបញ្ញត្តិក្រសួងស្តីពីការអនុវត្តបទដ្ឋានគណនេយ្យកម្ពុជា (CAS) | ២០០៣ |
| បទបញ្ញត្តិក្រសួងស្តីពីពន្ធលើប្រាក់ចំណេញ | ២០០៣ |
| ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីពន្ធដារ | ២០០៣ |
| អនុក្រិត្យ ស្តីពីវិទ្យាស្ថានកម្ពុជាគណនេយ្យករសាធារណៈ និងសវនករ | ២០០៣ |
| អនុក្រិត្យស្តីពីការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណនេយ្យជាតិ | ២០០៣ |
| បទបញ្ញត្តិក្រសួងស្តីពីពន្ធលើប្រាក់បៀវត្សរ៍ | ២០០៣ |
| ច្បាប់ស្តីពីគណនេយ្យ សវនកម្មក្រុមហ៊ុន និងអាជីពខាងគណនេយ្យ | ២០០២ |
| ច្បាប់ស្តីពីសវនកម្មលើអង្គភាពរបស់រដ្ឋាភិបាល | ២០០០ |
| អនុក្រិត្យ ស្តីពីអាករលើតម្លៃបន្ថែម | មិនដឹង |
| បទបញ្ញត្តិក្រសួងស្តីពីពន្ធលើប្រាក់ចំណូល | មិនដឹង |
| ច្បាប់ស្តីពីពន្ធដារ | ១៩៩៧ |
| សារាចរ លេខ៦៣៥ ស្តីពីការចេញវិញ្ញាបនប័ត្របញ្ជាក់លើគណនីធុរកិច្ច | ១៩៩៤ |
| បទបញ្ញត្តិក្រសួង លេខ១៨ ស្តីពីការកំណត់ឱ្យធុរកិច្ចបង់ពន្ធលើប្រាក់ចំណេញ និងប្រាក់ចំណូល | ១៩៩៤ |
| ច្បាប់ស្តីពីគណនេយ្យ | ១៩៩២ |
| ***ធនាគារ និងហិរញ្ញវត្ថុ*** | |
| ច្បាប់ស្តីពីផលប័ត្ររដ្ឋាភិបាល | កំពុងរៀបចំ |
| ច្បាប់ស្តីពីផលប័ត្រ និងការដោះដូរ | កំពុងរៀបចំ |
| ច្បាប់ស្តីពីការធានារ៉ាប់រង | ២០០០ |
| បទបញ្ញត្តិក្រសួងស្តីពីការចេញអាជ្ញាប័ណ្ណធនាគារ | ២០០០ |
| បទបញ្ញត្តិក្រសួងស្តីពីការកែរចនាសម្ព័ន្ធចាត់តាំងធនាគារពាណិជ្ជក្រៅប្រទេសកម្ពុជា (FTRC) | ១៩៩៩ |
| ច្បាប់ស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុ | ១៩៩៩ |
| ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនគារជាតិកម្ពុជា | ១៩៩៦ |
| ***ពាណិជ្ជកម្ម*** | |
| ច្បាប់ស្តីពីវិធាននៃប្រភពដើម (Law on Rules of Origin) | កំពុងរៀបចំ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ច្បាប់ស្តីពីគយ | ពង្រាង |
| បទបញ្ញត្តិក្រសួងលេខ ៦០៧ ( ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ស្តីពីការបង្កើត និងការដាក់-ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋករ | ខែសីហា ឆ្នាំ២០០៦ |
| អនុក្រិត្យ ស្តីពីការគ្រប់គ្រងហានិភ័យ | ខែមីនា ឆ្នាំ២០០៦ |
| អនុស្សរណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ផ្ញើទៅកាន់ GMAC ( ដោយលុបចោលវិញ្ញាបនបត្របញ្ជាក់ពីការកែច្នៃ) | ២០០៥ |
| ច្បាប់ស្តីពីការចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោក (WTO) | ២០០៤ |
| បទបញ្ញត្តិក្រសួងស្តីពីការអនុវត្តសេវាកម្មអធិការកិច្ចលើទំនិញមុនពេលដឹកជញ្ជូន | ២០០០ |
| បទបញ្ញត្តិស្តីពីការអនុវត្តសេវាកម្មអធិការកិច្ចលើទំនិញមុនពេលដឹកជញ្ជូន ( ភ្ជាប់ជាមួយនឹងបទបញ្ញត្តិក្រសួងខាងលើ) | ២០០០ |
| បទបញ្ញត្តិក្រសួងស្តីពីសកម្មភាពពាណិជ្ជរបស់ក្រុមហ៊ុនពាណិជ្ជកម្ម | ២០០០ |
| បទបញ្ញត្តិក្រសួងដែលធ្វើវិសោធនកម្ម និងបំពេញបន្ថែមលើការចេញវិញ្ញាបនប័ត្រប្រភពដើម វិក្កយប័ត្រ និងពិព័រណ៍ពាណិជ្ជកម្ម | ១៩៩៩ |
| បទបញ្ញត្តិក្រសួងស្តីពីការចេញវិញ្ញាបនប័ត្រប្រភពដើម វិក្កយប័ត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណ តាំងពិព័រណ៍សម្រាប់រោងចក្រកាត់ដេរ | ១៩៩៩ |
| សេចក្តីសម្រេចលេខ ១១២ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំ និង ចាត់ចែងនីតិវិធី និងបទបញ្ញត្តិនីហរណកម្ម និងអាហរណកម្ម | ១៩៩៤ |
| ច្បាប់ដែលដាក់កម្រិតពន្ធគយលើទំនិញដែលនាំចេញ និងនាំចូល | ១៩៨៩ |
| ***ការងារ*** | |
| ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីការងារ | ពង្រាង |
| ច្បាប់ស្តីពីការងារ (វិសោធនកម្ម) | ១៩៩៧ |
| អនុក្រិត្យ ស្តីពីការនាំចេញពលករកម្ពុជាទៅធ្វើការនៅបរទេស | ១៩៩៥ |
| ច្បាប់ស្តីពីការងារ | ១៩៩៣ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ***សិទ្ធិបញ្ញា*** | |
| ច្បាប់ស្តីពីការការពារប្លង់គំនូសព្រាងទីតាំង (Layout Design) នៃ IC | កំពុងរៀបចំ |
| ច្បាប់ស្តីពីព័ត៌មានមិនផ្សាយចេញ | កំពុងរៀបចំ |
| អនុក្រឹត្យ លេខ៦៤ (រាជរដ្ឋាភិបាលកម្ពុជា) ស្តីពីការអនុវត្តច្បាប់ទាក់ទិននឹងម៉ាក ឈ្មោះ- យីហោ និងអំពើនៃការប្រកួតប្រជែងមិនត្រឹមត្រូវ | ខែកក្កដា ឆ្នាំ២០០៦ |
| ច្បាប់ស្តីពីរក្សាសិទ្ធិ និងសិទ្ធិដែលពាក់ព័ន្ធ | ២០០៣ |
| ច្បាប់ស្តីពីប័ណ្ណប៉ាតង់ វិញ្ញាបនប័ត្រទម្រង់គំរូផលប្រយោជន៍ (Utility Model Certificates) និងប្លង់រចនាឧស្សាហកម្ម (Industrial Design) | ២០០៣ |
| ច្បាប់ស្តីពីម៉ាក ឈ្មោះយីហោ និងអំពើនៃការប្រកួតប្រជែងមិនត្រឹមត្រូវ | ២០០២ |
| បទបញ្ញត្តិក្រសួងស្តីពីនីតិវិធីរបស់នាយកដ្ឋានទ្រព្យសម្បត្តិបញ្ញា | ១៩៩៧ |
| ***ហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន និងដីធ្លី*** | |
| ច្បាប់ស្តីពីការដឹកជញ្ជូនរបស់ពាណិជ្ជករ | កំពុងរៀបចំ |
| ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹក | កំពុងរៀបចំ |
| ច្បាប់ស្តីពីការចង្អុលបង្ហាញទីតាំងភូមិសាស្ត្រ | កំពុងរៀបចំ |
| ច្បាប់ស្តីពីសម្បទាន | ពង្រាង |
| អនុក្រឹត្យស្តីពីការអនុវត្តច្បាប់សម្បទាន | ពង្រាង |
| ច្បាប់ស្តីពីអាកាសចរស៊ីវិល | ពង្រាង |
| ក្រមផ្លូវហាយវេ (Highway Code) | ពង្រាង |
| ច្បាប់ស្តីពីទូរគមនាគមន៍ | ពង្រាង |
| អនុក្រឹត្យស្តីពីការគ្រប់គ្រងដីធ្លីរដ្ឋ | ២០០៥ |
| សេចក្តីណែនាំបង្ហាញអំពីនីតិវិធីសវនការរបស់គណៈកម្មការសុរិយោដីជាតិ | ២០០៥ |
| បទបញ្ញត្តិក្រសួងស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី | ២០០២ |
| អនុក្រឹត្យ លេខ៤៨ ស្តីពីការចុះបញ្ជីដីធ្លីយូរៗម្តង | ២០០២ |
| អនុក្រឹត្យ លេខ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី | ២០០២ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| អនុក្រិត្យ លេខ៤៦ ស្តីពីនីតិវិធីបង្កើតផែនទីសន្ទស្សន៍សុរិយោដី និងបញ្ជីដីធ្លី | ២០០២ |
| អនុក្រិត្យ លេខ១៣១ ស្តីពីការកំណត់តម្លៃអាជ្ញាប័ណ្ណអតិបរមា ទៅឱ្យអ្នកផ្តល់សេវាកម្ម ថាមពលអគ្គិសនីនៅក្នុងប្រទេសកម្ពុជា | ២០០១ |
| ច្បាប់ស្តីពីដីធ្លី | ២០០១ |
| ច្បាប់ស្តីពីអគ្គិសនី | ២០០១ |
| អនុក្រិត្យស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើ | ២០០០ |
| អនុក្រិត្យ លេខ១១ ស្តីពីកិច្ចសន្យាបែបស្ថាបនា-ប្រតិបត្តិ-ផ្ទេរ (BOT) | ១៩៩៨ |
| ច្បាប់ស្តីពីផែនការប្រើប្រាស់ដីធ្លី នគរូបនីយកម្ម និងសំណង់ | ១៩៩៤ |
| សេចក្តីសម្រេចលេខ ៣៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការរៀបចំផែនការដីធ្លី និងនគរូបនីយកម្ម លើតំបន់នានានៅជុំវិញភ្នំពេញ ក្រុង និងខេត្តនានា | ១៩៩៣ |
| ***ទេសចរណ៍*** | |
| ច្បាប់ស្តីពីការទប់ស្កាត់ល្បែងស៊ីសង | ១៩៩៦ |
| ច្បាប់ស្តីពីការការពារមរតកវប្បធម៌ | ១៩៩៦ |
| ***កសិកម្ម បរិស្ថាន*** | |
| ច្បាប់ស្តីពីការគ្រប់គ្រងធនធានមនុស្ស | កំពុងរៀបចំ |
| ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីព្រៃឈើ | ពង្រាង |
| ច្បាប់ស្តីពីជលផល | ពង្រាង |
| ច្បាប់ស្តីពីរុក្ខាប្រមាញ់ | ២០០២ |
| អនុក្រិត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង | ២០០០ |
| អនុក្រិត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក | ១៩៩៩ |
| អនុក្រិត្យស្តីពីការគ្រប់គ្រងកាកសំណល់ឬង | ១៩៩៩ |
| ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (LEPNRM) | ១៩៩៧ |
| អនុក្រិត្យស្តីពីការប្រគល់សិទ្ធិលក់និងនាំចេញផលិតផលកៅស៊ូ ទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៩៩៤ |

| ច្បាប់ និងបទបញ្ញត្តិនានា | ឆ្នាំអនុម័ត, ស្ថានភាពបច្ចុប្បន្ន |
|---|---|
| អនុក្រិត្យស្តីពីការបង្កើតគណៈកម្មការអចិន្ត្រៃយ៍ជាតិ សម្រាប់សម្របសម្រួលឯកជនូបនីយកម្ម និងការជំរុញចំការកៅស៊ូ | ១៩៩៤ |
| សេចក្តីសម្រេចលេខ ៦៥ ស្តីពីការចាត់ទុកជាមោឃៈនូវនីតិវិធីដែលមានស្រាប់ សម្រាប់ការនាំចេញឈើហ៊ុប | ១៩៩៤ |
| ព្រះរាជក្រិត្យស្តីពីការការពារតំបន់ធម្មជាតិ | ១៩៩៣ |
| ***សង្គម*** | |
| **ច្បាប់ស្តីពីសញ្ជាតិ** | **១៩៩៦** |
| ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរ និងកេងប្រវ័ញ្ច (សម្រាប់ការពារក្រុមដែលងាយរងគ្រោះនានា) | ១៩៩៦ |
| ច្បាប់ស្តីពីសារព័ត៌មាន | ១៩៩៥ |
| ច្បាប់ស្តីពីអន្តោប្រវេសន៍ | ១៩៩៤ |
| ច្បាប់នីតិវិធីព្រហ្មទណ្ឌ | ១៩៩៣ |
| ច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនិងតុលាការ ដែលអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជា (ដែលអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) | ១៩៩២ |

កំណត់សម្គាល់ទី ១ : "កំពុងរៀបចំ" : កំពុងត្រូវបានធ្វើពង្រាងនៅថ្នាក់ក្រសួង

កំណត់សម្គាល់ទី ២ : "ពង្រាង" : បានបញ្ជូនទៅរដ្ឋសភាជាតិ ដើម្បីអនុម័តិ ឬមួយទៅកាន់កិច្ចប្រជុំគណៈរដ្ឋមន្ត្រី ដើម្បីបញ្ចប់ជាពង្រាងច្បាប់ មុននឹងត្រូវបានបញ្ជូនទៅរដ្ឋសភាជាតិ

ប្រភព : ក្រុមសិក្សារបស់ JICA

### ១០.១.៣ ច្បាប់ស្តីពីការវិនិយោគ

#### (១). ស្ថានភាពបច្ចុប្បន្ននៃច្បាប់វិនិយោគនៅកម្ពុជា

#### (i) បរិយាកាសវិនិយោគបើកចំហរ

បច្ចុប្បន្ននេះ ពុំមានច្បាប់ ឬបទបញ្ញត្តិស្តីពីការវិនិយោគ ដើម្បីអនុវត្ត សម្រាប់តែការវិនិយោគបរទេសផ្ទាល់នៅឡើយទេ។ បរិយាកាសវិនិយោគនៅកម្ពុជាបើកចំហរបែបនេះ ប្រសិនបើវិនិយោគិន មិនស្វែងរកការលើកទឹកចិត្តដែលផ្តល់ឱ្យក្រោមច្បាប់វិនិយោគទេនោះ ដោយសាមញ្ញពួកគេអាចចុះបញ្ជីឯកសារ អាជីវកម្មនៅក្រសួងពាណិជ្ជកម្ម បង្កើតក្រុមហ៊ុន

និងដាក់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិ។ ម្យ៉ាងវិញទៀត ប្រសិនបើវិនិយោគិនស្វែងរកការលើកទឹកចិត្តដែលផ្តល់ឱ្យក្រោមច្បាប់វិនិយោគនោះ ពួកគេត្រូវតែទទួលអាជ្ញាប័ណ្ណ (វិញ្ញាបនប័ត្រចុះបញ្ជីវិនិយោគ) សម្រាប់គម្រោងដែលទទួលយកបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**(ii) ច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤**

ច្បាប់ស្តីពីវិនិយោគឆ្នាំ ១៩៩៤ គ្របដណ្តប់រាល់គម្រោងវិនិយោគវិស័យឯកជនទាំងក្នុងស្រុកនិងក្រៅស្រុក ដែលស្នើឱ្យមានការលើកទឹកចិត្តសម្រាប់វិនិយោគ។ ការលើកទឹកចិត្តសម្រាប់វិនិយោគដែលផ្តល់ឱ្យក្រោមច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ គឺសប្បុរសណាស់ ប៉ុន្តែរបាយការណ៍របស់ ICS ដែលរៀបរៀងក្រោមក្របខ័ណ្ឌចំរុះ ដោយ WTO, World Bank, ITC, UNCTAD, IMF និង UNDP បានគូសបញ្ជាក់ថា "ក្រុមហ៊ុនភាគច្រើន ដែលបានអនុម័តដោយច្បាប់ស្តីពីការវិនិយោគនៅកម្ពុជា មិនត្រូវបានផ្តល់នូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញទេ ហើយចំពោះក្រុមហ៊ុនដែលបំរើអោយទីផ្សារក្នុងស្រុក ដែលបាន អនុម័តក្រោមច្បាប់ស្តីពីការវិនិយោគនៅកម្ពុជានេះដែរ ក៏មិនបានទទួលការអនុញ្ញាតិអោយនាំចូលដោយរួចពន្ធគយ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់ឆ្នាំទី១ នៃប្រតិបត្តិការរបស់ខ្លួនដែរ, ការសំរេចចិត្ត លើការអនុម័តគំរោងវិនិយោគ និងការផ្តល់ការលើកទឹកចិត្តមានទំនោរទៅរកការនិយាយដោយ ប្រុងប្រយ័ត្ន ដែលនាំឱ្យមានការចំណាយប្រតិបត្តិការ"លាក់កំបាំង" ហើយរដ្ឋាភិបាលជ្រើសរើសយក "ច្បាប់ល្បែង" (Rule of the Game) និងយកថ្លៃបន្ថែមទៀតទៅលើ ធុរកិច្ច តាមរយៈការចេញប្រកាស (បទបញ្ជាក្រសួង)។

**(iii) វិសោធនកម្មលើច្បាប់ស្តីពីវិនិយោគឆ្នាំ ១៩៩៤**

នៅក្នុងកាលៈទេសៈបែបនេះហើយ ទើបច្បាប់វិនិយោគឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្ម កាលពីថ្ងៃ ទី៣ ខែកុម្ភៈ ឆ្នាំ២០០៣។ ការធ្វើវិសោធនកម្មនេះមានគោលដៅឱ្យមានដំណើរការអនុម័តិចំពោះការវិនិយោគ និងការផ្តល់ការលើកទឹកចិត្ត ដោយមានគោលការណ៍កាន់តែសាមញ្ញ អាចទស្សន៍ទាយបាន និងមិនអាចិកំបាំង ពីព្រោះគេធ្លាប់រំពឹងថាប្រព័ន្ធដែលអាចទស្សន៍ទាយបាន មិនអាចិកំបាំង និងមានតម្លាភាព នឹងដំណើរការក្នុងការដាក់កម្រិតចំពោះការជ្រៀតជ្រែកបែបការិយាធិបតេយ្យរបស់មន្ត្រីរដ្ឋាភិបាល និងក្នុងការកាត់បន្ថយឱកាសនៃការចំណាយក្រៅផ្លូវការ។

**(iv) ចំណុចសំខាន់ៗនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ**

"ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ" នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៣ គឺធ្វើឡើងដើម្បីដាក់ចេញនូវប្រព័ន្ធអនុម័តដោយស្វ័យប្រវត្តិចំពោះគម្រោងវិនិយោគនានា ដែលត្រូវតែត្រូវបានបញ្ចប់ឱ្យរួចរាល់ក្នុងរយៈពេល ៣១ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណុំបំពេញវិនិយោគ លុំកណាគម្រោងនោះមិនស្ថិតនៅក្នុងចំណោមវិស័យដែលហាមឃាត់ ឬដាក់កម្រិតចំពោះដើមទុនឯកជន។ គេរំពឹងថា ក.អ.ក នឹងដើរតួនាទីជាច្រកចេញ-ចូលតែមួយ និងទទួលបានរាល់អាជ្ញាប័ណ្ណចាំបាច់ទាំងអស់ ដែលតម្រូវសម្រាប់ការវិនិយោគជួសមុខឱ្យអ្នកដាក់ពាក្យសុំ

វិនិយោគ។ អាជ្ញាប័ណ្ណ ឬការយល់ព្រមចំពោះការវិនិយោគមួយ នឹងត្រូវចេញមិនត្រឹមតែជូនចំពោះវិនិយោគិន ឬសហគ្រាសវិនិយោគប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគម្រោងវិនិយោគផងដែរ។

"អនុក្រិត្យលេខ ១១១ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ" ក៏ត្រូវបានចេញកាលពីថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៥ ផងដែរ។

ចំណុចសំខាន់ៗនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ គឺមានដូចខាងក្រោម :

(i) ការប្រើប្រាស់ច្បាប់ : ដើម្បីគ្រប់គ្រងរាល់គម្រោងវិនិយោគដែលមានគុណសម្បត្តិ "គ.ល.គ"សម្រាប់កំណត់នីតិវិធីដោយបុគ្គលណាមួយដែលបង្កើត"គ.ល.គ"មួយ

(ii) គម្រោងវិនិយោគតិចជាង២លានដុល្លារអាមេរិក : នឹងតម្រូវឱ្យចុះបញ្ជីសំណើវិនិយោគជាមួយអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង "អ.គ.វ.ខ-ក" យោងតាម "អនុក្រិត្យលេខ ១៧ អនក្រ/បក ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង" ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៥

(iii) "គ.ល.គ": "គ.ល.គ" គឺជាគម្រោងវិនិយោគមួយ ដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ (FRC-Final Registration Certificate)

(iv) ដំណើរការដាក់ពាក្យសុំវិនិយោគ : ដំណើរការ និងរយៈពេលចាប់ពីដាក់ជូនសំណើវិនិយោគ រហូតដល់ទទួលបាន FRC ត្រូវបានបង្ហាញ នៅក្នុងតារាង ១០-១-៤។

**តារាង ១០-១-៤ ដំណើរការ និងរយៈពេល ចាប់ពីដាក់សំណើវិនិយោគ រហូតដល់ទទួលបាន** FRC

| ដំណើការ | លក្ខខណ្ឌ/អ្វីៗដែលតម្រូវឱ្យមាន | រយៈពេល |
|---|---|---|
| ដាក់ជូនសំណើវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ "អ.គ.វ.ខ-ក" | បង់ថ្លៃដាក់ពាក្យសុំចំនួន៧លានរៀល | គ្មាន |
| ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ពី ក.អ.ក ឬ "អ.គ.វ.ខ-ក" | សំណើមានរាល់ព័ត៌មានទាំងអស់ដែលត្រូវការ។ សំណើនេះមិនត្រូវបានធ្វើឡើង ដោយពាក់ព័ន្ធនឹងសកម្មភាពដែលរាប់បញ្ចូលក្នុងបញ្ជីអវិជ្ជមាន ឬដែលធ្លាប់ពីមុនមក ឬដែលបច្ចុប្បន្ននេះត្រូវបានអនុវត្តដោយវិនិយោគិន ឬបុគ្គលណាផ្សេងទៀត និងដែលបានទទួលការលើកទឹកចិត្ត | រយៈពេល៣ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីដាក់សំណើវិនិយោគជូនទៅ ក.អ.ក ឬ "អ.គ.វ.ខ-ក" |
| ទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការអនុម័ត ការផ្តល់សិទ្ធិអំណាច ការជម្រះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬការចុះបញ្ជីពី | បំពេញបានតាមលក្ខខណ្ឌ ឬតម្រូវការ សម្រាប់ការអនុម័ត ការផ្តល់សិទ្ធិអំណាច ការជម្រះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬការចុះបញ្ជី | រយៈពេល ២៨ ថ្ងៃ (ថ្ងៃធ្វើការ) គិតចាប់ពីថ្ងៃទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីមាន |

| ដំណើការ | លក្ខខណ្ឌ/អ្វីៗដែលតម្រូវឱ្យមាន | រយៈពេល |
|---|---|---|
| បណ្តាក្រសួង ឬអាជ្ញាធរដែលពាក់ព័ន្ធ | | លក្ខខណ្ឌ |
| ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរពី ក.អ.ក ឬ "អ.គ.វ.ខ-ក" | ទទួលបាននូវរាល់ការអនុម័តិការផ្តល់សិទ្ធិអំណាច ការជម្រះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬការ ចុះ បញ្ជីពីបណ្តាក្រសួង ឬអាជ្ញាធរដែលពាក់ព័ន្ធ | រយៈពេល ២៨ ថ្ងៃ (ថ្ងៃធ្វើ-ការ) គិតចាប់ពីថ្ងៃទទួលបាន វិញ្ញាបនប័ត្រចុះបញ្ជីមាន លក្ខខណ្ឌ |

ប្រភព : "សៀវភៅមគ្គុទ្ទេសន៍អំពីច្បាប់ និងវិនិយោគនៅកម្ពុជា បោះពុម្ពឆ្នាំ ២០០៦" ដោយ Mekong Law Group & "ច្បាប់ និង បទបញ្ញត្តិនានា អំពីការវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា" ដែលបោះពុម្ពផ្សាយ ក្នុងខែធ្នូ ឆ្នាំ២០០៥ ដោយ ក.អ.ក

**(v)** ការលើកទឹកចិត្តវិនិយោគ : គ.ល.គ ត្រូវបានទទួលការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម :

- គ.ល.គ អាចនឹងជ្រើសរើសយកការទទួលបានការរួចពន្ធលើប្រាក់ចំណេញ ឬអាចនឹងប្រើប្រាស់ ការដករំលោះពិសេស ។
- ការលើកលែងពន្ធលើប្រាក់ចំណេញ (ដោយជ្រើសរើស) : រយៈពេលរួចពន្ធ រួមមាន "រយៈពេលគន្លឹះ" + ៣ឆ្នាំ + រយៈពេល អាទិភាព :
  - រយៈពេលគន្លឹះអតិបរិមា : គឺជាប្រាក់ចំណេញឆ្នាំទីមួយ ឬរយៈពេលបីឆ្នាំបន្ទាប់ពី "គ.ល.គ" រកចំណូលបានជាលើកទី១ មួយណាក៏បានដែលឆាប់រហ័សជាង
  - រយៈពេលអាទិភាព : ត្រូវបានកំណត់ដោយច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ
  - គ.ល.គ ត្រូវតែទទួលបានវិញ្ញាបនប័ត្របំពេញកាតព្វកិច្ចប្រចាំឆ្នាំមួយ ដើម្បីឱ្យមានសិទ្ធិទទួលបាន "ការលើកលែងពន្ធលើប្រាក់ចំណេញ" ។
- ការដករំលោះពិសេស (ដោយជ្រើសរើស) : ប្រាក់ឧបត្ថម្ភសំរាប់ការដករំលោះពិសេសចំនួន ៤០% នៃតម្លៃអចលនទ្រព្យរូបិយថ្មី ឬដែលប្រើរួច នៅក្នុងផលិតកម្ម ឬលំនាំកែច្នៃ។
- ការនាំចូលបរិក្ខាផលិតកម្ម និងសម្ភារៈសំណង់ដោយមិនបង់ពន្ធគយ : ចំពោះ គ.ល.គ ក្នុងស្រុក គ.ល.គ ដែលមានបំណងនាំចេញ និង គ.ល.គ ខាងឧស្សាហកម្មគាំទ្រ
- ការនាំចូលដោយមិនបង់ពន្ធគយនូវវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងឧបករណ៍ប្រើប្រាស់បន្ថែម សម្រាប់ផលិតកម្ម : ចំពោះ គ.ល.ព ដែលមានបំណងនាំចេញ និង គ.ល.គ ខាងឧស្សាហកម្មគាំទ្រ
- គ.ល.គ មួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ជំរុញពិសេស "ត.ជ.ព" ឬ តំបន់កែច្នៃនាំចេញ "ត.ក.ច" : ទទួលបាននូវការលើកទឹកចិត្ត និងបុព្វសិទ្ធិដូចគ្នានឹង គ.ល.គ ផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ស្តីពីវិសោធន

កម្មច្បាប់ស្តីពីវិនិយោគ

- ការធានាចំពោះការវិនិយោគ
- ភាពមានសិទ្ធិទទួលបានការលើកទឹកចិត្តវិនិយោគ : បណ្តាគម្រោងវិនិយោគដែលមានចុះក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រិត្យលេខ១១១ មិនមានសិទ្ធិទទួលបានការលើកទឹកចិត្តវិនិយោគទេ។

(vi) ការបានមក និងការរួមបញ្ចូលគ្នា : បណ្តាសិទ្ធិ បុព្វសិទ្ធិ និងសិទ្ធិទទួលបាននានា នៃ គ.ល.ព អាចត្រូវបានផ្ទេរ ឬប្រគល់ទៅឱ្យបុគ្គលម្នាក់ដែលទទួលបាន ឬបញ្ចូលគ្នានូវ គ.ល.គ មួយ ដែលត្រូវតែ យល់ព្រមសិនពី ក.អ.ក ឬ "អ.គ.វ.ខ-ក" ។

(vii) ការប្រើប្រាស់ដីធ្លី : ការជួលដីដោយមិនកំណត់ ត្រូវបានយល់ព្រម ហើយវិនិយោគិនត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិធ្វើជាម្ចាស់ និងការពារសន្តិសុខនូវអចលនវត្ថុ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនលើដីធ្លីនេះ។

(viii) ការដោះស្រាយជម្លោះ : តួនាទីរបស់ ក.អ.ក ជាអ្នកសម្រុះសម្រួល ត្រូវបានចែងយ៉ាងច្បាស់លាស់ ហើយការដោះស្រាយវិវាទដោយមជ្ឈត្តវិនិច្ឆ័យនៅក្នុង ឬក្រៅប្រទេសកម្ពុជា ក្រោមបណ្តាវិធានអន្តរជាតិ ត្រូវបានយកមកប្រើជាវិធានការដោះស្រាយចុងក្រោយ។

**(២) បញ្ហានានានឹងត្រូវដោះស្រាយ ដែលទាក់ទងនឹងច្បាប់វិនិយោគ នៅកម្ពុជា**

គោលបំណងចំបងនៃការធ្វើវិសោធនកម្មច្បាប់វិនិយោគឆ្នាំ១៩៩៤ គឺការវាយតម្លៃឡើងវិញលើការលើកទឹកចិត្តខាងហិរញ្ញវត្ថុ ដោយសារប្រាក់ចំណូលរដ្ឋាភិបាលកើនឡើង ការណែនាំឱ្យស្គាល់នូវដំណើរការនៃការយល់ព្រមចំពោះការវិនិយោគ និងការលើកទឹកចិត្ត ដែលមានតម្លាភាព អាចទស្សន៍ទាយបាន និងមិនអាចិកំបាំង។ ហេតុដូច្នេះហើយបានជាពេលដែលគំនិតចង់ឱ្យមានការលើកទឹកចិត្តត្រូវបានបញ្ចេញជាទូទៅនោះ គេក៏ កំណត់រយៈពេលចំពោះជំហាននីមួយៗក្នុងដំណើរការអនុម័តការវិនិយោគ ដូចដែលបានបង្ហាញនៅក្នុងតារាង ១០-១-៤ ហើយវិធីសាស្ត្រគណនាការលើកទឹកចិត្តដោយស្វ័យប្រវត្តិ ត្រូវបានយកមកប្រើ។ ផ្ទុយទៅនឹងគោលបំណងរបស់ខ្លួន នៅតែមានបញ្ហាមួយចំនួន ដែលទាក់ទិននឹងការអនុវត្តច្បាប់ ដូចបង្ហាញខាងក្រោម :

១) វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

យោងតាមច្បាប់វិនិយោគ វិញ្ញាបនប័ត្រចុះបញ្ជីចុងក្រោយចំពោះសំណើវិនិយោគត្រូវតែចេញនៅក្នុងរយៈពេល ២៨ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ។ ប៉ុន្តែតាមការពិត រដ្ឋាភិបាលធ្លាប់មិនបានធ្វើដូច្នេះនៅពេលខ្លះ ឬមិនបានអនុញ្ញាតឱ្យមានការចុះបញ្ជីសំណើវិនិយោគដោយស្វ័យប្រវត្តិឡើយ បើទោះជារយៈពេល២៨ថ្ងៃដែលកំណត់ក្នុងច្បាប់ កន្លងផុតក៏ដោយ។ ហេតុផលចំបងដែលនាំឱ្យមានការពន្យាពេលចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនេះ គឺថាមានតែប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាប៉ុណ្ណោះ ដែលមានសិទ្ធិចុះហត្ថលេខាទទួលស្គាល់ការចុះបញ្ជីបែបនេះ

ហើយនៅពេលដែលប្រធាន ក.អ.ក គឺជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានភារកិច្ចជាច្រើន និងការងារជាប្រចាំទៀតនោះ ដូច្នេះពេលខ្លះ សម្តេចក៏មិនអាចបំពេញតម្រូវការទាំងនេះទាន់ពេលវេលាទេ។ សព្វថ្ងៃនេះ អនុប្រធាន ក.អ.ក ក៏មានសិទ្ធិចុះហត្ថលេខាផងដែរ ហើយភាគច្រើននៃវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរសម្រាប់គម្រោងវិនិយោគធម្មតាៗ ត្រូវតែចេញនៅក្នុងរយៈពេល ២៨ថ្ងៃ (ថ្ងៃធ្វើការ) (ក្នុងករណីជាច្រើន តែពី១៥ ទៅ២០ថ្ងៃ)។ ទោះជាយ៉ាងណាក៏ដោយគម្រោងវិនិយោគខ្លះ ដូចបានកំណត់ត្រង់មាត្រា ៦.១(ឃ) នៃ"អនុក្រឹត្យលេខ១១១អនក្រ/បក ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ" មិនត្រូវបានរាប់បញ្ចូលទៅក្នុងខចែងរយៈពេល៣ថ្ងៃ សម្រាប់ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីតាមលក្ខខណ្ឌទេ ដូច្នេះហើយវាចេញពីខចែងរយៈពេល ២៨ថ្ងៃ សម្រាប់ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរ។ ព្រោះតែមាត្រាទី៧ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ មិនបានចែងពីអត្ថិភាពនៃការមិន រាប់បញ្ចូលបែបនេះ គេផ្តល់អនុសាសន៍ឱ្យធ្វើការកែប្រែទៅលើបញ្ញត្តិដែលពាក់ព័ន្ធនៃច្បាប់វិនិយោគ ដើម្បីធ្វើឱ្យកាន់តែច្បាស់លាស់ទៅលើលក្ខខណ្ឌយល់ព្រមចំពោះការចុះបញ្ជីវិនិយោគជាស្ថាបពរ។

**២) ការរួចពន្ធនាំចូលលើវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងឧបករណ៍ប្រើប្រាស់បន្ថែមសម្រាប់ផលិតកម្ម**

ដោយគិតថា ទីផ្សារក្នុងស្រុកនៅកម្ពុជាមានទំហំតូច ហើយមិនមានឧស្សាហកម្មជាដុំកំភួនច្រើន ដែលអាចនឹងរងផលប៉ះពាល់ពីទំនិញនាំចូលនោះ គេអាចធ្វើឱ្យមានលក្ខណៈសាមញ្ញចំពោះវិធីសាស្ត្រត្រួតពិនិត្យលើការយល់ព្រមចំពោះការនាំចូលដោយរដ្ឋជាអ្នកទទួលបន្ទុកពន្ធនូវវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងឧបករណ៍ប្រើប្រាស់បន្ថែមសម្រាប់ផលិតកម្ម។ យ៉ាងហោចណាស់ ក៏គេអាចឈប់លែងប្រើបញ្ជីមេ (master list) នៅ ពេលដែលគេដាក់ឱ្យប្រតិបត្តិនូវ ASYCUDA ។

**៣) ការលើកទឹកចិត្តសម្រាប់បណ្តាតំបន់**

ច្បាប់វិសោធនកម្មចែងថា គ.ល.ព មួយដែលមានទីតាំងស្ថិតនៅក្នុង SPZ ឬ EPZ មានសិទ្ធិទទួលបានការលើកទឹកចិត្ត និងបុព្វសិទ្ធិដូចគ្នានឹង គ.ល.ព ផ្សេងៗទៀត ដែលបានចែងនៅក្នុងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគផងដែរ។ ប្រសិនបើពុំមានការលើកទឹកចិត្តជាបន្ថែម ឬជាពិសេស សម្រាប់តំបន់ជំរុញពិសេស (SPZ) ឬ EPZ ទេនោះ ក៏នឹងពុំមានគម្រោងវិនិយោគពីបរទេសដោយផ្ទាល់ជាដុំកំភួនច្រើន មកដាក់ទីតាំង នៅក្នុង SPZ ឬ EPZ នោះដែរ។

**៤) ការលើកទឹកចិត្តជាទូទៅ**

យោងវិសោធនកម្មច្បាប់វិនិយោគឆ្នាំ ១៩៩៤ ខ្លះបានបង្ហាញថា វិនិយោគិនអន្តរជាតិសង្កត់ធ្ងន់ថែមទៀតទៅលើទិដ្ឋភាពមិនមែនហិរញ្ញវត្ថុនៃបរិយាកាសវិនិយោគ និងការលើកចិត្តទាំងមូល ជាជាងការលើកទឹកចិត្តខាងហិរញ្ញវត្ថុនៅពេលដែលពួកគេជ្រើសរើសទីតាំងវិនិយោគ។ ទុកបីជាដូច្នេះក៏ដោយ ក៏ការលើកទឹកចិត្ត មិនមែនហិរញ្ញវត្ថុបែបនេះ ដែលជាដំណើរការសាមញ្ញ អាចទស្សន៍ទាយបាន និងមិនអាចិកំបាំង ក្នុងការយល់ព្រមចំពោះវិនិយោគ និងក្នុងការផ្តល់ការ

លើកទឹកចិត្ត ហើយនិងការអនុវត្តដោយតម្លាភាពនូវការចេញអាជ្ញាប័ណ្ណ ការជម្រះបញ្ជីពន្ធដារឬពន្ធគយ នឹងមិនគ្រប់គ្រាន់ក្នុងការជំរុញ FDI ដើម្បីឱ្យជួយដល់ឧស្សាហូបនីយកម្មរបស់ប្រទេសនេះឡើយ។ ដើម្បីប្រើប្រាស់ FDI ជាគោលបំណងសម្រាប់ឧស្សាហូបនីយកម្មរបស់ប្រទេសនេះ គេអាចស្វែងរកការលើកទឹកចិត្តផ្សេងៗទៀត ដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម (SME), ការធ្វើហិរញ្ញប្បទានដល់ SME, ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជំរុញពាណិជ្ជកម្ម, ការបង្កើនជំនាញ គ្រប់គ្រង ជាដើម ហើយដែលទាំងនេះត្រូវបានបញ្ចូលទៅក្នុងវិសោធនកម្មច្បាប់វិនិយោគ។

**៥) ទំនាក់ទំនងរវាងច្បាប់ស្តីពីវិនិយោគ និងបទប្បញ្ញត្តិពាក់ព័ន្ធ**

"អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចេញនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៥ ដើម្បីបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្តក្រុង ដែលជាអ្នកដោះស្រាយការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីៗជា គ.ល.ព មួយ ដែលមានដើមទុនវិនិយោគដែលមានបរិមាណតិចជាង ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក។ ម្យ៉ាងវិញទៀត មាត្រាទី៦នៃច្បាប់ស្តីពីវិនិយោគ ចែងថាបុគ្គល ទាំងអស់ដែលមានបំណងបង្កើត គ.ល.ព ត្រូវដាក់សំណើវិនិយោគទៅ ក.អ.ក តាមសំណុំបែបបទនិងយោងទៅតាមនីតិវិធីនៃច្បាប់នេះនិងអនុក្រឹត្យនេះ។ ព្រោះតែ គ.ល.ព មិនមែនជាផ្នែកមួយនៃ ក.អ.ក នោះ ខចែងដែលពាក់ព័ន្ធនៃច្បាប់ស្តីពីវិនិយោគនេះ ត្រូវតែត្រូវបានកែប្រែដើម្បីផ្តល់សិទ្ធិអំណាចដល់ "អ.គ.វ.ខ-ក"។

"អនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស (ត.ព.ស)" ក៏ត្រូវបានចេញផងដែរ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ សម្រាប់បង្កើត "ត.ព.ស"នៅក្នុងប្រទេសកម្ពុជា និងគ្រប់គ្រងលើ "ត.ព.ស"។ នៅក្រោមអនុក្រឹត្យ "ត.ព.ស" នេះ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា "គ.ស.ព" ត្រូវបានបង្កើតឡើងជាផ្នែកទី៣ នៃ ក.អ.ក។ បណ្តាខចែងដែលពាក់ព័ន្ធនៃច្បាប់វិនិយោគនេះត្រូវតែត្រូវបានកែប្រែ ព្រោះថា "គ.ស.ព" ត្រូវបាន អនុញ្ញាតឱ្យដោះស្រាយចំពោះការដាក់ពាក្យសុំចុះបញ្ជីវិនិយោគ និងការចេញវិញ្ញាបនប័ត្រចុះបញ្ជីនៅក្នុង "ត.ព.ស" តាមរយៈសាខារបស់វា "រដ្ឋបាលតំបន់"។

**(៣). អនុសាសន៍សម្រាប់កែលំអនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ**

ដោយទាក់ទិននឹងការចេញអនុក្រិត្យ "អ.គ.វ.ខ-ក" "អនុក្រិត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មលើច្បាប់វិនិយោគ (អនុក្រិត្យអនុវត្តន៍ច្បាប់វិនិយោគ)" នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ និងអនុក្រិត្យ "ត.ព.ស" នោះ ច្បាប់វិនិយោគដែលត្រូវបានធ្វើវិសោធនកម្មនេះ តម្រូវឱ្យមានវិសោធនកម្មបែបនេះ ដូចបានរៀបរាប់ខាងក្រោម :

- *មាត្រាទី២ "គ.ល.ព ដែលនាំចេញ" : ការបកប្រែត្រឹមត្រូវជាភាសាអង់គ្លេស "* គ.ល.ព *ដែលនាំចេញ មានន័យថា គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលផលិតកម្មរបស់វាត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រិត្យ"។*

- *មាត្រាទី៤ : បន្ថែម "**៣-គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា "គ.ស.៣"** " និងកែប្រែជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិចំនួន**បី** ដូចខាងក្រោម"។*
- *មាត្រាទី៦ : កែប្រែខចែងជា "រាល់បុគ្គលដែលមានបំណងបង្កើត គ.ល.ព ត្រូវដាក់សំណើវិនិយោគនៅ "ក.អ.ក" ឬ* ***ស្ថាប័នតាមការចាត់តាំងរបស់ ក.អ.ក*** *តាមទម្រង់ និងតាមនីតិវិធី ដែលមានចែងក្នុងច្បាប់នេះ និងអនុក្រឹត្យ ។*
- ***មាត្រាទី៧** : បង្កើតប្រការទី២ ជា "ក្រុមប្រឹក្សា ឬ "អ.គ.វ.ខ-ក" មានសិទ្ធិពន្យាការចុះបញ្ជី ក្នុងករណីដែលចែងដោយឡែក នៅក្នុងអនុក្រឹត្យនេះ ហើយក្នុងករណីបែបនេះ ក្រុមប្រឹក្សានេះ ឬ "អ.គ.វ.ខ-ក" ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជាក់ពីហេតុផលជាក់លាក់ ទៅអ្នកដាក់ពាក្យសុំ ក្នុងរយៈពេល ៣ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដាក់សំណើវិនិយោគ"។*
- *មាត្រាទី១៤.៩ : លុបចោល"SPZ ឬ EPZ" ហើយបន្ថែមពាក្យ" តំបន់សេដ្ឋកិច្ចពិសេស (SEZ)" ទៅលើ និងកែប្រែការចែងដែលថា" គ.ល.ព មួយដែលមានទីតាំងនៅក្នុង SEZ ដែលជ្រើសរើស ដែលមានចុះក្នុងបញ្ជីអាទិភាពអភិវឌ្ឍន៍ដែលចេញដោយក្រុមប្រឹក្សានេះ* ***និងអនុម័តក្រោមច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធ****នោះមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តខាងហិរញ្ញវត្ថុ និងបុព្វសិទ្ធិនានា ដូចគ្នានឹង គ.ល.ព ដែលចែងក្នុងច្បាប់នេះផងដែរ។ ការលើកទឹកចិត្ត មិនមែនហិរញ្ញវត្ថុ និងបុព្វសិទ្ធិនានាផ្សេងទៀត សម្រាប់ SEZ ត្រូវបានកំណត់នៅក្នុងច្បាប់ ឬអនុក្រឹត្យដែលចែងអំពី SEZ"។*
- *មាត្រាទី១៤ :បង្កើតកថាខ័ណ្ឌទី១២ ជា "* ***សកម្មភាពវិនិយោគដែលមិនសមស្របចំពោះការលើកទឹកចិត្តខាងលើត្រូវបានកំណត់នៅក្នុងអនុក្រឹត្យ*** *"។*

ដើម្បីខិតខំឱ្យមាន *FDI* កាន់តែច្រើនឡើងៗ នៅក្នុង *SEZ* និងដើម្បីបង្កើតមូលដ្ឋានសម្រាប់ឧស្សាហូបនីយកម្មរបស់ប្រទេស គេចង់ឱ្យមានការផ្តល់នូវលក្ខខណ្ឌអំណោយផលថែមទៀត សម្រាប់ទាក់ទាញ *FDI* ចូលទៅក្នុង *SEZ*។ ការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុដែលអាចនឹងផ្តល់ទៅឱ្យគម្រោងវិនិយោគ នៅក្នុង *SEZ* ត្រូវបានសង្ខេបនៅក្នុងជំពូកបន្ទាប់។

មាត្រាទី៤.៣.៣ នៃអនុក្រិត្យ *SEZ* ចែងថា "រាល់ក្រសួងឬស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ត្រូវផ្ទេរទៅឱ្យអ្នកតំណាងរបស់ខ្លួន (នៅក្នុងរដ្ឋបាលនៃ *SEZ*) នូវអំណាចគ្រប់គ្រាន់ ដើម្បីធ្វើសេចក្តីសម្រេចចិត្តតាងនាម ឱ្យក្រសួងឬស្ថាប័ននោះ ដោយយោងតាមសិទ្ធិអំណាចរៀងៗខ្លួន នៅក្នុងតំបន់។" ហើយអនុក្រិត្យដដែលនេះ ក្រោមមាត្រាទី ៤.៣.៥.គ កំណត់ថាភារកិច្ចមួយក្នុងចំណោមជាច្រើនរបស់រដ្ឋបាល *SEZ* គឺពិនិត្យមើលសំណើវិនិយោគសម្រាប់ការចុះបញ្ជីពិនិត្យលើការលើកទឹកចិត្ត កាចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងវិញ្ញាបនប័ត្រ ប្រភពដើមផលិតផល ដែលស្នើឡើងដោយវិនិយោគិនក្នុងតំបន់ ដើម្បីឱ្យការសម្រេចចិត្តអាចត្រូវបានធ្វើឡើង នៅក្នុងតំបន់សម្រាប់វិនិយោគិនក្នុងតំបន់។ យោងតាម

ខចែងទាំងនេះ មានតែរដ្ឋបាល *SEZ* ប៉ុណ្ណោះ ទទួល និងពិនិត្យមើលសំណើវិនិយោគ ដើម្បីសុំឋានៈនៃ គ.ល.ព និងចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរនៅក្នុង *SEZ*។ បើការនេះ ត្រូវបានអនុញ្ញាត ច្បាប់ស្តីពីវិនិយោគ ដែលបានធ្វើវិសោធនកម្មរួចត្រូវតែត្រូវបានកែប្រែ ដើម្បីបង្កលទ្ធភាពឱ្យមានការផ្ទេរអំណាចបែបនេះ។ នៅក្នុងករណីខ្លះ អនុក្រឹត្យនេះមិនអាចផ្លាស់ប្តូរ កែប្រែ ឬធ្វើវិសោធនកម្មលើ ច្បាប់មួយបានទេ។

### ១០.១.៤ បទបញ្ញត្តិនានាដែលទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេស

#### (១) ស្ថានភាពបច្ចុប្បន្ននៃបទបញ្ញត្តិនានាដែលទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា

ការពិនិត្យមើលលើការនាំយកនូវទស្សនទានអំពីតំបន់ជំរុញសេដ្ឋកិច្ច មកក្នុងប្រទេសកម្ពុជា ត្រូវបានចាប់ផ្តើមមុនគេ នៅក្នុងបណ្តាឆ្នាំនៃទសវត្សរ៍ទី៦០។ ក្នុងរយៈពេល១០ឆ្នាំខ្លះថ្មីៗនេះ ក្រោមឈ្មោះថា តំបន់ជំរុញពិសេស តំបន់កែច្នៃនាំចេញ តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនេះ គេបានត្រិះរិះពិចារណាពី តំបន់ជំរុញខាងសេដ្ឋកិច្ចជាច្រើនប្រភេទផ្សេងៗគ្នា ហើយពង្រាងច្បាប់នីមួយៗក៏ត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមនោះដែរ។ ជាចុងក្រោយ "អនុក្រឹត្យ (លេខ១៤៨ អនក្រ បក) ស្តីពីការបង្កើត និងការគ្រប់គ្រង លើតំបន់សេដ្ឋកិច្ចពិសេស" (នៅទីនេះ ហៅថា" អនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស") ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី និងចេញនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥ រួមជាមួយនិង " អនុក្រិត្យ (លេខ១៤៧ អនក្រ.បក) ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក.អ.ក " ដែលក្រោមអនុក្រឹត្យនេះ គ.ស.ព ត្រូវបានបង្កើតឡើង។ អនុក្រិត្យស្តីពី *SEZ* មានបំណងផ្តល់ឱ្យវិនិយោគិននូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងសម្បទាទ្រទ្រង់នានា និងដើម្បីប្រមូលធនធានដូចជា ទូរគមនាគមន៍ ការផ្គត់ផ្គង់ទឹក និងអគ្គិសនី ក៏ដូចជាសម្បទាទ្រទ្រង់ផ្សេងៗទៀត និងហេដ្ឋារចនាសម្ព័ន្ធច្បាប់និងសង្គម សម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច នៅក្នុងតំបន់ទាំងនេះ។ ហេតុផលចម្បងក្នុងការបង្កើត *SEZ* គឺដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធិភាពទៅនឹងបញ្ហាប្រឈម ឱ្យមានការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជា និង ដើម្បីបង្កើនការអភិវឌ្ឍដែលជំរុញដោយតម្រូវការ ដូចជាការជំរុញការនាំចេញ។

ចំណុចសំខាន់ៗនៃអនុក្រិត្យ (លេខ១៤៨អនក្រ.បក) ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ច ពិសេស (អនុក្រិត្យស្តីពី *SEZ*)" ត្រូវបានសង្ខេប ក្នុងតារាង ១០-១-៥ ខាងក្រោម។

**តារាង ១០-១-៥ ចំណុចសំខាន់ៗនៃអនុក្រិត្យ (លេខ១៤៨) ស្តីពីការបង្កើត និងការគ្រប់គ្រងលើតំបន់សេដ្ឋកិច្ចពិសេស**

| ចំណុចនានា | ការពិពណ៌នា |
|---|---|
| ១. លក្ខខណ្ឌមូលដ្ឋាននៃតំបន់សេដ្ឋកិច្ចពិសេស | ដី ៥០ហិចតា ឬច្រើនជាងនេះ មានរបងព័ទ្ធជុំវិញ (សម្រាប់តំបន់កែច្នៃនាំចេញ និងតំបន់ពាណិជ្ជកម្មសេរីក្នុងតំបន់នីមួយៗ)។ ការគ្រប់គ្រង និងការិយាល័យរដ្ឋបាលតំបន់ រាល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងអស់ត្រូវតែត្រូវបានផ្តល់ឱ្យ។ ប្រព័ន្ធលូ ប្រព័ន្ធប្រើប្រាស់កាកសំណល់ឬឡើងវិញ កន្លែងស្តុកទុកនិង គ្រប់គ្រងកាកសំណល់ឬង វិធានការការពារបរិស្ថានត្រូវតែត្រូវបានបង្កើតឡើង។ |

| ចំណុចនានា | ការពិពណ៌នា |
|---|---|
| ២. នីតិវិធីសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេស | អ្នកអភិវឌ្ឍន៍តំបន់ដាក់សំណើសុំការយល់ព្រមចំពោះការអភិវឌ្ឍន៍ទៅកាន់ គ.ស.ព និងដាក់ពាក្យសុំ គ.ល.គ (គម្រោងវិនិយោគដែលមានគុណសម្បត្តិគ្រប់គ្រាន់)។ តម្លៃដាក់ពាក្យសុំ : ៧លានរៀល។<br>គ.ស.ព ត្រូវឆ្លើយតបការយល់ព្រម ឬបដិសេធនូវសំណើ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី)ថ្ងៃ ធ្វើការទៅកាន់អ្នកអភិវឌ្ឍន៍តំបន់។ អ្នកអភិវឌ្ឍន៍តំបន់ រៀបចំនូវការសិក្សាលំអិតអំពីភាពអាចធ្វើបានខាងសេដ្ឋកិច្ច ប្លង់មេហេដ្ឋារចនាសម្ព័ន្ធ និងឯកសារបញ្ជាក់ផ្សេងៗទៀត ដូចដែលបានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជី តាមលក្ខខណ្ឌ ក្នុងរយៈពេល ១៨០ថ្ងៃធ្វើការ។ ក្នុងរយៈពេល ១០០ថ្ងៃធ្វើការបន្ទាប់ពីទទួលបានឯកសារគម្រោងខាងលើ គ.ស.ព ទទួលការយល់ព្រមចាំបាច់ទាំងអស់ ការផ្តល់សិទ្ធិអំណាចពីរដ្ឋាភិបាល និងចេញវិញ្ញាបនប័ត្រ- ចុះបញ្ជីចុងក្រោយ។ |
| ៣. ការប្រកាសនូវការបង្កើត *SEZ* | យោងតាមការចេញវិញ្ញាបនប័ត្រចុះបញ្ជីចុងក្រោយ ដោយ គ.ស.ព អនុក្រឹត្យប្រកាសពីការបង្កើត *SEZ* និងកំណត់ពីព្រំខ័ណ្ឌសីមា។ |
| ៤. រចនាសម្ព័ន្ធគ្រប់គ្រងនៃតំបន់សេដ្ឋកិច្ចពិសេស | គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដោះស្រាយបញ្ហាច្បាប់ និង បច្ចេកទេសហួសពីសិទ្ធិអំណាចរបស់រដ្ឋបាលតំបន់ និងដើម្បីទទួលបាន និងស្វែងរកដំណោះស្រាយចំពោះពាក្យបណ្តឹងណាមួយ ដែលប្តឹងដោយអ្នកអភិវឌ្ឍតំបន់ ឬវិនិយោគិនតំបន់។ ប្រធាន គ.ស.ព គឺជាប្រធាននៃ ក.អ.ក។<br>គ.ស.ព ស្ថិតក្រោម ក.អ.ក គឺជាអង្គភាព"ច្រកចេញ-ចូលតែមួយ" ដែលទទួលបន្ទុកអភិវឌ្ឍន៍ គ្រប់គ្រង និងត្រួតពិនិត្យមើលលើតំបន់សេដ្ឋកិច្ចពិសេស។ រដ្ឋបាលតំបន់ គឺជាយន្តការ "ច្រកចេញ-ចូលតែមួយ " ដែលចាត់ចែងឡើង និងមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នីមួយៗ។ |
| ៥. ភារកិច្ចនានារបស់អ្នកអភិវឌ្ឍតំបន់ | មានដើមទុន និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្នុងតំបន់ដែលក្នុងនោះមានធនធានមនុស្ស ដើម្បីគ្រប់គ្រងលើសកម្មភាពនានារបស់តំបន់ មានសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេសកសាងហេដ្ឋារចនាសម្ព័ន្ធ ជួលដីធ្លី និងផ្តល់សេវាកម្មដល់វិនិយោគិនតំបន់ រៀបចំបុគ្គលិកសន្តិសុខ និងធានានូវសណ្តាប់ធ្នាប់សាធារណៈល្អ ជាដើម |
| ៦. នីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្ត | គ.ស.ព ពិនិត្យមើល និងផ្តល់ការលើកទឹកចិត្តដល់ *SEZ* ទាំងអស់<br>ការលើកទឹកចិត្តទាំងអស់ត្រូវបញ្ជាក់ឱ្យបានច្បាស់ នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីចុងក្រោយ |
| ៧. ការលើកទឹកចិត្តទៅលើពន្ធដារ | **សម្រាប់អ្នកអភិវឌ្ឍតំបន់** : រយៈពេលលើកលែងពន្ធទៅលើប្រាក់ចំណេញត្រូវផ្តល់ឱ្យក្នុងរយៈពេលអតិបរមា ៩ឆ្នាំ។ ពន្ធនាំចូល និងពន្ធដទៃទៀតជាបន្ទុករបស់រដ្ឋ សម្រាប់បរិក្ខានាំចូល និងសម្ភារៈសំណង់ដែលនឹងត្រូវបានប្រើប្រាស់ នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ។<br>**សម្រាប់វិនិយោគិនតំបន់** : មានសិទ្ធិទទួលបានការលើកទឹកចិត្តទៅលើពន្ធគយ និងពន្ធដារ ដូចគ្នានឹង គ.ល.ព ដទៃទៀតដែរ ក្រោមច្បាប់វិសោធនកម្មលើច្បាប់វិនិយោគ។ ការលើកទឹកចិត្ត ទៅលើអាករលើ |

| ចំណុចនានា | ការពិពណ៌នា |
|---|---|
| | តម្លៃបន្ថែម ក្នុងអត្រា 0% ត្រូវទទួលបាន លុះត្រាតែសម្ភារៈទិន្នផលនៃ ផលិតកម្មត្រូវបាននាំចូលមកកាន់ទីផ្សារក្នុងស្រុក។ |
| ៨. ការលើកទឹកចិត្តផ្សេងៗទៀត | អ្នកអភិវឌ្ឍ ឬវិនិយោគិនតំបន់ ឬនិយោជិតបរទេស អាចផ្ទេរប្រាក់ចំណូលទាំងអស់ពីការ- វិនិយោគ និងប្រាក់បៀវត្សរ៍ ដែលទទួលបានពីតំបន់។<br>ប្រព្រឹត្តិកម្មមិនរើសអើងចំពោះជនបរទេស គ្មានជាតូបនីយកម្ម និងតម្លៃមិនកំណត់ ដូចដែលបានចែងក្នុងមាត្រានានានៃវិសោធនកម្មច្បាប់វិនិយោគ។ |
| ៩. វិធាននានាសម្រាប់តំបន់កែច្នៃនាំចេញ *(EPZ)* | ត្រូវតែមានច្រកចេញ ឬច្រកចូលជាក់លាក់។ ពុំមាននរណាម្នាក់អាចស្នាក់នៅបន្ទាប់ពីម៉ោងធ្វើការឡើយ លើកលែងតែបុគ្គលណាដែល រដ្ឋបាលតំបន់ ផ្តល់សិទ្ធិអំណាចឱ្យ។ ពេលវេលាទ្បើងទាត់សម្រាប់ចូល និងចេញ ត្រូវតែកំណត់ដោយបទបញ្ជាផ្ទៃក្នុង។ ការនាំចូល ឬនាំចេញទំនិញមកពី ឬទៅកាន់ *EPZ* ត្រូវបានចាត់ទុកជាការនាំចូល ឬនាំចេញ ទំនិញមកពី ឬទៅកាន់ប្រទេសកម្ពុជា។ ទំនិញត្រូវវាយត្រាយ៉ាងត្រឹមត្រូវដោយមន្ត្រីគយ មុននឹងនាំចូល ឬនាំចេញ។ ពុំមានធុរកិច្ចលក់រាយអាចមានទីតាំងនៅក្នុង *EPZ* ឡើយ។ វិនិយោគិនតំបន់មិនអាចប្រើប្រាស់សម្ភារៈទិន្នផលនៃផលិតកម្ម ដែលផលិតនៅក្នុង *EPZ* ដោយគ្មានការអនុញ្ញាតពីរដ្ឋបាល *SEZ* ឡើយ។ វិនិយោគិនតំបន់ នៅក្នុង *EPZ* អាចស្នើរដ្ឋបាល *SEZ* ទិញទំនិញពីទីផ្សារក្នុងស្រុកបាន។ ការទិញបែបនេះត្រូវតែបានត្រួតពិនិត្យមើលដោយមន្ត្រីគយ។ |
| ១០. កម្លាំងការងារ | ជនបរទេសអាចត្រូវបានផ្តល់ការងារឱ្យធ្វើ រហូតដល់ដប់ (១០)% នៃចំនួននិយោជិតសរុប។ |
| ១១. ការបណ្តុះបណ្តាលវិជ្ជាជីវៈ | អ្នកអភិវឌ្ឍតំបន់មានភារកិច្ចមួយ ក្នុងការធ្វើសហប្រតិបត្តិការជាមួយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីជួយសម្រួលដល់ការបណ្តុះបណ្តាលពលករកម្ពុជា និងដើម្បីជំរុញចំណេះដឹង និងជំនាញថ្មីៗ។ |
| ១២. វិសោធនកម្មលើអនុក្រិត្យ | អនុក្រិត្យនេះត្រូវតែបានកែប្រែបន្ថែមបន្ថយ យោងតាមកាលៈទេសៈដែលកំពុងផ្លាស់ប្តូរ និង ទៅតាមសេចក្តីត្រូវការនៃស្ថានភាពទូទៅ ក្នុងកំឡុងពេលអនុវត្តន៍របស់វា ដោយផ្អែកតាម សំណើរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុម័តដោយគណៈកម្មាធិការ ដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។ |

ប្រភព : ចងក្រងដោយ ក្រុមសិក្សា **JICA** ផ្អែកលើការបកប្រែជាភាសាអង់គ្លេសនៃអនុក្រឹត្យលេខ ១៤៨ ស្តីពីការបង្កើត និងគ្រប់គ្រងនៃតំបន់សេដ្ឋកិច្ចពិសេស

**(២) បញ្ហាដែលនឹងត្រូវបានដោះស្រាយ ដោយពាក់ព័ន្ធនឹងបទបញ្ញត្តិនានាដែលទាក់ទិននឹង SEZ**

អនុក្រិត្យ SEZ មានបញ្ហាខ្លះ ដែលគេផ្តល់អនុសាសន៍ឱ្យដោះស្រាយ ធ្វើឱ្យប្រសើរឡើង និង/ឬកែប្រែ ក្នុងខណៈដែលគេរំពឹងឱ្យមានការតាក់តែងច្បាប់អំពី SEZ នៅពេលអនាគតដ៏ឆាប់ៗនេះ។ ក្នុងចំណោមបញ្ហាទាំង នោះ មានបញ្ហាសំខាន់ៗមួយចំនួន ដូចជា :

**(i) សេចក្តីត្រូវការសំរាប់ធ្វើឱ្យឯកភាពចំពោះតំបន់ជំរុញសេដ្ឋកិច្ច**

ក្នុងខណៈដែលកំពុងពិនិត្យមើលតំបន់ជំរុញសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ឈ្មោះជាច្រើនត្រូវបានប្រើប្រាស់សំរាប់ តំបន់ទាំងនោះក្នុងពេលកន្លងមក។ មានតាំងពី តំបន់ជំរុញពិសេស “SPZ” និងតំបន់កែច្នៃសំរាប់នាំចេញ “EPZ” ដែល ត្រូវបានប្រើប្រាស់ក្នុងមាត្រាទី ១៤.៩ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ "តំបន់ឧស្សាហកម្ម" ត្រូវបានប្រើ ប្រាស់នៅក្នុងអនុក្រឹត្យស្តីពីការបង្កើតតំបន់ឧស្សាហកម្មក្រុងព្រះសីហនុ" នៅឆ្នាំ ១៩៩៥។ ទោះបីឈ្មោះ នៃតំបន់ជំរុញ សេដ្ឋកិច្ចនៅកម្ពុជា ត្រូវបានយល់ទាំងអស់គ្នាថាបានសំរេចជា "តំបន់សេដ្ឋកិច្ចពិសេស" តាមការចេញនូវអនុក្រឹត្យតំបន់ សេដ្ឋកិច្ចពិសេស កាលពីថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ក៏ដោយ ក៏អនុក្រឹត្យនេះ មិនបានរាប់បញ្ចូលនូវបទប្បញ្ញត្តិ ដែល ប្រកាសឱ្យច្បាស់នូវការឯកភាពនៃឈ្មោះរបស់តំបន់ដែរ ហើយក៏មិនបានលុបឈ្មោះ "តំបន់ជំរុញពិសេស" ឬ "តំបន់ ឧស្សាហកម្ម" ចោលដែរ។ វាជាការសំខាន់ណាស់ ដើម្បីផ្តល់ឱ្យវិនិយោគិននូវការយល់ដឹងឱ្យបានច្បាស់ ថាមានតែទំរង់នៃ តំបន់ជំរុញសេដ្ឋកិច្ចតែមួយប៉ុណ្ណោះនៅកម្ពុជា ដែលមានឈ្មោះថា "តំបន់សេដ្ឋកិច្ចពិសេស"។

**(ii) ការលើកទឹកចិត្ត និងប្រព្រឹត្តកម្មអនុគ្រោះ**

នៅពេលការលើកទឹកចិត្តខាងហិរញ្ញវត្ថុដែលផ្តល់ទៅឱ្យវិនិយោគិនតំបន់ ក្នុងអនុក្រិត្យស្តីពី SEZ ដូចគ្នានឹងការ លើកទឹកចិត្តទាំងឡាយដែលផ្តល់ទៅឱ្យ គ.ល.ព ក្រោមវិសោធនកម្មច្បាប់វិនិយោគនេះ ការលើកទឹកចិត្ត មិនមែនហិរញ្ញវត្ថុ ក៏មានលក្ខណៈទូទៅផងដែរនៅខាងក្រៅតំបន់។ ការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុទាំងនេះអាចត្រូវបានយកមកប្រើនៅ ក្នុងវិស័យនៃការត្រួតពិនិត្យគយលក្ខខណ្ឌផលិតកម្ម អធិការកិច្ចផ្សេងៗ វិធីសាស្ត្របង់ពន្ធ និកម្មភាព និងការគ្រប់គ្រង ការងារជាដើម។ ដើម្បីបញ្ចូលវិធានការជំរុញ SMEs ជាមួយនិងសកម្មភាពរបស់តំបន់ នឹងទទួលបានផលប្រយោជន៍ ផងដែរ សម្រាប់ទាំងគោលបំណង ជំរុញឧស្សាហកម្មក្នុងប្រទេស និងទាំងប្រតិបត្តិការធុរកិច្ចរបស់វិនិយោគិនតំបន់។

**៣) ការដាក់កម្រិតដែលកំណត់ក្នុងដែនដីគយខុសគ្នា**

អនុក្រិត្យស្តីពី SEZ ចែងថា មិនត្រូវមាននរណាម្នាក់ស្ថិតនៅក្នុង EPZ ឡើយ បន្ទាប់ពីពេលវេលា ជាទៀងទាត់ សម្រាប់ការចូលនិងចេញ លុះត្រាមានកាយល់ព្រមពីរដ្ឋបាល SEZ។ លើសពីនេះទៅទៀត អនុក្រិត្យស្តីពី SEZ ចែងថា

អ្នកអភិវឌ្ឍតំបន់មានភារកិច្ចសហការ ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយសម្រួលដល់ការបណ្តុះបណ្តាលពលករកម្ពុជា និងដើម្បីជំរុញចំណេះដឹង និងជំនាញថ្មីៗ ។

ជាទូទៅ EPZs ឬ SEZs នៅក្នុងប្រទេសដទៃទៀត ត្រៀមជាស្រេច ក្នុងការផ្តល់នូវលក្ខខណ្ឌប្រតិបត្តិកាន់តែសេរី ការត្រួតពិនិត្យខាងរដ្ឋបាលតិចជាង និងដំណើរការខាងនីតិវិធីងាយស្រួលនិងលឿនជាងនៅខាងក្រៅតំបន់ ។ អាកប្បកិរិយាសំខាន់ឆ្ពោះទៅភាពជោគជ័យនៃការបង្កើត និងការគ្រប់គ្រងតំបន់ ហាក់ដូចជាមិនត្រូវ "ដាក់កម្រិត ឬកំហិតចំពោះវិនិយោគិនទេ" ប៉ុន្តែត្រូវ "បម្រើវិនិយោគិន" វិញ ។ នៅក្នុងច្បាប់ខាងមុខ គួរតែមានវិធានការដែលគួរឱ្យចូលចិត្តជាងនេះ កាន់តែលំអិតថែមទៀត ដែលទាក់ទិននឹងបញ្ហាខាងរដ្ឋាភិបាល និងខាងនីតិវិធីដែលនឹងជួបប្រទះ ។

### (៣) ការតាក់តែងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស

បន្ទាប់ពីរដ្ឋាភិបាលបានចេញ" អនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ( អនុក្រឹត្យស្តីពី SEZ " នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ បច្ចុប្បន្ននេះវាកំពុងដំណើរការទៅលើការអនុម័តិច្បាប់ថ្មីអំពី SEZ ។ ចលនានេះមានលក្ខណៈអំណោយផលណាស់ចំពោះ FDIs នៅពេលដែលច្បាប់មួយមានមូលដ្ឋានកាន់តែរឹងមាំ ក្នុងចំណោមពលរដ្ឋ និងមានបទដ្ឋានច្បាប់ប្ញងមាំជាងអនុក្រឹត្យ ។ ដោយពិនិត្យមើលលើអនុក្រិត្យស្តីពី SEZ មានទិដ្ឋភាពសំខាន់ខ្លះនឹងត្រូវបានពិចារណា នៅពេលដែលតាក់តែងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដែលរួមមានដូចខាងក្រោម :

**(i) កំណត់ទស្សនទានអំពីតំបន់សេដ្ឋកិច្ចពិសេសឱ្យកាន់តែច្បាស់លាស់ :**

អនុក្រឹត្យស្តីពី SEZ មិនចែងច្បាស់លាស់ថាតើ SEZ ត្រូវតែមានដែនដីគយខុសគ្នាមួយ ដូចជាតំបន់កែច្នៃសម្រាប់នាំចេញ (EPZ) និង/ឬតំបន់ពាណិជ្ជកម្ម (FTZ) ។ វាគ្រាន់តែចែងថា SEZ ត្រូវមានទីកន្លែងផលិតកម្មមួយដែលមានតំបន់ឧស្សាហកម្មទូទៅ (GIZ) និង/ឬ EPZ ។ ត្រូវតែធ្វើឱ្យវាច្បាស់លាស់ថាតើ SEZ ដែលមានតែ GIZ ប៉ុណ្ណោះ ត្រូវបានលើកទឹកចិត្តផងដែរឬទេ។ ជាបន្ថែម ប្បញ្ញត្តិដែលប្រកាសពីទំរង់ការរបស់ "តំបន់សេដ្ឋកិច្ចពិសេស" គឺជាទំរង់ការនៃតំបន់ជំរុញសេដ្ឋកិច្ចមួយ និងតែមួយនៅកម្ពុជាដែលត្រូវតែលើកយកមកធ្វើ ។

**(ii) ដាក់បញ្ញត្តិឱ្យបានច្បាស់លាស់អំពីទំនាក់ទំនង ក្នុងចំណោមក្រុមប្រឹក្សាតំបន់សេដ្ឋកិច្ចពិសេសនៃកម្ពុជា**

គ.ស.ព និងគណៈកម្មាធិការវិនិយោគកម្ពុជា "គ.វ.ក" ឬអនុគណៈកម្មាធិការវិនិយោគខេត្តក្រុង "អ.គ.វ.ខ-ក" ដែល ទាក់ទិននឹងដំណើរការដាក់ពាក្យស៊ីវិនិយោគ និងចេញអាជ្ញាប័ណ្ណ សម្រាប់ គ.ល.ព :

ត្រូវតែចែងឱ្យបានច្បាស់លាស់ថា វិនិយោគិនម្នាក់ដែលចូលមក SEZ ត្រូវបានតម្រូវឱ្យដាក់សំណើវិនិយោគទៅកាន់រដ្ឋបាលតំបន់ ហើយសំណើបែបនេះមិនតម្រូវឱ្យដាក់ទៅកាន់ គ.វ.ក ឬ "អ.គ.វ.ខ-ក"។ ការភ័ន្តច្រឡំបែប

នេះអាចនឹងកើតឡើង នៅពេលពុំមានការពន្យល់ទៅលើទំនាក់ទំនងរវាងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ និង អនុក្រឹត្យស្តីពី SEZ ។

**(iii) ផ្តល់ការពន្យល់ថែមទៀតទៅលើលក្ខខណ្ឌដែលទាក់ទងនឹងវិនិយោគិនចំពោះតំបន់ និងកែកំហុសក្នុងការសម្តែងចេញនូវកាយវាចាចិត្ត :**

មាត្រាទី ៣-៣ នៃអនុក្រឹត្យស្តីពី SEZ ចែងថា "វិនិយោគិនតំបន់ដែលចាប់ផ្តើមសកម្មភាពផលិតកម្ម ឬសេវាកម្ម នៅក្នុងវិស័យដែលអនុញ្ញាតដោយច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធ នៅក្នុងតំបន់សេដ្ឋកិច្ចណាមួយ ត្រូវបំពេញទម្រង់បែបបទដោយផ្អែកលើនីតិវិធី" ។ គេផ្តល់អនុសាសន៍ឱ្យរៀបរាប់ ឱ្យបានពិតប្រាកដថាតើនៅពេលណា និងទម្រង់បែបបទអ្វី នៅក្នុងវិស័យណាមួយ ដែលនឹងត្រូវបានបំពេញ។ ការរៀបរាប់ដ៏ស្រពិចស្រពិល មិនច្បាស់លាស់អាចនឹងនាំឱ្យមានការភ័ន្តច្រឡំ ដែលមិនចាំបាច់ក្នុងចំណោមវិនិយោគិននានា។

មាត្រាដដែល នៃអនុក្រឹត្យស្តីពី SEZ ក៏ចែងផងដែរថា" ការលើកទឹកចិត្តណាមួយដែលផ្តល់ជូនវិនិយោគិនតំបន់ ***ត្រូវបានសម្រេចចិត្តដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស*** តាមរយៈយន្តការ" ច្រកចេញ-ចូលតែមួយ" ដែលស្ថិតនៅនឹងកន្លែង និងយោងតាមបណ្តាច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ" ។ ដោយអនុលោមទៅ តាមប្បញ្ញតិនានានៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ការលើកទឹកចិត្តវិនិយោគ សម្រាប់ គ.ល.ក ត្រូវផ្តល់ជូនដោយស្វ័យប្រវត្តិ នៅពេលដែលចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរ។ ប្រសិនបើការរៀបរាប់ខាងលើមានន័យថា រដ្ឋបាលតំបន់ ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យចេញវិញ្ញាបនប័ត្រចុះបញ្ជីចុងក្រោយនោះ គេផ្តល់អនុសាសន៍ឱ្យចែងឱ្យបានត្រឹមត្រូវណាស់។ លើសពីនេះទៅទៀត បើច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានធ្វើផែនការមានប្បញ្ញត្តិ ដែលស្រដៀងគ្នានោះការបែងចែកអំណាចរវាង "គ.ស.ព" និង "គ.វ.ក/អ.គ.វ.ខ-ក" ត្រូវបានចែងឱ្យបានច្បាស់លាស់ ទាំងនៅក្នុងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ និងរួមទាំងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។

**(iv) កំណត់ និងចែងឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌផ្តល់អាជ្ញាប័ណ្ណវិនិយោគដែលកាន់តែអនុគ្រោះ ប្រសិនបើមាន ជាងនៅក្នុងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ :**

នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរ ត្រូវបានចែងឱ្យចេញ ក្នុងរយៈពេលខ្លីច្រើនជាងដែលបានចែងក្នុងច្បាប់វិនិយោគដែលធ្វើវិសោធនកម្ម ហើយ "គ.ស.ព" និយាយថាវាគឺជាអត្ថប្រយោជន៍មួយក្នុងចំណោមជាច្រើនទៀត សម្រាប់វិនិយោគិន ដើម្បីឱ្យដាក់ទីតាំងនៅក្នុងតំបន់។ ទោះយ៉ាងណាក៏ដោយ ពុំមានប្បញ្ញត្តិ ដែលរៀបរាប់ពីចេតនាបែបនេះរបស់ "គ.ស.ព" នៅក្នុងអនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដែលមិនមានតម្លាភាព និងមិនអាចទស្សន៍ទាយបាន។ គេផ្តល់អនុសាសន៍យ៉ាងខ្លាំងឱ្យកំណត់ និងចែងឱ្យច្បាស់លាស់នៅក្នុងផែនការច្បាប់ស្តីពីតំបន់សេដ្ឋកិច្ច

ពិសេស នូវរយៈពេលអតិបរមាដែលតម្រូវសម្រាប់ការចុះបញ្ជីគម្រោងវិនិយោគ និងការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាបពរ ។

**(v) ណែនាំនូវវិធានការត្រួតពិនិត្យដែលមានលក្ខណៈកាន់តែបត់បែន ដើម្បីផ្តល់នូវបរិស្ថានធុរកិច្ចកាន់តែសេរី :**

វិធីសាស្ត្រត្រួតពិនិត្យការចូលប្រកបដោយភាពទន់ភ្លន់នៅក្នុងតំបន់កែច្នៃសំរាប់នាំចេញ ជាពិសេសសំរាប់កម្មករ ត្រូវចាំបាច់ធ្វើសំរាប់ធានាបាននូវការប្រតិបត្តិរបស់រោងចក្រដោយសេរី ។ ទាក់ទិនទៅនឹងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍន៍តំបន់ដើម្បីសំរួលការបណ្តុះបណ្តាលកម្មករកម្ពុជា ការលើកទឹកចិត្តមិនមែនជាសារពើពន្ធ ដែលជាករណីលើកលែងនោះ អាចត្រូវបានផ្តល់ឱ្យអ្នកអភិវឌ្ឍន៍តំបន់នូវបន្ទុកហិរញ្ញវត្ថុរបស់ពួកគេតិចជាងមុន ។

**(vi) ការកែប្រែនៃប្បញ្ញតិនៃអនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងបទបញ្ញតិពាក់ព័ន្ធ**

ច្បាប់ជាភាសាអង់គ្លេសនៃមាត្រា ៣.១.៣ (b) នៃអនុក្រឹត្យតំបន់សេដ្ឋកិច្ចពិសេស វាបានពិពណ៌នាថា តំបន់សេដ្ឋកិច្ចពិសេសត្រូវតែមានរបងព័ទ្ធជុំវិញ (សំរាប់តំបន់កែច្នៃសំរាប់នាំចេញ តំបន់ពាណិជ្ជកម្មសេរី និងសំរាប់រោងចក្រនៃវិនិយោគិននិមួយៗនៅក្នុងតំបន់និមួយៗ) ។ យោលទៅតាមការពន្យល់របស់ ក.អ.ក វាចាំបាច់ដើម្បីមានរបងព័ទ្ធទីតាំងនៃតំបន់កែច្នៃសំរាប់នាំចេញ និងតំបន់ពាណិជ្ជកម្មសេរីតែប៉ុណ្ណោះ ។ វាហាក់បីដូចជាមានកំហុសឆ្គងខ្លះក្នុងការបកប្រែភាសាអង់គ្លេស ហើយប្រសិនបើដូចនេះ ការបកប្រែខុសនេះ ត្រូវតែមានការកែតំរូវក្នុងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ។

មាត្រា ៧.៣ ចែងថារាល់ការនាំចូលដោយអ្នកអភិវឌ្ឍន៍តំបន់ និងវិនិយោគិនតំបន់ ត្រូវស្របទៅតាមច្បាប់ពាក់ព័ន្ធស្តីពីអធិការកិច្ចមុនពេលផ្ទុកទំនិញ (PSI) ។ យោលទៅតាមការពន្យល់របស់ ក.អ.ក "គ.ស.ព" នាពេលថ្មីៗនេះមានការយល់ព្រមមួយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានគយ និងរដ្ឋាករ) ថាកាតព្វកិច្ច PSI មិនត្រូវអនុវត្តន៍ចំពោះវិនិយោគិនដែលមានទីតាំងក្នុងដែនដីគយផ្សេងគ្នាទេ ។ ការផ្លាស់ប្តូរនេះ ត្រូវតែដាក់នៅក្នុងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ហើយទន្ទឹមនឹងនេះ បទបញ្ជាក្រសួងស្តីពីការអនុវត្តន៍នៃសេវាកម្មអធិការកិច្ចមុនពេលផ្ទុកទំនិញ ត្រូវតែធ្វើការកែប្រែ ។

**(៤) ការលើកទឹកចិត្ត ឬបុព្វសិទ្ធិបន្ថែម ដែលអាចផ្តល់ដល់គម្រោងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស**

ការលើកទឹកចិត្ត និងបុព្វសិទ្ធិនានា ដែលផ្តល់ក្រោមអនុក្រិត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានសង្ខេ នៅក្នុងតារាងទី ១០-១-៦ ដូចខាងក្រោម :

**តារាងទី ១០-១-៦ ការលើកទឹកចិត្ត នៅក្នុង** SEZ

| **អ្នកទទួលផលប្រយោជន៍** | **ការលើកទឹកចិត្ត** |
|---|---|
| អ្នកអភិវឌ្ឍតំបន់ | រយៈពេលលើកលែងពន្ធទៅលើប្រាក់ចំណេញត្រូវផ្តល់ឱ្យ ក្នុងរយៈពេលអតិបរមា ៩ឆ្នាំ ។<br>ពន្ធនាំចូល និងពន្ធដទៃទៀតត្រូវត្រូវបានលើកលែងសម្រាប់បរិក្ខានាំចូលបរិក្ខាសំណង់ និង សម្ភារៈ |

| អ្នកទទួលផលប្រយោជន៍ | ការលើកទឹកចិត្ត |
|---|---|
| | ដែលនឹងត្រូវបានប្រើប្រាស់នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់។<br>ក្រោមរូបភាពនៃការអនុញ្ញាតជាបណ្តោះអាសន្ន (AT) អ្នកអភិវឌ្ឍតំបន់អាចស្នើនាំចូល មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ ដែលប្រើប្រាស់សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ យោងតាម ច្បាប់ និងបទបញ្ញត្តិនានា ដែលនៅជាធរមាន។<br>អ្នកអភិវឌ្ឍតំបន់អាចទទួលបានសម្បទានដីធ្លី ពីរដ្ឋ សម្រាប់បង្កើត SEZ នៅតំបន់ដែលកៀកនឹងព្រំដែន ឬតំបន់ដែលដាច់ឆ្ងាយពីគេ។ |
| វិនិយោគិនតំបន់ | មានសិទ្ធិទទួលការលើកទឹកចិត្តលើពន្ធគយ និងពន្ធដារ ដូចគ្នានឹង គ.ល.ព ដទៃទៀតដែរ។<br>ទទួលបានការលើកទឹកចិត្ត ទៅលើអាករលើតម្លៃបន្ថែម ក្នុងអត្រា 0% លុះត្រាតែសម្ភារៈ ទិន្នផលនៃផលិតកម្មត្រូវបាននាំចូលមកកាន់ទីផ្សារក្នុងស្រុក។ |
| ជាទូទៅ | អ្នកអភិវឌ្ឍ ឬវិនិយោគិនតំបន់ ឬនិយោជិតបរទេស អាចផ្ទេរប្រាក់ចំណូលទាំងអស់ពីការ- វិនិយោគ និងប្រាក់បៀវត្សរ៍ ដែលទទួលបានពីតំបន់។<br>ការចាត់ទុកជាជនបរទេសដោយមិនរើសអើង មិនជាតូបនីយកម្ម និងតម្លៃមិនកំណត់។ |

ប្រភព : ចងក្រងដោយក្រុមសិក្សា **JICA** ផ្អែកលើការបកប្រែជាភាសាអង់គ្លេសនៃអនុក្រឹត្យលេខ ១៤៨ ស្តីពីការបង្កើត និងគ្រប់គ្រងនៃតំបន់សេដ្ឋកិច្ចពិសេស

នៅពេលអនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដែលធ្វើផែនការរួចគេផ្តល់អនុសាសន៍ឱ្យផ្តល់ជូនការលើកទឹកចិត្ត និង បុព្វសិទ្ធិបន្ថែមដូចខាងក្រោម :

(i) សម្រាប់រាល់វិនិយោគិនទាំងអស់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

រាល់តម្លៃឈ្នួល ឬបន្ទុកទាំងអស់ត្រូវបង្ហាញឱ្យបានច្បាស់លាស់ នៅលើក្តារខៀនដែលដាក់នៅក្នុងការិយាល័យរដ្ឋបាលតំបន់។ គ្មានតម្លៃឈ្នួលឬបន្ទុកផ្សេងទៀត ត្រូវបានហាមប្រាមមិនឱ្យស្នើឱ្យបង់នោះទេ។

រដ្ឋបាលតំបន់ ត្រូវបង្កើតមជ្ឈមណ្ឌលស្វែងរកការងារមួយ ដែលណែនាំវិនិយោគិនឱ្យស្គាល់កម្មករ និង និយោជិតដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដោយមិនគិតថ្លៃ ឬយកថ្លៃតិចតួចប៉ុណ្ណោះ។

រដ្ឋបាលតំបន់ ត្រូវរៀបចំ និងផ្តល់កិច្ចសន្យាការងារដែលមានលក្ខណៈរួបរួម សរសេរជាភាសាខ្មែរ ដែលត្រូវបានប្រើប្រាស់ដោយរាល់វិនិយោគិនទាំងអស់ នៅក្នុងតំបន់។

ការចំណាយសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់ដោយនិយោជក ដល់កម្មករ និងនិយោជិតកម្ពុជា ត្រូវតែដកចេញពីប្រាក់ចំណេញសុទ្ធរបស់គម្រោងវិនិយោគ។

វិនិយោគិននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានលើកលែងពីការចំណាយជាមុនទៅលើពន្ធប្រាក់ចំណេញ ឬត្រូវបានអនុញ្ញាតឱ្យបង់ពាក់កណ្តាលឆ្នាំជាមុន ទៅលើពន្ធប្រាក់ចំណេញ។

(ii) សម្រាប់វិនិយោគិននៅក្នុង EPZ និង FTA (ដែនដីគយខុសគ្នា)

ការត្រួតពិនិត្យដោយបញ្ជីមេ (master list) ទៅលើការនាំចូលកត្តាផលិតកម្មដោយមិនគិតពន្ធនោះ មិនត្រូវបានអនុវត្តចំពោះគម្រោងនានា នៅក្នុង EPZ ឬ FTA នៃ SEZ ឡើយ។ វិនិយោគិនដែលមានទីតាំងនៅក្នុងតំបន់បែបនេះ មានលទ្ធភាពនាំចូលកត្តាផលិតកម្មដោយសេរី ដោយគ្រាន់តែដាក់ជូននូវឯកសារប្រតិវេទន៍ការនាំចូលប៉ុណ្ណោះ។

ការត្រួតពិនិត្យលើការនាំចេញ-នាំចូលដោយវិធី "ច្រកចេញចូលតែមួយ" ត្រូវបានអនុវត្តនៅក្នុងឱកាសឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើបាន។

ការធ្វើសវនកម្មលើការជម្រះបញ្ជីជាក្រោយ(PCA)ឬវិធីគ្រប់គ្រងហានិភ័យ ត្រូវបានអនុវត្តចំពោះរាល់ការនាំចូលទាំងអស់មកកាន់តំបន់បែបនេះ។

ពុំមានអធិការកិច្ចនៅនឹងកន្លែងក្នុងរោងចក្រ ត្រូវបានអនុវត្ត មុនពេលវេចខ្ចប់ឡើយ។

កូដកម្មការងារត្រូវតែត្រូវបានដាក់កម្រិត នៅខាងក្នុងតំបន់បែបនេះ។ (កូដកម្មការងារត្រូវបានអនុញ្ញាតនៅខាងក្រៅរបង។)

(iii) **សម្រាប់វិនិយោគិននៅក្នុងតំបន់ឧស្សាហកម្មទូទៅ**

បញ្ញត្តិនៃ "សេវាកម្មច្រកចេញចូលតែមួយ" ចំពោះវិនិយោគិន នៅក្នុងតំបន់ឧស្សាហកម្មទូទៅ ត្រូវតែត្រូវបានធានា

ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក.អ.ក ត្រូវរៀបចំប្រាក់កម្ចីពីរជំហាន (TSL) ដែលនឹងត្រូវបានប្រើប្រាស់ដោយវិនិយោគិនធុនតូចនិងមធ្យម (SME) ក្នុងស្រុក នៅក្នុងតំបន់ឧស្សាហកម្មទូទៅតែប៉ុណ្ណោះ

ដោយសហការជាមួយអ្នកអភិវឌ្ឍតំបន់ គ.ស.ព ត្រូវរៀបចំបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល នៅក្នុងតំបន់ឧស្សាហកម្មទូទៅ ដើម្បីផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាជំនាញបច្ចេកទេស គណនេយ្យ និង/ឬម៉ាឃីធីង ជូនដល់សហគ្រិន SME កម្មករ និងនិយោជិតកម្ពុជាទាំងឡាយ។

ដោយសហការជាមួយវិស័យឯកជន ដែលក្នុងនោះមានក្រុមហ៊ុនបរទេសផងដែរ គ.ស.ព ត្រូវរៀបចំបង្កើតមជ្ឈមណ្ឌលម៉ាឃីធីង ដើម្បីជួយដល់សកម្មភាពម៉ាឃីធីងរបស់ SMEs ដែលមានទីតាំង នៅក្នុងតំបន់ឧស្សាហកម្មទូទៅ។

គ.ស.ព ត្រូវជួយបង្កើតវេបសាយ (web-site) របស់ SMEs ដែលមានទីតាំងនៅក្នុងតំបន់ឧស្សាហកម្មទូទៅ និងត្រូវរៀបចំ ការតាំងពិព័រណ៍ផលិតផល និងបច្ចេកវិជ្ជារបស់ពួកគេ។

### ១០.១.៥ អនុសញ្ញាក្យូតូ ដែលកែប្រែថ្មី

### (១) សាវតា និងស្ថានភាពបច្ចុប្បន្ននៃអនុសញ្ញាក្យូតូ ដែលកែប្រែថ្មី

(i) **អង្គការគយពិភពលោក** (WCO) **និងប្រទេសកម្ពុជា**

ឈ្មោះផ្លូវការនៃ WCO គឺ "ក្រុមប្រឹក្សាសហប្រតិបត្តិការគយ (CCC)" ដែលមានទីស្នាក់ការនៅឯទីក្រុងប្រ៊ុយសែលនៃប្រទេសបែលហ្សិក។ WCO ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥២ នៅពេលដែល "អនុសញ្ញាបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ" ចូលជាធរមាន។ WCO មានគោលបំណងជំរុញសុខដុមនីយកម្ម និងការធ្វើឱ្យប្រព័ន្ធគយមានភាពងាយស្រួលសាមញ្ញ នៅក្នុងប្រទេសដែលជាសមាជិក និងសហប្រតិបត្តិការអន្តរជាតិ នៅក្នុងរដ្ឋបាលគយ។

ចំនួននៃប្រទេស/តំបន់ដែលជាសមាជិក មាន ១៦៤ គិតត្រឹមខែមករា ឆ្នាំ២០០៥ ហើយប្រទេសកម្ពុជាបានចូលរួមក្នុងអនុសញ្ញានេះ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០១ ជាសមាជិកទី ១៥៥។

(ii) "អនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យសាមញ្ញ និងសុខដុមនីយកម្មលើនីតិវិធីគយ" (អនុសញ្ញាក្យូតូ)

"អនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យសាមញ្ញនិងសុខដុមនីយកម្មលើនីតិវិធីគយ" (អនុសញ្ញាក្យូតូ) ត្រូវបានអនុម័តដោយក្រុមប្រឹក្សាសហប្រតិបត្តិការគយ (CCC, ដែលបច្ចុប្បន្នគឺ WCO) នៅឯទីក្រុងក្យូតូ ប្រទេសជប៉ុនក្នុងឆ្នាំ១៩៧៣ ហើយចូលជាធរមាន ក្នុងឆ្នាំ១៩៧៤។ វាបានកំណត់នូវប្រាក់វិភាជន៍ ដែលមិនបង់ពន្ធសម្រាប់អ្នកធ្វើដំណើរឆ្លងប្រទេស ការបង្កើតច្រកពណ៌បៃតង និងច្រកពណ៌ក្រហម នៅឯទីស្នាក់ការគយជាដើម ប៉ុន្តែវាមិនបានផ្តល់បញ្ញត្តិគ្រប់គ្រាន់ ដើម្បីគ្របដណ្តប់ទៅលើចលនានៃទំនិញ ដូចជាការនាំចូល/ការនាំចេញ ដោយប្រើប្រាស់កុងតេន័រទេ។

(iii) **"ពិធីសារនៃវិសោធនកម្ម" (អនុសញ្ញាក្យូតូដែលកែប្រែថ្មី)**

"ពិធីសារនៃវិសោធនកម្ម" (អនុសញ្ញាក្យូតូដែលកែប្រែថ្មី) ត្រូវបានអនុម័តនៅទីក្រុងប្រ៊ុយសែលក្នុងខែមិថុនា ឆ្នាំ១៩៩៩ យល់ព្រមឱ្យប្រទេសអណ្តោចូលជាសមាជិកទី៤០នៃអនុសញ្ញានេះ ក្នុងខែធ្នូ ឆ្នាំ២០០៥ និងបានចូលជា

ធរមាននៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦។ ជាមួយនិងវិសោធនកម្មនេះ WCO មានគោលបំណងផ្តល់នូវ "ប្លង់សម្រាប់នីតិវិធីគយដ៏ទំនើបនិងមានប្រសិទ្ធភាព ក្នុងសតវត្សរ៍ទី២១"។ WCO និយាយថា នៅពេលដែលអនុសញ្ញាក្យូតូដែលកែប្រែនេះត្រូវបានអនុវត្តយ៉ាងទូលំទូលាយនោះ វានឹងផ្តល់ឱ្យពាណិជ្ជកម្មអន្តរជាតិនូវភាពអាចទស្សន៍ទាយបាន និងប្រសិទ្ធភាព ដែលពាណិជ្ជកម្មទំនើបត្រូវការ។ ចំណុចសំខាន់ជាងគេ ក្នុងចំណោមបណ្តាគោលការណ៍អភិបាលកិច្ចថ្មី នៃអនុសញ្ញាក្យូតូដែល កែប្រែនេះ គឺជាការតាំងចិត្តរបស់រដ្ឋបាលគយ ក្នុងការផ្តល់នូវតម្លាភាព និងភាពអាចទស្សន៍ទាយបាន សម្រាប់រាល់អ្នកទាំងឡាយណាដែលពាក់ព័ន្ធនឹងទិដ្ឋភាពនានា នៃពាណិជ្ជកម្មអន្តរជាតិ។ អនុសញ្ញា ក្យូតូដែលកែប្រែនេះជំរុញដល់ការសម្របសម្រួលពាណិជ្ជកម្ម និងការត្រួតពិនិត្យដ៏សក្តិសិទ្ធិ តាមរយៈប្បញ្ញត្តិច្បាប់របស់វា ដែលលំអិតអំពីរបៀបប្រើប្រាស់នីតិវិធីដ៏សាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាព។ អនុសញ្ញាក្យូតូដែលកែប្រែនេះក៏មានវិធានថ្មីៗនិងដែលជាកាតព្វកិច្ច សម្រាប់ការអនុវត្តរបស់វា ដែលគ្រប់ ភាគីចុះកិច្ចសន្យាទាំងអស់ត្រូវតែព្រមទទួលយក ដោយគ្មានលក្ខខណ្ឌ។

**(២) មាតិកានៃអនុសញ្ញាក្យូតូដែលកែប្រែថ្មី**

(i) ការត្រួតពិនិត្យរបស់គយ

អនុសញ្ញាក្យូតូដែលកែប្រែនេះរួមមានតួសេចក្តី ឧបសម្ព័ន្ធទូទៅនិងឧបសម្ព័ន្ធជាក់លាក់។ ក្នុងករណីនៃអនុសញ្ញាក្យូតូ ប្រទេសដែលជាសមាជិកអាចប្រើប្រាស់បញ្ញត្តិណាមួយដោយសម្រាំង ប៉ុន្តែនៅក្នុងអនុសញ្ញាក្យូតូដែលកែប្រែនេះតួសេចក្តី និងឧបសម្ព័ន្ធទូទៅត្រូវតែត្រូវបានអនុវត្ត ក្នុងរយៈពេល៣ឆ្នាំ និង ៥ឆ្នាំ រៀងៗគ្នា បន្ទាប់ពីការផ្តល់សច្ចានុម័ត នៅក្នុងប្រទេសដែលជាសមាជិកពាក់ព័ន្ធ។

ចំណុចស្នូលនៃអនុសញ្ញាក្យូតូដែលកែប្រែនេះ គឺត្រង់ជំពូកទី៦"ការត្រួតពិនិត្យរបស់គយ" នៃឧបសម្ព័ន្ធទូទៅ។ គោលការណ៍នៃជំពូកទី៦ គឺមានដូចខាងក្រោម :

ធ្វើការត្រួតពិនិត្យតិចបំផុតដែលចាំបាច់ ដើម្បីធានានូវភាពអនុលោមតាមច្បាប់ : ការត្រួតពិនិត្យរបស់គយត្រូវបានដាក់កម្រិតចំពោះកន្លែងណាដែលចាំបាច់ ដើម្បីធានានូវភាពអនុលោមតាមច្បាប់គយ

ប្រើប្រាស់ការគ្រប់គ្រងហានិភ័យ នៅក្នុងការត្រួតពិនិត្យរបស់គយ :

- គយនឹងប្រើប្រាស់ការវិភាគពីហានិភ័យ ដើម្បីកំណត់ថាតើបុគ្គលណាមួយ និងទំនិញណាមួយរួមទាំងមធ្យោបាយដឹកជញ្ជូនផង គួរត្រូវបានត្រួតពិនិត្យ និងវិសាលភាពនៃការត្រួតពិនិត្យ
- គយត្រូវអនុម័តយុទ្ធសាស្ត្រវាស់វែងពីភាពអនុលោមតាមច្បាប់ ដើម្បីគាំទ្រដល់ការគ្រប់គ្រងហានិភ័យ
- ប្រព័ន្ធត្រួតពិនិត្យរបស់គយត្រូវបញ្ចូលនូវការត្រួតពិនិត្យដែលផ្អែកលើសវនកម្ម

ធ្វើឱ្យអាចរកបាននូវព័ត៌មានដែលត្រឹមត្រូវ ទាន់សម័យ និងងាយស្រួលរក : គយត្រូវខិតខំធ្វើកិច្ចសហ-

ប្រតិបត្តិការជាមួយរដ្ឋបាលគយផ្សេងទៀត និងប្រឹងប្រែងបញ្ចប់នូវកិច្ចព្រមព្រៀងជំនួយរដ្ឋបាល ទៅវិញទៅមកដើម្បីធ្វើឱ្យប្រសើរឡើងដល់ការត្រួតពិនិត្យរបស់គយ ។ គយត្រូវត្រូវខិតខំធ្វើកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជកម្ម និងប្រឹងប្រែងបញ្ចប់អនុស្សារណៈនៃការយោគយល់គ្នា ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការត្រួតពិនិត្យរបស់គយ ។

ការប្រើប្រាស់ជាអតិបរមានូវបច្ចេកវិជ្ជាព័ត៌មាន : គយនឹងប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាន និងពាណិជ្ជកម្មតាមអេឡិចត្រូនិច (E-commerce) ឱ្យបានវិសាលភាពធំធេងបំផុត តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការត្រួតពិនិត្យរបស់គយ ( បទដ្ឋានអន្តរកាល) ។

ការគ្រប់គ្រងហានិភ័យ គឺជាប្រភេទមួយនៃវិធីសាស្ត្រត្រួតពិនិត្យរបស់គយ ដែលនឹងត្រូវបានអនុវត្តដោយផ្អែកលើការវិភាគពីទិន្នន័យប្រវត្តិរបស់ពាណិជ្ជករ ទំនិញ ប្រទេសប្រភពដើម ដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ។ លក្ខណៈមួយដែលជឿនលឿននិងជាហេតុលំបាកបំផុត ក្នុងចំណោមជាច្រើននោះ គឺការគ្រប់គ្រង ហានិភ័យដែលផ្អែកលើទិន្នន័យប្រវត្តិរបស់ពាណិជ្ជករនេះឯង ។

វារួមមានវដ្តជីវិត៤ដំណាក់កាល : ការកំណត់រក ការវិភាគ ការវាយតម្លៃ និងការតាមដានត្រួតពិនិត្យ ។ ដោយប្រើប្រាស់ការគ្រប់គ្រងហានិភ័យនេះ គេរំពឹងថាភាពញឹកញាប់ និងវិសាលភាពនៃការពិនិត្យមើលខាងរូបសាស្ត្រលើទំនិញនឹងកាន់តែតិចជាងមុន ហើយគេនឹងយល់ដឹងអំពីភាពទុកចិត្តបានទៅលើសវនកម្មជម្រះបញ្ជី ដែលធ្វើជាខាងក្រោយ ។

ចំណុចស្នូលផ្សេងទៀតនៃក្របខ័ណ្ឌ WCO គឺប្រើប្រាស់ឧបករណ៍ស្វែងរក (detection equipment) ដែលមិនមានលក្ខណៈឈ្លានពាន ដើម្បីធ្វើឱ្យការពិនិត្យមើលមានភាពស័ក្តិសិទ្ធិ ។

(ii) បណ្តាតំបន់សេរី

នៅក្នុងជំពូកទី២ នៃឧបសម្ព័ន្ធជាក់លាក់ D អនុសញ្ញាក្យូតូដែលកែប្រែនេះដាក់បញ្ញត្តិថា "តំបន់សេរី" មានន័យជាផ្នែកមួយនៃដែនដីរបស់ភាគីចុះកិច្ចសន្យាម្នាក់ ដែលជាទីកន្លែងដែលគេចាត់ទុកជាទូទៅចំពោះទំនិញណាមួយដែលណែនាំថ្មីត្រឹមតែពន្ធនាំចូល និងពន្ធដារដែលពាក់ព័ន្ធ នៅពេលដែលស្ថិតនៅ ខាងក្រៅដែនដីគយ ។

វាចែងយ៉ាងលំអិតអំពីបទដ្ឋាននានា និងបទដ្ឋានអន្តរកាល សម្រាប់ការអនុញ្ញាតឱ្យទំនិញចូលទៅក្នុង តំបន់សិទ្ធិអំណាចប្រតិបត្តិនៅក្នុងតំបន់ ទំនិញដែលប្រើប្រាស់នៅក្នុងតំបន់ ការផ្ទេរកម្មសិទ្ធិភាព ការយកទំនិញចេញ ការប៉ាន់តម្លៃពន្ធគយនិងពន្ធដារ និងការបិទតំបន់ ។

### (៣) វិធានការបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្របទៅតាមអនុសញ្ញាក្យូតូដែលកែប្រែ

រហូតមកពេលនេះ ពុំមានប្រទេសអាស៊ានដែលបានផ្តល់សច្ចានុម័តិចំពោះអនុសញ្ញាក្យូតូដែលកែប្រែនេះឡើយ រួមទាំងប្រទេសកម្ពុជាផង។ ប៉ុន្តែ នៅក្នុងប្រទេសខ្លះ បានចាប់ផ្តើមការងារសម្រាប់ប្រុងប្រៀបជាស្រេចហើយ។ ប្រទេសថៃ និងម៉ាឡេស៊ីបានចាប់ផ្តើមនីតិវិធីរួចហើយ សម្រាប់ការចូល ហើយប្រទេសថៃមានផែនការផ្តល់សច្ចានុម័តិចំពោះអនុសញ្ញានេះ ត្រឹមចុងខែមិថុនា ឆ្នាំ២០០៦។ ប្រទេសវៀតណាមកំពុងរៀបចំវិសោធនកម្ម ច្បាប់ និងបទបញ្ញត្តិនានា ដើម្បីឆ្លើយតបទៅនឹងការតម្រូវរបស់អនុសញ្ញានេះ។

ទាក់ទងនឹងអនុវត្តន៍ការគ្រប់គ្រងហានិភ័យ ប្រទេសថៃស្ថិតនៅក្នុងដំណាក់កាលជឿនលឿនបំផុត។ វាបានតម្លើងប្រព័ន្ធកុំព្យូទ័ររួចជាស្រេចដែលបច្ចុប្បន្ននេះកំពុងត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យប្រវត្តិរបស់ពាណិជ្ជករ។ គេនិយាយថា ចំនួននៃទិន្នន័យប្រវត្តិបែបនេះបានឈានឡើងដល់ ១០.០០០ ត្រឹមខែតុលា ឆ្នាំ ២០០៦។ នៅប្រទេសអណ្ឌូនេស៊ី ប្រព័ន្ធជម្រះបញ្ជីពន្ធគយដែលបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ ក៏ត្រូវបានបង្កើតឡើងរួចជាស្រេចដែរ ប៉ុន្តែពួកគេមានផលលំបាកខ្លះ ក្នុងការប្រមូលទិន្នន័យប្រវត្តិរបស់ពាណិជ្ជករ។ ប្រទេសម៉ាឡេស៊ីមានមហិច្ឆិតាណាស់ក្នុងការធ្វើឱ្យសម្រេចនូវការគ្រប់គ្រងហានិភ័យក្នុងឆ្នាំ២០០៦។

នៅកម្ពុជា បច្ចុប្បន្ននេះ ១០០% នៃទំនិញទាំងក្នុងនិងក្រៅប្រទេសត្រូវបានត្រួតពិនិត្យមើល ហើយរាជរដ្ឋាភិបាលកម្ពុជាមានផែនការកាត់បន្ថយអត្រានេះឱ្យធ្លាក់ចុះដល់ ៥០% ត្រឹមចុងឆ្នាំ២០០៦ រហូតដល់២៥% ត្រឹមចុងឆ្នាំ២០០៧ និង ៥% ត្រឹមចុងឆ្នាំ២០១០។ ដើម្បីសម្រេចនូវគោលដៅនេះ គេត្រូវតែណែនាំឱ្យស្គាល់នូវប្រព័ន្ធគ្រប់គ្រងហានិភ័យ ដែលផ្អែកលើទិន្នន័យប្រវត្តិរបស់ពាណិជ្ជករ។

ដើម្បីធ្វើឱ្យនីតិវិធីគយមានភាពងាយស្រួល រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តចាប់ផ្តើមពីការណែនាំនូវ "ប្រព័ន្ធគយច្រកតែមួយ" ដែលប្រើប្រាស់ប្រព័ន្ធមួយតាមកុំព្យូទ័រហៅថា "ASYCUDA" ដែលតាមរយៈនេះក្រុមហ៊ុនពាណិជ្ជដាក់សំណុំបែបបទនាំចូល/នាំចេញតែមួយទៅកាន់ CED ហើយបន្ទាប់មកបន្តទៅកាន់ផ្នែករដ្ឋាភិបាលដែលពាក់ព័ន្ធ។ "ASYCUDA" ដែលជាប្រព័ន្ធជម្រះបញ្ជីពន្ធគយដ៏ទូលំទូលាយមួយ ហើយដែលពិត ជាបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យនោះ ត្រូវបានគ្រោងតម្លើង នៅឯទីស្នាក់ការកណ្តាលនៃ CED ត្រឹម ចុងឆ្នាំ២០០៦ ហើយបណ្តាកុំព្យូទ័រនៅនឹងចំណត នឹងត្រូវបានប្រើប្រាស់ក្នុងរវាងពាក់កណ្តាលឆ្នាំ២០០៧ នៅឯចំណុចពាណិជ្ជកម្មធំៗបំផុត ដូចជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ "ASYCUDA" នឹងត្រូវបានប្រើប្រាស់ សម្រាប់ធ្វើឱ្យនីតិវិធីនាំចូល/នាំចេញមានភាពងាយស្រួល នៅពេលចាប់ផ្តើម ហើយត្រូវបានគ្រោងឱ្យប្រើប្រាស់ សម្រាប់គោលបំណងគ្រប់គ្រងហានិភ័យ។ តាមរយៈការណែនាំឱ្យស្គាល់ នូវប្រព័ន្ធនេះ រាជរដ្ឋាភិបាលកម្ពុជារំពឹងថានឹងកាត់បន្ថយបន្ទុកការិយាធិបតេយ្យទៅលើសកម្មភាពពាណិជ្ជ និង ឱកាសប្រព្រឹត្តអំពើពុករលួយ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានប្រកាសរួចហើយថា បែបបទនាំចូល/នាំចេញតែមួយ "ឯកសាររដ្ឋបាលតែមួយ" ត្រូវបានអនុម័តហើយនឹងត្រូវបានប្រើប្រាស់ចាប់ពីខែមីនា ឆ្នាំ២០០៦ ដែលនឹងជាជំហានទីមួយក្នុងការសម្រេច "ប្រព័ន្ធគយច្រកតែមួយ"។ ទាក់ទងនឹងការយកមកប្រើនូវវិធីសាស្ត្រពិនិត្យមើលដែលមិនមានលក្ខណៈឈ្លានពាននេះ គេបានតម្លើងរួចហើយនូវឧបករណ៍ស្វែងរកដោយកាំរស្មីអិក្ស នៅឯទីស្នាក់ការគយ ក្នុងកំពង់ផែ ក្រុងព្រះសីហនុ។

នៅក្នុងប្រការទី ៦-២ នៃជំពូកទី៦ នៅក្នុងឧបសម្ព័ន្ធទូទៅ អនុសញ្ញាក្យូតូដែលកែប្រែថ្មីនេះ កំណត់ថា "ការត្រួតពិនិត្យរបស់គយត្រូវបានដាក់កម្រិតចំពោះកន្លែងណាដែលចាំបាច់ដើម្បីធានានូវភាពអនុលោមទៅតាមច្បាប់គយ"។ នៅក្នុងករណីប្រទេសកម្ពុជា ក្រមគយដ៏ទូលំទូលាយពុំទាន់ត្រូវបានអនុម័តនៅឡើយទេទោះ បីជាពង្រាងត្រូវបានធ្វើហើយអស់រយៈពេលជាយូរកន្លងមកក្តី។ គេតម្រូវឱ្យពិនិត្យមើលលើភាពអនុលោមរបស់
ពង្រាងបញ្ញត្តិនេះ ស្របទៅតាមតម្រូវការរបស់អនុសញ្ញាក្យូតូដែលកែប្រែថ្មីនេះទេ ហើយអនុម័តឱ្យបានឆាប់។

**(៤) ការបង្កើតឡើងថ្មីៗនូវច្រកតែមួយ និងការអនុវត្តនូវអនុសញ្ញាក្យូតូដែលកែប្រែ**

ដើម្បីផ្តល់នូវមូលដ្ឋានច្បាប់ សម្រាប់អនុវត្តវិធីសាស្ត្រគ្រប់គ្រងហានិភ័យនោះ អនុក្រឹត្យស្តីពីការសម្របសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ត្រូវបានចេញរួចហើយ ក្នុងខែមិថុនា ឆ្នាំ២០០៦ ដែលបន្ទាប់មកគឺ "ប្រកាសលេខ ៦០៧ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ស្តីពីការបង្កើត និងការដាក់ឱ្យប្រតិបត្តិនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មលើគយ និងរដ្ឋករ" នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៦ និង "ប្រកាសលេខ ១០១៥ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ស្តីពីការបង្កើតក្រុមសម្របសម្រួលអន្តរទីភ្នាក់ងារ ទៅលើកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ" នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦។

កិច្ចសន្យាទិញនៃ ASYCUDA ត្រូវបានបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ ២០០៦ ហើយការបណ្តុះបណ្តាលបុគ្គលិកនាយកដ្ឋានគយ និងរដ្ឋាករ ទៅលើការគ្រប់គ្រងហានិភ័យ ក៏ត្រូវបានអនុវត្តរួចហើយដែរ នៅក្នុងប្រទេសម៉ាឡេស៊ី។ លើសពីនេះទៅទៀត "ប្រកាសលេខ៦០៧ សហវ ស្តីពីការបង្កើត និងការដាក់ឱ្យប្រតិបត្តិនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មលើគយនិងរដ្ឋាករ" ត្រូវបានចេញក្នុងខែសីហា ឆ្នាំ ២០០៦ ហើយការិយាល័យគ្រប់គ្រងហានិភ័យត្រូវបានបើកនៅក្នុងទីស្នាក់ការគយ និងរដ្ឋាករ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏បានចេញផងដែរនូវ "ប្រកាសលេខ១១៤៦ សហវ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោង ដែលធ្វើស្វ័យប្រវត្តិកម្មលើគយ" នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦ ដើម្បីអនុវត្តគម្រោង។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងត្រៀមចាប់ផ្តើមប្រើប្រាស់ ASYCUDA នៅឯកំពង់ផែក្រុងព្រះសីហនុ ចាប់ពីចុងឆ្នាំ២០០៧។

## ១០.២ ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម

### ១០.២.១ តំបន់សេដ្ឋកិច្ចពិសេស

ចាប់ពីខែមករា ឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តជាផ្លូវការ នូវតំបន់សេដ្ឋកិច្ចពិសេសចំនួន ៧ (តំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ តំបន់សេដ្ឋកិច្ចពិសេសឆាយឆាយអូនាង តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ តំបន់សេដ្ឋកិច្ចពិសេសដូងឈើវ៉ន្តាំងដិន តំបន់សេដ្ឋកិច្ចពិសេសកំពត និង តំបន់សេដ្ឋកិច្ចពិសេសម៉ានហាតាន់) តាមរយៈអនុក្រិតស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងតំបន់សេដ្ឋកិច្ចពិសេសចំនួន ៧ទៀតក៏បានទទួលអាជ្ញាប័ណ្ណពី គ.ស.ព ផងដែរ។ តំបន់សេដ្ឋកិច្ចពិសេសដែលអនុញ្ញាតិនាពេលបច្ចុប្បន្ននេះនៅប្រទេសកម្ពុជា ត្រូវបានបង្ហាញនៅក្នុងតារាង ១០-២-១។ SEZ តៃសេងបាវិត, SEZ ឧកញ៉ាម៉ុង និង SEZ កំពង់ចាម ក៏បានដាក់ពាក្យសុំការអនុម័តពី គ.ស.ព ផងដែរ។

ក្នុងចំនោមតំបន់ទាំងនេះ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានចាប់ផ្តើមអនុវត្តគម្រោង នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ហើយរំពឹងថា នឹងអាចបញ្ចប់គម្រោងដំណាក់កាលទីមួយ ត្រឹមចុងឆ្នាំ២០០៧ ហើយតំបន់សេដ្ឋកិច្ចមេនហាតាន់ក៏មាន វិនិយោគិនពារូបរួចហើយដែរ ដែលកំពុងប្រតិបត្តិនៅក្នុងតំបន់នេះ។

**តារាង ១០-២-១ តំបន់សេដ្ឋកិច្ចពិសេសដែលបានអនុម័តរបស់ប្រទេសកម្ពុជា គិតត្រឹមខែមករា ឆ្នាំ២០០៧**

| Name of the SEZ | Description |
|---|---|
| **1. Koh Kong SEZ** | |
| Location | Neang Kok Village, Pakkhlong Commune, Mundul Seyma District, Koh Kong Province |
| Area | 336.24 ha. |
| Project Implementation | Fences have already been built. |
| **2. Suoy Chheng SEZ** | |
| Location | Neang Kok Village, Pakkhlong Commune, Mundul Seyma Destrict, Koh Kong Province |
| Area | 100 ha. |
| Project Implementation | n.a. |
| **3. S.N.C SEZ** | |
| Location | Sangkat Bet Trang, Prey Nob District, Sihanoukville City |
| Space | 150 ha. |
| Project Implementation | Not yet implemented |
| **4. Stung Hao SEZ** | |
| Location | Sangkat O Tres, Stung Hav District, Sihanoukville |
| Area | 192 ha. |
| Project Implementation | n.a. |
| **5. N.L.C. SEZ** | |
| Location | Prey Phdao and Thhlok Village, Chrok Mates Commune, Sray Teals District, Sray Rieng Province |
| Area | 105 ha. |
| Project Implementation | The company has built a road 20m long and 8m wide. |
| **6. Manhattan SEZ** | |
| Location | Bavit and Bati Commune, Chantrea District, Sray Rieng Province |
| Area | 157 ha. |

| | |
|---|---|
| Project Implementation | 1) The company has already built infrastructure: connecting power grid from Vietnam and fencing of the first phase of 70 ha.<br>2) To date, there are three investment companies.<br>- Best Way Industry Co., Ltd.(Taiwan): Bicycle production with 350 workers with a plan to increase to 1,000 workers<br>- S.Y.G. Steel International Co., Ltd. (Taiwan): Screw production with 108 workers.<br>- Kingmaker, shoes factory, was inaugurated in late July 2006 and is under construction.<br>3) 14 governmental officials from the CSEZB, the Customs and Excise Department, Ministry of Commerce, CAMCONTROL, and the Labor and Vocational Training Department providing one-stop service for paperwork are stationed at the SEZ Administration Office. |
| **7. Chhay Chhay O'Neang SEZ** | |
| Location | Poipet Commune and Nimit Commune, O Chhrov District, Banteay Meanchey Province |
| Area | 467 ha. |
| Project Implementation | 1) Has built sub-base for highway, 18km long & 50m wide, from Kon Damrey village, NR No.5 through Industrial Zone to Dry Port and business zone and to Thai border. The company plans to pave the road to a width of 20m.<br>2) Reclaiming the whole site and port, and building infrastructure<br>3) Has been building fences and administrative buildings<br>4) Has negotiated with H.E. Kok An of Amco Company to buy electricity for supplying the industrial zone. |
| **8. Doung Chhiv Phnom Den SEZ** | |
| Location | Kiri Vong District, Takeo Province |
| Area | 79 ha. |
| Project Implementation | By the end of 2006 |
| **9. Phnom Penh SEZ** | |
| Location | Khan Dangkao, Phnom Penh and Ang Snuol District, Kandal Province (8 km from Phnom Penh International Airport on NR 4) |
| Area | 353 ha. |
| Project Implementation | The first phase to be completed by the end of 2007 |
| **10. Kampot SEZ** | |
| Location | Koh Toch commune, Kampot district, Kampot Province |
| Area | 145 ha. |
| Project Implementation | 4 phases from May 2005 to October 2010 |
| **11. Sihanoukville SEZ** | |
| Location | Stung Hav District, Sihanoukville City |
| Area | 178 ha. |
| Project Implementation | First phase construction: reclaiming the land and fencing, from 2006 – May 2007 |
| **12. Tai Seng Bavet SEZ** | |
| Location | Bavet District, Svay Rieng Province |
| Area | 99 ha. |
| Project Implementation | n.a. |
| **13. Oknha Mong SEZ** | |
| Location | Srea Ambel District, Koh Kong Province |
| Area | 100 ha. |
| Project Implementation | n.a. |
| **14. Goldfame Pak Shun SEZ** | |
| Location | Sa Ang District, Kandal Province |
| Area | 80 ha. |
| Project Implementation | n.a. |

Source: Compiled by the JICA Study Team basing on the Project Implementation Sheets prepared by the CDC

## ១០.២.២ អគ្គិសនី

### (១) ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធអគ្គីសនីនៅកម្ពុជា

នៅក្នុងប្រទេសកម្ពុជា ច្បាប់អគ្គិសនីត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០១ ដែលបន្ទាប់មក មានការចេញអនុក្រិត្យជាច្រើន ដើម្បីចែងអំពីវិស័យថាមពល ហើយអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ត្រូវបានបង្កើតឡើង ជានីតិបុគ្គលសាធារណៈមួយ ដើម្បីដើរតួជានិយ័តករ និងជាអាជ្ញាកណ្តាល ក្នុងសកម្មភាពធុរកិច្ចវិស័យថាមពល។

យុទ្ធសាស្ត្រវិស័យថាមពលកម្ពុជា គឺកសាងខ្សែចម្លងចរន្ត ដើម្បីភ្ជាប់ទីប្រជុំជនធំៗនៃតំបន់ពីរ (ដែលតំបន់ប៉ែក ខាងត្បូងរួមមាន ទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត និងក្រុងព្រះសីហនុ និងតំបន់ ប៉ែកខាងលិចរួមមាន ខេត្តបន្ទាយមានជ័យ បាត់សំបង និងសៀមរាប) ដើម្បីនាំចូលថាមពលអគ្គិសនីពីប្រទេស ជិតខាង ក្នុងអំឡុងពេលកសាង និងដើម្បីបង្កើតរោងចក្រថាមពលអគ្គិសនីខ្នាតធំ ដែលមានការចំណាយទាបលើ ការបង្កើតថាមពល។

អគ្គិសនីនៅកម្ពុជា ត្រូវបានបង្កើតឡើង និង/ឬបែងចែកដោយស្ថាប័នខាងក្រោម :

(i) ក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ដែលជាសហគ្រាសរដ្ឋ

(ii) ស្ថាប័នឯកជននានាដូចជា ក្រុមហ៊ុនផលិតថាមពលអគ្គិសនីឯករាជ្យ (IPP) នៅតាមទីរួមខេត្តនានា

(iii) អ្នកទទួលបានអាជ្ញាប័ណ្ណនៅតាមទីប្រជុំជនតូចៗ និង

(iv) សហគ្រាសអគ្គិសនីជនបទ ១ព្រៃវែង នៅក្នុងតំបន់ជនបទ។

EDC មានអាជ្ញាប័ណ្ណមួយដែលរួមចូលគ្នា (ទាំងការផលិត និងការបែងចែក) ក្នុងការផ្គត់ផ្គង់អគ្គិសនី នៅភ្នំពេញ ក្រុងព្រះសីហនុ សៀមរាប កំពង់ចាម តាកែវ និងបាត់ដំបង។ សម្រាប់តំបន់ខាងត្បូង កិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី (PPA) ត្រូវបានចុះហត្ថលេខា ដើម្បីនាំចូលថាមពលអគ្គិសនីពីប្រទេសវៀតណាម។ កិច្ចព្រមព្រៀងមួយទៀតសម្រាប់ ឥណទានពីធនាគារពិភពលោក (WB) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏ ត្រូវបានចុះហត្ថលេខា ដើម្បីកសាងបណ្តាញ ផ្ទេរថាមពលពីភ្នំពេញទៅតាកែវ និងទៅកាន់វៀតណាម រួមទាំង ការអភិវឌ្ឍអគ្គិសនីកម្មជនបទ នៅតំបន់នេះ។ គេរំពឹងថា ការនាំចូលថាមពលអគ្គិសនីក្នុងបរិមាណដ៏ធំសម្បើម ពីប្រទេសវៀតណាម នឹងចាប់ផ្តើម ត្រឹមចុងឆ្នាំ២០០៧។ គេរំពឹងថា ប្រទេសកម្ពុជា នឹងនាំចូលថាមពលអគ្គិសនី ចំនួន៨០មេហ្គាវ៉ាត់ ពីប្រទេសវៀតណាមក្នុងរយៈពេលពីរឆ្នាំដំបូង ហើយនឹង បង្កើនរហូតដល់ ២០០មេហ្គាវ៉ាត់ ចាប់ពីឆ្នាំទីបីទៅ។

សម្រាប់តំបន់ប៉ែកខាងជើងវិញ PPA សម្រាប់ការនាំចូលនូវថាមពលអគ្គិសនីពីប្រទេសថៃត្រូវបានចុះហត្ថលេខា។ កិច្ចព្រមព្រៀងវិនិយោគជាមួយក្រុមហ៊ុន ASK ត្រូវបានចុះហត្ថលេខាផងដែរ ដើម្បីកសាងបណ្តាញផ្ទេរថាមពលអគ្គិសនី ពីព្រំដែនថៃ ទៅទីរួមខេត្តចំនួនបី។ កម្ពុជាអាចនាំចូលថាមពលអគ្គិសនីជាច្រើនមេហ្គាវ៉ាត់ ពីប្រទេសថៃត្រឹមឆ្នាំ២០០៧។ ការកសាងបន្ថែមនូវបណ្តាញផ្ទេរចរន្តអគ្គិសនី ពីទីរួមខេត្តបាត់ដំបង ទៅកាន់តំបន់ដែលនៅជុំវិញ ក្នុងចម្ងាយ៤០គម នឹងត្រូវ

បានធ្វើឡើង ដោយប្រាក់កំចីពីធនាគារពិភពលោក។ ប្រព័ន្ធថាមពលបច្ចុប្បន្ន នៅកម្ពុជា រួមមានប្រព័ន្ធដែលនៅដាច់ដោយឡែកជាច្រើន ដែលផ្តល់ដោយអ្នកទទួលបានអាជ្ញាប័ណ្ណផ្សេងៗគ្នា។ អាជ្ញាប័ណ្ណនៅតាមទីប្រជុំជនតូចៗ ដែលនៅជិតព្រំដែនគឺជាវថាមពលអគ្គិសនីពីប្រទេសជិតខាង ដើម្បីផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់ នៅក្នុងប្រទេសកម្ពុជា រីឯអ្នកទទួលបានអាជ្ញាប័ណ្ណនៅតំបន់ផ្សេងទៀត មានម៉ាស៊ីនភ្លើងរបស់ខ្លួន ដែលប្រព័ន្ធថាមពលអគ្គិសនីនៅទីក្រុងភ្នំពេញ ទទួលបានការផ្គត់ផ្គង់ពីសហគ្រាសរដ្ឋ ដែលធំជាងគេមួយឈ្មោះថាអគ្គិសនីកម្ពុជា (EDC)។ អគ្គិសនីកម្ពុជាតែមួយអាចផ្គង់ផ្គង់ថាមពលអគ្គិសនីបាន ២៦.៥%នៃការផ្គត់ផ្គង់អគ្គិសនីសរុបក្នុងឆ្នាំ២០០៥ ហើយ ៧១.១%ទៀត ផ្គត់ផ្គង់ដោយក្រុមហ៊ុនផលិតថាមពលអគ្គិសនីឯករាជ្យ និង ២.៤% ត្រូវបានផ្គត់ផ្គង់ដោយអ្នកទទួលបានអាជ្ញាប័ណ្ណរួម ចំនួន១០០ ក្នុងឆ្នាំ២០០៥។ ក្នុងចំណោមការផលិតអគ្គិសនីសរុបដោយ EDC មាន ៩៤.៦% ឬ ២៣៣លានគីឡូវ៉ាត់ម៉ោង ត្រូវបានបញ្ជូន ដោយប្រើប្រាស់បន្ថែម ៥.៤% ឬ ១៣លានគីឡូវ៉ាត់ម៉ោង។

ប្រព័ន្ធថាមពលនៅកម្ពុជា គឺថា IPP ដែលកំពុងផលិតអគ្គិសនី នៅក្នុងតំបន់ភ្នំពេញ លក់អគ្គិសនី ក្នុងតម្លៃខុសៗគ្នា ទៅតាមតម្លៃប្រេងឥន្ធនៈ ទៅឱ្យរដ្ឋាភិបាល (ពោលគឺ EDC) ដែលជាអ្នកផ្គត់ផ្គង់វិញទៅឱ្យអ្នក ប្រើប្រាស់នៅក្នុងតំបន់ជុំវិញភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ IPP ដែលកំពុងផលិតនៅតាមខេត្តនានា និង IPP ដែលកំពុងបែងចែកអគ្គិសនីដែលនាំចូលពីប្រទេសជិតខាង លក់អគ្គិសនីដោយផ្ទាល់ទៅឱ្យអ្នកប្រើប្រាស់។

**តារាង ១០-២-២ ក្រុមហ៊ុនផលិតថាមពលឯករាជ្យ (IPP) នៅកម្ពុជា**

| ក្រុមហ៊ុនផលិតថាមពលឯករាជ្យ | ប្រភពនៃការវិនិយោគ | តំបន់ផ្គត់ផ្គង់ |
|---|---|---|
| CETIC International Hydropower Development Co., Ltd. | ប្រទេសចិន | ភ្នំពេញ និងកំពង់ស្ពឺ |
| Cambodia Utilities Pte. Ltd. (CUPL) | ម៉ាឡេស៊ី | ភ្នំពេញ |
| Jupiter Power (Cambodia) Co., Ltd. (គ្មានទៀតទេ) * | អាមេរិច | ភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង |
| Khmer Electric Power Ltd. (KEP) | កម្ពុជា | ភ្នំពេញ |
| Cambodia Electricity Private (CEP) | កម្ពុជា | ភ្នំពេញ |
| City power | កម្ពុជា | ភ្នំពេញ |
| Colben System Pte Ltd (Colben) | សិង្ហបុរី | ភ្នំពេញ ក្រុងព្រះសីហនុ |
| IPPថ្មី ដែលជាសាខារបស់ City power | កម្ពុជា | ពោធិ៍សាត់ |

សម្គាល់: ការពន្យារអាជ្ញាប័ណ្ណប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន Jupiter នៅកម្ពុជា នឹងបញ្ចប់ ក្នុងឆ្នាំ២០០៦។
ប្រភព : អាជ្ញាធរអគ្គិសនីកម្ពុជា

**តារាង ១០-២-៣ ក្រុមហ៊ុននាំចូលថាមពលអគ្គិសនី នៅកម្ពុជា**

| ក្រុមហ៊ុននាំចូលថាមពលអគ្គិសនី | នាំចូលពី | តំបន់ផ្គត់ផ្គង់ |
|---|---|---|
| Franasie Import Export Co., Ltd. | ថៃ | កំរៀង ភ្នំព្រឹក សំពៅលូន |
| MSP Development Co., Ltd. | ថៃ | ភូមិផ្សារព្រំ |
| Anco Brothers Co., Ltd. | ថៃ | ប៉ោយប៉ែត |
| Duty Free Shop Co., Ltd. (DFS) | ថៃ | កោះកុង ទីប្រជុំជនអូស្មាច់ |
| Electricite du Cambodge (EDC) | វៀតណាម | ស្រុកពញាក្រែក មេមត់ បាវិត កំពង់ត្រាច |

ប្រភព : ក្រុមសិក្សាចៃកា

គិតត្រឹមឆ្នាំ២០០៥ អគ្គិសនីនៅកម្ពុជាតាមប្រភព ត្រូវបានផ្គត់ផ្គង់ដោយរោងចក្រវារីអគ្គិសនី២ (មួយ នៅគីរីរម្យដែលភ្ជាប់ទៅភ្នំពេញតាមរយៈប្រព័ន្ធថាមពលខេត្តកំពង់ស្ពឺ និងមួយទៀតនៅរតនៈគីរីដែលភ្ជាប់ទៅថាមពលអគ្គិសនីនៅខេត្តរតនៈគីរីរបស់ EDC) និងដោយរោងចក្រថាមពលម៉ាស៊ូតជាច្រើន ដែលប្រើ HFO ឬ LDO។ រោងចក្រវារីអគ្គិសនីទាំង២នេះ ផ្គត់ផ្គង់ថាមពលអគ្គិសនី ចំនួន ៤៣.៥៤២លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ៥% នៃការផ្គត់ផ្គង់ថាមពលអគ្គិសនីសរុប នៅកម្ពុជា ហើយថាមពលចំហុយដែលដុតដោយ HFO ផ្គត់ផ្គង់ចំនួន ២៨.៣៨៥លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ៣.២% នៃការផ្គត់ផ្គង់សរុប ហើយម៉ាស៊ីនភ្លើងដែលដើរដោយប្រេងម៉ាស៊ូត ឬ HFO ផ្គត់ផ្គង់ចំនួន ៨០៧.៣២៥ លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ៩១.៨% គិតត្រឹមឆ្នាំ២០០៥។

តម្លៃអគ្គិសនីដែលយកដោយ IPPs គឺថ្លៃណាស់ បើធៀបនឹងបទដ្ឋានអន្តរជាតិ។ តម្លៃជាមធ្យមនៅក្នុងឆ្នាំ២០០៥ ទាំងមូល ដែលយកដោយពួកគេ គឺរវាង០.១៧ដុល្លា ក្នុងមួយគីឡូវ៉ាត់ម៉ោង។ ក្រុមហ៊ុនផ្គត់ផ្គង់ខ្លះទៀត ដូចជាក្រុមហ៊ុន Jupiter នៅខេត្តកំពង់ឆ្នាំង យកថ្លៃរហូតដល់ទៅជាង ០.២០ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង។ បើប្រៀបធៀបនឹងតម្លៃអគ្គិសនី ក្នុងចំណោមប្រទេសផ្សេងៗខាងក្រោម គេរកឃើញថាតម្លៃនេះនៅ កម្ពុជា គឺមានកម្រិតខ្ពស់បំផុតដែលមានភាពគួរឱ្យទុកចិត្តបានក្នុងកម្រិតទាប។

**តារាង ១០-២-៤ តម្លៃថាមពលអគ្គិសនី សម្រាប់ឧស្សាហកម្ម (ក្នុង១គីឡូវ៉ាត់ម៉ោង)**

| ទីក្រុង | ហាណូយ | បាងកក | កួឡាឡាំពួរ | ហ្សាការតា | សិង្ហបូរី | ភ្នំពេញ | ក្រុងព្រះសីហនុ |
|---|---|---|---|---|---|---|---|
| តម្លៃ (ជាដុល្លារ) | 0,0៧ | 0,0៤ | 0,0៥ | 0,0៤ | 0,0៧ | 0,១២-0,១៥ | 0,១៣៥-0,១៧៥ |

សម្គាល់ : គិតត្រឹមឆ្នាំ២00៥

ប្រភព : ក្រុមសិក្សារបស់ JICA

ក្រៅពីប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីទាំងបីខាងលើដែលបង្កើតនៅក្នុងប្រទេសនេះកម្ពុជាក៏បាននាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង ដែលនោះគឺប្រទេសថៃ និងវៀតណាម។ គិតត្រឹមឆ្នាំ២00៥ កម្ពុជាបាន នាំចូលថាមពលអគ្គិសនីចំនួន ៥៦.៨៣៨ លានគីឡូវ៉ាត់ម៉ោងពីប្រទេសថៃ និងជាង ២៥.៤0៧លានគីឡូវ៉ាត់ម៉ោង ពីវៀតណាម។ គិតត្រឹមឆ្នាំ២00៥នេះ តម្លៃថាមពលអគ្គិសនីដែលនាំចូលពីប្រទេសថៃ ខុសគ្នា គឺចាប់ពី 0.0៦0 ទៅ 0.0៧៧ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង រីឯតម្លៃថាមពលអគ្គិសនីដែលនាំចូលពីវៀតណាម គឺថេរ ដែលស្មើ នឹង 0.0៦៩ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង។ បើទោះជាកម្ពុជាអាចផ្គត់ផ្គង់ថាមពលអគ្គិសនីចំនួន ៦៤២លាន គីឡូវ៉ាត់ម៉ោងដោយខ្លួនឯង និង ៥៧លានគីឡូវ៉ាត់ម៉ោងទៀត នាំចូលពីប្រទេសជិតខាងក៏ដោយ ក៏ប្រទេសនេះ នៅតែមិនអាចផ្គត់ផ្គង់ថាមពលអគ្គិសនីបានគ្រប់គ្រាន់ សម្រាប់ប្រជាពលរដ្ឋខ្លួននៅឡើយទេ ជាពិសេសនៅតាម តំបន់ជនបទ។

**រូបភាព ១០-២-១ ការផលិត និងការនាំចូលថាមពលអគ្គិសនីសរុប**




ប្រភព: អាជ្ញាធរអគ្គិសនីកម្ពុជា

នៅតាមតំបន់ក្រៅក្រុងជាច្រើន នៅមិនទាន់អាចទទួលបានសេវាកម្មផ្គត់ផ្គង់ថាមពលអគ្គិសនីបាន ២៤ម៉ោងនៅ

ឡើយទេ។ ហើយសូម្បីតែនៅម៉ោងផ្គត់ផ្គង់ធម្មតា ក៏មិនអាចទុកចិត្តបានដែរ។ ជាមួយនិងកម្រិត បច្ចុប្បន្ននៃការផ្គត់ផ្គង់ និងគុណភាព គឺវាមិនគ្រប់គ្រាន់ទេ ក្នុងការឆ្លើយតបទៅនឹងតម្រូវការអគ្គិសនី សម្រាប់តំបន់សេដ្ឋកិច្ចពិសេស (SEZ)។ នៅពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្ទេរចរន្តអគ្គិសនីចប់តាមគម្រោង ហើយរោងចក្រវារីអគ្គិសនីដែលធំជាងគេ ដែលមានសមត្ថភាពដល់ទៅ ១៩៣.២មេហ្គាវ៉ាត់ នៅកំចាយ បានបញ្ចប់ហើយនោះ ទើបគេអាចធានាបាននូវការផ្គត់ផ្គង់ថាមពលអគ្គិសនី។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានឹងនៅតែពឹងផ្អែកលើការផ្គត់ផ្គង់ថាមពលអគ្គិសនីពីប្រទេសជិតខាង ដូចជាថៃ វៀតណាម និងក្រោយមកពីឡាវ ដើម្បីអាចបំពេញតម្រូវការដែលចេះតែកើនឡើង នាពេលអនាគត។

**(២) ហេដ្ឋារចនាសម្ព័ន្ធនិងការផ្គត់ផ្គង់អគ្គិសនី នៅជុំវិញតំបន់សេដ្ឋកិច្ចពិសេស ក្នុងប្រទេសកម្ពុជា**

នៅក្នុងចំណោម SEZ ជាច្រើន SEZ ក្រុងព្រះសីហនុ, SEZ ភ្នំពេញ និង SEZ ម៉ាហាតាន់ (ខេត្តស្វាយរៀង) កំពុងត្រូវបានអភិវឌ្ឍ និងឃើញថានឹងកាន់តែមានជោគជ័យនៅពេលនេះ។ ដូច្នេះអត្ថបទនេះ ផ្តោតលើ SEZ ទាំងនេះនៅកម្ពុជា។ ទាក់ទងនឹងការផ្គត់ផ្គង់អគ្គិសនីទៅកាន់ SEZ ទាំងនេះមានមធ្យោបាយ ដែលពួកគេអាចទទួលបានការផ្គត់ផ្គង់អគ្គិសនី ដោយអាស្រ័យលើទីកន្លែងដែលពួកវាស្ថិតនៅនិងដែល :

(i) ថាមពលអគ្គិសនីកំពុងត្រូវបានផ្គត់ផ្គង់ដោយ EDC ឬមួយដោយ IPP (តាមរយៈ EDC ក្នុងទីក្រុងភ្នំពេញ

(ii) ថាមពលអគ្គិសនីដែលផ្គត់ផ្គង់ដោយប្រទេសថៃ ឬមួយដោយវៀតណាម អាស្រ័យលើទីតាំងនៃ SEZ និង

(iii) ថាមពលអគ្គិសនីដែលផលិតដោយរោងចក្រអគ្គិសនីដែលកសាងដោយខ្សែក នៃ SEZ នីមួយៗ

គេកត់សម្គាល់ថា ការផ្គត់ផ្គង់អគ្គិសនីរបស់ EDC បច្ចុប្បន្ននេះ ទៅជាមានតម្លៃទាបជាង បើធៀបនឹងអគ្គិសនីដែលផលិតដោយម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន។ ពីព្រោះតែម៉ាស៊ីនភ្លើងរបស់ឧស្សាហកម្មភាគច្រើនដើរដោយប្រេងម៉ាស៊ូតដែលមានចំហេះខ្លាំង ដែលតម្លៃរបស់វាកំពុងកើនឡើងនោះ វានឹងកាន់តែសន្សំសំចៃច្រើនក្នុងការប្រើប្រាស់ម៉ាស៊ីនភ្លើងផ្ទាល់ខ្លួនដែលដើរដោយប្រេងឥន្ធនៈធ្ងន់ (Heavy Fuel Oil) ដែលនឹងចំណាយអស់ត្រឹមតែ 0.១៣ដុល្លារ ប៉ុណ្ណោះ ក្នុងមួយគីឡូវ៉ាតម៉ោង ថ្វីបើការបំពាក់ម៉ាស៊ីននេះចំណាយទុនច្រើនក៏ដោយ។ បច្ចុប្បន្ននេះ SEZ ភាគច្រើននៅកម្ពុជា ទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅមានកម្រិត ដោយនាំទៅរក ស្ថានភាពមួយដែលទាមទារឱ្យមានការផលិតថាមពលអគ្គិសនី ដែលអាចទុកចិត្តបាន ហើយដែលចាំបាច់ សម្រាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្ម នៅតាមតំបន់នីមួយៗ ព្រោះថាវានឹងចំណាយពេលច្រើនឆ្នាំដើម្បីទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីដោយផ្ទាល់ពី EDC បានគ្រប់គ្រាន់។ ហេតុដូច្នេះហើយ វាគឺជា "ការចាំបាច់បំផុត" សម្រាប់ SEZ នីមួយៗ ក្នុងការបង្កើត IPP ដោយផ្ទាល់ខ្លួន ដើម្បីផ្តល់ដល់បណ្តាឧស្សាហកម្មក្នុងតំបន់នេះ។ វានឹងមិនអាចសម្រេចបានប្រាក់ចំណេញទេ ពេលដំបូងនោះ បើគ្រាន់តែផ្គត់ផ្គង់ទៅឱ្យបណ្តាឧស្សាហកម្មតូចៗមួយចំនួន នៅក្នុង SEZ។ ទោះយ៉ាងណាក៏ដោយ គេអាចដោះស្រាយបញ្ហានេះបាន ដោយផ្គត់ផ្គង់ថាមពលអគ្គិសនីទៅ ឱ្យទាំងបណ្តាឧស្សាហកម្មក្នុងតំបន់ និង EDC (នៅពេល EDC អាចទទួលការផ្គត់ផ្គង់បាន) ឬទៅឱ្យអ្នកប្រើប្រាស់ចុងក្រោយ។ រូបភាព

១០-២-២ បង្ហាញពីប្រព័ន្ធចែកចាយដែលមានស្រាប់ និងប្រព័ន្ធដែលអាចនឹងមាន របស់ IPP ក្នុង SEZ ។

**រូបភាព ១០-២-២ ប្រព័ន្ធចែកចាយដែលមានស្រាប់ និងប្រព័ន្ធដែលអាចនឹងកើតមានរបស់ក្រុមហ៊ុនផលិតថាមពលឯករាជ្យនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស**

**(ក) ប្រព័ន្ធចែកចាយដែលមានស្រាប់ នៅក្នុងតំបន់ជុំវិញទីក្រុងភ្នំពេញ**




**(ខ) ប្រព័ន្ធចែកចាយដែលមានស្រាប់ នៅក្នុងតំបន់ផ្សេងទៀតដែលគ្មានបណ្តាញរបស់អគ្គិសនីកម្ពុជា**




**(គ) ប្រព័ន្ធចែកចាយដែលអាចនឹងមាន នៅក្នុង SEZ ដែលគ្មានបណ្តាញរបស់អគ្គិសនីកម្ពុជា**




**(ឃ) ប្រព័ន្ធចែកចាយដែលអាចនឹងមាន នៅក្នុង SEZ ដែលអាចមានបណ្តាញរបស់អគ្គិសនីកម្ពុជា**




ប្រភព : ក្រុមសិក្សា JICA

គេកត់សម្គាល់ថា IPP ដែលបង្កើតនៅក្នុង SEZ អាចលក់ថាមពលអគ្គិសនីដែលនៅសេសសល់ទៅឱ្យ EDC ហើយទៅឱ្យអ្នកប្រើប្រាស់នៅក្រៅតំបន់។ ទោះយ៉ាងណាក៏ដោយ វាកាន់តែសន្សំសំចៃសម្រាប់ SEZ ដែលនៅជុំវិញតំបន់ព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ក្នុងការនាំចូលអគ្គិសនីដោយផ្ទាល់ ពីប្រទេសជិតខាង និងយល់ព្រមចំពោះប្រព័ន្ធចែកចាយ ដូចបានបង្ហាញនៅក្នុងរូបភាព១០-២-២ ខាងលើ។

ចំពោះករណីតំបន់ព្រំដែនកម្ពុជា-ថៃ វាកាន់តែសាមញ្ញដែលថាអាជ្ញាធរអគ្គិសនីខេត្តខាងភាគីកម្ពុជា អាចចរចារជាមួយអាជ្ញាធរខេត្តរបស់ភាគីថៃ ហើយ IPP អាចចាប់ផ្ដើមនាំចូលថាមពលអគ្គិសនី តាមចំនួនដែលត្រូវការ នៅពេលវាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីជាមួយ EDC។ ទោះយ៉ាងណាក៏ដោយ ដោយសារតែ EDC ខ្លួនឯង កំពុងនាំចូលថាមពលអគ្គិសនីពីប្រទេសវៀតណាមនោះ មានដំណាក់កាលជាច្រើនទៀតដែលពាក់ព័ន្ធនឹងការនាំចូលថាមពលអគ្គិសនីពីវៀតណាម ដូចដែលបានបង្ហាញខាងក្រោម។

**(៣) ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទៅឱ្យ SEZ ភ្នំពេញ**

ដោយសារវាស្ថិតនៅជុំវិញទីក្រុងភ្នំពេញ និងខេត្តកណ្ដាល ការផ្គត់ផ្គង់អគ្គិសនីគឺមិនមែនជាបញ្ហាធំ នោះទេ តែទោះយ៉ាងណាក៏ដោយ ការផ្ទេរចរន្តអគ្គិសនីទៅកាន់តំបន់ជាក់លាក់នេះគួរតែត្រូវបានដោះស្រាយ។ **EDC** ជាអ្នកផ្គត់ផ្គង់អគ្គិសនីភាគច្រើន នៅទីក្រុងភ្នំពេញ។ កន្លែងជាច្រើនដូចជាភូមិបាក់ខែង ភូមិខ្វរ សង្កាត់ព្រែកលាប ខ័ណ្ឌឬស្សីកែវ ត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយក្រុមហ៊ុនតូចៗផ្សេងទៀត ដែលទទួលបានអាជ្ញាប័ណ្ណរួមគ្នា រីឯអគ្គិសនីនៅខេត្តកណ្ដាលទទួលការផ្គត់ផ្គង់ភាគច្រើនពី **EDC**។ អគ្គិសនីនៅតាមបណ្ដាខណ្ឌផ្សេងៗទៀត ទទួលការផ្គត់ផ្គង់ពីក្រុមហ៊ុនមានអាជ្ញាប័ណ្ណរួម ចំនួន១៧ គិតត្រឹមឆ្នាំ២០០៥។ **EDC** បានផ្គត់ផ្គង់ដល់ អតិថិជនឧស្សាហកម្មចំនួន ៧០១កន្លែង ក្នុងទីក្រុងភ្នំពេញ គិតត្រឹមឆ្នាំ២០០៤ ក្នុងតម្លៃខុសៗគ្នា ពី៤៨០ ទៅ ៦០០រៀល (០.១២-០.១៥ដុល្លារ) ក្នុងមួយគីឡូវ៉ាត់ម៉ោង ដោយ

អាស្រ័យលើការប្រើប្រាស់។ **IPP** ភាគច្រើន ស្ថិតនៅភ្នំពេញ ហើយពួកគេលក់ថាមពលអគ្គិសនីទៅឱ្យ **EDC** ដែលជាអ្នកផ្គត់ផ្គង់វិញទៅឱ្យអ្នកប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ **IPP** ដែលស្ថិតនៅខាងក្រៅទីក្រុងភ្នំពេញផ្គត់ផ្គង់អគ្គិសនីដោយផ្ទាល់ដល់អ្នកប្រើប្រាស់។ កាលពីពេលថ្មីៗនេះ ក្រុមហ៊ុន **Asiatic Group (Holdings) Limited** បានប្រកាសថាសាខារបស់ខ្លួន គឺក្រុមហ៊ុន **Colben Sytem Pte Ltd (Colben)** បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ដើម្បីផ្គត់ផ្គង់ថាមពលផ្តាច់មុខទៅឱ្យសាជីវកម្មអភិវឌ្ឍន៍កម្ពុជា-ជប៉ុន **(JCDC)** សម្រាប់ការអភិវឌ្ឍ **SEZ** ភ្នំពេញ នៅពេលក្រោយមក។ ស្ថិតក្រោមលក្ខខណ្ឌនៃអនុស្សារណៈយោគយល់គ្នានេះ ក្រុមហ៊ុន **Colben** នឹងបង្កើតរោងចក្រផលិតថាមពលអគ្គិសនី ដែលមានសមត្ថភាពដំបូង ១០មេហ្គាវ៉ាត់ ដោយផែតកលើមូលដ្ឋានកសាង- ធ្វើជាម្ចាស់-ប្រតិបត្តិ **(BOO)** ដើម្បីផ្តល់ដល់ការអភិវឌ្ឍដំណាក់កាលទីមួយ លើផ្ទៃដី១៤០ហិចតា នៃផ្ទៃដី **SEZ** ចំនួន៣៦៥ហិចតា។ ជាការតបស្នងវិញ **JCDC** នឹងទិញអគ្គិសនី ពីរោងចក្រនេះ ដើម្បីចែកចាយទៅកាន់ **SEZ**។ គេរំពឹងថាគម្រោងដំបូង និងការចំណាយវិនិយោគសម្រាប់រោងចក្រថាមពលនេះ គឺតិចជាង៨លាន ដុល្លារ បន្ទាប់ពីគិតពីការចំណាយអភិវឌ្ឍន៍ ការផ្តល់ហិរញ្ញប្បទាន ការគូសគ្រោង វិស្វកម្ម និង ការសាងសង់។

បច្ចុប្បន្ននេះ SEZ ក្រុងភ្នំពេញ មិនអាចទទួលបានការផ្គត់ផ្គង់អគ្គិសនី ពី EDC ទេ ដោយសារតែគ្មាន បណ្តាញផ្ទេរចរន្តទៅកាន់តំបន់នេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ SEZ ភ្នំពេញ នឹងអាចទទួលការផ្គត់ផ្គង់ពីរោងចក្រថាមពលរបស់ក្រុមហ៊ុន Colben ដែលនឹងត្រូវបានសាងសង់ថ្មី ដោយផែតកលើមូលដ្ឋានកសាងធ្វើជា ម្ចាស់ប្រតិបត្តិ (BOO). ដូច្នេះការផ្គត់ផ្គង់អគ្គិសនីតាមតម្រូវការ សម្រាប់ SEZ នេះ នឹងអាចធានាបាន បើ មិនច្រើន ក៏នៅក្នុងកម្រិតណាមួយដែរ។ គួរកត់សំគាល់ដែរថា ក្រុមហ៊ុន Colben មានផែនការកសាងម៉ាស៊ីនថាមពលជជុះជាច្រើន ដើម្បីអាចនឹងមានសំណួរ អំពីភាពអាចទុកចិត្តបានទៅលើការផ្គត់ផ្គង់អគ្គិសនីទៅឱ្យ SEZ នេះនៅពេលអនាគតប្រសិនបើ SEZ ភ្នំពេញ មិនអាចទទួលបានការផ្គត់ផ្គង់ពី EDC បន្ទាប់ពីបណ្តាញផ្ទេរ ត្រូវបានបង្កើតហើយនោះ[២]។ SEZ នេះ បានភ្ជាប់កិច្ចសន្យាជាមួយ EDC ក្នុងការលក់ថាមពលអគ្គសនីដែល នៅសល់ ទៅឱ្យបណ្តាញរបស់វា នៅក្នុងដំណាក់កាលដំបូង ជាមួយនិងវិនិយោគិនខ្លះ។ EDC កំពុងរៀបចំ ផែនការផ្គត់ផ្គង់មជ្ឈមណ្ឌលថ្មីធំៗ ដោយប្រើខ្សែផ្ទេរចរន្ត ១១៥ KV ដោយ ភ្ជាប់ទៅនឹងស្ថានីយ៍រងថ្មីនៅ ភាគខាងលិចក្រុងភ្នំពេញ។

**(៤) ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ**

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងខ្ចីប្រាក់ ODA ជាមួយ JBIC កាលពីខែមីនាឆ្នាំ២០០៦ ដែលមានចំនួនសរុបដល់ទៅ ៣១៨ លានយ៉េន សម្រាប់គម្រោងអភិវឌ្ឍន៍ SEZ កំពង់ផែក្រុងព្រះសីហនុ។ ក្រោមគម្រោងនេះ SEZ មួយដែលមានផ្ទៃក្រឡាប្រមាណ ៧០ ហិចតា នឹងត្រូវបានបង្កើតឡើង នៅ ក្បែរកំពង់ផែក្រុងព្រះសីហនុ

---

[២] ប្រភព : លោក Pierre Yves Catry, នាយកគ្រប់គ្រង ក្រុមហ៊ុនកូមិនខ្មែរ

ដែលពីមុនត្រូវបានអភិវឌ្ឍដោយប្រាក់កម្ចី ODA ផងដែរ។ JBIC ក៏បានឧបត្ថម្ភគាំទ្រដល់ការស្តារ និងពង្រីកគម្រោងកំពង់ផែក្រុងព្រះសីហនុ និងគម្រោងបណ្តាញផ្លូវខ្នងទូរគមនាគមន៍ ហើយ ក៏បានផ្តល់ជូនរដ្ឋាភិបាលនូវសំណើគោលនយោបាយស្តីពីការជំរុញ និងការជួញសម្រួលដល់ការវិនិយោគ ដើម្បី ធ្វើឱ្យប្រសើរឡើងដល់បរិយាកាសវិនិយោគ។

ទីក្រុងព្រះសីហនុបច្ចុប្បន្នទទួលការផ្គត់ផ្គង់អគ្គិសនីពី EDC។ ក្រុមហ៊ុនមានអាជ្ញាប័ណ្ណរួមតូចបីទៀត ផ្គត់ផ្គង់អគ្គិសនីដល់ទីប្រជុំជនផ្សារវាលរេញ ខ័ណ្ឌព្រៃនប់ សង្កាត់ទំនប់រលក និសង្កាត់កំពេញ ឃុំស្ទឹងហាវ ផ្សារស្ទាច់ដេង សង្កាត់រាម ខណ្ឌព្រៃនប់ ក្នុងខេត្តនេះ។ EDCបាននិងកំពុងផ្គត់ផ្គង់អគ្គិសនីដល់អតិថិជនឧស្សាហកម្ម ចំនួន១០០ កន្លែង នៅក្រុងព្រះសីហនុ គិតត្រឹមឆ្នាំ២០០៥ ក្នុងតម្លៃដែលខុសគ្នាចាប់ពី ០.១៣៥ ទៅ ០.១៧៥ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង អាស្រ័យលើកម្រិតនៃការប្រើប្រាស់។ ទីក្រុងព្រះសីហនុ ជាតំបន់មួយ ក្នុងប្រទេសកម្ពុជា ដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីរយៈពេល ២៤ ម៉ោង ដូចទីក្រុងភ្នំពេញដែរ ដែលមិនដូចនឹង តំបន់ផ្សេងៗទៀតទទួលបានការផ្គត់ផ្គង់អគ្គិសនី ទៅតាមពេលម៉ោងដែលកំណត់ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ន EDC កំពុងផ្គត់ផ្គង់ថាមពលអគ្គិសនីត្រឹមតែ ១០មេហ្គាវ៉ាត់ប៉ុណ្ណោះសម្រាប់ទីក្រុងនេះទាំងមូល (ដែលក្នុងនោះ ៥មេហ្គាវ៉ាត់ត្រូវបានផ្គត់ផ្គង់ទៅឱ្យ EDC ដោយក្រុមហ៊ុន Colben)។ គួរកត់សំគាល់ផង ដែរថា EDC និងក្រុមហ៊ុន Colben កំពុងប្រើម៉ាស៊ីនថាមពលអគ្គិសនីដដុះ ដូច្នេះវានៅតែជាសញ្ញាសួរមួយ អំពីការផ្គត់ផ្គង់អគ្គិសនីទៅឱ្យ SEZ ដែលឯករាជ្យទាំងស្រុង នៅក្នុងទីក្រុងមួយនេះ។ បច្ចុប្បន្ន SEZ ក្រុងព្រះសីហនុទទួលបានការផ្គត់ផ្គង់ពី EDC និងក្រុមហ៊ុន Colben (តាមរយៈ EDC) នៅមានកម្រិត។ ទោះជាយ៉ាងណាក៏ដោយក្រុងព្រះសីហនុដែលនឹងក្លាយទៅជាមូលដ្ឋានបូមប្រេងពីក្នុងសមុទ្រនោះមិនអាចទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រទេសជិតខាងបានទេ ដោយសារតែគ្មានភ្ជាប់បណ្តាញផ្ទេរចរន្ត។ គេគួរតែបង្កើតរោងចក្រថាមពលមួយ ដើម្បីឱ្យទីក្រុងនេះមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់។ ត្រឹមឆ្នាំ២០០៨ គេនឹងភ្ជាប់បណ្តាញផ្ទេរចរន្តថាមពលមកពី ប្រទេសវៀតណាម ទៅកាន់ទីក្រុងភ្នំពេញ ដោយកាត់តាមខេត្តតាកែវ ហើយនឹងនាំចូលថាមពលអគ្គិសនីចំនួន ៨០ មេហ្គាវ៉ាត់ពីប្រទេស វៀតណាម។ ត្រឹមឆ្នាំ២០០៩ គេរំពឹងទុកថា នឹងមានការ- ភ្ជាប់បណ្តាញផ្ទេរចរន្តពីខេត្តតាកែវ ទៅខេត្តកំពតនិងក្រុងព្រះសីហនុ តាមរយៈការនាំចូលថាមពលអគ្គិសនីពី វៀតណាម។ ត្រឹមឆ្នាំ២០១០ នឹងមានរោងចក្រថាមពលវារីអគ្គិសនីកំចាយដែលអាចផលិតថាមពលបានដល់ទៅ ១៩៣.២ មេហ្គាវ៉ាត់ ដែលនៅមិនឆ្ងាយប៉ុន្មានពីក្រុងព្រះសីហនុទេ។ ត្រឹមឆ្នាំ ២០១០ គេរំពឹងថា នឹងបញ្ចប់ការសាងសង់រោងចក្រថាមពលដែលដើរដោយធ្យូងថ្ម នៅក្រុងព្រះសីហនុ ហើយរោងចក្រថាមពល ដែលដើរ ដោយធ្យូងថ្មចំនួន ២០០មេហ្គាវ៉ាត់បន្ថែមទៀត នឹងត្រូវបានបង្កើតឡើងនៅតំបន់ដូចគ្នានេះត្រឹមឆ្នាំ២០១១។

**(៥) ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅ SEZ មេនហាតាន់ ( ខេត្តស្វាយរៀង)**

SEZ ម៉ាហាតាន់ (ខេត្តស្វាយរៀង) ស្ថិតនៅឃុំបាវិត និងឃុំបាទី ក្នុងខេត្តស្វាយរៀង ដែលជាប់នឹង ព្រំប្រទល់

ប្រទេសវៀតណាម។ SEZ នេះ ត្រូវបានអភិវឌ្ឍ និងប្រតិបត្តិដោយក្រុមហ៊ុនម៉ាហាតាន់។ SEZ នេះ បានចាប់ផ្តើមដំណើរការកាលពីដើមឆ្នាំ២០០៦។ រហូតមកដល់ខែសីហា ឆ្នាំ២០០៦ SEZ នេះផ្តល់ការងារជូន កម្មករក្នុងស្រុកចំនួន ៤០០នាក់ នៅឯរោងចក្រដែលមានទិសដៅនាំចេញពីរ ដែលកំពុងផលិតកង់ និងខ្មៅ ហើយ រោងចក្រស្បែកជើងមួយទៀតក៏ទើបត្រូវបានសម្ពោធ កាលពីចុងខែកក្កដា ឆ្នាំ២០០៦។ ផលិតផលទាំងអស់ នេះត្រូវបាននាំចេញទៅកាន់ទីផ្សារអឺរ៉ុប តាមរយៈកំពង់ផែក្រុងហូជីមិញ នៃប្រទេសវៀតណាម។ SEZ នេះ មានមន្ត្រីរដ្ឋាភិបាលចំនួន១៤រូប មកពីនាយកដ្ឋានគយ និងរដ្ឋាករ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំពុងបម្រើសេវាកម្មច្រកចេញ-ចូលតែមួយ លើការរត់ការឯកសារផ្សេងៗ[៣]។ ឃុំបាវិត
របស់ខេត្តស្វាយរៀង ដែលជាទីតាំងរបស់ SEZ នេះ អាចទទួលបានការផ្គត់ផ្គង់អគ្គិសនីពី EDC តាមរយៈការនាំចូលអគ្គិសនីពីវៀតណាម។ កម្ពុជាបាននាំចូលថាមពលអគ្គិសនីចំនួន ៤.៩២៨ លានគីឡូវ៉ាត់ម៉ោង ដើម្បីផ្គត់ផ្គង់តំបន់នេះ ចាប់តាំង ពីឆ្នាំ២០០៤មក។ តំបន់នេះក៏ទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីពេញ២៤ម៉ោង ដូច នៅទីក្រុងភ្នំពេញ ផងដែរ។ គួរកត់សំគាល់ដែរថា ក្រុមហ៊ុនម៉ាហាតាន់ ដែលជាអ្នកអភិវឌ្ឍន៍ SEZ ស្វាយរៀង គ្រោងនឹងនាំចូលថាមពលអគ្គិសនីដោយផ្ទាល់ពីវៀតណាម ដោយមិនចាំបាច់ឆ្លងកាត់ EDC ដើម្បីផ្គត់ផ្គង់ ដល់ឧស្សាហកម្មនៅក្នុងតំបន់នេះ[៤]។ ដូច្នេះប្រសិនបើវាពិតជាកើតឡើងមែនការផ្គត់ផ្គត់អគ្គិសនីទៅឱ្យ SEZ នេះនឹងត្រូវបានធានាទោះតិចឬច្រើនក្នុងពេលអនាគត។ គេនឹងបង្កើនបណ្តាញផ្ទេរចរន្តពីវៀតណាម ទៅខេត្ត ស្វាយរៀង ឱ្យបានពី ២២KV ទៅ ១១៥KV ត្រឹមឆ្នាំ២០០៧ ដោយសារតែគេរំពឹងថា តម្រូវការប្រើប្រាស់ ថាមពលអគ្គិសនី នៅតំបន់នេះ នឹងមានការកើនឡើង។

**(៦) បញ្ហាដែលឧស្សាហកម្មនៅកម្ពុជាកំពុងជួបប្រទះ ពាក់ព័ន្ធនឹងការផ្គត់ផ្គង់អគ្គិសនី**

ផ្នែកនេះវិភាគជាសំខាន់ទៅលើបញ្ហាដែលទាក់ទិននឹងថាមពលអគ្គិសនី ដែលឧស្សាហកម្មភាគច្រើននៅកម្ពុជាកំពុងជួបប្រទះ តាមរយៈការស្ទាបស្ទង់មតិដោយសំភាសន៍ឧស្សាហកម្មទាំងនេះ។ ការវិភាគនេះផ្តោតជាចំបងទៅលើវិស័យឧស្សាហកម្មកាត់ដេរ ព្រោះវាជាវិស័យឧស្សាហកម្មច្រើនជាងគេដោយមានការនាំចេញរហូត ដល់ទៅជាង៨០% នៃការនាំចេញសរុប។ ដោយសារថារោងចក្រកាត់ដេរភាគច្រើន ស្ថិតនៅជុំវិញទីក្រុងភ្នំពេញ គេបានជ្រើសយកប៉ាន់គំរូរោងចក្រនៅក្នុងទីក្រុងនេះ សម្រាប់ធ្វើការស្ទាបស្ទង់មតិ។

ផ្នែកលើការសំភាសន៍ស្ទាបស្ទង់មតិ ជាមួយនិងឧស្សាហកម្មកាត់ដេរ ដែលប្រើកម្លាំងពលកម្មយ៉ាងច្រើននៅជុំវិញទីក្រុងភ្នំពេញ កាលពីខែកញ្ញា ឆ្នាំ២០០៦ បានបង្ហាញថា ការផ្គត់ផ្គង់អគ្គិសនីរបស់ EDC មានភាពល្អប្រសើរជាងមុន

---

[៣] សេចក្តីថ្លែងការណ៍របស់លោក ឡារី កៅ ម្ចាស់ SEZ ស្វាយរៀង នៅក្នុងអត្ថបទចេញផ្សាយរបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា កាលពីខែសីហា ឆ្នាំ២០០៦

[៤] ប្រភព : លោក ឡារី កៅ អគ្គនាយកក្រុមហ៊ុន ម៉ាន់ញ៉ាថាន់

(ប្រហែលពី៦-៩ខែមុន)។ រោងចក្រកាត់ដេរភាគច្រើននៅភ្នំពេញមានប្រភពផ្គត់ផ្គង់អគ្គិសនី ចំនួនពីរ ទីមួយគឺ EDC ដែលគ្រប់គ្រងដោយរដ្ឋ ហើយមួយទៀត គឺម៉ាស៊ីនភ្លើងដើរដោយប្រេងម៉ាស៊ូតរបស់ រោងចក្រផ្ទាល់ខ្លួន។ កាលពីមុន រោងចក្រប្រើអគ្គិសនីពី EDC ត្រឹមតែ៣0% ប៉ុណ្ណោះ ព្រោះរោងចក្រជាច្រើន ប្រើម៉ាស៊ីនភ្លើងដើរដោយប្រេងម៉ាស៊ូតខ្លួនឯង ដែលជាប្រភពថាមពលអគ្គិសនីជាទីទុកចិត្ត សម្រាប់ដំណើរការ។

តម្លៃអគ្គិសនីរបស់ EDC នៅតាមរោងចក្រភាគច្រើនគឺពី 0.១៥-0.១៧ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោងខណៈពេលដែលការប្រើប្រាស់ម៉ាស៊ីនភ្លើងដើរដោយប្រេងម៉ាស៊ូតផ្ទាល់ខ្លួន ចំណាយអស់ពី 0.១៨-0.២៣ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង ដោយសារតែតម្លៃប្រេងឥន្ធនៈចេះតែឡើងថ្លៃនាពេលបច្ចុប្បន្ននេះ។ ប៉ុន្តែរោងចក្រកាត់ដេរនៅក្រៅទីក្រុងភ្នំពេញត្រូវពឹងផ្អែកលើម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ដើម្បីទទួលបានការផ្គត់ផ្គង់អគ្គិសនីប្រកប ដោយស្ថេរភាព។ បើទោះជាថ្លៃដកហូតលើម៉ាស៊ីនភ្លើងមានកម្រិតខ្ពស់ក៏ដោយ ក៏ការចំណាយលើថាមពល អគ្គិសនីដែលបានពីម៉ាស៊ីនដែលដើរដោយប្រេងឥន្ធនៈធ្ងន់នេះ គឺថោកជាងច្រើនប្រហែលត្រឹមតែ 0.១៣ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោងប៉ុណ្ណោះ បើធៀបនឹងការចំណាយលើថាមពលអគ្គិសនី ដែលផលិតដោយប្រេងម៉ាស៊ូត ដែលមានចំហេះខ្លាំងនោះ។ គិតត្រឹមឆ្នាំ២00៦ ចំណែកនៃតម្លៃអគ្គិសនីក្នុងតម្លៃសរុបតាម FOB នៃមុខទំនិញសំលៀកបំពាក់ទូទៅ គឺប្រហែល៦% អាស្រ័យលើប្រភេទសំលៀកបំពាក់ ដែលផលិត ដោយសារតម្លៃអគ្គិសនី កាន់តែខ្ពស់ពីប្រភពម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ដែលបណ្តាលមកពីថ្លៃប្រេងកើនឡើង។ កាលពីឆ្នាំ២00៤ ចំណែកនៃ តម្លៃអគ្គិសនីនេះ មានត្រឹមតែ៤%ប៉ុណ្ណោះ។ ចំណែកថ្លៃអគ្គិសនីនឹងមានត្រឹមតែ៣% នៃតម្លៃ FOB ប៉ុណ្ណោះ ប្រសិនបើដំណើរការតែម៉ាស៊ីនដេរ ហើយមិនប្រើម៉ាស៊ីនត្រជាក់នោះ។ ហេតុដូច្នេះហើយ មានការផ្លាស់ប្តូរតិចតួចពីការប្រើម៉ាស៊ីនភ្លើងផ្ទាល់ខ្លួនទៅជាការប្រើថាមពលអគ្គិសនីពី EDC។ ដោយគិតពិចារណាពីលទ្ធភាពនា ពេលអនាគតនៃការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ដែលមានការផលិតដោយប្រើប្រាស់អគ្គិសនីនោះវា ជាការសំខាន់ក្នុងការសាងសង់ស្ថានីយ៍ថាមពលវារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជានិងបង្កើតបណ្តាញផ្លាស់ប្តូរថាមពលចំរុះក្នុងចំណោមប្រទេសមហាអនុតំបន់ទន្លេមេគង្គ។

**តារាង ១០-២-៥ រចនាសម្ព័ន្ធថ្លៃដើម ក្នុងឆ្នាំ២00៦**

| សមាសភាគថ្លៃដើម | ភាគរយ |
|---|---|
| តម្លៃលក់តាម FOB | ១00 |
| ថ្លៃដើមនៃវត្ថុធាតុដើមនាំចូល | ៥៩ |
| ចំណាយលើកម្មករ | ១២ |
| ចំណាយផ្សេងៗទៀតលើមនុស្ស (ការគ្រប់គ្រង រដ្ឋបាល និង | ៨ |

| សមាសភាគថ្លៃដើម | ភាគរយ |
|---|---|
| ប្រាក់ក្រោមតុ) | |
| ចំណាយលើថាមពល | ៦ |
| ចំណាយលើរំលោះ និងការជួលដីធ្លី | ៩ |
| ប្រាក់ចំណេញមិនទាន់បង់ពន្ធ | ៦ |

ប្រភព: ក្រុមសិក្សារបស់ JICA

### ១០.២.៣ ទូរគមនាគមន៍

#### (១) ស្ថានភាពទូរគមនាគមន៍បច្ចុប្បន្ននៅកម្ពុជា

(i) ស្ថាប័នធ្វើផែនការ និងបទបញ្ញត្តិ សម្រាប់គោលនយោបាយទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) ជាអ្នកបង្កើតគោលនយោបាយ និងជានិយតករ ក្នុងវិស័យទូរគមនាគមន៍នៅកម្ពុជា។ MPTC ជាអ្នកប្រតិបត្តិបណ្តាញទូរស័ព្ទអចល័ត ប៉ុន្តែកាលពីខែមករា ឆ្នាំ២00៦ ក្រសួងបានបង្កើតសហគ្រាសរដ្ឋមួយ ឈ្មោះថា "ទូរគមនាគមន៍កម្ពុជា" ដោយវិនិយោគដើមទុនចំនួន ៤0.៣លានដុល្លារ និងប្រើប្រាស់បុគ្គលិកចំនួន ៧00នាក់ សម្រាប់ផ្តល់សេវាកម្មប្រព័ន្ធទូរស័ព្ទអចល័ត ដែលមានលេខខាងដើម 0២៣។ ទូរគមនាគមន៍កម្ពុជា នឹងត្រូវបានធ្វើឯកជនភាវូបនីយកម្ម ត្រឹមឆ្នាំ២00៨។

ក្នុងឆ្នាំ២000 រដ្ឋាភិបាលបានបង្កើតអាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិជ្ជាទំនាក់ទំនងព័ត៌មានជាតិ (NIDA) ដើម្បីជំរុញវិស័យព័ត៌មានវិទ្យា និងបង្កើតគោលនយោបាយព័ត៌មានវិទ្យា រយៈពេលខ្លី មធ្យម និងវែង ដើម្បី ឱ្យមានកំណើនសេដ្ឋកិច្ចអតិបរមា និង ដើម្បីត្រួតពិនិត្យនិងធ្វើសវនកម្មលើគម្រោងព័ត៌មានវិទ្យាទាំងអស់។

(ii) **សេវាកម្មទូរស័ព្ទ**

អ្នកជាវប្រព័ន្ធអចល័តមានការកើនឡើងតិចតួចប៉ុណ្ណោះ ខណៈពេលដែលដង់ស៊ីតេនៃការប្រើប្រាស់ទូរស័ព្ទនៅកម្ពុជា មានការកើនឡើង ៣ដង កាលពី ៥ឆ្នាំមុន ដូចបានបង្ហាញនៅតារាង ១០-២-៦។ នាចុងឆ្នាំ ២00៥ ដង់ស៊ីតេនៃការប្រើប្រាស់ទូរស័ព្ទនៅកម្ពុជាស្មើនឹង ៦.២៤ ដែលក្នុងនេះអ្នកជាវទូរស័ព្ទចល័តមានចំនួន ៥.៩៤។ ម្យ៉ាងវិញទៀតមានជាង ៩៥%នៃអ្នកជាវទូរស័ព្ទទាំងអស់ ប្រើប្រាស់ទូរស័ព្ទចល័ត។ កម្ពុជាជាប្រទេស ទីមួយក្នុងពិភពលោកដែលចំនួនអ្នកប្រើ ប្រាស់ទូរស័ព្ទចល័ត ច្រើនជាងទូរស័ព្ទអចល័ត។ នេះមកពីកង្វះខាតនូវ សេវាកម្មប្រព័ន្ធទូរស័ព្ទអចល័ត។ វិទ្យាស្ថានស្រាវជ្រាវទូរគមនាគមន៍អន្តរជាតិឯកជនមួយ បានប៉ាន់ប្រមាណថាមានអ្នកប្រើទូរស័ព្ទចល័តដល់ទៅជាង ១.១ លាននាក់ ហើយមាន អ្នកប្រើទូរស័ព្ទអចល័តតិចជាង ៤0.000នាក់ ប៉ុណ្ណោះ នាចុងឆ្នាំ ២00៥ ។

**តារាង ១០-២-៦ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទ និងសេវាគ្របដណ្តប់**

| | | ឆ្នាំ ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|---|
| ចំនួនប្រជាជន | | ១៣.០០០.០០០ | ១៣.៤៣៣.០០០ | ១៣.៧៧០.០០០ | ១៤.១១១.០០០ | ១៤.១៤៥.០០០ |
| ចំនួនអ្នកប្រើប្រាស់ | ទូរស័ព្ទអចល័ត | ៣៣.៤៩៤ | ៣៥.៤១៩ | ៣៧.១៩៤ | ៣៩.៨៦៥ | ៤១.១០៤ |
| | ទូរស័ព្ទចល័ត | ២២៣.៤៥៨ | ៣២១.៦២១ | ៤៨៩.៥០៤ | ៦៥៩.៣២៤ | ៨៤០.៩១៦ |
| | សរុបរង | ២៥៦.៩៥២ | ៣៥៧.០៤០ | ៥២៦.៦៩៨ | ៦៩៩.១៨៩ | ៨៨២.០២០ |
| សេវាគ្របដណ្តប់ | ទូរស័ព្ទអចល័ត | ០,២៥ | ០,២៦ | ០,២៧ | ០,២៨ | ០,៣០ |
| | ទូរស័ព្ទចល័ត | ១,៧២ | ២,៣៩ | ៣,៥៥ | ៤,៦៧ | ៥,៩៤ |
| | សរុបរង | ១,៩៧ | ២,៦៥ | ៣,៨២ | ៤,៩៥ | ៦,២៤ |

ប្រភព : ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC)

បើធៀបជាមួយនឹងប្រទេសក្នុងសមាគមន៍អាស៊ានផ្សេងទៀត ដង់ស៊ីតេការប្រើប្រាស់ទូរស័ព្ទនៅកម្ពុជានៅតែមានចំនួនទាបជាង ដូចបង្ហាញនៅតារាង១០-២-៧។ តួលេខឆ្នាំ២០០៥ ដែលស្មើនឹង ៦.២៤ នៅកម្ពុជា គឺតិចជាងដង់ស៊ីតេអ្នកប្រើប្រាស់ទូរស័ព្ទ នាឆ្នាំ២០០២ នៅប្រទេសឥណ្ឌូនេស៊ី ក្នុងចំនួនច្រើននៅឡើយ។

**តារាង ១០-២-៧ ដង់ស៊ីតេប្រើប្រាស់ទូរស័ព្ទ នៃប្រទេសអាស៊ាន**

| ឈ្មោះប្រទេស | ទូរស័ព្ទអចល័ត | ទូរស័ព្ទចល័ត | សរុប |
|---|---|---|---|
| កម្ពុជា (ឆ្នាំ ២០០២) | ០,២៦% | ២,៤០% | ២,៦៦% |
| ភូមា (ឆ្នាំ ២០០២) | ០,៦១% | ០,០៣% | ០,៦៤% |
| ឡាវ (ឆ្នាំ ២០០២) | ១,១២% | ១,០០% | ២,១២% |
| ឥណ្ឌូនេស៊ី (ឆ្នាំ ២០០២) | ៣,៦០% | ៥,៥២% | ៩,១២% |
| វៀតណាម (ឆ្នាំ ២០០២) | ៦,៥៨% | ២,៣៤% | ៩,១៩% |
| ហ្វីលីពីន (ឆ្នាំ ២០០២) | ៤,១៧% | ១៧,៧៧% | ២១,៩៤% |
| ថៃ (ឆ្នាំ ២០០១) | ៩,៨៧% | ២៦,០៤% | ៣៥,៩១% |
| ម៉ាឡេស៊ី (ឆ្នាំ ២០០១) | ១៩,៧៩% | ៣៤,៩៩% | ៥៤,៦៧% |
| ប្រ៊ុយណេ (ឆ្នាំ ២០០១) | ២៨,៩៤% | ៤៣,៧២% | ៧២,៦៦% |

| ឈ្មោះប្រទេស | ទូរស័ព្ទអចល័ត | ទូរស័ព្ទចល័ត | សរុប |
|---|---|---|---|
| **សិង្ហបុរី (ឆ្នាំ ២០០២)** | **៤៦.៣៥%** | **៧៩.១៣%** | **១២៥.៤៨%** |
| **ចិន (ឆ្នាំ ២០០១)** | **១៣.៨១%** | **១១.១៧%** | **២៤.៩៨%** |
| **ជប៉ុន (ឆ្នាំ ២០០១)** | **៥៨.៥៨%** | **៦២.១១%** | **១២០.៦៩%** |

ប្រភព: ឯកសារ Word ICT Visual Data Book 2004

នៅកម្ពុជា មានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទអចល័តចំនួន៣ ក្រុមហ៊ុនផ្តល់សេវាហៅចេញទៅក្រៅប្រទេសចំនួន ៣ និងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័តចំនួន ៤។ ឈ្មោះ និងសេវាកម្មរបស់ក្រុមហ៊ុនទាំងនេះ ត្រូវបានដោយបង្ហាញដោយសង្ខេប នៅក្នុងតារាង ១០-២-៨។

**តារាង ១០-២-៨ ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍**

| ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទអចល័ | ទូរស័ព្ទចល័ត | អន្តរជាតិ | អ៊ិនធឺណិត |
|---|---|---|---|---|
| **Telecom Cambodia** | **X (023)** | | **X** | **X** |
| **CaminTel** | **X** | | | **X** |
| **Camshin (Cambodia Shinawatra)** | **X** | **X (011)** | | **X** |
| **CamGSM (Mobitel)** | | **X (012)** | **X (Tele2)** | **X** |
| **CASACOM (Cambodia Samart** | | **X (015 / 016)** | | **X** |
| **CamTel** | | **X (018)** | | |
| **3tel Cafe (008)** | | | **X (PC/Phone)** | |
| **Cogetel** | | | | **X (Online)** |

ប្រភព : ក្រុមសិក្សារបស់ JICA

ក្នុងចំណោមក្រុមហ៊ុនប្រព័ន្ធទូរស័ព្ទចល័តទាំងអស់ ក្រុមហ៊ុន Mobitel មានស្ទើរតែពាក់កណ្តាលនៃចំណែកទីផ្សារ ហើយក្រុមហ៊ុន Camshin និង CASACOM មានចំណែកទីផ្សារចំនួន ១ភាគ៤ ខណៈពេលដែល Telecom Cambodia មានចំណែកទីផ្សារប្រព័ន្ធទូរស័ព្ទអចល័តជាង ៦០% ។

ចំពោះសេវាទូរស័ព្ទអន្តរជាតិវិញ មានច្រកអន្តរជាតិ២ នៅកម្ពុជា ទីមួយគឺផ្តល់ដោយ MPTC និង មួយទៀតផ្តល់ដោយ Tele2 ។ រហូតមកដល់ពេលថ្មីៗនេះ MPTC ធ្លាប់រកចំណូលបានដល់ទៅ ៨៥% ពីសេវាកម្ម ទូរស័ព្ទអន្តរជាតិ ហើយជាហេតុធ្វើឱ្យច្រកទូរស័ព្ទអន្តរជាតិនេះ នៅតែជាប្រភពចំណូលចំបងរបស់រដ្ឋាភិបាល។ បើទោះជាគេបញ្ចុះតម្លៃការហៅចេញទៅអន្តរជាតិពី ១ភាគ៣ មក១ភាគ៤ ក៏ដោយក៏តម្លៃនេះនៅតែខ្ពស់។ ដោយសារហេតុផលបែបនេះហើយ ទើបអ្នកប្រើប្រាស់ងាកទៅរកវិធីប្រើប្រាស់ផ្សេងទៀតវិញ ដូចរៀបរាប់ខាងក្រោម ហើយការធ្វើអាជីវកម្មសេវាកម្មទូរស័ព្ទហៅចេញក្រៅប្រទេសដោយផ្ទាល់មុខ បានចាប់ផ្តើមចុះថយ :

- ពឹងផ្អែកលើការទទួលការហៅចូល

- ប្រើប្រាស់សេវាទូរស័ព្ទចល័តដែលមានតម្លៃថោកជាង
- ការប្រើប្រាស់កើនឡើងទៅលើការហៅចេញតាមអ៊ិនធឺណិត (VoIP-Voice over Internet Protocol) បើទោះជាការប្រើប្រាស់នោះខុសច្បាប់ក៏ដោយ ។

ការប្រើប្រាស់ VoIP នៅពេលមួយនោះ ធ្លាប់ត្រូវបានហាមប្រាមដោយបទបញ្ញត្តិរបស់រាជរដ្ឋាភិបាល (សេចក្តីប្រកាសស្តីពីបម្រាមប្រើប្រាស់ Voice over Internet របស់ MPTC នៅថ្ងៃទី៣0 ខែធ្នូ ឆ្នាំ១៩៩៨) ។ ប៉ុន្តែកាលពីពេលថ្មីៗនេះ "3tel Cafe´" ដែលប្រតិបត្តិការឡើង ក្រោមកិច្ចសន្យាសហប្រតិបត្តិការធុរកិច្ចរវាង MPTC និងក្រុមហ៊ុន AZ Communication បានចាប់ផ្តើមសេវាកម្មកុំព្យូទ័រទៅទូរស័ព្ទ (PC-to-Phone) ហើយពេលខ្លះ សេវាហៅចេញទៅក្រៅប្រទេសរបស់ពួកគេ មានតម្លៃត្រឹមតែ ១ភាគ៥ នៃអត្រាហៅចេញទៅ ក្រៅប្រទេស ដោយប្រើប្រាស់ទូរស័ព្ទអចល័តប៉ុណ្ណោះ ។

(iii) **សេវាអ៊ីនធឺណិត**

អ៊ីនធឺណិតត្រូវបានណែនាំជាដំបូង មកក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៧ ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) ដោយមានការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (MPTC) នៃប្រទេសកាណាដា ហើយបច្ចុប្បន្ននេះវាត្រូវបានចាត់ចែងទាំងស្រុងដោយ MPTC ក្រោមឈ្មោះថា CamNet ។ បច្ចុប្បន្ននេះ កម្ពុជាមានក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតចំនួន៧ ដូចជាក្រុមហ៊ុន CamNet Online (CogeTel) Open Forum, CaminTel, Telesurf, Camshin និង Casacom ។ គេប៉ាន់ស្មានថា នៅឆ្នាំ២00៣ កម្ពុជា នឹងមានអ្នកជាវអ៊ិនធឺណិតជាប្រចាំចំនួន ១៣.000នាក់ និងអ្នកប្រើប្រាស់អ៊ិនធឺណិតចំនួន ៤0.000នាក់ ។ អ្នកជាវ និងអ្នកប្រើប្រាស់សេវាអ៊ិនធឺណិតភាគច្រើន ស្ថិតនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងក្រុង- ព្រះសីហនុ ។ បច្ចុប្បន្ននេះ សេវាអ៊ីនធឺណិត broadband ត្រូវបានកំពុងផ្តល់ឱ្យតាមរយៈ ADSL (ពេលខ្លះ មានលក្ខណៈមិនប្រើខ្សែ) ឬតាមរយៈខ្សែកាបអុបទិក នៅក្នុងទីក្រុងភ្នំពេញ ។

International Internet Exchange (IIX) ឬ IP Gateway ត្រូវបានដំណើរការដោយក្រុមហ៊ុន CamNet ដែលមានសមត្ថភាព bandwidth សរុប 22 Mbps ។ IP Gateway ត្រូវបានតភ្ជាប់ជាមួយនិង THAICOM Gateway ឬ JCSAT តាមរយៈផ្កាយរណប ហើយបន្ទាប់មកភ្ជាប់ទៅនឹងបណ្តាញអ៊ិនធឺណិតមេនៅហុងកុង ។ ខ្សែកាបអុបទិកត្រូវបានតម្លើង ដោយមានជំនួយពី German KFW ក្នុងឆ្នាំ១៩៩៩ ចាប់ពី ប្រទេសថៃ ទៅវៀតណាម ដោយកាត់តាមប៉ោយប៉ែត-ខេត្តបាត់ដំបង-ក្រុងភ្នំពេញ-បាវិត ។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី សម្រាប់ "គម្រោងនៃបណ្តាញឆ្អឹងខ្នងទូរគមនាគមន៍មហាតំបន់មេគង្គ (ច្រកកំណើននៃប្រទេសកម្ពុជា)" ត្រូវបានចុះហត្ថលេខា ក្នុងខែមីនា ឆ្នាំ ២00៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និង JBIC ហើយគម្រោងតម្លើងខ្សែកាបអុបទិកដែលមានប្រវែង ៤00គ.ម ដែលភ្ជាប់កំពង់ចាម ភ្នំពេញ និងក្រុងព្រះសីហនុ ក៏បានចាប់ផ្តើមរួចហើយដែរ ។

(iv) **សេវាប្រៃសណីយ៍**

ពុំមានសេវាប្រៃសណីយ៍ក្នុងស្រុក ដែលអាចរកបាននៅក្នុងប្រទេសកម្ពុជាទេ ហើយជាការសំខាន់ដែលត្រូវកសាងបណ្តាញសេវាប្រៃសណីយ៍ឡើងវិញ ជាពិសេសដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច នៅបណ្តាខេត្តនានា។

**(២) អនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើងដល់ទូរគមនាគមន៍ និងសេវាកម្ម**

ក្រៅពីកសាងបណ្តាញសេវាប្រៃសណីយ៍ឡើងវិញនៅក្នុងប្រទេសមួយក៏នៅមានការធ្វើឱ្យប្រសើរឡើងជាចាំបាច់ដល់សេវាទូរគមនាគមន៍ ដូចរៀបរាប់ខាងក្រោម ដើម្បីជំរុញការវិនិយោគក្នុងប្រទេសកម្ពុជា ជាពិសេសនៅតាមបណ្តាខេត្តនានា :

កាត់បន្ថយតម្លៃទូរស័ព្ទ (ទាំងក្នុងស្រុក និងក្រៅស្រុក ចល័ត និងអចល័ត) និងតម្លៃអ៊ីនធឺណិត

បង្កើនសមត្ថភាពទូរស័ព្ទចល័ត ដើម្បីឆ្លើយតបតម្រូវការដល់កំពូល នៅក្នុងតំបន់ទីក្រុង

បង្កើនសមត្ថភាពច្រកទូរស័ព្ទហៅចេញអន្តរជាតិ

ពង្រីកសមត្ថភាពទូរស័ព្ទ នៅក្នុងតំបន់ជនបទ

ពង្រីកបណ្តាញអ៊ីនធឺណិតជាឆ្អឹងខ្នងជាតិ ទៅដល់គ្រប់ខេត្តក្រុងទាំងអស់

ធ្វើឱ្យប្រសើរឡើងដល់ទំនាក់ទំនងអ៊ីនធឺណិតអន្តរជាតិ ដើម្បីធ្វើឱ្យមានការតភ្ជាប់អ៊ីនធឺណិតដែលមានល្បឿនខ្ពស់ ជាមួយនិងប្រទេសដទៃទៀត

ពង្រីក broadband access សម្រាប់អ៊ីនធឺណិត (បង្កើនការតភ្ជាប់ខ្សែកាបអុបទិក)

តម្លៃនៃការហៅចេញជាអន្តរជាតិ ០,៩ ដុល្លារក្នុង១នាទី នៅថ្ងៃដើមសប្តាហ៍ គឺថ្លៃខ្ពស់ជាងតម្លៃ របស់ក្រុមហ៊ុនសេវាទូរស័ព្ទឯកជនរបស់ជប៉ុន សម្រាប់ការហៅចេញពីប្រទេសជប៉ុនមកកម្ពុជាទៅទៀត ដែលថ្លៃតែ ៧.៩ យេន ក្នុង៦វិនាទី ពីខ្សែទូរស័ព្ទអចល័ត និងថ្លៃតែ ៨.៥ យេន ក្នុង៦វិនាទី ពីខ្សែទូរស័ព្ទចល័ត ប៉ុណ្ណោះ។ តម្លៃប្រចាំខែនៃ Broadband internet ១៩៩ ដុល្លារ សម្រាប់ល្បឿន ២៥៦ Kbps (២.០០០ MB : ប្រើប្រាស់ មិនគិតថ្លៃ, ចាប់ពី ២.០០១MB ដល់ ៥.០០០MB មានតម្លៃ ០,០៩ ដុល្លារ/MB, លើសពី ៥.០០១MB មានតម្លៃ ០,០៨ ដុល្លារ/MB) នោះក៏មានតម្លៃខ្ពស់ណាស់ផងដែរ បើប្រៀបធៀបនឹងអត្រាតម្លៃក្នុងប្រទេសជប៉ុន។ ទន្ទឹមនោះ វាមានការពិបាកយ៉ាងខ្លាំង ក្នុងការហៅចេញទៅប្រទេសចិន ពីទីក្រុងភ្នំពេញ ដោយទូរស័ព្ទចល័តនៅក្បាលព្រលប់។ ដោយសារតែទូរគមនាគមន៍គឺជាអាយុជីវិតសម្រាប់ធុរកិច្ចធំៗនោះ កាលៈទេសៈទាំងនេះ គឺពិតជាកត្តាមិនលើកទឹកចិត្តដល់វិនិយោគិនពីបរទេសឡើយ។ រាជរដ្ឋាភិបាលគួរតែជំរុញការប្រកួតប្រជែង ក្នុងចំណោមអ្នកផ្តល់សេវាទូរគមនាគមន៍ ដើម្បីកាត់បន្ថយអត្រាតម្លៃនិងបង្កើនសមត្ថភាពការហៅទូរស័ព្ទ។

## ១០.២.៤ ផ្លូវថ្នល់

### (១) ស្ថានភាពបច្ចុប្បន្ននៃបណ្តាញផ្លូវថ្នល់នៅកម្ពុជា

បណ្តាញផ្លូវនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមអភិវឌ្ឍនៅដើមទសវត្សទី០០ ហើយទំហំគ្របដណ្តប់ សរុបមានប្រវែងប្រហែល ៣៩.៣១០គម ដែលផ្លូវជាតិមានប្រវែង ៤.៦៩៥គម (ផ្លូវជាតិលេខ១ មានប្រវែង ២.០៥២គម និងផ្លូវជាតិលេខ២មានប្រវែង ២.៦៤៣គម) ផ្លូវក្នុងខេត្តមានប្រវែង ៦.៦១៥គម និង ផ្លូវជនបទមានប្រវែងប្រហែល ២៨.០០០គម។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាពុំមានផ្លូវ expressway ដែលបែងចែកទេ។

ប្រទេសកម្ពុជាមានច្រករបៀងសំខាន់ៗពីរ ដែលកំពុងបម្រើការធ្វើចរាចរណ៍ គឺច្រកពីខាងកើតដល់ ខាងលិច និងច្រកពីខាងជើងដល់ខាងត្បូង។ ច្រកពីខាងកើតដល់ខាងលិច កាត់ប្រទេសកម្ពុជា ថៃឡង់ដ៍ និង វៀតណាម តាមរយៈផ្លូវជាតិលេខ ១, ៥, ៦ និង៧។ ម្យ៉ាងវិញទៀត របៀងសេដ្ឋកិច្ចជើង-ត្បូង ភ្ជាប់ប្រទេស ឡាវ ជាមួយឈូងសមុទ្រសៀម និងវៀតណាម តាមរយៈផ្លូវជាតិលេខ ៧, ៣, ៤ និង២។

ទាក់ទងនឹងការងាររដ្ឋបាលសម្រាប់ផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) គឺទទួលខុសត្រូវចំពោះផ្លូវជាតិ ផ្លូវអន្តរជាតិ និងផ្លូវក្នុងខេត្ត។ ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ទទួលបន្ទុកផ្លូវជនបទ។

យោងតាមរបាយការណ៍វឌ្ឍនភាព (Progress Report) ស្តីពី "ការសិក្សាអំពីការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ នៅប្រទេសកម្ពុជា"ដែលរៀបរៀងដោយក្រុមសិក្សារបស់ JICA ក្នុងខែសីហា២០០៥ បានឱ្យដឹងថាដង់ស៊ីតេផ្លូវ(គ.ម/គ.ម$^{២}$) នៅកម្ពុជា អាចធ្វើការប្រៀបធៀបជាមួយនឹងប្រទេសអាស៊ានដទៃទៀតបាន ប៉ុន្តែមានកម្រិតទាបនៅឡើយ ចំពោះដង់ស៊ីតេផ្លូវដែលក្រាលថ្ម ដូចដែលបានបង្ហាញនៅក្នុងតារាង ១០-២-៩។

**តារាង ១០-២-៩ ដង់ស៊ីតេផ្លូវថ្នល់របស់ប្រទេសអាស៊ាន និងជប៉ុន**

| | ដង់ស៊ីតេផ្លូវថ្នល់ (ទាំងអស់) | ដង់ស៊ីតេផ្លូវថ្នល់ (ដែលក្រាលថ្ម) |
|---|---|---|
| កម្ពុជា | ០,២១៧ | ០,០១១ |
| ម៉ាឡេស៊ី | ០,២១០ | ០,១៥២ |
| ឥណ្ឌូនេស៊ី | ០,១៨៨ | ០,០៨៧ |
| ហ្វីលីពីន | ០,៥៩៨ | ០,០៥៥ |
| ថៃឡង់ដ៍ | ០,៣៧៩ | ០,០៨៤ |
| វៀតណាម | ០,២៨៣ | ០,០៧១ |
| ជប៉ុន | ៣,១០៣ | ០,១៦៤ |

ប្រភព : របាយការណ៍វឌ្ឍនភាព (Progress Report) នៃ "ការសិក្សាអំពីការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ នៅក្នុងប្រទេសកម្ពុជា" ដែលរៀបរៀងដោយក្រុមសិក្សារបស់ JICA ក្នុងខែសីហា ឆ្នាំ ២០០៥

ក្នុងរបាយការណ៍ដដែលនេះ អត្រាជាភាគរយនៃបរិមាណដឹកជញ្ជូន តាមមធ្យោបាយនៅប្រទេសកម្ពុជា ត្រូវបានធ្វើការវិភាគ ដូចបង្ហាញនៅក្នុងតារាង ១០-២-១០ ដែលតាមរយៈនេះ គេអាចសង្កេតឃើញពីសារសំខាន់នៃផ្លូវថ្នល់ចំពោះសកម្មភាពសេដ្ឋកិច្ច ក្នុងប្រទេសកម្ពុជា។

**តារាង ១០-២-១០ អត្រាអ្នកធ្វើដំណើរ និងបរិមាណដឹកជញ្ជូនទំនិញ តាមមធ្យោបាយ (ឆ្នាំ២០០៣)**

| មធ្យោបាយ | អ្នកធ្វើដំណើរ | ទំនិញ |
|---|---|---|
| ផ្លូវគោក | ៦៥% | ៦៩% |
| ផ្លូវដែក | ២០% | ១០% |
| ផ្លូវទឹកដែលនៅឆ្ងាយពីសមុទ្រ | ១៥% | ២០% |

ប្រភព : របាយការណ៍វឌ្ឍនភាព (Progress Report) នៃ "ការសិក្សាអំពីការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ នៅក្នុងប្រទេសកម្ពុជា" ដែលរៀបរៀងដោយក្រុមសិក្សារបស់ JICA ក្នុងខែសីហា ឆ្នាំ ២០០៥

## (២) ផែនការផ្លូវហាយវេអន្តរជាតិ

មានគម្រោងផ្លូវហាយវេអន្តរជាតិចំនួន៣ ដែលឆ្លងកាត់ប្រទេសកម្ពុជា : ផ្លូវហាយវេអាស៊ី ផ្លូវហាយវេអាស៊ាន និងផ្លូវមហាអនុតំបន់មេគង្គ។ ដូចបានបង្ហាញក្នុងតារាង១០-២-១១ ផ្លូវមួយចំនួនត្រួតគ្នា។ ២០% នៃប្រវែងផ្លូវហាយវេទាំង ៣ សរុប ក្នុងប្រទេសកម្ពុជា នឹងក្លាយជាផ្លូវមាន២ចំណែកដែលចាក់កៅស៊ូ ឬក្រាលថ្ម ប្រវែងពាក់កណ្តាលទៀតនឹងក្លាយជាផ្លូវមាន២ចំណែកតូចដែលចាក់បេទីមពីរជាន់ ហើយ ៣០%ដែលនៅសល់ នឹងមានគុណភាពទាបជាងផ្លូវខាងលើ។

**តារាង ១០-២-១១ ផ្លូវហាយវេអន្តរជាតិ**

| ផ្លូវ | ផ្លូវ GMS | ផ្លូវហាយវេអាស៊ី | ផ្លូវហាយវេអាស៊ាន | ផ្លូវជាតិកម្ពុជា | ប្រវែងសរុប (គម) |
|---|---|---|---|---|---|
| ប៉ោយប៉ែត-ស៊ីសុផុន-ភ្នំពេញ-បាវិត | ភាគកណ្តាល | AH1 | AH1 | ផ្លូវជាតិលេខ១ និង ៥ | ៥៧២.៤ |
| ក្រុងព្រះសីហនុ-ភ្នំពេញ-កំពង់ចាម- | ទំនាក់ទំនង | AH11 | AH11 | ផ្លូវជាតិលេ | ៧៥៥.០ |

| ផ្លូវ | ផ្លូវ GMS | ផ្លូវហាយវេអាស៊ី | ផ្លូវហាយវេអាស៊ាន | ផ្លូវជាតិកម្ពុជា | ប្រវែងសរុប (គម) |
|---|---|---|---|---|---|
| ស្ទឹងត្រែង-ត្រពាំងក្រាល | អន្តរបៀង | | | ៥៤, ៦ និង ៧ | |
| ចាំយាម-កោះកុង-ស្ពានភូមិដូង-ស្រែអំបិល-ចម្ការហ្លួង | ភាគខាងត្បូងតាមឆ្នេរសមុទ្រ | - | AH123 | ផ្លូវជាតិលេខ៤៨, លេខ៣ និងលេខ៣៣ | ១៦៣.៣ |
| សៀមរាប-ព្រះវិហារ-ស្ទឹងត្រែង-រតនគិរី-ព្រំដែលអូរយ៉ាដាវ | ភាគខាងជើង | - | - | ផ្លូវជាតិលេខ៦៦ និង ៧៨ | ៨៦៤.៩ |
| | | | ប្រវែងសរុប (គ.ម) | | ១.៩៥៥.៦ |

ប្រភព : របាយការណ៍វឌ្ឍនភាព (Progress Report) នៃ "ការសិក្សាអំពីការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ នៅក្នុងប្រទេសកម្ពុជា" ដែលរៀបរៀងដោយក្រុមសិក្សារបស់ JICA ក្នុងខែសីហា ឆ្នាំ ២០០៥

**(៣) បណ្តាគម្រោងបង្កើនផ្លូវថ្នល់**

ក្នុងឆ្នាំ២០០០ ប្រទេសកម្ពុជាជួបប្រទះនឹងទឹកជំនន់ដ៏ធំមួយ ដែលបានបំផ្លាញបណ្តាញផ្លូវថ្នល់កម្ពុជាយ៉ាងធ្ងន់ធ្ងរ។ ផ្លូវថ្នល់ប្រវែង ២.៦០០គម និងស្ពានប្រវែង ៣.០០០ម គេរាយការណ៍ថា ត្រូវបានខូចខាត។ ដោយមានជំនួយពីអន្តរជាតិដ៏ច្រើន ការស្តារបណ្តាញផ្លូវថ្នល់ឡើងវិញនៅតែកំពុងដំណើរការ។

បច្ចុប្បន្ននេះ គេរំពឹងថានឹងបញ្ចប់ប្រហែល៩៨% លើការងារស្តារឡើងវិញ និងកែលំអផ្លូវជាតិលេខ១ រហូតដល់ផ្លូវជាតិលេខ៧ នៅត្រឹមឆ្នាំ២០០៨ ហើយការងារកែលំអសម្រាប់កំណាត់ផ្លូវជាតិលេខ១ ដែលនៅសល់នឹងត្រូវបញ្ចប់ជាស្ថាបពរនៅឆ្នាំ២០១០។ គម្រោងនេះត្រូវបានប្រើប្រាស់ដោយជំនួយពីប្រទេសជប៉ុន និងកម្ចីផ្សេងៗពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) ប្រទេសកូរ៉េ និងប្រទេសចិន។

**១០.២.៥ អាកាសចរណ៍**

ដោយសារគោលនយោបាយបើកចំហរជើងមេឃរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួននៃក្រុមហ៊ុនអាកាសចរណ៍ចូលមកក្នុងប្រទេសកម្ពុជា មានចំនួនកើនឡើងជាបន្តបន្ទាប់ ក្នុងបណ្តាឆ្នាំថ្មីៗនេះ។ ជើងហោះហើរត្រង់ អន្តរជាតិ ឆ្ពោះទៅកាន់

ប្រទេស/តំបន់ចំនួន៧ គឺបច្ចុប្បន្ននេះកំពុងតែដំណើរការ ចាកចេញពីអាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ ដែលឆ្ពោះទៅទិសដៅចំនួន ៩ ដូចបានបង្ហាញក្នុងតារាង ១០-២-១២។ ក្រៅពីនេះ ជើងហោះហើរខ្លះ ចេញដំណើរ និងចុះចតនៅខេត្តខេត្តសៀមរាប។

**តារាង ១០-២-១២ ការហោះហើរចាកចេញនាសិសិរដូវ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**
**(ចាប់ពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៥ ដល់ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៦)**

| ប្រទេស/តំបន់ | ទិសដៅ | ភាពញឹកញាប់នៃការហោះហើរ |
|---|---|---|
| ប្រទេសចិន | ក្វាងចូវ (ប៉េកាំង) | ក្នុង១ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| | ស្សៀងហៃ | ជើងហោះហើរ២ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាស ចរណ៍ ១ |
| ប្រទេសថៃ | បាំងកក | ក្នុង៦ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ៤ |
| | | ជើងហោះហើរ៤ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| ប្រទេសសឹង្ហបុរី | សឹង្ហបុរី | ក្នុង២ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| | | ជើងហោះហើរ៤ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| ប្រទេសវៀតណាម | ហូជីមិញ | ក្នុង៣ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ២ |
| ប្រទេសតៃវ៉ាន់ | ឯតប៉ិ | ក្នុង១ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| | | ជើងហោះហើរ៣ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| | | ជើងហោះហើរ៥ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| ប្រទេសម៉ាឡេស៊ី | គួឡា ឡាំពួរ | ក្នុង២ថ្ងៃ x ក្រុមហ៊ុនអាកាសចរណ៍ ២ |
| | សៀមរាប-គួឡាឡាំពួរ | ជើងហោះហើរ៣ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |
| | ប៉េណាំង | ជើងហោះហើរដឹកទំនិញ៣ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាស ចរណ៍ ១ |
| ហុងកុង | ហុងកុង | ជើងហោះហើរ៤ដង ក្នុង១សប្តាហ៍ x ក្រុមហ៊ុនអាកាសចរណ៍ ១ |

ប្រភព : របៀបសាយផ្លូវការរបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

អាកាសយានដ្ឋានកងកេង (ក្រុងព្រះសីហនុ) បានបើកបំរើការឡើងវិញ នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៧ និងកំពុងមានផែនការចាប់ផ្តើមជើងហោះហើរជាអន្តរជាតិនាពេលដ៏ខ្លីខាងមុខ។ អាកាសយានដ្ឋានខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅភាគខាងជើងទីក្រុងភ្នំពេញ និងនៅក្បែរផ្លូវជាតិលេខ ៥ ហាក់ដូចជានឹងចាប់ផ្តើមសេវាកម្មរបស់ខ្លួនឡើងវិញនាពេលខាងមុខនេះដែរ។ ការស្តាបនាផ្លូវតភ្ជាប់គឺកំពុងតែដំណើរការ ហើយគេក៏កំពុងតែរៀបចំ ផែនការក្នុងការតំឡើង

កំណល់ (siding) ផ្លូវរថភ្លើងដែរ។ ម្យ៉ាងវិញទៀត អាកាសយានដ្ឋានខេត្តកោះកុង បច្ចុប្បន្ននេះបានផ្អាកដំណើរការ។

អាកាសយានដ្ឋានធំ៧២ដែលកំពុងតែដំណើរការ គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានសៀមរាប និងអាកាសយានដ្ឋានកងកេង (ក្រុងព្រះសីហនុ) បានត្រូវប្រគល់កិច្ចសន្យាឱ្យក្រុមហ៊ុនរួមទុនគ្នារវាងបារាំង និងម៉ាឡេស៊ី សម្រាប់ប្រតិបត្តិការ គ្រប់គ្រង និងអភិវឌ្ឍន៍។

### ១០.២.៦ ផ្លូវដែក

នៅក្នុងប្រទេសកម្ពុជា មានផ្លូវដែកចំនួន២ខ្សែដែលកំពុងដំណើរការ គឺខ្សែភាគខាងជើង (ប្រវែង៣៨៦ គម) និងខ្សែភាគខាងត្បូង (ប្រវែង២៦៤គម) ដែលចេញដំណើរពីទីក្រុងភ្នំពេញ។ ចំពោះខ្សែភាគខាងជើង ជើងចេញដំណើរចុងក្រោយ ដែលមានប្រវែង៤៨គម ទៅកាន់ប៉ោយប៉ែត (ស៊ីសុផុន-ប៉ោយប៉ែត) កំពុងផ្អាក ដោយសារតែពុំមានការថែទាំយកចិត្តទុកដាក់ និងអំពើឆក់ប្លន់ ក្នុងរបបខ្មែរក្រហម។ បច្ចុប្បន្ននេះមានប្រជាជន រស់នៅមិនស្របច្បាប់ជាច្រើនជុំវិញផ្លូវរថភ្លើង ក្នុងកំណាត់ផ្លូវដែលផ្អាកដំណើរការនេះ។

ចំពោះខ្សែភាគខាងត្បូងវិញ មានបម្រើសេវាដឹកជញ្ជូនអ្នកដំណើរម្តង ក្នុង១សប្តាហ៍ និងប្រហែលជា ១០ដងក្នុង ១ ខែ សម្រាប់ការដឹកទំនិញ។ រថភ្លើងចេញដំណើរពីទីក្រុងភ្នំពេញ នៅវេលាម៉ោង ៦:៣០ ព្រឹក និង ទៅដល់ក្រុងព្រះសីហនុនៅម៉ោង ៥:៣០ល្ងាច។ ល្បឿនជាមធ្យមគឺតិចជាង៣០គម/ម៉។ នៅលើផ្លូវជាច្រើនមានការខ្វះខាតនូវប៉ុស្តិ៍ឡុងសម្រាប់ផ្លូវដែក និងពុំមានផ្លាកសញ្ញាចរាចរតាមបណ្តោយផ្លូវដែកទេ។ រថភ្លើងភាគច្រើនដឹកប្រេងសម្រាប់ម៉ាស៊ីន ស៊ីម៉ង់ និងអង្ករមកភ្នំពេញ ហើយដឹកឈើ និងថ្ម ត្រឡប់ទៅក្រុងព្រះសីហនុវិញ។ តារាង ១០-២-១៦ បង្ហាញពីការដឹកជញ្ជូនរបស់ផ្លូវដែកតាមខ្សែ និងមុខទំនិញ ក្នុងឆ្នាំ២០០៣។

**តារាង ១០-២-១៣ ការអនុវត្តការងារដឹកជញ្ជូនរបស់ផ្លូវដែក តាមខ្សែ និងមុខទំនិញ (ឆ្នាំ២០០៣)**

| | ខ្សែភាគខាងជើង | ខ្សែភាគខាងត្បូង |
|---|---|---|
| ផលិតផលប្រេងឥន្ធនៈ | ១៨.៩០០ តោន (១៥,៥%) | ១១៤.៩០០ (៣៨,២) |
| ស៊ីម៉ង់ | ៤៣.៧០០ (៣៥,៧) | ១៧៥.៧០០ (៥៨,៤) |
| អង្ករ | ៩.៥០០ (៧,៧) | ២.០០០ (០,៧) |
| ផ្សេងៗទៀត | ៥.០០០ (៤,១) | ២០០ (០,០៧) |
| ប្រតិបត្តិការខាងក្នុង | ៤៥.៤០០ (៣៧,១) | ៨.០០០ (២,៧) |
| សរុប | ១២២.៥០០ (១០០,០) | ៣០០.៧០០ (១០០,០) |

ប្រភព : ទំព័រ ក-៣-១ នៃរបាយការណ៍វឌ្ឍនភាព (Progress Report) នៃ "ការសិក្សារបស់ JICA ស្តីពីការអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់"

បច្ចុប្បន្ននេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងអនុវត្តគម្រោងមួយដែលមានឈ្មោះថា "ការសិក្សាសម្រាប់ការស្តារផ្លូវដែកឡើងវិញ នៅកម្ពុជា" ហើយគេរំពឹងថា របាយការណ៍នៃការសិក្សា និងផែនការស្តារឡើងវិញនេះ នឹងមានលទ្ធផល នៅចុងខែសីហា ឆ្នាំ២០០៦។ ADB កំពុងកំណត់គោលដៅ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពផ្លូវដែក ដោយប្រើថវិកាចំនួន២០លានដុល្លារ ក្នុងកំឡុងពេល៣ឆ្នាំ ដើម្បីឱ្យល្បឿនសេវាកម្ម អតិបរមា នឹងកើនឡើង រហូតដល់ ៥០គម/ម៉ោង។

រាជរដ្ឋាភិបាលកម្ពុជាមានផែនការផ្លាស់ទីតាំងស្ថានីយ៍នៅភ្នំពេញ ទៅជិតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញហើយប្រើប្រាស់ផ្លូវដែកចាស់ធ្វើជាផ្លូវមួយ សម្រាប់សម្រួលដល់ការកកស្ទះចរាចរ លើផ្លូវឆ្ពោះទៅកាន់ អាកាសយានដ្ឋាននេះ អាជ្ញាធរកំពង់ផែក្រុងព្រះសីហនុមានបំណងនឹងតម្លើង siding ទៅឱ្យទីធ្លាដាក់កុងធេនឺ របស់ខ្លួនហើយក្រុមហ៊ុនផលិតស៊ីម៉ង់នានាក្នុងខេត្តកំពត ក៏ស្នើសុំនូវ siding សម្រាប់រោងចក្ររបស់ពួកគេដែរ រីឯរាជរដ្ឋាភិបាលស្នើឱ្យគូសបួង់ siding ដ៏វែង ទៅកាន់អាកាសយានដ្ឋាន ក្នុងខេត្តកំពង់ឆ្នាំង។ ប្រសិនបើល្បឿនរថភ្លើងអតិបរមាទៅជា ៥០គម/ម៉ោង នៅពេលនោះត្រូវតែមានប្រព័ន្ធផ្តល់សញ្ញាថ្មី ដើម្បីសុវត្ថិភាពអ្នកឆ្លងកាត់។

### ១០.២.៧ កំពង់ផែសមុទ្រ

នៅក្នុងប្រទេសកម្ពុជាមានកំពង់ផែទឹកសមុទ្រដ៏ជ្រៅតែមួយប៉ុណ្ណោះនៅក្រុងព្រះសីហនុ។ វាបានបញ្ចប់ការពង្រីកដំណាក់កាលទីមួយនូវទីធ្លាដាក់កុងតេនឺរ ២៤០ម ហើយបច្ចុប្បន្ននេះកំពុងតែអនុវត្តការពង្រីក ដំណាក់កាលទីពីរ នូវផែនាវាចត ១៦០ម។ ប៉ុន្តែ ដោយសារតែគោលនយោបាយបើកចំហរសមុទ្ររបស់រាជរដ្ឋាភិបាល កំពង់ផែតូចមួយត្រូវបានបើកនៅក្បែរកំពង់ផែក្រុងព្រះសីហនុ ហើយវាកំពុងតែស្រូបទាញនូវបរិមាណទំនិញជាច្រើន ដែលដឹកដោយនាវាតូចៗ។ គេនិយាយថាកំពង់ផែតូច ដែលពាក់ព័ន្ធនេះគិតថ្លៃកំពង់ផែទាបជាងការជម្រះបញ្ជីគយ មានភាពងាយស្រួលជាងហើយពន្ធគយ ថោកជាង ពីព្រោះពេលខ្លះពន្ធគយនេះត្រូវបានផ្តល់ជំនួសដោយកម្រៃមិនផ្លូវការ។

### ១០.២.៨ ការដឹកជញ្ជូនតាមផ្លូវទឹកដែលនៅឆ្ងាយពីមាត់សមុទ្រ

បណ្តាញផ្លូវទឹកកម្ពុជាដែលឆ្ងាយពីមាត់សមុទ្រ ភាគច្រើនរួមមានទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ដែលសរុបទៅមានប្រវែងប្រហែល ១.៧៥០គ.ម នៅក្នុងរដូវវស្សា ហើយអាចស្រកចុះ នៅក្នុងរដូវប្រាំង រហូតដល់៥៨០គ.ម តែប៉ុណ្ណោះ ដែលកប៉ាល់អាចធ្វើនាវាចរណ៍បាន។ មានកំពង់ផែទន្លេធំៗ ចំនួន៧ ក្នុងប្រទេស កម្ពុជា ដូចខាងក្រោម :

កំពង់ផែភ្នំពេញ

កំពង់ផែកំពង់ចាម : ១០០គ.ម នៅផ្នែកខាងលើ ពីភ្នំពេញ នៅលើដំណើរខ្សែទឹកហូរនៃទន្លេមេគង្គ

កំពង់ផែក្រចេះ : ១១៥គ.ម នៅផ្នែកខាងលើ ពីកំពង់ផែកំពង់ចាម នៅលើដំណើរខ្សែទឹកហូរនៃទន្លេមេគង្គ

កំពង់ផែស្ទឹងត្រែង : ១៥០គ.ម នៅផ្នែកខាងលើ ពីកំពង់ផែក្រចេះ នៅលើដំណើរខ្សែទឹកហូរនៃទន្លេមេគង្គ

កំពង់ផែអ្នកលឿង : ៦០គ.ម នៅផ្នែកខាងក្រោម ពីកំពង់ផែភ្នំពេញ នៅលើដំណើរខ្សែទឹកហូរនៃទន្លេ មេគង្គ

កំពង់ផែកំពង់ឆ្នាំង : ៩០គ.ម នៅផ្នែកខាងលើ ពីភ្នំពេញ នៅលើទន្លេសាប

កំពង់ផែចុងឃ្នៀស (សៀមរាប) : ១៩០គ.ម នៅផ្នែកខាងលើ ពីកំពង់ផែកំពង់ឆ្នាំង នៅលើទន្លេសាប

ការដឹកទំនិញតាមកុងតេនឺរ គឺអាចធ្វើបានតែសម្រាប់ដើមកៅស៊ូ រវាងភ្នំពេញ និងកំពង់ចាមប៉ុណ្ណោះ។ ក្នុងកំឡុងពេលរដូវប្រាំង ខ្សែទឹកផ្នែកខាងលើនៃទន្លេមេគង្គ ពីកំពង់ចាម និងទន្លេសាប នឹងមិនអាចធ្វើនាវាចរណ៍បានទេ ពីព្រោះតែកម្រិតទឹករាក់។ ភាពខុសគ្នានៃកម្រិតទឹករវាងរដូវប្រាំង និងវស្សា ពេលខ្លះរហូតដល់ ១០ម ឯណោះ។ ហេតុដូច្នេះហើយ ការដឹកជញ្ជូនតាមផ្លូវទឹកដែលឆ្ងាយពីសមុទ្រទៅប្រទេសកម្ពុជា មានការកំណត់ព្រំដែន ដែលមិនអាចចៀសវាងបាន។

**១០.២.៩ ធនធានទឹក**

**(១) ការផ្គត់ផ្គង់ទឹកនៅទីក្រុង**

នៅទីក្រុងភ្នំពេញ អាជ្ញាធរផ្គត់ផ្គង់ទឹកភ្នំពេញ (PPWSA) ដែលជាសហគ្រាសសាធារណៈមួយ បាននឹងកំពុងផ្តល់ទឹក ចាប់តាំងពីឆ្នាំ ១៩៩៦។ បណ្តាញរបស់វាបានពង្រីកខ្លះ ដល់៣២០គ.ម ប៉ុន្តែវានៅតែត្រូវការការងារស្តារនីតិសម្បទា ទោះបីជាម្ចាស់ជំនួយជាច្រើន បាននិងកំពុងជួយយ៉ាងណាក៏ដោយ។

តំបន់ផ្សេងទៀតនៃប្រទេស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ជាអ្នកទទួលខុសត្រូវចំពោះការផ្គត់ផ្គង់ទឹកនៅទីក្រុង ហើយនៅក្នុងករណីជាច្រើន វាផ្តល់ដល់បណ្តាក្រុមហ៊ុនឯកជននូវអាជ្ញាប័ណ្ណដែលផ្តល់សិទ្ធិសម្រាប់ផ្គត់ផ្គង់ទឹកជាលក្ខណៈអាជីវកម្ម។ ក្រុងព្រះសីហនុ គឺជាករណីលើកលែងតែមួយគត់ដែលមានអាជ្ញាធរផ្គត់ផ្គង់ទឹកក្រុងព្រះសីហនុ ជាអ្នកកំពុងផ្គត់ផ្គង់ទឹកទៅឱ្យទីក្រុង។

**(២) ការផ្គត់ផ្គង់ទឹកនៅជនបទ**

នៅក្នុងតំបន់ជនបទ ប្រជាជនភាគច្រើនពឹងផ្អែកលើទឹកក្នុងដី ទឹកទន្លេ និង/ឬទឹកភ្លៀង។ ទោះបីជា កម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ គឺប្រហែល ៤.០០០ម.ម នៅប្រទេសកម្ពុជា យ៉ាងណាក៏ដោយ ក៏មានការខុសប្លែកគ្នាយ៉ាងធំធេងរវាងរដូវវស្សា និងរដូវប្រាំង ហើយលើសពីនេះទៀត ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ជា ហេតុធ្វើឱ្យមានការលំបាកក្នុងការធានាការផ្គត់ផ្គង់ទឹកឱ្យមាននិរន្តរភាព សម្រាប់កសិកម្ម។

**(៣) ទឹកសម្រាប់ឧស្សាហកម្ម**

ប្រសិនបើមានតំបន់ឧស្សាហកម្មជាច្រើន ដែលនឹងត្រូវបានបង្កើតឡើង នៅក្នុងតំបន់ក្រុងព្រះសីហនុនោះការធានាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ឧស្សាហកម្ម នឹងជាបញ្ហាដែលលំបាកបំផុត។ ទោះបីជាគេអាចពឹងពាក់ទៅលើទឹកក្នុងដី ជា

ប្រភពផ្គត់ផ្គង់ដ៏មានស្ថេរភាពមួយក៏ដោយ ក៏គុណភាពទឹកអាចនឹងមិនឆ្លើយតបទៅនឹង តម្រូវការរបស់ឧស្សាហកម្មខ្លះដែរ ដោយសារតែសមាសធាតុអំបិល។ មធ្យោបាយមួយក្នុងចំណោមជាច្រើនក្នុង ការប្រឈមនឹងបញ្ហានេះ គឺទទួលទឹកពីទន្លេក្បាលឆាយ និងបញ្ជូនវាតាមម៉ាស៊ីនបូមទឹក កាត់តាមបំពង់ទុយោរ ទៅកាន់តំបន់ក្រុងព្រះសីហនុ។ ទោះបីវាចំណាយច្រើនក៏ដោយ ក៏វានឹងជាមធ្យោបាយតែមួយគត់ ដើម្បីធ្វើឱ្យទឹកមានគ្រប់គ្រាន់សម្រាប់ឧស្សាហកម្ម នៅក្នុងតំបន់ប្រសិនបើបណ្តាតំបន់ឧស្សាហកម្មធំ៧នឹងត្រូវបានបង្កើតមែននោះ។ ក្រុមហ៊ុនផលិតថាមពលឯករាជ្យ (IPP) របស់ចិនមួយ ឥឡូវនេះកំពុងមានផែនការកសាងទំនប់មួយ ដើម្បីបង្កើតថាមពលនៅកំចាយ ខេត្តកំពត ហើយគេអាចយកទឹកសម្រាប់ឧស្សាហកម្ម នៅត្រង់ខ្សែទឹក ហូរចុះនៃទំនប់។ ទាំងប៉ៃលិន និងកោះកុង ក៏ស្ថិតនៅក្នុងលក្ខខណ្ឌប្រសើរដែរ ពីព្រោះវាមានការផ្គត់ផ្គង់ទឹក ដែលផុសឡើង។

ទន្លេមេគង្គក៏អាចជាប្រភពផ្គត់ផ្គង់ទឹកគួរជាទីពឹងពាក់បានផងដែរប៉ុន្តែមានបញ្ហាពីរ។ បញ្ហាទីមួយគឺថា គេមិនអនុញ្ញាតឱ្យនរណាម្នាក់យកទឹកដោយសេរីពីមេគង្គទេពីព្រោះវាជាទន្លេអន្តរជាតិមួយដែលប្រទេសជាច្រើនមានផលប្រយោជន៍។

បញ្ហាទីពីរគឺថា ជាតិអាសេទិកចូលទៅក្នុងទន្លេពីដី នៅត្រង់ចំណុចខ្លះ តាមខ្សែទឹកហូរ ហើយដែលចាំបាច់ត្រូវមានការប្រុងប្រយ័ត្ន។

# ជំពូកទី ១១
# អនុសាសន៍ក្នុងការអភិវឌ្ឍន៍សមត្ថភាពសំរាប់ការជំរុញការវិនិយោគនៅក្នុង ក.អ.ក/គ.វ.ក

## ១១.១ សេចក្តីផ្តើម

នៅក្នុងជំពូកនេះ ការអភិវឌ្ឍន៍សមត្ថភាពលើកស្ទួយការធ្វើវិនិយោគទុននៅក្នុង ក.អ.ក/គ.វ.ក នឹងត្រូវបានគេលើកយកមកនិយាយ។ ក.អ.ក/គ.វ.ក បានកំពុងផ្តោតលើការធ្វើអោយប្រសើរឡើងផ្នែកបរិយាកាសច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយនិងបន្ទាប់មកទៀត បុគ្គលិកទាំងអស់នៅក្នុង ក.អ.ក/គ.វ.ក អោយមានចំណេះដឹងខ្ពស់ខាងច្បាប់។ ផ្ទុយទៅវិញ វាពិបាកខ្លាំងណាស់ក្នុងការនិយាយថា ក.អ.ក/គ.វ.ក មានប្រពន្ធ័អង្គការចាត់តាំងមួយដែលត្រូវបាន ផ្អែកលើរបៀបរបបធ្វើជំនួញធម្មតា រាប់បញ្ចូលទាំងការកំណត់អំពីតំរូវការរបស់អ្នកវិនិយោគទុន។ ក្រោយមកទៀត បុគ្គលិករបស់ ក.អ.ក/គ.វ.ក នឹងបានមានអត្ថប្រយោជន៍ពីចំណេះដឹងខាងជំនួយដែលត្រូវបានពង្រឹង។ គោលបំណងនៃជំពូកនេះ គឺដើម្បីលើកឡើងនូវគោលការណ៍នានាដើម្បីលើកស្ទួយការធ្វើវិនិយោគនៅទីផ្សារខាងក្រៅ ជាពិសេសប្រទេសជប៉ុន ក្នុងទស្សនៈមួយនៃបណ្តាញជំនួយមួយ។ ដំបូងឡើយការវិភាគមួយទៅលើអង្គការចាត់តាំងសំរាប់ ក.អ.ក/គ.វ.ក នឹងត្រូវបានគេលើកយកមកពិនិត្យ។ ទីពីរ ការអភិវឌ្ឍន៍អង្គការនៅក្នុង ក.អ.ក/គ.វ.ក នឹងត្រូវបានគេផ្តល់អនុសាសន៍ ក្រោយមកទៀត មានការផ្តល់យោបល់នានាសំរាប់ការលើកស្ទួយការធ្វើវិនិយោគទុន។ ទីបួន ការអនុវត្តអនុសាសន៍តាមការកំណត់ នឹងត្រូវបានគេ លើកឡើង។

## ១១.២ ការវិភាគស្ថាប័នសំរាប់ ក.អ.ក/គ.វ.ក

### ១១.២.១ ទិដ្ឋភាពទូទៅនៃ ក.អ.ក/គ.វ.ក

រដ្ឋាភិបាលកម្ពុជាបានធ្វើកម្មវិធីកំណែទំរង់មួយដើម្បីលើកស្ទួយការអភិវឌ្ឍន៍វិស័យឯកជននៅឆ្នាំ១៩៩៤។ ជាផ្នែកមួយនៃការធ្វើកំណែទំរង់នេះច្បាប់ ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៤ បានបង្កើតស្ថាប័នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលស្ថាប័ននេះបានក្លាយទៅ ជាស្ថាប័នសំរេចខ្ពស់បំផុត របស់រដ្ឋាភិបាល សំរាប់ការវិនិយោគឯកជននិងសាធារណៈ។ គណៈកម្មាធិការវិនិយោគកម្ពុជា "គ.វ.ក" គឺស្ថាប័នប្រតិបត្តិការរបស់ កអ.ក សំរាប់ការវិនិយោគឯកជន។ ស្ថាប័ន គ.វ.ក ពិនិត្យលើការដាក់ពាក្យសុំ និងផ្តល់ការយល់ព្រមអោយវិនិយោគិន និងគំរោងវិនិយោគនានាដែលត្រូវតាមតំរូវការរបស់ច្បាប់វិនិយោគបរទេសឆ្នាំ ១៩៩៤ ដែលកំណត់បែបបទ សំរាប់វិនិយោគបរទេស និងបានផ្តល់ការលើក ទឹកចិត្តសំរាប់ការប្រកួតប្រជែង សំរាប់ការ វិនិយោគឯកជនដោយផ្ទាល់។ ស្ថាប័ន ក.អ.ក/គ.វ.ក ដឹកនាំដោយនាយករដ្ឋមន្ត្រីសម្តេចហ៊ុន សែន និងបង្កើតឡើង ដោយរដ្ឋមន្ត្រីថ្នាក់ខ្ពស់ពីបណ្តាស្ថាប័ន របស់រដ្ឋាភិបាលដែលមានការពាក់ពន្ធ័។ អគ្គលេខាធិការ ក.អ.ក ដឹកនាំការងាររដ្ឋបាលនៃប្រតិបត្តិការនេះ។ ស្ថាប័នមួយទៀតរបស់ ក.អ.ក គឺគណៈកម្មការនីតិសម្បទានិងការអភិវឌ្ឍន៍កម្ពុជា "គ.ជ.នា" បានត្រូវបង្កើតឡើងដើម្បី សំរបសំរួលជំនួយ

អភិវឌ្ឍន៍ផ្លូវការ (ODA) ពីបណ្ដាអង្គការផ្ដល់ជំនួយនានានៅឆ្នាំ ១៩៩៤។ ការបង្កើត បន្ថែមថ្មីៗបំផុតទៀត គឺគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា "គ.ស.ព" ដែលជាស្ថាប័នមួយចេញពីស្ថាប័ន ក.អ.ក/គ.វ.ក ដោយសារលទ្ធផលនៃសេចក្ដីប្រកាសនៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស (SEZ) នៅខែធ្នូ ឆ្នាំ ២០០៥ ។ ក្នុងគោលបំណងដើម្បីបង្កើត និងគ្រប់គ្រងតំបន់ពិសេស និងដើម្បីធានាថាបរិយាកាសវិនិយោគជួយជំរុញដល់សកម្មភាពផលិតកម្ម ការប្រកួតប្រជែង កំណើនសេដ្ឋកិច្ចជាតិ ជំរុញការនាំចេញ ការបង្កើតការងារ។ ស្ថាប័ន ក.អ.ក/គ.វ.ក និង គ.ស.ព ផ្ដល់សេវាច្រកចេញចូលតែមួយផ្ដល់ការសំរេចចិត្ត ទាក់ទងនឹងការអនុញ្ញាត និងការលើកទឹកចិត្តវិនិយោគ ក្នុងរយៈ ពេលតិចជាង28ថ្ងៃបន្ទាប់ពីបានផ្ដល់នូវវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខ័ណ្ឌ។ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស វិនិយោគិន នឹងត្រូវបានផ្ដល់អោយនូវការលើកលែងពន្ធសំរាប់ការនាំចូលសំភារៈបរិក្ខារផលិតកម្ម បរិក្ខារសាងសង់ និងធាតុចូលផលិតកម្ម។

### ១១.២.២ នាយកដ្ឋាន ចំណុះ គ.វ.ក

នៅក្នុងស្ថាប័ន គ.វ.ក មាននាយកដ្ឋានចំនួនប្រាំបីស្ថិតក្រោមការដឹកនាំរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង ដោយមានបុគ្គលិកជាង ៥០ នាក់ដែលត្រូវបានរើសមកបំរើការនៅក្នុងស្ថាប័ននេះ។ បុគ្គលិកភាគច្រើននៅក្នុងស្ថាប័ន CIB ត្រូវបានបញ្ជូនមកពីក្រសួងត្រួវខ្សែបណ្ដាញផ្សេងៗ ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងបរិស្ថាន និងបណ្ដាក្រសួងផ្សេងៗទៀត។ ភារៈកិច្ចចំបងរបស់នាយកដ្ឋាននីមួយៗនៅក្នុងស្ថាប័ន CIB ត្រូវបានសង្ខេបដូចខាងក្រោមនេះ។

**(១) នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងលើកស្ទួយការវិនិយោគៈ**

- (i) *ជំរុញការវិនិយោគដោយផ្ទាល់ពីបរទេសចូលមកក្នុងប្រទេសកម្ពុជា ។*
- (ii) *ជួយស្ថាប័ន គ.វ.ក លើកិច្ចការជាច្រើនទាក់ទងទៅនឹងការចូលជាសមាជិក WTO របស់ប្រទេសកម្ពុជា ។*
- (iii) *រៀបចំ និងគ្រប់គ្រងឯកសារទាំងអស់នៃក្រុមហ៊ុនវិនិយោគ ដោយដាក់បញ្ចូលជាប្រព័ន្ធទិន្នន័យ ។*
- (iv) *រៀបចំកម្មវិធីនានាដូចជាសន្និសិទ សិក្ខាសាលា និងវេទិកានានា ។*
- (v) *បោះពុម្ពផ្សាយយុទ្ធសាស្ត្រនៃវិនិយោគឯកជនដែលទាក់ទងទៅនឹងរដ្ឋាភិបាល ។*
- (vi) *ជួយសំរបសំរួលអ្នកវិនិយោគទុនដោយអោយគេទំនាក់ទំនងដោយផ្ទាល់ជាមួយស្ថាប័នពាក់ព័ន្ធនានាហើយ និង;*
- (vii) *សំរបសំរួលការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការតំបន់ (អាស៊ាន) មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន និងអង្គការអន្តរជាតិនានា។*

**(២) នាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្តៈ**

- (i) *ពិនិត្យគំរោងស្នើសុំវិនិយោគ;*
- (ii) *សិក្សា និងវាយតម្លៃលើការសិក្សាលទ្ធភាពវិនិយោគនានា;*
- (iii) *ផ្ដល់យោបល់ដល់អ្នកដាក់ពាក្យសុំដើម្បីកែតំរូវកំហុសផ្សេងៗនៅក្នុងការបំពេញបែបបទ និងឯកសារផ្សេងៗ;*

(iv) *រៀបចំ និងបំពេញបែបបទឯកសារផ្សេងៗដែលទាក់ទងទៅនឹងគំរោងស៊ីនិយោគដាក់ជូនកិច្ចប្រជុំច្រកចេញ-ចូលតែមួយ;*

(v) *ធ្វើការត្រួតពិនិត្យលើគ្រប់វិនិយោគទាំងអស់ ។*

**(៣) នាយកដ្ឋានវាយតំលៃខាងបរិស្ថានៈ**

(i) *ធ្វើការសំរបសំរួលការរៀបចំជាមួយក្រសួងបរិស្ថាន ។*

**រូបភាព ១១-២-១ រចនាសម្ព័ន្ធរបស់ ក.អ.ក/គ.វ.ក**



**(៤) នាយកដ្ឋានសម្របសម្រួលកិច្ចការអន្តរក្រសួងៈ**

(i) *រៀបចំកំណត់ហេតុប្រជុំនៃវេទិការដ្ឋាភិបាលសំរាប់ផ្នែកឯកជន*

(ii) *សរសេរកំណត់ហេតុនៃកិច្ចប្រជុំច្រកចេញ-ចូលតែមួយ*

(iii) *ពិនិត្យគំរោងស្នើសុំការលើកលែងពន្ធនាំចូលរបស់ក្រុមហ៊ុនកាត់ដេរ និងគំរោងពង្រីករបស់ក្រុមហ៊ុនកាត់ដេរដទៃទៀត ចាប់ពីឆ្នាំទីពីរ ដើម្បីដាក់ជូនកិច្ចប្រជុំអន្តរក្រសួង*

(iv) *រៀបចំរបៀបវារៈ និងរបាយការណ៍នានារបស់កិច្ចប្រជុំអន្តរក្រសួងស្តីពីការលើកលែងពន្ធនាំចូល ហើយនិង*

(v) ជួយ "គ.វ.ក" លើកិច្ចការជាច្រើនទាក់ទងទៅនឹងការចូលជាសមាជិក WTO របស់ប្រទេសកម្ពុជា ។

**(៥) នាយដ្ឋានវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជនៈ**

(i) *ផ្តួចផ្តើមយុទ្ធសាស្ត្រសំរាប់ពេលបច្ចុប្បន្ន និងយូរអង្វែង ។*

**(៦) នាយកដ្ឋាននិតិកម្ម និង ច្បាប់វិនិយោគៈ**

(i) *ផ្តល់ការប្រឹក្សាច្បាប់ដល់ គ.វ.ក ។*

(ii) *សំរបសំរួលការបង្រួបបង្រួមសំរាប់រាល់ជំលោះទាំងអស់របស់ក្រុមហ៊ុនវិនិយោគ ។*

(iii) *សិក្សា និងតាក់តែងច្បាប់ បទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការវិនិយោគ ។*

(iv) *ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាត លើ ប្រការ និង អនុស្សារណៈរបស់ក្រុមហ៊ុន ។*

(v) *ជួយ គ.វ.កលើបញ្ហានានាដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងទ្វេភាគីលើការជំរុញនិងការការពារវិនិយោគរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសនានា ។*

(vi) *ជួយ CIB លើបញ្ហានានាដែលទាក់ទងសំណើររបស់ក្រុមហ៊ុនក្នុងការប្តូរភាគហ៊ុន ប្តូរឈ្មោះ ប្តូរទីតាំង ការទិញ និង ការបញ្ចូលគ្នា ។ល ។*

**(៧) នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគៈ**

(i) *ត្រួតពិនិត្យ និងតាមដានការវិនិយោគ និង ប្រតិបត្តិគម្រោង*

(ii) *ប្រមូលទិន្នន័យរបស់សកម្មភាពវិនិយោគ*

(iii) *ត្រួតពិនិត្យ និងរាយការណ៍ទីតាំងវិនិយោគដែលស្នើដោយក្រុមហ៊ុនមុននឹងធ្វើការពិនិត្យសំរេចដោយច្រកចេញ-ចូលតែមួយ និង ក្រុមប្រឹក្សានាយក ក.អ.ក ។*

(iv) *ត្រួតពិនិត្យ រាយការណ៍ និងគណនាលើការនាំចេញ-នាំចូលដោយរួចពន្ធដែលស្នើឡើងដោយក្រុមហ៊ុន និងសហគ្រាស ។*

(v) *ត្រួតពិនិត្យ និងរាយការណ៍លើការប្តូរទីតាំង អាជ្ញាប័ណ្ណ រយះពេលពន្ធលើប្រាក់ចំនេញ និងការពង្រីកគំរោងវិនិយោគដែលស្នើដោយក្រុមហ៊ុនវិនិយោគ ។*

(vi) *ត្រួតពិនិត្យ និងរាយការណ៍លើការដកលក់ និងដកប្រាក់របស់ក្រុមហ៊ុនវិនិយោគ ។*

(៨) **នាយកដ្ឋានរដ្ឋបាលៈ**

(i) *ផ្តល់សេវារដ្ឋបាលទូទៅ ។*

(ii) *គ្រប់គ្រងបុគ្គលិក ចុះបញ្ជីរាល់លិខិតស្នាមនៅក្នុងសៀវភៅចុះបញ្ជី និងទទួលរាល់គំរោងស្នើសុំទាំងអស់ ។ ហើយនិង*

(iii) *សរសេរ និងបញ្ជូនលិខិតផ្លូវការនៅក្នុងក្របខ័ណ្ឌCIB ក៏ដូចជាអតិថិជន ។*

**១១.២.៣ បញ្ហាប្រឈមបច្ចុប្បន្ននៅ ក.អ.ក/គ.វ.ក**

ជាបឋម ការលំបាកចម្ចតាអាចត្រូវបានគេចង្អុលបង្ហាញនៅក្នុងគ្រប់នាយកដ្ឋានទាំងអស់របស់ ក.អ.ក/គ.វ.ក។ ការលំបាកទាំងនេះមានដូចជា (i) ការខ្វះខាតម៉ាស៊ីនកំព្យូទ័រ និងសូហ្វែ software, (ii) កង្វះខាតរបស់បុគ្គលិកផ្នែកជំនាញ IT និង (iii) កង្វះខាតរបស់បុគ្គលិកផ្នែកជំនាញភាសាបរទេស ជាពិសេសភាសាអង់គ្លេស។ ទាក់ទងទៅនិងម៉ាស៊ីនកុំព្យូទ័រ នាយកដ្ឋានរដ្ឋបាលមានបញ្ហាធ្ងន់ធ្ងរមែនទែន។ ភារៈកិច្ចសំខាន់មួយ ក្នុងចំណោមភារៈកិច្ចសំខាន់ៗរបស់នាយកដ្ឋាននេះ គឺត្រូវសរសេរលិខិតផ្លូវការ ហើយផ្ញើរទៅក្រសួងផ្សេងៗ ក៏ដូចជាអង្គការផ្សេងៗនៅខាងក្រៅស្ថាប័ន។ ដោយសារម៉ាស៊ីនកំព្យូទ័រ ម៉ាស៊ីនបោះពុម្ព printers និងម៉ាស៊ីនថតចំលងចាស់ៗ ជាហេតុបង្កនូវការលំបាកនៅក្នុងការផ្តល់សេវាបែបនេះអោយមានលក្ខណៈសមរម្យមួយ។ ទាក់ទងទៅនឹងកម្មវិធីកុំព្យូទ័រ ការចាប់ផ្តើមប្រើប្រព័ន្ធទិន្នន័យហាក់ដូចជាការចាំបាច់មួយសំរាប់នាយកដ្ឋាននានា នៅក្នុងក្របខ័ណ្ឌ ក.អ.ក ក្នុងគោលបំណងដើម្បីចែករំលែកព័ត៌មានគ្នា។ ទីពីរ ការលំបាកធំមួយទៀតក្នុងចំណោមការលំបាកនានានៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក ត្រូវបានទាក់ទងទៅនឹងបញ្ហាហិរញ្ញវត្ថុ។ ឧទាហរណ៍ ដោយសារថវិកាមានកំរិតចំនួន (US$ 2,000-10,000 ក្នុងមួយឆ្នាំ) នៅក្នុងនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញគំរោងវិនិយោគឯកជន មានការលំបាកនៅក្នុងផលិតឯកសារសំរាប់ការជំរុញការវិនិយោគ។ ប្រាក់បៀវត្សរ៍របស់បុគ្គលិកនៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក ជាទូទៅតិចជាងឆ្ងាយណាស់ប្រៀបធៀបទៅ និងផ្នែកឯកជន ដូច្នេះវាហាក់ដូចជាពិបាកសំរាប់បុគ្គលិកដើម្បីរក្សាការយកចិត្តទុកដាក់ខ្ពស់នៅក្នុងការិយាល័យ។ ជាងនេះទៅទៀតស្ថាប័ន ក.អ.ក/គ.វ.ក កំពុងប្រឈមមុខការលំបាកនៅក្នុងការរើសបុគ្គលិកថ្មី។ ទីបី ការលំបាកផ្សេងៗដែលនាយកដ្ឋាននីមួយៗ កំពុងជួបប្រទះត្រូវបានសង្ខេបនៅក្នុងតារាង 11-2-1 ។

**តារាង ១១-២-១ បញ្ហាប្រឈមនៅក្នុងនាយកដ្ឋាន ចំពោះ ក.អ.ក/គ.វ.ក**

| នាយកដ្ឋាន | បញ្ហាផ្សេងៗ |
|---|---|
| នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញគម្រោងវិនិយោគឯកជន | កង្វះខាតបុគ្គលិកជំនាញ ផ្នែកជំរុញការវិនិយោគ ទំនាក់ទំនងសាធារណៈ និង ភាសាបរទេស |
| នាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត | ទូទៅ |
| នាយកដ្ឋាន វាយតំលៃខាងបរិស្ថាន | ទូទៅ |

| | |
|---|---|
| នាយកដ្ឋានសម្របសម្រួលកិច្ចការ<br>អន្តរក្រសួង | កង្វះខាតក្នុងការចែករំលែកពតិមានជាមួយនាយកដ្ឋានផ្សេងៗ |
| នាយកដ្ឋានវិភាគយុទ្ធសាស្ត្រ<br>នៃការវិនិយោគឯកជន | ទូទៅ |
| នាយកដ្ឋាននិតិកម្ម និង<br>ច្បាប់វិនិយោគ | ទូទៅ |
| នយកដ្ឋានត្រួតពិនិត្យ<br>និងតាមដានគម្រោងវិនិយោគ | កង្វះមធ្យោបាយសំរាប់ធ្វើការត្រួតពីនិត្យ(ដូចជាមធ្យោបាយធ្វើដំណើរ ទូរស័ព្ទ អ៊ិនធឺណេត ម៉ាស៊ីនថត,,,) របៀបប្រមូលពតិមាន, ទំនាក់ទំនងជាមួយវិនិយោគិន និងភាសាបរទេស) |
| នាយកដ្ឋានរដ្ឋបាល | សំភារះការិយាល័យចាស់ៗ |
| គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា | ដោយសារស្ថាប័នទើបតែបង្កើតថ្មីដូចនេះមានភាពខ្វះខាតជំនាញជាច្រើនដោយរួមបញ្ចូលទាំង<br>ការវិភាគគំរោងនិងប្រមូលពតិមាន |

Source: JICA Study Team

**Deleted:** កង្វះខាតបុគ្គលិកជំនាញ ត្រួតពិនិត្យ តាមដាន ប្រមូលពតិមាន និងទំនាក់ទំនងវិនិយោគ
**Formatted:** Font: 16 pt, Not Bold
**Formatted:** Font: 16 pt, Not Bold
**Formatted:** Font: 16 pt, Not Bold
**Formatted:** Font: 16 pt, Not Bold
**Formatted:** Font: 16 pt, Not Bold
**Formatted:** Font: 16 pt

## ១១.៣ ការអភិវឌ្ឍន៏អង្គការចាត់តាំងនៅក្នុង ក.អ.ក/គ.វ.ក

### ១១.៣.១ ការបង្កើតអោយមានបណ្ណាល័យផ្ទុកឯកសារ

ដូចដែលបានរៀបរាប់ខាងលើ ការលំបាកក្នុងពេលបច្ចុប្បន្នរបស់ស្ថាប័ន ក.អ.ក/គ.វ.ក គឺពាក់ព័ន្ធទៅនឹងទំនាក់ទំនងវិនិយោគ ការបង្កើតឱ្យមានបណ្ណាល័យផ្ទុកឯកសារ ត្រូវបានលើកឡើងក្នុងផែនការរយះពេលខ្លីក្នុងការបំរើសេវាវិនិយោគ។ សេវាកម្មដែលត្រូវផ្តល់អោយ ត្រូវបានរំពឹងទុកប្រកបដោយប្រសិទ្ធភាមដោយហេតុការលំបាកក្នុងការប្រមូលពតិមាន ដែលទាក់ទងទៅនឹងការវិនិយោគនៅកម្ពុជា។ ពតិមានទាំងអស់ដែលពាក់ព័ន្ធ ត្រូវបានដាក់ក្នុងបណ្ណល័យហើយអ្នកវិនិយោគមានសិទ្ធិទទួលបានពតិមានទាំងនោះកំឡុងពេលម៉ោងធ្វើការ។ ពតិមានទាំងនោះរួមមានទាំងពតិមានស្តីពី ក្រុមហ៊ុន ស្តីពីផលិតផល បច្ចេកវិជ្ជា វិស័យ និងច្បាប់របស់កម្ពុជា។ ជាពិសេស ក.អ.ក/គ.វ.ក ចាំបាច់គ្រប់គ្រងពតិមានដែលមានការពាក់ព័ន្ធទៅនឹងច្បាប់ បទប្បញ្ញត្តិ និងអនុក្រិតផ្សេងៗ ក្នុងទំរង់មួយច្បាស់លាស់ដើម្បីងាយស្រួលក្នុងការផ្តល់ជូនអ្នកវិនិយោគ។ ក.អ.ក/គ.វ.ក ចាំបាច់រៀបចំអោយមានសេវាថតចំលង។ ជាការសំខាន់ក្នុងការបង្កើតអោយមានបណ្ណាល័យផ្ទុកឯកសារ ជាមជ្ឈមណ្ឌលពតិមានសំរាប់វិនិយោគិន ដែលជាកត្តានាំឆ្ពោះទៅការធ្វើអោយប្រសើរឡើងនូវសេវាកម្មវិនិយោគ។

### ១១.៣.២ កិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងការចែករំលែកព័តិមាន

វាត្រូវគេមើលឃើញថា ការលំបាកមួយចំនួនសំរាប់ស្ថាប័ន ក.អ.ក/គ.វ.ក គឺកិច្ចសហការពីនាយកដ្ឋានមួយទៅនាយកដ្ឋានមួយ នៅមានកំរិត និងកង្វះការចែករំលែកពតិមាន ជាពិសេស ប្រតិបត្តិការត្រួតពិនិត្យនៅក្នុងក្របខ័ណ្ឌ ក.អ.ក/គ.វ.ក ។ ប្រតិបត្តិការត្រួត ពិនិត្យនេះចែកជាពីរដំណាក់កាលខុសគ្នា ដែលពាក់ព័ន្ធទៅនឹង

**Formatted:** Indent: Left: 0 cm, Line spacing: At least 0 pt
**Formatted:** Font: Not Bold

នាយកដ្ឋានចំនួន៣ : គឺនាយកដ្ឋានវិភាគគំរោង វិនិយោគ និងការលើក ទឹកចិត្ត ,នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ និងនាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង។ ដំណាក់ទី១ គឺការចុះត្រួតពិនិត្យចំពោះរាល់សំណើសុំវិនិយោគទាំងអស់ (លើកលែងតែក្នុងតំបន់សេដ្ឋកិច្ចពិសេស) មុនពេលចេញវិញ្ញាបនបត្រ័ចុះបញ្ជីជាស្ថាពរ។ កិច្ចការនេះ ពាក់ព័ន្ធនឹងនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ និងនាយកដ្ឋានវិភាគគំរោងវិនិយោគ និងការលើកទឹកចិត្ត។ ដោយសារតែការចេញវិញ្ញាបនបត្រ័ចុះបញ្ជីជាស្ថាពរ ជាភារៈកិច្ចរបស់នាយកដ្ឋានវិភាគគំរោងវិនិយោគ និងការ លើកទឹកចិត្ត ដូច្នេះនាយកដ្ឋាននេះ មានរក្សាទុកពតិមាន របស់វិនិយោគក្នុងស្រុកក៏ដូចជាវិនិយោគបរទេស ផ្អែកលើការអនុញ្ញាតិ អោយវិនិយោគ ។ លទ្ធផលនៃការចុះពិនិត្យក្នុងដំណាក់កាលនេះក៏ជាមូលដ្ឋានសំរាប់អោយនាយកដ្ឋានវិភាគគំរោងវិនិយោគ និង ការលើកទឹកចិត្ត ផ្ដល់ការលើកទឹកចិត្តអោយក្រុមហ៊ុនធ្វើការនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ នូវសំភារៈសំណង់ គ្រឿងម៉ាស៊ីន និងសំភារៈបរិក្ខា ព្រមទាំងធាតុចូលសំរាប់បំរើអោយផលិតកម្មរបស់ខ្លួនក្នុងឆ្នាំទី១។ ចំពោះដំណាក់ទី២ នៃការចុះត្រួតពិនិត្យ គឺធ្វើឡើងចំពោះសំណើសុំនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ សំរាប់ឆ្នាំទី២នៃដំណើរការផលិតកម្មរបស់ក្រុមហ៊ុន។ នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ និងនាយកដ្ឋានវិភាគគំរោងវិនិយោគ និងការលើកទឹកចិត្តនៅតែបន្ត សហការគ្នាចុះត្រួតពិនិត្យលើគ្រប់ឧស្សាហកម្ម លើកលែងតែឧស្សាហកម្មកាត់ដេរ។ ការចុះពិនិត្យឧស្សាហកម្មកាត់ដេរចាប់ពីឆ្នាំទី២នៃផលិតកម្ម នេះជាភារៈកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ និង នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង។ ប៉ុន្តែនាយកដ្ឋានចុងក្រោយនេះ មិនធ្វើកិច្ចការពង្រីកអាជីវកម្មឡើយ ព្រោះកិច្ចការ នេះជាភារៈកិច្ចរបស់នាយកដ្ឋានវិភាគគំរោងវិនិយោគ និងការលើកទឹកចិត្ត។ ដូចនេះ ជាលទ្ធផលនៃប្រតិបត្តិការត្រួតពិនិត្យ នាយកដ្ឋានវិភាគគំរោងវិនិយោគ និងការលើកទឹកចិត្តមានពតិមានថ្មីសុក្រិត្យអំពី ឧស្សាហកម្មផ្សេងដ៏ទៃទៀត ក្នុងខណៈដែលនាយកដ្ឋាន សំរបសំរួលកិច្ចការអន្តរក្រសួង មានពិតមានសុក្រឹត្យ អំពីការសុំនាំចូលដោយ ពន្ធជាបន្ទុករបស់រដ្ឋចាប់ពីឆ្នាំទី២ឡើងទៅ របស់វិស័យកាត់ដេរ (លើកលែងការពង្រីកអាជីវកម្ម)។ ទោះជាយ៉ាងណាក៏ដោយ យើងឃើញថា ការចែករំលែកពិតមាននៅមានកំរិតតិចតួច រវាងនាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត, នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោង និងនាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង។ ជាលទ្ធផល ដោយសារការបែងចែកនេះហើយ ទើបពិតមានត្រូវបានរក្សាទុកដោយអន្លើ១ នៅតាមនាយកដ្ឋានទាំង៣ ដែលវាមានការលំបាកក្នុងកាប្រមូលផ្តុំពិតមានទាំងអស់នេះ។ បន្ថែមលើនេះទៀត ក្រោយការត្រួតពិនិត្យនៃប្រតិបត្តិការរវាងនាយកដ្ឋានទាំងបី ឃើញថានាយកដ្ឋាននីតិកម្ម និង ច្បាប់វិនិយោគ ទទួលបន្ទុកលើកិច្ចការ កែប្រែលក្ខន្តិកៈ ភាគហ៊ុន និងទីតាំងក្នុងករណីដែលមានការផ្លាស់ប្តូរ ។ល។ ដូច្នេះគ្រប់នាយកដ្ឋានទាំងអស់នៅ ក្នុងស្ថាប័ន ក.អ.ក/គ.វ.គ ត្រូវសហការគ្នា និងចែករំលែកព័តិមានគ្នា។

ដើម្បីសំរេចបានការចែករំលែកព័តិមានគ្នាក្នុងចំណោមនាយកដ្ឋានទាំងអស់នេះ ការបង្កើតអោយប្រើទិន្នន័យមូលដ្ឋានមួយគឺជាការសំខាន់នៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក។ តាមពិតបណ្តាញក្នុងអង្គភាពមួយ (LAN) ត្រូវបានដំឡើងដើម្បីចែកចាយពតិមាននៅក្នុងនាយកដ្ឋានជាច្រើន រាប់បញ្ចូលទាំងនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងការជំរុញការ

**Deleted:** វាត្រូវគេមើលឃើញថា ការលំបាកមួយចំនួនសំរាប់ស្ថាប័ន ក.អ.ក/គ.វ.ក គឺកិច្ចសហការពីនាយកដ្ឋានមួយ ទៅនាយកដ្ឋានមួយនៅ និងកង្វះការចែករំលែកពតិមាន។ ជាពិសេសប្រតិបត្តិការត្រួតពិនិត្យនៅក្នុងក្របខ័ណ្ឌ ក.អ.ក/គ.វ.ក ពាក់ពន្ធ័ទៅនឹងនាយកដ្ឋានចំនួន៣: នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្តទទួលបន្ទុក គ្រប់ឧស្សាហកម្មដោយមិនរាប់បញ្ចូលវិស័យកាត់ដេរដែលសុំរួចពន្ធក្នុងឆ្នាំទី២(លើកលែងការពង្រីកអាជីវកម្ម) ។ខណៈដែលនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ ជាមួយនាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួងទទួលបន្ទុកវិស័យកាត់ដេរលើការសុំរួចពន្ធសំរាប់ឆ្នាំទី២ លើកលែងការពង្រីកអាជីវកម្ម។ រាល់សំណើសុំការលើកទឹកចិត្ត ផ្អែកវិនិយោគទាំងអស់នៅក្នុង ក.អ.ក/គ.វ.ក លើកលែងតែតំបន់សេដ្ឋកិច្ចពិសេស បានត្រូវធ្វើ និងវាយតម្លៃនៅក្នុង នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត ដូច្នេះនាយកដ្ឋាននេះ ផ្ទុកពតិមានទាំងវិនិយោគក្នុងស្រុក និងវិនិយោគ បរទេសដោយផ្អែកលើមានការអនុញ្ញាតិ។ ជាងនេះទៀត នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត មានព័តិមាន ថ្មីសុក្រិត្យអំពីឧស្សាហកម្មផ្សេងៗទៀត លើកលែងតែឆ្នាំទី២ នៃវិស័យកាត់ដេរ ជាលទ្ធផលនៃប្រតិបត្តិការត្រួតពិនិត្យ ក្នុងខណៈពេលដែលនាយកដ្ឋានត្រួតពិនិត្យនិងតាមដាន គំរោងវិនិយោគដោយសហការជាមួយ និង នាយកដ្ឋានសំរប សំរួលកិច្ចការអន្តរក្រសួង មានពតិមានសុក្រិត្យអំពីវិស័យ កាត់ដេរក្នុងការសុំរួចពន្ធឆ្នាំទី២លើកលែងការពង្រីក អាជីវកម្ម។ ទោះជាយ៉ាងណាក៏ដោយយើងឃើញថាទំនាក់ទំនងពតិមាននៅមានកំរិតតិចតួច រវាងនាយកដ្ឋានវិភាគ គំរោង និងការលើកទឹកចិត្ត និងនាយកដ្ឋានត្រួតពិនិត្យនិងតាមដាន គំរោងដោយសហការជាមួយនាយកដ្ឋានសំរប សំរួលកិច្ចការអន្តរក្រសួង ដោយសារការបែងចែកនេះហើយ ព័តិមាន ត្រូវបានរក្សាទុកដោយផ្អែក១ទៅ តាមនាយក ដ្ឋានចំនួន៣ ដូច្នេះ វាមានការលំបាកក្នុងការយកព័តិមានទាំងអស់។ បន្ថែមលើនេះទៀត ក្រោយការត្រួតពិនិត្យនៃ ប្រតិបត្តិការ រវាងនាយកដ្ឋានទាំងបីឃើញថានាយកដ្ឋាននិតិកម្ម និងច្បាប់វិនិយោគ ដោយសហការជាមួយនាយកដ្ឋាន វិភាគគំរោង និងការលើកទឹកចិត្តទទួបន្ទុកលើការកែប្រែលក្ខន្តិកៈ ភាគហ៊ុន និងទីតាំងក្នុងករណីដែលមានការផ្លាស់ ប្តូរ ។ល។ ដូច្នេះគ្រប់ នាយកដ្ឋានទាំងអស់នៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក ត្រូវសហការគ្នា និងចែករំលែកព័តិមានគ្នា។ ¶

¶

វិនិយោគឯកជន និងនាយដ្ឋានត្រួតពិនិត្យនិងតាមដានគំរោង។ តែវាមិនបានយកមកអនុវត្ត ដោយសារមួយផ្នែកគឺកង្វះខាតចំណេះដឹងខាង IT និងមួយផ្នែកទៀតត្រូវការចំណាយខ្ពស់លើការថែទាំ។ ហេតុដូច្នេះហើយ នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញការវិនិយោគឯកជន និងនាយកដ្ឋានត្រួតពិនិត្យ និងតាមដាយគំរោងវិនិយោគ ដាក់បញ្ចូលទិន្នន័យគំរោង (ការចុះបញ្ជីក្រុមហ៊ុនថ្មីៗ) ក្នុងប្រពន្ធ័ពីរផ្សេងគ្នា។

### ១១.៣.៣ ការណែនាំឱ្យប្រើប្រព័ន្ធផ្អែកលើលទ្ធផលការងារជាមូលដ្ឋាន

ពាក់ព័ន្ធទៅនឹងប្រាក់បៀវត្សន៏នៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក ប្រព័ន្ធផ្អែកលើលទ្ធផលការងារ អាចចាប់ផ្តើមដើម្បីលើកទឹកចិត្តបុគ្គលិកនិងជួយពង្រឹងគុណភាពស្ថាប័នទាំងមូល។ យើងអាចផ្តល់ជាប្រាក់រង្វាន់ពិសេសដល់បុគ្គលិកម្នាក់ៗ។ យ៉ាងណាក៏ដោយ ការផ្តើមអោយមានប្រព័ន្ធលទ្ធផលការងារ គួរស្ថិតក្នុងលក្ខណៈប្រុងប្រយ័ត្នព្រោះ វាអាចបណ្តាលអោយមានភាពរីករវរ និងប៉ះបាល់ដល់អារម្មណ៏បុគ្គលិក។ ដូច្នេះវាជាការសំខាន់ក្នុងការកំនត់មាត្រដ្ឋានបរិមាណច្បាស់លាស់ ដូចជាការដឹកនាំកិច្ចប្រជុំពាណិជ្ជកម្ម ការចងក្រងផែនការវិនិយោគ និងកិច្ចព្រមព្រៀងវិនិយោគក្នុងប្រទេស។ ប្រការសំខាន់ក្នុងការប្រាប់ពតិមានទាំងនេះ ដល់បុគ្គលិក ទាំងអស់ដើម្បីអោយពួកគេអាចវាយតំលៃខ្លួនឯង ហើយនឹងទទួលបាននូវការគាំទ្រ។

Deleted:

## ១១.៤ ការជំរុញវិនិយោគ

### ១១.៤.១ បញ្ជីនៃការជំរុញវិនិយោគ (បញ្ជីឈ្មោះក្រុមហ៊ុន និងព័តិមានអំពីផលិតផល)

ការលំបាកមួយនៅក្នុងចំណោមការលំបាកជាច្រើនសំរាប់ស្ថាប័នមន្ត្រី ក.អ.ក/គ.វ.ក គឺថាពួកគេមិនមានចំណេះដឹងទូលំទូលាយអំពីផលិតផលផ្សេងៗគ្នាច្រើនមុខ អំពីក្រុមហ៊ុន និងឧស្សាហកម្មផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះមន្ត្រីបំរើការងារខាងការលើកស្ទួយការវិនិយោគ មានការលំបាកច្រើនក្នុងការផ្គូរផ្គងរវាងតំរូវការ របស់អ្នកផលិតក្នុងស្រុក និងតំរូវការរបស់អ្នកវិនិយោគនៅបរទេសដោយមានប្រសិទ្ធិភាព។ ដោយសារហេតុនេះ មន្ត្រីបំរើការងារខាងការលើកស្ទួយការវិនិយោគត្រូវជំរាបអ្នកមានគំរោងវិនិយោគមិនមែនគ្រាន់ភាពសំខាន់នៃបរិយាកាសវិនិយោគប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ត្រូវផ្តល់ព័តិមានលំអិតអំពីការធ្វើជំនួញដែរ។ ការប្រមូលព័តិមានជាទូទៅជាកិច្ចការត្រូវ ប្រើប្រាស់ពេលវេលាច្រើន។ តែទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់តំរូវការពីទីផ្សារក្នុងស្រុក ដើម្បីជំរុញឱកាសរកស៊ីផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ បញ្ជីរការជំរុញការវិនិយោគនឹងជួយដល់មន្ត្រីនៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក ដើម្បីជំរុញផលិតផល ឬក្រុមហ៊ុននានានៅក្នុងប្រទេសកម្ពុជាដល់អ្នកវិនិយោគទុន។ នៅក្នុងការសិក្សានេះ យើងបានរកឃើញផ្នែកដែលជាសក្តានុពលចំនួន ៥ (ផ្នែកវាយនភ័ណ្ឌ និងឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មស្បែកជើង ឧស្សាហកម្មកសិផលិតកម្ម ឧស្សាហកម្មគ្រឿងយន្ត និងឧស្សាហកម្មអេឡិចត្រូនិច) ដើម្បីទាក់ទាញការវិនិយោគបរទេសដោយផ្ទាល់ ជាពិសេសពីប្រទេសជប៉ុន។ តែទោះជាយ៉ាងណាក៏ដោយផ្នែកទាំងនេះទំនងជាផ្តល់ ឱកាសខុសៗគ្នាច្រើនសំរាប់ការធ្វើវិនិយោគ (សូមមើលតារាង១១-៤-១)។ ដូចនេះ ទាក់ទងទៅនឹងការបង្កើតបញ្ជីសំរាប់ការជំរុញការវិនិយោគ លក្ខណៈផ្សេងៗនៅក្នុងឧស្សាហកម្មនីមួយៗគួរតែត្រូវបានគេលើកយកពិចារណាអោយស៊ីជំរៅ។

**តារាង ១១-៤-១ កាលានុវត្តន៍ភាពនៃការវិនិយោគលើវិស័យជាគោលដៅទាំង៥ សំរាប់វិនិយោគជប៉ុន**

| ឧស្សាហកម្ម | ការរំពឹងទុកឱកាសវិនិយោគនៅកម្ពុជា |
|---|---|
| ផ្នែកវាយនភ័ណ្ឌនិង ឧស្សាហកម្មកាត់ដេរ | ភាគច្រើនទទួលធ្វើបន្ត(ដេរយកកំរៃ) និង មួយភាគការវិនិយោគផ្ទាល់បរទេស |
| ឧស្សាហកម្ម ស្បែកជើង | ភាគច្រើនទទួលធ្វើបន្តនិង មួយភាគការវិនិយោគផ្ទាល់បរទេស |
| ឧស្សាហកម្មកសិផលិតកម្ម | ជំនួយបច្ចេកទេស និង វិនិយោគផ្ទាល់បរទេស |
| ឧស្សាហកម្មគ្រឿងយន្ត | វិនិយោគផ្ទាល់បរទេស |
| ឧស្សាហកម្មអេឡិចត្រូនិច | វិនិយោគផ្ទាល់បរទេស |

Source: JICA Study Team

តាមការស្តែងចេញដោយការសិក្សារបស់យើង នៅក្នុងផ្នែកវាយនភ័ណ្ឌ និងកាត់ដេរ ក៏ដូចជាឧស្សាហកម្មស្បែកជើង សាជីវកម្មជប៉ុនហាក់ដូចជាចង់ធ្វើអោយមានភាពទូលំទូលាយនូវបណ្តាញចុះកិច្ចសន្យារបស់គេជាមួយក្រុមហ៊ុននានានៅក្នុងប្រទេសកម្ពុជា ជំនួសអោយការប្រើ FDI (នៅក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ក្រុមហ៊ុនជប៉ុនដូចជាចង់ដូរពីប្រាក់កំរៃជើងសារលើការផលិតទៅជាការវិនិយោគបរទេស)។ បន្ថែមលើនេះទៀត ក្រុមហ៊ុននាំមុខនានានៅក្នុងផ្នែកទាំងនេះមិនមែនជាក្រុមហ៊ុនក្នុងស្រុក ក៏ប៉ុន្តែជាក្រុមហ៊ុនបរទេសរាប់បញ្ចូលទាំងក្រុមហ៊ុនចិន តៃវ៉ាន់ និងកូរ៉េ។ ដូច្នេះ បញ្ជីនានាសំរាប់ធ្វើការជំរុញការវិនិយោគគួរតែមានព័ត៌មានអោយបានទូលំទូលាយសំរាប់គោលបំណង វិនិយោគជប៉ុនដែលចង់មកវិនិយោគក្នុងវិស័យនេះ។

មន្ត្រីនៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក នឹងត្រូវបានគេតំរូវអោយស្វែងរកឱកាសវិនិយោគពីក្រុមហ៊ុនក្នុងស្រុក និងក្រៅប្រទេសនៅក្នុងប្រទេសកម្ពុជា។ ទាក់ទងទៅនឹងពត៌មានស្តីពីបញ្ជីសំរាប់ការលើកស្ទួយការធ្វើវិនិយោគ ពត៌មានស្តីពីការរកស៊ីទូទៅរបស់ក្រុមហ៊ុន ក៏ដូចជាប្រភេទអ្វីខ្លះដែលក្រុមហ៊ុននេះត្រូវការកិច្ចសហការ ដូចជាផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ ឬទីផ្សារគួរតែត្រូវបានគេលើកឡើង។ គំរូស្តីពីតារាងបញ្ជីសំរាប់ការជំរុញការធ្វើវិនិយោគនៅក្នុងផ្នែកកាត់ដេរមាននៅក្នុងតារាង ១១-៤-២។ គំរូក្រុមហ៊ុនដែលចង់ប្រើខ្សែសង្វាក់ផលិតកម្មរបស់គេ និងនាំចេញទៅលក់នៅប្រទេសជប៉ុន។

**តារាង ១១-៤-២ បញ្ជីនៃការជំរុញវិនិយោគ (ឧទាហរណ៍ឧស្សាហកម្មកាត់ដេរ)**

| **Company Name** | **Taiwan Garment (Cambodia) Co** |
|---|---|
| ប្រទេស ឬ តំបន់ | Taiwan |
| ឆ្នាំកកើត | 2000 |
| អាស័យដ្ឋាន | NrI Road, Khan Russey Keo, Phnon Penh |
| ទូរស័ព្ទ | 023-30-5899 |

| | |
|---|---|
| ទូរសារ | 023-30-5900 |
| បុគ្គលទាក់ទង | Mr. Jack Lee |
| អ៊ីមែល | tgc@hotmail.com |
| អាជីវកម្ម | Garment |
| ផលិតផលចំបងទាំង៥ | Casual shirts, underwear, socks |
| អតិថិជនគោល | A Corp. B Corp. C Corp |
| នាំចេញទៅកាន់ជប៉ុន | Yes |
| ប្រទេសសំខាន់ដែលត្រូវនាំចេញ | EU 40%, USA 30%, Taiwan 20%, Japan 10% |
| ចំណូលប្រចាំឆ្នាំ | US$ 500,000 |
| ទុនវិនិយោគ | US$ 100,000 |
| **ពតិមានក្រុមហ៊ុនមេ** | |
| ឈ្មោះក្រុមហ៊ុន | Taiwan Garment |
| អាស័យដ្ឋាន | 123 King St, Taiwan |
| ទូរស័ព្ទ | 77-123-5867 |
| ទូរសារ | 77-123-5889 |
| អ៊ីមែល | tg@hotmail.com |
| សំណើវិនិយោគ/ពតិមានគំរោង | |
| ពតិមានលំអិត | The Expansion of production capacity of shocks to the Japanese market, the introduction of new machinery. |
| ចំណាយលើការវិនិយោគ | US$ 100,000 |
| ប្រភពទុន | Long-term loans |
| បែបផែនសារជីវកម្ម | Subcontracting |
| ពតិមានបន្ថែម | Utilization of production line |

Source: JICA Study Team

### (1) ការប្រមូលព័តិមាន

បញ្ហាបារម្មណ៍ធំជាងគេបង្អស់នៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក អាចជានាយកដ្ឋានដែលមានភារៈកិច្ចនៅក្នុងការធ្វើបញ្ជីសំរាប់ការជំរុញការធ្វើវិនិយោគ។ ក្រុមធ្វើការសិក្សាស្រាវជ្រាវរបស់អង្គការ JICA ស្នើសុំអោយមានកិច្ចប្រតិបត្តិការរួមគ្នាមួយរវាងនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ សហការជាមួយនាយកដ្ឋានសំរប

សំរួលកិច្ចការអន្តរក្រសួង ហើយនាយកដ្ឋានវិភាគគំរោងនិងការលើកទឹកចិត្ត និងនាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញគំរោងវិនិយោគឯកជន។ ម្យ៉ាងវិញទៀត កិច្ចសហការពីនាយកដ្ឋានមួយទៅនាយកដ្ឋាមមួយទៀត ហើយនិងការចែករំលែកពតិមានគ្នាគឺមានសារៈសំខាន់។

(i) *ការប្រើប្រាស់អោយមានប្រសិទ្ធភាពនៃបណ្តាញដែលកំពុងមានស្រាប់នៅក្នុង ក.អ.ក/គ.វ.ក*

មន្ត្រីនៅក្នុងនាយកដ្ឋានត្រួតពិនិត្យនិងតាមដានគំរោង សហការជាមួយ នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង ក៏ដូចជាមួយមន្ត្រី នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត ចុះធ្វើការត្រួតពិនិត្យ។ ជាពិសេសនាយកដ្ឋានត្រួតពិនិត្យនិងតាមដានគំរោងក៏នឹងដាក់ចេញនូវកំរងសំណួរស្ទាបស្ទង់មតិទៅក្រុមហ៊ុននានានៅក្នុងប្រទេសកម្ពុជា។ ដូចនេះ ពតិមានអាចត្រូវបានគេប្រមូលប្រកបដោយប្រសិទ្ធិភាពខ្ពស់តាមរយៈនាយកដ្ឋានទាំងនេះ។ តែទោះជាយ៉ាងណាក៏ដោយវាមិនគ្រប់គ្រាន់ទេក្នុងការប្រមូលពតិ មានចាំបាច់ដោយនាយកដ្ឋានទាំងនេះ ព្រោះជាធម្មតាគេធ្វើការតែជាមួយ ក្រុមហ៊ុនហើយដែលទុនវិនិយោគមកពីបរទេស។

(ii) *កិច្ចសហប្រតិបត្តិការជាមួយសមាគមន៏ពាណិជ្ជកម្ម*

មធ្យោបាយមួយទៀតសំរាប់ការប្រមូលព័តិមានអោយមានប្រសិទ្ធិភាព អាចត្រូវយបានសំរេចដោយមានកិច្ចសហការជាមួយសមាគមន៏ពាណិជ្ជកម្មនានានៅក្នុងប្រទេសកម្ពុជា (សូមមើលតារាង ១១-៤-៣)។ សមាគមន៏ពាណិជ្ជកម្មទាំងនេះ ជាទូទៅមានព័តិមានដែលមានតម្លៃអំពីក្រុមហ៊ុននានា ជាពិសេសឧស្សាហកម្ម និងតំបន់។ នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញការវិនិយោគឯកជន ហាក់ដូចជានាយកដ្ឋានដ៏សក្តិសមដើម្បីបង្កើតបណ្តាញទំនាក់ទំនងទាំងនេះជាមួយសមាគមន៏ពាណិជ្ជកម្ម។ ចំណុចខ្សោយមួយនៅក្នុងចំណុចខ្សោយជាច្រើននៃនាយកដ្ឋាននេះ ត្រូវបានលើកយកមកបង្ហាញ គឺដោយមានកង្វះខាតចំណេះដឹងអំពីក្រុមហ៊ុនកម្ពុជា និងឧស្សាហកម្មផ្សេងៗ។ ដូចនេះវាហាក់ដូចជាមានការលំបាកសំរាប់ពួកគេនៅក្នុងកិច្ចសំរួលពាណិជ្ជកម្មផ្សេងៗជាមួយឧស្សាហកម្មក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា។ បណ្តាញពតិមានជាមួយសមាគមន៏ពាណិជ្ជកម្ម នឹងជំរុញចំណេះដឹងរបស់មន្ត្រីអំពីឧស្សាហកម្មនៅក្នុងស្រុក ហើយនិងឱកាសពាណិជ្ជកម្មផ្សេងៗ នៅក្នុងនាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញការធ្វើវិនិយោគឯកជន។ ប៉ុន្តែនៅក្នុងផ្នែកកសិ-ឧស្សាហកម្ម វាហាក់ដូចជាមានការពិបាកក្នុងការយកពតិមានពីសមាគមន៏កសិកម្មនានា ដោយមានមានរចនាសម្ពន្ធ័ចាត់តាំងទន់ខ្សោយ។ ពតិមានអំពីកសិ-ឧស្សាហកម្ម រួមមាន ផលិតផលកសិកម្ម និងទីន្លែងដែលផលិតផលទាំងបានត្រូវផលិត។ គេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ពតិមានផ្សេងៗស្តីពីដីសម្បទានសេដ្ឋកិច្ច និងគំរោងកសិកម្មផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ វាមានបញ្ចូលទាំងពតិ មានស្តីពីផលិតផល ផ្សេងៗដូចជាដំឡូងមី ស្វាយចន្ទី ឈ្មោះអ្នកផលិត និងទីតាំងផលិត (សូមមើលតារាង ក-៤-១)។

ជាងនេះទៀត ការរៀបចំតាក់តែងបញ្ជីសំរាប់ជំរុញការធ្វើវិនិយោគនេះ នឹងត្រូវបានស្នើសុំដោយកម្មវិធីមួយឈ្មោះ "កម្មវិធីប្រតិភូ" ដែលចាត់ចែងដោយអង្គការអភិវឌ្ឍន៏ឧស្សាហកម្មអង្គការសហប្រជាជាតិ (UNIDO) ដែលអង្គការនេះ នឹងត្រូវបានលើកយកនិយាយនៅផ្នែកខាងក្រោយ។

**Deleted:** *ស្ថាប័ន*

**Deleted:** បេសកកម្ម ទៅមើលក្រុមហ៊ុនជាច្រើន សំរាប់ ការ

**Formatted:** Font: Not Bold, No underline

**Deleted:** ហើយនិង

**Deleted:**

**Deleted:**

**Deleted:**

**តារាង ១១-៤-៣ បញ្ជីឈ្មោះសមាគមន៍ពាណិជ្ជកម្មនៅកម្ពុជា**

| ឧស្សាហកម្ម | ឈ្មោះសមាគមន៍ | អាស័យដ្ឋានទំនាក់ទំនង |
|---|---|---|
| ឧស្សាហកម្មទូទៅ | សភាពាណិជ្ជកម្មភ្នំពេញ | Building No 7B, The Corner of Road 81&109, Sangkai Boeung Raing, Khan Daun Penh, Phnom Penh, Cambodia<br>Tel: 855-23-212-265<br>Fax: 855-23-212-270<br>www.ppcc.org.kh<br>E-mail: ppcc@online.com.ph<br>Contact: Mr. Diep Leng,<br>Deputy Director General |
| សហគ្រាសធុនតូច និងមធ្យម | សមាគមសហគ្រាសធុនតូច និងមធ្យភ្នំពេញ (PSMIA) | No. 06, Street 288, Beung Keng Kang1, 12302 Phnom Penh, Cambodia<br>Tel: 855-23-983 476/ 218 652<br>Fax: 855-23-218 652<br>Mobile:855-12-858 180/899 960/834 197<br>E-mail: smecambodia@sme.forum.org.kh<br>Web site : www.smecambodia.org<br>www.sme.biznet.com |
| ឧស្សាហកម្ម កាត់ដេរ | សមាគមរោងចក្រកាត់ដេរ នៅកម្ពុជា (GMAC) | Nr. 175 Jawahharlal Nehru Blvd, Phnom Penh Cambodia<br>Tel: 855-23-301-181<br>Fax: 855-23-369-398<br>www.gmac-cambodia.org |
| កសិ-ឧស្សាហកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ផ្នែកសេដ្ឋកិច្ច និង ដីសម្បទាន<br>http://www.maff.gov.kh/elc/index.html |

Source: JICA Study Team

### ១១.៤.២ ការចេញផ្សាយសារពត៌មានប្រចាំខែ

ក្នុងគោលបំណងដើម្បីផ្តល់ពតិមានថ្មីៗអំពីពតិមាននៃការធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជា ជូនដល់អ្នកវិនិយោគទុន និងអ្នកវិនិយោគទុនដែលជាសក្តានុពល ការចេញសារពតិប្រចាំខែត្រូវបានគេផ្តល់អនុសាសន៍អោយធ្វើ ។ មាតិកានៃ

ពតិនេះគួរដាក់បញ្ចូលនូវពតិមានចុងក្រោយបំផុត ពតិមានអំពីការធ្វើវិនិយោគនិងស្ថិតិ ការណែនាំអំពីក្រុមហ៊ុនបរទេសមួយនៅក្នុងប្រទេសកម្ពុជា ហើយនិងការណែនាំអំពីបុគ្គលិកនៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក។ ការបោះពុម្ពឯកសារនេះអាចធ្វើតាមក្រដាស ឬតាមអ៊ីមែល។ សៀវភៅព័ត៌មានដែលធ្វើតាមអ៊ីម៉ែល អាចត្រូវបាន គេផលិតចេញដោយមានតម្លៃថោក ហើយសន្សំសំចៃពេលវេលាក្នុងការបញ្ជូនទៅអោយ។ បន្ថែមលើនេះទៀត វាជាការចាំបាច់ដែលទិន្នន័យរួមមួយត្រូវបានបង្កើតឡើង ដែលនឹងផ្តល់បញ្ជីដ៏ទូលំទូលាយមួយដល់អ្នកទទួលទាំងអស់លើព័ត៌មាននានា រាប់បញ្ចូលទាំងអ្នកវិនិយោគទុនដែលជាសក្តានុពលផងដែរ សិក្ខាកាម និងបេសកកម្មនានា និងសំណួរនានាពីក្រុមហ៊ុនផ្សេងៗ។ គំរូនៃខ្លឹមសារទាំងនេះត្រូវបានបង្ហាញនៅខាងក្រោម។

**រូបភាព ១១-៤-១ គំរូលិខិតសារពតិមានសំរាប់ ក.អ.ក/គ.វ.ក**

Deleted:

សារពតិមាន**CDC/CIB** (ខ្លឹមសារគំរូ )

បោះផ្សាយ : លេខ១ កញ្ញា ២០០៦

**1.** ពតិមានចុងក្រោយបំផុត

គោលបំនង: ផ្តល់ពតិមានថ្មីៗដល់: អ្នកវិនិយោគ អ្នកមានបំនងវិនិយោគ និង ស្ថាប័នពាក់ព័ន្ធរដ្ឋាភិបាល

(e.g. ការកែប្រែច្បាប់ អនុក្រិត ការណែនាំប្រព័ន្ធថ្មី ។ល។)

**2. ពតិមានវិនិយោគ ស្ថិតិ និង សកម្មភាពរបស់ CDC/CIB**

គោលបំនង: ផ្តល់ពតិមានការវិនិយោគ ការអនុញ្ញាតវិនិយោគ ការអនុញ្ញាតទុនវិនយោគ

បន្ថែមក្នុងឆ្នាំ ២០០៦ នឹងការបង្ហាញសកម្មភាពខែមុនរបស់ **CDC/CIB**

(e.g. បេសកម្មវិនិយោគ)

**3. ក្រុមហ៊ុនប្រចាំខែ**

( សម្ភាសន៏ក្រុមហ៊ុន ភ្ជាប់ជាមួយរូបថត )

គោលបំនង: ផ្តល់នូវចំណាប់អារម្មណ៏វិជ្ជមានដល់អ្នកមានបំនងមកវិនិយោគ

**4. បុគ្គលិកប្រចាំខែរបស់ CDC/CIB**

ប្រភព : ក្រុមសិក្សា JICA

### ១១.៤.៣ ការអភិវឌ្ឍន៍វេបសៃត៍ (Web Site)

ជាមួយការអភិវឌ្ឍន៍ដ៏លឿននៃសង្គមពតិមាននៅក្នុងរយៈពេលៗប៉ុន្មានឆ្នាំនេះ វេបសៃត៍ បានក្លាយទៅជាឧបករណ៍

មួយក្នុងចំណោមឧបករណ៍ផ្តល់ពត៌មានដ៏មានប្រសិទ្ធិភាពនៅក្នុងពិភពលោក។ ជាអកុសលគេហទំព័ររបស់ ក.អ.ក/គ.វ.ក មិនត្រូវបានគេបញ្ចូលពត៌មានថ្មីៗអស់រយៈពេលជាយូរមកហើយ។ ជាងនេះទៅទៀត វាកំរមានពត៌មានគ្រប់គ្រាន់ណាស់ (តាមពិតទៅមានទំព័រជាច្រើនមិនដំណើរការ)។ អញ្ចឹងហើយ វាមានការលំបាកសំរាប់អ្នកចង់វិនិយោគចូលមើលដើម្បីយកពត៌មានសំរាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ បញ្ហាផ្សេងៗ ខាងក្រោម អាចត្រូវបានគេធ្វើការកត់សំគាល់នៅក្នុងស្ថាប័ន ក.អ.ក/គ.វ.ក បច្ចុប្បន្ននេះ (សូមមើលតារាង ១១-៤-៤)។

Deleted:

¶

**តារាង ១១-៤-៤ បញ្ហាមួយចំនួនក្នុងគេហទំព័ររបស់ស្ថាប័ន ក.អ.ក/គ.វ.ក នាពេលបច្ចុប្បន្ន**

| ផ្នែករបស់គេហទំព័រ | បញ្ហា |
|---|---|
| អំពី CDC/CIB | គ្មានការពន្យល់ច្បាស់លាស់អំពីស្ថាប័ន និង រចនាសម្ព័ន្ធរបស់ស្ថាប័ន |
| ទិដ្ឋភាពទូទៅនៃប្រទេស<br>- ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ច | ពត៌មានចុងក្រោយបំផុតគឺត្រឹមឆ្នាំ១៩៩៩ |
| មគ្គុទេសន៍ពាណិជ្ជកម្ម | ៩ក្នុងចំណោម១២ផ្នែកបានបង្ហាញក្នុងគេហទំព័រ តែមានការលំបាកក្នុងការអាន ជាងនេះទៅទៀតពត៌មានទាំងនោះចាស់ៗ |
| ប្រព័ន្ធទិន្នន័យគំរោង | មិនដំណើរការ |
| នីតិវិធីក្នុងការចាប់ផ្តើម | ផ្នែកមួយចំនួនក្នុងការលើកទឹកចិត្តវិនិយោគ ការអភិវឌ្ឍន៍តំបន់ ការអនុវត្តគំរោងទំរង់វិនិយោគ និងការណែនាំជាជំណាក់ៗ មិនដំណើរការ |
| ពត៌មានឧស្សាហកម្ម | ផ្នែកទី៣នៃពត៌មានបានបង្ហាញដូចជា កសិកម្ម រ៉ែនិងថាមពល ទូរគមនាគមន៍ ប៉ុន្តែឧស្សាហកម្មដែលមានភាពប្រកួតប្រជែងជាងគេដូចជា ឧស្សាហកម្មកាត់ដេរ និងស្បែកជើងមិនមាន |
| ការភ្ជាប់ទៅនឹងផ្នែកសំខាន់ៗ | ពត៌មាន ត្រូវបានកំរិតកំណត់ ចំពោះឈ្មោះរបស់អង្គការ ហើយលេខទូរស័ព្ទ និងទូរសារមិនបានភ្ជាប់ទៅនឹងអង្គការទាំងនោះ |
| ទស្សនា CDC/CIB | ពត៌មានមានកំណត់ ដូចជា ឈ្មោះរបស់អង្គការ ហើយលេខទូរស័ព្ទនិងទូរសារមិនបានភ្ជាប់ទៅនឹងអង្គការទាំងនោះ |
| សំភារះបង្ហាញ | គ្មានពត៌មាន |

ប្រភព: ក្រុមសិក្សា JICA

គេហទំព័ររបស់ ក.អ.ក/គ.វ.ក គួរតែត្រូវបានធ្វើឱ្យប្រសើរឡើងជាមួយពត៌មានចុងក្រោយបង្អស់ ហើយនឹងត្រូវបានបញ្ចូលជាទៀងទាត់ពេលវេលា។ ពត៌មាននេះក៏គួរតែត្រូវបានផ្តល់ជាភាសាផ្សេងៗដែររួមមានភាសាអង់គ្លេស ជប៉ុន និងភាសាចិន។ ទាក់ទិនទៅនឹងការបង្កើតគេហទំព័ររបស់ ក.អ.ក/គ.វ.ក អ្នកផ្តល់ជំនួយអន្តរជាតិនានាដូចជា មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន និង MIGA នឹងអនុវត្តន៍គំរោងនេះ។ ជាពិសេសកម្មវិធីគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌល ASEAN-ជប៉ុន បានចាប់ផ្តើមរួចហើយ ដោយមានការបញ្ជូនក្រុមបេសកកម្មផ្នែក IT មួយក្រុមមក ក.អ.ក/គ.វ.ក នៅខែកញ្ញា ឆ្នាំ២00៦។ គោលបំណងនៃបេសកកម្មគឺដើម្បីបង្កើតគេហទំព័រជាភាសាជប៉ុន បង្កើតមូលដ្ឋានទិន្នន័យ

ក្រុមហ៊ុន និងបង្កើតសមត្ថភាពផ្នែក IT សំរាប់ការផ្សាយពត៌មានប្រចាំខែដូចបានពោលខាងលើ។ គេមានបំណងចាប់ផ្តើមប្រតិបត្តិការនៅពាក់កណ្តាលដើមឆ្នាំ ២០០៧។ តែបញ្ហាសំខាន់ សំរាប់ការបង្កើតគេហទំព័រ គឺទាក់ទងទៅនឹងនិរន្តរភាព។ មានជំរើសពីរយ៉ាងសំរាប់ការ សំរេចបាននិរន្តរភាពនៅក្នុងពេលអនាគត។ ជំរើសទី ១ គឺត្រូវរើសបុគ្គលិកផ្នែក IT ហើយផ្តល់ការបណ្តុះបណ្តាលអោយបានល្អគ្រប់គ្រាន់សំរាប់ការថែទាំនៅពេលអនាគត។ ជំរើសទី២ គឺត្រូវដាក់ការថែទាំនេះអោយទៅក្រុមហ៊ុនឯកជនធ្វើ។ ជំរើសទាំងពីរនេះ សុទ្ធតែត្រូវការថវិកាសំរាប់ការថែទាំនៅក្នុងពេលអនាគត។

## ១១.៥ ការបង្កើតបណ្តាញពត៌មានជាមួយប្រទេសជប៉ុន និងការជំរុញការធ្វើវិនិយោគទុន

Deleted:

### ១១.៥.១ ការបង្កើតក្រុមការសំរាប់ប្រទេសជប៉ុន ដែលហៅថា Japan Group

ក្នុងគោលបំណងដើម្បីទាក់ទាញការធ្វើវិនិយោគជប៉ុនអោយចូលមកកម្ពុជាការ បង្កើតក្រុមការងារសំរាប់ប្រទេសជប៉ុន ‘ក្រុមជប៉ុន’ នៅក្នុងនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការធ្វើវិនិយោគទុន ដែលធ្វើការតែជាមួយទីផ្សារជប៉ុនមួយមុខគត់ នឹងត្រូវបានគេផ្តល់អនុសាសន៏អោយបង្កើតឡើង។ ជាទូទៅក្រុមហ៊ុនជប៉ុន មិនមានបទពិសោធន៏ (សូម្បីតែពត៌មាន) នៅក្នុងទីផ្សារប្រទេសកម្ពុជា។ ដូច្នេះ ក្រុមការងារសំរាប់ប្រទេសជប៉ុននឹងដើរតួនាទីនៅក្នុងការផ្តល់ការទុកចិត្តដល់អ្នកវិនិយោគទុនជប៉ុន (ការទុកចិត្តគឺជាតម្លៃនៃការធ្វើជំនួញនៅក្នុងប្រទេសជប៉ុន)។ ក្រុមការងារសំរាប់ប្រទេសជប៉ុន នឹងត្រូវបានបង្កើតឡើង ដោយមានការសហការលើការត្រួតពិនិត្យ របស់អ្នកជំនាញការសំរាប់ការជំរុញការវិនិយោគនៅក្នុងពេលអនាគត។ ជាពិសេស ការវិនិយោគរបស់ជប៉ុន ចូលមកកម្ពុជាត្រូវបានគេរំពឹងមិនមែនត្រឹមតែជាមួយក្រុមហ៊ុនចំរុះជាតិនោះទេ តែធ្វើឡើងដោយក្រុមហ៊ុនដែល មានទំហំខ្នាតតូចនិងមធ្យម (ឧទាហរណ៏វិស័យកាត់ដេរ) កង្វះខាតខាងជំនាញភាសាបរទេស ដូចនេះ បុគ្គលិកខ្មែរដែលចេះនិយាយភាសាជប៉ុន នឹងត្រូវបានគេតំរូវអោយធ្វើការជាមួយនៅក្នុងក្រុមនេះ។ ទាក់ទងទៅនឹងការរើសបុគ្គលិក និស្សិតអាហារូបករណ៏ ដែលបានសិក្សានៅតាមសាកលវិទ្យាល័យជប៉ុន នឹងក្លាយជាបេក្ខជន ដ៏សក្តិសមបំផុត ឬបុគ្គលិកដែលមានបទពិសោធន៏ធ្វើការងារជាមួយជនជាតិជប៉ុន នឹងត្រូវបានគេផ្តល់អនុសាសន៏ អោយរើសចូលធ្វើការនៅក្នុងក្រុមនេះ។ តួនាទីរបស់បុគ្គលិកនៅក្រុមការងារសំរាប់ប្រទេសជប៉ុន មានដូចជា (i) ការស្ថាបនាបណ្តាញជាមួយអង្គការ និងក្រុមហ៊ុនជប៉ុន (ii) ការផ្តល់ពត៌មានអោយជនជាតិជប៉ុន (iii) ចាត់ចែង និងរៀបចំកិច្ចប្រជុំអំពីការធ្វើជំនួញជាមួយក្រុមហ៊ុនជប៉ុន (iv) ជួយដល់ភ្ញៀវជនជាតិជប៉ុន (អាចជាវិនិយោគិនអនាគត) ចូលមកកម្ពុជា (v) ផ្តល់ការពិគ្រោះតាមលំដាប់លំដោយក្នុងការឆ្លើយតបទៅនឹងសំណើរ នានាពីក្រុមហ៊ុនជប៉ុនដែលនឹងអាចមកវិនិយោគនៅក្នុងប្រទេសកម្ពុជា (vi) បេសកកម្មជំនួញទៅទីផ្សារជប៉ុន (vii) តាក់តែងឯកសារសំរាប់ការលើកស្ទួយការវិនិយោគជាភាសជប៉ុន។ បុគ្គលិកក្រុមការងារសំរាប់ប្រទេសជប៉ុន ត្រូវគេរំពឹងអោយបំពេញតួនាទីជាអ្នកអាជ្ញាកណ្តាលសំរាប់ប្រទេសជប៉ុន និងកម្ពុជានៅក្នុងការធ្វើធុរកិច្ច។

### ១១.៥.២ ការបង្កើតបណ្តាញពត៌មាននានាជាមួយអង្គការជប៉ុន

ទាក់ទងទៅនឹងការប្រមូលព័ត៌មាន អ្នកមានបំណងវិនិយោគជាជនជាតិជប៉ុន ធ្វើការទាក់ទងតាមវិធីបីយ៉ាងដូចខាង

ក្រោមដើម្បីប្រមូលព័ត៌មាន (i) អង្គការរបស់រដ្ឋាភិបាលដូចជា (JICA and JETRO) (ii) ក្រុមហ៊ុនពាណិជ្ជកម្មទូទៅ និង (iii) ក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់ (iv) អង្គការអន្តរជាតិប្រចាំ ប្រទេសជប៉ុនដូចជាមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន និង (UNIDO) (v) ផ្សេងៗបួករួមទាំងសភាពាណិជ្ជកម្ម ។ ដូច្នេះវាហាក់ដូចជាមានសារៈសំខាន់សំរាប់ ក.អ.ក/គ.វ.ក ក្នុងការបង្កើតបណ្តាញទំនាក់ទំនងពត៌មានជាមួយបណ្តាអង្គការទាំងនេះ។ ឧទាហរណ៍អង្គការជំរុញវិនិយោគរបស់រដ្ឋាភិបាលជប៉ុនគឺ (JETRO) ជាមួយ និងវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច (IDE) ។ អង្គការ JETRO/IDE មានបណ្តាល័យចំនួន ៣ ក្នុងប្រទេសជប៉ុន។ វាជាកន្លែងធម្មតាសំរាប់អ្នកចង់វិនិយោគ ដើម្បីមកកន្លែងអង្គការ (JETRO) ដើម្បីយកពត៌មាន។ បន្ថែមលើនេះទៀត ការិយាល័យអង្គការ (JETRO) នៅទីក្រុងបាងកក នាពេលបច្ចុប្បន្ននេះក៏មានបណ្តាល័យផ្ទាល់ខ្លួន ហើយធ្វើការមកលើប្រទេសកម្ពុជា ហើយដែលចង់បង្កើតអោយមានបណ្តាញទំនាក់ទំនងជាមួយ ក.អ.ក/គ.វ.ក។ យ៉ាងណាមិញ ពួកគេយល់ឃើញថា បច្ចុប្បននេះមិនទាន់មាននរណាម្នាក់ដើរតួជាអ្នកគ្រប់គ្រងពត៌មានជាមួយ ក.អ.ក/គ.វ.ក នៅឡើយទេ។ អាស័ដ្ឋានទំនាក់ទំនងរបស់ (JETRO) ដែលមានទីតាំងនៅទីក្រុងបាងកក ដូចខាង ក្រោមនេះ។

| | |
|---|---|
| **JETRO**<br>**Bangkok Office** | 16th FL.Nantawan BLDG, 161 Rajdamri Road, Bangkok 10330 Thailand<br>Attn: Mr. Makoto Oyabu, Research Dept<br>Tel : 0-2253-6441<br>Fax: 0-2253-2020<br>email: bgk-pr@jetro.go.jp |

ក្រុមហ៊ុនពាណិជ្ជកម្មជាទូទៅតែងតែដើរតួជាប្រភពពត៌មានទី២ ហើយក្រុមហ៊ុនពាណិជ្ជកម្មធំៗភាគច្រើនមានការិយាល័យតំណាងនៅក្នុងទីក្រុងភ្នំពេញ។ ដូច្នេះស្ថាប័នCDC/CIB ត្រូវបង្កើតបណ្តាញទំនាក់ទំនងអំពីការធ្វើជំនួញអោយបានទូលំទូលាយជាមួយពួកគេ។ ប្រភេទទី៣គឺក្រុមហ៊ុនផ្តល់សេវាខាងការពិគ្រោះយោបល់ ក៏ដូចជាក្រុមហ៊ុនសារនកម្មធំៗដែលប្រតិបត្តិការងារខាងការពិគ្រោះយោបល់អំពីការធ្វើវិនិយោគសំរាប់ក្រុមហ៊ុនជប៉ុន។

អង្គការអន្តរជាតិជាច្រើនបូករួមទាំង មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន និង (UNIDO) បានជួយ ក.អ.ក/គ.វ.ក ក្នុងការរៀបចំចាត់ចែងសិក្ខាសិលាស្តីពីការធ្វើវិនិយោគក៏ដូចជាបេសកម្មផ្សេងៗ។ជាងនេះទៅទៀត សភាពាណិជ្ជកម្មជប៉ុននៅទីក្រុងបាងកកមានការចាប់អារម្មណ៏យ៉ាងខ្លាំងលើការអភិវឌ្ឍន៍បណ្តាញពត៌មានជាមួយ ក.អ.ក/គ.វ.ក។

អាស័ដ្ឋានទំនាក់ទំនងរបស់សភាពាណិជ្ជកម្មជប៉ុនប្រចាំទីក្រុងបាងកកដូចបង្ហាញខាងក្រោមនេះ

| | |
|---|---|
| Japanese Chamber of Commerce, Bangkok | 15F Amarin Tower, 500 Ploenchit Road, Kwang Lumpini, Khet Patumwan, Bangkok, 10330 Thailand.<br>Attn. : Mr. Yoshito Kato<br>Assistant to Secretary General,<br>Email : kato@jcc.or.th<br>Tel : +66-02-256-9170/Fax : +66-02-652-0931<br>http: //www.jcc.or.th/ |

មួយផ្នែកពីការដែលបានរៀបរាប់អង្គការខាងលើ វាអាចនឹងផ្តល់សារៈសំខាន់ដល់ ក.អ.ក/គ.វ.ក ក្នុងការបង្កើត

បណ្តាញជាមួយ (i) ក្រុមហ៊ុនដែលបានចូលរួមសិក្ខាសាលាស្តីពីបេសកកម្ម និងការធ្វើវិនិយោគ (ii) ក្រុមហ៊ុនដែលធ្វើទស្សនៈកិច្ចនៅ ក.អ.ក/គ.វ.ក (iii) ក្រុមហ៊ុនដែលបានធ្វើការទាក់ទងតាមវេបសៃត៍។ ដូចអនុសាសន៍ (JETRO) ប្រចាំទីក្រុងបាងកក ការដែលមានប្រធានគ្រប់គ្រងពតិមានក្នុង ក.អ.ក/គ.វ.ក គឺផ្តល់សារៈសំខាន់ក្នុងការផ្តល់ពតិមានវិនិយោគប្រកបដោយប្រសិទ្ធភាពខ្ពស់។ តំណែងនេះគួរតែស្ថិតនៅជាមួយនាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញការវិនិយោគឯកជន ហើយតំរូវអោយធ្វើការចែករំលែកពតិមានរវាងនាយកដ្ឋានមួយទៅ នាយកដ្ឋាននីមួយៗ ក្នុងការប្រមូលពតិមាន និងទិន្នន័យវិនិយោគ។

### ១១.៥.៣ សំភារៈក្នុងការជំរុញការធ្វើវិនិយោគជាភាសាជប៉ុន

ក្នុងគោលបំណងដើម្បីជំរុញទីផ្សារជប៉ុន សំភារៈសំរាប់ការជំរុញការវិនិយោគសមរម្យជាភាសាជប៉ុន នឹងត្រូវតែមានរៀបចំឡើងនៅក្នុងពេលអនាគត (លើកលែងតែសំរាប់សៀវភៅមគ្គុទេសន៍សំរាប់ការធ្វើវិនិយោគ ដែលរៀបឡើងដោយក្រុមសិក្សា JICA។ ឯកសារទាំងនេះមាន (i) កូនសៀវភៅស្តីពីការជំរុញវិនិយោគ មានលក្ខណៈឯកទេស (ii) ខិត្តប័ណ្ណ (iii) គេហទំព័រជាភាសាជប៉ុន ហើយនិង (iv) CD-R មានដូចជា ការធ្វើទំនាក់ទំនងសាធារណៈ ខ្សែភាពយន្តនិយាយអំពីទីតាំងឧស្សាហកម្មនានា រឿងជ័យជំនះផ្សេងៗ ហើយនិងការ ធ្វើបទសំភាសន៍ជាមួយក្រុមហ៊ុនបរទេសនៅក្នុងប្រទេសកម្ពុជា។ ចំពោះសំភារះទាំងនេះគួរតែបង្កើតឡើង ដោយឋិត ក្រោមការណែនាំរបស់ជំនាញការវិនិយោគជប៉ុន ដែលនឹងត្រូវបញ្ជូនមកក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

### ១១.៥.៤ បេសកកម្មអំពីការជំរុញវិនិយោគ និងសិក្ខាសាលាផ្សេងៗ

សកម្មភាពសំរាប់ការជំរុញការធ្វើវិនិយោគមុនដំបូងបង្អស់នៅក្នុងទីផ្សារជប៉ុននឹងជាបេសកកម្មសំរាប់ការជំរុញវិនិយោគ និងសិក្ខាសាលារយៈពេលខ្លីៗ។ គោលបំណងនៃសិក្ខាសាលានិងបេសកកម្មទាំងនេះគឺមិនមែនគ្រាន់តែ ដើម្បីពន្យល់អំពីពតិមានផ្នែកច្បាប់ស្តីពីការធ្វើវិនិយោគប៉ុណ្ណោះទេក៏ប៉ុន្តែក៏ជាសកម្មភាពជំនួញដែរ។ និយាយមួយបែបទៀត មន្ត្រីដែលត្រូវបានបញ្ជូនទៅប្រទេសជប៉ុនត្រូវតែលក់ការធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជាទៅឱ្យក្រុមហ៊ុនជប៉ុន។ មន្ត្រី ក.អ.ក/គ.វ.ក ជាទូទៅមានចំណេះដឹងខាងច្បាប់។ តែចំណាប់អារម្មណ៍របស់អ្នកផ្តល់ជំនួយ មិនមែនគ្រាន់តែខាងច្បាប់នោះទេ ក៏ប៉ុន្តែក៏គេត្រូវការខាងពតិមានអំពីការរកស៊ីផងដែរ តើក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាផលិតផលិតផលបែបណាខ្លះ តើផលិតផលកសិកម្មមានអ្វីខ្លះនៅលើទីផ្សារ ឬតើក្រុមហ៊ុនណាមួយ នៅក្នុងប្រទេសកម្ពុជាចង់នាំចេញទំនិញរបស់គេទៅប្រទេសជប៉ុន។ មន្ត្រីនៅក្នុង ក.អ.ក/គ.វ.ក ត្រូវតែនាំយក ពតិមានពីការផ្តល់ជំនួយទាំងនេះសំរាប់បេសកកម្មការជំរុញការធ្វើវិនិយោគទៅប្រទេសជប៉ុន។ បញ្ជីផលិតកម្មអំពីការវិនិយោគដូចបានពោលខាងលើនឹងជួយដល់មន្ត្រី ក.អ.ក/គ.វ.ក ក្នុងការជំរុញការវិនិយោគរបស់ប្រទេសជប៉ុន ចូលមកក្នុងប្រទេសកម្ពុជា។ មានមធ្យោបាយ ៣ នៃការអនុវត្តន៍ បេសកម្មនិងសិក្ខាសាលាដើម្បីជំរុញការធ្វើវិនិយោគដូចខាងក្រោម។

**(1) មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន**

មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន បានរៀបចំសិក្ខាសាលាស្តីពីការវិនិយោគ បេសកកម្មផ្សេងៗ និងវគ្គបណ្តុះបណ្តាលផ្សេងៗអំពីប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០១។ មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន គឺជាមជ្ឈមណ្ឌលពតិមានដ៏ធំជាង

គេបង្ហស់ស្តីពីបញ្ហានានារបស់បណ្តាប្រទេសអាស៊ាន។ ដូចនេះ ក.អ.ក/គ.វ.ក ត្រូវតែប្រើប្រាស់បណ្តាញទាំងនេះ នៃមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ហើយជំរុញវិនិយោគនៅកម្ពុជា។

(i) *សិក្ខាសាលាអំពីការធ្វើវិនិយោគនៅក្នុងប្រទេសជប៉ុន*

គោលបំណងនៃសិក្ខាសាលាស្តីពីការវិនិយោគ គឺដើម្បីជំរុញការវិនិយោគរបស់ជប៉ុនអោយចូលមក កម្ពុជានៅក្នុងប្រទេសកម្ពុជា។ សិក្ខាសាលាភាគច្រើនត្រូវបានធ្វើឡើងនៅក្នុងទីក្រុងតូក្យូ និងនៅអូសាកា។ ខ្លឹមសារនៃប្រធានបទផ្សេងៗគឺមានលក្ខណៈទូលំទូលាយច្រើន។ ដូចនេះប្រធានបទ គួរតែត្រូវបានជាក់លាក់ដូចជាអំពីឧស្សាហកម្មណាមួយជាក់លាក់។ សិក្ខាសាលាផ្សេងៗទៀតនៅក្នុងទីក្រុងដទៃទៀត ក៏គួរតែត្រូវបានពិចារណាសំរាប់ការសំរួលដល់អ្នកចង់មកធ្វើវិនិយោគ ដែលមិនមានពត៌មានគ្រប់គ្រាន់អំពីបរិយាកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះទៀត គួរត្រូវមានការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងពត៌មាន ICT ដែលអនុញ្ញាតអោយក្រុមហ៊ុននានា នៅក្នុងទីក្រុងក្នុងតំបន់នានាចូលរួមនៅក្នុងសិក្ខាសាលាតាមរយៈសន្និសិទតាមការបញ្ចាំង វីដេអូ។

(ii) *បេសកកម្មមកកាន់ប្រទេសកម្ពុជា*

បន្ថែមលើសិក្ខាសាលានានានៅក្នុងប្រទេសជប៉ុន មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន រៀបចំបេសកកម្មនានាមកកាន់ប្រទេសកម្ពុជា។ វានឹងជាការសំខាន់ដែល ក.អ.ក/គ.វ.ក ផ្តល់នូវពត៌មានទូលំទូលាយស្តីពីបរិយាកាសវិនិយោគ និងកាលានុវត្តន៍ផ្សេងៗដល់អ្នកចង់វិនិយោគសំរាប់បេសកកម្មទាំងនេះ។ ការអញ្ជើញភ្ញៀវវាគ្មិនមកពីសមាគមន៍កាត់ដេរនៅក្នុងប្រទេសកម្ពុជា (GMAC) ឬមកពីសភាពាណិជ្ជកម្មនឹងជាពត៌មានដ៏មានប្រយោជន៍ ។ កិច្ចប្រជុំផ្សេងៗគួរតែត្រូវបានរៀបចំតាមរយៈទស្សនៈកិច្ចរោងចក្រ ឬក្រុមហ៊ុននៅ តាមផ្នែកនីមួយៗ។

**(2) អង្គការអភិវឌ្ឍន៍ឧស្សាហកម្មអង្គការសហប្រជាជាតិ (UNIDO)**

ការិយាល័យសំរាប់ការជំរុញការធ្វើវិនិយោគនិងបច្ចេកវិទ្យានៅក្នុងទីក្រុងតូក្យូរបស់អង្គការ UNIDO ផ្តល់ផែនការសំរាប់ជំរុញវិនិយោគមួយមានឈ្មោះថា "កម្មវិធីប្រតិភូ" ឱ្យដល់មន្ត្រីនានាដែលមកពីប្រទេសមិនសូវជឿនលឿន។ មន្ត្រី ដែលត្រូវបានគេបញ្ជូនអោយទៅធ្វើការត្រូវតែគេតំរូវឱ្យបំពេញទំរង់មួយឈ្មោះថា "គំរូទំរង់គំរោងវិនិយោគឧស្សាហកម្ម (IIPP)" អោយអង្គការនេះជាមុន។ គោលបំណងនៃទំរង់បែបបទនេះ គឺដើម្បីចង្អុលបង្ហាញសេចក្តីត្រូវការនៃក្រុមហ៊ុនកម្ពុជា ដើម្បីផ្គូរផ្គងវាជាមួយក្រុមហ៊ុនជប៉ុន។ ដូចបានរៀបរាប់ខាងលើ ការលើកគំរោងរបស់ក្រុមសិក្សារបស់អង្គការ JICA បញ្ជីសំរាប់ការ លើកស្ទួយការធ្វើវិនិយោគ (ក្រុមហ៊ុន និង បញ្ជីព័តិមានអំពីផលិតផល) អាចត្រូវបានគេយកមកប្រើជំនួសអោយទំរង់ IIPP។ នៅក្នុងកម្មវិធីប្រតិភូមន្ត្រី ក.អ.ក/គ.វ.ក រៀនអំពីរបៀបធ្វើបទបង្ហាញអំពីគំរោងធ្វើជំនួញរបស់គេ នៅក្នុងការិយាល័យនាទីក្រុងតូក្យូរបស់អង្គការ UNIDO បន្ទាប់មកមន្ត្រីទាំងនេះទៅទស្សនៈកិច្ចតាមក្រុមហ៊ុននីមួយៗជាមួយនឹងបញ្ជីសំរាប់ការជំរុញ ការធ្វើវិនិយោគដោយសហការជាមួយអង្គការ UNIDO (កិច្ចប្រជុំការងារទាំងនេះ ត្រូវបានរៀបចំឡើងដោយអង្គការ UNIDO)។ ក្រោមកម្មវិធីនេះ

អង្គការ UNIDO កន្លែងស្នាក់នៅ និងប្រាក់ចេញបេសកម្ម តែថ្លៃសំបុត្រយន្តហោះ គួរតែត្រូវបានចេញដោយស្ថាប័នដែលបញ្ជូនមន្ត្រីទៅ មានន័យថា ក.អ.ក/គ.វ.ក។ រយៈពេលនៃកម្មវិធីនេះ គឺប្រហែល ៣ សប្តាហ៍។

**(3) ការពង្រឹងបេសកកម្មវិនិយោគ ក្នុងកិច្ចសហប្រតិបត្តិការជាមួយសមាគមពាណិជ្ជកម្មផ្សេងៗទៅកាន់ប្រទេសជប៉ុន**

កាលពីពេលថ្មីៗនេះ ក.អ.ក/គ.វ.ក ធ្វើបេសកកម្មសំរាប់ជំរុញការវិនិយោគ ដោយសហការជាមួយសភាពាណិជ្ជកម្មទៅបណ្តាប្រទេសជិតខាង។ កិច្ចសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្មនេះ គួរតែត្រូវបានពង្រឹង ការរាប់បញ្ចូលកិច្ចសហប្រតិបត្តិការជាមួយសមាគមន៍រោងចក្រកាត់ដេរកម្ពុជា GMAC ហើយនិងទីផ្សារជប៉ុន។ ជាទូទៅវិនិយោគិនសក្តានុពល ចង់បានពត៌មានធុរកិច្ចនៅកម្ពុជា និងសមាគមពាណិជ្ជកម្ម មានពត៌មានអំពីការធ្វើពាណិជ្ជកម្មរបស់ពួកគេ។ ដូចនេះបេសកកម្មសំរាប់ការលើកស្ទួយការធ្វើវិនិយោគ អាចត្រូវបានរៀបចំដោយមានប្រសិទ្ធិភាពដោយការសហការរវាងរដ្ឋ-ឯកជនកម្ពុជា។

**១១.៥.៥ ការបង្កើតការិយាល័យតំណាងរបស់ ក.អ.ក/គ.វ.ក នៅក្នុងប្រទេសជប៉ុន - ការិយាល័យតំណាងជប៉ុន**

ក្នុងគោលបំណងដើម្បីលើកជំរុញវិនិយោគជប៉ុនអោយចូលមកកម្ពុជា ការបង្កើតការិយាល័យតំណាងដែលមានឈ្មោះថា *'Japan Desk'* នៅក្នុងប្រទេសជប៉ុនត្រូវគេរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងពេលអនាគត។ គោលបំណងផ្សេងៗនៃការបង្កើតការិយាល័យតំណាងរបស់ជប៉ុន គឺត្រូវធ្វើការលក់ដូរគំរោងវិនិយោគនានាឱ្យទៅក្រុមហ៊ុនជប៉ុនដើម្បីផ្តល់សេវាពិគ្រោះយោបល់អោយទៅក្រុមហ៊ុនជប៉ុន ដើម្បីរៀបចំសិក្ខាសាលាផ្សេងៗដើម្បី ប្រមូលពត៌មានទីផ្សារនិងដើម្បីផ្តល់សេវាពាក្យស្នើសុំវិនិយោគនានា។ មានជំរើសជាច្រើនដើម្បីបង្កើតការិយាល័យតំណាង ជាពិសេសបញ្ហានានាដូចជាការងារ និងការិយាល័យធ្វើការគួរតែត្រូវបានពិនិត្យមើល។

**(1) បញ្ហាការរើសបុគ្គលិកអោយចូលបំរើការងារ**

មានវិធីសាស្រ្តបួនយ៉ាងក្នុងការរើសបុគ្គលិកអោយចូលបំរើការងារ ហើយដែលត្រូវបានគេយកមកពិចារណាសំរាប់ការបង្កើតការិយាល័យនៅក្នុងប្រទេសជប៉ុន :

- ការប្រើប្រាស់ធនធានដែលកំពុងមានស្រាប់;
- ការរើសបុគ្គលិកថ្មីអោយចូលបំរើការងារ;
- ការធ្វើរបៀបជួលបុគ្គលិកបន្ត ឬ
- ការបង្កើតទីភ្នាក់ងាររបស់ ក.អ.ក/គ.វ.ក ផ្សេងៗ (ដោយផ្តល់ប្រាក់កំរៃជើងសារ) ។

*(i) ការប្រើប្រាស់ធនធានដែលមានស្រាប់*

មានវិធីពីរយ៉ាងសំរាប់ការប្រើធនធានដែលមានស្រាប់បច្ចុប្បន្ន (a) ការប្រើប្រាស់តំណាងពាណិជ្ជកម្មនៅក្នុងស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន និង (b) ការបញ្ជូនបុគ្គលិកម្នាក់មកពី ក.អ.ក/គ.វ.ក។ ជំរើសខាងដើមទីមួយមានប្រៀបច្រើនលើការចំណាយ ព្រោះជំរើសនេះមិនតំរូវអោយមានការចំណាយបន្ថែមទេ។ ចំណែកឯភាពអវិជ្ជមានវិញ វាតំរូវអោយមានការរៀបចំជាច្រើនជាមួយស្ថាប័ននានា ដូចជាក្រសួងការបរទេស ឬក្រសួងពាណិជ្ជកម្ម។ បន្ថែមលើនេះទៀត មន្ត្រីតំណាងពាណិជ្ជកម្មមានការងាររបស់គេរួចទៅហើយ។ ដូចនេះ

វាមិនច្បាស់លាស់អំពីប្រសិទ្ធិភាព ដែលជំរើសនេះអាចផ្តល់អោយ។ ជំរើសចុងក្រោយមានភាពវិជ្ជមាន នៅក្នុងការគ្រប់គ្រងបុគ្គលិក ព្រោះគេជាបុគ្គលិករបស់ ក.អ.ក/គ.វ.ក។ តែវាអាចមានបញ្ហា ប្រសិនបើ មន្ត្រីដែលមិនចេះនិយាយភាសាជប៉ុនត្រូវបានគេបញ្ជូនអោយទៅធ្វើការងារ។ ដូចនេះ ជំនាញភាសាជប៉ុនមានអត្ថប្រយោជន៍ណាស់សំរាប់មុខងារនេះ។ ក.អ.ក/គ.វ.ក នឹងអាចបណ្តុះបណ្តាលបុគ្គលិកនៅក្នុង ក្រុមការងារសំរាប់ប្រទេសជប៉ុន ដែលមានគំរោងធ្វើឡើងនេះ ឬបើមិនធ្វើការប្រើប្រាស់ធនធានដែលមានស្រាប់ ក៏ប៉ុន្តែធ្វើការជ្រើសរើសជនជាតិខ្មែរ ដែលកំពុងរស់នៅក្នុងប្រទេសជប៉ុន តែវានៅមិនទាន់ច្បាស់នៅឡើយ ទេអំពីកិរិតនៃការធ្វើការងារពីមន្ត្រីនោះ ប្រសិនបើប្រពន្ធ័ប្រាក់ខែត្រូវបានផ្អែកលើស្តង់ដារបស់រដ្ឋាភិបាលកម្ពុជានោះ។

(ii) *ការជ្រើសរើសអោយចូលបំរើការងារនៃអ្នកឯកទេសខាងការលក់ដូរជនជាតិជប៉ុន*

វិធីសាស្រ្តមួយដ៏មានប្រសិទ្ធិភាពក្នុងចំណោមវិធីសាស្រ្តជាច្រើន គឺត្រូវជួលអ្នកឯកទេសលក់ម្នាក់ជនជាតិជប៉ុន ដោយប្រើប្រព័ន្ធអោយប្រាក់បៀវត្សន៍ផ្អែកលើការបំពេញការងារ។ ភាពវិជ្ជមានជាច្រើននៃជំរើសនេះ គឺប្រសិទ្ធិភាពការងារ ដោយផ្អែកលើប្រពន្ធ័លើកទឹកចិត្ត និងជំនាញភាសា និងអាចផ្តល់ការទុកចិត្ត។ ក្រុមហ៊ុនសហគ្រាសខ្នាតតូច និងមធ្យមជប៉ុន SME ជាទូទៅចូលចិត្តធ្វើការជាមួយមន្ត្រីដែលជាជនជាតិជប៉ុន។ ដូចនេះ ជំរើសនេះផ្តល់ភាពមានប្រសិទ្ធិភាពជាងជំរើសទី១ (i) ។ តែភាពអវិជ្ជមាននៃជំរើសនេះគឺការពិចារណាលើការចំណាយ (ការជួលបុគ្គលិកដែលជាជនជាតិជប៉ុន តំរូវអោយមានការរៀបចំផែនការច្រើនទាក់ទងទៅនឹងការចំណាយ។)

(iii) *ការជួលបន្ត*

វិធីសាស្រ្តដ៏មានប្រសិទ្ធិភាពមួយទៀត គឺប្រើវិធីសាស្រ្តជួលបន្ត។ ទាក់ទងទៅនឹងកិច្ចព្រមព្រៀងសំរាប់ការជួលបន្ត ក.អ.ក/គ.វ.ក ស្នើសុំការដេញថ្លៃ ហើយបញ្ជូនអោយទៅក្រុមហ៊ុនឯកជនជប៉ុន ដែលមានបទពិសោធន៍ដើម្បីធ្វើការផ្តល់សេវាពិគ្រោះយោបល់ក្រុមហ៊ុនជប៉ុន។ ក្នុងគោលបំណងដើម្បីធានាអោយបាននូវការបំពេញការងាររបស់ក្រុមហ៊ុនមួយដែលត្រូវបានជ្រើសរើស សន្ទស្សន៍សំរាប់បង្ហាញការងារត្រូវតែបង្កើតឡើង។សន្ទស្សន៍ទាំងនេះមានដូចជា: ចំនួនកិច្ចប្រជុំដែលត្រូវបានធ្វើឡើង ចំនួនសិក្ខាសាលាអំពីការជំរុញការធ្វើវិនិយោគទុនត្រូវបានរៀបចំធ្វើ ចំនួនធ្វើដំណើរជាលក្ខណៈពាណិជ្ជកម្មរបស់ជនជាតិជប៉ុនមកកម្ពុជា ចំនួននៃការរៀបចំផែនការវិនិយោគផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ តែគេកត់សំគាល់ឃើញថាភាពអវិជ្ជមានគឺការចំណាយខ្ពស់។

(iv) *ទីភ្នាក់ងារលក់ផ្សេងៗរបស់ ក.អ.ក/គ.វ.ក នៅក្នុងប្រទេសជប៉ុន*

វិធីសាស្រ្តមួយទៀតគឺត្រូវស្វែងរកដៃគូជប៉ុន (ទីភ្នាក់ងារផ្សេងៗដើម្បីជំរុញការធ្វើវិនិយោគមកកម្ពុជា) ហើយត្រូវបានផ្តល់ជាប្រាក់កំរៃជើងសារ (ភាគរយណាមួយនៃចំនួនទឹកប្រាក់វិនិយោគ)។ នៅពេលវិនិយោគិនធ្វើការវិនិយោគចូលមកក្នុងប្រទេសកម្ពុជា ក.អ.ក/គ.វ.ក (ឬរដ្ឋាភិបាលកម្ពុជា) ផ្តល់ឱ្យនូវប្រាក់កំរៃជើងសារដល់ទីភ្នាក់ងារទាំងនេះ។ នៅក្នុងជំរើសនេះ ការចំណាយដំបូងៗនឹងមានចំនួនទាបជាងជំរើសផ្សេងៗទៀត។

តែវានៅតែត្រូវការមន្ត្រីម្នាក់ដើម្បីស្វែងរកដៃគូ ហើយធ្វើការលើគំរោងនេះដដែល ប៉ុន្តែមិនចាំបាច់មានមន្ត្រីម្នាក់ស្នាក់នៅធ្វើការនៅក្នុងប្រទេសជប៉ុនទេ។ ដៃគូនោះអាចជាក្រុមហ៊ុនពាណិជ្ជកម្មទូទៅឬក្រុមហ៊ុនពិគ្រោះយោបល់ផ្សេងៗនៅក្នុងប្រទេសជប៉ុន។ គុណប្រយោជន៍នៃជំរើសនេះ គឺថាការចំណាយសំរាប់ការងារនោះត្រូវបានផ្អែកទាំងស្រុងលើការប្រតិបត្តិការងារ។ ម្យ៉ាងវិញទៀត គុណវិបត្តិនៃជំរើសនេះ គឺថាកំរិតនៃការតាំងចិត្តពីដៃគូជប៉ុនមានកំរិតណាក្នុងការបំពេញការងារនេះនៅមិនទាន់ច្បាស់ នៅឡើយទេ។ និយាយម្យ៉ាងទៀត ការប្តេជ្ញាចិត្តក្នុងការងារត្រូវបានកំណត់ដោយតម្លៃនៃកំរៃជើងសារ ដែលភាគីកម្ពុជានឹងផ្តល់អោយ។ ដូចនេះ រដ្ឋាភិបាលកម្ពុជានឹងតំរូវអោយរៀបចំត្រៀមខ្លួនសំរាប់ការចំណាយ លើកំរៃជើងសារ។

**តារាង ១១-៥-២ ការប៉ាន់ស្មានការចំណាយ និង កំរិតការងារសំរាប់ការិយាល័យតំណាងជប៉ុន**

| វិធីសាស្ត្រ | ចំណាយ | កំរិតការងារ |
|---|---|---|
| (i-a) អនុពន្ធ | ទាប | ទាប |
| (i-b) បុគ្គលិក ក.អ.ក/គ.វ.ក | មធ្យម | ទាប / មធ្យម |
| (ii) *អ្នកឯកទេសខាងការលក់ដូរជនជាតិជប៉ុន* | មធ្យម / ខ្ពស់ | មធ្យម / ខ្ពស់ |
| (iii) *ការជួលបន្ត* | ខ្ពស់ | ខ្ពស់ |
| (iv) *ទីភ្នាក់ងារ* | មធ្យម / ខ្ពស់ | មធ្យម / ខ្ពស់ |

Source: JICA Study Team

**(2) បញ្ហាការិយាល័យធ្វើការ**

បញ្ហាទី២ដែលត្រូវតែពិចារណានោះ គឺថាទីកន្លែងការិយាល័យធ្វើការងារនៅក្នុងប្រទេសជប៉ុន។ ជំរើសមានដូចខាងលើ (i) - (ii) តំរូវអោយមានការិយាល័យសំរាប់ធ្វើការងារ។ ជំរើសល្អបំផុតគឺត្រូវដាក់ការិយាល័យនៅក្នុងស្ថានទូតកម្ពុជាដែលប្រចាំនៅប្រទេសជប៉ុន។

*(i) ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន*

ការដាក់ទីតាំងនៅក្នុងស្ថានទូតកម្ពុជា ហាក់ដូចជាជំរើសដ៏ល្អបំផុតសំរាប់ការិយាល័យតំណាងប្រចាំប្រទេសជប៉ុនទាក់ទងទៅនឹងហិរញ្ញវត្ថុ។ ដូចនេះស្ថាប័ន CDC/CIBនឹងត្រូវបានគេតំរូវអោយរៀបចំការងារនេះជាមួយក្រសួងពាក់ពន្ធ័។

*(ii) ការជួលការិយាល័យនៅក្នុងប្រទេសជប៉ុន*

ក្នុងការជួលការិយាល័យសំរាប់ធ្វើការនៅក្នុងប្រទេសជប៉ុន វាពាក់ពន្ធ័ទៅនឹងការចំណាយខ្ពស់។ តែទីក្រុង Yokohama ផ្តល់កន្លែងការិយាល័យដោយពិសេសសំរាប់តែរដ្ឋាភិបាលបរទេស។ ទីក្រុង Yokohama មានទីតាំងស្ថិតនៅចំងាយ 30 km ពីទីក្រុងតូក្យូ។ ដូចនេះត្រូវគេផ្តល់អនុសាសន៏អោយបង្កើតការិយាល័យការងារ

នៅក្នុងប្រទេសជប៉ុននៅក្នុងមជ្ឈមណ្ឌលគាំទ្រពាណិជ្ជកម្មពិភពលោកទីក្រុង Yokohama (WBC)។ មានការិយាល័យចំនួន៤ប្រភេទនៅក្នុងមជ្ឈមណ្ឌលនេះ (សូមមើលតារាង១១-៥-៣)។ បន្ទប់ស្តង់ដារនៃមជ្ឈមណ្ឌលនេះ ត្រូវបានបំពាក់ទៅដោយសំភារៈដូចជា តុ កៅអី ទូដាក់ឯកសារ ទូរសព្ទ័ និង ទូរសារ។ ការគិតលុយសំរាប់ការប្រើប្រាស់ទូរសព្ទ័ ការប្រើអ៊ិនធ័រណេត ហើយនិងចំណាយជាក់ស្តែងសំរាប់ការថតចំលង និងក្រដាសគួរតែត្រូវបានចំណាយដោយអ្នកប្រើបន្ទប់ការិយាល័យនោះ។ នៅពេលបច្ចុប្បន្ននេះ ការិយាល័យសំរាប់ការជំរុញការវិនិយោគមួយចំនួនរួមមានៈ សាធារណរដ្ឋឆែក ហ្វីលីពីន ស្រីឡាំងកា សួនឧស្សាហកម្មផ្សេងៗរួមមាន ASCENDAS (ប្រទេសសឹង្ហបូរី), Shanghai Pudong (ប្រទេសចិន), ការិយាល័យតំណាងរដ្ឋផ្សេងៗមកពីសហរដ្ឋអាមេរិក និងប្រទេសប្រេស៊ីលត្រូវបានបោះទីតាំងនៅ WBCដែរ។

**តារាង ១១-៥-៣ ថ្លៃជួលការិយាល័យក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកទីក្រុង Yokohama**

| ប្រភេទ | ម៉ែត្រការ៉េ | ចំនួនអ្នកជួល | ថ្លៃជួល / ជួល (រួមបញ្ចូលពន្ធ) |
|---|---|---|---|
| A | $20m^2$(=$15ft^2$) | 3 | ¥60,000 (=US$ 521) |
| B | $12m^2$(=$129ft^2$) | 2 | ¥36,000 (=US$ 313) |
| C | $10m^2$(=$108ft^2$) | 1 | ¥30,000 (=US$ 260) |
| D | $6m^2$(= $64ft^2$) | 1 | ¥20,000 (=US$ 173) |

Note: US$1 = ¥115
Source: Yokohama World Business Center

| | |
|---|---|
| អាស័យដ្ឋានទាក់ទង | ជាន់ទី ៦ ,Yokohama World Porters, 2-1 Shinko2-Chome, Naka-ku,<br>Yokohama 231-0001 ប្រទេសជប៉ុន<br>ទូរស័ព្ទ : 045-222-2030 / ទូរសារ : 045-222-2088<br>គេហទំព័រ ://www.ywbc.org/english/index.html |

## ១១.៦ ការបង្កើតបណ្តាញការធ្វើជំនួយជាមួយប្រទេសផ្សេងៗ ហើយនិងការជំរុញការវិនិយោគទុន

ដូចយើងបានពិនិត្យរួចហើយអំពីការបង្កើតបណ្តាញដូចបានរៀបរាប់ខាងលើជាមួយប្រទេសជប៉ុន ក.អ.ក/គ.វ.ក ត្រូវធ្វើប្រតិបត្តិការស្រដៀងគ្នានៅក្នុងប្រទេសផ្សេងៗទៀត។ ប្រតិបត្តិការទាំងនោះរួមមានការបង្កើតក្រុមជំរុញការវិនិយោគសំរាប់ប្រទេសណាមួយ បេសកម្មវិនិយោគការបង្កើតបណ្តាញជាមួយរដ្ឋាភិបាលក៏ដូចជាសាជីវកម្មឯកជននានា ហើយនិងការបង្កើតការិយាល័យតំណាងមួយរបស់ ក.អ.ក/គ.វ.ក។ ប្រទេសនានា ដែលគួរត្រូវបានដាក់ជាគោលដៅនោះមានដូចជា ប្រទេសចិន កូរ៉េ តៃវ៉ាន់ ថៃឡង់ ម៉ាឡេស៊ី និងប្រទេស វៀតណាម។ ក្នុងចំណោមប្រទេសទាំងនោះយើងឃើញថាប្រទេសថៃឡង់ និងចិន ហាក់ដូចជាមានសារៈសំខាន់ណាស់ព្រោះ ក.អ.ក/គ.វ.ក នឹងអាច

ដាក់ជាគោលដៅចំនួនពីរក្រុមៈ ក្រុមហ៊ុនក្នុងស្រុក ក៏ដូចជាក្រុមហ៊ុនជប៉ុនដែលជាប់ទាក់ទងជាមួយនឹងប្រទេសទាំងពីរនោះ។ មានក្រុមហ៊ុនជប៉ុនដែលជាប់ទាក់ទងចំនួនជាង ៥,០០០ នៅក្នុងប្រទេសថៃ ហើយដែលកំពុងស្វែងរកឱកាសផ្សេងៗសំរាប់ការផ្លាស់ប្តូរ ទីតាំងរបស់គេសំរាប់ការ ផលិតផលិតផលអតិពលកម្មក្នុងប្រទេសជិតខាង។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនជប៉ុនមួយចំនួននៅ ក្នុងប្រទេសចិនហាក់ដូចជាមានចំណាប់អារម្មណ៍នៅក្នុងគោលនយោបាយមួយដែលមានឈ្មោះថា "ចិនបូកមួយ" ដែលនឹងកំពុងស្វះស្វែងរកទីតាំងសំរាប់ការធ្វើវិនិយោគថ្មីមួយនៅខាងក្រៅប្រទេសចិន។ បេសកកម្មសំរាប់ការជំរុញវិនិយោគដ៏សកម្ម ហើយនិងការបង្កើតការិយាល័យតំណាងនៅតាមបណ្តាប្រទេសទាំងនោះ ជាការពិតណាស់ នឹងជំរុញសមត្ថភាពការធ្វើវិនិយោគមកកម្ពុជាសំរាប់ ក.អ.ក/គ.វ.ក នៅក្នុងពេលអនាគត។

## ១១.៧ ការកំណត់ពេលវេលាអនុវត្តន៍អនុសាសន៍ដែលបានស្នើឡើង

នៅក្នុងខ្លឹមសារនេះ អនុសាសន៍ចំនួន ១៤ក្នុងការអភិវឌ្ឍន៍ ក៏ដូចជាការជំរុញការវិនិយោគត្រូវបានស្នើឡើងសំរាប់ការអភិវឌ្ឍន៍សមត្ថភាពរបស់ ក.អ.ក/គ.វ.ក។ តារាង ១១-៧-១ បានបង្ហាញពីពេលវេលាក្នុងការអនុវត្តន៍វិធានការទាំង ១៤ ដែលបានស្នើឡើង។

**តារាង ១១-៧-១ ការកំណត់ពេលវេលាអនុវត្តន៍អនុសាសន៍ដែលបានស្នើឡើងសំរាប់ ក.អ.ក/គ.វ.ក**

| **វិធានការ** | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការអភិវឌ្ឍន៍ស្ថាប័ន** | | | | | | | | | | | | |
| បណ្ណាល័យឯកសារ | | | | | | | | | | | | |
| ការចែករំលែកពត៌មាន | | | | | | | | | | | | |
| ប្រព័ន្ធបៀវត្សន៍ផ្អែកលើការងារ | | | | | | | | | | | | |
| | | | | | | | | | | | | |
| **ការជំរុញការវិនិយោគ** | | | | | | | | | | | | |
| តារាងជំរុញការវិនិយោគ | | | | | | | | | | | | |
| សហការជាមួយសមាគមពាណិជ្ជកម្ម | | | | | | | | | | | | |
| សារពត៌មាន | | | | | | | | | | | | |
| វេបសាយ | | | | | | | | | | | | |
| **(បណ្តាញពត៌មាន)** | | | | | | | | | | | | |
| ក្រុមការងារជប៉ុន | | | | | | | | | | | | |
| បង្កើតបណ្តាញជាមួយអង្គការជប៉ុន | | | | | | | | | | | | |
| បុគ្គលិកគ្រប់គ្រងពត៌មាន | | | | | | | | | | | | |
| សំភារៈសំរាប់ជំរុញការវិនិយោគ | | | | | | | | | | | | |
| បេសកម្មវិនិយោគ | | | | | | | | | | | | |
| សិក្ខាសាលាស្តីពីការធ្វើវិនិយោគ | | | | | | | | | | | | |
| តុជប៉ុន | | | | | | | | | | | | |

នៅក្នុងអនុសាសន៍ទាំង ១៤ ដូចដែលបានរៀបរាប់ខាងលើ គេនឹងធ្វើការកំនត់ជាអាទិភាពទៅតាមការចាំបាច់ ការប្រញាប់ និងការជាក់ស្តែង ក្នុងគោលបំនងដើម្បីធ្វើអោយពត៌មានវិនិយោគមានភាពងាយស្រួលក្នុងការប្រមូលជាពិសេស

ពតិមានពាណិជ្ជកម្មក្នុង ក.អ.ក/គ.វ.ក។ វិធានការណ៍នេះរួមបញ្ចូលទាំងកិច្ចពង្រឹងការចែករំលែកពតិមានក្នុង ក.អ.ក/គ.វ.ក ការបង្កើតតារាងជំរុញការធ្វើវិនិយោគ ហើយនិងការបង្កើតនូវបណ្តាញសហការណ៍យ៉ាងជិតស្និត ជាមួយសមាគមន៍ពាណិជ្ជកម្ម។ (សូមមើលតារាង ១១-៧-២)

អាទិភាពទី ២ ត្រូវបានផ្តល់ចំពោះវិធានការដែលៈ(i) បច្ចុប្បន្ន ជាការអភិវឌ្ឍន៍វេបសៃត៍ និងសិក្ខាសាលា និងបេសកម្ម វិនិយោគ និង (ii) ក្នុងគោលបំណងបង្កើនសមត្ថភាពផ្សព្វផ្សាយពតិមាន ដោយរួមទាំងការបង្កើតបណ្ណាល័យឯកសារ ការចេញផ្សាយសារពតិមាន រៀបចំក្រុម "ជប៉ុន" បង្កើតសំភារៈផ្សព្វផ្សាយ កសាងបណ្តាញជាមួយអង្គការជប៉ុន និងចាត់ចែងបុគ្គលិកគ្រប់គ្រងពតិមាន។

ជាទីបញ្ចប់ ការបង្កើត "តុជប៉ុន" គឺជាអាទិភាពទី ៣។ វានឹងមានសារៈប្រយោជន៍សំរាប់ការអភិវឌ្ឍន៍នៃសមត្ថភាពជំរុញការវិនិយោគនាពេលអនាគត ប៉ុន្តែទោះបីជាយ៉ាងណា ការធ្វើឱ្យប្រាកដចេញជារូបរាងនៃ "តុជប៉ុន" នេះ វាហាក់ដូចជាមានការលំបាកដោយសារតែថវិការរបស់ ក.អ.ក/គ.វ.ក នៅមានកំរិត ក្នុងខណៈនេះ។ វាអាចមាននឹងមានប្រសិទ្ធភាពខ្ពស់ នៅពេលដែលសញ្ញាណនៃ "ការវិនិយោគនៅកម្ពុជា" ត្រូវបានកាន់ជ្រួតជ្រាបក្នុងមជ្ឈដ្ឋានវិនិយោគិនជប៉ុននាពេលអនាគត។ បន្ថែមពីនេះទៅទៀត ប្រព័ន្ធប្រាក់បៀវត្សរ៍ផ្អែកលើស្នាដៃការងារ តំរូវឱ្យមានការពិចារណាយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្ត។

**តារាង ១១-៧-២ អនុសាសន៍ជាអាទិភាពដែលបានស្នើឡើង**

| **អាទិភាព** | **វិធានការដែលបានស្នើ** |
|---|---|
| អាទិភាពខ្ពស់បំផុត | **ការអភិវឌ្ឍន៍ស្ថាប័ន :** ការចែករំលែកពតិមាន<br>**ការជំរុញការធ្វើវិនិយោគ :** តារាងជំរុកការវិនិយោគ និងកិច្ចសហការណ៍ជាមួយសមាគមពាណិជ្ជកម្ម |
| អាទិភាពខ្ពស់បំផុត | **ការអភិវឌ្ឍន៍ស្ថាប័ន :** បណ្ណាល័យឯកសារ<br>**ការជំរុញការធ្វើវិនិយោគ :** សារពតិមាន វេបសាយ ក្រុមការងារជប៉ុន សំភារៈផ្សព្វផ្សាយ បេសកម្ម និង សិក្ខាសាលាស្តីពីវិនិយោគ បង្កើតបណ្តាញជាមួយអង្គការជប៉ុន និងចាត់ចែងបុគ្គលិកគ្រប់គ្រងពតិមាន |
| អាទិភាពទាប | **ការអភិវឌ្ឍន៍ស្ថាប័ន :** ប្រព័ន្ធប្រាក់បៀវត្សន៍ដោយផ្អែកលើការងារ<br>**ការជំរុញការធ្វើវិនិយោគ :** ការិយាល័យតំណាងនៅប្រទេសជប៉ុន |

Source:JICA Study Team

វិធានការជាអាទិភាពខ្ពស់ជាងគេ ក៏ដូចជាសិក្ខាសាលាស្តីពីធ្វើវិនិយោគ ការប្រើប្រាស់ពតិមានពាណិជ្ជកម្មតាមរយៈការកំណត់នូវិធានការជាអាទិភាពនឹងត្រូវធ្វើការពិនិត្យបន្ថែមទៀតក្នុង "ផែនការសកម្មភាព" ជំពូកក្រោយ។

# ជំពូកទី ១២
# គោលនយោបាយសំរាប់ការទាក់ទាញវិនិយោគបរទេសផ្ទាល់ក្នុងប្រទេសកម្ពុជា
# កំណែលំអ និងផែនការសកម្មភាព

## ១២.១ បញ្ហា ដែលត្រូវដោះស្រាយសំរាប់គោលនយោបាយទាក់ទាញការវិនិយោគបរទេសផ្ទាល់

នៅក្នុងជំពូកមុន គោលនយោបាយឧស្សាហកម្ម និងសេដ្ឋកិច្ចរបស់កម្ពុជា និងលទ្ធភាពសំរាប់ធ្វើឱ្យប្រាកដឡើងនូវការវិនិយោគបរទេសផ្ទាល់ ក្នុងផ្នែកនៃឧស្សាហកម្មសក្តានុពលដែលបានស្នើឡើង ត្រូវបានធ្វើការវិភាគ។ បញ្ហាដែលត្រូវដោះស្រាយ ដើម្បីនឹងទាក់ទាញការវិនិយោគបរទេសផ្ទាល់ បានត្រូវចង្អុលបង្ហាញ ហើយវិធានការកែលំអក៏ត្រូវបានស្នើឡើងដែរ។ បន្ថែមពីនេះទៀត ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម និងការវិនិយោគ ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធ និងការចាត់ចែង ព្រមទាំងមុខងាររបស់ ក.អ.ក/គ.វ.ក ក៏បានត្រូវធ្វើការសើរើឡើងវិញ។ សេចក្តីសង្ខេបនៃបញ្ហាដែលត្រូវដោះស្រាយ ត្រូវបានបង្ហាញជូនក្នុងតារាង ១២-១-១ ខាងក្រោម :

**តារាង ១២.១.១ សេចក្តីសង្ខេបនៃបញ្ហាដែលត្រូវដោះស្រាយសំរាប់ឧស្សាហកម្ម ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងក្នុងគោលដៅនៃគោលនយោបាយទាក់ទាញ FDI**

| ឧស្សាហកម្ម ស្ថាប័ន ក្របខ័ណ្ឌច្បាប់ | វិស័យ | បញ្ហាដែលបានលើកឡើង |
|---|---|---|
| កាត់ដេរ | ហេដ្ឋារចនាសម្ព័ន្ធ<br>ការអភិវឌ្ឍន៍ ឧស្សាហកម្ម<br>ការទាក់ទាញ FDI | ឧស្សាហកម្មកាត់ដេរនឹងនៅតែជាឧស្សាហកម្មសក្តានុពលសំរាប់រយៈពេលវែងដូចដែលបានធ្វើការវិភាគ និងការប្រមើមើលក្នុងទំព័រមុន។ កត្តាដែរជាគុណវិបត្តិមានដូចជានិតិវិធីក្នុងការធ្វើពាណិជ្ជកម្មមានភាពស្មុគស្មាញ និងការចំណាយក្រៅផ្លូវការ ដែលមិនអាចប្រកែកបាន។<br>ទោះយ៉ាងណាក៏ដោយ វាមិនមែនជាគុណវិបត្តិដ៏ធ្ងន់ធ្ងរក្នុងការ រក្សាទុក និង ធ្វើការណែនាំទៅ FDI ព្រោះដោយសារ ប្រាក់ចំនេញក្នុងវិស័យកាត់ដេរនៅ កម្ពុជាមិនទាបណាស់ណា បើ ប្រៀបធៀបជាមួយប្រទេសជិតខាង ចិរភាពប្រកួតប្រជែង ក្នុងការនាំចេញ ការផ្លាស់ប្តូរសន្សឹមៗនៃគុណវិបត្តិការធ្វើ អោយប្រសើរឡើងនូវស្ថាប័នរដ្ឋាភិបាល និង និន្នាការជំរុញ FDI ក្នុងវិស័យកាត់ដេរ។ |
| កសិកម្ម និងនេសាទ | ហេដ្ឋារចនាសម្ព័ន្ធ | ការយឺតយ៉ាវក្នុងការធ្វើអោយប្រសើរនូវប្រព័ន្ធធារាសាស្ត្រ បាន ជះឥទ្ធិពលមកលើផលិតកម្ម និងគុណភាពផលិតផលកសិកម្ម |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | កសិករភាគតិច មានការយល់ដឹង ជំនាញ និងការលើកទឹកចិត្តក្នុងការគ្រប់គ្រងទៅលើការត្រួតពិនិត្យសត្វល្អិត ការប្រើប្រាស់ជី និងការកែលំអរគុណភាព ដែលធ្វើអោយមានការធ្លាក់ចុះនូវតំលៃពាណិជ្ជកម្មនៃបន្លែផ្លែឈើ ជាលទ្ធផលនាំ ឱ្យមានការថយចុះចំនួនផលិតផលដែលត្រូវដឹកជញ្ជូនទៅកាន់ទីផ្សារ។<br>កំណែទំរង់ស្ថាប័ន ជាការដែលមិនអាចជៀសវាងបាន ដើម្បីធានានូវផលិតកម្ម កសិកម្មជាចីរភាព |
| | ការទាក់ទាញវិនិយោគផ្ទាល់បរទេស | ក្រុមហ៊ុនកែច្នៃចំនីអាហារ ត្រូវបានជំរុញឱ្យធ្វើទំនាក់ទំនងកាន់តែល្អឡើង ទាំងថវិកា និងពេលវេលាក្នុងការទិញសំភារ: |

| | | |
|---|---|---|
| ការកែច្នៃម្ហូបអាហារ | ហេដ្ឋារចនាសម្ព័ន្ធ | នាពេលបច្ចុប្បន្ន វាមានការលំបាកក្នុងការដឹកជញ្ជូនត្រី និងផល កសិកម្មអោយមានភាពស្រស់ៗ ដែលធ្វើអោយមានបញ្ហាក្នុង ការអភិវឌ្ឍន៍ទីផ្សារ ការបែងចែកផលិតផល និងការពង្រីក ផលិតកម្ម |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | គ្មានភ្នាក់ងារអធិការកិច្ចម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា ឬក៏លក្ខណៈពិសេស នៃការវាយតម្លៃ ត្រូវបានបង្កើតឡើងទេឡើយ ។ ទន្ទឹមនឹងនេះ ការកើនឡើងនូវ<br>កង្វល់ទូទាំងសកលលោកទៅលើបញ្ហាសុខភាព បានពន្លឿនការរឹតបន្តឹងបទប្បញ្ញត្តិអធិការកិច្ច ក្នុងការនាំទំនិញចូលប្រទេស ។ |
| | ការទាក់ទាញវិនិយោគផ្ទាល់បរទេស | ក្រុមហ៊ុនបរទេសកែច្នៃចំនីអាហារ មានការលំបាកក្នុងការទទួលបាននូវការគាំទ្រ គ្រប់គ្រាន់ដើម្បីនឹងវិនិយោគនៅកម្ពុជា |
| ស្បែកជើង | ហេដ្ឋារចនាសម្ព័ន្ធ | កិរិតវប្បធម៌របស់បុគ្គលិកនៅទាប ដែលបញ្ជាក់នូវផលិតភាពទាប<br>បណ្តាញភស្តុភារវាងរោងចក្រស្ថិតនៅជុំវិញក្រុងភ្នំពេញ និងកំពង់ផែក្រុងព្រះសីហនុ នៅមិនទាន់ គ្រប់គ្រាន់ |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | ដោយសារកង្វះខាតនៃកិច្ចសំរបសំរួលពាក់ព័ន្ធ មានកង្វះខាតមួយនៃការឯកភាព ក្នុងចំណោម សមាជិកជាឧស្សាហកម្ម<br>ពុំទាន់មានការណែនាំសំរាប់វិនិយោគនាពេលអនាគត<br>សំរាប់ទិសដៅរយៈពេលវែង វាជាការចំបាច់ក្នុងការបំបាត់ការ ពឹងផ្អែកលើផ្នែកនាំចូល |
| | ការទាក់ទាញវិនិយោគផ្ទាល់បរទេស | ការលើកទឹកចិត្តទៅលើឧស្សាហកម្មផលិតស្បែកជើង មិនទាន់គ្រប់គ្រាន់<br>ការលើកទឹកចិត្តក្នុងគោលបំនងទាក់ទាញវិនិយោគផ្ទាល់បរទេសដែលត្រូវបានផ្តល់ឯកទេសជំនាញក្នុង ការផលិតសំភារៈ និងផ្នែកធាតុចូល សំរាប់ឧស្សាហកម្ម ពុំទាន់ត្រូវបានផ្តល់អោយនៅឡើយ<br>និតិវិធីក្នុងការដាក់ពាក្យ និង ការអនុមតិ សំរាប់នាំចេញ និងនាំចូល គ្មានប្រសិទ្ធភាព |
| គ្រឿងអេឡិចត្រូនិច | ហេដ្ឋារចនាសម្ព័ន្ធ | ពុំទាន់មានសួនឧស្សាហកម្មជាមួយនឹងតំបន់សេរី និង ហេដ្ឋារ ចនាសម្ព័ន្ធគ្រប់គ្រាន់រួមទាំងស្ថេរភាព ក្នុងការផ្គត់ផ្គង់អគ្គិសនី<br>មិនមានការអភិវឌ្ឍន៍លើបណ្តាញដឹកជញ្ជូនដែរប្រតិបត្តិតាម SCM អន្តរជាតិ<br>ប្រព័ន្ធផ្គត់ផ្គង់ធនធានមនុស្សដូចជា អ្នកបច្ចេកទេស និង វិស្វករ មិនបានរៀបចំបានល្អ |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | (ឧស្សាហកម្មផ្ទាល់ខ្លួនមិនទាន់មាន) |
| | ការទាក់ទាញវិនិយោគផ្ទាល់បរទេស | សកម្មភាពជំរុញរបស់ស្ថាប័នពុំទាន់គ្រប់គ្រាន់ក្នុងការទាក់ទាញ<br>ទុនបរទេសមកវិនិយោគលើផ្នែកគ្រឿងអេឡិចត្រូនិច<br>យោងទៅលើ "ម៉ោងការងារ" ដែលបានចែងក្នុងច្បាប់ស្តីពីការ ងារ<br>មិនបានបំពេញតំរូវការប្រតិបត្តិការគ្រប់កាលៈទេសៈ |
| គ្រឿងយន្ត | ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនជាក់លាក់ក្នុងការផ្គត់ផ្គង់អគ្គិសនីអាចកំណត់បានថានៅទាប ហើយមានតែក្រុមហ៊ុនពីរ បីប៉ុណ្ណោះដែរទទួលបាននូវការផ្គត់ផ្គង់នេះ<br>សួនឧស្សាហកម្ម ដែរបានអភិវឌ្ឍន៍ដោយក្រុមហ៊ុនក្នុងស្រុកមិនបានបំពេញតំរូវការក្រុមហ៊ុន វិនិយោគបរទេស |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | បច្ចេកវិជ្ជាសំខាន់ៗដូចជា ចាក់ពុម្ព ការការពារកំដៅ និងបំលែង លោហធាតុ<br>ដែរជាផ្នែកសំខាន់របស់ឧស្សាហកម្មគ្រឿងយន្ត នៅមាមការខ្វះខាត<br>គោលនយោបាយ និងវិធានការក្នុងការអភិវឌ្ឍន៍ឧស្សាហកម្ម គាំទ្រនៅមានការខ្វះខាត |

| | | |
|---|---|---|
| | | ពលកម្មទំនាញ ដែរអាចបំពេញតំរូវការក្រុមហ៊ុនបរទេសមិន មានការបណ្តុះបណ្តាល |
| | ការទាក់ទាញវិនិយោគផ្ទាល់បរទេស | គំរោងវិនិយោគផ្ទាល់បរទេសក្នុងផ្នែកបរិក្ខាដឹកជញ្ជូន និងផលិត ផលលោហៈ<br>មិនត្រូវបានទទួលការលើទឹកចិត្តលើពន្ធលើប្រាក់ ចំនេញ លុះត្រាតែទុនវិនិយោគរបស់គេ ៣០០ពាន់ ឬ ច្រើន ជាងនេះ<br>វិនិយោគផ្ទាល់បរទេសលើឧស្សាហកម្មគ្រឿងយន្តក្នុងប្រទេស<br>កម្ពុជារហូតមកដល់សព្វថ្ងៃនេះសិងតែមិនមានសកម្មភាព |
| ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធទៅនឹងការវិនិយោគ និង<br>ការធ្វើពាណិជ្ជកម្ម | ទូទៅ | មិនពេញលេញ ទន់ខ្សោយ កំហុស ឬ ភាបមិនត្រឹមរបស់ច្បាប់ និង បទបញ្ញត្តិ<br>គឺជាផលប៉ះពាល់មួយយ៉ាងខ្លាំងដល់ប្រព័ន្ធច្បាប់<br>ហើយការកាត់ក្តីរបស់តុលាការតែងតែត្រូវបានចោទប្រកាន់ ដោយប្រជាជនក្នុងការលំអៀង និង ភាពមិនរឹងប៉ឹង |
| | | ភាគច្រើននៃការរងគ្រោះដែលពាក់ព័ន្ធទៅនឹងច្បាប់ របស់ពា ណិជ្ជកម្មកម្ពុជា គឺកង្វះខាតនូវច្បាប់ និង បញ្ញត្តិគ្រប់គ្រាន់ ។ ថ្វី ត្បិតតែរាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមក្នុងការជំរុញដំនើរ<br>ការអនុម័តបទបញ្ញត្តិដែលពាក់ព័ន្ធទៅនឹងវិនិយោគ និងការ ធ្វើពាណិជ្ជកម្ម ។<br>ច្បាប់សំខាន់ៗមួយចំនួនមិនទាន់បានតាក់តែង ឡើង |
| | | បន្ទាប់ពីចេញនូវអនុក្រិត PMIS អនុក្រិតក្នុងការអនុវត្តន៏ ច្បាង់ស្តីពីវិនិយោគ និង<br>អនុក្រិតតំបន់សេដ្ឋកិច្ចពិសេស យើង ឃើញមានការបកស្រាយមិនមិនស៊ីគ្នាខ្លះរវាងអនុក្រិតទាំង នោះជាមួយនិងវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ដែលវានឹង នាំមកនូវការយល់ច្រឡំដល់វិនិយោគិន ។<br>នៅក្នុងវិសោធនកម្ម ច្បាប់ស្តីពីវិនិយោគមិនអនុញ្ញាតិផ្តល់ការលើកទឹកចិត្តល្អជាង ដល់តំបន់ពិសេស |
| | | ទស្សនៈមិនច្បាស់លាស់ និងភាពទន់ខ្សោយនៃច្បាប់សំរាប់ តំបន់សេដ្ឋកិច្ចពិសេស ។<br>ការលើទឹកចិត្តមិនបានគ្រប់គ្រាន់ដូចជា តំបន់ពិសេស |
| | | ថ្វីត្បិតតែប្រព័ន្ធឯកសារគយត្រូវបានកែលំអរនៅតាមច្រកខ្លះ តំរូវការឯកសារមួយចំនួននៅតែមាន<br>ហើយការចាយលុយ ក្រៅផ្លូវការនៅតែទាមទារសំរាប់ករណីមួយចំនួន និងត្រូវចំ<br>នាយពេលយូរក្នុងការត្រួតពិនិត្យការនាំចេក នាំចូល |
| ស្ថាប័ន និង តួនាទីរបស់<br>ក.អ.ក/គ.វ.ក | ទូទៅ | ខ្វះការចែករំលែក និងកិច្ចសហការរវាងនាយកដ្ឋានមួយទៅ នាយកដ្ឋានមួយ<br>យោងទៅលើការជំរុញការវិនិយោគ ប្រតិបត្តិការចំបងរបស់ ក.អ.ក/គ.វ.ក<br>គឺផ្តល់នូវពតិមានដល់អ្នកវិនិយោគ<br>ខ្វះការប្រមែប្រមូលពតិមានវិនិយោគ ដែលវិនិយោគិនមានការ ចាប់អារម្មណ៏បំផុត សំរាប់<br>ក.អ.ក/គ.វ.ក |

Source: JICA Study Team

## ១២.២ ការស្នើសុំនូវវិធានការកែលំអ និងផែនការសកម្មភាពសំរាប់គោលនយោបាយទាក់ទាញ FDI

### ១២.២.១ វិធានការកែលំអ

ប្រសិនបើត្រូវបានណែនាំស្របតាមអនុប្រយោគនៃច្បាប់ វាច្បាស់ណាស់ថាការណែនាំនៃគោលនយោបាយការវិនិយោគ

បរទេសផ្ទាល់របស់កម្ពុជា នឹងជួបប្រទះបញ្ហាជាច្រើន។ ដូចនេះ ការលុបចោលនូវអនុប្បយោគទាំងនេះ គឺជាគន្លឹះដើម្បីធ្វើឱ្យចំរើនជឿនលឿននៃការវិនិយោគបរទេសផ្ទាល់ សំរាប់ឧស្សាហកម្មសក្តានុពលដែលបានពោលខាងលើ។ សំណើសុំនូវវិធានការកែលំអសំរាប់ការណែនាំគោលនយោបាយនៃការវិនិយោគបរទេសផ្ទាល់ ត្រូវបានបង្ហាញនូវក្នុងតារាង ១២-២-១។ នៅក្នុងតារាងខាងក្រោម គឺជាកាលវិភាគនៃការអនុវត្តន៍រួមគ្នា។ កំណែលំអ មានន័យសំរាប់ឧស្សាហកម្មសក្តានុពលទាំងនេះ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងធុរៈកិច្ច និងវិនិយោគ និងការចាត់ចែងការងារ និងមុខងាររបស់ ក.អ.ក/គ.វ.ក អាចត្រូវបានសង្ខេបដូចខាងក្រោម។ ជាមធ្យោបាយនៃការកែលំអ ពតិមានបានត្រូវប្រមូលពាក់ព័ន្ធទៅនឹងការទាក់ទាញនៃការជំរុញការវិនិយោគ ការស្ថាបនាសួនឧស្សាហកម្ម និងការអប់រំធនធានមនុស្សនៅក្នុងប្រភេទធុរៈកិច្ច។

**(1) ឧស្សាហកម្មកាត់ដេរ**

បរិយាកាសវិនិយោគសំរាប់ឧស្សាហកម្មផលិតសំលៀកបំពាក់ក្នុងប្រទេសកម្ពុជាកំពុងតែប្រសើរឡើងក្នុងប៉ុន្មានឆ្នាំនេះ។ កម្ពុជាហាក់ដូចជាមានភាពប្រកួតប្រជែងគ្រប់គ្រាន់ បើធៀបជាមួយប្រទេសចិន និងប្រទេសដទៃទៀត ដែលខ្លាំងក្នុងឧស្សាហកម្មសំលៀកបំពាក់នេះ។ ចំពោះវិនិយោគផ្ទាល់បរទេសលើវិស័យនេះ ត្រូវបានរំពឹងទុកថានឹងមានការកើនឡើង ដូច្នេះការចាំបាច់ណាមួយដើម្បីណែនាំនូវវិធានការជំរុញការវិនិយោគបរទេសផ្ទាល់ពិសេស និងជាក់លាក់ទេ ក្នុងវិស័យនេះ។

**(2) ឧស្សាហកម្មកែច្នៃចំនីអាហារ**

ក្នុងការជំរុញកំនើននៃឧស្សាហកម្មកែច្នៃចំនីអាហារអោយមានការប្រើប្រាស់យ៉ាងទូលំទូលាយនូវធនធានសកិកម្ម(បូករុក្ខាប្រមាញ់ និងនេសាទ)ក្នុងប្រទេស។ កម្ពុជាត្រូវបង្កើតនូវប្រព័ន្ធផ្គត់ផ្គង់ធនធានអោយបានគ្រប់គ្រាន់ ថ្វីបើពឹងផ្អែកទៅលើមូលធន និង បច្ចេកវិជ្ជាពីភាគីបរទេស។ ដូច្នេះហើយ ក្រៅពីការទាក់ទាញវិនិយោគផ្ទាល់បរទេស ក៏ត្រូវប្រឈរមុខនូវគោលនយោបាយដែលត្រូវធ្វើជាច្រើន បូករួមទាំងអង្គការសហការណ៏ផ្នែកកសិកម្ម និង អង្គភាពដទៃទៀតក្នុងការជំរុញវិស័យកសិ-ឧស្សាហកម្ម និង លក្ខ័ណ្ឌហេដ្ឋារចនាសម្ព័ន្ធដូចជាប្រព័ន្ធធារាសាស្ត្រ។

**(3) ឧស្សាហកម្មស្បែកជើង**

ក្នុងរយះពេលប៉ុន្មានឆ្នាំមកនេះ បរិយាកាសវិនិយោគសំរាប់ឧស្សាហកម្មផលិតស្បែកជើងមានការរីចចំរើនប្រសើរឡើង ក៏ដូចជាឧស្សាហកម្មផលិតសំលៀកបំពាក់ដែរ។ តែទោះជាយ៉ាងណាក៏ដោយ យើងឃើញថាចំនួនវិនិយោគផ្ទាល់បរទេសនៅមានចំនួនតិចតួច ដើម្បីធ្វើការជំរុញការវិនិយោគបរទេសក្នុងវិស័យនេះ ចាំបាច់ត្រូវផ្តល់អនុសាសន៍ក្នុងការអភិវឌ្ឍន៍ផែនការមេសំរាប់ឧស្សាហកម្មស្បែកជើងនេះ ដោយកិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីគោលនយោបាយទាក់ទាញវិនិយោគផ្ទាល់បរទេស ការអភិវឌ្ឍន៍ធនធានមនុស្ស ។ល។

**(4) ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ**

ក្រុមហ៊ុនបរទេស និងជប៉ុន នៅតែមានទស្សនៈចំពោះកម្ពុជា ថាមិនសមរម្យទាំងផលិតភាព និងនយោបាយ។

ដើម្បីជំនះបាននូវទស្សនៈបែបនេះ មានសេចក្តីត្រូវការជាប្រញាប់មួយ ដើម្បីបង្កើតលើមូលដ្ឋានដែល FDI នឹងអាចទទួលយកបាន តាមរយៈការរៀបចំ និងប្បញ្ញត្តិនៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ដែលរាប់បញ្ចូលទាំងតំបន់ឧស្សាហកម្ម និងបណ្តាញភស្តុភាជាអន្តរជាតិមានប្រសិទ្ធិភាពមួយ។ល។ ទាំងនេះ ត្រូវតែអមដោយយុទ្ធនាការជំរុញការវិនិយោគឱ្យបានខ្លាំងក្លាបំផុត ដែលរាប់បញ្ចូលទាំងការបោះពុម្ពនៃសៀវភៅមគ្គុទេសក៍វិនិយោគដែលមានទំនោរទៅរកការធ្វើធុរៈកិច្ច និងរៀបចំទស្សនៈកិច្ចទៅកាន់ក្រុមហ៊ុនកម្មន្តសាល នៅជប៉ុន និងក្រុមហ៊ុនបរទេសដទៃទៀតដែលមានទីតាំងនៅប្រទេសជិតខាង។

**(5) ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងធុរៈកិច្ច និងវិនិយោគ**

កំណែលំអក្នុងវិស័យតុលាការ ការបង្កើតក្រឹត្យពាក់ព័ន្ធ និងការអនុម័តនៃច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស គឺជាប្រការចាំបាច់បំផុត។ ប្បញ្ញត្តិនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ និងការអនុវត្តន៍ពេញលេញនូវប្រព័ន្ធប្រតិវេតន៍គយនៃបញ្ជរតែមួយ ត្រូវបានស្វែងរកយោលទៅតាមការប្រែប្រួលនៃបរិស្ថានវិនិយោគ។

**(6) ការចាត់ចែងការងារ/មុខងាររបស់ ក.អ.ក/គ.វ.ក**

ការបង្កើតប្រព័ន្ធចែករំលែកពតិមាន និងសហការណ៍ការងារ ដូចជាទិន្នន័យជាលក្ខណៈអេឡិកត្រូនិក រវាងនាយកដ្ឋានចំណុះ ក.អ.ក/គ.វ.ក គឺជាប្រការចាំបាច់។ ជាបន្ថែម ប្បញ្ញត្តិនៃពតិមានធុរៈកិច្ចសមស្របសំរាប់វិនិយោគិនសក្តានុពល គឺជាប្រការសំខាន់ ហើយបញ្ហានេះ អាចត្រូវបានសំរេចតាមរយៈការពង្រឹងមុខងារ និងពង្រីកបណ្ណាល័យនៃពតិមានក្នុង ក.អ.ក/គ.វ.ក។

**តារាង ១២-២-១ សេចក្តីសង្ខេបនៃសំណើជាវិធានការកំណែលំអ និងផែនការសកម្មភាពសំរាប់គោលនយោបាយទាក់ទាញការវិនិយោគបរទេសផ្ទាល់**

| ឧស្សាហកម្ម ស្ថាប័ន ក្របខ័ណ្ឌច្បាប់ | វិស័យ | វិធានការកែលំអរ | កាលវិភាគសំរាប់ការកែលំអ | ផែនការសកម្មភាព |
|---|---|---|---|---|
| កាត់ដេរ | ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍន៏ ឧស្សាហកម្ម ការទាក់ទាញ FDI | កិច្ចសំរួលមជ្ឈមណ្ឌលស្តុកទំនិញគួរតែបង្កើតនៅតំបន់សេដ្ឋកិច្ចពិសេសដើម្បីបង្រួមពេលវេលាក្នុងការនាំទំនិញចូល។<br>បង្កើតវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគុណភាពក្នុង CGTC ដើម្បីធ្វើការនាំចេញទៅកាន់ជប៉ុន<br>ដើម្បីនឹងពន្លឿនអន្តរកាលពីការដេរយកកំរៃជើងសារទៅជាការអភិវឌ្ឍន៏ និងនាំចេញ ការផ្តល់ហិរញ្ញវត្ថុក្នុងការស្តុកទំនិញ និងការផ្តល់ហិរញ្ញវត្ថុសំរាប់រោងចក្រ និងបរិក្ខា ដែលតំរូវការមុនសំរាប់អភិវឌ្ឍន៏ និងនាំចេញ។ | មធ្យម<br>ខ្លី<br>ខ្លី/មធ្យម | (គ្មាន) |

| | | | | |
|---|---|---|---|---|
| កសិកម្ម និងនេសាទ | ហេដ្ឋារចនាសម្ព័ន្ធ | កែលំអរប្រព័ន្ធធារាសាស្រ | មធ្យម/វែង | (គ្មាន) |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | ធ្វើការបណ្តុះបណ្តាល និង បង្រៀនកសិករឱ្យមានចំនេះដឹងលើការត្រួតពិនិត្យសត្វល្អិត ការប្រើប្រាស់ជី និងការកែលំអរគុណភាព ។ល។<br>បង្កើតនូវលក្ខ័ណ្ឌក្នុងការត្រួតពិនិត្យ និងវាយតំលៃម្ហូបអាហារ<br>កំណែទំរង់ស្ថាប័ន (ពង្រាងផែនការអភិវឌ្ឍន៍កសិកម្ម វិភាគនិន្នាយទាក់ព័ន្ធ ពង្រឹងគោលនយោបាយជំរុញការនាំចេញ ។ល។ | ខ្លី/មធ្យម<br>ខ្លី/មធ្យម<br>ខ្លី/មធ្យម | ធ្វើការកែលំអរ និងផ្តល់សិទ្ធជូនភ្នាក់ងារត្រួតពិនិត្យ និងវាយតំលៃម្ហូបអាហារ ។ |
| | ការទាក់ទាញវិនិយោគបរទេសផ្ទាល់ | អភិវឌ្ឍន៍ប្រព័ន្ធសហករណ៍ក្នុងទំរង់ជាសហជីពកសិករ ឬអ្នកនេសាទ | ខ្លី/មធ្យម | ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកកសិកម្ម និងនេសាទដើម្បីឱ្យមានស្ថេរភាពក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ។<br>ពង្រឹងការជំរុញផ្នែកវិនិយោគ |
| ការកែច្នៃម្ហូបអាហារ | ហេដ្ឋារចនាសម្ព័ន្ធ | កែលំអរប្រព័ន្ធធារាសាស្ត្រ<br>ធ្វើការអភិវឌ្ឍន៍នូវការផ្ទុកទំនិញក្នុងសីតុណ្ហភាពទាបដូចជា ឃ្លាំងផ្ទុកទំនិញត្រជាក់ និងប្រព័ន្ធដឹកជញ្ជូនត្រជាក់ ។ល។ | ខ្លី/មធ្យម<br>មធ្យម | បង្កើតនូវឧបករណ៍ឃ្លាំងផ្ទុកទំនិញក្នុងសីតុណ្ហភាពទាបដូចជាឃ្លាំងផ្ទុកទំនិញត្រជាក់និងប្រព័ន្ធដឹកជញ្ជូនត្រជាក់ ។ល។<br>ពង្រឹងសហករណ៍អ្នកនេសាទ និងកសិករ ដើម្បីធានាការផ្គត់ផ្គង់សំភារៈមានស្ថេរភាព |
| | ការអភិវឌ្ឍន៍ឧស្សាហកម្ម | ការបង្កើត នៃប្រភេទវាយតម្លៃម្ហូបអាហារ និងឧបករណ៍អធិការកិច្ច | ខ្លី/មធ្យម | ធ្វើការកែលំអរនិងផ្តល់សិទ្ធជូនភ្នាក់ងារអធិការកិច្ច និងវាយតំលៃ ម្ហូបអាហារ ។ |
| | ការទាក់ទាញវិនិយោគបរទេសផ្ទាល់ | បញ្ជូននូវពត៌មានដែលពាក់ព័ន្ធទៅនឹងម្ហូបអាហារ (ច្បាប់ បទបញ្ញត្តិផ្សេងៗ ពត៌មានទីផ្សារ ការផ្គត់ផ្គង់វត្ថុធាតុដើមពត៌មានពីគូរប្រកួតប្រជែង ។ល។) ទៅក្រុមហ៊ុនបរទេស ។ | ខ្លី/មធ្យម | ពង្រឹងកិច្ចសហប្រតិបត្តិការណ៍ផ្នែក កសិកម្ម និង នេសាទដើម្បីអោយមានស្ថេរភាពក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ។<br>ពង្រឹងការជំរុញផ្នែក |

| | | | | វិនិយោគ |
|---|---|---|---|---|
| ស្បែកជើង | ការអភិវឌ្ឍន៍ឧស្សាហកម្ម | រៀបចំឡើងវិញនូវសមាគមន៍ឧស្សាហកម្មស្បែកជើង<br>រៀបចំផែនការរបស់ឧស្សាហកម្មស្បែកជើង<br>ជំរុញផលិតកម្មក្នុងស្រុកនៃវត្ថុធាតុដើមសំរាប់ឧស្សាហកម្ម (ឧ.ហ ការកែច្នៃស្បែក) | ខ្លី<br>មធ្យម<br>វែង | គ្មាន |
| | ការទាក់ទាញការវិនិយោគបរទេសផ្ទាល់ | ប្បញ្ញតិនៃការលើកទឹកចិត្តដាក់លាក់សំរាប់ការវិនិយោគផលិតនូវវត្ថុធាតុដើម និងបំណែក សំរាប់បំរើឱ្យឧស្សាហកម្មស្បែកជើង (ឧ.ហ កាត់បន្ថយពន្ធលើប្រាក់ចំណេញ។ល។) | ខ្លី/មធ្យម | គ្មាន |
| ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ | ការជំរុញការវិនិយោគបរទេសផ្ទាល់ | ធ្វើឱ្យប្រសើរឡើងនូវមុខងារនិងសកម្មភាពជំរុញការវិនិយោគ (មុខងារវិភាគឧស្សាហកម្ម សៀវភៅមគ្គុទេសក៏វិនិយោគ មុខងារ "តុជប៉ុន" | ខ្លី | មិនមាន |
| | និតិវិធីរដ្ឋបាល | សមញ្ញកម្មនៃនិតិវិធីនាំចេញ-នាំចូល | ខ្លី | មិនមាន |
| | សួនឧស្សាហកម្ម | ការរៀបចំចាត់ចែងនៃសួនឧស្សាហកម្មជាមួយនឹងមុខងារនៃតំបន់សេរី | ខ្លី/មធ្យម | មិនមាន |
| | | ការអភិវឌ្ឍន៍នៃសួនឧស្សាហកម្ម ដែលការផ្គត់ផ្គង់នៃថាមពលគ្រប់គ្រាន់ ងាយស្រួលចូលដល់កំពង់ផែសំខាន់ៗ ការផ្គត់ផ្គង់ទឹកឧស្សាហកម្ម និងស្ថាបនាបណ្តាញទូរគមនាគមន៍ អាចត្រូវបានធានា | ខ្លី/មធ្យម | |
| | ការដឹកជញ្ជូនចែកចាយ | រៀបចំចាត់ចែងឡើងវិញ នូវបណ្តាញដឹកជញ្ជូនរវាងភ្នំពេញ និងក្រុងព្រះសីហនុសំរាប់កែលំអប្រសិទ្ធិភាព | មធ្យម/វែង | មិនមាន |
| | | រៀបចំចាត់ចែងនូវបណ្តាញភស្តុភាជាអន្តរជាតិ (របៀងសេដ្ឋកិច្ចកើត-លិចទី ២ ជើងហោះហើរដឹកជញ្ជូនទំនិញជាអន្តរជាតិ) | ខ្លី/មធ្យម | |
| | បណ្តុះបណ្តាលធនធានមនុស្ស | ការអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញ (បឋមសិក្សា មធ្យមសិក្សា និងការបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈ) | មធ្យម/វែង | មិនមាន |
| ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធទៅនឹងធុរកិច្ច និងវិនិយោគ | ទូទៅ | ពង្រឹងប្រព័ន្ធតុលាការ | មធ្យម/វែង | មិនមាន |
| | | ធ្វើការតាក់តែងនូវច្បាប់មួយចំនួនដូចខាងក្រោម<br>➢ ក្រមស៊ីវិល<br>➢ ច្បាប់ប្រឆាំងអំពើពុករលួយ<br>➢ ច្បាប់កិច្ចសន្យាពាណិជ្ជកម្ម<br>➢ ច្បាប់ស្តីពីធានាអន្តរសកម្ម<br>➢ ច្បាប់ស្តីពីការក្ស័យធន<br>➢ ច្បាប់ស្តីពី Anti-Dumping, Counterveiling Duties and Safeguard | ខ្លី | មិនមាន |

| | | | | |
|---|---|---|---|---|
| | | ➢ ច្បាប់ស្តីពីបទដ្ឋានឧស្សាហកម្ម<br>➢ ក្រមគយ<br>➢ ច្បាប់ស្តីពីរដ្ឋបាលស៊ីវិល | | |
| | | ប្បញ្ញត្តិនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ត្រូវតែមានការកែប្រែដើម្បីឱ្យទាន់នឹងសភាពការណ៍ផ្លាស់ប្តូរ | ខ្លី | មិនមាន |
| | | អនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងផ្តល់នូវការលើកទឹកចិត្តមិនមែនសារពើពន្ធដល់តំបន់ពិសេសទៅតាមច្បាប់ | ខ្លី | មិនមាន |
| | | បញ្ចប់នូវការអនុវត្តនីតិវិធីសាស្ត្រត្រួតពិនិត្យគយ តាមរយៈការគ្រប់គ្រងហានិភ័យ និងបញ្ជរតែមួយ | ខ្លី/មធ្យម | មិនមាន |
| មុខងារចាត់ចែងរបស់ ក.អ.ក/គ.វ.ក | ទូទៅ | បង្កើតរចនាសម្ព័ន្ធក្នុងការចែករំលែកពត៌មាន និងកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន<br>ធ្វើការប្រមែប្រមូលពត៌មានវិនិយោគសំរាប់ ក.អ.ក/គ.វ.ក<br>ផ្សព្វផ្សាយពត៌មានដល់វិនិយោគិន | ខ្លី<br>ខ្លី<br>ខ្លី/មធ្យម | បង្កើតនូវកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងចែករំលែកពត៌មាន<br>បញ្ជីជំរុញការវិនិយោគ<br>បង្កើតកិច្ចសហប្រតិបត្តិការជាមួយ សមាគមពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម<br>សិក្ខាសាលាវិនិយោគ ដោយប្រើប្រាស់ពត៌មានធុរៈកិច្ច ដែលប្រមូលដោយ ក.អ.ក/គ.វ.ក |

កំណត់សំគាល់ : ខ្លី (ក្នុងរយៈពេល ២ឆ្នាំ) មធ្យម (ក្នុងរយៈពេល ៥ឆ្នាំ) វែង (ក្នុងរយៈពេល ១០ឆ្នាំ)
ប្រភព : ក្រុមសិក្សាចៃកា

### ១២.២.២ សំណើ និងអាទិភាពនៃផែនការសកម្មភាពក្នុងគោលនយោបាយវិនិយោគបរទេសផ្ទាល់

ក្នុងចំណោមកំណែលំអជាច្រើន ក្រុមសិក្សាចៃកា បានកំណត់បញ្ហាទាំងនោះ ដែលគួរតែត្រូវបានដោះស្រាយដោយរដ្ឋាភិបាលកម្ពុជា លើគោលការណ៍អាទិភាព និងបានរៀបចំផែនការសកម្មភាពមួយសំរាប់ដំណោះស្រាយ របស់បញ្ហាទាំងនោះ ។ លក្ខណៈវិនិច្ឆ័យ ដែលធ្វើនៅក្នុងការជ្រើសរើសនៃបញ្ហាទាំងនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោមៈ

ក្នុងការរៀបចំផែនការសកម្មភាព យើងបានជ្រើសរើសការងារចំបងក្នុងគោលបំនងដោះស្រាយបញ្ហាវិនិយោគផ្ទាល់បរទេសលើឧស្សាហកម្មសក្តានុពល និងមានការពាក់ព័ន្ធដោយផ្ទាល់លើការទាក់ទាញ និងការលើកទឹកចិត្តវិនិយោគផ្ទាល់បរទេស ។

សាងសង់តំបន់ឧស្សាហកម្ម កែលំអរការដឹកជញ្ជូនអន្តរជាតិ បំពេញបន្ថែមនូវសមាសធាតុហេដ្ឋារចនាសម្ព័ន្ធ

ដូចជា អគ្គិសនី ទឹក និងទូរគមនាគមន៍ដែលត្រូវការថវិកាច្រើន។ និយាយសាមញ្ញ ការងារទាំងនេះបានកំពុងអនុវត្តន៍បន្តបន្ទាប់ដោយមូលនិធិពី ODA ជាលទ្ធផលការងារទាំងនេះមិនបានរាប់បញ្ចូលក្នុងផែនការសកម្មភាព។

ការងារដែរមានការពាក់ព័ន្ធទៅនឹងច្បាប់ក៏មិនត្រូវបានដាក់បញ្ចូនទៅក្នុងផែនការសកម្មភាពដែរ ព្រោះមានករណីជាច្រើន រាជរដ្ឋាភិបាលកម្ពុជាបានធ្វើ ឬកំពុងធ្វើការកែលំអរដើម្បីដោះស្រាយបញ្ហាដែរបានដាក់ចេញ ។ ក្នុងរាជរដ្ឋាភិបាល ក.អ.ក/គ.វ.ក គឺជាស្ថាប័នមួយទទួលបន្ទុកដោយផ្ទាល់លើគោលនយោបាយវិនិយោគផ្ទាល់បរទេស ដូចនេះហើយតំរូវអោយមានការគាំទ្រយ៉ាងខ្លាំងទៅលើសមត្ថភាពក្នុងការជំរុញវិនិយោគវិនិយោគ ជាឧទាហរណ៍ ការពង្រឹស្ថាប័ន និងសមត្ថភាពរបស់ ក.អ.ក/គ.វ.ក ជាលទ្ធផលត្រូវបានរួមបញ្ចូលក្នុងផែនការសកម្មភាព និងការផ្តល់អនុសាសន៍

យោងតាមគោលគំនិតខាងលើ ផែនការសកម្មភាពទាំង៩ដូចរៀបរាប់ខាងក្រោមត្រូវបានជ្រើរើស ដែលតំរូវអោយធ្វើការអនុវត្តភ្លាមៗ

| | |
|---|---|
| ផែនការសកម្មភាពទី១: | ផែនការសកម្មភាពសំរាប់ធ្វើការអភិវឌ្ឍន៏ក្នុង ក.អ.ក/គ.វ.ក " ការបង្កើតនូវកិច្ចសហប្រតិបត្តិការ និង ការចែករំលែកពតិមាន " |
| ផែនការសកម្មភាពទី២: | ផែនការសកម្មភាពសំរាប់ការជំរុញការវិនិយោគក្នុង ក.អ.ក/គ.វ.ក " តារាងជំរុញការវិនិយោគ " |
| ផែនការសកម្មភាពទី៣: | ផែនការសកម្មភាពសំរាប់ការជំរុញការវិនិយោគក្នុង ក.អ.ក/គ.វ.ក "បង្កើតនូវកិច្ចសហប្រតិបត្តិការជាមួយសមាគមពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម " |
| ផែនការសកម្មភាពទី៤: | ផែនការសកម្មភាពសំរាប់ការជំរុញការវិនិយោគក្នុង ក.អ.ក/គ.វ.ក "សិក្ខាសាលាស្តីពីវិនិយោគដោយប្រើប្រាស់ពតិមានវិនិយោគដែល ក.អ.ក/គ.វ.ក ធ្វើការប្រមូលបាន។ |
| ផែនការសកម្មភាពទី៥: | រៀបចំនូវផែនការមេសំរាប់ឧស្សាហកម្មស្បែកជើង |
| ផែនការសកម្មភាពទី៦: | ធ្វើការពង្រឹង និងកែលំអរនូវលក្ខ័ណ្ឌក្នុងការវាតតំលៃអាហារ និងភ្នាក់ងារត្រួតពិនិត្យ |
| ផែនការសកម្មភាពទី៧: | បង្កើតនូវឧបករណ៏ផ្ទុកទំនិញ ឃ្លាំងផ្ទុញទំនិញ និងប្រព័ន្ធដឹកជញ្ជូន សីតុណ្ហភាពទាប |
| ផែនការសកម្មភាពទី៨: | ផែនការសកម្មភាពក្នុងការអភិវឌ្ឍន៏ឧស្សាហកម្មកែរច្នៃអាហារ " ធ្វើការពង្រឹងនូវកិច្ចសហការរវាងផ្នែកកសិកម្ម និងជលផលដើម្បីស្ថេរភាពក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម " |
| ផែនការសកម្មភាពទី៩: | ផែនការសកម្មភាពក្នុងការអភិវឌ្ឍន៏ឧស្សាហកម្មកែរច្នៃអាហារ "ពង្រឹងនូវកិច្ចជំរុញវិនិយោគ (ធ្វើអោយប្រសើរឡើងនូវសមត្ថភាពបញ្ជូនពតិមាន " |

ផែនការសកម្មភាពទាំងនេះ គួរតែត្រូវបានអនុវត្តតាមលេខរៀងនៃអាទិភាព ដោយពិចារណាដល់សេចក្តីត្រូវការនៃការអភិវឌ្ឍន៏ តំរូវការពីការចាត់ចែងពាក់ព័ន្ធ និងសេចក្តីត្រូវការនៃក្រុមហ៊ុនបរទេស។ ពីទស្សនៈនេះ ផែនការសកម្ម

ភាពទីមួយៗ ត្រូវបានវាយតម្លៃផ្អែកលើ (១) ការប្រញាប់ (ក្នុងលក្ខខណ្ឌនៃពេលវេលា និងភាពត្រៀមជាស្រេចនៃការចាត់ចែងការងារពាក់ព័ន្ធ) (២) មូលនិធិចាំបាច់ (ភាពងាយស្រួលនៃថវិកា និងផលប្រយោជន៍លើចំណាយ) និង (៣) ប្រសិទ្ធិភាពដែលរំពឹងទុកពីផែនការទីមួយៗ។ លទ្ធផលនៃការវាយតម្លៃ ត្រូវបានបង្ហាញក្នុងតារាង ១២-២-២។

**តារាង ១២-២-២ លំដាប់នៃអាទិភាពរបស់ផែនការសកម្មភាព**

| ផែនការសកម្មភាព | | លក្ខណៈវិនិច្ឆ័យ | | | ពិន្ទុសរុប | អាទិភាព |
|---|---|---|---|---|---|---|
| | | ការប្រញាប់ (note 1) | មូលនិធិ (note 2) | ប្រសិទ្ធិភាពរំពឹងទុក | | |
| ក.អ.ក/គ.វ.ក | ផែនការសកម្មភាពសំរាប់ការអភិវឌ្ឍន៍ការចាត់ចែងការងារនៅក្នុង ក.អ.ក/គ.វ.ក : ការបង្កើតសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងការចែករំលែកពតិមាន។ | 3 | 3 | 3 | 9 | 1 |
| | ផែនការសកម្មភាពសំរាប់ការជំរុញវិនិយោគនៅ ក.អ.ក/គ.វ.ក : បញ្ជីជំរុញការវិនិយោគ | 3 | 3 | 3 | 9 | 1 |
| | ផែនការសកម្មភាពសំរាប់ការជំរុញវិយោគនៅ ក.អ.ក/គ.វ.ក : ការបង្កើតសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម | 3 | 3 | 3 | 9 | 1 |
| | ផែនការសកម្មភាពសំរាប់ការជំរុញវិនិយោគនៅ ក.អ.ក/គ.វ.ក : សិក្ខាសាលាវិនិយោគ ដោយប្រើប្រាស់ពតិមានដែលប្រមូលដោយ ក.អ.ក/គ.វ.ក | 3 | 3 | 3 | 9 | 1 |
| ឧស្សាហកម្ម | ធ្វើការកែលំអរ និងផ្ដល់សិទ្ធជូនភ្នាក់ងារត្រួតពិនិត្យ និងវាយតំលៃចំណីអាហារ។ | 3 | 2 | 3 | 8 | 1 |
| | បង្កើតនូវឧបករណ៏ឃ្លាំងផ្ទុកទំនិញក្នុងសីតុណ្ហភាពទាបដូចជាឃ្លាំងផ្ទុកទំនិញត្រជាក់និងប្រព័ន្ធដឹកជញ្ជូនត្រជាក់។ល។ | 2 | 1 | 2 | 5 | 4 |
| | ពង្រឹងកិច្ចសហការណ៏ផ្នែកកសិកម្ម និងនេសាទ ដើម្បីធានាបាននូវស្ថេរភាពក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម។ | 2 | 2 | 2 | 6 | 3 |
| | ពង្រឹងការជំរុញវិនិយោគសំរាប់ឧស្សាហកម្មកែច្នៃចំណើអាហារ | 2 | 3 | 2 | 7 | 2 |

Note 1: Based on (i) time, and (ii) readiness of the concerned organizations.
Note 2: Based on (i) budgetary easiness, and (ii) benefit against cost.
Source: JICA Study Team

## ១២.២.៣ ផែនការសកម្មភាព និងជំនួយបច្ចេកទេសសំរាប់ ក.អ.ក/គ.វ.ក

### (1) ផែនការសកម្មភាពសំរាប់ ក.អ.ក/គ.វ.ក

អាទិភាពនៃផែនការសកម្មភាពសំរាប់ភ្នាក់ងារជំរុញការវិនិយោគ "ក.អ.ក/គ.វ.ក" ហាក់បីដូចជាមានកំរិតខ្ពស់ ដោយសារការចាត់ចែងការងារកន្លែងខ្លះ មានឥទ្ធិពលលើគ្រប់ឧស្សាហកម្មនៅកម្ពុជា ក្នុងទិដ្ឋភាពនៃការវិនិយោគបរទេស។ ក្នុងការសិក្សានេះ កម្មវិធីចំនួន ៤ ដូចខាងក្រោម ត្រូវបានជ្រើសរើសជាផែនការសកម្មភាពសំរាប់ ក.អ.ក/គ.វ.ក។

### (i) ផែនការសកម្មភាពសំរាប់ការអភិវឌ្ឍន៍ការចាត់ចែងការងារ ក្នុង ក.អ.ក/គ.វ.ក

**តារាង ១២-២-៣ ការបង្កើតសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងការចែករំលែកពតិមាន**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សារំតា | មានភាពអន់ខ្សោយនូវកិច្ចសហប្រតិបត្តិការនិងការចែករំលែកពតិមានរវាងនាយកដ្ឋានមួយទៅនាយកដ្ឋានមួយក្នុង ក.អ.ក/គ.វ.ក |
| គោលបំនង | ធ្វើការពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋាន និង ជំរុញការចែករំលែកពតិមានក្នុង ក.អ.ក/គ.វ.ក (ជាពិសេសពាក់ព័ន្ធទៅនឹងនាយកដ្ឋានវិភាគគំរោងនិងការលើកទឹកចិត្ត នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង ដែលចាំបាច់ក្នុងការបង្កើតនូវយន្តការសហប្រតិបត្តិការ) |
| គោលសំខាន់ៗ | **ជំហានទី១:** កិច្ចព្រមព្រៀងលើកិច្ចសហប្រតិបត្តិការគួរធ្វើឡើងដោយប្រធានទាំងអស់ក្នុង ក.អ.ក/គ.វ.ក<br>**ជំហានទី២:** ទំរង់ទូទៅនៃការត្រួតពិនិត្យគួរតែបង្កើតសំរាប់នាយកដ្ឋានវិភាគគំរោងនិងការលើកទឹកចិត្ត នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង<br>**ជំហានទី៣:** ពតិមានត្រួតពិនិត្យដែលប្រមូលបានគួរតែធ្វើការបញ្ចូលគ្នា ហើយទុកក្នុងកន្លែងមួយច្បាស់លាស់ |
| កំណត់ពេលក្នុងការអនុវត្ត | រយះពេលខ្លី (ក្នុងឆ្នាំ ២០០៧) |
| ស្ថាប័នទទួលបន្ទុក | ក.អ.ក/គ.វ.ក<br>នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត<br>នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ<br>នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង<br>គ្រប់ប្រធានទាំងអស់ក្នុង ក.អ.ក/គ.វ.ក |
| ផលរំពឹងទុក | ការចែករំលែកពតិមានអាចអោយ ក.អ.ក/គ.វ.ក ធ្វើការប្រមែប្រមូលពតិមានសំខាន់ៗ និងធ្វើការពង្រឹងពតិមានស្ថិតិក្នុងស្ថាប័ន |

### (ii) ផែនការសកម្មភាពសំរាប់ការជំរុញការវិនិយោគក្នុង ក.អ.ក/គ.វ.ក

**តារាង ១២-២-៤ បញ្ជីជំរុញការវិនិយោគ**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សារំតា | មន្ត្រី ក.អ.ក/គ.វ.ក ពុំមានចំនេះដឹងទូលំទូលាយទៅនឹង ភាពផ្សេងគ្នានៃផលិតផលក្រុមហ៊ុន និងឧស្សាហកម្មក្នុងប្រទេសកម្ពុជា |
| គោលបំនង | ពង្រឹងនូវការប្រមែប្រមូលពតិមានវិនិយោគកម្ពុជាតាមការបង្កើតអោយមានតារាងជំរុញការវិនិយោគ |

| | |
|---|---|
| គោលសំខាន់ៗ | (i) ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់នូវបណ្តាញដែលមានស្រាប់ក្នុងCDC/CIB<br>ការប្រមូលពតិមានអាចធ្វើឡើងតាមរយះប្រតិបត្តិការត្រួតពិនិត្យដោយនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ ដោយសហការជាមួយនាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង និងនាយកដ្ឋានវិភាគគម្រោងនិងការលើកទឹកចិត្ត<br>(ii) សហការជាមួយសមាគមពាណិជ្ជកម្ម<br>វិធីមួយបែបទៀតក្នុងការប្រមូលពតិមានគឺអាចសំរេចបានតាមការចូលរួមជាមួយសមាគមពាណិជ្ជកម្ម ក៏ដូចជាសភាពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា។ នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការវិនិយោគ គឺជានាយកដ្ឋានដ៏សាកសមក្នុងការបង្កើតទំនាក់ទំនងជាមួយសមាគមពាណិជ្ជកម្ម |
| កំណត់ពេលក្នុងការអនុវត្ត | រយះពេលខ្លី (២០០៧-២០០៨) |
| ស្ថាប័នទទួលបន្ទុក | ក.អ.ក/គ.វ.ក<br>នាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត<br>នាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ<br>នាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង<br>នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការវិនិយោគ |
| ផលរំពឹងទុក | តារាងជំរុញការវិនិយោគនឹងធ្វើអោយប្រសើរឡើងនូវការចងក្រងពតិមានវិនិយោគទៅលើឧស្សាហកម្មក្នុងប្រទេសកម្ពុជា អាចអោយមន្ត្រី ក.អ.ក/គ.វ.ក ផ្តល់ពតិមានវិនិយោគដល់វិនិយោគិន |

**តារាង ១២-២-៥ ការបង្កើតកិច្ចសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សាវតា | មន្ត្រី ក.អ.ក/គ.វ.ក ពុំមានចំនេះដឹងទូលំទូលាយទៅនឹងភាពផ្សេងគ្នានៃផលិតផល ក្រុមហ៊ុន និងឧស្សាហកម្មក្នុងប្រទេសកម្ពុជា |
| គោលបំណង | ពង្រឹងនូវសមត្ថភាពក្នុងការប្រមូលពតិមានដោយបង្កើតនូវបណ្តាញសហការជាមួយសមគមពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម |
| វិធានការគាំទ្រ | (i) ចាត់តាំងបុគ្គលិក ដែលពាក់ព័ន្ធជាមួយសមាគមពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម ក.អ.ក/គ.វ.ក<br>(ii) បុគ្គលិកដែលធ្វើការស្រាវជ្រាវទៅលើឧស្សាហកម្មកម្ពុជា ដោយសហការជាមួយសមាគមពាណិជ្ជកម្ម ហើយធ្វើការកំនត់សំគាល់លើផលិតផល ឬសេវាកម្មសំរាប់វិនិយោគិនបរទេស<br>(ii) រៀបចំសិក្ខាសាលាស្តីពីវិនិយោគសំរាប់វិនិយោគិនបរទេស ដោយសហការជាមួយសមាគមពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម |

| | |
|---|---|
| គ្រោងការ | រយៈពេលខ្លី ( ២០០៧ ) |
| កាលវិភាគអនុវត្តន៍ | ក.អ.ក/គ.វ.ក "នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការវិនិយោគឯកជន" |
| លទ្ធផលរំពឹងទុក | មន្ត្រីជំរុញការវិនិយោគនឹងមានលទ្ធភាពធ្វើការផ្គូផ្គងរវាងតំរូវការអ្នកផលិតក្នុងស្រុក និង តំរូវការអ្នកវិនិយោគក្រៅប្រទេសយ៉ាងមានប្រសិទ្ធភាព ជាលទ្ធផលឱកាសវិនិយោគនឹងត្រូវបានបង្កើត ។ |

**តារាង ១២-២-៦ សិក្ខាសាលាវិនិយោគ ដោយប្រើប្រាស់នូវពត៌មានធុរកិច្ចដែលចងក្រងដោយ ក.អ.ក/គ.វ.ក**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សាវតា | យោងទៅលើការជំរុញវិនិយោគ មន្ត្រី ក.អ.ក/គ.វ.ក ផ្តោតការយកចិត្តទុកដាក់ទៅលើការពន្យល់បរិយាកាសច្បាប់ក្នុងប្រទេសកម្ពុជា ជាកំរក្នុងការផ្តល់នូវពត៌មានវិនិយោគ |
| គោលបំណង | បង្កើននូវចំនាប់អារម្មណ៏របស់អ្នកវិនិយោគមកលើប្រទេសកម្ពុជា ដោយមិនត្រឹមតែផ្តល់នូវពត៌មានពាក់ព័ន្ធទៅនឹងច្បាប់ ថែមទាំងពត៌មានវិនិយោគក្នុងសិក្ខាសាលា |
| វិធានការគាំទ្រ | (i) ផ្តល់ការពន្យល់ជាលក្ខណៈទូទៅលើឧស្សាហកម្មមួយៗ បន្ទាប់មកផ្តល់ពត៌មានវិនិយោគជាលក្ខណៈលំអិត ដោយប្រើប្រាស់នូវតារាងជំរុញការវិនិយោគ<br>(ii) ផ្តល់នូវពត៌មានវិនិយោគជាពិសេស ទីតាំង និងផលិតផល ដូចជាប្រភេទនៃផលិតផលដែលក្រុមហ៊ុនក្នុងស្រុកផលិត ឬឧស្សាហកម្មអ្វី ក៏ដូចជាផលិតផលកសិកម្មដែលអាចរកបានក្នុងតំបន់សំខាន់ៗក្នុងប្រទេសកម្ពុជា ។ |
| គ្រោងការ | រយះពេលខ្លី និងរយះពេលវែង |
| កាលវិភាគអនុវត្តន៍ | ក.អ.ក/គ.វ.ក "នាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការវិនិយោគឯកជន" |
| លទ្ធផលរំពឹងទុក | ចំនាប់អារម្មណ៏អ្នកវិនិយោគមកលើប្រទេសកម្ពុជានឹងត្រូវបានបង្កើនដោយធ្វើការផ្តល់នូវពត៌មានវិនិយោគតាមរយះមន្ត្រីរបស់ ក.អ.ក/គ.វ.ក |

### (២) ជំនួយបច្ចេកទេសសំរាប់ ក.អ.ក/គ.វ.ក

ក្នុងផ្នែកនេះ គំរោងជំនួយបច្ចេកទេសសំរាប់សហភាគីនៃការសិក្សានេះ "ក.អ.ក/គ.វ.ក" នឹងត្រូវបានស្នើឡើង ។ វាជាប្រការចាំបាច់ដើម្បីផ្តល់ឱ្យនូវជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធិភាពសំរាប់ ក.អ.ក/គ.វ.ក ទាក់ទិនទៅនឹងការអនុវត្តន៏នៃផែនការសកម្មភាព ។ គំរោងជំនួយបច្ចេកទេសសំរាប់ ក.អ.ក/គ.វ.ក ដូចខាងក្រោម នឹងត្រូវបានស្នើជាអនុសាសន៍ គឺ : (i) ការអភិវឌ្ឍន៏សមត្ថភាពជំរុញការវិនិយោគ និង (ii) ការអភិវឌ្ឍន៏បច្ចេកវិទ្យាពត៌មាន ។

(i) ការអភិវឌ្ឍន៏សមត្ថភាពជំរុញការវិនិយោគ

ការអភិវឌ្ឍន៏សមត្ថភាពជំរុញការវិនិយោគ នឹងត្រូវបានស្នើឡើងជាគំរោងការជំនួយបច្ចេកទេសដ៏មានតម្លៃបំផុតសំរាប់ ក.អ.ក/គ.វ.ក ។ កាលវិភាគនៃការអនុវត្តន៏ ត្រូវបានស្នើឡើងជាពីរដំណាក់កាល ។ គោលបំណងនៃដំណាក់កាលទី ១ គឺដើម្បីបង្កើតរចនាសម្ព័ន្ធចាត់ចែងការងារជាមូលដ្ឋានសំរាប់ការជំរុញវិនិយោគនៅក្នុង ក.អ.ក/គ.វ.ក ។ គោលបំណង

នៃដំណាក់កាលទី ២ គឺដើម្បីពង្រឹងសមត្ថភាពម៉ាឃិតធីងនៅក្នុង ក.អ.ក/គ.វ.ក។

**តារាង ១២-២-៧ ដំណាក់កាលទី ១ : ការបង្កើតប្រពន្ធ័ចាត់ចែងការងារ និងប្រតិបត្តិការនៅក្នុង ក.អ.ក/គ.វ.ក**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សារីតា | ក.អ.ក/គ.វ.ក គ្មានប្រព័ន្ធប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពសំរាប់ការជំរុញវិនិយោគ |
| គោលបំណង | ដើម្បីគាំទ្រដល់ការបង្កើតឡើងនៃប្រព័ន្ធប្រតិបត្តិការសមស្របមួយសំរាប់ការជំរុញវិនិយោគ និងការអភិវឌ្ឍន៏ការចាត់ចែងការងារនៅក្នុង ក.អ.ក/គ.វ.ក។ |
| វិធានការគាំទ្រ | ដើម្បីគាំទ្រដល់ការកែទំរង់ស្ថាប័ន និងការចាត់ចែងការងារនៅក្នុង ក.អ.ក/គ.វ.ក |
| គ្រោងការ | ជំនួយក្នុងការបង្កើតនៃសេវាកម្មដែលមានទិសដៅសំរាប់អតិថិជន<br>ជំនួយក្នុងការបង្កើតនៃក្រុមដែលផ្តោតតាមប្រទេសជាពិសេស ក្នុងនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញការវិនិយោគនៅក្នុង ក.អ.ក/គ.វ.ក<br>ជំនួយក្នុងការផលិតនៃបញ្ជីជំរុញការវិនិយោគ<br>ជំនួយក្នុងការពង្រឹងការចែករំលែកពត៌មានរវាងនាយកដ្ឋានក្នុង ក.អ.ក/គ.វ.ក<br>ជំនួយក្នុងការផលិតសម្ភារៈជំរុញការវិនិយោគ<br>ជំនួយក្នុងការបង្កើតការតភ្ជាប់ជាមួយអង្គការអន្តរជាតិ និងក្រុមហ៊ុនបរទេស<br>ជំនួយក្នុងការបង្កើតការតភ្ជាប់ជាមួយសភាពាណិជ្ជកម្ម និងសមាគមន៍ពាណិជ្ជកម្មនៅកម្ពុជា<br>ជំនួយក្នុងការផលិតលិខិតពត៌មានប្រចាំខែ<br>ជំនួយក្នុងការបង្កើតការអភិវឌ្ឍន៏វេបសៃត៍ និង<br>ជំនួយក្នុងការរៀបចំសិក្ខាសាលាវិនិយោគ និងបេសកកម្ម ព្រមទាំង<br>ជំនួយក្នុងប្រតិបត្តិការរបស់ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា "គ.ស.ព" |
| កាលវិភាគអនុវត្តន៏ | រយៈពេលខ្លី (2007-2009). |
| លទ្ធផលរំពឹងទុក | ជាលទ្ធផលនៃការបណ្តុះបណ្តាល ព្រមទាំងការផ្ទេរចំណេះធ្វើតាមរយៈជំនួយបច្ចេកទេស ចំណេះដឹងរបស់មន្ត្រីក្នុង ក.អ.ក/គ.វ.ក ក៏ដូចជាប្រព័ន្ធការងារជាមូលដ្ឋាន ព្រមទាំងរចនាសម្ព័ន្ធ នឹងត្រូវបានកែលំអឱ្យប្រសើរឡើង។ |

**តារាង ១២-២-៨ ដំណាក់កាលទី ២ : ការអភិវឌ្ឍន៏សមត្ថភាពម៉ាឃិតធីងនៅក្នុង ក.អ.ក/គ.វ.ក**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សារីតា | រចនាសម្ព័ន្ធចាត់ចែងការងារសំរាប់ការជំរុញវិនិយោគ នឹងត្រូវបានបង្កើតឡើងក្នុងដំណាក់ |

| | |
|---|---|
| | កាលទី ១១។ ប៉ុន្តែ វាត្រូវបានរំពឹងថា មន្ត្រីក្នុង ក.អ.ក/គ.វ.ក នឹងនៅតែមិនទាន់មានបទពិសោធន៍ក្នុងការធ្វើម៉ាឃិតធីងដែលមានចរិតជាការជំរុញការវិនិយោគនៅឡើយ។ |
| គោលបំណង | ដើម្បីពង្រឹងសមត្ថភាពម៉ាឃិតធីង និងការជំរុញវិនិយោគសំរាប់មន្ត្រីក្នុង ក.អ.ក/គ.វ.ក |
| វិធានការគាំទ្រ | ដើម្បីគាំទ្រដល់ផ្នែកទំនាក់ទំនងសាធារណៈ និងម៉ាឃិតធីង |
| គ្រោងការ | ជំនួយក្នុងការរៀបចំចងក្រងនៃយុទ្ធសាស្ត្រម៉ាឃិតធីងមួយ<br>ជំនួយក្នុងការរៀបចំចងក្រងនៃផែនការធុរៈកិច្ច<br>ជំនួយក្នុងការពង្រឹងជំនាញទំនាក់ទំនងសាធារណៈ<br>ជំនួយក្នុងការបង្កើតការិយាល័យនៅបរទេស និង<br>ជំនួយក្នុងការធ្វើបច្ចុប្បន្នភាពនៃសម្ភារៈជំរុញការវិនិយោគ |
| កាលវិភាគអនុវត្តន៍ | រយៈពេលមធ្យម (2010-2012). |
| លទ្ធផលរំពឹងទុក | ជំនាញម៉ាឃិតធីងនៃមន្ត្រី ក្នុង ក.អ.ក/គ.វ.ក នឹងត្រូវបានកែលំអឱ្យប្រសើរឡើង |

(ii) *ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន*

"កិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងការចែករំលែកពត៌មានក្នុង ក.អ.ក/គ.វ.ក" នឹងត្រូវបានស្នើឡើងជាផែនការសកម្មភាពមួយក្នុងផ្នែកមុន គោលបំណងដើម្បីបង្កើតនូវប្រព័ន្ធចាត់ចែងការងារសមស្របមួយ សំរាប់ការចែករំលែកពត៌មាន។ ដើម្បីនឹងសំរេចបាននូវលទ្ធផលគួរឱ្យពេញចិត្តនេះ ការគាំទ្រជាបច្ចេកទេសសំរាប់ផែនការនេះ ដែលមានឈ្មោះថា ការណែនាំនូវទិន្នន័យជាមូលដ្ឋានមួយ នឹងជាការសំខាន់បំផុត។

**តារាង ១២-២-៩ ការណែនាំនៃទិន្នន័យជាមូលដ្ឋានមួយ**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| សារៈ | ការណែនាំនៃគំរូត្រួតពិនិត្យរួមមួយ ត្រូវបានស្នើឡើង។ ប៉ុន្តែ ដើម្បីនឹងប្រើប្រាស់គំរូនេះ ការណែនាំនៃទិន្នន័យជាមូលដ្ឋាន នឹងធ្វើឱ្យវាមានប្រសិទ្ធិភាព |
| គោលបំណង | ពង្រឹងការចែករំលែកពត៌មានតាមរយៈការណែនាំនៃទិន្នន័យជាមូលដ្ឋាន<br>អាចធ្វើឱ្យមានការចែករំលែកពត៌មានរួមរវាងនាយកដ្ឋានចំណុះ ក.អ.ក/គ.វ.ក។<br>ដើម្បីផ្ទេរបច្ចេកវិទ្យាពត៌មាន ទៅមន្ត្រីក្នុង ក.អ.ក/គ.វ.ក |
| វិធានការគាំទ្រ | បញ្ជូនអ្នកជំនាញបច្ចេកវិទ្យាពត៌មានមក ក.អ.ក/គ.វ.ក |
| គ្រោងការ | ជំនួយក្នុងការធ្វើឱ្យប្រសើរឡើងនូវទិន្នន័យជាមូលដ្ឋានក្នុង ក.អ.ក/គ.វ.ក និង<br>បណ្ដុះបណ្ដាលបច្ចេកវិទ្យាពត៌មាន ដល់មន្ត្រី ក.អ.ក/គ.វ.ក |
| កាលវិភាគអនុវត្តន៍ | រយៈពេលខ្លី (2007). |

| | |
|---|---|
| លទ្ធផលរំពឹងទុក | ជាលទ្ធផលនៃការណែនាំនៃទិន្នន័យជាមូលដ្ឋាន បញ្ហាបច្ចេកទេសមួយក្នុងការចែករំលែកពត៌មាន នឹងត្រូវបានដោះស្រាយ។ កិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងការចែករំលែកពត៌មានក្នុងរង្វង់ ក.អ.ក/គ.រ.ក នឹងត្រូវបានពង្រឹងឱ្យប្រសើរឡើង។ |

## ១២.២.៤ ផែនការសកម្មភាពសំរាប់ឧស្សាហកម្ម

ផែនការសកម្មភាពចំនួន ៤ ត្រូវបានជ្រើសរើសសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម។ ក្នុងចំណោមពួកគេ "កំណែលំអ និងការផ្តល់សិទ្ធទៅឱ្យភ្នាក់ងារអធិការកិច្ច និងលក្ខណៈវិនិច្ឆ័យការវាយតម្លៃម្ហូបអាហារ" មានអនុផែនការសកម្មភាពចំនួនពីរ។ គ្រោងការនៃផែនការសកម្មភាព ត្រូវបានសង្ខេប ដើម្បីនឹងធ្វើអាទិភាពដូចខាងក្រោម:

**តារាង ១២-២-១០ ការពង្រឹង និង កំណែលំអលក្ខខ័ណ្ឌវាយតំលៃអាហារ និងភ្នាក់ងារត្រួតពិនិត្យ : ពង្រឹងមុខងារនៃមន្ទីរពិសោធន៍ពាក់ព័ន្ធនឹងម្ហូបអាហារ**

| សេចក្តីរៀបរាប់ | មាតិការផែនការ |
|---|---|
| សារតា | ការអភិវឌ្ឍន៍នៃលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃម្ហូបអាហារ និងការបង្កើតភ្នាក់ងារអធិការកិច្ចមួយ នៅកម្ពុជា ត្រូវបានពន្យា។<br>ក្រុមហ៊ុនកែច្នៃម្ហូបអាហារមិនបានទទួលការណែនាំ ឬការសិក្សា លើអនាម័យអាហារគ្រប់គ្រាន់ ពីរដ្ឋាភិបាល ឬស្ថាប័នសាធារណៈ |
| គោលបំនង | បង្កើតនូវការទទួលស្គាល់ជាអន្តរជាតិនូវប្រព័ន្ធអនាម័យអាហារ |
| គោលសំខាន់ៗ | បណ្តុះបណ្តាល និងផ្តល់ការអប់រំពីអ្នកជំនាញខាងអនាម័យអាហារ<br>- ពង្រឹងមុខងាររបស់ភ្នាក់ងារត្រួតពិនិត្យ (ការអភិវឌ្ឍន៍ធនធានមនុស្ស ពង្រីកបន្ថែមគ្រឿងបរិក្ខារ កែលំអរប្រតិបត្តិការ ។ល។)<br>អភិវឌ្ឍន៍លើលក្ខណវាយតំលៃអនាម័យអាហារ<br>- បង្កើនូវបទដ្ឋានសុវត្ថភាព និងប្រព័ន្ធតាមដានឧស្សាហកម្មកែច្នៃអាហារ<br>- ណែនាំនូវលក្ខណវាយតំសៃអាហារ ដូចជា បទដ្ឋាន CODEX<br>- ចេញនូវវិញ្ញាបនប័ត្រផ្សេងៗបញ្ជាក់ពីអនាម័យអាហារ (វាយឈ្មោះវត្ថុធាតុដើម សារជាតិ ផ្លាក សង្វាក់ផលិតកម្ម ក៏ដូចជាវិញ្ញាបនប័ត្របញ្ជាក់ពីអនាម័យ |
| កាលវិភាគនៃការអនុវត្តន៏ | ពង្រឹងមុខងាររបស់ភ្នាក់ងារត្រួតពិនិត្យ (រយះពេលមធ្យម)<br>បង្កើតនូវបទដ្ឋានសុវត្ថភាព និងប្រព័ន្ធតាមដានលើឧស្សាហកម្មកែច្នៃអាហារ (រយះពេល ខ្លី និងរយះពេលមធ្យម )<br>ណែនាំនូវលក្ខណវាយតំលៃអាហារជាអន្តរជាតិ (រយះពេលខ្លី)<br>ចេញនូវវិញ្ញាបនប័ត្រផ្សេងៗលើអនាម័យអាហារ (រយះពេលខ្លី និង រយះពេលមធ្យម) |
| ស្ថាប័នទទួលបន្ទុក | ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានពាណិជ្ជកម្មបរទេស និងនាយកដ្ឋានកាំកុងត្រូល)<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAALI) |

| | |
|---|---|
| | ក្រសួងសុខាភិបាល |
| លទ្ធផលរំពឹងទុក | បង្កើនផលិតកម្មកែច្នៃអាហារ ដោយធ្វើការកែលំអរនូវផលិតភាពផលិតកម្ម<br>បង្កើនការនាំចេញនូវអាហារកែច្នៃ ដែលអាចបំពេញតាមតំរូវការរបស់ប្រទេសនាំចូល<br>ការកើនឡើងនូវកង្វល់របស់បណ្តាក្រុមហ៊ុនក្នុងស្រុកទៅលើសុខភាពតាមរយះការណែនាំ<br>អោយស្គាល់នូវបទដ្ឋានអាហារអន្តរជាតិ |

**តារាង ១២-២-១១ ការពង្រឹង និង កំណែលំអលក្ខខ័ណ្ឌវាយតំលៃអាហារ និងភ្នាក់ងារត្រួតពិនិត្យ : ពង្រឹងមុខងារនៃមន្ទីពិសោធន៏អធិការកិច្ចពាក់ព័ន្ធនឹងកៅស៊ូ**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| **សារ៉ាតា** | ការគាំទ្រពីរដ្ឋាភិបាលចំពោះឧស្សាហកម្មកៅស៊ូ មិនទាន់គ្រប់គ្រាន់នៅឡើយ ។<br>ការអភិវឌ្ឍន៍នៃលក្ខណៈវិនិច្ឆ័យអធិការកិច្ច និងការបង្កើតភ្នាក់ងារអធិការកិច្ច ពាក់ព័ន្ធទៅនឹងឧស្សាហកម្មកៅស៊ូនៅកម្ពុជា ត្រូវបានពន្យា ។<br>អ្នកផលិតកៅស៊ូ ត្រូវបានដាក់កតព្វកិច្ចនាំចេញនៅក្នុងតម្លៃថោកជាងថ្លៃទីផ្សារ អន្តរជាតិ ដោយសារកង្វះខាតនៃប្រព័ន្ធធានាគុណភាពនៅកម្ពុជា ។ |
| **គោលបំនង** | ការបង្កើតប្រព័ន្ធផលិតកម្មកៅស៊ូដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ<br>ជំរុញការនាំចេញនៃផលិតផលកៅស៊ូ |
| **គោលសំខាន់ៗ** | ការអប់រំ និងបណ្តុះបណ្តាលអ្នកជំនាញ :<br>- ពង្រឹងការអភិវឌ្ឍន៏ធនធានមនុស្សនៃភ្នាក់ងារអធិការកិច្ច (ការធានាគុណភាព ការគ្រប់គ្រងដំណើរការ ការគ្រប់គ្រងផលិតកម្ម ។ល ។)<br>ការបង្កើតប្រព័ន្ធធានាគុណភាព :<br>- ពង្រឹងឧបករណ៏អធិការកិច្ច<br>- ណែនាំបទដ្ឋានអន្តរជាតិ ( ប្រព័ន្ធវិញ្ញាបនប័ត្រទទួលស្គាល់ទៅវិញទៅមកជាអន្តរជាតិ)<br>- ការចេញវិញ្ញាបនប័ត្រនៃអធិការកិច្ចកៅស៊ូ ( សន្លឹកអធិការកិច្ច ។ល ។) |
| **កាលវិភាគនៃការអនុវត្តន៏** | ការអប់រំ និងបណ្តុះបណ្តាលអ្នកជំនាញ : រយះពេលខ្លី និងមធ្យម (2007-2012).<br>បង្កើតប្រព័ន្ធធានាគុណភាព : រយះពេលខ្លី និងមធ្យម (2007-2012). |
| **ស្ថាប័នទទួលបន្ទុក** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ<br>- អគ្គនាយកដ្ឋាន នៃការដាំដុះកៅស៊ូ<br>- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(CRRI); |

| | |
|---|---|
| | - សាជីវកម្មផលិតកៅស៊ូរដ្ឋ (៧ ក្រុមហ៊ុន) |
| **លទ្ធផលរំពឹងទុក** | កំណែលំអក្នុងផលិតភាពនៃផលិតកម្មកៅស៊ូ<br>កំណើនក្នុងការនាំចេញនៃកៅស៊ូ<br>ការកើនឡើងនៃតម្លៃនាំចេញរបស់កៅស៊ូ ជាមួយនឹងការចេញនូវវិញ្ញាបនប័ត្រ<br>អធិការកិច្ចទទួលស្គាល់ជាអន្តរជាតិ |

**តារាង ១២-២-១២ ពង្រឹងកិច្ចជំរុញវិនិយោគ សំរាប់ឧស្សាហកម្មកែច្នៃម្ហូបអាហារ**

| ប្រភេទ | មាតិកានៃផែនការ |
|---|---|
| **សារំតា** | វិនិយោគផ្ទាល់បរទេសលើឧស្សាហកម្មកែច្នៃអាហារមានភាពអសកម្ម |
| **គោលបំនង** | ធ្វើការទាក់ទាញវិនិយោគផ្ទាល់បរទេសពីក្រុមហ៊ុនកែច្នៃអាហារក្រៅស្រុក<br>កែលំអរបរិយាកាសអោយក្លាយជាបរិយាកាសរាក់ទាក់ដល់វិនិយោគិន |
